គ្រប់គ្រងដោយគណៈកម្មការ
COMMISSION DES MŒURS & COUTUMES

អង្គុត្តរនិកាយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣០ លេខ ៥ ខែឧសភា

ព.ស. ២៥០០ គ.ស. ១៩៥៨

– ភ្នំពេញ –

DU CAMBODGE
P K 1
1958 . 5



តាំងលសនិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង	៣៨៣
	- សទ្ធម្មកថា ព្រះញាណវិរៃយៈ ភ័ន់-សាងុំ រៀបរៀង	៣៩៩
	- សិល្បៈពុទ្ធសាសនា ព្រះឧបាលីវង្ស សូរ-ហាយ រៀបរៀង	៤១១
	- សេចក្តីពិចារណានៃពុទ្ធសាសនិកជនម្នាក់ (តមក) លោកប៉ាយ-ប៊ុក រៀបរៀង	៤២១
ផ្នែកអក្សរសាស្ត្រ		
	- រឿងទេវន្តរបស់អម្រឹតក្សត្រីម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ	៤២៩
	- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ	៤៤៣
	- រឿងព្រេងនិងរឿងបុរាណនៃប្រទេសជប៉ុន (តមក) លោក ប៉ាយ-ប៊ុក ប្រែរៀបរៀង	៤៥៣
	- រឿងឯកអង្គក្ស័ត្រ (តចប់) លោក លាង-ហាប់-អាន ប្រែរៀបរៀង	៤៥៥
	- ប្រវត្តិទីក្រុងឧត្តុង្គ លោក ចាប-ពិន រៀបរៀង	៤៦៧
ផ្នែកកំណត់ទិដ្ឋប្រវត្តិការណ៍		
	- ពិធីបុណ្យទមស្ការព្រះសក្យមុនីចេតិយ មុខស្ថានីយ៍អយស្ម័យយោធ ស្រី-អ៊ូ រៀបរៀង	៤៧៣
	- វចនានុក្រមសុំស្ក្រឹត-ខ្មែរ (តមក) ព្រះមហាជាំង-ខាត់ រៀបរៀង	៤៧៨

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជាវ ២៣០រ៉ៀល

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

-Histoire du Bouddhisme au Cambodge (suite) par Vén. *PANG-KHAT* 383
-Sadhammakatha par Vén. *VANN-SADUM* 399
-Art bouddhique par Vén. *SOR-HAY* 411
-Réflexion d'un Bouddhiste (suite) par *M. RAY-BUC* . . . 421

PARTIE LITTERAIRE :

-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* 429
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . . 443
-Conte et Légende du Japon (suite) traduits par *M.RAY-BUC* 453
-Histoire d'un prince (suite) traduite par *M. LEANG-HAP-AN* 455
-Historique de la ville d'Oudong par *M. CHAP-PIN* 467

NOTES ET CHRONIQUES :

-Cérémonie de Namaskar au Sakya-Mouni-Cheddey devant la gare par *M. SREY-OU* 473
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT* 478

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

ប្រវត្តិពុទ្ធសាសនាដៅប្រទេសខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

(តមក)

និមន្តទៅដល់សុវណ្ណភូមិ ពួកអ្នកគោះស្មានថា លោកជាមិត្តនឹងអាកែវទឹក ព្រោះមានអាកែវទឹក តែងតែមកចាប់ខាក ក្នុងពាជត្រកូលយកទៅបរិភោគជារឿយៗ ហើយក៏បបួលគ្នាយកអាវុធ រត់ទៅប្រដន្ធនឹងសម្លាប់លោក ។ ព្រះមហាថេរមានថេរដីកាថា អាត្មាជាសមណៈអ្នកគាន់សីលៗលៗ កំពុងតែមានថេរដីកា អាកែវទឹកមកដល់ លោកសំដែងធម្មដំហិរិយ៉ែបន្ទាបអាកែវទឹក មិនឲ្យមកទៀត ហើយចាត់ការពារក្សានៅដុំវិញគោះ (ថេរោបិ តេ យាវ អទស្សនំ គាវ បលាបេត្វា ទិបស្សូ សមន្តតោ អារក្ខំ ឋបេសិ) តមក អ្នកគោះឲ្យឈ្មោះថាពាក ក្នុងពាជត្រកូលថា "សេរណ្តវៈ" តាំងពីកាលនោះមក" ។

ប្រកបពាគោះសិរីលង្កានេះថា សុវណ្ណភូមិ ជាគោះទៀតហើយ ប្រកបនឹងសេចក្តីអាង នៃអ្នកប្រាជ្ញទាំងពីរនាក់ខាងលើ. ឆ្លើយត្រូវគ្នាទាំងពីរនាក់យ៉ាងនេះ ដូចជាថាមិនបាច់ប្រកែកទៀតទេ ។ សន្មតថាជ្រោយជាសុវណ្ណភូមិ

សមដែរ តែបើថាគោះជាសុវណ្ណភូមិ ដូចជាងាស់ពិបាកស្ដាប់ ដូចនិយាយ ដែលថា កំកូនិគន្ធគៅកាន់សុវណ្ណទ្វីប ហើយដែលលោកសរដែលថា (គោះសុមាត្រា ឬ ម៉ាឡេស៊ី) ។ មួយទៀត គោះត្រង់ភូមិភាគនេះ មានច្រើនដូចគោះជ្វា សុមាត្រា ចីរណអូ សេឡេប ជាដើម តើគោះណាខុកជាសុវណ្ណភូមិ? ពិបាកនឹងកំណត់ឲ្យទៀងទាត់ទៀត ។

ចំណែកប្រកពចិន ក៏មិនមានន័យច្បាស់ពីសុវណ្ណភូមិថា នៅត្រង់ណាឲ្យច្បាស់លាស់ដែរ គ្រាន់តែថា "ព្រះភុទហ្វាន់ ចេ ម៉ុន(ស្រីមារ:?) ទ្រង់ទិវង្គត ក្នុងពេលច្បាំងនឹងប្រទេស គិន លិន "ព្រំដែនមាស", ថា "ពីប្រទេសនគរភ្នំទៅដល់អាណាច័ក្រ គិន លិន "ព្រំដែនមាស", ហើយថា ក្នុងអាណាច័ក្រ គិន-លិន នេះ ប្រជាជនគោរពព្រះពុទ្ធ មានស្រមណ៍ច្រើនពាន់" ។ លោកកសប្បៈ គ្រិស្តសតវត្សទី ១៨ ជាអ្នកអធិប្បាយសៀវភៅជាស្នាដៃលោកចិនយី តវ៉ិន បានដៅថា "អាណាចក្រ គិន-លិន នៅក្នុងគិន-ចៀវ(Kin-Tcheou) ដែលបែប្រថាគោះមាស:=សុវណ្ណទ្វីប ហើយថា លោកចិនយី-តវ៉ិន បានប្រើពាក្យគោះមាសនេះដល់ទៅពីរដង ដើម្បីហៅគោះសុមាត្រាឬតម្បន់ប៉ាឡេមបាំង ។ លោកចូតជេន បានរំឭកឲ្យដឹងថា " ជនជាតិម៉ាឡេស៍ហៅ គោះសុមាត្រា ថា ពូឡូវមាស (Pulau Mas) ប្រែថា "គោះមាស" ។

លោក ល. ព្រិក្ស, ត្រង់បទថា ពាណិជ្ជកម្មនឹងវិត្តារកម្មឥណ្ឌ ពីបុរាណកាល, សរសេរថា "តាំងពីខាងដើមគ្រិស្តសតវត្សម្ល៉ះ ឥណ្ឌ បានស្គាល់ឆ្នេរតេនសរីម នឹងជ្រោយម៉ាឡាយូថាជា "សុវណ្ណភូមិ" មកហើយ មានជាតកនិទានឆ្នាំគម្ពីរជើតា ខាងសាសនាបានដំណាលថា មានអ្នកដំណើរ បានមកស្វែងរកលោហធាតុវិសេស ត្រង់តម្បន់នេះ គម្ពីរ សំស្ក្រឹតហៅតម្បន់នេះថា "សុវណ្ណភូមិ" (Land of gold) ព្រមទាំង ហៅថា សុវណ្ណទ្វីបកោះមាស ឬ ជ្រោយមាស Island (or Peninsula) of gold" ។ ក្រោយពីខាងដើមគ្រិស្តសតវត្សមក មិនយូរប៉ុន្មាន អ្នកភូមិ សាស្ត្រក្រិកបានដៅឆ្នេរនេះថា ផែនដីមាស "Chryse the gold" (the "golden chersonese" or Peninsula ។ សព្វថ្ងៃនេះ មានភូមិមួយ ឈ្មោះ តា កួ-ប៉ា នៅខាងត្បូងតម្បន់ក្រា (Kra) គេថាជាកំពង់បុរាណនៅ ឆ្នេរខាងលិចជ្រោយ ។ មានផ្សារបុរាណមួយឈ្មោះតក្កោលៈដែល លោកប្តូឡេម៉ែ បានដៅតាលពីពាក់កណ្តាលសតវត្សទីពីរ នៃគ្រិស្តសតវត្ស រៀមកហើយនោះ គឺខំនឹងជា តា-កួ-ប៉ា នេះឯងហើយ ។ នៅឆ្នេរខាងកើត នៃជ្រោយ ម៉ាឡាយូ នេះ មានកំពង់ឈ្មោះ តាំព្រលិង្គ មួយទៀត ។ មាន គម្ពីរគម្ពីរឆ្នាំងតាត់ទៅវិញទៅមក រៀងកំពង់ទាំងពីរនេះតាំងពីបុរាណ កាល ។ តាមកំពង់នឹងតាមគម្ពីរគម្ពីរនេះ គេអាចដើរដំណើរហួតមក

ដល់ទន្ទេមណាម នឹង ទន្ទេមកុង ជាន់ជានៅឥណ្ឌូចិនមានរឿងព្រាហ្មណ៍ ហ៊ុន.ខៀន ជាន់ករិយាហើយជាន់សោយរាជ្យនៅប្រទេសនគរភ្នំ" ។

ការស្រាវជ្រាវរកសុវណ្ណភូមិ នៃអ្នកច្រៀជ្ជដែលបានពោលមកនេះ យើញថា លោកចោះសំដៅត្រង់គោះសុមាត្រាឬជ្រោយម៉ាឡាយូ សមតាមទំនងហេតុផលប្រកពជាលើនឹងភូមិសាស្ត្រដែរហើយ គួរនឹងចុះមតិយល់ស្របតាមទស្សនៈរបស់លោក មិនជាប់ប្រកែកទៀត តែទស្សនៈពាំងនេះ លោកមិនបានញ្ជាក់ហេតុ នាំឲ្យយើងនៅតែមានសង្ស័យ មិនពាន់អស់ចិត្តនៅឡើយ ដូច្នេះរឿងសុវណ្ណភូមិ ក៏នៅតែជារឿងអាថកំបាំងដដែល តែបើយើងទទួចដឹកឆ្លុះកែកាយៅទៀត គួរតែឆ្លើយថា ប្រកពជាលើនេះមានសេចក្តីគួរឲ្យចាប់ពិរុទ្ធថា "ព្រះសោណកត្តេនឹងព្រះទត្តរត្តេរៅសុវណ្ណភូមិ" ហើយប្រកពដដែលនេះ ត្រង់ពាហិរនិទានវណ្ណនាថា "ព្រះថេរៈពាំងពីរអង្គៅកាន់គោះ" ដូចជាមិនស្របគ្នា ត្រង់ពាក្យ "ភូមិ" នឹង "គោះ" នេះសោះ ។ គួរតែថា គោះជាសុវណ្ណទ្វីប ហើយដែនដីធំគួរថា សុវណ្ណភូមិ ទើបមានហេតុផលល្មមស្តាប់ជាន ព្រោះជ្រុងពិកពលោកត្រង់អាស៊ីភាគអគ្នេយ៍នេះ មានពាំងគោះ មានពាំងភាគដែនដីធំ ។ ប៉ុន្តែបើគោះសុមាត្រាមានរូបបញ្ជាក់ក្នុងតួឯងថា ទ្វីបស្រេចៅហើយ ថែមពាំងសមហេតុផលផង យើងនឹងនៅទទួចទៃយល់ថា "គោះសុមាត្រា"

ជាសុវណ្ណភូមិទៀតក៏មិនសមដែរ បើថាជ្រោយ ម៉ាឡាយូ ខុតជាត់ថាជា
សុវណ្ណភូមិក៏ដូចជាមានហេតុផលគួរដឿដែរ ហើយជនជាតិឥណ្ឌៀ ពី
អតីតកាលដែលតាំងនាមសុវណ្ណភូមិកាលនោះឡើយ ក៏មិនគួរនឹងធ្លាប់
សល់រំលឹកអ្វី សព្វបើពាក្យថាទ្វីប" នឹង "ភូមិ" នេះឡើយដែរ ។

យើងបានឃើញសុវណ្ណភូមិ តាមទស្សនៈអ្នកជ្រាជ្ញបុរាណហើយ
តទៅ យើងត្រូវរកសុវណ្ណភូមិតាមបុរាណវត្ថុ ដែលជាវប្បធម៌ឥណ្ឌៀ
ក្នុងភូមិភាគនេះទៀត ។

ការផ្សាយពុទ្ធសាសនា ទៅតាមបច្ចុប្បន្នទេសនេះ មាន ២ ផ្លូវគឺ
ផ្លូវគោក ១ ផ្លូវទឹក ១ ។ ផ្លូវគោកពុទ្ធសាសនា ផ្សាយទៅតាមតួតពា-
ណិជក្សរនេះ ដែលដើរលក់ដូរទៅតាមស្រុកភូមិនិគមជនបទ ក្នុងប្រ
ទេសឥណ្ឌៀក្តី ក្រៅប្រទេសឥណ្ឌៀក្តី. ផ្លូវទឹក តាមតួតពាណិជដើរសំ-
ពៅសមុទ្រ ដែលធ្វើដំណើរទៅលក់ដូរ តាមកោះតូចធំ ទៅក្នុងសមុទ្រ
សាគរថ្នែនដីណាដែលទៅតាមដើងគោកមិនបាន ។ ចំនៀមពុទ្ធសា-
សនិកជន ទោះជាពាណិជដើងគោកក្តី ទោះជាពាណិជដើងទឹកក្តី ក្នុងពេល
ធ្វើដំណើរម្តងៗតែងតែនិមន្តភិក្ខុសង្ឃ ឬ កសាងព្រះពុទ្ធរូបយកទៅជាមួយ
ដើម្បីការពារគេយន្តពាយតាមផ្លូវកន្លាផង ដើម្បីធ្វើសក្ការៈបូជា យក
ចំណែកកុសលតាមផ្លូវផង ។ សាសនាជនៃខ្មែរក៏មានចំនៀមដូចគ្នាដែរ ។

តែការផ្សាយពុទ្ធសាសនាធ្វើតែក្នុងរដូវចេញវស្សាទេ រដូវក្នុងវស្សា ព្រះ
តេភ្នុសង្ឃត្រូវឈប់សម្រាកអស់ត្រៃមាស ។ ចំពោះការមកសុវណ្ណភូមិ
ក្រៅពីព្រះសោណកត្ថេរនិងព្រះឧត្តរត្ថេរ ជាសមណទូត ដែលព្រះបាទ
ធម្មាសោកមហារាជ បានបញ្ជូនតាលពីពុទ្ធសតវត្សទី ៣ នោះ នៅមាន
ពួកពាណិជសំពៅសមុទ្រ បាននាំព្រះភិក្ខុសង្ឃ ឬព្រះពុទ្ធរូបមកជាមួយ
ខ្លះដែរ ។ ពាណិជសំពៅធ្វើដំណើរចេញ ពីភូមិភាគទក្ខិណទិសនៃ
ប្រទេសឥណ្ឌា (ទក្ខិណាបថឬដែកងឹសព្វថ្ងៃនេះ) មកលិចដូរនៅដែន
ដីអាស៊ីភាគអគ្នេយ៍ពាក់ព័ន្ធមូលនេះ ជាគោះក្តី ជាផែនដីក្តី ដែលយើងហៅ
ថាសុវណ្ណភូមិ, តាលមកដល់ហើយ ក៏ផ្សាយពុទ្ធសាសនាតាមទីឋាននា
នាដែលខ្លួនទៅដល់ ឋានទីឋាននោះ។ ដែលមានវប្បធម៌ឥណ្ឌាមក
ដល់ហើយ មានបុរាណវត្ថុ បុរាណដ្ឋាន បុរាណទេវរូប បុរាណសិលា
ចារឹកសព្វថ្ងៃនៅឡើង ដោយចំពោះព្រះពុទ្ធរូប "ទីបង្ករៈ=ព្រះពុទ្ធជាទីពឹង"
ដែលពួកពាណិជសំពៅចូលចិត្តកាប់អាន ។ ហេតុដូច្នេះហើយបានជាទី
ហាដែលនៅឆ្ងាយជាប់ស្រយាលពីប្រទេសឥណ្ឌានេះ មានវប្បធម៌
ឥណ្ឌាតាំងពីសម័យព្រេងនាយ ជាសក្ខីភាពដោះជាសពាសពេញដែនដី
ច្រើនកន្លែង គួរកត់សំគាល់ថា អាស៊ីភាគអគ្នេយ៍ពាក់ព័ន្ធមូល ជា
សុវណ្ណភូមិ មានហេតុផលសមបរិបូណ៌ មិនមានចន្លោះគួរឲ្យតក់ក៏បាន

ទៀតទេឬយ ។

ឯដែនដីនៅបន្ទោះតំណែនដ៏ចំនួននេះ ពីអតីតកាល មានតែប្រទេសចាម ខ្មែរ មន ទើបជាមានឮយូរទេ ។ ប្រទេសចាម ខ្មែរ មន តាំងនៅលើភាគដែនដីធំ ឯប្រទេសជាមានឮយូតាំងនៅតាមកោះ ។ ដែនដីតាំងនេះបានទទួលវប្បធម៌តំណែតាំងពីបុរាណកាល តែគេមិនអាចកំណត់សតវត្សបានទៀងទាត់ទេ ។ លោកហ្សង់ឆែនិយាយថា "មានវប្បធម៌តំណែចូលមកប្រទេសក្រៅតំណែ នឹងតំណែសុីមុនគ្រិស្តសករាជ" តែលោកសុីដេសថា "និយាយត្រឹមតែមានជនជាតិតំណែមកតាំងទីលានៅបន្តិចបន្តួច ក្នុងគ្រិស្តសតវត្សទី ២ នឹងទី ៣ ហើយបានផលចំរើនរុងរឿង ក្នុងគ្រិស្តសតវត្សទី ៤ នឹងទី៥ប៉ុណ្ណឹងហើយ" ចំណែកលោក ប៉.ឌុយប៉ុងថា "ពុទ្ធសាសនាជាសាសនា ដែលប្រទេសតាំងនេះបានទទួល តាំងពីទាងដើមគ្រិស្តសតវត្សទី១មុ៎ង ហើយមានជ័យជំនះឈ្នះការកន្តែប្រែតាំងទាងផ្លូវនេះយោងបាយ នឹងតាំងទាងផ្លូវយោសនា ព្រមតាំងមានដំណើតាំងនៅមាំមួន នឹងបិតថេរចិរកាលជាងវិត្តារកម្ម នៃតំណែដទៃតាំងអស់" ។ យោបល់លោកតាំងទាងលើនេះ មានហេតុមានផលគួរស្តាប់បាន យើងអាចផ្សំនិយាយថា ពុទ្ធសាសនាមកពីពុទ្ធសតវត្សទី៣ ហើយរុងរឿងចាប់តាំងពីទាងដើមគ្រិស្តសតវត្សមក ។

វប្បធម៌ឥណ្ឌៀខាងពុទ្ធសាសនា ដែលមាននៅលើភូមិភាគនេះ យើង អាចចែកជាមជ្ឈមណ្ឌលពុទ្ធសាសនា ៦ មណ្ឌលដូចតទៅនេះ ៖

១ - បុព្វទិសាភាគ ប្រទេសចម្បាជាដែនដីចាមពីអតីតកាល ប្រ ទេសនេះគាំពុទ្ធសាសនា មានន័កាយពុទ្ធសាសនា ២ គឺអរិយសម្មតិន័- កាយ នឹង សង្ឃិស្តាវាទិកាយ ។ មានព្រះពុទ្ធរូប សំរិទ្ធិមួយព្រះអង្គ ល្អ វិសេស ការរចនាបែបអមរាវតីនៅស្រុកដុងដឿង (Dông dung) ខេត្ត ក្វាងណាម (Quang-nam) ពីពុទ្ធសតវត្សទី ៣ ឬ ទី ៤ ។

២ បុព្វទិសមជ្ឈភាគ ប្រទេសនគរភ្នំ (Founan) ប្រទេសកម្ពុជា បច្ចុប្បន្ន ។ ប្រភពចិនចែងថា ព្រះបាទ ហ៊ិន ខៀន ព្រះនាង លៀវ យី = កៅណ្ឌិន្យ នាគ័សោមា=ព្រះថាងនាងនាគ័ ជាបឋមកប្រត្រិយ ស្ថាបនាប្រទេសនេះឡើងពីគ្រិស្តសតវត្សទី ១ ។ មានសិលាចារឹក ពុទ្ធ- សាសនាចរមបុរាណជាន់គេបង្អស់នៅឥណ្ឌូចិន ជាព្រះរាជប្រកាសព្រះ បាទហ្វាន់:ចេ មុ័ន (ស្រីមារ:?) ពីគ្រិស្តសតវត្សទី ២ ឬទី ៣, មានសិ- លាចារឹកបុរាណ ៤ ន័ងពុទ្ធរូបច្រើនជាសក្តិការ ។

៣- បច្ចិមទិសមជ្ឈភាគ ដែនដីមន័ងឹ:ខ្លា ប្រទេសសៀមសព្វ ថ្ងៃនេះ ។ មានចក្រចារថា យេ ធម្មា. . . នៅបុរាណដ្ឋាននគរបឋម ការរចនាចំក្រនេះ មិនមែនមានមុនគ្រិស្តសតវត្សទី ៦ ទេ ។ មានព្រះ

ពុទ្ធរូបសំរិទ្ធិមួយអង្គនៅបុរាណដ្ឋានពងទឹក (Pong-Tuk) ការរចនាបែបអមរាវតីគ្រិស្តសតវត្សទី ៣ ឬទី ៤ ។ មានព្រះពុទ្ធរូបសំរិទ្ធិមួយអង្គទៀត ការរចនាបែបអមរាវតីដែរ គេរកឃើញនៅនគរជ័យ។ ព្រះពុទ្ធរូបទាំងនេះចេញពីសាលាកុដារអង្គរប៊ូរី (ខេត្តតាកែវ) ។

៤- បច្ចុមិសាកាគ ប្រទេសមន ប្រទេសកូមាសព្វថ្ងៃនេះ មានសន្ធឹកមាសច្រើនសន្ធឹកថាវ៉ា យេ ធម្មា... នៅម៉ាហ្គនធ៍ម៉ាន់គានជិតក្រុងព្រោម (Prome) ពីគ្រិស្តសតវត្សទី ៥ ទីក្រុងថាតុង (Thaton) ជាក្រុងចាស់ឈ្មោះសុធម្មតី ឬ សុធម្មបុរៈ ដែលលោកចិនហៅថា ស្រីក្សេត្រ កាលពីគ្រិស្តសតវត្សទី ៧ ។

៥- ជ្រោយម៉ាឡាយូរ ប្រកពចិននិយាយថានៅទីនេះ មានរដ្ឋតូចៗគាន់តាមរាប់មិនអស់ តាំងតែពីគ្រិស្តសតវត្សទី ២ តែសិលាចារឹកក្នុងទីនេះមិនមានមុនគ្រិស្តសតវត្សទី ៤ ឡើយ ។

៦- ប្រជុំកោះ មានសិលាចារឹកច្រើនកន្លែង ។ សិលាចារឹកព្រះបាទមូលវ៉ែនក្នុងស្រុកកុតី (Kutei) នៅកោះបឺរណេអូ ពីខាងដើមគ្រិស្តសតវត្សទី ៥ ។ សិលាចារឹកព្រះបាទបូណាវ៉ែន នៅបច្ចុមគាគកោះជ្វាពីក្នុងរាង៥គ្រិស្តសតវត្សទី ៥ ដែរ ។ មានព្រះពុទ្ធរូប "ទីបង្ករៈព្រះពុទ្ធជាទីពឹង" ច្រើនអង្គ ការរចនាបែបអមរាវតី, មួយអង្គរកឃើញ

នៅស្រុកសេមប៉ាគា (Sempaga) ក្នុងកោះសេលែប (Célèbes) មួយអង្គទៀតរកឃើញនៅខាងត្បូងខែត្រដេមប៊ែរ (Jamber) ប្រទេសជ្វាខាងបុព្វទិស, មួយអង្គទៀតរកឃើញនៅលើខ្នងសេគុនតាំង (Séguntang) នៅកោះប៉ាឡេមប៉ាំង (សុមាត្រា) ចិនហៅកោះជ្វានេះថា យេ-ថាវ (Ye-Tiao =Yava dvipa) ពី គ.ស. ១៣២ ។

យើងបានប្រមូលឯកសារខាងលើនេះ មកត្រិះរិះមើលឃើញថា ទីហានតាំងនេះមានពុទ្ធសាសនាផ្សាយមកដល់ហើយ បើយកសក្ករាជមកធៀបគ្នាមើលទៀត ឃើញថា មិនមុនមិនក្រោយជាងគ្នាប៉ុន្មានទេ តែបើប្រសិនជាយកសិលាចារឹកពុទ្ធសាសនាសំស្ក្រឹត នៅប៉ែ កាញ់ ដែលបរមបុរាណជាងគេមកខ្ទុកជាមូលដ្ឋានវិញ នោះយើងនឹងអាចពោលបានថា ពុទ្ធសាសនាមកដល់ប្រទេសនគរភ្នំ (Founan) អតីតកម្ពុជាមុនជាងទីហានសុវណ្ណភូមិឯទៀតតាំងអស់ ។

ឱ្យមានសេចក្តីស្តាយណាស់ ដោយមិនមានឯកសារបញ្ជាក់ប្រស្នាចាក់ស្រែះ ដែលមានអាយុរាប់ពាន់ឆ្នាំកន្លងមកហើយនេះ ឲ្យច្បាស់លាស់ព្រោះដំណឹងដែលយើងបានដឹង តាមគម្ពីរមហាវង្ស ប្តូ បឋមសម្ពុទ្ធប្បាសាទិកាជាប្រតិភាកោះសីរីលង្កានោះ មានសេចក្តីត្រឹមតែថា " ព្រះមហាមោគ្គលិបុត្តតិស្សត្ថេរ ចាបបញ្ជូនព្រះសោណកត្ថេរនឹងព្រះឧត្តរត្ថេរ

ទៅតាន់សុវណ្ណភូមិពីពុទ្ធសតវត្សទី ៣ ហើយថា ព្រះថេរៈតាំងពីអង្គនេះនិមន្តមកគង់នៅនឹងឆ៍កោះ ប្រាសជនានុជន ក្នុងកោះនោះឲ្យចូលតាន់ពុទ្ធសាសនា" ប៉ុណ្ណឹង តែសព្វថ្ងៃនេះ យើងមិនមានព័ស្តុតាងគ្រប់គ្រាន់ថា កោះណាដែលព្រះថេរៈតាំង ២ អង្គនិមន្តមកគង់ ហើយតាំងជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនាក្នុងបឋមកាលនោះ ។

ហេតុដូចបានពោលមកនេះ យើងត្រូវតែយកកំពង់ពីពីអតីតកាលទៅតាមកោះតូចធំ តាមផែនដី ដែលមានពាណិជឥណ្ឌៀបានចូលមកតេមាសពីសម័យព្រៃនាយ ហើយបាននាំយកវប្បធម៌ឥណ្ឌៀ ចូលមកសាបព្រោះ ទំនឹបុពណាវត្ត បុពណាង្គាន បុពណាខេរវប្ប បុពណាសិលាចារឹក ដែលមានដេរជាសញ្ញាសពេញ ព្រមទាំងប្រភពចិន ប្រភពប្លង់ម៉ែដែលមានដំណើរមកតាន់អាស៊ីភាគអគ្នេយ៍ ពីអតីតកាលលមកជាសក្ខីភាព ហើយរួមពោលថា ផែនដីអាស៊ីភាគអគ្នេយ៍ទាំងមូលនេះជា "សុវណ្ណភូមិ" លែងប្រកែកតទៅទៀតបាន ។ ភូមិភាគទាំង ៦ តន្លៃងដែលបានពោលមកហើយនេះ ជាមជ្ឈមណ្ឌលដែលព្រះថេរទុត្តៈទាំងឡាយ មានព្រះសោណកត្ថេរនឹងព្រះឧត្តរត្ថេរជាដើម បានសាបព្រោះពូជសម្មាទិដ្ឋិ គឺព្រះពុទ្ធសាសនា ឲ្យចាក់ឫសគល់បណ្តុះបណ្តាល ឲ្យកើតជាពូជធារលូតលាស់ដុះដាលចំរើនឡើង ត្រាតែក្នុងបច្ចុប្បន្នកាលនេះ មានប្រជាជន

រាប់លាននាក់ ចូលកាន់សាសនាព្រះជិនស្រី " សាសនាឈ្នះខ្ពុកក្នុងលោក " ។

សម័យធគ្រាវ៉ាំ.- ពុទ្ធសតវត្សទី៦ទៅទី ១១ (ព.ស.៥៤៣-១០៩៣) គ្រិស្តសតវត្សទី១ទៅទី៦ (គ.ស.ទី១ ៥៥០) បើយើងយកគម្ពីរបឋមសម្ពន្ធប្បាសាទិកា ឬ គម្ពីរមហាវង្សជាប្រកពគោះសិរីលង្កាមកជាសក្ខីភាព យើងត្រូវនិយាយថា ព្រះពុទ្ធសាសនាបានចូលមកប្រទេសកម្ពុជាយើងតាំងពីពុទ្ធសតវត្សទី៣ (ព.ស. ๒๓๔) មុនគ្រិស្តសករាជ ๓๐๙ ឆ្នាំ ព្រោះជនជាតិកម្ពុជានេះតាំងទៅក្នុងមណ្ឌលសុវណ្ណភូមិខាងបូព៌ទិស ឬ អាស៊ីភាគអគ្នេយ៍ តែប្រកពឯកសារចាំងឡាយពុំបានកំណត់ឲ្យច្បាស់លាស់ថា ព្រះពុទ្ធសាសនាចូលមកក្នុងរដ្ឋកាលណា? ព្រះថេរៈអគ្គណា ឬ លោកណាបាននាំមកប្រដិស្ឋានមុនដំបូង? ដំណាំងនេះនៅក្នុងអាថិកំពុងចាំងអស់ ព្រោះហេតុការណ៍ចាំងឡាយមិនថាតែក្នុងកម្ពុជាទេ សូម្បីក្នុងភូមិភាគដទៃ ដែលមាននៅក្នុងសុវណ្ណភូមិចាំងប៉ុន្មានកាលពីមុនគ្រិស្តសករាជ តំ ច្រើនតែពុំស្គាល់មានប្រវត្តិអ្វីជាក់ស្តែងតាំង ម្ល៉ោះហើយលោកទុកសម័យនេះថាជាសម័យមុនប្រវត្តិសាស្ត្រតែម្តង ។

កាលនោះ ប្រទេសកម្ពុជាយើងមានសមញ្ញាថា ប្រទេស " នគរភ្នំ " ។ នាមាភិធេយ្យថា "នគរភ្នំ" នេះ ចំនួហៅថា ហ្វូណន

(Founan) ពាដជានីហៅថាពូមូ ត្រូវនឹងពាក្យខ្មែរបុរាណថា "ទមាក់= ទ្រមាក់ ប្រែថា "អ្នកជាញ់" ស្របនឹងសិលាចារឹកជាភាសាខ្មែរថា "កុរុង្គំ ឬ ព្រះអង្គ" ជាសំស្ក្រឹតថា "បរិតកូជ្ញាល" ប្រែថា "ស្តេចភ្នំ" ពាដជានីថា "វ្យាធបុរៈ ប៉ុរីអ្នកជាញ់" ជាទីក្រុងតាំងនៅនឹងតម្បន់ជាភ្នំ (ទំនងជានៅភ្នំឱ្យាច់សំបចុប្បន្ននេះឯងឬ) ព្រោះទីឋាននេះ មានបុរាណ-ដ្ឋាន នឹងបុរាណវត្ថុបូរាសម័យនគរភ្នំច្រើនណាស់ ព្រមទាំងមានសិលាចារឹកមួយនៅវត្តចក្រិត នៅនឹងដើងភ្នំពីត្រើស្តសតវត្សទី១០ និយាយថាបានសាងនៅរូបព្រះឥស្សូរមួយហៅថា "អត្រៃវ្យាធបុរេស្សរៈ" ដំកល់ក្នុងទីនេះផង ។ ពង្សាវតារក្នុងសម័យត្រង់នាយទាំងប៉ុន្មានបាត់បង់អស់ទៅតាមកាលវេលា នៅមានសល់ខ្លះតែសិលាចារឹក៤កន្លែង នៅរ៉ូគាញ់ខេត្តញ៉ាត្រាំង ១ (វៀតណាម) នៅអ្នកតាដំបងដែក ខេត្តតាកែវ ១ នៅប្រាសាទប្រាំលែង កូសាំងស៊ីន ១ នៅទន្លេបាទី ខេត្តតាកែវ ១ ។ សិលាចារឹកទាំងនេះ ខ្លះនិយាយពីព្រះរាជាគោរពសាសនាព្រាហ្មណ៍ ខ្លះនិយាយពីព្រះរាជាគោរពពុទ្ធសាសនា ។ ដទៃពីនេះ យើងមានប្រកាចិន ជាឯកសារដែលលោក ប៉.ពែលីយោបានប្រែចេញពីពង្សាវតារចិនទៀត ។ ប្រកាចិននេះ មាននិយាយពីពង្សាវតារយើងខ្លះ យើងអាចយកមកខ្លះជាពន្លឺត្រោលបំភ្លឺមើលពង្សាវតារនៃយើង តាលពីសម័យ

នគរក្នុងបានដឹងហេតុការណ៍ខ្លះដែរ ។

ចិននិយាយថា "ខ្មែរយើងបានសាងខ្លួនជាប្រជាជាតិមួយ មានរូបរាងកើតឡើងក្នុងពិភពលោកតាំងតែពីគ្រិស្តសតវត្សទី ១" ។ តែលោកហ្សាំងថា "នៅប្រទេសនគរនេះ មានជនជាតិឥណ្ឌៀបាននាំយកវប្បធម៌ខ្លួនមកផ្សាយតាំងពីពុទ្ធសតវត្សទី ៣ គឺតាំងពីមុនគ្រិស្តសករាជ ៣០០ ឆ្នាំ ម្ល៉េះ" ។ មានប្រភពចិនខ្លះនិយាយថា មានការទាក់ទងប្រទេសខ្មែរ ទឹងចិនតាំងពីមុនគ្រិស្តសករាជច្រើនរយឆ្នាំ តែដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្រទុកជាផ្លូវការរាប់ពីគ្រិស្តសតវត្សទី ៣ រៀងរហូតមក ។ រាជទូតចិនដែលមកប្រទេសយើងជាបឋមមុន គ.ស. ២៣១ បន្តិច ហើយមានពី គ.ស. ២៤៣ មករហូតដល់ គ.ស. ៤៤៣ ។ លោកចែកសម័យដូចតទៅនេះ ៖

១- សម័យមុនគ្រិស្តសករាជ

២- សម័យសាន់ គួ ហេ (San-Kouou-Tche) គ.ស.២២០-២៦០

៣ សម័យពង្សាវតារត្សិន (Tsin) គ.ស. ២៦៥ ៤១៩

៤- សម័យពង្សាវតារសុង (Song) គ.ស.៤២០-៤៧៨

៥- សម័យពង្សាវតារត្សី (Tsi) ខាងត្បូង គ.ស.៤៧៩-៥០១

៦- សម័យពង្សាវតារលាង (Leang) គ.ស. ៥០២-៥៥៦ឬ៥៧

សម័យសាន់គួ ចេ រដ្ឋបាលព្រះចៅក្រុងចិននាមវ៉ូ (Wou) គ.ស. ២២០-២៨០ បានបញ្ជូនតាំង-ថៃ (Kang-Thai) និងដូ-យឺង (Tchou-Ying) ជាបេសកម្មទូតមកកាន់ប្រទេសយើងនៅទាងដើមគ្រិស្តសតវត្សទី៣ ។ ឯកសារតាំងនេះ យើងអាចបង្ក្រងជាពត៌មានសំខាន់ ឲ្យយើងដឹងពីពិស្តារភាព ទ្រព្យសម្បត្តិប្រទេស ទំនៀមទម្លាប់ ប្រពៃណីប្រជាជន មុខរបរកសិកម្ម និងលំដាប់វណ្ណៈ ព្រមទាំងព្រះនាមព្រះរាជអគ្គទូតក្នុងសម័យនោះបានច្បាស់ដែរ ។ បើយើងប្រមូលឯកសារតាំងនេះមកប្រមូលគ្នាជាសង្ខិត្តន័យ យើងអាចដឹងបានដូចតទៅនេះ ៖

"ព្រះរាជអាណាចក្រនគរភ្នំ តាំងនៅទឹងនេរឈូងសមុទ្រមួយធំទាងកើតទល់ទឹងប្រទេសលិន យ៉ (ប្រទេសចម្ប៉ា, ចម្ងាយពីប្រទេសលិនយ៉មក ១០០០ លី, ទាងលិចទៅទល់ប្រទេសឥណ្ឌា) ទឹងអាណាចក្រគិន-លីន "ព្រំដែនមាស" ទំហំប្រទេសចំនួន ៣០០០លី ។ មានក្រុងច្រើនសុទ្ធសឹងតែព័ទ្ធដុំវិញដោយកំពែង, មានប្រាសាទភជស្ថានប្រកបដោយជាន់ មានគេហដ្ឋាន ។ លើដី មានព្រៃព្រឹក្សា. គ្រឿងទេសមានសត្វទឹក សត្វគោក បក្សី ក្អែក ចរចាត សេកឥណ្ឌា, ក្តឹងដីមានមាស, ស្ពាន់, សំណ ដែរ។ មិនមានអ្វីខ្វះខាតទេ មានសម្បត្តិប្រទេសដែលគេបានដោយក្រៅដូចមាស, ពេជ្រ, ខ័ណ្ឌចន្ទា, គជជាដើម ។ មាន

ដើមអំពៅ, ក្រទឹម, ក្រូចពោធិ៍សាត់ ដើមស្វា, ដើមដូង ។ ប្រជាជន
សម្បុរខ្មៅ សក់រួញ ប្រជុំភូមិមួយមានអណ្តូង១ រកស៊ីធ្វើស្រែចំការ
ចេះត្បាញវៃអម្បោះសូត្រ; ចេះសិល្បៈធ្នាក់ក្បាច់រចនា, ធ្វើចិញ្ចៀន
កងកណ្តឹ, ខ្សែក្រណ្តឹ ខ្សែដៃ កងដើង, មានថានប្រាក់ប្រើប្រាស
យកមាសប្រាក់គជគ្រឿងក្រអូបបន់ពន្ធជារ, មានក្បួនតម្រា, មាន
មន្តីរឯកសារ, អក្សរសេរសេរតាមអក្សរឥណ្ឌា, ទំនៀមការកូន៧ ឬ
បុណ្យខ្មោចដូចនៅប្រទេសលិនយីដែរ, ប្រជាជនគាន់សាសនាព្រាហ្មណ៍
គោរពព្រះមហេស្វរៈ, គាន់ពុទ្ធសាសនា ចេះធ្វើទេវរូបពិសម្រិទ្ធពីថ្ម បើ
មុខពីរមានដៃបួន, បើមុខបួនមានដៃប្រាំបី ដៃមួយៗគាន់គ្រឿង១បករណ៍
ផ្សេងៗ ឬគាន់ព្រះអាទិត្យព្រះចន្ទ ។ ទំនៀមគាន់ទុកខ្មោច ត្រូវគោរ
ពុកមាត់គោរសក់ ។ ទំនៀមកប់ខ្មោចមាន៤ យ៉ាងគឺ កប់ក្នុងដី ចោល
ក្នុងព្រៃស្មសានឲ្យសត្វស៊ី, ទម្លាក់ចោលក្នុងទឹក, ដុត ។ មានពាណិជ
លក់ដូរគ្រឿងទេស, មាសប្រាក់, សំពត់ព្រៃ ។ មានពាណិជពី
ប្រទេសផ្សេងទៅមកលក់ដូរ ។ ប្រទេសសម្ពុជ មានឈ្មោះខ្មែរ
ទៅនៅត្រួតត្រា នាម៉ឺនធ្វើស្តាំទាំងអស់ឈ្មោះ តូអង់លូអង់ ។ ប្រទេស
នគរភ្នំនិលិនយីទាំងពីរនេះ មានការទាក់ទងគ្នាតាមផ្លូវដើងទឹកដើងគោក
ហើយដូយគ្នាទៅវិញទៅមក ។

(មានត)

សទ្ធម្មកថា

ព្រះញាណវរិយៈ រ៉ាំង សាំ៉ុ រៀបរៀង

សទ្ធម្មោ នរុត្តមេ ភ្ញេ

សុខា សទ្ធម្មទេសនា

វេលានេះ នឹងអធិប្បាយតាមបទដែលព្រះគាថា ដែលបានដកស្រង់ខាងដើមនេះ ដើម្បីផ្សាយនូវប្រយោជន៍ នៃព្រះពុទ្ធសាសនា ដែលមានមកក្នុងព្រះត្រៃបិដក ដូចតទៅនេះ៖

បាទទី១ សទ្ធម្មោ នរុត្តមេ ភ្ញេ សាធុជនគួរគោរពព្រះសទ្ធម្ម។

បាទទី២ សុខា សទ្ធម្មទេសនា ការសំដែងព្រះសទ្ធម្មនាំមកនូវសេចក្តីសុខ។

ការគោរពព្រះសទ្ធម្ម ការសំដែងព្រះសទ្ធម្ម ជាការណីយកិច្ចរបស់អ្នកប្រាជ្ញ ដែលមានសន្ដានស្ងប់ ព្រោះព្រះសទ្ធម្ម ប្រៀបដូចជាធម៌ស្ងប់ ឬជាធម៌របស់លោកអ្នកស្ងប់។ លោកអ្នកមានគុណសម្បត្តិ ក្នុងការលះនូវធម៌ដែលគួរលះ និងធម៌ដែលគួរចំរើន អាចរក្សាខ្លួនមិនឲ្យកើតសេចក្តីវិនាសក្នុងអបាយទុគ្គតិ មានបញ្ញាវៃដូចជាដើម នេះហៅថា លោកអ្នកស្ងប់ ដោយមានសីល សមាធិ បញ្ញា ជាធម៌ស្ងប់ ក្នុង

សន្តាន ។ សប្បុរសទំាងឡាយ មានព្រះពុទ្ធជាដើម មាននាមថាជាអ្នកស្ងប់ ដែលហៅជាបាលីថាសន្តៈ ។ ពួកសន្តៈអ្នកស្ងប់ រមែងមានធម៌ស្ងប់ជាទីគោរពដ្រះថ្ល គឺមានហ៍ឫយធ្ងន់ក្នុងព្រះសទ្ធម្ម សមដោយបាលីថា សត្ថុ សទ្ធម្មករុណោ ព្រះសម្ពុទ្ធគ្រប់អង្គ សុទ្ធតែទ្រង់គោរពក្នុងព្រះសទ្ធម្ម គឺមានការគោរព តាំងពីក្នុងការស្តាប់ព្រះសទ្ធម្មជាដើមទៅ ដូច្នេះ អំពើកាយ វាចា ចិត្តរបស់លោកអ្នកស្ងប់ រមែងមានធម៌ស្ងប់ជាទីតាំង ហើយប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់ ដែលជាមូលនៃសេចក្តីសុខពិត ។ សមដោយបាលីថា សន្តោ សោ តេតា សមាយ ធម្មំ ទេសេតិ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ជាសន្តៈអ្នកស្ងប់ ទ្រង់សំដែងធម៌ ដើម្បីសេចក្តីស្ងប់ ។ ការសំដែងធម៌ ដើម្បីសេចក្តីស្ងប់នេះហើយ ដែលចាត់ទុកជាព្រះសទ្ធម្មទេសនា មកក្នុងបាលីថា សុខា សទ្ធម្មទេសនា ការសំដែងព្រះសទ្ធម្មនាំមកនូវសេចក្តីសុខ ។

សេចក្តីសុខក្នុងទីនេះ សំដៅយកនិព្វានមិនសុខ យ៉ាងបរិសុទ្ធឥតប្រែក្រាយ តើតឡើងអំពីព្រះសទ្ធម្ម មានព្រះសទ្ធម្មគឺសីលជាដើម ។ ពុំមែនខ្ជះខ្ជៀតដល់សាមិសសុខ ដែលមិនបរិសុទ្ធ តើតអំពីអសទ្ធម្មអាន រូបសំឡេង ជារបស់មនុស្ស ឬរបស់ទេព្តាជាដើម ហើយប្រែក្រាយទៅជាទុក្ខវិញឡើយ ។ ដ្បិតសេចក្តីសុខសោមនស្ស ព្រោះរូបសំឡេងជា

ដើមនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថាជាវិបរិណាមទុក្ខទៅហើយ ដោយសេចក្តីសុខសោមនស្សនោះ តែងតែប្រែក្លាយទៅជាទុក្ខវិញ នៅវេលាដែលអារម្មណ៍មានរូបជាដើមនោះវិបត្តិ ព្រោះហេតុមានការចាស់ស្វាប់ជាដើម ។ ហេតុនេះ ទើបអ្នកប្រាជ្ញតាំងខ្លាយ ពុំអាចលះព្រះសទ្ធម្មព្រោះអសទ្ធម្មឡើយ ប្រៀសេចក្តីថា លោកពុំអាចប្រព្រឹត្តទុច្ចរិត ព្រោះតែចង់បានលាភ យស សរសើរ សុខ ឬរូបសំឡេង ក្លិន រស ផ្សព្វ·នានា ឡើយ ។

ព្រះសទ្ធម្ម បើពោលដោយទ្វីមាន ៣ ប្រការគឺ បរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ បដិវេធសទ្ធម្ម ១ ។ ធម្មវិន័យ គឺព្រះត្រៃបិដក ជាសត្ថុសាសន: ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ដែលអ្នកប្រាជ្ញបានសង្គាយនារៀបចំទុកមក ប្រកបដោយអង្គចំនួន ៩ ប្រការ មានសុត្តៈ គេយ្យៈ ជាដើម ដែលជាគ្រឿងរៀនសូត្រជាន់ដំបូងសម្រាប់សាងសីល សមាធិ បញ្ញា ហៅថា បរិយត្តិសទ្ធម្ម ។ សីល សមាធិ បញ្ញា ដែលកើតឡើងដោយការប្រតិបត្តិតាមធម្មវិន័យ ហៅថា បដិបត្តិសទ្ធម្ម ។ មគ្គផលនិព្វាន ដែលកើតមានព្រោះសីល សមាធិ និងបញ្ញា ហៅថា បដិវេធសទ្ធម្ម ។

ព្រះពុទ្ធជាម្ចាស់ បានត្រាស់ដឹងហើយ ទ្រង់បំពេញពុទ្ធកិច្ចស្មើតែគ្នាៈពេលសម្រាក ។ ក្នុងចំណោមវេលា ៤៥ វស្សា តាំងពីបានត្រាស់ ឈ្ល

នឹងបរិនិព្វាន ទ្រង់មានពុទ្ធកិច្ច គឺប្រកាសព្រះសទ្ធម្មទាំង ៣ ប្រការ នឹង
ទ្រង់ប្រតិស្ឋានន្ទូវពុទ្ធសាសនមណ្ឌល ដែលប្រដាប់ដោយបរិស័ទ ៤ គឺ
ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ ក្នុងការប្រកាសព្រះសទ្ធម្ម ទ្រង់ប្រ
កាសដោយព្រះអង្គឯងផង ទ្រង់ត្រាស់ឲ្យពុទ្ធសាវ័កទាំងឡាយដួយប្រ
កាសផង ។ ឧទាហរណ៍ ដូចក្នុងបឋមពោធិកាល ទ្រង់បានប្រកាសព្រះ
ធម្មចក្ក នឹងព្រះសទ្ធម្មដទៃ ។ ទៀត មានអនត្តលក្ខណសូត្រជាដើម ។
កាលមានព្រះអរហន្តជាពុទ្ធសាវ័កបានចំនួន ៦០ រូបហើយ ទ្រង់តំបន្ធូន
ព្រះអរហន្តទាំងនោះ ឲ្យទៅប្រកាសព្រះសទ្ធម្ម ក្នុងទិសទីនានាហើយទ្រង់
ហាម មិនឲ្យទៅតាមផ្លូវតែមួយដល់ ២ រូបផង ដើម្បីឲ្យព្រះសទ្ធម្មធាប់
ផ្សព្វផ្សាយទៅបានច្រើនកន្លែង ទាំងព្រះអង្គឯង ក៏ធ្វើពុទ្ធដំណើរតែមួយ
ព្រះអង្គ សំដៅទៅប្រាសដដែលមួយពាន់នាក់ ឯនុរវេលាប្រទេសដែរ
ក្នុងរយៈពុទ្ធដំណើរនេះ ទ្រង់បានបំបួសព្រះកស្សបគ្គយាជដុមារ ៣០ អង្គ
ដែលបានស្គាប់ព្រះសទ្ធម្មទេសនាហើយ បានសម្រេចមគ្គផល រួចទ្រង់
បញ្ជូនទៅដូចមុន ទើបស្តេចធ្វើពុទ្ធដំណើរតែទៅតែមួយព្រះអង្គឯងទៀត ។
ហេតុការណ៍ប៉ុណ្ណេះជាដើម ធ្វើឲ្យយើងឃើញថា ព្រះអង្គមានពុទ្ធបំ
ណងធ្ងន់ណាស់ ក្នុងការផ្សាយព្រះសទ្ធម្ម ដើម្បីជាប្រយោជន៍ ដើម្បី
សេចក្តីសុខ ដើម្បីគុណដល់សត្វសព្វ ដោយព្រះមហាករុណា ។

ព្រះបរិយត្តិសទ្ធម្ម គឺធម្មវិន័យ ដែលមានមកក្នុងព្រះត្រៃបិដកជា
សត្ថុសាសនៈ អាចជាតំណាងព្រះអង្គ តាំងពីទ្រង់គង់ព្រះធរមានទៅ
ខ្លួយ ហេតុនេះហើយ ទ្រង់ជាព្រះអង្គទ្រង់ត្រាស់ថា " នរណាឃើញ
ធម៌ នរនោះ ឈ្មោះថាឃើញព្រះអង្គ ទោះបីពុំបានដួបព្រះកាយព្រះអង្គ។
នរណាគ្រាន់តែដួបព្រះកាយព្រះអង្គ តែពុំបានឃើញធម៌ នរនោះពុំ
អាចឈ្មោះថាបានឃើញព្រះអង្គឡើយ " ។ លុះហៀបចូលបរិនិព្វាន ទ្រង់
ត្រាស់១ ទៀបទៀតថា " អំណឹះពីព្រះអង្គទៅ ធម្មវិន័យដែលទ្រង់ត្រាស់
សំដែងបញ្ញត្តហើយនឹងជាសាស្តាតំណាងព្រះអង្គ ដូច្នេះ ពុទ្ធបរិស័ទ
ដែលបានប្រតិបត្តិតាមធម្មវិន័យ ឈ្មោះថាបានបូជាព្រះអង្គ ដោយសក្ការ-
បូជាយ៉ាងប្រសើរបំផុត " ។ ពួកពុទ្ធបរិស័ទដែលបានឃើញព្រះអង្គដោយ
វិចារណញ្ញាណ តាំងមានសេចក្តីស្នេហា គតញ្ញូ គតវេទី ចំពោះព្រះអង្គ
ចង់ឲ្យព្រះអង្គទ្រង់គង់ព្រះធរមានទៅ ដោយព្រះមហាករុណាទិគុណ រមែង
នាំគ្នាយកចិត្តទុកជាក់ក្នុងព្រះសទ្ធម្ម គោរពក្នុងព្រះសទ្ធម្ម លើកតំកើងនូវ
ព្រះសទ្ធម្ម ដែលមានមកក្នុងព្រះត្រៃបិដក ដោយការបរិយត្តិ នឹងការ
ប្រតិបត្តិ តាមសីល សមាធិ បញ្ញា ទោះបី លោកអ្នកតាំងនោះអស់តណ្ហី-
យកិច្ចជាលំនៃហើយក៏ដោយ ។ ការសង្គាយនារៀបរៀងផ្លូវនឹងផ្លាត់ធម្ម
វិន័យក្តី រៀនទន្ទេញធម្មវិន័យក្តី ផ្សាយធម្មវិន័យក្តី ជាការណីយកិច្ចនៃពុទ្ធ-

សាវកចាំងឡាយ តាំងពីព្រះពុទ្ធជាម្ចាស់ទ្រង់គង់ព្រះធរមាននៅឡើយ ។ ព្រះសារីបុត្តដែលជាតួអង្គអគ្គសាវក៏ បានស្រាបបង្គំទូលសុំព្រះពុទ្ធានុញ្ញាត ប្រជុំសង្ឃធ្វើសង្គាយនាមួយគ្រា ។ ក្នុងការសង្គាយនានោះ អគ្គលោកជាអ្នកសំដែងរៀបរៀងធម្មវិន័យ ក្នុងសង្ឃសន្និបាត នៅទីចំពោះព្រះភ័ក្ត្រនៃព្រះបរមសាស្តា លោកបានបញ្ជាក់គ្រប់កងធម៌ថា នេះជាធម៌ នេះជាវិន័យ នេះជាសត្ថុសាសន៍ លោកដ៏មានអាយុចាំងឡាយ គប្បីចាំទុកប៉ុនដូច្នេះៗ គ្រាព្រះដ៏មានបុណ្យបរិនិព្វានហើយ ពុទ្ធសាវ័កចាំងឡាយ មានព្រះមហាកស្សបជាប្រធាន បានប្រជុំធ្វើសង្គាយនា ដែលហៅថាបឋមសង្គាយនា ។ ក្នុងការសង្គាយនានេះ បានលើកព្រះវិន័យមកសង្គាយនាមុន ទើបសង្គាយនាព្រះធម៌ គឺព្រះសូត្រនិងព្រះអភិធម្ម ។ ព្រោះហេតុនោះ សត្ថុសាសន៍ ដែលទ្រទ្រង់មានឈ្មោះ តែពីរគឺធម៌ ១ វិន័យ ១ ក៏ប្រែកជាទៅជាបិដកចាំង ៣ គឺព្រះវិន័យបិដក ១ ព្រះសុត្តន្តបិដក ១ ព្រះអភិធម្មបិដក ១ ។ តាលសង្គាយនាបិដកនីមួយ ។ ចប់ ដោយយល់ឃើញព្រមគ្នាថា ជាធម៌ ជាវិន័យ ជាសត្ថុសាសន៍ហើយ ក៏នាំគ្នាសូត្រឲ្យបានចាំស្ទាត់ចាំងអស់ រួចប្រកាសផ្សាយធម្មវិន័យ ជារាបអស់ព្រះជន្មរៀងខ្លួន ។

តពីនោះមក ចេះតែមានការសង្គាយនាជាលំដាប់ គឺទុតិយសង្គាយនា តតិយសង្គាយនា ចតុត្ថសង្គាយនាជាដើម តាំងពីអរហន្តសម័យជារាបដល់

សម័យនេះ ។ ពស្តុតាងប្រាកដក្នុងប្រវត្តិពុទ្ធសាសនា សង្គាយនានៅជម្ពូ-
ទ្វីបមជ្ឈិមប្រទេស (ឥណ្ឌា) ៣ គ្រា ។ នៅលង្កាទ្វីប ៤ គ្រា នឹងនៅទប-
ទ្វីប សុវណ្ណភូមិយើងនេះច្រើនគ្រា ដូចជានៅប្រទេសភូមា នឹងប្រទេស
កម្ពុជាយើងនេះជាដើម ។ សង្គាយនាទាំងនេះ សុទ្ធតែជារបស់រដ្ឋ មាន
អង្គព្រះមហាក្សត្រ ឬប្រធានាធិបតី ជាពុទ្ធសាសនូបត្ថម្ភក៍ ។

ការសង្គាយនាទាំង ៦ ឱ្យ ដែលមានមកហើយ តាំងពីពុទ្ធសតវត្សរ៍
ទី ១ ដរាបដល់ពុទ្ធសតវត្សរ៍ទី ២៥ ដែលទើបកន្លងទៅនេះ សុទ្ធតែមាន
ការផ្ទៀងផ្ទាត់ចារលីព្រះត្រៃបិដក ឱ្យត្រឹមត្រូវ តាមបែបបទមសង្គាយនា
ដូចគ្នាទាំងអស់ ។

ការសង្គាយនា ព្រះត្រៃបិដក របស់រដ្ឋកម្ពុជាយើង ចាប់ផ្តើមដូចមក
តាំងពីក្នុងរជ្ជកាល នៃព្រះករុណាក្នុងព្រះបរមរត្តិយាកោដ្ឋ ដោយព្រះ
សង្ឃជាសង្គីតិកាចារ្យច្រើនរូប ដែលហៅថាក្រុមដំនុំព្រះត្រៃបិដក នៅ
ក្រុមពុទ្ធសាសនបណ្ឌិត្យ បានប្រជុំផ្ទៀងផ្ទាត់ព្រះត្រៃបិដកចារលី រួចប្រែ
ជាសម្រាយខ្មែរពាល់តែចប់ ទាំងបានបោះពុម្ពផ្សាយជាសៀវភៅ បានចំ-
នួន ៥២ ភាគហើយ នៅសល់ ៥៨ ភាគទៀតនឹងចប់ ដែលក្រុមនេះកំពុង
តែចាត់ការបោះពុម្ពតទៅ ។

យើងជាពុទ្ធបរិស័ទ គួរញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុងព្រះត្រៃបិដកនេះណាស់

គួរមើលគួរអាន គួរពិនិត្យ គួរជាវត្ថុកជាសម្បត្តិប្រចាំជីវិត ព្រោះជាក្បួនច្បាប់មានសារប្រយោជន៍ខ្ពង់ខ្ពស់បំផុត អាចញុំាងដំណឹងខាងពុទ្ធសាសនាឲ្យច្បាស់ប្រាកដឡើង ដល់មនុស្សនៃងាខ្ពើ តាំងអាចញុំាងសារធម៌ គឺសីលសមាធិបញ្ញា ឲ្យផ្សាយទ្រូតទ្រាបទៅក្នុងសន្តានៃសត្វលោកផង ។

យើងរាល់គ្នា ដែលបានសៀវភៅព្រះត្រៃបិដកពោះពុម្ព ជាច្បាលីម្ខាង សម្រាយម្ខាងរាល់ខំពីរបៃបនេះប្រសើរណាស់ ប្រៀបដូចបានប្រទីបប្អូតោមធំ ។ ពីរដួរ តាំងនៅអមផ្លូវតាំងសងខាង ដែលជាផ្លូវដើរទៅតាន់ទីក្សេមក្សាន្ត និងទុក្ខ និងភ័យ ។

មួយទៀត ការសង្គាយនាព្រះសទ្ធម្មក្តី ការជួយទុបត្ថម្ភក្នុងការសង្គាយនាដោយពិធីផ្សេង ។ ក្តី ដែលនឹងកើតឡើងបាន ក៏ដោយសារមានយោបល់សំខាន់ ។ មានដើមដូចតទៅនេះ៖

๑- ព្រះពុទ្ធជាម្ចាស់ មិនងាយកើតមានក្នុងលោក ព្រោះត្រូវតែសាងអភិនិហារអស់កាលយូរអង្វែងណាស់ ទើបបានត្រាស់ជាព្រះពុទ្ធ ។ តាលបើព្រះពុទ្ធមិនងាយ កើតមានហើយ ព្រះសទ្ធម្ម គឺធម្មវិន័យ ជាសត្ថុសាសនៈ ក៏មិនងាយកើតមានដែរ ។ ព្រះសទ្ធម្មតាំងឡាយមានព្រះបរិយត្តិសទ្ធម្មជាដើម សុទ្ធតែមានព្រះត្រៃបិដកនេះជាប្រកព ប្រៃសេចក្តីថា យើងគួរតែស្វះស្វែងរកព្រះសទ្ធម្ម ក្នុងព្រះត្រៃបិដកនេះឯង ។

๒- ការសំដែងព្រះសទ្ធម្ម ស្តាប់ព្រះសទ្ធម្ម រៀនសូត្រព្រះសទ្ធម្ម ប្រតិបត្តិញុំាងព្រះសទ្ធម្ម ឲ្យកើតមានក្នុងសន្តាន នេះរមែងប្រព្រឹត្តទៅដើម្បីសុខសន្តិភាព ។ ហេតុនេះទើបអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ពេញព្រះទ័យណាស់ ក្នុងការផ្សាយព្រះសទ្ធម្ម ដើម្បីប្រយោជន៍ដល់សត្វសត្វ ។

៣- ការសាងបារមីដើម្បីត្រាស់ជាព្រះពុទ្ធ នឹងការបំពេញពុទ្ធកិច្ចមានប្រកាសព្រះសទ្ធម្មទេសនាជាដើម ដោយព្រះមហាករុណានៃព្រះពុទ្ធជាម្ចាស់យើងនេះ ធ្វើឲ្យព្រះអគ្គវង្សក្នុងលំហកហួសប្រមាណ មុខគួរសំវែងអណោចអាណិតព្រះទ័យព្រះអង្គណាស់ ។ ហេតុនេះ យើងជាពុទ្ធបរិស័ទគួរទំប្រតិបត្តិឲ្យសមតាមពុទ្ធបំណង ។

៤- ព្រះពុទ្ធជាបរមសាស្តាយើង ទ្រង់រំលត់ទន្ទឹងបូលការនព្រះបរមនិព្វានកន្លងមក ជាងពីរពាន់ប្រាំរយឆ្នាំហើយ មានតែព្រះសទ្ធម្មគឺព្រះត្រៃបិដកជាពុទ្ធវចនៈនេះហើយ ដែលឋិតនៅជាតំណាងព្រះអង្គ ។ បើយើងជាពុទ្ធបរិស័ទ មិនយកចិត្តទុកដាក់ធ្វើសក្ការៈគោរពប៉ះពាល់បូជាព្រះសទ្ធម្ម គឺព្រះត្រៃបិដកជាតំណាងព្រះអង្គ ដោយអាមិសបូជា និងដោយបដិបត្តិបូជាទេ តើឲ្យនរណាយកចិត្តទុកដាក់ដំនួសវិញ ។

៥- ព្រះពុទ្ធសាសនា ដែលនឹងរុងរឿងថិតថេរចំរើនកាលទៅបាន

ក៏ដោយសារសម្ថបដិបត្តិ នៃពុទ្ធបរិស័ទទាំងអស់គ្នា ដែលមានបរិយត្តិ
គឺការរៀន ទន្ទេញ អានមើលនូវព្រះត្រៃបិដកនេះជាមូលហេតុ ។ ចុះបើ
យើងជាពុទ្ធបរិស័ទ មិនយកចិត្តទុកដាក់ ក្នុងបរិយត្តិនេះហើយ តើពុទ្ធ-
សាសនានឹងសង្ឃឹមលើនរណា ។ យើងតែងបានដឹងថា ព្រះពុទ្ធជាម្ចាស់
ទ្រង់ត្រាស់ថា សាសនាព្រះអង្គ ទ្រទ្រង់រឿង ដោយសារបរិស័ទ ដែលជា
កូនចៅព្រះអង្គ ចំរៀន ចំប្រតិបត្តិតាម ។ ព្រោះការរៀនហើយប្រតិបត្តិ
នេះ ជាគ្រឿងប្រកាសគុណ ព្រះអង្គគឺប្រកាសគុណព្រះរតនត្រ័យ ឲ្យ
ប្រាកដ ។

៦- មនុស្សនៃការក្នុងលោកសន្និវាសសព្វថ្ងៃនេះ កំពុងអំពាវនាវ
ស្រែករកសន្តិភាព ។ បើអត្ថរសព្រះសទ្ធម្មក្នុងផ្លែព្រះបិដកទាំង ៣ បាន
ផ្សាយជ្រួតជ្រាបទៅ ក្នុងពួកមនុស្ស នាសកលលោក យ៉ាងហោចត្រឹម
សីល ៥ ដែលហៅថានិច្ចសីល ។ ការអំពាវនាវរកសន្តិភាពនោះ មុខជា
សម្រេចផលតាមបំណង ។

ដោយអាស្រ័យយើងជាពុទ្ធបរិស័ទទាំងអស់គ្នា មានយោបល់ស្រប
គ្នាបែបៗនេះ ទើបវដ្ដយើងអាចធ្វើសង្គាយនាព្រះសទ្ធម្ម គឺព្រះត្រៃបិដក
ជាពុទ្ធវចនៈ បានសម្រេចផលដូចបមក ទើដូចគ្នាទៅមុខទៀត ។

កាលបើយើងបានសង្គាយនា ទើដួយៗបត្ថម្ភក្នុងការនេះ ដោយ

យើញថា អំពើប្រសើរនេះ ជាកតវេណីយកិច្ចរបស់ខ្លួន ដែលជាពុទ្ធបរិស័ទ
កូនចៅព្រះសម្មាសម្ពុទ្ធ គួរតែធ្វើដើម្បីសំដែងសេចក្តីកតញ្ញូ កតវេទី ចំពោះ
ព្រះអង្គដូច្នេះ ។ នោះយើងនឹងបានសម្រេចផលានិសង្សយ៉ាងខ្ពង់ខ្ពស់
តាលនឹកដល់អំពើដែលខ្លួនបានធ្វើហើយនេះគ្រាណា គ្រានោះសេចក្តី
សោមនស្សជ្រះថ្លា នឹងកើតមានដល់យើងមិនតិចឡើយ ។ ម្ល៉ោះហើយ
បុញ្ញកិរិយនេះ ស្មើនឹងបុណ្យ គឺសេចក្តីស្ងប់ នឹងសេចក្តីសុខសួស្តី រមែងហូរ
មកគាន់ខ្លួនសន្ធាន ពាំងយប់ពាំងថ្ងៃ តាមដែលយើងនឹកយកអំពើនេះ
មកជាអារម្មណ៍ ។

អធិប្បាយមកក្នុងព្រះសទ្ធម្ម ជាមិស្ងប់នាំឲ្យកើតសន្តិភាពនឹងសន្តិសុខ
ដែលសាធុជនគួរគោរព គួរបូជា ដោយអាមិសនឹងដោយសេចក្តីប្រតិបត្តិ
ដោយសង្ខេបតែប៉ុណ្ណេះ ។



កាន់ប្រាជ្ញកុំប្រឈមសម្រេចតាម　　ហួសហើយកុំហាមឲ្យតាមគេ
បទខ្វីតោងវៀរវៀសបែរ　　រឿនស្មេហ៍តោងស្ងួនចិត្តឲ្យស្ងួន ។
ប្រាក់មានលើកឲ្យគេខ្លីទៅ　　ចំណេះចេះនៅតែក្នុងក្បួន
ប្រពន្ធនៅឆ្ងាយអំពីខ្លួន　　ដល់ប្អូនត្រូវការអារចិត្ត ។
ចេះច្រើនលំបាកយ៉ាកនឹងគេច　　ចេះតិចព្រួយប្រាណរំខានតិត
ល្ងង់ល្ងើប្រើការដូចគេល្ងិត　　ឥតបើតិតមិនកើតការនោះបាន ។
តាំងខ្លួនតោងឃ្លាតពីខ្លួចេញ　　វែងណាសលសេញហួសប្រមាណ (១)
លក់ដូរមើលដើមឲ្យដឹងជាន　　តិតអានសឹមធ្វើតាមប្រាជ្ញា ។
ខ្លួកលឿនដំណើបអុំឲ្យលិច　　ត្បូងពេជ្រឆ៍ម្តេចគង់ប្រែធា
ទីស្ងាត់ប្រយ័ត្នចេញវាចា　　តិតអាថឯណាកុំអាងដិត ។
ភ្លាត់មាត់មិនខប់កំពប់ប្រាក់　　ភ្លាត់ដើង-ដើងបាត់មានថ្នាំបិទ
ភ្លាត់ការគង់តែបំបែរតិត　　ភ្លាត់ចិត្តគង់ចាប់ទៅតាមចេះ ។
យល់ញាតិឃ្លាតឋាប់ចាប់រាត　　យល់ការគង់ឃ្លាតឃ្លៀងចំណេះ
ដំរីដើងបួនគង់ភ្លាត់អេះ　　អ្នកប្រាជ្ញដែលចេះគង់ភ្លាត់ខ្លះ ។
ចាប់ត្រីដៃពីរតម្រាហាម　　ចាក់អង្កួរយកអង្កាមហាមមិនឈ្នះ
អុំខ្លួកឡើងភ្នំខ្ពស់មានះ　　បង់ព្រះទៅសំពះឯបាយ៉ាប ។

១- បើបាំងអ្នកខ្មែរល្អជាង " ទិតទំបំពេញហាតពត់ប្រាណ " ញ. ស. ។

សិល្បៈពុទ្ធសាសនា

ព្រះឧបាលីវង្ស ស៊ីវ៉ូ-ប៊ាយ រៀបរៀង

ពាក្យថា សិល្បៈ ជាពាក្យដែលយើងធ្លាប់និយាយមកដោយស៊ិបស៊ាំដែរហើយ, ប៉ុន្តែវេលានេះ ជាពេលចាំបាច់ក្នុងការសំដែងអំពីសិល្បៈដែលជាប់ទាក់ទងក្នុងផ្លូវពុទ្ធសាសនា ដូចសេចក្តីបរិយាយតទៅនេះ

សិល្បៈ ជាភាសាសំស្ក្រឹត, សិប្បៈ ជាភាសាបាលី ប្រែជាភាសាខ្មែរថា "ការឈ្លាសវៃដោយដៃ, ការប៉ិនប្រសប់, ជំនាញដ៏ថ្នឹក, ហត្ថកម្មដ៏ស្ទាត់ជំនាញ" ។

សិល្បៈជាឈ្មោះវិជ្ជាបច្ចេកទេស, ដែលប្រកបដោយហត្ថកម្មចាំដៃធ្វើវិធ្វាសដោយអំណាចនៃការហាត់រៀន, ការអប់រំរឿយៗ គឺថា វិជ្ជាកម្មណាដែលគេបានព្យាយាមសិក្សាធ្វើដោយផ្ទាល់ដៃ ជាបដល់ថ្នឹកចាំស្ទាត់ប្រាកដហាក់ដូចជាចម្លាក់ជាប់នៅក្នុងចិត្ត ឥតការខ្វល់ ឥតក្រេច, វិជ្ជាកម្មនោះឈ្មោះថា សិល្បៈពាំងអស់ ។

ពាក្យថា សិល្បៈ បើប្រែតាមធាតុថា "វិជ្ជាកម្មដែលគួរសិក្សា, ដែលគួរសេពគប់, ដែលគួរចូលចិត្ត" ដូចបាលីវិគ្រោះថា "អត្ថតោ មាតមា-សឹសន្តេហិ សិវិយតេតិ សិប្បំ វិជ្ជាកម្មណា ដែលបុគ្គលអ្នកប៉ុនប៉ងនូវប្រយោជន៍ដើម្បីខ្លួនគួរសេពគប់វិជ្ជាកម្មនោះ ហៅថា សិប្បៈ (សិល្បៈ)"

មួយទៀតថា សិក្ខិតព្វន្តិ សិប្បំ វិជ្ជាកម្មដែលគប្បីរៀន ហៅថាសិប្បៈ (សិល្បៈ) ។

សិល្បៈ បើចែកតាមលក្ខណៈ (គ្រឿងសំគាល់) មាន ៣ យ៉ាង ដូចសេចក្តីរៀបរាប់ព្រមទាំងអធិប្បាយតទៅនេះ

លក្ខណៈនៃសិល្បៈ (ហៅតាមភាសាបាលីថាសិប្បៈ) មាន ៣ យ៉ាងគឺ

๑- អតិឆេយ្យសិប្បៈ សិល្បៈដោយឈ្មោះ;

๒- ហេតុសិប្បៈ សិល្បៈកើតអំពីហេតុ;

๓. ផលសិប្បៈ សិល្បៈកើតអំពីផល ។

អធិប្បាយលក្ខណៈសិល្បៈ

๑- អតិឆេយ្យសិប្បៈ សិល្បៈដោយឈ្មោះ

សិល្បៈនេះ លោកអ្នកប្រាជ្ញសំដែងតាមឈ្មោះនៃវិជ្ជាកម្ម ដែលមានមកតាំងពីបុព្វកាល សឹងមានក្នុងគម្ពីរអដ្ឋកថាទាំង ២ក្នុងនិកាយត្រង់នូវគ្គរាប់ឈ្មោះសិល្បៈធំៗ ហៅថា "មហាសិប្បៈ" មាន ๑๒ យ៉ាងគឺ

๑) ហត្ថិសិប្បៈ សិល្បៈ ក្នុងការចង្អុតដំរី;

๒) អស្សសិប្បៈ សិល្បៈ ក្នុងការបង្អុតសេះ;

๓) រថសិប្បៈ សិល្បៈ ក្នុងការធ្វើរទេះ បររទេះ;

๔) ធនុសិប្បៈ សិល្បៈ ក្នុងការបាញ់ធ្នូ;

๕) ចារុសិប្បៈ សិល្បៈ ក្នុងការធ្វើគ្រឿងអាវុធមានជាដាវដោម,

៦) មុទ្ធាសិប្បៈ សិល្បៈ ក្នុងការរាប់តាញ៉ែគ្នេរដោយដៃទទេ

៧) គណនាសិប្បៈសិល្បៈក្នុងការគិតតាមលេខគណិតសាស្ត្រ;

៨) សទ្ធានសិប្បៈ សិល្បៈ ក្នុងការពិចារណា ដោយប្រាជ្ញាក្នុងបរទេស គឺនយោបាយ;

៩) លេខាសិប្បៈ សិល្បៈ ក្នុងការសរសេរៀបចំអក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ;

១០) តាវេយ្យសិប្បៈ សិល្បៈ ក្នុងការព្យាយាម;

១១) លោកាយតសិប្បៈ សិល្បៈ ក្នុងផ្លូវលោកមានវិជ្ជាពេទ្យ, វិជ្ជាផ្សំជាតុជាដើម;

១២) ឧត្តិវិជ្ជាសិប្បៈ សិល្បៈក្នុងវិជ្ជានីតិធម្មសាស្ត្រ, យុទ្ធសាស្ត្រ។ អាចារ្យក្នុងសាលាទិសាបាមោក្ខ ក្រុងតក្កសិលាក្នុងសម័យបុពណ្ណតែងយកសិល្បៈតាំង ១៦ យ៉ាងនេះ ទៅជាកត្តុកម្មវិធីសម្រាប់បង្រៀន។

សិប្បៈសាធារណៈដោយខ្លែកខ្លៃត មាន ៩ យ៉ាង គឺ

១) ទារុសិប្បៈ សិល្បៈ ក្នុងការកសាងដោយគ្រឿងឈើមានការសង់ផ្ទះជាដើម;

២) សុជាសិប្បៈ សិល្បៈ ក្នុងការកសាងដោយគ្រឿងកំបោរជាយអ, ឥដ្ឋ;

៣) លោហធាតុសិប្បៈ សិល្បៈ ក្នុងការរំលាយ សិតសូន គ្រឿងលោហធាតុ ;

៤) វត្ថុសិប្បៈ សិល្បៈ ក្នុងការធ្វើសំពត់ ;

៥) ចិត្តកម្មសិប្បៈ សិល្បៈ ក្នុងការគូររូបផ្សេងៗ ;

៦) ចម្មសិប្បៈ សិល្បៈ ក្នុងការសម្ងាប់ស្បែក ;

៧) មណិការសិប្បៈ សិល្បៈ ក្នុងការស្វែងរកពេជ្រ ច្នៃពេជ្រ ;

៨) ឆទ្បការសិប្បៈ សិល្បៈ ក្នុងការត្បាញផែង ត្បាញកន្ទេល,

៩) ឆហាបិតសិប្បៈ សិល្បៈ ក្នុងការកាត់ការសក់ ។

សិល្បៈ មាន ឈ្មោះ ៧ យ៉ាងទៀត គឺ

១) វេធសិប្បៈ សិល្បៈ ក្នុងការជ្រលក់សំពត់ ;

២) ឆេទនសិប្បៈ សិល្បៈ ក្នុងការកាត់សំពត់អាវ, ស្បង់ចីពរ ;

៣) សិព្វនសិប្បៈ សិល្បៈ ក្នុងការដេរប៉ាក់ ;

៤) រចនសិប្បៈ សិល្បៈ ក្នុងការឆ្លាក់ក្បាច់ក្បូរ ;

៥ កុម្ភការសិប្បៈ សិល្បៈ ក្នុងការធ្វើក្អម ឆ្នាំង ឬការដនៈ ពាសែសណាមួយ ;

៦) សុរាណ្ណាការសិប្បៈ សិល្បៈ ក្នុងការធ្វើមាស ;

៧) ជាដកសិប្បៈ សិល្បៈ ក្នុងរបាំ ។

ក្នុងគម្ពីរមង្គលត្ថទីបនីអដ្ឋកថាមង្គលសូត្រថា "វិជ្ជាណាមួយ ដែលគេរៀនហាត់ស្ទាត់បានបទប្បែកអស្ចារ្យ គួរឱ្យអ្នកដឹងគោតសរសើរ សូម្បីតែវិជ្ជាជ្រាតដុំក្រួស ក៏លោកហៅថាសាឡិតសិប្បៈ ឬសត្ថុសិប្បៈ ដែរ"។

២) ហោតុសិល្បៈ សិល្បៈកើតអំពីហេតុ ។

សិល្បៈពាំនអស់ ដែលជាប់ដោយហេតុកម្ម សុទ្ធតែកើតឡើងអាស្រ័យហេតុ គឺថាមានហេតុជាប្រភព (ជាដែនកើត)នៃសិល្បៈ។ ពាក្យថា "ហេតុ" បានដល់ដំណើរឬការណ៍ភ្លឺមួយ ដែលកើតមុនដំបូងបង្អស់ ដូចយ៉ាងអារម្មណ៍ណាមួយ ដែលមាននៅក្នុងគំនិតរបស់មនុស្ស ឬថា តួមនោសញ្ចេតនា ដែលអាច ដឹងកវែ ត្រិះរិះគិតការងារ ឬរកវិធីសម្ភារៈសម្រាប់ប្រើប្រាស់ លុះត្រិះរិះគិតឃើញជាក់ច្បាស់ហើយ ឈ្មោះថាមនោសញ្ចេតនា បានប្រមូលគំនិតនោះ ទុកឱ្យឋិតនៅមូល ក្នុងចិត្តសិប្បសួនល្អហើយ ។ លំដាប់ពីនោះមក យោនិសោមនសិការៈ ការកំណត់ធ្វើទុកក្នុងចិត្តដោយទប្បយុត្តិជ្រាបរបស់មនុស្ស ក៏រមែងកើតឡើង ដោយមានមនោសញ្ចេតនា ជាហេតុ លុះយោនិសោមនសិការៈ មានតម្លាំងឡើងដោយរួមជាមួយនឹងវីរិយៈ ក៏អាចបបួលដឹកនាំឱ្យចុះដៃចាប់ធ្វើនូវវត្ថុសម្ភារៈ ដែលកំណត់ទុកនោះ តាមស្នាមគំនូសរបស់គំនិត ដែលគិតឃើញពីមុនដរាបដល់ចុះដៃចាប់ធ្វើឱ្យកើតបានដូចបំណងឬមិនខាន់បានដូច

បំណងប៉ុន្តែការងារនោះចេះតែដួយបំភ្លឺមគ្គផលបន្តិចៗ ជាលំដាប់ឈ្មោះថាមានសិល្បៈដួយពង្រីកគំនិតឲ្យកាន់តែយល់ស្គាល់ដំណើរការណ៍នោះៗ ដោយមានយោនិសោមនសិការៈជាហេតុ ។

វត្ថុអ្វីៗពាំងអស់ មានចេតិយ ប្រាង្គ ប្រាសាទជាដើម ដែលកើតឡើងនោះបើល្អក្តី អាក្រក់ក្តី សុទ្ធតែកើតមកពីហត្ថកម្ម (ការងារដែលធ្វើដោយដៃ) ។ រូបវត្ថុដែលល្អ មកពីហត្ថកម្មស្អាតដំនាញ, រូបវត្ថុដែលមិនល្អមកពីហត្ថកម្មមិនពាន់ស្អាតដំនាញ ។ ដំណើរនេះបើពោលដោយរួបរួម គឺសិល្បៈពាំងអស់ សុទ្ធតែកើតមកអំពីហេតុ មានមនោគតិ (ដំណើរបស់គំនិត) ជាដំបូងបង្អស់ ដែលឲ្យកំណើតដល់សិល្បៈ ឬនឹងថាសិល្បៈគ្រប់យ៉ាងក្នុងលោកនេះ កើតមកអំពីមនោគតិរបស់មនុស្សដូច្នេះវិញក៏បាន ។ មនោគតិដែលគេបានអប់រំញឹកញាយនេះឯងជាមូលហេតុនាំឲ្យកើតសិល្បៈ ដោយមិនហួសអំភ្លើសយ៉ាងតិចមនុស្សខ្លះ ព្រោះថា មនោគតិរបស់មនុស្សអ្នកមានសមត្ថភាពមិនចេះនៅស្ងៀម ឈរត្រឹងទៅដដែលទេ ចេះតែមានការវិវត្តន៍ (ការសើរើរេរាវរក) នូវអព្ភូតវត្ថុ (វត្ថុដែលមិនពាន់កើតមាន) ជារឿយៗដួនកាលក៏ធ្វើបានសម្រេចដូចបំណងដួនកាលក៏ហួរ អស់មួយតំណអាយុក៏មាន ពីរបីតំណអាយុក៏មាន ។ -

សម័យជាលំដាប់តមក ពួកសិប្បីវន្ត (អ្នកមានសិល្បៈ) ក៏អាចរៀបចំ

និពន្ធក្នុងតម្រា ចងជាច្បាប់ទុកបន្តមកទៀត ដើម្បីឲ្យងាយក្នុងការបង្រៀនផ្សេងៗ ដល់មនុស្សជាន់ក្រោយ ។ ក្នុងតម្រា ដែលពួកសិប្បីនិពន្ធបាននិពន្ធទុកមកនោះ ហៅថា សិល្បសាស្ត្រ ប្រែថា គម្ពីរដែលនិយាយអំពីសិល្បៈ ជាបឋមក ។ ពួកអ្នកមានវិជ្ជាបច្ចេកទេស ពីដើមដំបូងបង្អស់នោះ ហាត់ខ្មីឃ្មីក្នុងការប្រើគំនិត ពិចារណាពិនិត្យពេកណាស់ ទម្រាំនឹងកើតបានជារូបសិល្បៈ, ជារូបសិល្បសាស្ត្រឡើង ។

អ្នកបច្ចេកទេសជាន់ក្រោយ ដែលចុះស្នាមក្នុងការសិក្សាតាមសំអាងសិល្បសាស្ត្រ ដែលគេបាននិពន្ធទុកមកហើយនោះ មិនសូវលំបាកហាត់ខ្មីឃ្មីយ ដោយមធ្យោបាយក្នុងមនោគតិប៉ុន្មានទេ ព្រោះហេតុមានក្នុងតម្រា, មានតម្ងឹងធី, មានរូបមន្ត" មានតម្ងឹសិកពរបស់បុព្វបុរសស្រាប់ ។។ វិជ្ជាបច្ចេកទេសរបស់មនុស្សដែលបានសិក្សាតាមក្នុងតម្រា តំរេះតែប្រកបដោយវឌ្ឍនភាពមានបដិសម្ភិទា (បែកគំនិតច្រាជ្រា) តែផ្សាយទូលាយតាន់តែធំចំរើនឡើងតមកទៀត ។ សិល្បៈទាំងអស់ដែលកើតមានឡើងដោយអ្នកនិពន្ធ ក៏ព្រោះតែគំនិតពាវកបស់មនុស្ស ជាបុព្វបុរសជាដើមហេតុ ។ ករណីនេះ សិល្បៈគ្រប់យ៉ាងទើបឈ្មោះថា កើតមកអំពីហេតុ ។

៣. ផលសិល្បៈ សិល្បៈកើតអំពីផល ។

សិល្បៈដែលសង្គ្រោះថា កើតអំពីផលនោះ សំដៅយកប្រយោគុផ្សេងៗ

មានចេតិយឬព្រះពុទ្ធរូបជាដើម ដែលបុព្វបុរស បានសាងទុកមកហើយ ដោយហុចឱ្យយើងបានឃើញដំនាងស្មាដៃស្អាតដំនាងញឹម មិនស្អាតដំនាងជារូបមានបែបភាពទ្រនំទ្រាយ, មានក្បាច់រចនា តាមដំនាន់ តាមសម័យ ដូនផលដល់យើង ដើម្បីឱ្យយើងឃើញបែបយ៉ាងរបស់វប្បធម៌នៃបុព្វបុរសតាមសម័យនោះ ។ ។ ពាក្យថា "ផល" ប្រែថា "កំរៃ, ផ្លែឈើ, សេចក្តីចំរើន. សេចក្តីរុងរឿង, សេចក្តីសម្រេចដូចបំណង, លាភ, យស, វង្សាន់" ។

ត្រង់ដែលថាសិល្បៈ កើតអំពីផលនោះ សំដៅយកការហាត់រៀនក្នុងផ្លូវសិល្បៈរបស់មនុស្សដែលសម្ងំនឹងយើញផលដែលត្រូវបាន, ការហាត់រៀននោះគឺបេះតែខំតស៊ូមិនខ្ជិចខ្ជួលស័ក្តណាមួយ ដោយមានបំណងចំពោះផលជានិទស្សន៍, មួយទៀត សិល្បៈនេះរាប់ថាជាផ្លូវអាជីវៈមួយដ៏ប្រសើរដែលនាំឱ្យមនុស្សមានជីវភាពធ្ងន់ធ្ងរ ។ ឧទាហរណ៍ ដូចសិល្បៈខាងការរចនាព្រះពុទ្ធរូប, ស្តូប, ចេតិយ, ប្រាង្គ, ប្រាសាទ, វិហារ, សាលា, គំនូរ និងការរចនាផ្សេងៗ របស់បុព្វបុរសដែលរីតួមកដល់យើងសព្វថ្ងៃឱ្យយើងបានឃើញជាទ័ស្តាងយ៉ាងជាក់ស្តែង ។ សិល្បៈរបស់យើងជាន់ក្រោយឈ្មោះថា កើតមកអំពីផលរបស់សិល្បៈនៃបុព្វបុរសដែលបានផ្តល់ទស្សន៍ឱ្យយើង ។ រូបភាពទាំងអស់ដែលបុព្វបុរសខ្មែរសាង

ខ្មែរដោយថ្នក់ក្តី ដោយឥដ្ឋក្តី ឈ្មោះថាជារូបសិល្បៈស្ថាពរ មានមកយូរហើយ ដើម្បីជានិទស្សន៍បង្ហាញយើងជាន់ក្រោយ ។

អំពីព្រះពុទ្ធរូប

ព្រះពុទ្ធរូប បើតាមអ្នកប្រាជ្ញប្រវត្តិសាស្ត្រត្រាច់ឆ្លាត់ស្រាវជ្រាវរកបុរាណវត្ថុកន្លែងប្រទេសផ្សេងៗ មានប្រទេសឥណ្ឌាជាដើម គេឃើញព្រះពុទ្ធរូបច្រើនបែប ប៉ុន្តែបើទុកជាយ៉ាងណា ក៏ព្រះពុទ្ធរូបនោះៗ ក្នុងតែរូបមនុស្សធម្មតាដែលអាចឲ្យអ្នកផងឃើញហើយ គួរឲ្យស្គាល់បានភ្លាមថាជារូបព្រះពុទ្ធ ។ មួយទៀត ព្រះពុទ្ធរូបដែលគេធ្វាក់ថ្នក្តី ឆ្លុំឈើក្តី គេតែងតម្រូវចិត្តនៃពុទ្ធសាសនិកជនផង ឲ្យត្រូវតាមមហាបុរិសលក្ខណៈនៃព្រះសម្មាសម្ពុទ្ធផង ។ ប៉ុន្តែក្នុងអ្នកសិល្បៈខ្លះ ដែលកសាងព្រះពុទ្ធរូបនោះគោរពតែអំពីថ្នក្តី ឆ្លុំឈើក្តី ឬគំនូរក្តី ច្រើនតែធ្វើទៅតាមបែបគាត្រង់ក្រោយមុខមាត់ របស់ជាតិខ្លួនឯងជាដរាប មិនសូវខុសអំពីមុខមាត់របស់ជាតិឯទៀបឡើយ ដែលនាំឲ្យយើងស្គាល់បានថា ជាការបង្ហាញរបស់ជាតិនេះ ជាតិនោះជាក់ច្បាស់ ។

បើតាមសេចក្តីរាយការណ៍ របស់អ្នកប្រាជ្ញ ដែលស្វែងរកបុរាណវត្ថុឃើញថា ព្រះពុទ្ធរូបដើមតែនឹងកើតមានឡើង ក្នុងសាលាងក្រោយដែលពុទ្ធសកវាជកន្លងទៅបានជាង ៤០០ ឆ្នាំហើយ ពុំមានកើតទេនៅក្នុង

តាលព្រះអង្គគង់ព្រះដន្ទនោះឡើយនោះទេ ។ ព្រះពុទ្ធរូបដែលកើតមុន ដំបូងបង្អស់ នៅក្នុងប្រទេសគន្ធារៈ ដោយព្រះបាទកនិស្កៈ ជាក្សត្រ មួយព្រះអង្គ ជាជាតិក្រិក ជាប់ពាក់ព័ន្ធតមកអំពីព្រះបាទអាឡិកសង់ដ្រ ដែលមានឥទ្ធិពលពង្រីកអាណាចក្រចូលមកក្នុងប្រទេសឥណ្ឌា ក្នុងតាល ពុទ្ធសតវត្សរ៍ ៤ ។ បន្តាប់មកពួកសិថ្យវន្ត ជាតិក្រិកខ្លះ ជាតិឥណ្ឌាខ្លះ បានតែកសាងព្រះពុទ្ធរូប ដោយការធ្លាក់ថ្នាក់មាន ខ្វះឈើកំមានតៗគ្នា តាំងពីតាលនោះមក ។

ប្រទេសកម្ពុជាមានព្រះពុទ្ធរូប៨បែប

១- ព្រះពុទ្ធរូបសមាធិ គង់ពត់ព្រះកែ្នងមានព្រះហស្តស្តាំផ្ងារ លើព្រះហស្តឆ្វេង តម្រួតលើព្រះកែ្នង ហៅថា វិតកមុទ្រា ។

២- ព្រះពុទ្ធរូបមារវិជ័យ (តាលផ្ចាញ់មារ) គង់ពត់ព្រះកែ្នងដូច ព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះហស្តស្តាំផ្ចាប់លើព្រះធរុ (ភ្លៅ) បង្អុលចុះ ទៅផែនដី, ព្រះហស្តឆ្វេងផ្ងារដាក់លើព្រះធរុ ហៅថា ភូមិស្បសមុទ្រា ។ ព្រះពុទ្ធរូបបែបនេះ តាលបើគេគួរនៅដញ្ជាំងវិហារ ឬលើផ្ទាំងសំពត់ ឃើញសុទ្ធតែមានរូបពួកតលមារពាសដែរ តាន់អាវុធរាល់ដៃ ។

(មានត)

លោក រ៉ាយ-ប៊ុក រៀបរៀង

(តមក)

សួរ-. ប៉ុះមានសាសនាខ្លះ គេថាព្រះអាទិទេពឲ្យបុណ្យឲ្យបាប នោះតើយ៉ាងណា ? ។

ឆ្លើយ-. ព្រះអាទិទេពឲ្យបុណ្យឲ្យបាបនោះ ជាការមិនពិតទេ ព្រោះថា ព្រះអាទិទេព ជាមហាបុរស ឬ អរិយបុគ្គលទៅហើយ បើទៅតាឬអសុរកាយដែលមានចិត្តខឹង ទោមនស្ស,ប្រទូស្តរ៉ាយនេះមានមែន,ឬទៅតាជួយគេឲ្យបានសេចក្តីសុខ ។ តែទៅតាណាដែលធ្វើមនុស្សឲ្យបានទទួលទុក្ខទោសភ័យ,ទុក្ខទោសតាំងនេះនឹងភ្លាត់ទៅលើទៅតានោះវិញមិនខាន។

សួរ- មនុស្សណាប្រព្រឹត្តបុណ្យ រំលត់ទៅសោយសម្បត្តិមនុស្ស-លោក , សម្បត្តិសួគ៌,សម្បត្តិព្រហ្ម មនុស្សណាប្រពឹត្តបាបរំលត់ទៅសោយទុក្ខកន្លងអបាយភូមិបួន ។ តើប្រព្រឹត្តយ៉ាងណាកុំឲ្យសោយផលនោះបានព្រោះថា បុណ្យ,បាបជាហេតុគាំងសោយផល ? ។

ឆ្លើយ- ពាក្យនេះប្រហែលជាចង់ថា មនុស្សកុំឲ្យប្រព្រឹត្តបុណ្យឬបាប,បានឬទេ ? មិនបានទេ ព្រោះមនុស្សមានចិត្ត,អាយតនៈចំហឲ្យបុណ្យ បាប ចេញ ចូលតាមចិត្ត គឺថាបើភ្នែកឃើញរូបហើយ

ចិត្តកើតឆម្មុសង្វែត, ចិត្តនោះជាបុណ្យ, បើភ្នែកឃើញរូប ចិត្តនោះកើតតាមនស្ស, ចង់អាឃាដញ្ជាបាទ ចិត្តនោះជាបាប បើភ្នែកនោះឃើញរូបហើយចិត្តនោះយល់ថា រូបនេះស្អាតល្អគួរត្រេកត្រអាល ស្រឡាញ់ស្នេហាដោយកាមគុណ ចិត្តនោះគឺបាប ។ មានដួងគាល បុណ្យ បាប ចេញចូលទៅក្នុងចិត្ត(មនោទ្វារវដ្ដនៈ)ហើយចិត្តមិនបានដឹងក៏មាន។ ព្រោះហេតុដូច្នេះ ត្រូវប្រព្រឹត្តបុណ្យគឺ ទាន សីល ភាវនា ឬសីលសមាធិបញ្ញា,លុះដល់ប្រាជ្ញា កើតមានឡើង ពិចារណាសង្ខារធម៌ជាអនិច្ចំ, ទុក្ខំ, អនត្តា, លះទង្វើបានផុតជ្រះស្រឡះ ចិត្តក៏ឈានកាន់ឈានសម្រេចមគ្គផល។ លុះត្រាតែចិត្តនោះទៅដល់លោកុត្តរៈផុតពីហេតុ គ្មានផល,ផុតពីគ្រឿងវិល ពីកង់លោក,កង់បក្រាំឡ,កង់លោភធាតុ,ផុតពីកម្ម, ផុតពីបុណ្យ បាប ចិត្តនោះគឺស្ថិតនៅពីលើកង់មានអានុភាពជាងគេ ប្រៀបដូចជាមនុស្សម្នាក់អង្គុយលើស្ពាន មានទឹកហូរត្រោមស្ពាន ទឹកហូរមិនអាចធ្វើឲ្យមនុស្សនោះរសាត់ទៅតាមកំឡាំងទឹកហូរដោយអំណាចខ្លួននោះបានឡើយ ។ ម្យ៉ាងវិញទៀត, ចិត្តរបស់បុគ្គលដែលបានដល់អរហត្តផលញាណ ដែលស្អាតបរិសុទ្ធ,ផូរផង់ តែងបានឯកន្តបរមសុខគឺសុខមិនមែនលាយឡំដោយទុក្ខផងឡើយ សុខលែងវិលកើតស្លាប់ សុខលែងមានជាតិជរា,ព្យាធិ ។

ការដែលមិនប្រព្រឹត្តបុណ្យ,បាប ដើម្បីចៀសវាងនូវកុំឲ្យមានផលបុណ្យ, ផលបាបនោះទៀត ព្រោះធម្មតាមនុស្សតាំងខ្លាយ តែងប្រព្រឹត្តបុណ្យឬបាបក្នុង១វិនាទី ។ ព្រះនិព្វានមិនមែនបានដោយការមិនប្រព្រឹត្តបុណ្យនោះទេ គឺបានមកដោយការពិចារណាឲ្យឃើញតាំងច្រាំ ដោយវិបស្សនាញាណ១០ ឧបមាដូចជាតិដូនកុំដែលគេយកទៅបម្រាញ ប្រចាប់ឲ្យចេញប្រៃ ការដូនោះយកទៅដាំយ៉ាងណា ក៏មិនដុះជាដើមដូនទៀតបាន ។

. សួរ- បុណ្យនឹងបាបដែលសត្វធ្វើរួចហើយស្ថិតនៅត្រង់ណា ? ។

ឆ្លើយ- បុណ្យបាបដែលសត្វធ្វើរួចហើយតែងស្ថិតនៅជាប់ចំពោះខ្លួនសត្វអ្នកធ្វើ ប្រៀបដូចស្រមោលតែងប្រព្រឹត្តប្រកិតទៅតាមរូបដូច្នោះឯង ។

សួរ គួរឲ្យសង្ស័យបើបុណ្យនឹងបាបជាប់ជាមួយនឹងខ្លួនសត្វ តើបុណ្យបិតនៅត្រង់ទីណា, បាបបិតនៅត្រង់ទីណា ? ។

ឆ្លើយ - បុណ្យនឹងបាបស្ថិតនៅជាមួយនឹងខ្លួនសត្វនេះ បុគ្គលមិនអាចនឹងចង្អុលបង្ហាញថា ស្ថិតនៅត្រង់ទីនេះ ទីនោះបានទេ ប្រៀបដូចរុក្ខជាតិតាំងពួង ដែលមិនទាន់មានផ្លែក្តីបចេញមកខាងក្រៅ គេមិនអាចចង្អុលបង្ហាញប្រាប់គ្នាថា ផ្លែឈើតាំងនោះបិតនៅត្រង់ទីនេះទីនោះបានឡើយ, ឯផ្លែបុណ្យនឹងបាបក៏ដូច្នោះដែរ ។

សួរ -. លោកដែលមានបុណ្យធំ ដូចព្រះពោធិសត្វ មហាកុសល
អ្វី ដែលនាំលោកឲ្យបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ? ។

ឆ្លើយ - ព្រះសម្មាសម្ពុទ្ធទ្រង់បដិសន្ធិជាត្រីយហេតុទុក្ខិដ្ឋ ឲ្យបាន
ត្រីយហេតុដោយប្រាជ្ញា ឲ្យបានទុក្ខិដ្ឋដោយធ្វើការកុសល ដោយសោម-
នស្ស. ឯត្រីយហេតុប្រកបដោយហេតុ៣គឺ អលោភៈ អទោសៈអមោហៈ។
អលោភៈ ត្រូវបានកោគសម្បត្តិ អទោសៈត្រូវបានរូបសម្បត្តិ អមោហៈ
ត្រូវបានបញ្ញាសម្បត្តិ ។

សួរ-. ចុះអ្នកដែលប្រព្រឹត្តកុសល ជាទុហេតុទុក្ខិដ្ឋនោះយ៉ាង
ណាទៅវិញ ? ។

ឆ្លើយ - អ្នកដែលប្រព្រឹត្តកុសល ជាទុហេតុទុក្ខិដ្ឋនោះគឺសោម
នស្សសហគតញាណវិប្បយុត្តអសង្ខារិក , សង្ខារិក , កុសលចិត្តប្រកប
ដោយសោមនស្សវេទនា តែប្រាសចាកប្រាជ្ញាធំមិនប្រកបដោយសង្ខារ
ឬប្រកបដោយសង្ខារ ។

ទុហេតុប្រកបដោយហេតុពីរគឺ អលោភៈ អទោសៈ ហើយញ៉ាំង
វិបាក ១២ គឺមហាវិបាក ៨ កុសលវិបាកអហេតុកៈ ៨ ឲ្យកើតឡើងដោយ
សារខ្លួន ។

សួរ-. ចុះអ្នកដែលប្រព្រឹត្តកុសល ជាត្រីយហេតុទុមកៈនោះ

យ៉ាងណាទៅ ? ។

ឆ្លើយ - អ្នកដែលប្រព្រឹត្តកុសលជាត្រយៈហេតុទុមកៈគឺប្រព្រឹត្តកុសលជាទុវេគ្គា , ព្រោះហេតុដូច្នេះ សម្បត្តិពាំងឮៗដែលបានមកតែយ៉ាងតណ្ហាល ។ ។

សួរ - ចុះអ្នកដែលប្រព្រឹត្តកុសលជាទុហេតុទុមក: យ៉ាងណាទៅ ? ។

ឆ្លើយ - អ្នកដែលប្រព្រឹត្តកុសលជាទុហេតុទុមកៈ គឺទុហេតុប្រកបដោយហេតុពីរគឺ អលោភៈ អទោសៈ ទុមកៈ បានសម្បត្តិជាយ៉ាងតណ្ហាល ។ ។

សួរ - តាមវចកុសល បើញែកមួយបែបទៀតតើយ៉ាងណា? ។

ឆ្លើយ - តាមវចកុសលញែកជាបុញ្ញកិរិយាវត្ថុ១០យ៉ាងគឺ

១- ទានៈ ការឲ្យទាន ,

២ សីលៈ ការរក្សាសីល,

៣- ភាវនា ការចំរើនភាវនា,

៤- អបចាយនៈ ការគោរពគោតក្រែងដល់ចាស់ព្រឹទ្ធាចារ្យ

៥- វេយ្យាវច្ចៈ ការខ្វល់ខ្វាយចាត់ចែងក្នុងកិច្ចបុណ្យ ,

៦- បត្តិទានៈ ការឲ្យទូរចំណែកបុណ្យ,

๗- បត្តានុមោទនា ការត្រេកអរក្នុងចំណែកបុណ្យដែលគេ
ឧទ្ទិសឲ្យមក,

๘- ទេសនា ការសំដែងធម៌ឲ្យអ្នកដទៃស្តាប់,

๙- ធម្មស្សវនៈ, ការស្តាប់ធម៌,

๑๐- ទិដ្ឋុជុកម្ម ការធ្វើទូវិដ្ឋិឲ្យត្រង់ ។

បុញ្ញកិរិយាវត្ថុ๑๐យ៉ាង បើអ្នកប្រព្រឹត្តតាម នឹងបានផលល្អមិនខាន ។

សួរ- ចុះយ៉ាងណាដែលហៅថារូបាវចរកុសល ? ។

ឆ្លើយ- ដែលហៅថារូបាវចរកុសល គឺកុសលដែលកើតឡើងចំពោះព្រះយោគាវចរ ដែលបានធ្វើសមាធិកម្មដ្ឋានបានចំរើនឈានតាំងពីបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន ។

๑- បឋមជ្ឈាន

បឋមជ្ឈាន យ៉ាងទន់(បរិត្ត) ទៅបដិសន្ធិនៅស្ថានព្រហ្មបារិសជ្ជា,

បឋមជ្ឈាន យ៉ាងកណ្តាលទៅបដិសន្ធិនៅស្ថានព្រហ្មបុរោហិតា,

បឋមជ្ឈាន ជាខ្ពស់ (ប្រណីត) ទៅបដិសន្ធិនៅមហាព្រហ្ម ។

๒- ទុតិយជ្ឈាន ឬតតិយជ្ឈាន.

ទុតិយជ្ឈាន ឬតតិយជ្ឈាន (ជាបរិត្ត) ទៅបដិសន្ធិនៅបរិត្តាភា,

ទុតិយជ្ឈានឬតតិយជ្ឈាន ជាមជ្ឈិមទៅបដិសន្ធិនៅអប្បមាណាភា,

ទុតិយជ្ឈាន ឬតតិយជ្ឈានជាទុក្កិដ្ឋ ទៅបដិសន្ធិនៅអាភស្សរ ។

๓- ចតុត្ថជ្ឈាន

ចតុត្ថជ្ឈាន(ជាបរិត្ត)ទៅបដិសន្ធិនៅបរិត្តសុភា, ចតុត្ថជ្ឈានជាមជ្ឈិម ទៅបដិសន្ធិនៅអប្បមាណសុភា , ចតុត្ថជ្ឈានជាបណីត ទៅបដិសន្ធិនៅសុភកិណ្ហ ។

๔- បញ្ចមជ្ឈាន

បញ្ចមជ្ឈាន មានចិត្តមិនខ្សោយណាយ ទៅបដិសន្ធិនៅវេហប្ផលា បញ្ចមជ្ឈាន មានចិត្តខ្សោយណាយ ទៅបដិសន្ធិនៅអសញ្ញីសត្តា ព្រហ្ម ,

បញ្ចមជ្ឈាន នៃពួកព្រះអនាគាមីបុគ្គលទៅបដិសន្ធិ ទៅបញ្ចសុទ្ធាវាស ។

ដែលឲ្យដឹងថា បដិសន្ធិគឺចំពោះបុគ្គលណា ដែលធ្វើឈានហើយទទួលមរណកាល ក្នុងពេលនោះ គឺស្លាប់ពីពេលនោះ ទៅកើតជារូបព្រហ្ម តាមថ្នាក់ឈានដែលខ្លួនបាន ។

សួរ-. ចុះអរូបាវចរកុសលតើយ៉ាងណាទៅ ? ។

ឆ្លើយ-. អរូបាវចរកុសល បានដល់ព្រះយោគាវចរ ដែលបានចម្រើនសមាធិកម្មដ្ឋានបានដល់អរូបជ្ឈាន មានអាកាសានញ្ចាយតនៈ

វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ នេវសញ្ញានាសញ្ញាយតនៈ ។

សួរ-. ខ្ញុំបានឮលោកអាចារ្យតំណាលថា ទេវតាឬព្រហ្ម ឥតមានធ្វើការអ្វីឡើយ ចេះតែសប្បាយរីករាយ ទៅលេងសួនច្បារ បេះផ្កា មានអាហារកំដរ សម្លសក្រកំដរ គ្រឿងស្រែកពាក់កំដរ តើចង់បានអ្វីបាន ដូចសេចក្តីប្រាថ្នា មែនឬទេ ? ។

ឆ្លើយ-. មែនពិត ព្រោះថា ស្ថានមនុស្សលោកជាកតកតសាង គតធ្វើបុណ្យជាបច្ចយហេតុ , ស្ថានឆកាមាវចរសួគ៌ , ស្ថានព្រហ្ម ជាកតសោយផលបុណ្យ, ស្ថានអបាយភូមិបួនគឺស្ថាន នរក - តិរច្ឆាន- អសុរកាយ-តិរច្ឆាន; ជាស្ថានសោយផលបាប ។ ឯឆកាមាវចរសួគ៌គ្មានពេលធ្វើបុណ្យ ទាន មានតែសប្បាយដោយអាម៉ិសផ្សែង ព្រោះថា មនុស្សដែលបានធ្វើទានរក្សាសីល ដល់ច្យុតពីមនុស្សជាតិទៅកើត ឯទេវលោក គឺប្រាសាទប្រាក់មាសផុសអណ្តែតមកតែម្តង៍ មានស្រីស្អាតក្រមការអាមាត្យ ។ល្អានមានបុប្ផា នៅខាងមុខវិមាន មានផ្កាកល្បព្រឹក្សជុះប្រចាំ ។ ដល់ទេវតាអស់បុណ្យគឺផ្កាកល្បព្រឹក្សប្រចាំអាយុនៃទេវតានោះស្រពោន ហើយទេវតានោះ មានរូបធ្លុំក្លិនជាលក្ខណៈ,សំគាល់ថា

(មានត)

ផ្នែកអក្សរសាស្ត្រ

រឿងនេវន្ត (ពាក្យកាព្យ)

លោក អម្ពតក្សត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះជាទេសម្តេចព្រះនរោត្តម

លោក ញ៉ុក-ថែម ពិនិត្យ (តមក)

តំណើរតំណែន តំណាថ្ងៃថ្ងៃ ពាក្យព្រោលជាប់ដល់ ជាប់ដួនហៅ
ខ្សែ ក្រុំប្រែដោយតល់ ដោយគិតយល់យល់ ខ្វែងខើបពណិនា ។ កាល
អង្គព្រះពន្ធ្យ ព្រះពោធិវង្ស វរៈទត្តលា ស្តេចនាំព្រះបួន ខ្ចឹមខ្ចួនថ្ងៃថ្ងា
ឆ្ពោះទៅមហា នគរស្តែងស្តេច ។ នេះនិងថ្ងៃឆត ថ្ងៃឆទៅអស្សត្ថរ នា-
នាំសម្តេច វរាជក្សត្រី ព្រះស្រីសារពេជ្ជ ពោធិស្តែងស្តេច ដោយផ្លូវរៃ
ហាស៍ ។ ពីយប់លុះលង់ ខ្វៀបទៅថ្ងៃត្រង់ ស្តេចគិតគុណា ព្រះបួន-
តស្សាណ ត្រែងឃ្វានអាហារ ស្តេចឲ្យអស្សពាហ៍ ចុះឈប់ក្នុងព្រៃ ។ ព្រះ
ព្រឹក្សាសន្ត សាន្តសាយយោនយាន យានយលឈឹងឈៃ ឈឹងឈរ
ស្រោងស្រស់ ល្អល្អះប្រៃពៃ លូតលាស់រៃគរៃ ទន្ទោនទងពោរ ។ ផ្ទៃផ្កាទង
ពា ដោយពួកដោយពារ ស្មកុណីសកុណា អនេកប្រើនក្តាត់ ឆ្លៀលឆ្លាត់
តាសោ ឮលាន់ពោរពេ្ធ ចឹកចាប់ផលា ។ ឥតមានរង្គោះ រង្គះរលោះ
ដល់ដើមដួយណា មើលមានពាំងស្រះ ជ្រៅជ្រះឥង្ហា កុត្រីកុត្រា ស្រង់

ស្រេចក្សេមក្រៃ ។ ពីរក៏ត្រូប្រសើរ តង់ត្រោមមូបឈើ សោយស្រេច
ក៏ត្រៃថ្ងៃ នាំនាងវរវង្ស ឡើងគង់មនោម័យ ហ៊ាចហោះច្រៀវច្រៃ តុំរង់វេ-
ក ។ រសៀលសុរិយន់ សុរិយាតបទន់ តាបទៅបច្ចិមា ហេតុតែដោយ
ល្បឿន សេះលឿនមហិមា ដល់ដែនក្រុងពា-ពណាសីនគរ ។ ស្តេចឈ្មៀង
នេត្រៃថ្ងៃ យង់យល់ដើមព្រៃ មួយមានមានត្រួយត្រ-សុំសាយសន្ធឹក អ-
ងឹកស្រស់ស្រៃ ឡះលះសំគរប្រ-ស្រ័យស្រប់សម្រាន្ត ។ មានស្រះមួយ
ដែត ព្រះចាទបពិត្រ ត្រាស់តាន់អស្សយោន ស្រះនោះថ្លាល្អ ចូរចរឈប់
ខាន ង្ហូតទឹកកំសាន្ត បន្តិចសឹមទៅ ។ សេះហោះចុះដល់ ស្រះស្រែង់
មណ្ឌល ស្តេចនាំប្អូនទៅ ចរចុះស្រែង់ស្រះ ដម្រះហ៊ុងសៅ ជន្លោះត្តីក្តៅ
ត្រសាលសុខសាន្ត ។ ស្តេចដកកុដ ឈូកឲ្យប្អូនទៅ សោយសម្រាក
ឃ្លាន បេះផ្លែឈូកឲ្យ នាងសោយក៏ត្រេកក្សាន្ត សោតសោយកំសាន្ត ទឹង
ព្រះអនុជា ។ ស្តេចផ្ទាស់ពស្ត្រទ្រង់ លីលាឡើងគង់ ត្រោមជ្រៃសាខា
សំណាលសំណេះ ត្រេកត្រៃះចរចា លេងលលេញជា- មួយព្រះប្អូនស្រី ។
ហេតុត្រៀវវេក វរវាជធីតា ទឹងព្រះចក្រី នាងនឹងនៅត្រាំ រងកម្មក្សត្រី
មានមកអំពី បុរាណអតីតា ។ បណ្តាលព្រះទ័យ ព្រះមហាក៏ត្រៃថ្ងៃ ឲ្យ
ទ្រង់គិតថា បើនាំប្អូនទៅ ចូលទៅនគរ តែពីរអង្គា យល់ពុំគួរសម ។
ហាក់អ្នកតាបតូច មិនមែនពន្ធ្យាជ ក៏ត្រេកក្សាន្តទុក្ខម គួរពុកមាសមេ នៅ

ឮដែរធំ អញទៅនាំស្តេ ន្ទូវពលសេនី ។ ន្ទូវយានមាសមក ទទួលនាង
យក ទៅគាន់បូរី គន់គិតស្រាប់ស្រេច សម្តេចចក្រី ប្រាប់ព្រះមហេសី
ន្ទូវអគ្គអស្សពោហ៍ ។ សោតសឹងបួលចិត្ត ដួចព្រះគំនិត ព្រះមហាក្សត្រា
ស្រេចក្សត្រទ្រង់តបៈ លើកព្រះហស្តទក្ខា ឲ្យគង់ទៅនា ដើមព្រះដែរធំ ។
ហើយស្តេចទ្រង់ផ្សង អស់ទេព្តាផង បពិត្រអញខ្ញុំ សូមពឹងបុណ្យផ្តើ
នាងលើអស់អ- ម្ចាស់ចូរជួយខ្ញុំ រងើបប់ក្សា ។ ស្រេចគង់សេះហោះ
រំពេចផ្តេកផ្លោះ ដល់ដួចចិន្តា ចូលថ្វាយអគ្គមហេ ទៀបបាទមាតា នាង
នាដប្រាំ ទុបពាដបុត្រនៃថ្ងៃ ។ ក្សត្រីប្រសើរ សួរសេពួដំណើរ ខ្លុតសោក
ពេតភ័យ ពងុត្តុខ្លួរ ទៀនទូលដោយន័យ ដំណើរដៀស្ដីយ ស្តេចបាន
ពនិតា ។ ឥឡូវខ្ញុំដាក់ ឲ្យនាងសំណាក់ នាក្រៀតាព បើបិតអាស្រ័យ
លើដែរសាខា តែអគ្គឯតា ចាំអគ្គអញខ្ញុំ ។ មកបៀបយោធា ន្ទូវស្តេចស្នេហា
អតទៅចាស់ខុំ ចេញទៅទទួល ចរចូលរដ្ឋរម្យ ថ្វាត់ថ្វាយបង្គំ ព្រះវរ-
មាតា ។ នាងស្តាប់បុត្រតន់ ទ្រង់ត្រេកពេកពន់ ឥតអ្វីឧបមា បន្ទូលបង្គាប់
ចូរធាប់ស្ងួនភ្ងា អាសូរធីតា សមភ្ញាចម្ងាក់ឯង ។

ពោធីធិបតី ប្រាប់ប្រើមន្ត្រី ឲ្យរៀបចាត់ចែង ចតុរង្គយោធា សេនា-
សឹងតែង គ្រឿងគ្រប់ក្រោះក្រែង សត្រូវលាយឡំ ។ ខ្លះរៀបពាដយាន
ប្រដាប់មាសមាន កូនឯកូសអតិរម្យ រៀបតូរឫតន្ត្រី រៀបស្រីព្រះស្នំ សាវឡើត

ចាស់ខ្ញុំ សឹងស្លាប់អង្គា ។ ចាត់ចែងរៀបចំ តាំងពីបឋម - យាមលុះ
ហួសអ- ធ្រាត្រទើបស្រេចស្រាប់ សម្តេចក្សត្រា ឡើងគង់អស្សពាហ៍
នានាំចេញទៅ ។

នេះនឹងពំណាំនា ឯវរធីតា កាលគ្រោយចមទៅ កាលណោះមាន
យក្ខ ស្រីម្នាក់យោះយៅ ពេលក់លក្តាត់ក្តៅ ដោយតាមពគា ។ ត្រាច់
ដើរតប្តី ពុំចុះដួចក្តី បំណងច្រាច្ចា ចរចូលអាស្រ័យ ត្រោមដៃសាខា
យក្ខឈ្មោះនេត្រា យល់រាក្សត្រី ។ នាងយក្ខសួរថា នាងមកពីណា
នាងនាមឈ្មោះអ្វី តែឯកអង្គច្រណា មិនមានស្វាមី ហេតុម្តេចនាងស្រី មក
នៅឯកា ។ ក្សត្រីស្តែងស្តាប់ ហើយថ្លែងច្រាយច្រាប់ ដោយដំណើរថា
ខ្ញុំជារាជបុត្រ មហាក្សត្រីថ្លូវ ទ្រង់ព្រះនាមា ហៅយសវតី ។ ព្រះវរ
មាតា នាមបទុមា ប្រសើរសល់ស្រី ស្រុកឈ្មោះគោសេយ្យ ពិដ័យបូរី
ខ្ញុំជាបុត្រី ឈ្មោះសុវណ្ណគេសរ ។ រីព្រះស្វាមី ទ្រើសទ្រង់ចារមី លើស
លោកាគរ នាមព្រះទេវទ្ត សោភ័ណថវរ ស្តេចគ្រងនគរ ពារាណសី ។
ស្តេចទៅនាំយក អង្គអញខ្ញុំមក ជាអគ្គមហេសី ស្នែងស្តេចខុកខ្ញុំ ឲ្យចាំ
នរបតី ស្តេចទៅបូរី រៀបពាជយោធា ។ ហើយស្តេចវង្វែល ចេញមកទទួល
ខ្ញុំទៅតាវ យក្សស្រីបានស្តាប់ នាងច្រាប់អស់អាថ ហេតុចិត្តប្តូរស្បា
ត្រេកអរពេកពាយ ។ អញនឹងសម្លាប់ ពាន់នេះឲ្យស្លាប់ យកគ្រឿងពាងង្ហាយ

ចានហើយប្រជាប់ សម្រាប់អង្គកាយ អង្គាអញក្លាយឲ្យចានសុទ្ធសាធ ។ អង្គអញចានទៅ រួមសេនិត្យទៅ នឹងអង្គព្រះបាទ ទេវន្តទ្រង់យស់ លុះអស់ជន្មជាតិ ជាឫដ្ឋនាងនាង នារីស្រែង្គា ។ គិតស្រេចតន្ត្រាត់ នៃនាងនាងធ្លាត់ ដល់ដែនពសុធា យក្សយោរដំបង សំពងដេរថា ហៃមេមោ-ហា តាចតាឡតិណា ។ ចិត្តចោរមុខរឹង ម៉ែចមឹងមិនដឹង អញជាមហេសីនាងចំលើតតរ អង្វរយក្ខស្រី សូមអ្នកប្រណី អាចអត់ទោសពៃ ។ ខ្ញុំនឹងនៅជា ខ្ញុំត្រាមបាទា នៃអម្ចាស់ថ្លៃ ដោយខ្លួនសុភាព ដរាបខ្ញុំក្រៃ សូមអ្នកអភ័យ ខុតជាខ្ញុំស្រី ។ រឹងរាយរឹងឆាក់ នាងនាងត្រូបំលឹកួណ៍ វរៈកងក្សត្រី នាងសន្ធប់លង់ ចាត់បងំស្មារតី យក្សស្មោនក្សត្រី កំណែកួយមរណា ។ និម្មិតឥន្ទ្រិយ សុទ្ធសាធទេវី យកគ្រឿងពស្ត្រា នៃនាងវរលឹកួណ៍ មកពាក់អាត្មា អូសសពធីតា ចោលក្នុងស្នូងជ្រៅ ។ ទេព្តាថ្នមថ្នាត់ ដាក់លើសំណាត់ រក្សាស្រីកៅ ជាសុខក្សេមក្សាន្ត មិនមានហ៊ុងសៅ បណ្តែតនាំទៅ ម្ចាស់ខ្ញុំ ។ ឲ្យនាងកល្យាណ ជាប់នឹងទៅស្ពានយាយចាស់តាចាស់ រកដធីតា ជ្រាបស្មារតីចប់ ហេតុទ្រង់ឈឺណាស់ លានព្រះនេស្តថ្ងូរ ។

យាយតាតើតក្តៅ នាំគ្នាចុះទៅ ឆ្លូតទឹកឈូរ។ យាយឆ្លូតទឹកស្តាប់ ឮស័ព្ទសៀងស្ងូរ នារីតេថ្ងូរ កិតក៏យផ្លើលភ្នាក់ ។ តាថាដកទង ខ្មោច

អ្នកលង មិនមើលឱ្យដាក់ យាយធ្វើយវិនិច្ឆ័យ សត្វអ្នកដំពាក់ នៅត្រាមគួច
អ្នក ចង្រ្កានថ្ងៃនៅ ។ តាបែរមើលយល់ ហើយកិតក័យសល់ ស្ទុះរត់
ឡើងនៅ ញ៉ែរដើងញ៉ែរដៃ ក្សត្រីចមនៅ បន្ទូលហាហៅ តាន់ដូនតាថា ។

ឧអ្នកតាយាយ អញ្ជើញមកអាយ អាសូរចៅក៏ ចៅជាមនុស្សពិត
កុំកិតកយា ចូរត្រាសមេត្តា ស្រង់យកចៅផង ។

យាយតាស្តែងស្តាប់ ព្រះសូរសោរសព្ទ៍ នាងនាថស្នេហ៍ស្នង ដឿជា-
មនុស្ស ករុណាកន្ធង យាយទៅត្រកង ប័ជាក់លើក្តៅ ។ យល់នាងវែ-
វង្ស ឥតព្រះភាស្តង្រ្គង់ ទើបយាយចៅរ៉ៅ ឱ្យចិនអាម្នាញ បណ្តេញតាទៅ
មិនឱ្យតាទៅ យង់យល់ធីតា ។ យកសៀវភៅ សម្លៀកស្រេចពរ យក
មកគ្រែហារ កេទសរកក្តើង ដុតឡើងម៉ីម្ចា បណ្តេញឱ្យតា ទៅជាំទឹកក្តៅ។
បបោសលាបថ្នាំ ស្នាមដែលជាំជាំ គ្រាន់បានស្រួកទៅ បបរដណ្តាំ ស្រេច
នាំចៅរ៉ៅ ក្រាត់ថ្នាយស្រីពៅ ឱ្យបរិភោគ្តា ។ យាយតាសួរសព្ទ ដំណើរ
គ្រាន់គ្រប់ រីនាងថ្លែងថា ដំណើរវៀបភប់ ប្រាប់ប្រាប់យាយតា វែង
មានករុណា មួយសារពោកព្រៃ ។

នេះយើងនៅនាំ ដំណើរបុត្តកម្ម នាងនាដថ្លាថ្លៃ តាលកម្មពីព្រេង
អង្វែងឆ្ងាយព្រៃ. ពោធីដៀស្ងួតដាយ យោនយកជាតិជា ។ ជដិលសេដ្ឋី
រីរាជក្សត្រី ជាតិជាកំណើ សេដ្ឋីស័ក្តិសម ពិតពុំឃ្លាតឃ្លា ឈ្មោះអមិត្តា

កុមារីវត្ត ។ សេដ្ឋីនោះនៅ លង់ចន្លិចទៅ គិតយល់កពាំដួ សង្ឃាវែតធ
ល្មៀង ពុំខ្វៀងពុំចាត់ សេដ្ឋីគិតតាត់ ចិត្តចោលធានធន់ ។ លះទីហាន
ល្អ លះខ្ញុំកំដរ លាកលាប្រពន្ធ ទៅនៅអាស្រ័យ នាព្រៃហោមន្តែ សេដ្ឋី
សាន់ចណ្តា. សាលាអាស្រ័យ ។ ផ្ទាស់អស់ពាពស្ត្រ បួសជាតាបស
រក្សាសីលថ្លៃ ចំរើនភាវនា ជាអាចិន្ត្រៃយ្យ តែស្រុកទឹនព្រៃ នោះនៅខៀប
គ្នា ។ រីឯប្រពន្ធ តែនធ្វើកោជន ខ្លួនឯងសព្វគ្រា ពុំបានប្រើខ្ញុំ តូចធំឯ
ណា ទៅធ្វើអាហារ ថ្វាត់ថ្វាយឥសី ។ ធ្វើស្រេចទូលទៅ ថ្វាយឥសីទៅ
នាព្រៃប្រក្រតី ទឹកឆាន់ទឹកស្រង់ នាន់ផ្គង់ឥសី ពោះទឹកក្តៅក្តី នាន់បំរើ
សព្វ ។ ល្ងាចរៀលំនៅ ព្រឹកឡើងវិលទៅ ទូលបង្គំន់គ្រប់ ទូវអស់
ចំណី ថ្វាយឥសីសព្វ រៀលៈគោរព គ្រប់ធម្មា ។ តិចទៅឡើងជាក
មានតិន្ទុម្នាក់ ក៏រូបសោភា សុភាពសោភ័ ទិព្វទីនៅនា តែលាសបព្វ-
តា ហោះមកលេងព្រៃ ។ យល់ហានព្រហ្ម ឥសីសីលា ត្រុះត្រែកពេក
ព្រៃ ចរចូលក័ក្តី ព្រះឥសីសេយ្យ ស្មានស្មោះទ្រាស្រ័យ សួរសន្ទនា ។

នេះនឹងស្រដី អមិត្តាកុមារី ទូលកោដនា ទៅយល់តិន្ទុ័ នឹងឥសី
លា ពីរពន្យរចា ទៅវិញទៅមក ។ ខេរទឹងញ៉ាមាត់ ជាក់កាដន់ចេញ
ថ្វាត់ ម្ដីម្នាចាប់យក ប៉ាន់ព័ត៌ផ្ដៅ សួរទៅជាក់ស្តែក កន្ត្រាក់ធ្លាក់មក រាត់
រាយឈ្មួចឈ្មី ។ ឥសីសោតយាត់ នាន់នារីវត្ត រើនឹងសែនខ្ញុំ រន្ធត់

ញ៉ាគាយ ស្ទើរវាយព្រះមុនី ព្រះភ្នំចនារី រួសរាំងភ្នំរដិត ។

រីនាងកិន្នរី បម្រះរួចខ្លឹ ហោះទៅឋានឋិត ឈឺអង្គុំក្រៃក្រំ ដំណាំ ពេកក្តាត់ ឈឺគាយឈឺចិត្ត ធុរេធ្យៃបង្ខាំងក្រៃ ។ រីនាងអមិក្តា ខេរំងដៀល ថា ព្រះឥសីសេយ្យ ទុអញមិនគិត នឿយហត់ហាលថ្ងៃ ស្មានជាព្រះ ទ័យ ឥសីស្លូតត្រង់ ។ ថាលាអញថា យល់ទោសតណ្ហា រាំងផ្លូច ផ្លូង នៃអង្គអាត្មា នៅនារដ្ឋស-ង្ឃារសូន្យចំណង់ បំណងច្រាថ្នា ។ មិនដឹង មកបែរ មកបួសចង់តែ ស្រីដោយព្រឹក្សា ទុអង្គអញអើយ នឿយព្រួយ អាសា អសោចិត្តគារ ឥតកិច្ចសូន្យសោះ ។

ឥសីលោមថា ហៃនាងសិតា កុំថាដូច្នោះ ចិត្តអញសុចរិត ពិត ។ ស្មោះ ។ រីកិន្នរនោះ សោតស្មោះត្រង់ខេ ។ ចួនហោះមកយល់ អស្រមមណ្ឌល ដូចឯងដូចគេ យង់យល់ព្រះមុនី យល់ដីយល់ថែរ យល់ព្រះសាមណេរ សឹងចង់បានបុណ្យ ។ ចរចូលឈរឈប់ ក្រញ្ជ្រាបគោ. រព ប្រណីប័តន៍សួរសុ ន្ទនាស្មោះស្មូន ត្រែងមានអាក់អ-ន្ធពាយមានម. ន្ទិលទោសពុំជា ។ ឥឡូវនាងអើយ រាយគ្នារួចហើយ ទឹងទំលាល់ណា បើពាក្យអញច្រាប់ ពុំស្តាប់រាល់ ពុំដឿចន្លា ពុំចេះនុនអត់ ។ នោះ ហើយឯណា ទឹងបានហៅជា ស្ត្រីកបវត្ត ប្រណីប័តន៍ស្វាមី ដូចស្រីអ. ស័ត្យ ចរចើនរំងមាត់ ចរចេសពាក្យធំ ។

នាងស្តាប់ឥសី ហេតុនាងជាស្រី រត្នៃថ្ងៃទត្តម ក្រួញក្រាបដួញដង្ស
ទុនអង្គបង្គំ ព្រះឥសីសុំ ស្នាលពោសា ។ ឥសីសោតប្រាស អនុញ្ញាត
អត់ពោស ហើយនាងធីតា លើកកោដន៍ចំណី ថ្វាយឥសីលា ផាន់
អស់កោដនា ដូចគាលប្រក្រតី ។ តាំងពីនោះណា នាងមកបួសជា តា-
បសិនី ធ្វើស្រមសាលា ខាងមហាឥសី ពាល់ក្បែរដីរ៉ែ ទៅព្រៃផងគ្នា ។

ហេតុកម្មប៉ុណ្ណោះ នាងនាងធ្លាក់ចុះ ទៅឆើវែក ទៅឮនរក ទល់
ទុក្ខវេទនា ច្រើនជាន់ជាតិជា អង្វែងយូរក្រៃ ។ លុះសែសអកុសល ដោយ
តេជបុណ្យផល នាំនាងវិលវៃ មកកើតជាតិជា បុត្រមហាក្សត្រថ្ងៃ ព្រះ
ឥសីសេយ្យ គឺព្រះទៅន្ទ ។ បានជាយក្ខិនី ក៏ក៏យក្សត្រី ព្រោះកាល
ជាតិមុន នាងក៏យកិន្នរ ថ្នមរាណាជន្ទ ជាតិជាទូនន់ ទូរអាត្មា ។

នេះនឹងថ្លែងគាល ព្រះបាទកូបាល ស្តេចនាំយោធា ទូស្តីនារី
ចេញពីរង្គោ ទៅតាំងសន្ធា ទល់ស្វាងសុរ៉ៃ ។ បរិបូណ៌បានដល់ ព្រះ
ថ្លៃមណ្ឌល យង់យល់យក្ខិនី ក្លែងរូបល្អល្អះ ដូចព្រះបួនស្រី ព្រះបាទ
នរបតី ស្នងព្រះពនិតា ។ នាងាំចុះថ្កាន ឲ្យតង់លើយាន ម្ដីម្នាថ្ងៃថ្វា
អស់តាំងចាស់ពុំ ទូស្តីស្នេហា អាមាត្យយោធា សឹងចូលបង្គំ ។ ដង្ហែ
នាំទៅ ទង្គើលខ្ចើលឡៅ កុងកុះអកើរម្យ បើកបាំងកាងកាន់ សែនគ្នាន់
បន្សំ តន្ត្រីប្រគំ រងំធ្វើយគ្នា ។ លុះដល់ប្រាសាទ ព្រះបរបនរនាថ

នាំនាងលីលា ចរចូលថ្វាយគរ ព្រះវរមាតា សួរសុទ្ធនា រោះរាយស្មោះ
សរ ។ អភ័យកុមារ ទូរនាងចន្ទា សោតសឹងត្រេកអរ ចរចូលវន្ទី ពោធី
បវរ តាំងនាងយក្ខកំ ថ្វាត់ថ្វាយបង្គំ ។

លង់លុះរាត្រី ស្តេចនាំយក្ខស្រី ចរចូលបន្ទំ ផ្ទំផ្ទឹមសង្ឃឹយ កំប្រុង
ថ្ងៃទត្តម សន្ទិះរំរ- ពឹងក្តងហ៍ឲយ ។ ដរាតពុំក្រអែប ក្រអូបក្លិនក្លែប
ដូចព្រះបួនថ្ងៃ ឬស្នួនទត្តម ត្រូវកំដៅថ្ងៃ បានជាមាសមៃ ចាត់ក្លិនពិដោរ។
កំរើកកំប្រុងចមចក្រ ធីរាជទ្រង់ស័ក្តិ វរញ្ញាណទត្តមោ លើកហត្ថប្រសើរ
គង់លើកាយោ យក្ខយង់មោហោ អង្អែលទុបអង្គ ។ យល់សាច់រំងាន់
ពេកតិតពុំខន់ ដូចនាងវរវង្ស ថ្ងៃកព្រះទ័យក្តាត់ ហើយកន្ត្រាក្រទ្រង់ ពិនិត្យ
ខតក្នង នេត្រយល់ជាលដែង ។ នេត្រឥតតែវថ្ងៃ ព្រះបាទដៀស្ងួដយ
ធ្វើជាប្រលែង យក្ខហារមាត់សើច សំណើចយល់ផ្សែង ស្តេច ជ្រាបជាក់
ស្តែង ជាយក្ខសាមាន្យ ។ ញាប់ញ័ររន្ធត់ ខរះខំសង្កត់ ព្រះទ័យធ្វើ
កក្ខន្ត ខំនឹងផ្តាច់ដន្ធា យក្សាសាមាន្យ ឱ្យសស់អស់ទាហាន សេនាសេនី ។
ក្តៅក្តាត់គិតថា នេះប្រាកដជា យក្ខចាប់ប្លួនស្រី ត្រកាលថ្ងៃថ្វា ស៊ីជាចំណី
គិតស្រេចចក្រី យានបាទយាត្រា ។ ផ្ទំលើខែនទី ឯអគ្គភូមី ប្រាមអស់
ស្តីថា អញពុំសប្បាយ ក្នុងកាយពុំជា កុំឱ្យនរណា មកវិវរដិត ។ ត្រាស់
ហើយចមចក្រ ខទូរស្ងួតាត់ ខង្គិះក្តៅក្តាត់ ត្រៀមក្រំឱ្យកន្ធួល អន់អួល

គន់គិត ដល់តែវារមិត្រ ទៀនទើបរួញថា ។ ទុបួនវិស្សាល វិសេសត្រកាល ត្រកូលថ្លៃថ្លា ថ្លៃភ្ញើមបងអើយ ម្តេចឡើយឃ្លាតឃ្លា ឃ្លាតខ្លួនស្ងួនភ្ងា ពុំជឹងជានដែរ ។ នេះគឺតម្នូព្រេង តាមមកបង្ហែង ឲ្យបងបង់មេបង់មាសកល្យាណ នៅឋានទូរេ នេះពីព្រោះតែ គំនិតអញបង ។ ច្រោកជជាក់ជា យក្ខយង់មោហា ចិត្តចោរខ្ទើសយ្ងង ភ្ញាមកពិឃាដ ដន្ទុជាតិនួនល្អង ស៊ីសាច់ប្អូនបង ជាតិជាអាហារ ។ នឹងសម្លាប់យក្ខ ជួរជាតិអបល័ក្ខណ៍ ទៅតាមស្ងួនភ្ងា គិតទៅគួរខ្លាស អស់ក្រុងប្រជា គេនឹងដៀលថាបង់បញ្ឆោតគេ ។ យកយក្ខអបល័ក្ខណ៍ អប្រិយដៀនជាក់ ម៉ែរហើយមាសមេ សូវកំរ្យៃដីវិត តាមមិត្រមាសស្នេហ៍ ទុកាសូវតែ មិត្រមាសស្នេហ៍ស្ងួន ។ ជាតិជាគូព្រេង អាចលះស្ងួនស្ងែង តាមអង្គអញបង ស្ងើខ្លួនស្ងើចិត្ត តែងមិត្រមូលផង ដើរដោយគន្ធង កនៃ្សារពេជ្ជ ។ ទុបួនព្រលឹង បងបានរួមនឹង ស្ងួនសង្ឃាសោច មួយយប់មួយថ្ងៃ កម្មអ្វីមកផ្តាច់ ឲ្យឃ្លាតរំពេច ពុំបានប៉ុន្មាន ។ សម្តេចពង្សពោ ធីសត្វវោធីពជថ្កើងថ្កាន លោកគិតព្រះប្អូន ខ្វឹមខ្លួនកល្យាណ ក្នុងស្រង់ខាតខាន សេពសោយកោដនា ។

សម្តេចជននី អនុជពាំងពី ខ្លួវស្ងើស្ងេហា មាត្យមុខមន្ត្រី សេនីសេនាសោតសង្វិតតែថា ស្តេចគង់សប្បាយ ។ វេលាយប់នោះ ស្តេចសោក

លង់លុះ ឆ្នេសឆ្នេព្រះតាយ មានទេពឯកអង្គ ទ្រើសទ្រង់រំទ្វើសាយ រួប
ឆោមពណ្ណរាយ រក្សាស្មេតច្ឆត្រ ។ យល់ក្សត្រពន្ធុក ស្តេចតែងសោយ
សោក គិតព្រះបួនវត្ថុ ទេព្តាគន់គិត អាណិតមហាក្សត្រ ចរចូលទៀប
ថ្នាក់ និយាយច្រាប់ថា ។ កុំស្តេចសោយសោក ចូរស្តេចឲ្យរេក ស្រី
ចេះទេសនា នោះនឹងបានយង់ យល់អង្គពនិតា ដូចព្រះចិន្តា កុំព្រួយ
ព្រះទ័យ ។ ព្រះពង្សពុទ្ធចក្រ ស្តែងស្តេចស្តាប់ជាក់ ទ្រង់ត្រេកអរក្រៃ
ចួនជាភ្ញីព្រោង ស្រេចស្រាង១ទ័យ ព្រះមហាក្សត្រថ្លៃ ដើរទៅស្រប់ស្រង់ ។
គ្រាន់ព្រើសព្រះតក្កែ ស្រេចក្សត្រទ្រង់ល័ក្ខណ៍ ប្រសើរស្តេចទ្រង់ គ្រប់
គ្រឿងប្រដាប់ សម្រាប់ព្រះអង្គ ស្តេចចរចេញគង់ ចុងពពកពេងដ៏យ ។
អាមាត្យសេនា មន្ត្រីយោងា គង់គាល់ត្រាស់ក្រៃ អណ្តាប់ធំតូច បីដូច
សត្វថ្លៃ ព្រះមហាក្សត្រថ្លៃ បង្គាប់ច្រាប់ថា ។ ចូររៀបណ្តាប់ បទ
អញ្ជេចង់ស្តាប់ ព្រះធម៌ទេសនា ចូរគិតច្រើណប្រុង រៀបសង់សាលា ពេន
ទង្គុំទៅនា ព្រះលោនព្រះនគរ ។ ហើយចូរអ្នកប្រើ មន្ត្រីម្នាក់ដើរ ចេញទៅ
វាយស្គរ សារសព្ទ័វាចា ក្សត្រាបវរ ទ្រង់ត្រិះរិះរក ក្សត្រីទេវី ។ ស្រីក្នុ
ខ្ញាត់ទៅ ទៅនៅឋានក្រៅ ឆ្ងាយពីបូរី គិតស្រេចស្តេចច្រាប់ បង្គាប់រាំង៣
ខ្នោះចូរមន្ត្រី នាំគ្នាវៃលៅ វាយស្គរឃោសនា ឲ្យសព្វជោយនា និគម
គ្រាមក្រៅ មន្ត្រីលុតលា ក្សត្រាចមៅ ប្រើដើរចេញទៅ សព្វស្រុកនានា ។

នេះយើងឈប់ទៅ នឹងថ្វាថ្លែងទៅ រឿងដើមគា ជានរស់ដីពជន្ម
ដោយគុណយាយតា ថ្នាក់ថ្នមក្សា មិនឲ្យមានហ្មង ។ នាង តង់សោយ
សោក សែនសល់អមោក្ស តិតក្សត្រប្បាស់ប្បង់ សព្វ។ រៀល ទាំ
រែងរង ន្ទូវគុក្ខសៅហ្មង ព្រះកត្តែអ័ប្បអន់ ។ ទ្រព្រះមិត្រមាស ប្អូន
ព្រាត់ព្រាតប្រាស់ ពីក្សត្រៀសោកណា តែងតែសោកា ទាំអួលអន់ ម្តេច
ឡើយពុំគន់ ពុំតិតទ្រង់ប្អូន ។ ឬក្សត្រៀតន្ទក បញ្ជោតប្អូនមក ចោល
ឲ្យសោះសូន្យ ជានរស់ដន្ទា ដោយសារតាដូន បើកុំសំប្អូន ក្សត្រៀ
ក្សយអាសា ។ ទ្រនេះសមយក្ខ ដូរជាតិអបល័ក្ខណ៍ កាឡាជាតិជា ខ្ញុ
ប្អូនសុទ្ធសាធ ព្រះបាទក្សត្រា ស្មានជាប្អូនក្លា ឥតឯសង្ស័យ ។ នាងនោះ
ស្រីយក្ខ ចិត្តចោរអបល័ក្ខណ៍ ដូរជាតិចង្រៃ ទ្រូស្តូទ្រើសឫស្យា ក្សត់
មហាក្សត្រៀថ្ម ជានជាដៀស្តង់យ ពុំមករកប្អូន ។ ទ្រគួរកន្ទុណា មាតាបិ-
តា សមសោករកកូន ដូរតែស្តេចពុំដឹង ដំណឹងសោះសូន្យ បើស្រាបជា
កូន មកទឹងស្វាមី ។ សមក្សត្រពុំប្រាណ ស្តេចទ្រង់ព្រះក្សាន្ត តិតថា
កូនស្រី មកនៅជាសុខ ឥតទុក្ខទឹងអ្វី មិនជ្រាបសេចក្តី ជាកូនកើតទុក្ខ ។
បើទ្រង់ជ្រាបជា កូនព្រាត់ប្រាសគ្នា សមព្រះជនក ជនន៍ថ្លើងថ្លល់ ខ្ញុញ
ឲល់តែទុក្ខ ពុំដែលបានសុខ ដល់មួយរៀល ។ ទ្រហេតុសំណាង បុណ្យ
ព្រេងខ្ញុំបាន សាងមកច្រើនគ្រា សូមទេពទិសទស សោឡសស្តេតា ដៀង

ដួយរក្សា ជនកជនន៏ ។ សូមស្តេចបានសុខ ប្រែប្រាសពោសទុក្ខ
ដូចកាលប្រត្រតី មួយសូមប្រទះ ដួចព្រះស្វាមី បរិបូណ៌ដូចក្តី ចំណង
ប្រាថ្នា ។ នាងនាដពន្ធក តែងតែសោយសោក សត្វ។ រៀល រីអ៊ំ-
មាត្យបរ ក៏យស្តរយោសនា ប្រាំពីរខេត់ គ្មានអ្នកណាធ្វើយ ។ ក៏យ
ដើរវៀនទៅ ចានដល់លំនៅ នៃយាយតាហើយ ស្រែកយោសនាថា
នរណាលោកអើយ ចេះធម៌ចូរធ្វើយ មកនាប់ម្ដង ។ យើង៏ឲ្យមាស
មែន ដម្លឹងមួយសែន ជាទ្រព្យបូជា នាងនាដស្តែង៏ស្តាប់ សារស័ព្ទយោ
សនា ហើយទ្រង់គិតថា នេះសមស្វាមី ។ ឲ្យរកដោយកិច្ច ដោយកល
ដូចម្តេច ឬព្រះបត្រី ជ្រាបជាប្អូនប្រុស ន៏ាសនរបតី សម្តេចស្វាមី ឲ្យមក
រកប្អូន ។ គួរអង្គអញ្ជើយ ថាចេះធម៌ហើយ យកមាសគេជូន ជាទ្រព្យ
បូជា ឲ្យគាឲ្យជូន ហើយទើបស្រីស្តួន ធ្វើយថាខ្ញុំចេះ ។

កាលណោះយាយតា គិតក៏យស្តីថា ម្តេចឡើយដូច្នេះ តាំង៏ពីខ្លួន
ចៅ មកបិតនៅនេះ មិនដែលឮចេះ សំដែង៏ទេសនា ។ ចៅសំដែង៏ម្តេច
មិនកើតសមស្តេច ឲ្យផ្តាច់ដន្ទា នៃយើង៏តាំង៏ប៊ី ក៏ណាក៏យព្រមគ្នា នាង
នាដធ្វើយថា ខ្ញុំចេះមែនពិត ។ ពុំលែង៏សើចឡើយ បានជាហ៊ានធ្វើយ
កុំយាយក៏យគិត អាមាត្យឮធ្វើយ ជាក់ហើយអាត្មាត់ លើលាឡើង៏បិត
លើផ្ទះយាយតា ។

(មានត)

រឿងសាមកុក

កណ្ឌទី ៣០

ឧកញ៉ាវិបុលកវីសេនា ង៉ូ-ភីង ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> ទំងំបេះទុបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ក្នុងសម័យនោះ ចូឆូតឹ្រមបញ្ជាកស្ត្រីអ្នកស្រុក ឲ្យទៅជាសុខៈក្បែរក្បាន្តហើយប្រឹក្សានឹងសេនាបាហានចាំងពួងថា យើងនឹងលើកកងទ័ពទៅវាយយកស្រុកខាងទិសបស្ចឹមទៀត អម្បាលដែលអ្នកឡើងស្តាប់បង្គាប់ស្រុកគឺជាវិ ហើយនឹងបានស្រាវជ្រាវកេងអួនហ្ន៎ នឹងអួនសុងផងទើបនឹងអស់ចំរូងបម្រាសតទៅ ។ ចោហងនឹងពួកបាហានតំស្រែកយាត់ហាមចូឆូថា អួនហ្ន៎ ។ អួនសុងនោះ មិនមែនចូលទៅអាស្រ័យនៅក្នុងស្រុកភូមិបានទេ ប្រហែលនាំគ្នាទៅជ្រកពួនទៅក្នុងព្រៃ ទោះបីនឹងមានបាហានទៅផងក៏តិចអ្នក ឯអាណាខែត្រខាងទិសបស្ចឹមនោះ សុទ្ធតែជា

ស្រុកតូចតាចរដាច់រដាច ហើយផ្លូវនឹងទៅនោះ ក៏ឆ្ងាយដាច់ស្រយាលណាស់ បើនឹងលើកកងទ័ពទៅវាយចំ ក៏ជាការមិនគួរល្មម ខ្ញុំចង់ឡើងប៉ៃវិនឹងឡើងពីដឹង នឹងលើកកងទ័ពទៅវាយយកស្រុកហ្ជីតោ មុខជាលោកនឹងលើកទៅជួយមិនទាន់ទេ ហេតុនេះ សូមឲ្យលោកលើកកងទ័ពត្រឡប់ទៅរក្សាស្រុកហ្ជីតោវិញស្រួលជាង ។

គុយកែតឆ្លើយថា ដែលចៅហានិយាយនោះមិនត្រូវទេ ព្រោះអាណាខែត្រខាងទិសបស្ចិមនោះ កាលអ្នកសៀវាស់ទៅឡើយ ក៏ចាន់ខំនុកបំរុងជាប្រក្រតី ការសឹកសង្គ្រាមក៏មិនដែលមានទៅដល់ មុខជាមានសេចក្តីធ្វេសប្រមាទ ឥឡូវអ្នកហ៊ុ , អ្នកសុងក៏ទៅអាស្រ័យនៅទីនោះផង ត្រូវតែយើងលើកកងទ័ពទៅច្រាបច្រាមឲ្យរាបទាបតែម្តង ឯឡើង ប៉ៃវិនោះជាមនុស្សជាងខាងសំដី នឹងគិតការអ្វីក៏មិនរហូតចាន វេលានេះចានឡើងពីមកខុក បើនឹងខំនុកបំរុងឲ្យដល់ខ្លាត ឡើងប៉ៃវិក៏មិនសូវខុកចិត្តឡើងពី ឯឡើងពីនោះគំយើញថា មិនមែនជាចិត្តស្មោះត្រង់នឹងឡើង ប៉ៃវិប៉ុន្មានដែលការពាំងពួនដែលគិតគ្នានោះ ក៏រមែងមិនស្រុះស្រួលនឹងគ្នាយើងមិនគួរនឹងញញើតខ្លាចឡើងប៉ៃវិនឹងឡើងពីសោះ ហេតុនេះខ្ញុំសូមឲ្យលោកលើកទ័ពទៅច្រាបច្រាមអាណាខែត្រ ខាងទិសបស្ចិមឲ្យចានរាបទាបសិនទើបស្រួល ។

សាមកុកខ្សែ៣១

តាំងពីចូរជូលើកទៅកាយប្រុកលៀវតាំង
គុយកែឈឺស្ទាប់កងស៊ីនទាងកាត់យកក្បាល
អូនហ៊ីអូនសុង ទៅឲ្យចូរជូ រហូតដល់សុនខៀន
ឃាត់មិនឲ្យខ្ចៅពីទៅទូលគំនាប់មន្ត្រីខែត្រ

ចូរជូយល់ត្រូវផង កំពាត់ចែងរកេះស្បៀងបាន ៣.០០០ ហើយ លើកកងទ័ពចេញទៅ ធ្វើដំណើរទឹកឆ្លងរកេះជាច្រើនខ្នង កំពង់ផ្លូវនោះកំផ្លាយជាច់ស្រយាល រាល់រកដើមឈើធំគ្មាន បើមានខ្សាច់បត់ជាត់មក កំបោកផង់ធ្វើជីខ្ពាច់ហុយលុបលើកដំទ័ព ។ ចូរជូយើញដូច្នោះគិតថា យើងលើកទ័ពមកនេះ ទាហានទឹងបានសេចក្តីលំបាកពេកណាស់ ទឹងចង់លើកកងទ័ពត្រឡប់ទៅវិញ លុះដល់ប្រឹក្សាទឹងគុយកែសោគង គុយកែកឹឈើដេកជាប់មកក្នុងរកេះ ចូរជូយើញគុយកែដេកឈឺធ្ងន់ក៏យំសោកហើយថា ដៃលអ្នកមកមានដម្ងឺឈឺដូច្នេះ កំពីព្រោះយើងលើកកងទ័ពនាំអ្នកមក យើងក៏មិនមានសេចក្តីសប្បាយទឹងចង់លើកទ័ពត្រឡប់ទៅស្រុកវិញ គុយកែឆ្លើយថា គុណបំណាចរបស់លោកមានទៅលើខ្ញុំនេះច្រើនណាស់ កុំគប្បីលោកវិតក្កទឹងខ្ញុំបាទឡើយ ទោះបីខ្ញុំទឹងស្លាប់ កំខុកដំរិតដៃលស្លាប់នោះ ជាទីតបស្នងសងគុណលោក

តែម្តងទៅ ដូចពាក្យបុរាណលោកពោលទុកថា ការអ្វីដែលមើលទៅ
ឃើញថា បានការបានប្រយោជន៍ហើយ គឺត្រូវតែខំប្រឹងធ្វើការនោះ ឲ្យ
បានសម្រេច ដែលនឹងត្រឡប់លើកកងទ័ពទៅស្រុកវិញគ្រានេះ ខ្ញុំបាទ-
ឃើញថាជាការនាំឲ្យមានប្រយោជន៍ពាំងសងខាង តាហានពាំងឡាយក៏
នឹងបានសេចក្តីព្រួយនឿយលំបាកទេទៅ បើដូច្នេះ សូមឲ្យលោក
បញ្ជាប់កងទ័ពនៅទីនេះសិន ដើម្បីនឹងសម្រាកកំឡាំងតាហានពាំងឡួង
ហើយត្រូវរើសរកតែតាហានណា ដែលខ្លាំងពូកែ ឲ្យមកស្បៀងអាហារ
ប្រកបដែរត្រាត់ស្តាយ ហើយឲ្យគាន់អាវុធគ្រប់ដៃ ចាប់យកអ្នកស្រុកឲ្យ
នាំផ្លូវលើកទៅចោមរាយយកស្រុកនីមួយ ។ កុំឲ្យមនុស្សដែលនៅក្នុងស្រុក
នោះដឹងខ្លួនខាន់ ទើបនឹងបានស្រុកដោយងាយ ។

ចូរឆ្លើយបំភ្លឺហើយគិតឃើញយល់ថាស្រួល ក៏ឲ្យប្រមូលកងទ័ពឈប់
នៅទីនោះជាដំណាក់ស្រុកអេកដីវ ហើយឲ្យហៅរកមេភូមិម្នាក់ចេញមក
នឹងឲ្យនាំផ្លូវទៅ មេភូមិនោះក៏ដំណាលថា ខ្ញុំបាទមិនសូវស្គាល់ផ្លូវព្រៃច្បាស់
លាស់ទេ តែមានតាហានអួនស្បៀវម្នាក់ ធ្លើជាកងត្រវែលឈ្មោះខៀនទីវត់
មកមកនៅក្នុងស្រុកនេះ ជាអ្នករៀនវៃខាងស្គាល់ផ្លូវព្រៃនឹងស្រុកភូមិពាំង
អស់មិនសល់ ។ ចូរឆ្លើយបង្គាប់ឲ្យកេខ្លួនខៀនទីវមកសួរយកផ្លូវនឹងឲ្យនាំ
ទៅ ។ ខៀនទីវក៏ដំណាលថា ដែលនឹងឲ្យលើកទ័ពទៅកាន់អាណាខែត្រខាង

ទំនប់ស្ងួមនោះ ខ្ញុំបាទនឹងនាំទៅបានតែថា ដំបន់ស្រុកលីវសៀនោះជាផ្លូវ
ជាប់ សយាលណាស់ បើនឹងដើរដើនក៏ត្រូវលុយទឹកនឹងតក់ល្បាប់ បើ
នឹងទៅដោយទូកទឹកក៏ពាក់ សូមឲ្យត្រឡប់ក៏នឹងទៅតាមផ្លូវដំបន់អីឡូនវិញ
តែទៅដល់ពាក់កណ្តាលផ្លូវលំបាកណាស់ នឹងត្រូវដើរទៅត្រាមរូនភ្នំតាម
កន្លែងចង្អៀត លុះផុតពីទីនោះទៅក៏ចេញទៅដល់វាលធំ ទើបគេចូល
ទៅតាមផ្លូវស្រុកលីវសៀវិញ ប៉ែកខុនថៅហ្វាយស្រុកនោះក៏មិនបានដឹង
ខ្លួន មុខជាលោកនឹងយកស្រុកនោះ បានដោយស្រួល ។

ចូធូបានស្តាប់ដូច្នោះក៏ត្រេកអរណាស់ ទើបចាត់ពាហានឲ្យទៅ
រក្សាគុយតែក្នុងជំបន់នោះ ហើយក៏តាំងឲ្យទៀនទីវជាមេពាហានទាំងវ៉ែត
ឲ្យទៀវលៀវជាកងមុខ ចូធូជាកងហ្នឹង ហើយលើកកងទ័ពទៅដល់
ភ្នំប៉ែកឡូនសាន ក៏ទទួលជួបបទះនឹងអ្នងហ៊ី , អ្នងសុង នឹងប៉ែកខុន
លើកពាហានជាច្រើនមកតាំងស្តាត់ផ្លូវទៅកែវភ្នំនោះ ប្រុមាត់វាលធំ
ទៀវលៀវឃើញដូច្នោះ ក៏ភ័យស្ងុតចិត្ត ទើបឲ្យពាហានឈប់សម្ងាត់
ហើយក៏បរសេះត្រឡប់មកជ្រាបប្តូធូថា ប៉ែកខុនថៅហ្វាយស្រុកលីវសៀ
លើកពាហានមកចាំស្តាត់ទៅមាត់ផ្លូវ ចូធូកាលស្តាប់ដឹងសេចក្តីដូច្នោះក៏
ឡើងទៅលើភ្នំ ឃើញពាហានប៉ែកខុនមិនបានតាំងជាក្បួនច័ត ចូធូ
ក៏ប្រគល់ទង់ដ៏ជ័យក្រហមសាជ្ញាសិទ្ធិសម្រាប់មេទ័ព ហើយប្រមូលពាហាន
ឲ្យទៀវលៀវស្រួតទៅបរពលពាហានចូលពង្គ័ពយកឯទ័ពប៉ែកខុន ទៀវ -

លៀកគ្នាទួលយកទង់ដំរីយហើយហៅទៅធ្វើ ស៊ីហ្គុង អ៊ីតាម ជា ៤ នាយ នឹងទៀវលៀវ នាំគ្នាបរសេះស្រុតរួតទៅ លុះដល់ប្រទល់ពាក់ចូលប្រ-កាប់ប្រចាក់សម្លាប់កងទ័ពបែកខ្ទេចស្លាប់ជាហានច្រើនណាស់ ។ ទៀវលៀវ ក៏ចូលបយុទ្ធនឹងបែកខ្ទេចជាពន្លឹក ហើយយកខ្លួនចាក់ត្រូវបែកខ្ទេចឆ្ងាត់ពីលើសេះស្លាប់ ពួកពលទាន់បែកខ្ទេចក៏មកចណ្តុះចុះចូលនៅទាន់ចូរធ្វើតាំងអស់ ។ អ្នកហ្មឺ អ្នកសុងយើញដូច្នោះ ក្នុងចាហានវាត់ទៅទាន់អាណាខែត្រទិសបូព៌ ។

ចូរធ្វើក៏នាំកងទ័ពចូលទៅក្នុងស្រុកលីវសៀ ហើយតាំងឲ្យទៀនទីវទៅឈរក្សាស្រុកនោះ ទៀនទីវអង្គុយយំហើយថា ខ្ញុំបានជាមនុស្សវេរវាត់ពីនាយទៅហ្វាយមក លោកបានមកដួចក៏មិនបាន បាត់ទោសនោះគុណលោកកើតបំផុតគ្មាន ដែលលោកមកថែមលើតទ្យធ្វើជាទៅហ្វាយស្រុកនេះទៀត យើញថាជាលើសកំឡាំងពេកណាស់ ព្រោះថាវាត់គេចវេរពីទៅហ្វាយនាយមកហើយ មកឲ្យអ្នកដទៃលើកដំកើងខ្លួនថាជាមនុស្សល្អត្រឹមត្រូវនោះ មិនសមគួរឡើយ ទោះបីលោកមិនគាំទ្រអាសូរនឹងតាប់សម្លាប់ខ្ញុំបានចេញ ព្រោះវិធីទង្វើនឹងប្រសាសន៍លោកត្រង់ខ្នេះគឺតាមការបុះ ។ ចូរធ្វើដូច្នោះក៏គឺពេញចិត្តណាស់ ទើបសរសើរទៀនទីវថាជាមនុស្សស្មោះត្រង់ពិតត្រង់ល្អមែន ហើយនិយាយថា

បើអ្នកមិនបួលចិត្តធ្វើដំរៅហ្វាយស្រុកគឺវាហ៊ុនុះ ហើយគឺតាំងទៀនទីពុកជាទីប្រឹក្សា ។

ខណៈនោះ ចូនធួចាប់បានសេះជាន ១ ម៉ូន ស្រុកនោះគឺអត់ឃ្លាន ដោយគ្មានស្បៀងអាហារ ដួនជាទេសកាលវេលាវង្វេងវង្វាច ចូនធួក៏ឲ្យលើកគង ទ័ពត្រឡប់មកវិញ ចម្ងាយផ្លូវប្រហែល ២ ពាន់សិន (គឺ ៨០ គីឡូម៉ែត្រ) ពួកគង ទ័ពក៏ថុតអស់ស្បៀងអាហារមិនទឹកដឹក ។ ចូនធួឲ្យសម្ងាប់សេះឈ្មីយនោះ ចែកឲ្យទាហានទាំងពួងស៊ី ហើយឲ្យដឹកអណ្តូងទឹកជម្រៅប្រហែល ៩ ព្យាម ១០ ព្យាម (២០ម.) ទើបបានទឹកចែកគ្នាឲ្យទាហានផឹក ហើយលើកមកដល់ស្រុកអេកដីវឲ្យឈប់ទ័ពចែកវង្វាន់បំណាច់ទាហានតួច តាមសមគួរ ឯអ្នកដែលឃាត់ហាមមិនឲ្យលើកទ័ពទៅច្បាំងទាន់ទិសបស្ចិមនោះ ចូនធួកែងឲ្យបំណាច់វង្វាន់ច្រើនជាងទាហានទាំងពួង ១ ភាគខ្លះ ២ ភាគខ្លះ ហើយប្រកាសដល់ទាហានទាំងពួងថា ដែលយើងលើកទ័ពមកវាយស្រុកលីវសៀគ្រានេះ ជាផ្លូវឆ្ងាយណាស់ ឃើញថាអ្នកហាមឃាត់ទាំងប៉ុន្មានត្រូវបានវង្វាន់ច្រើន ព្រោះយើងមិនស្គាប់ ដែលវាយយកបានស្រុកនោះ ព្រោះទេពួងជួយយើងទេ អំណឹះពីនេះទៅមុខ បើយើងធ្វើការអ្វី កុំឲ្យទាហានទាំងពួងគិតរញ្ជោរញ្ជើតថានឿយហត់ឬខ្វាចសឹកសត្រូវឡើយ ។

កាលបូធូមិនទាន់លើកត្រឡប់មកដល់នោះ គុយតែកក៏ស្លាប់ជាមុន ទាហានតំរុក្សាសពទុកចាំបូធូ លុះបូធូ តឡប់មកដល់ក៏ឲ្យរង្វាន់បំណាច់ទាហានហើយឲ្យតែងការសព បូធូក៏ឲ្យអ្នកជូបខឿនសែនសពគុយតែ ហើយគិយំសោកអាឡោះអាល័យថា គ្រានេះ គុយតែមកស្លាប់កណ្តាលផ្លូវ ទុមាដូចខ្ពើមចំលាយដីតែយើងចេញ ហើយនិយាយប្រាប់ទីប្រឹក្សាទាំងពួងថា អាយុអ្នកវាល់គ្នានឹងយើងស្រុតាលគ្នា តែគុយតែនោះអាយុក្មេងជាងយើងទេ យើងគិតថា ប្រសិនបើយើងស្លាប់មុន នឹងបានផ្ញើបុត្រការយាញាតិសាលោហិតនឹងកិច្ចការទាំងពួងឲ្យគុយតែជួយទំនុកបំរុងតទៅផ្លូវ គុយតែមកស្លាប់មុនយើងវិញ មិនគួរសោះឡើយ កាលណាឡើយយើងនឹងបានសេចក្តីសប្បាយ ។

ខណៈនោះ មានមនុស្សបំរើស្និទ្ធរបស់គុយតែម្នាក់ យកសំបុត្រ ១ ច្បាប់មកឲ្យបូធូហើយជំរាបថា សំបុត្រច្បាប់នេះ កាលគុយតែឈឺដិតស្លាប់នោះ បានខំទស្សាហ៍សរសេរទុកជូនលោក ពាក្យក្រៅពីនោះ គុយតែបានផ្តាំទុកថាឲ្យមហាទុបាដធ្វើតាមសំបុត្រនេះឲ្យបាន ។ ឯស្រុកលៀវតាំងនោះ តន់នឹងបានទៅក្នុងកណ្តាប់ដៃលោក ។ បូធូក៏ទទួលសំបុត្រនោះមកមើលហើយក៏ញាក់មុខ ហើយយកសំបុត្រនោះជាក់ក្នុងហិបលាក់ទុកទៅវិញ ទីប្រឹក្សានឹងសេនាទាហានទាំងពួងក៏មិនដឹងការថាអ្វីសោះ នាំគ្នាគិត

ឆ្ងល់សង្ស័យ លុះវេលាព្រឹកខ្ញុំដែរហ៊ានខ្លួន ក៏និយាយ ចាប់ចូលឆ្លើយថា ខ្ញុំបាទ ឮដំណឹងថា កងស៊ុនខង់ចេញហ្វាយស្រុកលៀវតាំង ដែលនៅខាងទិសបូព៌ នៃស្រុកគីដាំនេះ គិតអង់អាចត្រៀមលពយោធាតាំងជាបន្ទាយដ៏កក្ខ ស្មាមក្បែរមាំមួនណាស់ ពាំនាំអ្នកហ៊ានសុងក៏ទៅនៅពីងពាក់សំណាក់ អាស្រ័យនឹងកងស៊ុនខង់ដែរ ខ្ញុំបាទយល់ឃើញថា កងស៊ុនខង់នោះគង់ ជាសត្រូវនឹងលោក បានជាគិតធ្វើការដូច្នេះ សូមឲ្យលោកស្រួតលើក កងទ័ពទៅកំចាត់ចេញឲ្យទាន់ការ ហើយនឹងចាប់ខ្លួនអ្នកហ៊ាន អ្នកសុងផង ប្រសិនបើបង្អង់ខ្ញុំតយូរ កងស៊ុនខង់នឹងមានគំនិតគិតជាថ្មីឡើងទៀត ។

ចូលឆ្លើយស្តាប់ហើយក៏អស់សំណើចហើយតបថា ការនេះអ្នកកុំព្រួយជា ទុក្ខឡើយ យើងមិនបានឲ្យអ្នកទាំងអស់គ្នាបានសេចក្តីលំបាកទេ ត្រូវ ដួយស្តាប់សូរសព្ទដំណឹងមើល ៥ ថ្ងៃ ១០ ថ្ងៃសិនចុះ មុខជាកងស៊ុនខង់ នឹងកាត់យកក្បាលអ្នកហ៊ាន , អ្នកសុងមកឲ្យយើង ពាក្យនេះទាំងពួងឮដូច្នោះ ក៏មានសេចក្តីសង្ស័យទាំងអស់គ្នា ។

ឯអ្នកហ៊ាន , អ្នកសុងកាលតាំចេញពីចូលទៅនោះ មានពាក្យជាប់ ទៅផងប្រហែល ១ ពាន់ពាក្យ លុះទៅដល់ស្រុកលៀវតាំង ក៏ លាស្រាយរ៉ាយរឿងទាំងពួងប្រាប់អ្នកចាំទ្វារឲ្យចូលទៅដំរាបកងស៊ុនខង់ថា យើងជាបងប្អូននឹងមកសូមចូលនៅពឹងពាក់អាស្រ័យកងស៊ុនខង់តទៅ ។

អ្នកចាំទ្វារក៏នាំយកសេចក្តីនោះចូលទៅដំរាបកងស៊ុនខង ។ ដូច្នេះហើយកំ-
ប្រុក្សាទីនាម៉ឺនមុខមន្ត្រីនិងអស់សេនាពាហនពាំងពួងថា ឥឡូវ អ្នកហ៊ឺ,
អ្នកសុង្គវគ្រាចេញពីចូរូមក ខ្ញុំចូលមកពឹងពាក់អាស្រ័យនៅក្នុងស្រុកយើង
អ្នកពាំងពួងនឹងយល់ឃើញប្រការម្តេច ? ។ កងស៊ុនកុងជាប្អូន ធ្វើយថា
កាលគ្រាអ្នកសៀវនៅរស់មិនទាន់ស្លាប់នោះឡើយនោះ ខ្ញុំពុំដំណឹងថា
អ្នកសៀវប្រុងនឹងលើកទ័ពមកធ្វើអន្តរាយស្រុកយើងរឿយ ។ ឥឡូវ អ្នកហ៊ឺ,
អ្នកសុង្គ , ខ្ញុចស្រុកគេមក បើយើងឲ្យចូលនៅអាស្រ័យនោះគំរើញ
ថាមិនខំនង ព្រោះចិត្តអ្នកហ៊ឺ , អ្នកសុង្គនោះទបមាដូចក្អែក ទោះបីឲ្យ
អាស្រ័យនៅហ៊ាយ យូរទៅគង់នឹងប្រែចិត្តគិតប្រទូស្តរាយដណ្តើមយក
ស្រុកយើង បីដូចក្អែកដណ្តើមយកសម្បុកគាះ។ បើដូច្នេះ ត្រូវតែយើង
បណ្តេញឲ្យអ្នកហ៊ឺ , អ្នកសុង្គឲ្យចូលមកចុះ រួចសឹមគិតចាប់ខ្លួនសម្លាប់
ចេញ ហើយកាត់ក្បាលយកទៅឲ្យចូរូ ស្រុកយើងក៏នឹងមិនមាន
សេចក្តីអន្តរាយគេទៅ ។ កងស៊ុនខងគបទៅថា បងត្រែងលោចូរូនោះមាន
កំឡាំងខ្លាំងពូកែឡើងខ្លៃត ហើយនឹងលើកកងទ័ពធ្ងងមកវាយយកស្រុក
យើង ដែលយើងនឹងឲ្យសម្លាប់អ្នកហ៊ឺ អ្នកសុង្គនោះមិនគួរ ប៉ែបញ្ចឹមទុកជា
ពាហនក៏នឹងបានជាកំឡាំង ហើយយើងនឹងលើកទ័ពទៅបង្ក្រាបនឹងចូរូ
ស្រួលល្អជាង ។

(មានត)

រឿងព្រេងនឹងរឿងបុរាណប្រទេសជប៉ុន

(តមក)

លោក រ៉ាយ-ប៊ុក ប្រែរៀបរៀង

ស្បែកមុខលោកជ្រួញ, បបូរមាត់ញ័រចំប្រប់, ទឹកភ្នែកហូរហាម ។ តើតាចាស់យាយចាស់នោះក័យដោយហេតុអ្វី? ។

នៅដិតតាចាស់យាយចាស់, មានមុខរបងផ្ទះដែលស្ងួតនៅមាត់ស្ទឹង មាននាងកញ្ញាម្នាក់អង្គុយមុខស្មុកស្មាំនឹញ័រខ្លួន ។ នាងមានសក់វែងធ្លាក់ប្រាស់ស្មា ។ ភ្នែកនាងបើកធំ ត្រោមចិញ្ចើមខ្ពស់ជួបជាន់នឹងសន្លឹកខ្លួចស្បូខ្មៅយកពាក្អូម៉ាន់ ដែលមានសភាពសម្បើមអស្ចារ្យ គួរខ្លាចគក់ស្លុតពន់ពេក ។ តើម៉ែតាមាតា នឹងនាងកញ្ញាម្នាក់នោះខ្លាចអ្វី? ។

បន្តិច, ស្រាប់តែភ្លៀងស្អុះស្អះដើងដើរ, គឺដើងមនុស្ស ឬទៅតាក៏មិនដឹង មានបុគ្គលមួយរូប ចិតចូលមកដិត . . . បុគ្គលនោះគឺអាទិទេពភ្នំរះសង្ឃរាជនាមថា ស៊ុសាណូ ។ បុគ្គលនោះចូលមក, មានអាទុកាពអស្ចារ្យពេកណាស់, មានព្រះខ័នសៀតនៅចង្កេះ ។ អាទិទេពស៊ុសាណូនេះ, គេបានដេញចេញពីមហាមេឃ, ដោយព្រះនាងអាទិទេវីស៊ូរីយ៉ា ឬស៊ូរីយោអាទិ

ទៅវិញ ។ អាទិទេពស៊ុសាណូក៏ចុះទៅគាន់ដែនដី ធ្វើដំណើរកាត់ខេត្តអ៊ីហ្សូម៉ូ ។ លោកក្រទេក្រទៅឃើញដំបងតូចមួយ ដែលដនជាតិជប៉ុនធ្លាប់ប្រើសម្រាប់រកអាហារគោដនត្រប់យ៉ាងឃើញបែបនេះ ។ លោកគិតថា បើប្រសិនជាអញដើរទៅមានលើស្ទឹងមុខជាមានមនុស្សនៅមិនខាន ។ គឺក្នុងពេលនោះឯង ដែលអាទិទេព ស៊ុសាណូ បានជួបប្រទះនឹង គាថស់យាយ ៧ស់ពាន់ពីរនាក់នឹងនាងកញ្ញា ។

អាទិទេពនេះ បានប្រព្រឹត្តមោះមិនគប្បី ដែលនាំឲ្យគេនិរទេសចេញពីមហាមេឃ ។ តែនៅលើដីវិសេសនៅជាមួយនឹងមនុស្សជាតិ អាទិទេពនោះនៅជាមានសភាពចិត្តជាមនុស្សនៅវិញ ។ លោកមានចិត្តអាណិតអាសូរដល់គាថស់យាយចាស់នឹងនាងកញ្ញាម្នាក់ ហើយក៏សួរគាថស់ថា “ ម្ចាស់លោកតា ។ ឈ្មោះអ្វី ? ” ។ គាថស់ក៏ធ្វើយតបទៅអាទិទេពស៊ុសាណូវិញថា: “ខ្ញុំឈ្មោះអស៊ីនហ្សូស៊ី (Asinazuci) ខ្ញុំជាបុត្រនៃអាទិទេពមហាគីរី កាយោឈ្មោះនាងតីនហ្សូស៊ី (Tenazuci) កូនស្រីខ្ញុំគឺព្រះអង្គម្ចាស់ក្សត្រីគុនីសៈដា (Kunisada) ។

អាទិទេពស៊ុសាណូទូន្មានសួរហើយសួរទៅគាថស់តទៀតថា: ម្តេចក៏អ្នកយំ ? គាថស់តបថា :

មានត

លោក លាង ហាប់-អាន ប្រែរៀបរៀង

(តទៅ)

ព្រះរាជាបានទ្រង់បង្គាប់ឲ្យគេរៀបសង់ប្រាសាទមួយយ៉ាងស្អាត នៅកណ្តាលព្រៃស្ងាត់ មានរៀបគ្រែមាសរំលេចនូវគ្រឿងតែក្តីព្រោងព្រាតដំកល់អគ្គីព្រះនាងហើយឲ្យធ្វើបង់យ៉ាងញឹក ជាំបន្ទាគ្រប់មុខចម្រុះ កុំឲ្យមនុស្សតែណាចូលបៀតបៀនបាន ។

ព្រះនាងទ្រង់សន្ធប់សូន្យសុង ប៉ុន្តែ ព្រះកត្តុនៅស្រស់ប៉ៃ បឹមធ្វើឲ្យព្រះបិតាមាតាទឹកអាល័យជាអនេក ។ ជង្រឹមព្រះនាងដកចេញចូលយ៉ាងតិច។ ប៉ុន្តែ ព្រះនេត្រនៅបិទជិត ។ គេអាចសន្និដ្ឋានថា ព្រះនាងទ្រង់ផ្ទុពុំទាន់ផ្តួតទេ ។

លុះធ្វើសេចក្តីសោកសង្រេងហើយ ព្រះរាជាក៏ទ្រង់ចាត់នាម៉ឺន ស្រីស្នំដែលទុកព្រះហឫទ័យច្បាស់ ឲ្យនៅយាមរក្សាព្រះនាង ទំនិចចាត់ចែងការក្នុងដំណាក់នោះ ។ ក្រោយដែលព្រះរាជាយាងចេញផុតមក មនុស្សទាំងប៉ុន្មាន ដែលត្រូវនៅថែរក្សាទីឯយាមដំណាក់នោះ ក៏ដេកលក់សូន្យសុងគ្រប់គ្នាទៅជាមួយព្រះនាងទៅ ។

កាលវេលាកន្លងផុតមកអស់ ១០០ឆ្នាំ មានព្រះរាជបុត្រស្តេចមួយព្រះ

អគ្គ នៅនគរដ៏ទៃ ទ្រង់បានលាព្រះបិតាចេញមកប្រពាតបរបាញ់ប្រិត មាន
ពួកបរិវារហែហមជាច្រើន ។ ព្រះអង្គម្ចាស់នោះបានយាងកាត់ព្រៃ
ជាច្រើនអន្លើ ដោយពុំមានប្រទះសត្វអ្វីដល់មួយទេរួយ ។ តមក ស្រាប់តែ
ជ្រុលព្រះអង្គមកដល់ក្នុងព្រៃស្មសានស្ងាត់ឈឹង ជាកន្លែងដែលដុតសំអង្គ
ព្រះពាជបុត្រីនោះ ។ ព្រះអង្គម្ចាស់ចាលព្រះនេត្រទៅកណ្តាលព្រៃ ស្រាប់
តែឃើញប្រាសាទមួយ ផុះលេចឡើងត្រដែត នៅក្នុងព្រៃស្ងាត់ជ្រងំ ។
ព្រះអង្គម្ចាស់ឆ្ងល់ក្នុងព្រះទ័យណាស់ ទើបគ្រាស់សួរទៅពាជបរិពារក្នុម ។
អ្នកខ្លះគ្រាបទូលថា ប្រាសាទភ្នំច, ខ្លះថា ប្រាសាទបត្តិតើតឯង, ខ្លះថា
ប្រាសាទយក្សដ៏មានទំនិលរ្បាញ ឆ្ងាច់ចាប់មនុស្សយកទៅស៊ីតរឆ្ងឹង ពុក
ដូចជាភ្នំ ។ ដោយពាក្យភ្ញាក់ព្រឺតតួរខ្លឹងដៀនោះ ព្រះអង្គម្ចាស់ចង់ដឹងហេតុ
ដោយច្បាស់លាស់, ទ្រង់ឆ្ងល់ជាអនេក ។ មួយរំពេច មានបុរសចំ
ណាស់ម្នាក់ ក្នុងចំណោមនោះបានថ្វាយសេចក្តីថា “ សូមព្រះអង្គទ្រង់ព្រះ
សណ្តាប់ ប្រមាណជាង ៥០ ឆ្នាំមុខនោះ ឪពុកខ្ញុំបានប្រាប់
ថាប្រាសាទនេះ សង់ដំកល់អង្គបុត្រីដ៏ឆើតឆាយ របស់ស្តេចត្រង់ពាជសម្បត្តិ
ក្នុងនគរមួយនោះ ដោយព្រះពាជបុត្រីនេះ ត្រូវទំនាយរបស់យាយទេពតំង
ថ្ងៃកំណើត ១០ ថ្ងៃ គ្មានចាស់សោះ, ហើយព្រះនាងនឹងបានតើនឡើង ដោយ
ព្រះពាជបុត្រស្តេចណាមួយ មកជាស្តីតើនឡើងនឹងបានជាគូរវាសនា ។

គ្រាន់តែឮប៉ុណ្ណោះ ព្រះអង្គម្ចាស់ដូចជាឃើញដុំពេជ្រដ៏ ថ្លៃថ្លៅនៅពីមុខ ពេញដោយសេចក្តីស្នេហាចំពោះរូបឆើតឆាយ ព្រះអង្គម្ចាស់ប្រថុយអង្គគ្មានឧកញ្ចាច ។ ព្រះអង្គលាក្រុមបរិពារ តម្រង់ទៅប្រាសាទនោះ ។ រថបន្ទាប់មុតក៏ញែកផ្លូវយ៉ាងស្អាត ថ្វាយព្រះអង្គម្ចាស់ ។ មានអំណរឥតគណនា ព្រះអង្គម្ចាស់ក៏យាងចូលទៅ ។ រីឯក្រុមបរិពារដែលបម្រុងនឹងចូលតាម ក៏អាត់ខានដោយរថបន្ទាប់នោះរួមយ៉ាងញឹកដិតមកវិញ។ព្រះអង្គម្ចាស់ស្ទើចនឹងប្រាសាទនោះ ទ្រង់ឡើងដណ្តើរតែ ចូលទៅលែងក្នុងដែលត្រៀបត្រាស់ទ្ធសឹងតែរូបផ្សែង ។ ។ ព្រះអង្គម្ចាស់ចូលទៅលែងមួយទៅមាត់ទ្វារមានសុទ្ធតែមនុស្សអ្នកយាម ខ្លះកាន់កាំភ្លើង ខ្លះកាន់ស្នាព្រញ ជាវៀតបិត ពួកថា ខ្លះអង្គុយ ខ្លះឈរ ប៉ុន្តែ សុទ្ធតែលក់ឈឹងពាំនអស់ ។ ឆើរតែតែរន្ធត់ដោយភាពដ៏ស្ងាត់សូន្យឈឹងនោះ ព្រះអង្គម្ចាស់តាំងជាប្រុងមាំ ពុំមានខ្លាចៗព្រះអង្គគាត់តម្រង់ទៅបន្ទប់ ដែលក្នុងស្អាតមួយ។ គ្រាន់តែឈានដើងទៅ ស្រាប់តែទ្រង់ក្លាក់នឹងពន្លឺភ្លៃឆកចរ ណាដ៏ក្លៀវ ព្រះអង្គពោលព្រះនេត្រចំទៅមុខឃើញមុងមួយសស្គុះ ។ នៅលើព្រះទែនមានស្ត្រីម្នាក់ រូបឆោមស្អាតស្រស់បញ្ចង្គ ដណ្តប់ជាហ៊ុំរលេចទៅដោយក្បាច់រចនាដ៏ពិសេស ដេកស្លូកស្តើង ។ នៅលើក្បាលដំណេកមានតុហ៊ុនមួយ ជាក់ពែងតែពែងស្រាជាដង្វាយ ។ តែឆើតែធ្លល់ឥតឧបមា ព្រះអង្

ម្ចាស់យាន៧ដងតមុន ។ មួយរំពេចស្រាប់តែទ្រង់បន្ទន់អង្គចុះក្រាបទៀប
ដើនវែ្រ ហើយលុតដង្ហិនក្តាម ។

ដោយទំនាយផុតអស់ហើយ ព្រះពាដបុតីក្រោកឡើង ។ នៃក្រាព្រះ
នាងរំពៃ៧លើអង្គព្រះអង្គម្ចាស់ ។ ព្រះនាងត្រាស់សួរថា ព្រះអង្គនេះ
ហើយឬ ដែលជាអ្នកមានវិជ្ជាចេស្តា ។ ម្ចាស់ប្តូនធំចាជាអង្វែងតាល អស់
១ សតវត្សមែកហើយ ។ តេញ្ញាដ៏ាំយអំណា ព្រះអង្គម្ចាស់ដែលពុំធ្លាប់ប្រ
ទះស្ត្រីឆើតឯកយ៉ាងនេះ តាំងតែតែប្តូតអង្គ៧កន្លងសេចក្តីស្នេហាតំរេក
ពាំងស្រុង ។ ហើយទ្រង់តប៧ព្រះនាង ដោយពាក្យផ្អែមល្ហែមសរសើរ
ឯសនាដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ។ ព្រះនាងទ្រង់បានសន្ធនាយ៉ាងយូរអំពីពរ
ទំនាយអាក្រក់របស់យាយទេព ទឹងពរប្រសើរបស់នាងទេពធីតាក្មេងអស់
រយៈវេលា ៤ ម៉ោង - លំដាប់នោះ មន្ទុស្សក្នុងដំណាក់ប្រាសាទពាំងអស់
ក៏ដឹងខ្លួនក្រោកឡើងគ្រប់ៗគ្នា ដូចធើបពីដេក ។ អ្នកពាំងអស់ចាប់ធ្វើ
ការងារដូចកាលមុន ។

តមក អ្នកព្រះស្មាយ ក៏បានចូលមកអញ្ជើញព្រះពាដបុត្រីឲ្យយាង៧ទៅ
សោយត្រាដូចធម្មតា ។ ដោយអត់អាហារដាយូរនាំ ព្រះពាដបុត្រីក៏មាន
ព្រះសារីរិយ៍ឲ្យព្រះអង្គម្ចាស់ដួយគ្រាប់លើតឡើង ។ ព្រះនាងទ្រង់ព្រះកាយ
យ៉ាងធើតនាយ ។ តន់យ៉ាងនោះតែងដាយ ព្រះនាង៧បន្ទូលព្រះបន្ទូលថា

សម្លៀកបំពាក់ខ្លះនេះ ពុំបានមានសៅហ្មងទៅឡើយ ។

បន្តិចមក ព្រះអង្គម្ចាស់សង្ឃរាជាំងខ្លាំងគ្នាមក ប្រដុំសោយក្រយា ស្ងោយដំឡូយឈ្ងប់ នៅលើតុកែវថ្មយ៉ាងស្អាតៗ តូរ្យតន្ត្រីលេងប្រគំថ្វាយ ព្រះអង្គ ។ ស្ត្រីស្អុំយ៉ាងស្អាតជាត់ទ្រលុក ។ បំរើព្រះនាងយ៉ាងប្រុមប្រិយ ។ ក្រោយមក ព្រះនាងក៏ចូលទៅផ្ទំយ៉ាងស្កប់ស្កល់ ជាមួយនឹងព្រះអង្គម្ចាស់ ។

ព្រឹកព្រាងព្រះសុរិយា ព្រះពាយផាយផាត់រះតើយ ។ បក់តិះដោះភ្ញែនភ្លាំ តងអរញ្ជះតមកលើប្រាសាទព្រះពជបុតី ។ ព្រះអាទិត្យរះទៅដើងមេឃបញ្ចេញសូវិសេនស្មើភ្លឺត្រចះ បំភ្លឺប្រាសាទដ៏ភ្លឺផ្លេក បក្សីរកស្លាម្រិគម្រិគាយំហៅកញ្ជ្រៀវត់ហើរប្រសាចខ្លាត់ខ្លូនចេញពីសំបុកខ្ទំ ក្នុងព្រៃជ្រៅមានព្រៃផ្សារយ៉ាងគ្រលួច តគ្នាមុនពេលដែលចេញពីសំបុកទៅរកស៊ី ព្រះអង្គម្ចាស់ខ្លែតើន ដំរព្រះកាយស្រេចនឹងសោយស្កប់ស្កល់ក៏សូមលាព្រះនាងសង្ឃរត្រឡប់ទៅនគរវិញ ដោយខ្លាចព្រះពជបិតាខន្ធឹង ។ ព្រះពជបុត្រីខលួលឲ្យព្រះអង្គម្ចាស់ឃ្លាតចេញទៅយ៉ាងពិបាក ។

ចំណែកឯ ព្រះមាតាបិតាខ្លែតព្រះវិតក្កខន្ធឹងចាំមើលផ្លូវ ព្រះអង្គម្ចាស់យ៉ាងខ្ញុចផ្សា ។

ប្រមាណជាម៉ោង១០ព្រឹក ព្រះអង្គម្ចាស់ក៏ឃានយាងដល់មកព្រះនគរវិញ ព្រះអង្គខ្លែតដោះសារព្រះបិតាមាតាថា តាលដែលយាងទៅប្រពាតព្រៃ

នោះ ព្រះអង្គទ្រង់រង្វេងផ្លូវពីពាជបរិពារសំណាក់ដើមទួមអ្នកតាប់ទសព្រះអង្គ ទ្រង់ផ្ទុំអស់មួយរាត្រីនៅទីនោះ ។ អ្នកតាប់ទសក៏បានរៀបក្រយាស្វាយថ្វាយព្រះអង្គ លុះព្រឹកឡើងទើបគេនាំចូលមកវគនគរយើញវិញ ។ រីឯព្រះរាជបិតាដ៏ជាកំសត្រទ្រង់ទសពិធកំទ្រង់ដឿបុត្រគ្មានសង្ស័យ ចំណែកព្រះរាជមាតាពុំអាចដឿដល់បន្តិចឡើយ ។ ព្រះនាងទ្រង់សង្ស័យជាយ៉ាងខ្លាំង ដោយព្រះអង្គម្ចាស់ចេញទៅប្រពាតព្រៃលង់ៗថ្ងៃ ហើយដួនតាលទ្រង់ពុំបានវិលចូលមកនគរវិញដល់ទៅបីបួនថ្ងៃ ។

ព្រះអង្គម្ចាស់លួចលាក់ទៅរួមមេត្តី នឹងព្រះរាជបុត្រីគ្រប់ពេលវេលាពីរឆ្នាំគត់ ព្រះនាងទ្រង់មានបុត្រមួយគូ បុត្រប្សងជាស្ត្រី ទ្រង់ថ្វាយព្រះនាមថាព្រះកុត្រីរស្មី ព្រះរាជបុត្របង្ខាប់ប្រុស ទ្រង់ថ្វាយព្រះនាមព្រះអង្គម្ចាស់អាទិត្យ ព្រោះទ្រង់មានពណ៌សម្បុរស្រស់ជាង ។

ព្រះរាជមាតាទ្រង់បានហៅព្រះអង្គម្ចាស់ជាបុត្រមកពន្យល់ជាប្រក្រតីអំពីការដើរបរបាញ់ដ៏លាមក ប៉ុន្តែ ព្រះអង្គម្ចាស់ពុំបានធ្វើឲ្យបែកការណ៍ឡើយ ដោយព្រះអង្គបានដឹងជាក់ថាព្រះមាតាជាស្តេចយក្ខិនី ហើយដែលព្រះរាជបិតាទ្រង់អភិសេកយកនោះ ដោយព្រះនាងយក្ខិនីមានវិជ្ជេស្តាខាងបញ្ឆូលស្នេហ៍ ហើយព្រះនាងមានកោតសម្បត្តិយ៉ាងស្តុកស្តម្ភៗម៉្យាងទៀត ដោយទ្រង់ខ្ចាចសេចក្តីសាហាវរបស់ព្រះនាង ។

រំលងកាលប្រមាណពីរឆ្នាំមកទៀត ព្រះរាជាជាបិតាក៏ទ្រង់ទិវង្គត ។ ។ អំណាចគ្រប់គ្រងរាជធានី ក៏ធ្លាក់មកលើព្រះអង្គម្ចាស់ទាំងអស់ សម្រេចដូចប្រាថ្នា ហើយព្រះអង្គម្ចាស់ក៏ទ្រង់ប្រកាសនូវរាជាភិសេក ព្រះអង្គ ចំពោះមុខនាម៉ឺនសព្វមុខមន្ត្រី ។ ព្រះអង្គក៏ទ្រង់នាំព្រះរាជបុត្រីជាអគ្គមហេសី ចូលមកក្នុងព្រះនគរបស់ព្រះអង្គ ត្រមាំងព្រះរាជបុត្រទាំងគូ ។

ក្រោយមក ព្រះមហាសត្វត្រអង្គនេះ ទ្រង់យាងចេញទៅតយុទ្ធនឹងស្តេចចក្រពត្តិឯ បទេសនាយ ។ ព្រះអង្គបានទុកជាក់អគ្គមហេសី ព្រមទាំងព្រះរាជបុត្រថ្វាយព្រះមាតាយក្តីនឹងថែរក្សា ព្រោះព្រះអង្គត្រូវចេញទៅប្រតិបត្តិការៈសុះព្រះរាជាចេញផុតទៅ ព្រះរាជមាតាបានបញ្ជូនព្រះនាងសុណិសា ព្រមទាំងព្រះរាជនត្តាទាំងគូ ឲ្យទៅនោកក្នុងដំណាក់មួយជាប់សង្កត់ នាកណ្តាលព្រៃ ។ ក្រោយមកព្រះនាងបានហៅនាយឆ្មាំដំនិត មកបង្គាប់ថា ទៅថ្លាស្អុក យើងចង់បានថៅស្មើមកស៊ីជាអាហារ ឲ្យបានឆ្ងាញ់ម្ត្ចង ។ ហួសនិស្ស័យនាយឆ្មាំភ្លាត់មាត់ត្រវីក្បាល ។ ព្រះនាងតបន្ទន្ទមទៀតថា ហើយយើងចង់ឲ្យតាស្មោយ៉ាងពិសា ។

នាយឆ្មាំនឹកថាជាការពុតប៉ិនងឹងដូតាមបង្គាប់យក្ខសាហាវនេះឡើយ ប៉ុន្តែ ដោយព្រះរាជបង្គាប់ នាយឆ្មាំក៏គាន់តាំចិតយ៉ាងធំមួយតម្រង់ទៅបន្ទប់

ព្រះពរជកុមារីរស្មី ដែលទើបនឹងបានជន្មាយុ ៤ឆ្នាំភ្លុយ ។ គ្រានតែចូលទៅដល់ ព្រះនាងរស្មីក៏ស្ទុះត្រួតមកឧបកនាយឆ្មាំសួមនំសោយ ។ មានសេចក្តីមេត្តាជាអនេក នាយឆ្មាំទំលាក់គាំងតែពីដៃចោលហើយ ក៏ចុះដើរឆ្ពោះទៅគ្រោលសត្វ ចាប់មេពពែធាត់មួយប្រហារជីវិត ដើម្បីកូនយកមកថ្វាយព្រះនាងយកទុនី ។ ក្នុងពេលនោះ នាយឆ្មាំក៏នាំព្រះនាងរស្មីយកទៅលាក់ផ្ទៃនឹងភរិយាខ្លួនឯងនាកណ្តាលគ្រោល ។

ប្រាំបីថ្ងៃក្រោយមក ព្រះនាងយក្ខទុនីសាហាវ ដោយសេចក្តីញ៉ាំមក៏ហៅនាយឆ្មាំមកបង្គាប់ទៀតថា យើងចង់ស៊ីថៅអាទិត្យទៀត ឯងត្រូវស្វែងរកញ៉ាំមកថ្វាយយើង ។ នាយឆ្មាំទទួលព្រះពរជបង្គាប់ចុះទៅដំណាក់ព្រះពរជកុមារអាទិត្យ ដែលមានជន្មាយុប្រមាណ ៣ ឆ្នាំប៉ុណ្ណោះ ។ ពេលនោះ ព្រះពរជកុមារកំពុងតាន់ក្រមង់ផ្កាបន្លែងលេង ។ នាយឆ្មាំក៏នាំយកទៅផ្ទៃទៅភរិយាខ្លួនទៀត ហើយក៏ទៅប្រហារកូនពពែដ៏ធំធាត់ស្អាងស្រស់យកមកថ្វាយព្រះនាងយក្ខទុនីដូចប្រាថ្នា ។

ដោយស្មាដៃឯករបស់នាយឆ្មាំ ព្រះនាងយក្ខទុនីមានសេចក្តីញ៉ាំមិនប្រក្រតី ។ ល្ងាចមួយ ទ្រង់បានហៅនាយឆ្មាំដដែលមកបង្គាប់ថា ឥឡូវនេះទៅសម្លាប់ព្រះសុណិសាយើងទៀត យើងចង់ឲ្យឯងទៅប្រហារសួរឲ្យពិសាដូចបុត្រយកមកឲ្យយើងក្នុងខណៈនេះ ។ នាយឆ្មាំទទួលព្រះពរជបង្គាប់

ដោយវិតក្កកន្ត ប្រាណ ។ ព្រះនាងក្សត្រីពេលនោះ មានជន្មាយុ ៦០ ឆ្នាំ ហួយ
ដោយតុំរាប់បញ្ចូលនូវ ១០០ ឆ្នាំដែលព្រះនាងទ្រង់ផ្តួសូន្យសុន្ទរនោះឡើយ ។
សម្បុកព្រះនាងស្តុតជាងមនុស្សធម្មតា ប៉ុន្តែព្រះនាងនៅល្អឆើត ដោយ
សារពណ៌សម្បុរឯកប៉ុណ្ណោះ ។ នាយឆ្មាំចាស់ប្រកបមិនដឹងនឹងរកសត្វឯណា
ក្នែងក្រាយល្មមឲ្យយកទៅដឹកគាត់មេត្តាគាន់តាំបិតតាំងតោមួយចូលទៅក្នុង
ជំណាក់ព្រះនាង បំណងប្រល័យជីវិតបង់ ។ ដល់ហើយដោយតេជានុភាព
របស់ព្រះនាងដ៏ថ្លៃថ្លា នាយឆ្មាំទលាក់តាំបិតចោល លុតជង្គង់ទូលតាមពិត
ព្រះនាងហួសព្រះចិត្ត តំទ្រង់មានព្រះរាជឱថា "ម្នៃតាឆ្មាំ តាត្រូវធ្វើតាម
សេចក្តីបង្គាប់ពុះ ខ្ញុំត្រូវតែបូជាជីវិតជូនតា ខ្ញុំធំធាន់ទៅជួបជុំបុត្រធីតាខ្ញុំ
ដែលបានចែកស្ថានផុតទៅមុនជាបណ្តើលជីវិតរបស់ខ្ញុំ ។ មានបន្ទូលយ៉ាង
នេះ ដោយព្រះនាងស្មានជាក់ថា ព្រះរាជបុត្រគេធ្វើគត់សូន្យទៅហើយ ។

តំយញ្ញ៎ នាយឆ្មាំទូលតបថា "បពិត្រព្រះម្ចាស់ក្សត្រីដ៏ពេញលក្ខ័ណ
ទូលព្រះបង្គំពុំជាចំចិត្តធ្វើតាមព្រះរាជបង្គាប់ឡើយ ទ្រង់ពុំផុតសង្ឃឹមរកេ
ទូលព្រះបង្គំនឹងទទួលអនុគ្រោះប្រហារមេបៀមចាស់ សូក្នែងថ្វាយព្រះនាង
យកកូនឲ្យបានជួបជំណង ឯព្រះរាជកុមារទាំងពីរពុំសុគតទេ សូមទ្រង់យាង
ទៅទួមរបស់ទូលព្រះបង្គំពិតជាអស់យ៉ាងសុខសាន្ត ។ នាយឆ្មាំក៏នាំព្រះម្ចាស់
ក្សត្រីយកទៅលាក់ឯកន្លែងខ្លួន ។ ព្រះម្ចាស់ក្សត្រីទ្រង់សោយសោកានឹង

ព្រះរាជបុត្រទាំងពីរ ។ នាយឆ្នាំក៏ឃានទៅប្រហារមេចៀមចាស់មួយស្ទុ
យ៉ាងឆាប់យកទៅថ្វាយព្រះនាងយក្ខិនី ។ ដោយស្មាដៃឯករបស់នាយឆ្នាំ
ព្រះនាងយក្ខិនីទ្រង់ត្រាប់ព្រះឧស្ភ ស្មានជាតំណាងព្រះម្ចាស់ក្សត្រីពិត។ ។
ហើយសព្វព្រះរាជហឫទ័យ នឹងសេចក្តីឃ្លានរបស់ខ្លួន ។ ព្រះនាង
យក្ខិនីបានគិតថា បើព្រះរាជបុត្រវិលត្រឡប់ពីចម្បាំងវិញ នឹងនិយាយកូតក
ថា មានឆ្កែតំណាចបានមកឆ្លើយជាព្រះម្ចាស់ក្សត្រីព្រមទាំងព្រះរាជបុត្រ
ទាំងគូ ពាំយកទៅបាត់ក្នុងរាត្រីវេលារាត្រី ដែលព្រះនាងទៅគំនាប់ ទៅឯ
ព្រះរាជតំណាក់ជាចំណែកឯង ។

ល្ងាចមួយ ព្រះនាងយក្ខិនីដែលឆ្លាប់ចេញទៅឆ្កត់លបតាមគ្រូ ដើម្បី
ហុតឈាមបរិភោគសាច់ស្រស់ ក៏ទ្រុលដំណើរទៅដល់ខ្នុមការិយានាយឆ្នាំ។
ព្រះនាងយក្ខិនី បានឮសូរមាត់ព្រះរាជកុមារអាទិត្យ ស្រែកយំ យ៉ាងខ្លាំង
ដោយព្រះមាតាគិតវាយ ហើយនឹងសំដីដ៏ខ្ទន់ក្ងន់របស់ព្រះនាងរស្មី ដែល
កំពុងអង្អែរព្រះមាតា កុំឲ្យវាយព្រះអនុជ។ ចំណែកជាតំណាងសំដី ព្រះម្ចាស់ក្សត្រី
ជាសុណិសានឹងព្រះរាជនត្តា ព្រះនាងយក្ខិនីទ្រង់ ព្រះគោងជាអនេក ។
ហើយទ្រង់នឹកភ្ញាសនឹងចាញ់ភោកនាយឆ្នាំ ។ លុះព្រលឹមឡើងព្រះនាង
យក្ខិនីបានបញ្ជូញសំឡេងដ៏ញាប់ញ័រ ធ្វើឲ្យរន្ធត់អស់ពស្ត្រនាម៉ឺនសព្វមុខ
មន្ត្រីជន ព្រះនាងទ្រង់បង្គាប់ឲ្យនាយពាហានយកពាងមួយជាតំពេញសុទ្ធ
សឹងសត្វមានពិសគឺក្អែប ពស់វែក តូចធំ គឺងគត់ទូលមក ដើម្បីចាប់ព្រះ

ម្ចាស់ក្សត្រីទូរព្រះពជបុត្រពាំងពីរព្រមនាយឆ្មាំនូវកិរិយា គ្រួសានឹងបាត្រាវ
ពាំងអស់ បងំលាក់ឲ្យសត្វអាសីរពិសសាហាវពាំងនោះប្រហារជីវិតបង់ ។
ពេលវេលាក៏មកដល់ យក្ខិនីឲ្យពេជ្ឈឃាជ ចងអ្នកមាននោសពាំងអស់
រៀបបម្រុងនឹងចាប់ចោះទៅឲ្យពស់ស្អែចប្រហារ ។ ខណៈនោះ ព្រះពជា
ដែលទ្រង់ប្រាំងមានជ័យជំនះទ្រង់យាងមកពាន់កាលវេលាដ៏សាហាវនោះ ។
ដឹងជាក់ជាព្រះពជបុត្រមកដល់ហើយ ព្រះនាងយក្ខិនីដែលកំពុងសំដែង
អាការជើញាប់ញ័រធ្លាក់ខ្លួនទៅក្នុងវេរាមួយរំពេច ។ ព្រះនាងចាញ់ចារមីនឹង
រកមធ្យោបាយពុំបានព្រមពាំងនឹកញ្ញាសព្រះពជបុត្រមហាមាកទ្រង់ស្តុះលោត
ជាំក្បាលខ្លួនឯងធ្លាក់ទៅក្នុងពាង ។ រីឯសត្វអាសីរពិសកាលបើបានដល់
តណ្ហាប់ដៃហើយ ក៏ពុំមានបង្អង់ដល់មួយរំនាទី ក៏ចិកប្រហារជីវិតបង់ ។

ព្រះពជាទ្រង់អស្ចារ្យនឹងអំពើយោរយៅដ៏ក្រៃលែងនេះ ។ ប៉ុន្តែ ទ្រង់
មិនដឹងគិតធ្វើដូចម្តេច ព្រោះព្រះនាងយក្ខិនីរងគ្រោះស្លាប់បង់ជីវិតទៅហើយ
ព្រះនាងក៏ត្រូវជាមាតារបស់ព្រះអង្គដែរ ។ ព្រះពជាក័យន្ធត់ចូលទៅស្រាយ
ចំណងព្រះអគ្គមហេសីព្រមពាំងព្រះពជបុត្រ នាយឆ្មាំ កិរិយានឹងពួកញាតិ
សោយសៅគា ទឹកអាណិតជាពន់ពេក ។ តមក ព្រះមហាក័ត្រក៏
សោយពជ្ឈជាសុខសាន្តជាមួយព្រះពជវង្សបុត្រធីតា ក្នុងព្រះពជធានី ជា
អង្វែងតាល ។

ជាអាសានរឿង នាងទេពធីតាចិត្តសប្បុរសពាំង ៦ អង្គលុះផុតសង្ឃរកំចាន់ទៅចាប់បដិសន្ធិនៅឯទេវលោកនាយ ចំណែកនាងទេពធីតាក្មេងជាងគេ ដែលមានប្រាជ្ញាឈ្លាសវៃ បានដួយព្រះរាជបុត្រីចាន់ទៅកើតនៅឋានទេវលោកដ៏ខ្ពង់ខ្ពស់ជាងគេជាសុខសាន ។ ឯយាយទេពចង្រៃញ៉ែរញ៉ាក់ចង្អាប់ពីប្តូនាព្រះរាជបុត្រីត្រឡប់ទៅឋានវិញ ត្រូវទេពនិករពាំងអស់បំបរបង់បណ្តេញចេញ ពីតន្លែងលែងឲ្យនៅជាមួយ ។ យាយទេពញាសគេណាស់ក៏ទៅចងកសម្លាប់ខ្លួនមួយរំពេច ធ្លាក់ទៅឯនរក ៨រយោជន៍ ។ ឯព្រះនាងយក្ខិនី ជាមាតាព្រះរាជា ដែលឥតធម៌មេត្តា ចិត្តដូចតិរច្ឆានលុះដាច់ជន្មាយុក្តាមទៅ ក៏ទ្រាក់ដាំក្បាល ជ្រមុចទៅក្នុងខ្លុះភ្លើងជាមួយយាយទេពជាអាន្តរិកប្ប ។ នេះគេស្រ័យផលនៃសេចក្តីឈ្នានិសន្ធិសេចក្តីភ្យាចាទ ។

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

ប្រវត្តិនិក្រុងឧត្តុង្គ

លោក ចាប-ពិន រៀបរៀង

ទីក្រុងឧត្តុង្គចាប់ផ្តើមកសាងឡើងនៅសតវត្សទី ២២ នៃពុទ្ធសករាជ សតវត្សទី ១៧ នៃគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យ-ជេដ្ឋាទី ២ ដូចមានចែងក្នុងព្រះរាជពង្សាវតារប្រទេសកម្ពុជាតទៅនេះ :

ក្នុងពុទ្ធសករាជ ២១៦៤ គ្រិស្តសករាជ ១៦២០ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាជាអម្ចាស់ដីតែលើតូ្បង ស្តេចគង់នៅព្រះរាជវាំងល្វាឯម (ស្រុកព្រៃល្វាផ្អែម) ទ្រង់នាំព្រះអគ្គមហេសីព្រះស្នំក្រុមការសេនាបតីនិងនាម៉ឺនសព្វមុខមន្ត្រីខ្វាក់ការពាំងពួន ចុះព្រះទីនាំងនាវាស្តេចយាងទៅប្រពាតនៅដំបន់អូរត្រែងលាយ ក្នុងខេត្តសំរោងទង ទ្រង់ប្រថាប់នៅព្រះពន្ធាជាយូរថ្ងៃ រួចស្តេចយាងទៅក្រសាលនៅទីតាដុង យាយជ័យ ទ្រង់ទតឃើញទីជួលមួយនៅជិតស្រះកែវជាទីមានទេសភាពល្អ ក៏ទ្រង់ចាប់ព្រះរាជ-ហរិទ័យហើយទ្រង់មានព្រះតម្រាស់នឹងមន្ត្រីខ្វាក់ការពាំងពួន មានហោរាធិបតីជាដើមថា "យើងចង់សាងព្រះរាជវាំងគង់នៅទីនេះ តើអស់អ្នកពាំងពួនយល់ថាម្តេច? " ។ ទកញ្ញីហោរាធិបតី មុំ គន់គូរពិនិត្យមើលទីជីនោះ

ដោយក្បួនហោរាសាស្ត្រហើយក្រាបបង្គំទូលថា " ខ្ញុំនេះមានដឃកូមិស្ស
ណាស់ត្រូវតាមក្បួនទាយថា ទឹងមានជ្ញឹតបរុតដះឈ្នះអស់សត្រូវទាំង ៨
ទិស " ។

ព្រះរាជាទ្រង់ជ្រាបដូច្នោះ ទ្រង់ចាត់ទុកញ៉ាក្រឡាហោម តែវ ឲ្យជា
នាយកចាត់ការកសាងព្រះរាជវាំងនៅដំបន់ស្រះតែវនោះ, ទ្រង់ចាត់ហើយ
ស្តេចត្រឡប់មកព្រះបរមរាជវាំងល្អាងមកវិញ ។

ទុកញ៉ាក្រឡាហោមតែវកំពង្គាប់ទៅចៅហ្វាយស្រុកឲ្យកណ្តាបណ្តា
ពស្ត្រគាប់ឈើមកធ្វើជាព្រះបរមរាជវាំងតាមព្រះរាជបញ្ជា ។ លុះប្រមូល
គ្រឿងសម្ភារៈបានសព្វគ្រប់ហើយ ទុកញ៉ាក្រឡាហោម តែវ បង្គាប់មេ
ការឲ្យចាប់ផ្តើមចាត់ការលើកដីធ្វើជាបន្ទាយមានប៉មដុំវិញ សង់ជាព្រះរាជ-
មន្ទីរ ព្រះរាជដំណាក់ធំតូច ទឹងបុងព្រះរាជកោង ប្រមាណ ១០ ខែទើបរួច
ស្រេចហើយយកសេចក្តីក្រាបបង្គំទូលសូមទ្រង់ជ្រាបសព្វគ្រប់ប្រការ ។

លុះទ្រង់ជ្រាបហើយ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាជាអម្ចាស់ដ៏វិត
លើតួន ស្តេចចេញចាកព្រះបរមរាជវាំងល្អាងមក ទ្រង់ឡើងគង់ព្រះទីនាំង
នាក់ធ្វើព្រះរាជដំណើរតាមផ្លូវទន្លេសាប មួយអាទ្ទើងដោយព្រះអគ្គមហេសី
ព្រះស្នំក្រមការ ព្រះរាជវង្សាវុំវង្ស សេនាបតី នាម៉ឺនសព្វមុខមន្ត្រី
ខ្ញុំព្រះការគ្រប់ក្រុមជារាជបរិពារ, ដល់តំពង់តាដុង យាយជ័យ ទ្រង់

ប្រថាប់នៅទីនោះ ៣ រាត្រីទ្រង់ព្រះរាជបញ្ញត្តឲ្យហៅទីនោះថា " កំពង់-ហ្ន " ហើយទ្រង់ត្រាះរាជបញ្ជាក្នាក់ងារមុខក្រសួងឲ្យរៀបចំធ្វើព្រះរាជពិធីឡើងព្រះរាជកំនត់ថ្មី ទំមន្តព្រះសង្ឃរាជគណៈចម្រើនព្រះបរិត្ត ៣ ថ្ងៃ ចូលព្រះរាជពិធីនៅថ្ងៃ ៩ កើត ខែផល្គុន ឆ្នាំវក ចោស័ក ពុទ្ធសករាជ ២១៦៤ គ្រិស្តសករាជ ១៦២០ ហើយព្រះរាជវង្សានុវង្ស ព្រះអគ្គមហេសី ព្រះស្នំត្រមការ ៗ សេនាបតី មន្ត្រីខ្ញុំព្រះរាជការជារាជបរិពារ ហែស្តេចឡើងពីកំពង់ហ្ន ចូលទៅគង់ក្នុងព្រះរាជកំនត់ថ្មី រួចឲ្យរៀបធ្វើព្រះរាជពិធីសម្ពោធព្រះនគរ ៣ ថ្ងៃទៀត ដោយមានល្បែងមហោស្រពគ្រប់បែបជាទ្បាក់អធឹកអធំក្រៃពេក ទើបទ្រង់តាំងនាមព្រះនគរ (ទីក្រុង) ថា " ព្រះបរមរាជកំនត់មហានគរទុគ្គព្ភជ័យ ប៊ុរីរម្យទុគ្គមរាជធានីវេសនដ្ឋាន " ។

ចំណែកព្រះរាជវង្សានុវង្ស សេនាបតី នឹងមន្ត្រីខ្ញុំព្រះរាជការទាំងពួងក៏តាំងទីភូមិនៅជាសុខដុំដុំរៀងដិតព្រះបរមរាជកំនត់នោះ ប្រកបដោយសេចក្តីសុខសប្បាយ ។

សេចក្តីបញ្ជាក់ៈ

មានឯកសារ ១ បញ្ជាក់ថា :

តាជុនជាស្វាមី យាយដួយជាភរិយា ជាម្ចាស់ទីដែលកសាងព្រះបរមរាជវាំងនោះ គាត់ជាអ្នកមានទ្រព្យសម្បត្តិសុកសប្បាយមានខ្ញុំ

កំដរច្រើន ជាចាស់ទុំ មានមុខមាត់ជាធំគេនៅស្រុកនោះ តែដល់រដូវលំ-
ហើយទឹកស្រក ត្រីចុះទៅមាត់ទន្លេច្រើន គាត់ធ្វើរោងមួយនៅទីនោះ
ជារោងធំទូលាយសម្រាប់គាត់នាំមនុស្សម្នាទៅធ្វើត្រីសាច់ប្រហុកផ្អក ។
អស់ពួកនាម៉ឺនសព្វមុខមន្ត្រីក៏តែងតែទៅសំណាក់អាស្រ័យធ្វើ ត្រីសាច់នៅ
រោងនោះដែរ, តាដុងយាយដ័យជាម្ចាស់រោងតែងទទួលរាក់ទាក់រាប់អាន
អស់លោកនាម៉ឺនទាំងនោះ តែងរៀបចំអាហារជូនពីសាតាមសេចក្តី
សប្បាយរាល់ពេលដែលទៅសំណាក់ ។

ព្រះករុណាព្រះបាទសម្តេចព្រះដ័យដង្គា ទ្រង់សព្វព្រះរាជហឫទ័យ
យកទីទួលរបស់តាដុងយាយដ័យនោះធ្វើព្រះបរមរាជវាំង ហើយទ្រង់
សន្មតនាមព្រះរាជធានីថ្មីនោះថា "ក្រុងទត្តុង្គមានដ័យ" គឺពាក្យថា ទត្តុង្គ
យកតាមឈ្មោះតាដុង ពាក្យថា មានដ័យ តាមឈ្មោះយាយដ័យដែល
ជាម្ចាស់ទីទួលនោះឯង ។

សេចក្តីសង្ខេប :

មុនបន្ទាប់សម័យទត្តុង្គ ប្រទេសខ្មែរយើងមានព្រះរាជធានីនៅល្វា-
ឯម (ស្រុកព្រៃល្វាផ្អែម) លុះដល់ពុទ្ធសតវត្សទី ២២ គ្រិស្តសតវត្សទី
១៧ ព្រះករុណាព្រះបាទសម្តេចព្រះដ័យដង្គាទី២ ស្តេចចេញចាកព្រះ
រាជធានីនោះមកគង់នៅព្រះរាជធានីទត្តុង្គមានដ័យ ក្នុងពុទ្ធសករាជ ២១៦៤
គ្រិស្តសករាជ ១៦២០ ។

ទីក្រុងទត្តឝ្គមានជ័យ មានព្រះមហាក្សត្រគង់នៅអស់ថ្ងៃរៀលជាង ២ សតវត្សគឺ ២៤៣ ឆ្នាំ ។ បណ្តាវង្សតាលពាន់នោះ ចំពោះវង្សតាលព្រះបាទអង្គជ័យ (ហៅព្រះសង្កា) ដែលទ្រង់សោយរាជ្យនៅពុទ្ធសករាជ ២៦៧៣-២៦៧៩ គ្រិស្តសករាជ ១៣១០-១៧៣៦ ស្តេចចេញចាកទីក្រុងទត្តឝ្គមានជ័យទៅគង់នៅបន្ទាយលង្វែក ជាទីក្រុងចាស់ដែលធ្លាប់មានមកហើយ ។ ពេលដែលព្រះបាទអង្គជ័យស្តេចទៅគង់បន្ទាយលង្វែកនោះ, ទីក្រុងទត្តឝ្គនៅពុំមានព្រះមហាក្សត្រគង់. ក្រោយពីនោះ ២០ ឆ្នាំទើបមានព្រះមហាក្សត្រគង់នៅឡើងវិញ ។

បណ្តាព្រះមហាក្សត្រដែលគង់នៅក្រុងទត្តឝ្គ ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមា (ព្រះអង្គឌួង ព្រះបរមរាជ) នឹងព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណរាជ) ទ្រង់បានស្ថាបនាទត្តមន្ទីរជាច្រើន គឺព្រះករុណាព្រះបរមរាជ ទ្រង់បានស្ថាបនាផ្សារថ្មល់ពីទត្តឝ្គទៅតំពតចម្ងាយ ១៤០ គីឡូម៉ែត្រ, ព្រះករុណាព្រះសុវណ្ណរាជ ទ្រង់បានស្ថាបនាប្រាសាទ ព្រះពុទ្ធដំណាក់ជាច្រើន, គ្រឹះស្ថានមហាស្រព, បណ្ណាល័យដោយគ្រឿងឈើ, ឥឡូវនេះបាក់បែកអស់ទៅហើយ ។

ដល់មកពុទ្ធសតវត្សទី ២៥ គ្រិស្តសតវត្សទី ១៩ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ស្តេចចេញចាកព្រះរាជធានីទត្តឝ្គមានជ័យមកគង់នៅព្រះរាជធានីភ្នំពេញក្នុងពុទ្ធសករាជ ២៤០៦ គ្រិស្តសករាជ ១៨៦៣ ។

ទីក្រុងខេត្តឆ្ពោះមានដំយ ជាទីក្រុងចាស់មុនបន្ទាប់ក្រុងភ្នំពេញ ឋិតនៅ
ចន្លោះទិសពាយ័ព្យនឹងទិសខេត្តរនៃក្រុងភ្នំពេញ ចម្ងាយ ៤០ គីឡូម៉ែត្រ។

សព្វថ្ងៃ ទីក្រុងខេត្តឆ្ពោះ ជាឈ្មោះស្រុកមួយ ហៅថា "ស្រុកខេត្តឆ្ពោះ
ក្នុងទីរួមខេត្តកំពង់ស្ពឺ ជាក្រុងមានទេសភាពចាប់រវៀបរយដោយមានភ្នំ
ព្រះរាជទ្រព្យ (ភ្នំអង្គារស) នឹងភ្នំត្រែត្រឹងជាដើមជាលំអ មើលឥតមានឆ្អែត
ភៅយើញកំពូលភ្នំទាំងនោះ ស្រួចខ្ពស់ត្រដែតត្រដឹមគួរឥតរាយ ។
នៅលើកំពូលភ្នំព្រះរាជទ្រព្យ មានព្រះមហាចេតិយជាច្រើន សុទ្ធតែ
វិចិត្រដោយក្បូរក្បាច់រចនាជាស្នាដៃនៃសិល្បការីខ្មែរដែលជំនាញ ។ ក្នុង
គ្រានោះ ជាព្រះចេតិយបញ្ជាព្រះអដ្ឋធាតុនៃព្រះរាជា ព្រះអគ្គមហេសី
ព្រះរាជវង្សាឧវង្សក្សត្រា ក្សត្រី ជាបុព្វបុរសរបស់ព្រះរាជវង្សខ្មែរ ។
បណ្តាព្រះចេតិយទាំងនោះ ព្រះចេតិយដែលចាស់ជាងគេ គឺព្រះចេតិយ
ដែលបញ្ជាព្រះអដ្ឋធាតុនៃព្រះស្រីសុរិយោព័ណ៌ ដែលទ្រង់ព្រះទិវង្គត
ពីពុទ្ធសករាជ ២១៦៣ គ្រិស្តសករាជ ១៦១៩ ។

ត្រង់ទីព្រះបរមរាជវាំងសារពើយុត្ត ដែលជាព្រះរាជដំរិសនដ្ឋាន
សម័យខេត្តឆ្ពោះមានដំយ, ឥឡូវក្លាយទៅជាទីវត្ត ហៅតាមពាក្យសាមញ្ញ
ថា "វត្តកងរាំង" តាមផ្លូវការថា "វត្តហិរញ្ញវត្ថុជនបទី" ហើយមានវត្តអា
រាមឯទៀតជាច្រើន នៅជិត ។ ទីនោះ មានវត្តព្រះបាទឆ្ពោះ នឹងវត្តកាំងចាស់ជា
ដើម ដែលជាអាស្រ័យនៃពួកបព្វជិតពុទ្ធដំណើរសរបស់ជាតិខ្មែរយើង ។

កំណត់ដំណើរប្រវត្តិការណ៍

ពិធីបុណ្យដងស្ពារព្រះសក្យមុនីចេតិយ ជាផ្លូវការ នៅមុខស្ថានីយអយស្ទ័យយាន ក្រុងភ្នំពេញ

ស្រី-អ៊ូ រៀបរៀង

កាលពីថ្ងៃសៅរ៍១៥ កើតខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥០១ (៣-៥-៥៨) នៅមុខស្ថានីយអយស្ទ័យយាន មានធ្វើពិធីបុណ្យដងស្ពារព្រះសក្យមុនីចេតិយ ក្រោមព្រះពរជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះឧបយុវរាជ ។

នៅវេលាម៉ោង ១៧ នឹង ៣០ នាទី មានការជួបជុំព្រះសង្ឃចំនួន ៤ គណៈ, ព្រះរាជវង្សានុវង្ស, ប្រធានសភាចំនួន ៤ នាយករដ្ឋមន្ត្រី, សមាជិករាជរដ្ឋាភិបាល សមាជិកសភាចំនួន ៤. មន្ត្រីគ្រប់ដំណែន ចំនួនជាច្រើន ព្រមទាំងឧបាសកឧបាសិកា បានមកប្រជុំ បានស្តេចយាន បានអញ្ជើញមកដល់ ។

ម៉ោង ១៨ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្តេចព្រះឧបយុវរាជ ស្តេចយាងមកដល់ ដោយមានឯកឧត្តមឧត្តមសេនី-ផែត, ឯកឧត្តម សាន-យុន លោកគួ-រុន, លោកវរសេនីយ៍ទោ មាស-ហ៊ុល, លោក

វរសេនីយត្រី ស-ហោ ព្រមទាំងព្រះរាជបរិពារ ឃានហែព្រះអង្គផង ។

ពេលនោះ ឥហានក្រុមរក្សាព្រះអង្គ , ក្រុមខេមរភូមិន្ទ , ក្រុមឥ-ហានធំត្រយោង ក្រុមឥហានដើងទឹក ក្រុមឥហានរថក្រោះ ក្រុមយុវន យុវតី ពាជសង្គមនិយមខ្មែរ ក្រុមកូនកងវរសេនាតូចរក្សាព្រះអង្គ ឃានធ្វើការវិភជ្ជកិច្ចយ៉ាកិត្តិយស ចំពោះព្រះរាជាតាមទម្លាប់ ។

ក្នុងខណៈនោះ មហាមេឃស្រទំត្រជាក់ បង្អោរចុះនូវតំណក់ទឹកយ៉ាងល្អិត ។ ហាក់ដូចជារួមធ្វើពិធីបុណ្យនមស្ការព្រះសព្វមុនីចេតិយនោះជាមួយឥទ្ធិបរិស័ទផងដែរ ។

ចំណែកផ្ទៃបន្ទោរកំបោញញន្ធឹជាលច្រៀតពេញអាកាស ដូចជាឋតបេតពតិមានៃពិធីបុណ្យនេះ ពាំងផ្គរកំបន្ធឹសំឡេងរំងំ ហាក់ដូចជាស្រែកថ្វាយស័ព្ទសាធុការពរ នាំឲ្យពួកទេវាសកទេវាសិការីតែកយ ពន់ពេក

បន្ទាប់មក ព្រះតុណាជាអម្ចាស់ដីវិតលើតួង ស្តេចយាងចូលក្នុងព្រះពន្ធាកិត្តិយស ដោយមានយុវជន ១ រូប យុវតី ១ រូប បង្ហិនទង់ជាតិទង់ទង់សាសនាឡើងសន្សឹម ។ ទង្គឹមគ្នា ជាកិច្ចផ្តើមនៃការបើកពិធីបុណ្យ ។

ឯក្រុមសិស្សអនុវិទ្យាល័យនារី ទង់ក្រុមសិស្សសាលាគរុវិជ្ជា កំពុងច្រៀងបទនគរាជ ទង់បទសរសេញ្ញ ដោយបទ្ធឹឡើងនូវសំឡេងស្រទន់ព្រមៗគ្នា ដ៏ពិរោះគួរសរសើរ ។

តមក លោក ផូ-ត្រឿង រដ្ឋមន្ត្រីក្រសួងធម្មការ សង្គមកិច្ចនិងការងារ

ចូនថ្លែងសុន្ទរកថាមួយ ដ៏ពីរោះក្បោះក្បាយ អាងនាមពាជ្ឈាតិចុលនឹង
ក្នុងនាមផ្ទាល់របស់លោក សំដែងនូវអំណរព្រះមហាករុណាគុណនឹង
សេចក្តីកតញ្ញូដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាថ្លៃវិសេសនឹងសម្តេចព្រះ
បិតាឯកពាជ្យជាតិ ដែលទ្រង់បានស្តេចយាងមកជាព្រះពាជាធិបតី ក្នុងពិធី
បុណ្យនមស្ការព្រះសក្យមុនីចេតិយ ហើយថ្លែងរៀបរាប់អំពីប្រវត្តិនៃព្រះ
បរមសារីរិកធាតុ នឹងសេចក្តីគោរពចំពោះព្រះបរមអដ្ឋិធាតុ ដែលដំកល់
នៅលើព្រះសក្យមុនីចេតិយ ព្រមទាំងថ្លែងអំពីសាសនធម៌នៃព្រះសក្យមុនី
ដែលបានមកប្រតិស្ឋាន ក្នុងប្រទេសកម្ពុជា ជាច្រើនសតវត្សមកហើយ
ដោយព្រះមហាក័ត្រខ្មែរ នឹងប្រជាជាតិខ្មែរ មានដំណឹយ៉ាងម៉ុតមាំ
ចំពោះព្រះពុទ្ធាភិនិ ។ ព្រះពុទ្ធនុភាពនោះ តំបានតតាំងនឹងជាថិរកាល នឹងរុង
រឿងជានិរន្តរ៍ ហាក់ដូចជាព្រះសម្ពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ។

លុះចប់សុន្ទរកថារបស់លោករដ្ឋមន្ត្រីក្រសួងធម្មការហើយ ទើបលោក
ចាប-ពិន នាយការិយាល័យនៃក្រុមជំនុំនេមទម្លាប់ខ្មែរ នៅពុទ្ធសា-
សនបណ្ឌិត្យបានទៅថ្វែងសេចក្តីក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ដ៏វិសេ
លើត្បូង នឹងសម្តេចព្រះព្រះបិតាឯកពាជ្យជាតិ មានសេចក្តីដូចតទៅ៖

សូមព្រះតេជះដ៏កល់លើត្បូង!

សូមព្រះពាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ដ៏វិសេ នឹងសម្តេច
ព្រះបិតាឯកពាជ្យជាតិ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

រីឯនេះ ទូលព្រះបង្គំជាខ្ញុំ ជាអ្នកនាំពុទ្ធបរិស័ទមស្ការព្រះសក្យ-
មុនីចេតិយ សូមព្រះគុណជាអម្ចាស់ដ៏វិតលើត្បូង នឹងសម្តេចព្រះបិតា
ឯកវាជាតិ ទ្រង់ព្រះមេត្តាប្រោសទទួល ព្រមទាំងពុទ្ធបរិស័ទទាំងអស់
ទទួលតាមទាំងបាលីទាំងសម្រាយ ๑ សង្កាត់ម្តង ។ ។ រួចហើយ
លោក ចាប-ពិន កាន់ផ្តើមនាំមស្ការដកបដលាចប់ ។

តមក ព្រះគុណជាអម្ចាស់ដ៏វិតលើត្បូងនឹងសម្តេចព្រះបិតាឯកវាជ-
ជាតិ ព្រមទាំងព្រះរាជបរិពារទ្រង់បាននិស្ចយយាងមៃប្រទក្សិណព្រះសក្យ-
មុនីចេតិយ ដោយមានលោក ចាប-ពិន ជាអាចារ្យនាំព្រះរាជដំណើរ ។
រួចព្រះនរបតីនឹងព្រះបិតាឯកវាជាតិ ទ្រង់បូជាគ្រឿងសក្ការៈមានផ្កា
កម្រងជាដើម ថ្វាយចំពោះព្រះបរមសារីរិកធាតុ ។ បន្ទាប់មក មន្ត្រីត្រប់
ដំណែងទាំងឥហានទាំងស៊ីវិល នឹងពុទ្ធបរិស័ទទាំងឡាយ បាន
ថ្វាយគ្រឿងសក្ការបូជា ចំពោះព្រះបរមសារីរិកធាតុនោះដែរ ។

ក្រោយពីនោះ ព្រះគុណជាអម្ចាស់ដ៏វិតលើត្បូង នឹងសម្តេចព្រះ
ទេបយុវរាជស្តេចយាងឡើងគាន់ព្រះពន្លា ព្រះសង្ឃគង់ចំរើនពុទ្ធដ្ឋយមង្គល ។
លុះចប់តិចូហើយ នៅវេលាម៉ោង ๖ នឹង ๔๐នាទី ព្រះគុណជា
អម្ចាស់ដ៏វិតលើត្បូង នឹងសម្តេចព្រះទេបយុវរាជ ស្តេចយាងត្រឡប់មកគាន់
ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារជវែល ហៃព្រះអង្គផង ។

តមកទៀត ពួកពុទ្ធបរិស័ទបានរួបរួមគ្នាធ្វើវិសាខបូជា សូត្រធម៌រំលឹកព្រះគុណព្រះរតនត្រ័យ ដរាបទល់អរុណរះ ក្រោមអធិបតីភាពនៃប្រធានពុទ្ធសមាគមទាំង ៣ ដោយសទ្ធានឹងសេចក្តីជ្រះថ្លា ។

ពិធីដាក់បាត្រព្រះសង្ឃជាង ៥០០ អង្គ នៅមុខព្រះសក្យមុនីចេតិយ

ដល់ព្រឹកឡើងថ្ងៃអាទិត្យ ១ កេីតខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស. ២៥០១ (៤-៥-៥៨) នៅមុខព្រះសក្យមុនីចេតិយ មានការជួបជុំពុទ្ធបរិស័ទជាច្រើនពាន់នាក់ មានគ្រឿងសំលៀកបំពាក់យ៉ាំសមរម្យ ភាន់ខ្លួ គ្រឿងសក្ការៈបូជានឹងចង្ហាន់ មានទឹកមុខស្រស់ញញឹមពោរពេញដោយសោមនស្សជាយ៉ាងក្រៃលែង ខ្ញុះឈរ ខ្ញុះអង្គុយ នាំចាំដាក់បាត្រព្រះសង្ឃ ។

វេលាម៉ោង ៨ និង ៤០ នាទី លោកជូ-ត្រឿង រដ្ឋមន្ត្រីក្រសួងធម្មការ បានអញ្ជើញមកដល់ទីនោះ ដោយមានមន្ត្រីក្រសួងធម្មការជូនដំណើរមកផង ។

បន្ទាប់មក ព្រះសង្ឃជាង ៥០០ អង្គ និមន្តបិណ្ឌបាតតាមដងវៃនៃពួកពុទ្ធបរិស័ទ ជាលំដាប់គ្នាមក ។

ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ និងពិធីបុណ្យវិសាខបូជា បានចប់សព្វគ្រប់ ក្រោយពេលដែលដាក់ទង់ជាតិនឹងទង់សាសនា ដែលបានបង្កតពីថ្ងៃទី ៣ ខសភានោះ ។

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

-វហន, បុ. កិរិយាញាប់ញ័រនៃរាងកាយ (សេចក្តីព្រួយចិត្ត) ។ - *វិទ្យា*, ស្ត្រី. វិជ្ជាទាយតាមលក្ខណៈនៃរាងកាយ ។ -*សំស្ការ*, -*កម៌ន* នបុ. អំពើពាក់ព័ន្ធរាងកាយ ។ - *សំហតិ* ស្ត្រី. កិរិយាដាប់ដិតស្ថិទ្ធនៃកាយ ។ -*សំហិតា* ស្ត្រី. គម្ពីរសំហិតា ឬ សំឡេងនៃស្មៅនឹងព្យញ្ជនៈក្នុងអង្គនៃវចនៈមួយ ។ ។ - *ស្កន្ធ* បុ. ផ្នែកនៃវិជ្ជា ។ - *ស្បតិ* បុ. កិរិយាប៉ះពាល់នៃអង្គ ។ -*ហារ* ឬ -*ហរិ* បុ. កថា ឬ កិរិយាធ្វើអាការនៃកាយក្នុងពេលនិយាយ ។ - *ហ៊ីន* គុ. នៃលតតអង្គ ។ - *ហ៊ីនស* បុ. តាមព្រះពាមទេព ។ *អង្គាធិប* បុ. ព្រះរាជាក្នុងក្រុងអង្គៈ ។ *អង្គានុកូល* គុ. នៃលអនុកូលទៅតាមអង្គ ។ *អង្គានុលេបន* នបុ. កិរិយាប្រស់ព្រំរាងកាយដោយគ្រឿងក្រអូប ។ *អង្គាភ្ជ*, *អង្គាភ្ជន* បុ. ពន្លែងដូតខ្លួន ។ *អង្គីការណ* នបុ. ឬ *អង្គីការ* បុ. កិរិយាកំណត់ កិរិយាព្រមទទួល ដីសម្បទាន ។

អង្គៃ បុ. ឈ្មោះមនុស្សផ្សេង ។ ។ តាមព្រះរាជាក្នុងក្រុងអង្គៈ ។ ពហុ. ប្រជាជននៃនអង្គៈ (នៅបង្គំលុសឲ្យថ្ងៃនេះ) ដំបន់ភគស្សរ ។

(មានត)

ដំណឹងពិសេស

មជ្ឈដ្ឋានព្រះពុទ្ធសាសនាមួយធំដែរ ស្ថាបនាឡើងនៅទីក្រុងវ៉ាស៊ីនតុន

តាមសារពត៌មានក្នុងស្រុកខ្លះ បានសរសេរថា មជ្ឈដ្ឋានព្រះពុទ្ធ-សាសនាមួយជាលើកដំបូង នៅក្នុងសហរដ្ឋអាមេរិក ធំស្ថាបនាឡើងនៅក្រុងវ៉ាស៊ិនតុន. ក្រោមកិច្ចចាត់ចែងនៃរដ្ឋបូតនានានៃប្រទេសចាំងឡាយ ដែលគាន់ព្រះពុទ្ធសាសនា ។


ប្រជាជនមិត្តពុទ្ធសាសនាអាមេរិកាំងក៏បានចំនុកបំរុងអង្គការនេះដែរ។

មជ្ឈដ្ឋាននេះនឹងទទួលព្រះសង្ឃគ្រប់គណៈ ខាងព្រះពុទ្ធសាសនា ទៅសំណាក់អស្រ័យទៅពីនោះ ។

មជ្ឈដ្ឋាននេះ មានចែកជាសណ្ឋានដូចតទៅ ៖

មួយបន្ទប់សម្រាប់អាន, មួយបន្ទប់សម្រាប់បណ្ណាល័យ, មួយបន្ទប់ជាតន្ទែងសំណាក់សម្រាប់ព្រះសង្ឃ ដែលនិមន្តទៅគាន់សហរដ្ឋអាមេរិក ។ មិនតែប៉ុណ្ណោះ, មជ្ឈដ្ឋាននេះនឹងមានចោះពុម្ពផ្សាយដំណឹងផ្សេងៗ ខាងព្រះពុទ្ធសាសនាផង ។

សព្វថ្ងៃ, ដើម្បីឲ្យមជ្ឈដ្ឋាននេះ បានកើតជារូបរាងពិតប្រាកដឡើង, គេបានបង្កើតគណៈកម្មការមួយ សម្រាប់ចាត់ចែងការ ដែលមានអង្គទូតប្រទេសកូមា ប្រទេសកម្ពុជា ប្រទេសសៀមជាសមាជិក ព្រមទាំងជ្រើសរើសយកអ្នកជំនាញការអាមេរិកាំងបីនាក់ទៀត ឲ្យមកជួយចាត់ចែងកិច្ចនេះផង។



កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ



ឆ្នាំទី ៣០ លេខ ៦ ខែមិថុនា

ព.ស. ២៥០០ គ.ស. ១៩៥៨

– ភ្នំពេញ –

K-1
58-6



ភ្នំពេញសន្ទនា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ ព្រះមហា ជា-ខាត រៀបរៀង	៤៧៩
	- សិល្បៈពុទ្ធសាសនា ព្រះឧបាលីវង្ស សូរ-ហាយ រៀបរៀង	៤៩៥
	- ព្យែធមិពុទ្ធសាសនា ព្រះញាណវីរៈ រ៉ាន់-សាន់ រៀបរៀង	៥១១
	- សេចក្តីពិចារណានៃពុទ្ធសាសនិកជនម្នាក់ (តមក) លោក ភ័យ-ប៊ុក រៀបរៀង	៥១៩
ផ្នែកអក្សរសាស្ត្រ		
	- រឿងទេវនែ្ទរបស់អម្រឹតក្សត្រីម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ	៥២៣
	- រឿងសាមកុក (តមក) ឧកញ៉ា ន្ហ-កន ប្រែ	៥៣១
	- រឿងសំណាញ់ព័រនាក ចង់ពង្រឹងទឹកសមុទ្រ លោក ទៀង-តៃ-ឈុន ប្រែរៀបរៀង	៥៤១
	- រឿងព្រេងនឹងរឿងបុរាណនៃប្រទេសជប៉ុន (តមក) លោក ភ័យ-ប៊ុក ប្រែរៀបរៀង	៥៥១
	- ប្រវត្តិវិហារអង្គរសេ លោក ចាប-ពិន រៀបរៀង	៥៨៣
	- សុភាសិតសារធម៌ប៊ែរ្យ លោក ភ័យ-ប៊ុក ប្រែរៀបរៀង	៥៦០
ផ្នែកកំណត់ឧដ្ឋប្រវត្តិការណ៍		
	- ពត៌មានផ្សេង ។ របស់ក្រសួងធម្មការ	៥៦៣
	- ពិធីបុណ្យស្រោចទឹកថៅអធិការ លោក ឯន-បង់ រៀបរៀង	៥៦៩
	- វចនានុក្រមសំស្ក្រឹត ខ្មែរ (តមក) ព្រះមហាជ័ង-ខាត រៀបរៀង	៥៧៤

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជាវ ២៣០/០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

-Histoire du Bouddhisme au Cambodge (suite) par Vén. *PANG-KHAT* 479
- Art bouddhique par Vén. *SOR-HAY* 495
-Culture bouddhique par Vén. *VANN-SADUM* 511
- Réflexion d'un Bouddhiste (suite) par *M. RAY-BUC* . . . 519

PARTIE LITTERAIRE :

-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* 523
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . . 531
-Légende des « Deux Amis qui voulaient tarir la mer » traduite par *M. TIANG-TAY-CHHUN* 541
-Conte et Légende du Japon (suite) traduits par *M.RAY-BUC* 551
-Histoire du Temple Adharas (Oudong) par *CHAP-PIN* . . . 553
-Proverbes perses par *M. RAY-BUC* 560

NOTES ET CHRONIQUES :

-Chronique du Ministère des Cultes
-Cérémonie du Bain de Chau Athikar 563
par *M. EN-PANG* 569
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT* 574

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

ផ្នែកសាសនា

ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ជ័ង - ខាត់ រៀបរៀង

(តមក)

ប្រទេសនគរភ្នំពាក់ទន់រហូតទៅដល់ប្រទេសឥណ្ឌៀ ។ មានពាណិជឥណ្ឌៀម្នាក់ឈ្មោះ កៀ-សាំង លី «Kia-Seang-Li) បានមកលក់ដូរដល់ប្រទេសនគរភ្នំ ប្រហែលជាក្នុងគណ្ឋាល គិស្តសតវត្សទី ២ ហើយសរសើរថាប្រទេសយើងនេះចំរើនរុងរឿង ។ ហេតុនេះហើយបានជាក្នុងរជ្ជកាលព្រះបាទក្រុងចិនឆ្នាំមៀ (wou) គ.ស. ២៦២-២៨០ មានន័យយ៉ាថា ព្រះបាទហ្វាន់ចាន់ប្រទេសនគរភ្នំ បានបញ្ជូនពជទូតជាកន្ត្រៃមួយអង្គ ព្រះនាមស៊ូ-វូ (Sou-Wou) ឲ្យទៅកាន់ប្រទេសឥណ្ឌៀ (ប្រហែលជាខាងចុងគ្រិស្តសតវត្សទី២) ចុះសមុទ្រទៅកំពង់តៃវ-គីវ លីគីកំពង់តង្កោលៈ សព្វថ្ងៃនេះហៅថាតាកូបានៅជ្រោយមាឡាយូ ដែលជាដែនដីខ្មែរខាងបច្ចិមទិសទល់សមុទ្រឥណ្ឌៀ, ដើរសំពៅសៀរតាមឈូងសមុទ្រកាត់ស្រុកជាច្រើន មួយឆ្នាំបានដល់ទន្លេឥណ្ឌៀ (ទន្លេគង្គា)

ហើយធ្វើដំណើរតាមទូកទៅទៀត ចំនួន ៧០០០ លីបានដល់ទៅកដ
ឆានីស្តេចតណ្ឌៀ ។ លោកស៊ូ-ឡេវីយល់ថា ព្រះរាជានេះជាវង្ស
ម៉ារ៉ុង: ។ ព្រះរាជាអង្គនេះ ស្ទើចណាស់លាន់ព្រះនុស្ដថា នុហ្ម៉ា នៅ
ត្រើយសមុទ្រខ្ញុំមានមនុស្សដែរតើ! ហើយគ្រាស់បង្គាប់ឲ្យនាំពាដទូតខ្មែរ
ដើរមើលប្រទេសតណ្ឌៀ ។ ដល់ពេលត្រឡប់វិញ ព្រះរាជាតណ្ឌៀបាន
បញ្ជូនពាដទូតព្រះអង្គម្នាក់ឈ្មោះចិន-សុនឲ្យមកជាមួយពាដទូតខ្មែរផងព្រម
ទាំងនាំយកដង្វាយមានសេះប្រទេសយូចេ ៤ (សេះសន្ធពដែលមាននៅ
តាមជង្ហុនទន្លេសិន្ធុ) ជាដើមមកថ្វាយស្តេចខ្មែរ ។ ទាំងពៅទាំងមក ៤ ឆ្នាំ
បានដល់មកប្រទេសនគរភ្នំវិញ តែកាលនោះហើយដែលស្តេចក្រុងចិនព្រះ
នាមវ៉ូបានបញ្ជូនកាំង-ថៃ (Kang-Thai) នឹង ជូ យឹង (TChou-Ying) ជា
ឯកអគ្គទូតចិនឲ្យមកកាន់ប្រទេសនគរភ្នំ ក្នុងរជ្ជកាលព្រះបាទហ្វាន់-ស៊ុន
ទំនង់ជាក្នុងគ.ស. ២៥៩-២៣០ បានជួបពាដទូតតណ្ឌៀ ចិន សុន ហើយ
សាកសួរទំនៀមទំលាប់នឹងស្ថានភាពប្រទេសតណ្ឌៀផង ។

ប្រកពចិន មានដំណាលពីព្រះរាជានៅប្រទេសនគរភ្នំច្រើនព្រះអង្គ ។
ព្រះរាជាមួយអង្គ ប្រហែលជាខាងចុងគ្រិស្តសតវត្សទី ២ ទ្រង់ព្រះនាម
ហ្វាន់ម៉ុនឬហ្វាន់ ចេ ម៉ុន (ស្រីមារ:?) ជាព្រះរាជាគាំពុទ្ធសាសនា មាន
ភក្តាទុកាពល្បីល្បាញ ។ ប្រកពចិនរៀបរាប់ថា នៅនគរភ្នំមានព្រះរាជដីនជា

ស្តេចសាយពណ្ណជាទំនៀម ព្រះពន្ធនីមួយអង្គព្រះនាម លៀ-យី Feuille de Saule) ព្រះរូបធោមល្អល្អះដូចជាព្រះពន្ធកុមារ ហើយមានពាហ្មណ៍ម្នាក់ឈ្មោះ ហុន-ខៀន បានធ្វើសារមួយដែលទេពតាប្រទាន កំចុះសំពៅមកកាន់ប្រទេសនគរកុំ ព្រះនាងលៀ-យី លើកវេហ៍ពលទៅច្បាំងតនឹងព្រាហ្មណ៍ហុន-ខៀននោះ តែខ្លួបាត់ចេស្តាក៏ព្រមទទួលយកជាស្វាមី ។ ព្រះបាទហុន ខៀននឹងព្រះនាងលៀ-យីនេះ ជាបឋមក្សត្រ ។ រឿងព្រះបាទហុន-ខៀននឹងព្រះនាងលៀ យី តាមឯកសារចិននេះធ្វើយមកត្រូវគ្នានឹងសិលាចារឹកនៅមីសឺន (Myson) ក្នុង គ ស ៦៤៨ និយាយថា ព្រះបាទកៅណ្ឌិន្យបានប្រតិស្ឋានលិង្គនៃព ដែលទ្រង់បានពីអស្សត្ថាមន៍ជាបុត្រព្រាហ្មណៈមកដំកល់ទុកនៅក្រុងតាប៉ុរៈ បានព្រះនាងនាគីសោមាជាអគ្គមហេសី ហើយតាំងជាពង្សដំបូងនៃប្រទេសនេះឡើង។ សិលាចារឹកនៅប្រាសាទបក្សីចាំក្រុងពីគ ស ៨៤៨ ចែងទុកថា ព្រះបាទរុទ្រវរ្ម័នជាព្រះរាជាទីបំផុតសម័យនគរកុំ ជាព្រះពង្សតាំងមកពីព្រះបាទកៅណ្ឌិន្យនឹងព្រះនាងនាគីសោមា ។ ព្រះបាទហុន-ខៀននឹង ពះនាងលៀ យីរបស់ចិន ព្រះបាទកៅណ្ឌិន្យនឹងព្រះនាងនាគីសោមារបស់សិលាចារឹកមីសឺន គឺ ពះថោង នាងនាគជាបឋមក្សត្រិយ៍របស់ខ្មែរ នៅនគរគោកធ្មកក្នុងពង្សាវតារយើងពិតប្រាកដ ។ ឯកសារចិននិយាយតមកទៀតថា

ព្រះបាទហ៊ុន ទៀនទឹងព្រះនាងសៀវយីនេះ មានព្រះរាជបុត្រមួយព្រះអង្គ ហើយទ្រង់តែងតាំងឲ្យគ្រួតគ្រាប្រទេសសមន្តរាជ ៧ នគរ ។ តមក, មានព្រះរាជាតំណាងវង្សមួយអង្គនាម ហួន-ប៊ុន-ហួង (Houen-P'an-Houang) លើកទ័ពទៅច្បាំងដណ្តើមយកសមន្តរាជទាំង ៧ បាន ហើយ បញ្ជូនព្រះរាជបុត្រទឹងព្រះរាជនគ្គាព្រះអង្គទៅសោយរាជ្យដំនួសវិញ ។ ព្រះបាទហួន-ប៊ុន-ហួងនេះ ទ្រង់គ្គតក្នុងព្រះជន្មាយុកំណត់ ៤០ វស្សា (គ្រិស្តសតវត្សទី ២) ព្រះរាជបុត្រព្រះអង្គទី ២ ព្រះនាមប៊ុន-ប៊ុន ឡើងសោយរាជ្យ ហើយទ្រង់តែងតាំងទត្តមសេនីយម្នាក់ឈ្មោះហ្វាន់-ម៉ន ឲ្យសម្រេចព្រះរាជការកិច្ចថ្វាយ ។ បីឆ្នាំក្រោយមក ព្រះបាទប៊ុន-ប៊ុនទ្រង់ទិវង្គតទៅ ទៀត ទើបអ្នកនគរលើកទត្តមសេនីយហ្វាន់-ម៉នជាព្រះរាជាឲ្យឡើងសោយរាជ្យតមក ។ ព្រះបាទហ្វាន់-ម៉ន ឬហៅមួយទៀតថា ហ្វាន់-ចេ-ម៉ុន (ស្រីនារ:?)នេះ ទ្រង់ជាព្រះរាជាគ្មាហានហ៊ាយវាងវៃណាស់ ទ្រង់បានឡើងជាមហាក្សត្រាធិរាជនៃប្រទេសនគរភ្នំ ។ ទ្រង់បានលើកសែនា្ទគុកាពទៅវាយយកប្រទេសជិតខាងឲ្យចុះចូលព្រះអង្គទាំងអស់ ប្រទេសជិតខាងសុទ្ធតែជាសមន្តរាជព្រះអង្គ ។ ទ្រង់បានកសាងរាជនាវីធំៗហើយដើរឆ្លងមហាសមុទ្រសាគរទៅច្បាំងយកអាណាចក្រ ១០ មកចំណុះព្រះអង្គទៀត ។ ព្រះរាជអាណាចក្រព្រះអង្គរីកធំទូលាយបានចំនួន ៥ ឬ ៦ តាន់លើសលើសដើម ។

ទ្រង់មានព្រះរាជបំណងលើកអេហ៍ពាលៈទៅប្លន់យកពាជអាណាចក្រគិន - លិន (Kin-Lin) " ព្រំដែនមាស " ទៀត តែអនិច្ចទ្រង់ព្រះឈួន ហើយទ្រង់មិនឆ្លៀតក្នុងឱកាសនោះទៅ ។

មានសិលាចារឹកខ្មែរមួយ ចាស់បរមបុរាណជាងគេបង្អស់នៅដែនដីអាស៊ីកាគអគ្នេយ៍នេះ គេហៅថាសិលាចារឹក វ៉ូ កាញ់ ហើយគេអាចប្រដូចអក្សរទៅនឹងសិលាចារឹកស្រុទ្រគាម៍នៅគីរនារ (Girnar) ឬ សាតកណ៌ាវ៉ាសិស្ឋីបុត្រៈ (Sâtakarni vâsisthiputra) នៅកាន់ហេរី (Kanheri) តែស្រាទេទ្បើគោការីនឹងនូវត្រឹស្នាមនៃប្រទេសឥណ្ឌៀក្តៅ-ណាចិសបាន ។ សិលាចារឹកនេះ ថ្លែងពីព្រះបាទស្រីមារៈ គឺព្រះបាទហ្វាន់-ថេ ម៉ន់របស់ចិន (?) ថាទ្រង់ជ្រះថ្លាចំពោះពុទ្ធសាសនាប្រាកដជាដូចសិលាចារឹកជាព្រះរាជប្រកាសព្រះបាទធម្មាសោកមហាពាជនៃប្រទេសឥណ្ឌៀដែរ ហើយគេបានរកឃើញនៅស្រុកវ៉ូ-កាញ់ (Vo-Canh) ខេត្តញ៉ាត្រាំង ។ ដោយហេតុតែគេបានរកឃើញនៅដែនដីចាមបុរាណ (វៀតណាមសព្វថ្ងៃ) គេស្មានដោយច័ន្ទច្បាស់ ទើបគេទុកជាក់ថាជាសិលាចារឹកប្រទេសចម្ប៉ាទៅវិញ តែលោកលូ ហ្វ៊ីណូត៍ពិចារណាឃើញថា ទីឋានស្រុកវ៉ូ-កាញ់នេះ កាលពីអតីតកាលមិនមែនជាដែនដីចម្ប៉ាទេ គឺជាសមត្ថពាជប្រទេសនគកុំ ។ កាគខាងលើសិលាចារឹករលុបរលាយ

អក្សរអស់ហើយ មិនអាចមើលសុភាពជាច្រើន តែគេស្គាល់ច្បាស់ដោយតួអក្សរដែលចាស់បុរាណពេក ស្ទើរតែមុនអក្សរចារឹកឥណ្ឌៀនលើនេះខ្លះទៀតផង ឬនជាអ្នកប្រាជ្ញអក្សរបុរាណដូចលោកបារថ៍ (Barth) និងបែរហ្គាញ (Bergaigne) ថាយថាអក្សរសិលាចារឹកភ្នំ-គាញនេះ ខ្លះនជាក្នុងគ្រិស្តសតវត្សទី ៣ មានតែឡើងទៅដល់ក្នុងគ្រិស្តសតវត្សទី ៦ ទៀតផង ។ សេចក្តីក្នុងសិលាចារឹកនោះថា ព្រះករជាវង្សស្រីមារៈបានគ្រាស់បង្គាប់ឲ្យចារឹកទុក ដើម្បីជាអនុស្សាវរីយចំពោះព្រះបាទស្រីមារៈជារាជកុលៈគឺបឋមវង្សដ្ឋនថ្វាចំពោះពុទ្ធសាសនា ដោយ ទន់យល់ច្បាស់នូវគតាគតដំណើរអន្ទោលស្ទាប់តើតនៃសត្វលោកក្នុងវដ្តសង្សារ ទ្រង់ប្រកបដោយមេត្តាករុណាដល់សព្វសត្វហើយទ្រង់គ្រាស់បង្គាប់ឲ្យបរិច្ចាគព្រះរាជទ្រព្យព្រះអង្គធ្វើជាទាន ទុកជាសាធារណៈប្រយោជន៍ ទីបំផុតទ្រង់ផ្តែផ្តាំទុកថា សូមព្រះរាជាសោយរាជ្យជាដំណែតទៅអនាគតឲ្យប្រតិបត្តិតាមព្រះរាជប្រកាសនេះ ដើម្បីជាប្រយោជន៍ធំដល់សត្វលោក ។ ខ្ញុំដកស្រង់ហើយប្រែសម្រួលសេចក្តីក្នុងសិលាចារឹកនេះទុកជូនលោកអ្នកតាំងឡាយអានដូចតទៅនេះ ៖

អត្ថបទ

. . . ប្រជានំ . . . ប្រថមវៃជយ . . . ណ្ឌិមសាម ។ អាជ្ញា

បិតំសន្ទស៊ិ ពជវរណោ . . . ពជគណោ . . . វ៉ាគម្ហតំ បិពន្ធុ ក្រ័មារ . . . ពជកុល . . . ដ . . . ន ក្រ័មារ . . . លោ . . . ន កុលនន្ទនេន អាជ្ញាបិតំ ស្នូជន . . . ស . . . មខ្សៀ វ៉ាកំស្ប ប្រជាហិតករំ ករណោវរណោ!! លោកស្សាស្ស គតាគតិ វិ . . . ន សង្ឃាសនាទ្សាសីនេន បុត្រត្រោតរិ នាន្ទ្រកេ ស្នូសមីករណធនេន តប្តេម្ហ យតកិញ្ចិទ្រជតំ សុវណ្ណមបិ វ៉ សស្ថាវញ្ចន្តិមំ តោង្គាគារិក ប្ប . . . ន ប្រិយហិតេ ស្នូវិសម្ភំ មយា តទេវំ មយាន្ទជ្ញាតំ ករិស្សៈ- បិ ពជតិនុមន្តស្ស វិទិតមស្តុ ប មេ កត្តស្សា វិរស្សៈ . . . ។ ប្ប

សេចក្តីប្រែសម្រួល

". . . សេចក្តីករុណាចំពោះសត្វសត្វទាំងឡាយ . . . ប្រថម - ជ័យ . . . ថ្ងៃពេញបុណ្ណមី (?) ព្រះរាជាទ្រង់បានប្រកាសក្នុងពជស- កាថា " ចូរប្រជាជនត្រេបធឹកនូវទឹកអម្រឹត ពោលគឺព្រះពជបន្ទូលព្រះ ពុទ្ធ . . . ជាវង្សនៃព្រះពុទ្ធស្រីមារៈ ទ្រង់បានជាកិត្តិយសនៃរាជវង្សស្រី- មារៈ ទ្រង់បានប្រកាសក្នុងកណ្តាលជំនុំជន នូវព្រះពជបន្ទូលសូរសីហ- នាទជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ ទ្រង់ជាកំណាទាំងពីរដើម្បីសើរ ទ្រង់ប្រថាប់លើសង្ឃាសនៈ (ព្រះពជបល្ង្កស្នូតធ័ត្រ ?) ហើយទ្រង់ - ឈ្វេងយល់នូវគតាគតិ គឺការអន្ទោលស្ទាប់កើតនៃមនុស្សលោក ទើប

ត្រាស់ថា "កាលបើកូនខ្ញុំក្តី បងប្អូនខ្ញុំក្តី មិនមែនអ្នកកន្ទៀតទេ ជានសម្រេច
បំណងខ្លួនហើយ (ជានសោយរាជ្យតទៅ ?) (ខ្ញុំសូមឲ្យយក) សម្បត្តិ
ខ្ញុំទាំងអស់ប្រាក់មាសសឹង្ហរមក្តី អសឹង្ហរមក្តី ទៅប្រើជាវត្ថុសម្រាប់ជាទី
រឹតរាយនឹងជាប្រយោជន៍ដល់សត្វលោកតាំងឡាយ ។ នេះជាសេចក្តី
បញ្ជារបស់ខ្ញុំ ។ សូមព្រះពជាតាំងឡាយនៅក្នុងអនាគត ប្រតិបត្តិតាម
បញ្ជាខ្ញុំនេះកុំបីខាន ដោយចូរប្រឹក្សាជាមួយសេវាមាត្យឈ្មោះពីរ...
របស់ខ្ញុំ" ។

សិលាចារឹកនេះខ្លះជាសក្ខីភាពគឺជាឯកសារខ្មែរទាត់ បញ្ជាក់ថា
ប្រទេសនគរភ្នំគាន់ពុទ្ធសាសនា ។ គួរពុទ្ធសាសនិកជនខ្លួចងចាំនូវព្រះ
នាមព្រះពជាអង្គនេះខ្លះជាអនុស្សាវរីយ៍ សម្រាប់ជូជាបុព្វការីបុគ្គលដែល
ជានទទួលព្រះពុទ្ធសាសនាខ្លះជាអរិយធម៌ប្រទេសមក ដើម្បីឲ្យជនានុជន
ជានក្រេបផឹកនូវទឹកអម្រឹតគឺសេចក្តីសុខចំរើនក្សេមក្សាន្ត ឲ្យជានសមតាម
ព្រះពជបំណង ដូចខ្ញុំជានត្រាស់ខ្លះក្នុងសិលាចារឹកជាច័ស្តុតាងស្រាប់ ។

យើងជានស្រាវជ្រាវរកដំណឹងពុទ្ធសាសនាដែលចូលមកប្រតិស្ឋាន
នៅក្នុងប្រទេសយើង តាំងពីសាលពុទ្ធសតវត្សទី ៣ នោះ ឥឡូវនេះ យើង
ជានដឹងថាក្នុងរដ្ឋសាលព្រះចាទស្រីមារៈគ្រិស្តសតវត្សទី ២ ព្រះពុទ្ធសាស-
នាជានលូតលាស់ដុះដាលក្នុងប្រទេសយើងហើយ ដូចមានសេចក្តីប្រា -

កដក្នុងសិលាចារឹកជាព្រះរាជប្រកាសព្រះបាទស្រីមារៈនេះស្រាប់ តែតាល
តមក ពុទ្ធសាសនាបាត់ដំណឹងច្រើនឆ្នាំទៀត នាំឲ្យយើងស្គាយក្រៃលែង។

ក្នុងគ្រិស្តសតវត្សទី៥ (គ.ស. ៤៧៩ ៥០១) ពង្សាវតារចិនពាដរង្វ
ត្សៃពង្សន (Tsi méridionoaux) មានដំណាលថា ព្រះពាជានៅ
នគរភ្នំគាន់ពុទ្ធសាសនា។ ដំណឹងនេះនាំឲ្យយើងរីករាយពន់ពេក។ ពង្សា
វតារចិននេះចែងថា ព្រះពាជានគរភ្នំ ជាពាជវង្ស កៅ-ចិន-ដូ (កៅណ្ឌិន្យ)
ព្រះនាម ចូ យើ ចាំ មួ (ជយវរ្ម័ន) គឺព្រះចាន់កៅណ្ឌិន្យជយវរ្ម័ន ទ្រង់
ទ្បើនសោយពាជ្យក្នុង ព.ស. ១០៦១ (គ.ស. ៥៧៨) តាលដើមទ្រង់កាន់
សាសនាព្រាហ្មណ៍ គោរពព្រះមហេស្វរៈ (ព្រះឥស្វរ) តែតមក ទ្រង់
កាន់ពុទ្ធសាសនាវិញ។ ក្នុងរជ្ជតាលព្រះអង្គ យើងបានដឹងថា " ក្នុង
ព.ស. ១០៦៧ (គ.ស.៥៨៤) ទ្រង់បានបញ្ជូនតិក្ខណា គា សាំង តិ
តិក្ខុសាក្យនាគសេនៈជាតិឥណ្ឌា ជាបេសកជនទៅកាន់ពាដសំណាក់ព្រះ
ចៅក្រុងចិន វ៉ូ-ទី ទ្រង់បានផ្ញើគ្រឿងបណ្ណាការទៅថ្វាយព្រះចៅក្រុងចិន
គឺរូបមាតាពាដមាស១ រូបដំរីឆ្នើពីឌីមចន្ទន៍ក្រឹស្ញាស ១ ព្រះស្ពឹបពី ឆ្នើពី
ភ្លុក សំពត់ពីរជាប់ ចានកែវពិទូរ្យ (?)ពីរ ថាសជាត់ស្វាឆ្នើពីក្រាស ១ ។
តិក្ខុសាក្យនាគសេននេះទៅដល់ពាដសំណាក់ព្រះចៅក្រុងចិនហើយ បាន
រៀបរាប់ពីស្ថានភាពនៅប្រទេសនគរភ្នំគ្រប់ប្រការ ថ្វាយព្រះពរព្រះ.ហ

ក្រុងចិនឲ្យទ្រង់ជ្រាប ។ ចំពោះសាសនា កិក្ខុនាគសេន:ថ្លាយព្រះពរ
ថា ប្រទេសនគរភ្នំកាន់សាសនាព្រាហ្មណ៍ គោរពព្រះមហេស្សរៈ (ព្រះ
អីស្សរ) ឯព្រះពុទ្ធសាសនាក៏ចំរើនរុងរឿងណាស់ដែរ មានសមណៈច្រើន
ក្រៃលែង ចំណែកការប្រតិបត្តិព្រះពុទ្ធវចនៈក៏ធឹងតែប្រពៃណាស់ទៀត។
កាលកិក្ខុនាគសេនៈត្រឡប់មកវិញ, ព្រះចៅក្រុងចិនបានសុំឲ្យលោកនាំ
គ្រឿងបណ្ណាការមកថ្វាយព្រះចៅនគរភ្នំវិញដែរ គឺសំពត់ត្រៃផ្ទៃពណ៌បៃ
តង, ស្វាយ មានផ្កា ពណ៌ខៀវ, សៀង មួយមុខ១៥ផាប់ ។ ក្នុង
ព.ស. ១០៤៦ (គ.ស.៥០៣) ព្រះបាទកៅណិនទ្រដយវ៉ែនបានបញ្ជូនរាជ
ទូតម្នាក់ទៅកាន់រាជសំណាក់ព្រះចៅក្រុងចិនទៀត ។ គ្រានេះ, ទ្រង់
បានឲ្យនាំគ្រឿងបណ្ណាការ សុទ្ធសឹងជាផលិតផលប្រទេសទៅថ្វាយព្រះ
ចៅក្រុងចិនគឺព្រះពុទ្ធរូបធ្វើពីផ្កាថ្មសមុទ្រនឹងវត្ថុដទៃទៀតច្រើន ។

ទ្រង់បានបញ្ជូនកិក្ខុខ្មែរពីរអង្គ ទៅប្រែព្រះត្រៃបិដកនៅប្រទេសចិនព្រះ
ថេរៈពីរអង្គនេះគង់នៅប្រទេសចិនក្នុងរវាងខាងចុងគ្រិស្តសតវត្សទី ៥
នឹងខាងដើមគ្រិស្តសតវត្សទី ៦ ។ ព្រះថេរៈមួយអង្គ នាមសេង-គា-
ប៊ូ-ឡូគឺសង្ឃបាលោ កើតពី គ.ស. ៤៦០ លោកចេះភាសាច្រើនភាសា ។
ព្រះចៅក្រុងចិននាមវ៉ូក្នុងរាជវង្សលាងគ.ស.៥០៦ សុំនិមន្តលោកឲ្យជួយ
ប្រែព្រះត្រៃបិដក លោកធ្វើការអស់រវៈ ១៦ ឆ្នាំ នៅហ្វូណន-ក្នុង

(Founan-Kouan) ប្រែថា "ការិយាល័យប្រទេសនគរភ្នំ" ។ ព្រះសង្ឃបាលត្រូវនេះសុគតក្នុងឆ្នាំព.ស. ១០៦៧ (គ.ស.៥២៤) ។

ព្រះថេរៈមួយអង្គទៀត នាមថា មុន-តូ-ឡូ (Man-To-Lo) មន្ត្រីឬ មន តូ ឡូ សេន (Man-To-Lo-Siem) មន្ត្រីសេនៈ ។ លោកនិមន្តទៅដល់រាជសំណាក់ព្រះចៅក្រុងចិនឈ្មោះ (រាជវង្សលោង) ក្នុងព.ស. ១០៤៧ (គ.ស.៥០៣) ហើយបានទទួលព្រះរាជានុញ្ញាតឲ្យចូលធ្វើការប្រែព្រះត្រៃបិដកជាមួយព្រះមហាសង្ឃបាលត្រូវ ។ សេចក្តីប្រែជាស្នាព្រះហស្តព្រះថេរៈទាំងពីរអង្គនេះ មានជាប់ព្រះនាមនៅក្នុងព្រះត្រៃបិដកចិនរហូតមកដល់បច្ចុប្បន្នកាល ។ កាលសម្តេចព្រះទបយុរាជសីហនុវ៉ូនស្តេចយាងទៅប្រទេសចិនក្នុងគ.ស.១៩៥៦ កាលនោះអធិបតីសមាគមពុទ្ធសាសនាចិន បានយកសេចក្តីប្រែជាស្នាព្រះហស្តនៃព្រះថេរៈទាំងពីរអង្គនេះមកថ្វាយសម្តេច ទុកជាសក្ខីភាពនៃមិត្តភាពខ្មែរ-ចិន ដែលមានអាយុ ១៩០០ ឆ្នាំមកហើយ ។

ជាទៃព្រីប្រកពចិន យើងមានសិលាចារឹកពីកន្លែងទៀតពីសម័យនគរភ្នំខាងបុរីគ្រិស្តសតវត្សទី៥ ថ្ងៃនីពីព្រះបាទកៅណ្ឌិន្យជយវរ្ម័ន ។ សិលាចារឹកមួយនៅប្រាសាទ ៥ ស្លែង ស្រុកទឹកឈូ (ខេត្តព្រៃកប្បាស្ទ) រៀបរាប់ថា ព្រះរាជកុមារនាមគុណវរ្ម័នពាជបុត្រនៃព្រះរាជា "ព្រះបន្ទ

នៃពាជវង្សកៅណ្ឌិន្យ" ទ្រង់ត្រាស់បង្គាប់ឲ្យចារឹកទុកថា ទីនេះព្រះវរបិតា ព្រះអង្គយកបានមកពី "ទីទឹកកក់" ហើយតែងតាំងទ្រង់ឲ្យត្រួតត្រា ។ សិលាចារឹកមួយទៀតនៅអ្នកតាដំបងដែក (ខេត្តតាកែវ) ថ្លែងពីព្រះអគ្គមហេសីព្រះបាទកៅណ្ឌិន្យជយវរ្ម័នមានព្រះនាងកុលប្រភាវតី ទ្រង់មានប្រាថ្នាចេញចាកលោក ហើយទ្រង់បានតសាន់ទៅលើយដំកល់ថដំមាកព្រៃស្អាតធ្វើពីមាសសុទ្ធ ព្រមទាំងលំនៅសម្រាប់ព្រាហ្មណ៍នឹងស្រះ ។ ព្រះនាងកុលប្រភាវតីអង្គនេះ ជាព្រះពាជជននីពាជកុមារគុណវរ្ម័ន ។ ព្រះបាទកៅណ្ឌិន្យជយវរ្ម័នទ្រង់ទិវង្គតក្នុងព.ស. ១០៥៧ (គ.ស.៥១៤) ។

ព្រះបាទុទ្រវរ្ម័នទ្រង់ឡើងសោយរាជ្យតសន្តតិវង្សព្រះវរបិតាមក ។ ប្រភពចិនពង្សាវតារពាជវង្សត្បូខាងត្បូងនិយាយតមកទៀតថា ព្រះបាទលៀវ-គួ-ចាំ ម៉ូ គឺទុទ្រវរ្ម័ន ជាព្រះពាជបុត្រព្រះស្នំ មិនមែនជាអគ្គមហេសីទេ ទ្រង់ធ្វើគតមកពីជាពាជកុមារ (ប្រហែលជាពាជកុមារគុណវរ្ម័នជាព្រះពាជបុត្រព្រះអគ្គមហេសីព្រះនាងកុលប្រភាវតី?) ហើយឡើងសោយរាជ្យក្នុងគ.ស.៥១៤ គឺឆ្នាំដែលព្រះវរបិតាទ្រង់ទិវង្គត ។ លុះបានឡើងសោយរាជ្យហើយ ទ្រង់តំបញ្ជូនពាជទូតទៅកាន់សំណាក់ព្រះចៅក្រុងចិនច្រើនដង ។ ពាជទូតដែលទ្រង់បានបញ្ជូនក្នុងព.ស. ១០៦២ (គ.ស.៥១៩) បាននាំយកគ្រឿងបណ្ណាការព្រះអង្គ គឺបដិមាកររាងវើរ? (Image heu-

reuse) ដើម្បីខ្ចីមកចុះនៅណៀ ស្មឹកពោធិព្រឹក្ស គជឈ្ងន គ្រឿងទេស គ្រឿងក្រអូបផ្សែងៗច្រើនទៅថ្វាយព្រះចៅក្រុងចិន ។ ពាជទូតដែលទ្រង់បញ្ជូនក្នុងព.ស. ១០៨៤ (គ.ស. ៥៣៩) បាននាំគ្រឿងបណ្ណាការព្រះអង្គតឺ សត្វមាសព្រមទាំងផលិតផលប្រទេសជាច្រើនទៀត ។ ពាជទូតនេះបានក្រាបទូល ពះចៅក្រុងចិនថា នៅប្រទេសនគរភ្នំមានព្រះបរមសារីរិកធាតុ គឺព្រះកេសមួយសរសៃវែងចំនួន ៣ មែត្រ ។ ទ្រង់ជ្រាបដំណឹងប្រសើរនេះហើយ ព្រះចៅក្រុងចិនបញ្ជូនកិកូបេ យុន ចាវឱ្យតាមពាជទូតខ្មែរមកដណ្តើមព្រះបរមសារីរិកធាតុនោះយកបាត់ហួតឥឡូវនេះទៅ ។

ប្រកពចិននេះ មានសេចក្តីធ្វើយស្រេចមិនសំលាចារឹកខ្មែរនៅប្រាសាទតាព្រហ្មទន្ទេចាទីពីក្នុងព្ធុសតវត្សរ៍ ១១ (គ្រិស្តសតវត្សរ៍ ៦) ថាព្រះចាទុទ្រវ្ន៍ជាព្រះពាជបុត្រព្រះចាទកៅណ្ឌិន្យជយវ្ន៍នេះ ទ្រង់កាន់ពុទ្ធសាសនាដែរ ហើយគោរពព្រះបរមសារីរិកធាតុនៃអង្គព្រះសម្មាសម្ពុទ្ធដូចមានសេចក្តីក្នុងសិលាចារឹកនោះថា ៖

"ព្រះដ៏នស្រីទ្រង់ឈ្នះនូវសត្រូវពោលគឺកិលេស ព្រមទាំងវាសនាទ្រង់ប្រកប.ដោយសម្បទាគ្រប់ប្រការមានពោធិញ្ញាណឥតទើសទាល់ សល់ចំពាក់អ្វីឡើយ មានព្រះទ័យប្រកបដោយករុណាចំពោះសត្វសត្វ មានព្រះយសធំទូលំទូលាយ ឥតមានមោះមន្ទិលអ្វីឡើយ ហើយផ្សាយ

ផ្សាភៀត្រប់ទិសានុទិស ។ ព្រះអង្គស្រោចស្រង់សត្វដែលលិចលង់ក្នុងវដ្តសង្សារគឺត្រៃតព ហើយបានដល់ត្រើយត្រាណហានព្រះនិព្វានដ៏ឧត្តមឥតអ្វីប្រៀបបានឡើយ ។ ព្រះ សីធាតុ (គឺព្រះបរមសារីរិកធាតុ) ព្រះអង្គដែលតែងតែផ្តល់ប្រយោជន៍ធំដល់សព្វសត្វទាំងឡាយ តាំងពីតែផ្តល់ប្រយោជន៍ដល់សព្វសត្វ លុះហូតមកដល់ឥឡូវនេះ . . . . ។ អំពើជាព្រះពាជកុសលដែលទ្រង់ (ព្រះបាទរុទ្រវ៉ែន) បានចំពេញចំពោះព្រះធម៌ហើយ មិនមែនដើម្បីតែព្រះពាជករណីយកិច្ចប៉ុណ្ណោះទេ គឺទ្រង់បំពេញដើម្បីអនុគ្រោះដល់លោកទាំងមូលផង ។ ទ្រង់គោរពព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ . . . ទ្រង់បានតាំងព្រះអង្គពេញជាឧបាសក ដែលឥតមានអំពើបាបលាមក . . . . . " ។

សេចក្តីប្រ៉ាណ្ណែនាំឲ្យយើងដឹងបានថា ក្នុងរជ្ជកាលព្រះបាទរុទ្រវ៉ែន យើងមានព្រះបរមសារីរិកធាតុគឺព្រះកេសមួយសរសៃសម្រាប់ជាទីសក្ការៈបូជា តែគួរអនុញ្ញាយើងត្រូវទាតបង់លែងបានគោរព ដោយព្រះចៅក្រុងចិន (ពាជវង្សត្រីទាងត្បូង) យកបាត់ទៅ ។ រឿងនេះមគោរពព្រះបរមសារីរិកធាតុនេះ នៅប្រទេសកូមាយើងបានដឹងថា ប្រពៃណីមនុនិយាយថា គបុសៈនឹងកលិកៈ ជាបឋមឧបាសកនោះ ជាជាតិមន បានព្រះកេសធាតុយកមកដំកល់ទុកក្នុងសង្ឃគ្គារចេតិយ ឬ ចេតិយស្វាគន ។

ចុះព្រះបរមសារីរិកធាតុរបស់យើង ដែលចែងទុកក្នុងសិលាចារឹកប្រាសាទតាព្រហ្ម ទន្ទេចាំទីនេះ តើបានពីណាមក ? គួរនឹងឲ្យគិតថា ព្រះបរមសារីរិកធាតុនេះជាមរតករបស់តបុស:នឹងកល្ងិក:ទុកឲ្យជាតំណែរ ព្រោះជាសាច់សន្ដានជាមួយគ្នា ។

ក្នុងរជ្ជកាលព្រះចោទកៅណ្ឌិន្យជយវរ្ម័ននឹងព្រះចោទវុន្ទ្រវរ្ម័ននេះ ព្រះពុទ្ធសាសនាចំរើនរុងរឿងណាស់ ។ ព្រះចោទវុន្ទ្រវរ្ម័ន ប្រហែលជាទ្រង់គិរីឆ្នាំរវាងឆ.ស. ១០៨៣ (គ.ស. ៥៤០) ។

សម័យនគរភ្នំ ក្នុងរជ្ជកាលនៃព្រះចោទកៅណ្ឌិន្យជយវរ្ម័ននឹងព្រះចោទវុន្ទ្រវរ្ម័នកើតមានពុទ្ធរូបប្រើនអង្គ ធ្វើពីថ្ម , ពីសំរិទ្ធ ឬពីឈើ ជាការបន្ថែមខ្មែរ បែបអមរាវតី , គុប្ត , គន្ធារៈ មថុរ ឬ អជន្តា ។ ក្នុងរាជ្យនៅអង្គរបូរីជាមជ្ឈមណ្ឌលនៃការកសាងបដិមាកររាមនក្តីឈ្មោះលក្ស្មីន្ទ្រាញ ។ បដិមាករ ការបន្ថែមបែបក្នុងជា ផ្សាយទូទៅពេញដែនដីនគរភ្នំ ទិសខាងកើតទៅដល់ភាគខាងត្បូងនៃវៀតណាមកណ្តាល ។ នៅមឿងនៃឆយ៉ា - (មឿងជយ , សៀមភាគក្រោម) មានរូបអាវលោកតេស្សរមួយ ការបន្ថែមបែបក្នុងជា ។ លោកសីដែសថា រូបនេះ មានការបន្ថែមដូចហរិហរៈនៅអាស្រមមហាឫសី ។

ព្រះពុទ្ធរូបការបន្ថែមក្នុងជាចែកជា ២ មណ្ឌលគឺ :

១- នៅអង្គរបុរីនឆ្នាំជូតទាង មានព្រះពុទ្ធរូបធ្វើពីថ្មចាស់ជាងគេបំផុតនៅអាស៊ីភាគអគ្នេយ៍ ។

២- នៅត្រពាំងវែង ខាងត្បូងខេត្តព្រះត្រពាំង (ត្រាវិញ) ។

ព្រះពុទ្ធរូបថ្មនៅវត្តរំលេកចាស់ជាងគេ ការបនាខ្នែ ថែបគុប្ត ទ្រង់សណ្តែតឈរ ក្រោមហស្ត ស្រុកព្រៃកប្បាស (ខេត្តតាកែវ) ពុទ្ធសតវត្សទី ១០ (គ្រិស្តសតវត្សទី ៩) ។ ព្រះពុទ្ធរូបថ្មនៅត្រើងខៀង ទ្រង់ - សណ្តែតឈរ ក្រោមហស្ត (ខេត្តលង់ហា) ពុទ្ធសតវត្សទី ១០ ។ ព្រះពុទ្ធរូបឈើ ទ្រង់សណ្តែតឈរ ក្រោមហស្តនៅទឹកឡៅ (ខេត្តព្រៃកប្បាស) ពុទ្ធសតវត្សទី ១១ (គ្រិស្តសតវត្សទី ៦) ។ ព្រះពុទ្ធរូបសំរិទ្ធិ នៅវត្តបាណន់ (ខេត្តបាត់ដំបង, ព្រះពុទ្ធរូបនៅភ្នួលព្រះនាគ (ខេត្តកំពង់ស្ពឺ), ទ្រង់សណ្តែតឈរក្រោមហស្តដូចគ្នា ។ ព្រះពុទ្ធរូបនៅសំឆ (ខេត្តព្រះត្រពាំង) ព្រះពុទ្ធរូបនៅត្រពាំងវែង (ខេត្តព្រះត្រពាំង ពីរអង្គនេះគង់ខាត់សមាធិ ។ មានព្រះពុទ្ធរូបនៅវត្តអាចារ្យចាស់ (ខេត្តព្រះត្រពាំង) មានព្រះពុទ្ធរូបនៅកាប់សាំងហ្សាក់ (Cap Saint Jacques) ។ ព្រះពុទ្ធរូប ៣ អង្គ មានចារឹកពុទ្ធភាសិតថា យេ ធម្មា - - - ។ មួយអង្គនៅវត្តឈ្នះដឹតអង្គរបូរី (ខេត្តតាកែវ, មួយអង្គនៅត្រពាំងវែង (ខេត្តព្រះត្រពាំង),

មានត

ព្រះឧបាលីវង្ស ស្សរ-ប៊ាយ៉ រៀបរៀង

(តចប់)

៣— ព្រះពុទ្ធរូបសំដែងធម្មចក្រ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំក្តោបម្រាមធ្វើជាវង់មូលដូចជាកង់រទេះ, ព្រះហស្តឆ្វេងធ្វើអាការដូចព្រះហស្តស្តាំកំមាន ជាក់លើព្រះទុំកំមានហៅថា ធម្មចក្រមុទ្រា ។ ព្រះពុទ្ធរូបបែបនេះ កាលបើគេគូរ តែងតែមានរូបបញ្ចវគ្គិយភិក្ខុ កំពុងអង្គុយគោរព ស្តាប់ធម្មចក្កប្បវត្តនសូត្រ ដែលជាបឋមទេសនា ។

៤— ព្រះពុទ្ធរូបប្រទានអភ័យ ជាតំណាងកាលដែលព្រះអង្គសំដែងធម៌ប្រោសសត្វក្នុងទីណាមួយ មានព្រះភាយឈរកំមាន គង់ពត់ព្រះភ្នែនកំមាន ព្រះហស្តស្តាំពេញទៅមុខ ព្រះហស្តឆ្វេងសំយុងចុះហៅថាអភយមុទ្រា ។

៥— ព្រះពុទ្ធរូបប្រទានពរ មានព្រះហស្តទាំងពីរសំយុងចុះបែរបាតព្រះហស្តទៅខាងមុខ ទ្រង់គង់ពត់ព្រះភ្នែនកំមាន ទ្រង់ឈរកំមាន ជាតំណាងកាលបរិស័ទណាមួយចូលមកថ្វាយបង្គំដោយត្រូវតាមចង់ដួចចង់ឃើញក្តី ក្រាបទូលសួរធម៌អាថិចំពោះព្រះអង្គក្តី ហៅថា វរមុទ្រា ។

៦— ព្រះពុទ្ធរូបទ្រង់ឈរឱបទាត្រ ជាតំណាងកាលដែល

ព្រះអង្គទ្រង់នមន្តបំណុចាត ហៅថា ចុតាទានមុទ្រា ។

๗— ព្រះពុទ្ធរូបទ្រង់ដុំ ជាតំណាងកាលដែលព្រះអង្គផ្ដុំផ្ដៀង ព្រះកាយទៅខាងស្ដាំ ព្រះបាទឆ្វេងតម្រួតលើព្រះបាទស្ដាំ ដោយទ្រង់ផ្ដុំជម្ងាក្ដី ផ្ដុំលើមញ្ចាសនៈជាអនុដ្ឋានសញ្ញា ទ្រង់បរិនិព្វានក្ដី ហៅថា សយនមុទ្រា ។

๘— ព្រះពុទ្ធរូបជាតប្រាក់ ជាតំណាងកាលព្រះអង្គគង់នៅក្នុងស្រះមុចលិន្ទ ដែលក្នុងពេលនោះមានភ្លៀងបង្អុរខ្លាំង មានឥសីរាជមកពេនព័ទ្ធព្រះអង្គបើកពពារគ្របបាំងលើព្រះអង្គ ដើម្បីការពារភ្លៀង ។

ពាក្យថា "មុទ្រា" នេះជាពាក្យសំស្ក្រឹត, បាលីថា "មុទ្ធា" ប្រែជាខ្មែរថា "គ្រឿងសំគាល់, បែបយ៉ាង, អាការ, ឥរិយាបថ, គ្រា, សញ្ញា" ។

ព្រះពុទ្ធរូបទាំង៨បែបនេះ ជារូបដែលគេយកឋ្មមកធ្វាក់ក៏មាន យកចម្លាក់ពុម្ពលាយស៊ីម៉ង់ត៍ធឹងក្បាច់ចោះពុម្ពក៏មាន ឥឡូវនេះគេច្រើនតែចោះពុម្ព ។ ព្រះពុទ្ធរូបដែលមានគ្រឿងសំគាល់ផ្សេងៗគ្នានេះ ជាបែបសិល្បៈនៃបុព្វបុរសជាតិខ្មែរ ជាពុទ្ធសាសនិកជាន់និកាយថេរវាទី ដែលគួរគោរពគួរដឿបានដោយពិត ព្រោះជារូបដែលកសាងត្រូវតាមគោលរឿងពុទ្ធប្បវត្តិ ។ ព្រះពុទ្ធរូបទាំង ៨ បែបនេះនៅប្រទេសខ្មែរយើង គេមិនគ្រាន់តែ

រចនាដោយផ្កាក់ឈើថ្ម ឬបោះពុម្ពដោយស៊ីម៉ង់ទេ ឃើញគេតូរនៅជញ្ជាំងវិហារកំមាន តូរលើផ្ទាំងសំពត់ក៏មាន លើផ្ទៃកញ្ចក់ក៏មាន គឺគេតូរតាមរឿងពុទ្ធប្បវត្តិ ឬទសជាតក, មានរូបមួយបែបទៀតដែលអ្នកស្រុកហៅថាព្រះពុទ្ធរូបទ្រង់គ្រឿង ប៉ុន្តែតាមពិតរូបនេះ ពុំមែនជាព្រះពុទ្ធរូបទេ គឺជារូបស្តេចចក្រ ឬជារូបព្រះមេត្តេយ្យពោធិសត្វ មានទ្រង់មកុដ, សង្ហារ, ខ្សែសុវាន៌ធំចិញ្ចៀនដូចរូបស្តេចទ្រង់មកុដ ឬរូបស្រីល្ងាន ។

ព្រះពុទ្ធរូបនាគប្រក់ ទៅប្រទេសឥណ្ឌៀ មិនដែលឃើញមានទេ មានតែក្នុងប្រទេសខ្មែរ ដែលតើតឡើងដោយសិល្បៈខ្មែរក្នុងសម័យខាងក្រោយដែលគេកសាងតាមរឿងពុទ្ធប្បវត្តិ ។

អំពីស្តូប-បេតិយ

ស្តូបជាគារវត្ថុ ជាទីបញ្ចុះសព ឬអដ្ឋិធាតុរបស់បុគ្គល មានមាតាបិតាជាដើម ដែលគេគួរគោរព ។ រូបភាពស្តូបមានពាងមូលខាងក្រោមរឹតធំត្រអាក ខាងលើរៀបស្មើចដូចអកតំបោះក៏មាន, មានពាងតាលដូចផ្តិលផ្កាប់ក៏មាន, ដែលគេកសាង ដោយពូនដីជាតំនូតក៏មាន កសាងដោយឥដ្ឋដោយថ្មក៏មាន, ស្តូបគ្រប់បែប ច្រើនតែមិនសូវមានក្បាច់រចនាទេ ច្រើនតែលាតរលើនដុំវិញ ។ ពាក្យថា "ស្តូប" ជាភាសាសំស្ក្រឹត បាលីថា- "ថូប" គឺគោលជាគ្រឿងចំណាំទីតន្លែងអដ្ឋិធាតុសម្រាប់គោរពបូជា ។

ចេតិយជាឈ្មោះគារវៈតួដូចស្តូបដែរ ។ ពាក្យថា "ចេតិយ" ប្រែថា ទីដែលគួរគោរព គួរបូជា ។ ចេតិយមានទំហំកំពស់ធំខ្ពស់ជាងស្តូប ពាំនក្លាងរៀបច្រើនតែប្រកបក្បាច់រចនាផ្សេង ។ គ្នា, គេតសាងដោយឥដ្ឋ ថ្មកំមាន ដោយសុីម៉ងត៍កំមាន ។ ចេតិយប្រជាប់ដោយកំពូលរៀបស្រួចកំមាន ជាក់ធត្រូវតែធ្វើដោយស្ពាន់ត្រង់កំពូលកំមាន, កំពូលមានមុខ ៤ដូចជាមនុស្សដែលគេច្រើនហៅថា "មុខព្រហ្ម" កំមាន ។ ចេតិយដែលធ្វើជាកំពូលមុខព្រហ្មនេះ ដោយឆ្លាប់ជាប់ពាក់ព័ន្ធនឹងសាសនាព្រាហ្មណ៍ ដោយហេតុសាសនាព្រាហ្មណ៍ តែងគោរពនមស្ការចំពោះព្រះព្រហ្មដែលឋិតនៅឯឋានព្រហ្ម ដោយហេតុថា ព្រះព្រហ្មមានធម៌ ៤ ប្រការគឺ មេត្តា ករុណា មុទិតា ឧបេក្ខា ។ មួយទៀត ខាងអ្នកកាន់ពុទ្ធសាសនាមហាយានថា រូបដែលមានមុខ ៤នេះ ជារូបព្រះពោធិសត្វអវលោកិតេស្វរៈ ដែលគេតសាងទុកគោរពនមស្ការនោះ សុទ្ធតែមានមុខ ៤ សម្ងឹងចុះក្រោម ដើម្បីសំគាល់ថា លោកតែងប្រមើលសុខទុក្ខមនុស្សលោក ពាំនាមរបស់អវលោកិតេស្វរៈ គេតែងហៅថាសមន្តមុខៈ ប្រែថា "មានមុខជុំវិញ" ។

នៅប្រទេសកម្ពុជាយើង រូបភាពចេតិយមានច្រើនប្លែកណាស់ ឥតដូចគ្នាទេ ប្លែកទៅតាមស្នាដៃរបស់ពួកសិល្បករដែលគាចធ្វើបាន ដើម្បី

បញ្ចុះអដ្ឋិធាតុរបស់អ្នកមានគុណ ឲ្យសមគួរដល់តិត្តិយសរបស់គេអ្នកមាន
គោតសម្បត្តិ ឬឲ្យសមរម្យដល់តម្លៃគុណនៃលោកអ្នកមានគុណមានមាតា
បិតាជាដើម ។ រូបពាន្ធន៍ព្រាយទំហំកំពស់ចេតិយចាំងអស់ បើទុកជា
ច្រើនបែប ដោយដំនាញសិល្បករយ៉ាំងណាក៏ដោយ គង់រួមបញ្ចូលក្នុងប្រ-
ភេទចេតិយ ៤ យ៉ាងប៉ុណ្ណោះ ។

អំពីចេតិយ ៤ ប្រភេទ

១- ធាតុចេតិយ ចេតិយសម្រាប់បញ្ចុះព្រះបរមសារីរិកធាតុនៃ
ព្រះសម្មាសម្ពុទ្ធ, ឬសារីរិកធាតុនៃព្រះបច្ចេកពុទ្ធ, ព្រះអរហន្តធំឆ្ងាយ
ចក្រពត្រ; ប៉ុន្តែបើពោលតាមសម័យនិយម សូម្បីចេតិយដែលបញ្ចុះអដ្ឋិ-
ធាតុសាមញ្ញជន ក៏គេហៅថា ធាតុចេតិយ បានដែរ ។

២- ធម្មចេតិយ ចេតិយសម្រាប់តំកល់ព្រះធម្មក្ខន្ធ (ព្រះត្រៃបិដក)
ឬហៅ ធម្មមន្ទីរ សម្រាប់ទុកគម្ពីរជាដើមក៏បាន ។

៣- បរិភោគចេតិយ ចេតិយសម្រាប់បញ្ចុះគ្រឿងបរិក្ខាររបស់
ព្រះសម្មាសម្ពុទ្ធ មានវត្ថុពន្ធបង្កើនធំធម្មត្រកជាដើម ។

៤- ឧទ្ទេសិកចេតិយ ចេតិយដែលសាងចំពោះព្រះសម្មាសម្ពុទ្ធ
ដើម្បីនមស្ការគោរពបូជាសូម្បីព្រះពុទ្ធរូបក៏ពាប់ថា ឧទ្ទេសិកចេតិយដែរ ។

បើតាមមហាបរិនិព្វានសូត្រ ក្នុងកាលដែលព្រះសម្ពុទ្ធទ្រង់ព្រះគោតម

ទ្រង់សំដែងចំពោះពួកភិក្ខុមានព្រះអានន្ទជាប្រធានថា " ចត្តារោ មេ ភិក្ខវេ ឋូបារហាបុគ្គលា សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ អរហា ចក្កវត្តី រាជា " ប្រែថា ម្នាលភិក្ខុទាំងឡាយបុគ្គល ៤ ពួកនេះគឺ ព្រះសម្មាសម្ពុទ្ធ ១ ព្រះបច្ចេកពុទ្ធ ១ ព្រះអរហន្ត ១ ស្តេចចក្កពត្រ ១ គួរដល់ការបញ្ចុះក្នុងស្តូប ។

បុគ្គល ៤ ពួក ខាងលើនេះ ជាបុគ្គលជាន់ខ្ពស់បំផុត ជាទីគោរពសក្ការបូជារបស់ពុទ្ធបរិស័ទ, រាជបរិស័ទដោយពិត ។ យើងជាពុទ្ធបរិស័ទសម័យជាន់ក្រោយមិនអាចនឹងស្វែងរក ព្រះអដ្ឋជាតុបុគ្គលជាន់ខ្ពស់នោះមកបញ្ចុះ ក្នុងចេតិយបានដោយងាយឡើយ មានតែព្រះអដ្ឋជាតុនៃព្រះមហាត្រៃយ៍, អដ្ឋជាតុមាតាបិតា, គ្រូអាចារ្យទើបរាជ្ជបុរសប៉ុណ្ណោះ ទុកជាទីគោរពបូជា របស់យើងដែរហើយ ។

ចេតិយ បើតាមប្រវត្តិការណ៍ក្នុងគម្ពីរព្រះពុទ្ធសាសនាថាជាវត្ថុស័ក្តិសិទ្ធិមួយដែលគេសាង ទុកជាទីគោរពបូជាមានមកតាំង ពីព្រេង ព្រឹទ្ធមុនសម័យពុទ្ធកាល ដែលមានឈ្មោះថា ជាវ៉ាឡចេតិយ សារន្ទចេតិយ ជាដើម ។

អំពីប្រាង្គ-ប្រាសាទ

ពាក្យថា "ប្រាង្គ" ជាពាក្យសំស្ក្រឹត រាប់ថាជាគារវត្ថុដែលមានទ្រង់ទ្រាយដូចប្រាសាទដែរ ប៉ុន្តែមានទំហំ កំពស់ តូចជាងប្រាសាទហើយ

ច្រើនតែមានពាន ៤ ជ្រុងខ្ពស់ច្រឡោ មានកំពូលខ្ពស់ តែតសាន់លើទី លានខ្ពស់មួយថ្នាក់ឬពីរបីថ្នាក់ ។ ពាក្យថា "ប្រាង្គ" ប្រែថា "សេនាសនៈ មានតួពាន់ប្រាកដស្មើដោយប្រាសាទ" ឬថា "មានគម្រោងដូចប្រាសាទ" ប្រាង្គនេះគេតែងធ្វើដោយឥដ្ឋ ឬថ្ម មានក្បាច់រចនា សម្រាប់បញ្ចុះ សម្រាប់ដំកល់អដ្ឋិធាតុ ដូចចេតិយដែរ ។

ពាក្យថា "ប្រាសាទ" ជាពាក្យសំស្ក្រឹតដែរ បាលីថា "បាសាទ" ប្រែថា "គ្រឹស្ថានជាទីញ៉ាំងចិត្តឲ្យជ្រះថ្លា, គ្រឹស្ថានគួរឲ្យសប្បាយ" ។ ប្រាសាទ គឺផ្ទះដែលធំខ្ពស់លាយខ្ពស់មានកំពូលក្តី ឥតកំពូលក្តី មានរចនាក្បាច់ក្បែរក្តី មិនមានក្តី ដែលល្អប្លែកអស្ចារ្យគួរឲ្យកោតសរសើរ ដូចយ៉ាងប្រាសាទអង្គរធំ, ប្រាសាទបាយ័ន, ប្រាសាទអង្គរតូចជាដើម ។ ប្រទេសកម្ពុជាយើងមានប្រាសាទអង្គរ ជាគ្រឿងបង្ហាញនូវសិល្បៈរបស់វិស្វកវិទ្វៃសម័យបុរាណ ដល់ជនបរទេស ។ ប្រាសាទអង្គរឧកជាគោលចារឹកនៃប្រទេសកម្ពុជា ឬជា មុត្រាមួយដ៏ធំបំផុតរបស់ជាតិខ្មែរ ពាក់ថាជាផលនៃសិល្បៈរបស់បុព្វបុរសខ្មែរ ។ ប្រជាជនច្រើនប្រទេសដែលបានមកមើលប្រាសាទអង្គរ ច្រើនតែ លាន់មាត់ស្ងើចសរសើរសិល្បៈរបស់បុព្វបុរសយើង ។

តាមអ្នកប្រាជ្ញបរទេសខាងបុរាណវត្ថុ ដែលបានស្គាល់ប្រវត្តិការណ៍អង្គរ យើញថា វិស្វកវិទ្អកសាងប្រាសាទអង្គរ ជាមនុស្សប្រចេកទេស

ដោយសិល្បៈយ៉ាងធំតក្នុងលោក ។ ប្រាសាទអង្គរវត្តជាឧទ្ទិសមួយ ដ៏អស្ចារ្យដែលជាស្នាដៃរបស់សិល្បករនៃជាតខ្មែរសម័យបុរាណ ពុំមែនជនបរទេស ឬទេវបុត្តណាមួយ មកសាងប្រាសាទអង្គរទេ ។

អំពី វិហារ-សាលា-គំនូរ

វិហារ ប្រែថា "លំនៅ ទីជ្រកកោន, ទីនៅអាស្រ័យ" ។ ពាក្យថា "វិហារ" នេះបានដល់សេនាសនៈគ្រប់យ៉ាងទាំងកុដិ សាលាធំ ភួច ឬ ទីវត្តទាំងមូលរបស់បព្វជិតពុទ្ធសាសនិក ប៉ុន្តែខ្មែរយើងច្រើនហៅតាមទម្លាប់ចំពោះតែ ឧបោសថាគារ (ពេនទបោសថ) ដែលមានព័ទ្ធ-សីមាថាជាវិហារ ។ បែបតាពត្រង់ព្រាយនឹងការបានរបស់វិហារនៅប្រទេសយើង ហាក់ដូចជាចេញមកអំពីសិល្បៈរបស់ជាងតែម្នាក់ ដោយហេតុយើញវិហារគ្រប់ស្រុកខេត្តស្រដៀងៗគ្នា គឺមានពាង, មានរបៀងមានបាគន់, មានដហ្វាជង្គារ, មានហោជាង មានក្បាច់រចនា ប្រហែលៗគ្នា ។ វិហារដែលកសាងក្នុងសម័យមុនច្រើនតែធ្វើដោយឈើ តឡូវនេះច្រើនតែកសាងដោយគ្រឿងបេតុងអារម៉ែប្លងដោយឥដ្ឋ ព្រះពុទ្ធ-រូប ស្តូប ចេតិយជាដើមនេះ កប់ថាជារតនាវតីរបស់ព្រះពុទ្ធសាសនា ជាវត្ថុស្តាងនៃប្រទេសកម្ពុជាតទៅ ។

សាលា ច្រើនសំដៅយកសេនាសនៈសម្រាប់ប្រើប្រាស់តាមកាលវេលា មិនមែនជាកន្លែងសម្រាប់ដេកនៅប្រក្រតីទេ ដូចឧបដ្ឋានសាលា

ក្នុងវត្តសម្រាប់ពុទ្ធបរិស័ទប្រើប្រាស់តាមកាលមួយ។ សិក្ខាសាលាសម្រាប់តែចូលរៀនប៉ុណ្ណោះជាដើម ពុំមែនសម្រាប់ដេកនៅឡើយ ។ ឧបដ្ឋានសាលាគ្រប់វត្ត ក៏មានបែបភាពប្រហែល ។ គ្នាដែរ ។

ចំណែករូប ព្រះសម្ងាស់ពុទ្ធតាមរឿងបឋមសម្ពោធិ ឬ ទសជាតក្នុងប្រទេសយើងដែរជាធំគួរបានគួរនៅលើក្រជាស, លើផ្ទាំងសំពត់ឬគួរនៅជញ្ជាំងវិហារ ជាសិល្បៈដែលទាក់ទងលើព្រះពុទ្ធសាសនាពាំងអស់ ។

សិល្បៈគ្រប់យ៉ាងរបស់ជនជាតិខ្មែរ ដែលកើតមានឡើង ច្រើនតែយកបែបតាមគម្ពីរព្រះពុទ្ធសាសនា ដោយឃានសិក្សារៀនសូត្រ បានដឹងរឿងដឹងប្រវត្តិការណ៍ក្នុងផ្លូវព្រះពុទ្ធសាសនា ហើយអាចប្រជិដ្ឋយករឿងនោះៗមកគូរជារូបភាព ឲ្យឃើញច្បាស់ដឡើង ដោយយកព្រះពុទ្ធសាសនា ជាទ្រឹស្តី សូម្បីព្រះឥន្ទ, ព្រះព្រហ្ម, ទេវតា, នរក, ប្រេត, យក្ស ដែលមិនបាច់បានឃើញសោះ ក៏អាចគូរកើត ទោះបីគំនូររូបនោះៗ ដូចមែនក្តី មិនដូចក្តី ឲ្យតែគួរសន្ធឹងយកបានក៏ចេះតែគួរតែ ។ តាមគ្នាមក ទុកជាអ្នកសិល្បៈណាមួយ ក៏មិនអាចបាច់កំហុសគំនូរទាំងនោះបាន ដោយហេតុគ្មានរូបព្រះឥន្ទ ព្រះព្រហ្ម មានដីតែរសែមែនយកមកផ្ទៀងកើតឡើយ ។

ព្រះពុទ្ធរូប ស្តូប ចេតិយ ប្រាង្គ ប្រាសាទ វិហារ សាលា គំនូរដែលមានមកហើយនោះឈ្មោះថាជារូបពន្ធនៃសិល្បៈ ឬជាលទ្ធផលរបស់សិល្បៈនៃបុព្វបុរសខ្មែរអ្នកគោរពព្រះពុទ្ធសាសនា ឬថាការកសាងវត្តពាំង

អស់មានព្រះពុទ្ធរូប ស្លាប ចេតិយ ជាដើមនេះ ទុកជាទត្តមគតិនៃពុទ្ធ-
បរិស័ទក្នុងសម័យបុរាណ ដើម្បីឲ្យយើងជាន់ក្រោយឃើញសិល្បៈនៃបុព្វ-
បុរស ហើយយើងក៏អាចចម្លងយកបែបសិល្បៈនោះៗតមកទៀត ។

ប្រយោជន៍នៃពុទ្ធសាសនា

ខេមរជនក្នុងប្រទេសកម្ពុជា ទទួលផល អំពីព្រះពុទ្ធសាសនា
ជាច្រើនយ៉ាង ដូចសេចក្តីដែលត្រូវសំដែងតទៅនេះ

១-ព្រះពុទ្ធសាសនា ទុកជាចក្ខុក្រឹះស្ថាន ជួមហាមន្ទីរជាទីកើត
នៃសិល្បៈ, ទស្សនវិជ្ជា, វិទ្យាសាស្ត្រ និងសីលធម៌ គប្រពៃណីដ៏ល្អ ។ ព្រះ
ពុទ្ធសាសនាមានអត្ថបទល្អ ។ ច្រើនណាស់សម្រាប់ប្រតិបត្តិដើម្បីរលត់ទុក្ខ
នាំមកនូវសេចក្តីសុខ, ជាសាសនាបំភ្លឺប្រយោជន៍ តាំងអំពីបច្ចុប្បន្នដល់
បរលោក ជាសាសនាឲ្យសិទ្ធិបរិបូណ៌ដល់សត្វលោកគ្រប់មនុស្សនឹងតិរច្ឆាន,
ព្រះពុទ្ធសាសនាទុកដូចជាដួងប្រទីបមួយដ៏ធំក្នុងលោក សម្រាប់ព្រលឹងបំភ្លឺ
ឲ្យមនុស្សលោកឃើញសិល្បៈ, ឃើញផ្លូវប្រតិបត្តិ, ដើរកាត់តម្រង់ទៅរក
សន្តិសុខចំរើនពាំនបច្ចុប្បន្នទំនបរលោក ជាសាសនាលុកពារកយើញមគ្គ-
ផលនិព្វានបាន ។ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍
ជាច្រើនយ៉ាង ដូចយ៉ាងសេចក្តីចំរើន ឈានលឿនទៅមុខ។ របស់មនុស្ស
លោក ក៏ច្រើនតែកើតមកអំពីព្រះពុទ្ធសាសនាជាដំបូង សូម្បីវិទ្ធសាស្ត្រ
ទំនវិទ្យាសាស្ត្រ ដែលពាក់ថាជាវិជ្ជាសម័យថ្មី ក៏កើតមកអំពីអ្នកប្រាជ្ញដែល

ចម្ងន់ផ្តិតយកវរបៀបអំពីព្រះពុទ្ធសាសនាខ្លះមិនខាន បើមិនច្រើនក៏តិច ។

គ្រប់ប្រទេសទាំងអស់ ច្រើនតែទទួលជឹងថា សេចក្តីចំរើន ក្នុងសិល្បៈវិទ្យា ឋានទទួលកំណើតអំពីសាសនា ។ អ្នកប្រាជ្ញប្រវត្តិសាស្ត្រប្រទេសជប៉ុន បានសរសេរចុះក្នុងប្រវត្តិសាស្ត្រថា " ព្រះពុទ្ធសាសនាជាសាសនានាំសេចក្តីចំរើនមកប្រគល់ឲ្យប្រទេសជប៉ុន, ព្រះពុទ្ធសាសនាបានបីតគ្រាប្រទេសជប៉ុន ដោយទ្រឹស្តីមុនជំបូងបង្អស់ ឲ្យប្រទេសជប៉ុនឈមមុខទៅរកសេចក្តីចំរើន ព្រោះហេតុនោះ យើងជាជាតិជប៉ុននៅចុងប៉ូចបូតាប្រទេស គួរណាស់តែសើរើ សិក្សាអនុវត្តព្រះពុទ្ធសាសនាដោយគោរព មិនត្រូវធ្វេសប្រហែស " ។

๒-ព្រះពុទ្ធសាសនា ជាអណ្តាំ សម្រាប់តើតនៃការសិក្សា ពោះបីការសិក្សានោះតុំបានធំទូលាយ ដោយមិនជាន់បានអនុវត្ត តំណាងចិញ្ចឹមសិល្បៈក្នុងជីវិតរបៀបរបៀបមិនបែរជាតិខ្មែរ ឲ្យមានជីវិតជាប់ជូដរាមិនដាច់ ។ ប្រទេសកម្ពុជារបស់យើង ដែលមានការចេះដឹងក្នុងលទ្ធិសាសនាក្តី ក្នុងសិល្បៈណាមួយក្តី ផ្លូវអក្សរសាស្ត្រក្តី សុទ្ធតែតើតមកអំពីវត្តអារាមរបស់ព្រះពុទ្ធសាសនាជាដំបូង សូម្បីរដ្ឋាភេទ្យ ក៏ច្រើនតែតើតមកអំពីបព្វជិតពុទ្ធសាសនិក ទោះបីមានវិនិយ ហាមមិនឲ្យបព្វជិតធ្វើពេទ្យមើលជម្ងឺក៏ហាមបានដោយត្រណាស់ ដោយហេតុបព្វជិត មើលជម្ងឺឲ្យទេ មិនចាប់យកថ្លៃ ។

៣- វត្តអារាមពុទ្ធសាសនា ជាកន្លែងប្រជុំប្រជាជន ដើម្បីសន្ទនាពីធម៌អាថ៌ប្តីព្រឹត្តិការណ៍នានាតាមសេចក្តីចេះដឹងក្នុងសម័យនិយមនោះៗ ។ វត្តអារាមខ្មែរជារោងរៀនហត្ថកម្មមួយ ក្នុងផ្លូវសិល្បៈ មានរៀនការជាងឈើ ការកសាងវិហារសាលាជាដើម ។ ពួជនាវនៃសេចក្តីចំរើនរបស់យើងដែលមានឈ្មោះជាប់មក ជាប្រទេសមានអក្សរសាស្ត្រ. មានបុរាណវត្ថុជាគ្រឿងបង្ហាញសិល្បៈឲ្យឃើញជាកេរ្តិ៍ដំណែល, មានប្រជាជាតិជាម្ចាស់ប្រទេសមានមហាក្សត្រសោយរាជ្យកំដោយអំណាចគុណភាពនៃព្រះពុទ្ធសាសនាជួយទ្រទ្រង់ ឬថា ព្រះពុទ្ធសាសនា ជាឃ្លាំងទុកជាកន្លែងសិល្បៈព្រមទាំងអក្សរសាស្ត្ររបស់ជាតិ ឲ្យមានជីវិតរស់នៅរហូតមក, រួមសេចក្តីថា "ព្រះពុទ្ធសាសនានាំមកនូវប្រយោជន៍យ៉ាងធំ ឲ្យប្រទេសកម្ពុជាយើង" ។

៤- ប្រទេសកម្ពុជាយើង កំយើងអាចបានឃើញជាក់ច្បាស់ហើយគឺថា កាលដែលប្រទេសយើងមិនទាន់មានសាលារៀនអក្សរសាស្ត្រក្នុងផ្លូវការនៅឡើយ មានតែវត្តអារាមហ្នឹងឯង ជាសាលារៀន, កាលដែលផ្លូវការមិនទាន់មានមន្ទីរពេទ្យព្យាបាលរោគនៅឡើយ មានតែវត្តអារាមជាមន្ទីរពេទ្យសម្រាប់មើលជម្ងឺនៃប្រជាជន; មិនត្រឹមតែមើលជម្ងឺកាយប៉ុណ្ណោះទេ អាចពិនិត្យមើលជម្ងឺចិត្តផងទៀត ព្រោះថាការកើតទុក្ខព្រួយជារម្ភក្នុងផ្លូវចិត្តនេះ ចាត់ជារោគមួយយ៉ាងធំណាស់ វត្តអារាមនៃព្រះពុទ្ធសាសនាឈ្មោះថាជាកន្លែងសម្រាប់រម្ងាប់រោគកាយ - ចិត្ត ដែលមានទុក្ខ

ឲ្យជួរស្រាលកំមាន ឲ្យជាសះស្បើយពីកំមាន ។

៥-វត្តធំៗក្នុងក្រុងភ្នំពេញ ជារាជធានីនៃប្រទេសកម្ពុជាយើង មានគឺវត្តឧណ្ណាលោម, វត្តលង្កា, វត្តសាវាំង. វត្តបទុមវតី ជាដើម ជាវត្តទទួលបន្ទុកនៃពួកភិក្ខុ-សាមណេរ នឹងកុមារតូចធំ ជាន់ច្រើនណាស់ ។ វត្តនីមួយៗ មានភិក្ខុសាមណេរ នឹងកុមារ ដែលទំស្នះពន្លះចេញអំពីស្រុកខែត្រផ្សេងៗ មកនៅបះកួះជ្រំជាមួយគ្នា ដើម្បីសិក្សារៀនសូត្រ យកចំណេះវិជ្ជា ព្រោះថាក្រុងភ្នំពេញជាទីប្រជុំធំ សម្បូណដោយការសិក្សាជាងទីឯទៀត ។ ពួកភិក្ខុដែលមកនៅក្នុងវត្តទាំងនោះ ជាន់ធ្ងន់ ទាំងមានសមត្ថភាពគ្រាន់បើ ហើយជាន់ទទួលហាន៎ះឆ្លើជាមេកុដិ អាចទទួលចិញ្ចឹមភិក្ខុសាមណេរនឹងកុមារឲ្យនៅរៀនសូត្រផង ទាល់តែសម្រេចការសិក្សា ។ ពួកកុមារដែលមកនៅអាស្រ័យជ្រកកោន ក្នុងវត្តជាមួយនឹងព្រះសង្ឃនោះ សុទ្ធតែជាកូនអ្នកស្រែចំការ ដែលក្រទ័លទ្រព្យសម្បត្តិ គួរអាឲ្យណាបអាធ័ម អាណិតអាសូរពួកកុមារកំសត់ទាំងនេះពន់ពក បើកុំតែមានវត្តព្រះពុទ្ធសាសនា ប្រហែលជា មិនបានទទួលស្គាល់ការសិក្សា ដូចកូនអ្នកមានទ្រព្យទេ ប្រៃសេចក្តីថា "កូនអ្នកក្រីក្រធនធានរស់នៅដោយសារបាយវត្ត" ។ ទំព្រាំទ្រនៅបំពេញការសិក្សាទាំងរហាមរហាម ទាល់តែសម្រេចផលនៃការសិក្សាបានឡើងហាន៎ះទៅជាអ្នកមានជីវភាពខ្ពង់ខ្ពស់តាមសមគួរដល់សមត្ថភាពរបស់ខ្លួន, ចំណែកខាងឯកូនអស់លោកឥស្សរជន ឬកូន

គឺហេតុ មិនត្រូវគាមកជ្រកកោននៅអាស្រ័យក្នុងវត្តឡើយ ។

កូនចៅរបស់អ្នកក្រីក្រ ចូលទទួលសេចក្តីសង្គ្រោះ អំពីបព្វជិតពុទ្ធ-សាសនិកក្នុងឆ្នាំនីមួយ ។ ចូលច្រើននាក់ណាស់ ដូចយ៉ាងវត្តធំ ។ មានកុមារចំនួន ៣០០ ឬ ៤០០ នាក់ ។ ចំនួនពួកកុមារទាំងប៉ុណ្ណោះ បើជាពជរដ្ឋាតិចូលទទួលយកទៅចិញ្ចឹមវិញ អស់ប្រាក់ថវិកាជាតិ មិនមែនតិចទេ ។ កុមារទាំងនេះ ឈ្មោះថា រស់នៅដោយអាស្រ័យនឹងមូលព្រះពុទ្ធ-សាសនា នៅជ្រកកោនក្រោមម្លប់ទង់ជ័យព្រះពុទ្ធសាសនា ។ ប្រឹងប្រែងសិក្សាពាល់តែចូលទទួលលទ្ធផល នៃការសិក្សារបស់ខ្លួន ។ ការណ៍នេះឃើញថា ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាយើង មានប្រយោជន៍ដ៏ធំធេងណាស់ អាចជួយសង្គ្រោះទំនុកបំរុងដល់ប្រទេសជាតិបាន គឺថា វត្តនៃព្រះពុទ្ធសាសនា ពុកដូចជាកន្លែងទទួលភ្ញៀវអាហារបូតរណ៍មួយដ៏ប្រសើរដល់អ្នកក្រីក្រ, អាចចិញ្ចឹមមនុស្សទ័លក្រ ដែលមិនមានលំនៅជ្រកកោន និងអាហារបរិភោគ ។ វត្តរបស់ព្រះពុទ្ធសាសនា ឈ្មោះថា ចូលជួយសម្រួលការនៃពជរដ្ឋាតិចូលឲ្យធូរស្រាលចូលច្រើនណាស់ ។

៦- បព្វជិតពុទ្ធសាសនិក នៅវត្តអារាមគ្រប់ស្រុកមានលោកចៅអធិការគ្រប់គ្រងជាដើម ដែលភាគច្រើន ក្នុងការសិក្សាធម្មនិយាយហើយចូលចុះស្មាមកធ្វើការសិក្សាតាមសម័យនិយម ។ ការសិក្សាប្បាប់ព្រះពុទ្ធ-សាសនា របស់បព្វជិតពុទ្ធសាសនិកនោះ ជាកម្លាំងមួយដែលនាំឲ្យមាន

ប្រាជ្ញាស្មារតីបរិបូណ៌ នាំឲ្យកូនក្នុងផ្លូវធម៌ផង ផ្លូវលោកផង គឺថា ការសិក្សានោះ ដួយឲ្យបានជីវិតនោះមានទត្តមគតិនឹងសមត្ថភាព ពាំនាំពួកទុបាសកដើរផ្លូវត្រឹមត្រូវបានដឹកនាំចិត្ត ឲ្យមានសទ្ធាជ្រះថ្លា ក្នុងការគាំទ្រសាសនៈសម្រាប់បំរើព្រះពុទ្ធសាសនាផង បំរើប្រទេសជាតិផង ។ ដូចយ៉ាងសាលាសិក្សាអក្សរសាស្ត្រ ដែលកើតមានព្រោងព្រាតក្នុងស្រុក-ខេត្តផ្សេងៗ មានខេត្តកណ្តាល តាកែវ-ស្វាយរៀងជាដើម ច្រើនតែកើតអំពីចំហាយនៃការសិក្សាព្រះពុទ្ធសាសនា ជាដើមគឺ គឺថា សាលាសិក្សាពាំនោះកើតឡើងបានដោយសារស្មារដៃរបស់ព្រះសង្ឃមានចៅអធិការ ឬគ្រូសូត្រជាដើមណែនាំពួកគ្រូហាស្តដើរត្តឲ្យគាំទ្រដោយឥតមើលបំណាំពជង្ហាកិបាលឡើយ លុះគាំទ្រហើយដូនប្រគល់សាលាសិក្សានោះដល់ពជង្ហាកិបាល ដើម្បីឲ្យពជការចាត់ចែង រកគ្រូបង្រៀនតាមផ្លូវការតទៅ ដែលអាចគាំពារពជង្ហាកិបាល ដួយកម្លាំងហិរញ្ញវត្ថុនៃពជង្ហាកិបាលឲ្យចំណេញថវិកាជាតិបានច្រើនណាស់ ។

ដំណើរនេះសរឲ្យឃើញថា "ព្រះពុទ្ធសាសនា គាលបើបុគ្គលណាបានអប់រំសិក្សាល្អហើយ អាចនាំឲ្យធ្លុះបំភ្លឺឃើញសារប្រយោជន៍ក្នុងផ្លូវធម៌បានផង ផ្លូវលោកបានផង" ។ ព្រះពុទ្ធសាសនាឈ្មោះថាជាសាសនាដួយពលរដ្ឋប្រទេសកម្ពុជា ឲ្យចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួនបានដោយបរិបូណ៌ ជាសាសនាមានទ្រឹស្តីល្អ អាចដួយសាងវឌ្ឍនធម៌នឹងសាមគ្គីធម៌

របស់ជាតិ ឲ្យកើតមានឡើង ។

៧-អក្សរសាស្ត្រខ្មែរ សម្រាប់ប្រទេសយើងបើកុំតែមានវត្តអារាមនៃពុទ្ធសាសនាក ប្រហែលជាសាបសូន្យអស់ទៅហើយ ព្រោះហេតុនោះ វត្តអារាមឈ្មោះថាជាកន្លែងសម្រាប់រក្សាទុកនូវសិល្បសាស្ត្រចំពោះមកអក្សរសាស្ត្ររបស់ជាតិទុកឲ្យរស់នៅ ។ អក្សរសាស្ត្រនេះទុកជាពន្លឺរបស់ជាតិ កាលបើបាត់អក្សរសាស្ត្រហើយ ជាតិក៏អាប់ឧនសាបសូន្យទៅជាលំដាប់ ដោយហេតុនេះពុទ្ធសាសនានៅប្រទេសយើងឈ្មោះថាជាសាសនាជួយជ្រោមជ្រែងរក្សាទុកនូវអក្សរសាស្ត្រជាតិ ។

បណ្ឌិតពុទ្ធសាសនិក ដែលបានរៀនគួរឲ្យដឹងផ្លូវនិទ្ទេសរ: គឺរៀនគម្ពីរបាលីព្រះត្រៃបិដក បើចាំយល់សព្ទភាសាបាលី ងាយប្រែពីបាលីមកជាភាសាខ្មែរបានដោយងាយ បានបោះពុម្ពផ្សាយចេញជាសៀវភៅធំ-តូចគរគោកសួមអញ្ជើញមើលក្នុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងបណ្ណាគារឯទៀតៗ ដើម្បីញ្ជាសៀវភៅខ្មែរដោះជាសពន់មិនឈ្លះ ។ សៀវភៅអក្សរខ្មែរផ្សាយផ្នែកពុទ្ធសាសនា បើញ្រោងព្រោតទាំងនេះប្រើនតែកើតអំពីស្នាដៃព្រះសង្ឃ ដែលបានរៀនក្នុងផ្លូវព្រះពុទ្ធសាសនា ។ ប្រទេសកម្ពុជាដែលមានវប្បធម៌ ខាងផ្លូវសិល្បសាស្ត្រ, អក្សរសាស្ត្រតំពូងរើបៗទៅរកផ្លូវចំរើនដូរឿងមកនេះ ដោយកម្លាំងស្មើនៃព្រះពុទ្ធសាសនាជាច្រើនដរ

ព្រះញាណវរិយៈ រ៉ាំង-សាង៉ុំ រៀបរៀង

អ្វីជាវប្បធម៌ ? អ្វីជាពុទ្ធសាសនា ?

— សាកាតសព្វយ៉ាងដែលតាំងឡើងក្នុងភូមិប្រទេស ដោយអំពើផ្សេង ។ មានការគោរពក្តីរាប់អានសាបព្រោះបណ្តុះជាំផ្សំបំបៅជាដើម ឬក្នុងតាយប្រទេស ដោយការសិក្សាអប់រំបណ្តុះនិស្ស័យសន្តាន នេះជាវប្បធម៌ ។

— ធម៌វិន័យដែលព្រះពុទ្ធទ្រង់សំដែង ទ្រង់បញ្ជាតួកប្រោសសត្វលោកហៅថា ពុទ្ធសាសនា ។ ពុទ្ធសាសនាជាវប្បធម៌តើតអំពីព្រះពុទ្ធ ។ ព្រះពុទ្ធ កាលដែលទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ហើយទ្រង់ទេសនាប្រោសសត្វទូទៅ ហៅថា ទ្រង់បានសាបព្រោះបណ្តុះជាំផ្សំវប្បធម៌ព្រះពុទ្ធសាសនាក្នុងពិភពលោក ។

វប្បធម៌ពីណៀសម័យបុរាណ

ធំដំសម័យពុទ្ធកាល

ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះសម្ពោធនឹងទ្រង់ត្រាស់ដឹងនៅប្រទេសឥណ្ឌា កាតខាងដើងដែលក្នុងសម័យនោះគេទុកជាមជ្ឈិមប្រទេស ។ សម័យ

នោះឥណ្ឌៀកាគខាងដើមមានអារម្មណមិខ្ពស់ថ្លៃដូចជាឥណ្ឌៀកាគខាងក្រៅ ដោយ
មានវប្បធម៌ខាងបច្ចេកទេសនឹងខាងរដ្ឋប្បវេណីនោះជាយ ព្រមទាំងខាងនីតិ
នឹងវិន័យសំខាន់ជាង ។ ឥណ្ឌៀកាគខាងដើមមានឥទ្ធិពលក្នុងការកំណត់ហានៈឥណ្ឌៀកាគខាងក្រៅឲ្យថោកទាបដូចហាននេះ សូម្បីតែក្នុង
ឥណ្ឌៀកាគខាងដើមជាមួយគ្នាក៏បែងហានៈប្រជាជនជា ៤ ត្រកូលគឺត្រកូល
ក្សត្រ ត្រកូលព្រាហ្មណ៍ ត្រកូលវៃស្យៈ (ឈ្មួញ) ត្រកូលសូទ្រៈ (អ្នក
ជាវ) ។ បណ្តាត្រកូលទាំង ៤ នេះ ត្រកូលក្សត្រនឹងត្រកូលព្រាហ្មណ៍
ជាត្រកូលខ្ពស់ដោយមានវប្បធម៌ជាន់ខ្ពស់ ត្រកូលវៃស្យៈជាត្រកូលបន្ទាប់
បន្សំ ដោយមានវប្បធម៌ថ្នាក់កណ្តាល ត្រកូលសូទ្រៈជាត្រកូលទាបជាង
គេបង្អស់ដោយមានវប្បធម៌ថោកទាបបំផុត កាលបើមានវប្បធម៌ផ្សេងគ្នា
តាមហានៈត្រកូលដូច្នេះ អារម្មណមិសេចក្តីចម្រើនរុងរឿងដោយអាកប្ប-
កិរិយាទាំងឡាយ មានសម្បុកបំពាក់នឹងសីលធម៌ ចរិយាជាដើមក៏ផ្សេង
គ្នាទៅតាមនោះ ។ ដល់ព្រះពុទ្ធជាម្ចាស់ជាន់ត្រាស់មក ទ្រង់ផ្សាយអនុត្តរ-
ធម៌ ទ្រង់ទម្លាយហានៈចំពោះជនដែលមកពីត្រកូលទាំង ៤ នោះ ទោះបី
ត្រកូលណាក៏ដោយឲ្យតែចូលបួសក្នុងធម្មវិន័យរបស់ព្រះអង្គ ទ្រង់ទុកជាក់
ហានៈជាស្មើគ្នាទាំងអស់ឲ្យគោរពដល់គ្នានឹងគ្នាតែតាមវស្សាចាស់ខ្ចីនឹងការ
ចេះដឹងតិចច្រើនប៉ុណ្ណោះហើយនឹងទ្រង់អប់រំនិស្ស័យពុទ្ធបរិស័ទ ដោយ

នាយកធម៌នានា មាន ពាន ស័ល តាវនា ឫស័ល សមាធិ បញ្ញា ជាដើម រហូតដល់មគ្គផលនិព្វានជាទីបំផុត ។ ដូច្នេះឈ្មោះថា ព្រះពុទ្ធជាម្ចាស់ទ្រង់បានសាបព្រោះបណ្តុះដាំផ្សាំពូជវប្បធម៌ពុទ្ធសាសនា ទុកក្នុងប្រទេសឥណ្ឌា ជាមជ្ឈិមប្រទេសដែលជាជាតិភូមិរបស់ព្រះអង្គ ក្នុងសម័យពុទ្ធកាល ។ លុះព្រះអង្គបរិនិព្វានទៅ ទើបវប្បធម៌នោះសាយភាយចេញទៅតាមប្រទេសនានាជាបច្ចន្តប្រទេស ជាបណ្តើរៗទៅទាំងពិភពលោកដូចយើញប្រាកដក្នុងសម័យបច្ចុប្បន្ននេះ ។

វប្បធម៌ពុទ្ធសាសនាផ្សាយមកកាន់សុវណ្ណភូមិ

បច្ចន្តប្រទេសទាំងពួងក្នុងទ្បបទីបសុវណ្ណភូមិ ជានទ្បលយកវប្បធម៌ពុទ្ធសាសនាមកសាបព្រោះបណ្តុះដាំនៅសម័យក្រោយពុទ្ធកាលគឺក្នុងសតវត្សទី ៣ នៃពុទ្ធសកពជ នារជ្ជកាលអសោកមហាពជ ដោយព្រះមោគ្គលីបុត្តតិស្សត្ថេរជាសង្ឃប្រមុខ ជានចាត់ព្រះថេរៈ ២ រូបគឺព្រះសោណកត្ថេរ ១ ឧត្តរត្ថេរ ១ ឲ្យជាសមណទូតនាំវប្បធម៌ពុទ្ធសាសនាមកផ្សាយដល់សុវណ្ណភូមិ ដែលតាមប្រកពខ្លះថាតាំងនៅក្នុងអាណាចក្រភូមា ដែលមានអរហន្តសីមា ន័ងសិលាចារឹកជាពស្តុតាង នៅរហូតដល់សម័យបច្ចុប្បន្ននេះ ។

ឯប្រទេសកម្ពុជាយើង បើតាមសិលាចារឹកក្នុងចេតិយដ្ឋាននានា

នៅសតវត្សទី ៨ នៃ ព.ស. សម័យនគរភ្នំ (ហ្វូណន់) ប្រាកដថាមានពុទ្ធសាសនាមកចាក់ឫសលូតលាស់ ពាសពេញអាណាខែត្រទៅហើយ ។ កាលបើដូច្នេះ អាចសន្និដ្ឋានថា ប្រទេសកម្ពុជាបានទទួលវប្បធម៌ពុទ្ធសាសនាតាំងពីមុនសម័យនោះទៅទៀត គឺថាប្រហែលតាំងពីសតវត្សទី ៣ ឬទី ៤ នៃព.ស. ដំណាលឬ បន្តាបន្ទាប់គ្នា ទឹងប្រទេសភូមានោះដែរ ព្រោះទំពំនឹងកើតបានជាសិលាចារឹកបែបនេះ ក៏អាស្រ័យមានជនាន្តរជនដើម្បីគោរពគាន់មកមុនយូរក្រៃលែងរហើយ ពាំនសម័យនោះ នៅខុបខ្ចប់សុវណ្ណភូមិយើង មានប្រជាជាតិតែ ៣ ផង គឺភាគខាងលិចប្រជាជាតិមន, ភាគខាងកើតប្រជាជាតិចាម, ភាគកណ្តាលប្រជាជាតិខ្មែរ ។ ដូច្នេះឃើញថាប្រជាជាតិទាំង ៣ អាចផ្សាយឬ អាចបម្លែងវប្បធម៌ទៅវិញទៅមកបានដោយងាយ, ហើយបើនឹកដល់រឿងមួយទៀតថាជាតិខ្មែរនឹងជាតិមនមានអម្បូរកោសាជាមួយគ្នា ដែលហៅថាកាសាមន ខ្មែរ ប្រាកដមកដល់ឥឡូវនេះ ក៏តែងតែឃើញថាសមណាស់ទៅទៀត ។ រួមហេតុការណ៍ទាំងអស់ទៅអាចសន្និដ្ឋានថា វប្បធម៌ពុទ្ធសាសនាខាងថេរវាទ ដែលជាគួនឹងអាចរីយរាល ចូលមកចាក់ឫសជុះជាលក្ខណ៍ប្រទេសយើង តាំងពីមុនសម័យនគរភ្នំ ។ ជាតិខ្មែរដែលធ្លាប់តែគាន់សាសនាព្រាហ្មណ៍មកពីមុនៗ ក៏បែរត្រឡប់មកគោរពគាន់ពុទ្ធសាសនាតាំងព្រះមហាក្សត្រ តាំងអាណាប្រជា

ពស្ត្រ គាន់តែច្រើនឡើងច្រើនឡើង ។ លុះចូលមកដល់សម័យចេនឡា
គឺពីសតវត្សទី ១១ ទៅទី ១៤ នៃ ព.ស. ក្នុងរវាងនេះវប្បធម៌ពុទ្ធសាសនា
ខាងអាចរិយវាទ ក៏បានផ្សាយចូលមកដល់ខ្មែរ បានចាត់ថ្នាសលួត
លាស់ឡើងជាគូនឹងសាសនាព្រាហ្មណ៍ ដោយមានឥទ្ធិពលផ្សាយចូល
គាន់ព្រះពាជសំណាក់ក្នុងរដ្ឋាលខ្លះៗផង ដរាបមកដល់សម័យអង្គរ គឺពី
សតវត្សទី ១៤ ទៅទី ២០ នៃព.ស. ក្នុងរវាងនេះ នារដ្ឋាលខ្លះក៏តែងតែ
មានឥទ្ធិពលយ៉ាងអស្ចារ្យ មានព្រះមហាក្សត្រគោរពរាប់អានថ្វាយព្រះអង្គ
ជាពុទ្ធសាសនិក ដូចព្រះបាទជ័យវរ្ម័នទី ៧ ដែលមានព្រះកិត្តិនាមល្បី
ល្បាញ មានព្រះពាជអាណាខែត្រដ៏ធំទូលាយ ក្នុងសតវត្សទី ១៣ នៃ
ព.ស. ។ ក្នុងរដ្ឋាលព្រះអង្គ ទ្រង់បានសាងចេតិយដ្ឋានសំខាន់ៗ មា
ប្រាសាទ តាព្រហ្ម ព្រះខ័ន ធីឆាយ័នជាដើម ដែលគុកជាវប្បធម៌ខាង
ការចនានៃព្រះពុទ្ធសាសនាលទ្ធិអាចរិយវាទ ទាំងបានសាងមន្ទីរពេទ្យ
ស្ថាន ថ្កល់ សាលាសំណាក់ជាសពាស ក្នុងព្រះពាជអាណាចក្រ ។ តាម
សិលាចារឹកក្នុងបុពណ៌ស្ថានទាំងឡាយ បំភ្លឺឲ្យឃើញថាព្រះអង្គជាបណ្ឌិត
ឯកមួយ ទាំងខាងសាសនៅបាយ ទាំងខាងនយោបាយ ។ ទាំងព្រះនាង
ជយាទេវី អគ្គមហេសីព្រះអង្គក៏ជាសាស្ត្រាចារ្យខាងព្រះពុទ្ធសាសនា ។

មូលហេតុព្រះត្រៃបិដកស្លឹករឹត

វប្បធម៌ពុទ្ធសាសនាផ្នែកអក្សរសាស្ត្រ តាំងពីព្រះពុទ្ធជាម្ចាស់គង់

ព្រះធរមាននៅដរាបមក លោកអ្នកចំរើព្រះពុទ្ធសាសនាពាំនង់ឲ្យយ៉ាងគ្រាន់តែរៀនសូត្រឲ្យចេះចាំ ហើយបង្ហាត់បង្រៀនធំធំប្រជុំសង្ឃយ៉ាងដោតត្រង់ធម្មវិន័យជាបិដក ៣ (ព្រះត្រៃបិដក) ធំធង់ផ្សៀងផ្សាត់ឲ្យត្រឹមត្រូវបួចចាំខ្ទុកត ។ គ្នាមកដោយការស្វាធ្យាយន៍លើកពុទ្ធវចនៈឡើងកាន់ចិត្តពាំនង់អស់ឥតមានចាកដាក់ស្ងឹកតែឫដាក់ផ្ទាំនសិលា ដូចដែលយើនធ្លាប់បានឃើញនៅប្រទេសយើនធំនប្រទេសភូមាដើមទេ ។ សូម្បីវប្បធម៌ពុទ្ធសាសនាហូរចូលមកចាក់ឫសក្នុងប្រទេសខ្មែរ លុតលាស់ឋិតនៅដរាបទល់រដ្ឋកាលព្រះបាទជយវរ្ម័នទី ៧ ហើយអត្ថបទព្រះត្រៃបិដកស្ងឹកតែនេះ កំមិនប្រាកដថាមាននោះឡើយ ។ ឃើញមានតែអត្ថបទបន្តិចបន្តួចដែលចារឹកនៅផ្ទាំនឫដូចក្នុងសម័យអសោកមហាពដែរ ។ លុះមកដល់រដ្ឋកាលព្រះបាទជយវរ្ម័នទី ៧ ទើបមានរឿងដំណាលថា ព្រះអង្គបានបញ្ជូនព្រះរាជបុត្រឲ្យទៅបួសរៀននៅគោះសេរលង្កានៅសតវត្សទី ១៨ នៃព.ស. ហើយវិលមកប្រទេសវិញក្នុងសតវត្សដែល ។ ក្នុងព្រះដំណើរបំពេញបេសកកម្មនៃព្រះថេរៈជាព្រះរាជបុត្រនេះ គង់មានកុលបុត្រខ្មែរច្រើនរូបតាមហែជាសហគារ៍ ហើយគង់មាននាំព្រះត្រៃបិដកស្ងឹកវិតនឹងបករណ៍ឯទៀតច្រើនមកកាន់ប្រទេសខ្លួននៅវេលាត្រឡប់វិញ ។

វិប្បធម៌ពុទ្ធសាសនាផ្នែកអក្សរសាស្ត្រ

វិប្បធម៌ខាងអក្សរសាស្ត្រពុទ្ធសាសនា ទុកជាគ្រឿងរចនាពិសេសមួយ តាំងឡើងដោយសារព្រះពុទ្ធនិងព្រះអនុពុទ្ធលោកអ្នកបំរើព្រះពុទ្ធសាសនា ។ ព្រះពុទ្ធជាម្ចាស់យើងដោយព្រះអង្គទ្រង់បានស្តេចចេញទៅសាងអភិនិស្ក្រមប្រព្រឹត្តទុក្ករកិរិយាអស់ ៦ ព្រះវស្សាហើយបានត្រាស់ដឹងជាព្រះពុទ្ធនៅដែនមគធៈផង នឹងដោយ ពះអង្គត្រាស់សំដែងធម៌ប្រោសវ៉ៃនេយ្យសត្វក្នុងដែននេះជាមុនផង ទើបទ្រង់យកភាសាអ្នកដែននេះដែលហៅថា មគធភាសា មកប្រើប្រកាសធម្មវិន័យដែលទ្រង់បានត្រាស់ដឹង គឺសំដែងធម៌ បញ្ញត្តវិន័យ ដោយភាសានេះទាំងអស់ ។

ពីដើមមកមគធភាសា សម្រាប់ប្រើតាមធម្មតាស្រុក មិនទាន់កប់ថាជាតន្តិភាសា ដូចភាសាសំស្ក្រឹតទេ លុះព្រះពុទ្ធទ្រង់យកមកប្រើក្នុងការផ្សាយព្រះពុទ្ធសាសនាក៏បានទទួលការរចនាក្លាយទៅជាតន្តិភាសា (ភាសាមានរបៀប) ប្រកបដោយលក្ខណៈវចនៈ វិភត្តិ កាល បទ ឯកច្ចយជាដើមយ៉ាងបរិបូណ៌ ហើយផ្ទុកដោយប្បាប់ធម្មវិន័យ មានអត្ថរសជ្រាលជ្រៅ ។ មគធភាសា មានពាក្យហៅម្យ៉ាងទៀតថា ប៉ាលីភាសា ជាភាសាសម្រាប់ប្រកាសធម្មវិន័យពុទ្ធសាសនានេះ ដល់មកក្នុងឆ្នាំបឋមសង្គីតិកាលព្រះសង្គីតិការៈតាំងឡាយ បានចាត់ការរួបរួមទៅជាព្រះបិដក ៣ ដោយ

យកចាលីដទៃ។ មានចាលីនិទានជាដើមមកបញ្ចូលផ្សំផង ។ ចាលីដើមដែលបានឡើងតាន់សង្គាយនាទាំងនេះ ចាត់ជាបករណ៍មួយឈ្មោះថាមូលបករណ៍ (គម្ពីរដើម) ឬហៅថាចាលីដដែលក៏បាន ។ បករណ៍ជាអត្ថវណ្ណនា (សម្រាប់ពណ៌នាសេចក្តី) នៃចាលីនេះហៅថា អដ្ឋកថា ។ បករណ៍ជាអត្ថវណ្ណនានៃបករណ៍ទាំងពីរ គឺចាលី និងអដ្ឋកថា ហៅថាដីកា ។ បករណ៍ក្រៅពីនេះ មានវិសុទ្ធិមគ្គ និងមង្គលត្ថទីបនីជាដើម ហៅថា តន្តិមុត្ត ឬបករណវិសេស ។

ឯព្រះបករណ៍ទាំងឡាយមានអដ្ឋកថាជាដើម តើតឡើងជាលំដាប់តាំងពីអរហន្តសម័យ ហើយច្រើនតែជាចាលីភាសា ។ ទោះមានបករណ៍ខ្លះតាំងនៅជាភាសាដទៃ ក៏ពួកពុទ្ធសាវ័កទាំងឡាយ នាំគ្នាប្រែមកជាចាលីភាសាវិញ ដូចរឿងព្រះពុទ្ធឃោសាចារ្យអ្នកស្រុកមគធៈបាននិមន្តទៅលង្កាទ្វីបប្រែអដ្ឋកថាចេញពីសីហឡភាសាមកជាចាលីភាសា នៅពុទ្ធសតវត្សទី ១០ គឺធ្វើភាសាដែលកត់អដ្ឋកថានោះ ឲ្យទៅជាចាលីភាសាស្របទៅតាមភាសាដែលកត់មូលបករណ៍ ដើម្បីឲ្យផ្សាយទៅកាន់ប្រទេសនានាបានដោយស្រួល ។

លោក រ៉ាយ-ប៊ុក រៀបរៀង

(តចប់)

ទេវតាដ៏តប្បុតហើយ ។ ដល់ទេវតាអស់បុណ្យគឺមានស្រីស្តុំក្រមការ អាមាត្យត្រឿងបបោគតាំងប៉ុន្មាន ទេព្រានក៏លាយបាត់គ្មានសល់ឡើយ ។ ទេវតាមានទេវតាល្អ ទេវតាអាក្រក់ ទេវតាល្អជួយជោះទុក្ខមនុស្សសត្វ យកតាសារគេ ជួយឲ្យគេបានរួចរស់ដ៏រឹតផុតពីខ្មាំងសត្រូវ ទេវតាអាក្រក់ព្យាបាទអាឃាដគំនុំគេ ធ្វើបាបគេ ឲ្យទុក្ខទោសភ័យខ្លាចគេ ។ ព្រះឥន្ទ្រាធិពង ជាស្តេចនៃទេវតា លោកគង់នៅស្ថានត្រៃត្រឹង្សដែលមានដំរី ឯពាណៈជាព្រះពាជយាន ទឹងស្រះបុក្ខរណីជាដើម ។

ឯស្ថានព្រហ្មមានរូបព្រហ្ម ទឹងអរូបព្រហ្ម ,រូបព្រហ្ម ចំពោះព្រះយោគាវចរដែលបានធ្វើសមាធិកម្មដ្ឋាន បានសម្រេចរូបជ្ឈាន អរូបព្រហ្ម ចំពោះអ្នកដែលចម្រើនមេត្តាភាវនា បានស្ងាត់ដំនាញធ្វើសក្តិឆ្នាំអរូបជ្ឈាន រូបព្រហ្មទឹងអរូបព្រហ្មសោយបីតិ, សុខៈឯកគ្គតា ជាអាហារសន្សំនៅដោយឈានចិត្តនោះឯង ។

ពួកទេវតាទឹងព្រហ្ម សុទ្ធតែដាច់បបាតិកកំណើត គឺកើតឡើងចម្រើនវ័យវឌ្ឍនាការប៉ុនបុរសស្ត្រី ១៦ ឆ្នាំ តែម្តង ។

សួរ- ចុះអ្នកដែលធ្វើបុណ្យបាន ចាប ឬ អ្នកដែលធ្វើចាបបាន បុណ្យ យ៉ាងណាទៅវិញ ?

ឆ្លើយ- អ្នកដែលធ្វើបុណ្យបានចាបនោះ មិនមែនទេ, អ្នកធ្វើបុណ្យទៀតែងតែបានបុណ្យ ឯចាបនេះជាផលអំពើអាក្រក់ពីអតីត ដែលមកឲ្យផលក្រោយពេលដែលបានធ្វើបុណ្យ, ឯបុណ្យដែលធ្វើនោះមិនទាន់ឲ្យផលទៅឡើយ ។ ឯធ្វើចាបបានបុណ្យក៏មានន័យប្រហែល ។ គ្នាដែរ ។

សួរ- សត្វដែលទៅកាន់ទុគ្គតិភព តើដោយហេតុអ្វី ? ។

ឆ្លើយ- សត្វដែលទៅកាន់ទុគ្គតិភព ដោយលោភៈ, ទោសៈ មោហៈឬដោយអកុសលចិត្ត ១២ គឺលោភមូល ៨ ទោសមូល ២, មោហមូល ២ ។ លោភៈ ទោសៈ មោហៈ ច្រើននាំសត្វទៅកាន់ចិត្តវិស័យ នរក តិរច្ឆាន, លោភៈចាំងអនិដ្ឋ, ទោសៈចាំងទុក្ខ មោហៈចាំងអនត្ថា ។

ចាបចាំងអស់តើតមកអំពីអកុសលចិត្ត ១២ អកុសល ១២ ក៏ដាដើមចមនៃចាបអកុសលចាំងឡាយ ។

សួរ- តើកម្មមានប៉ុន្មានយ៉ាង ? ។

ឆ្លើយ- កម្មបើសំដែងដោយកិច្ចមាន ៤ យ៉ាង គឺ

១ ជនកកម្ម កម្មជាកុសល ឬ អកុសល ឲ្យសម្រេច

កិច្ច ជាបដិសន្ធិគឺញ៉ាំងសត្វឲ្យកើត ។

๒- ឧបត្ថម្ភកកម្ម កម្មជាកុសល ឬ អកុសល ដែលជួយគាំទ្រផលកម្ម ដែលឲ្យផលមុននោះ ។

๓- ឧបបីឡកកម្ម កម្មជាកុសល ឬ អកុសល ដែលបៀតបៀនផ្តួលកម្មជាអកុសលដែលឲ្យផលមុននោះ ។

๔- ឧបឃាដកកម្ម កម្មជាកុសល ឬ អកុសល ដែលចូលទៅសម្លាប់បង្អស់នូវកម្ម ដែលឲ្យផលមុននោះ ហើយឲ្យផលដោយខ្លួនឯង ។

កម្មបើសំដែងដោយលំដាប់ដែលឲ្យផលនោះមាន ๔ យ៉ាង គឺ

๑- ជនកកម្ម កម្មជាកុសល ឬ អកុសលយ៉ាងធ្ងន់ យ៉ាងដំ ចំណែកខាងកុសលបានខាងឈានសមាបត្តិ ចំណែកខាងអកុសលបានខាងបញ្ចានន្តរិយកម្ម ។

๒- អាសន្នកម្ម កម្មជាកុសល ឬ អកុសលដែលបុគ្គលធ្វើក្នុងកាលជិតមរណកាលហើយរឭកចាំបាន ។

๓- អាចិណ្ណកម្ម កម្មល្អ ឬ អាក្រក់ ដែលបុគ្គលធ្វើតែម្តងហើយសន្សំនឹកឃើញ ។ មិនមានជាប់មិនមានក្ងេច ។

๔- កដត្តាកម្ម កម្មជាកុសល ឬ អកុសល ដែលជាកម្មមានកំលាំងខ្ចាត់ចាយថយ ។

កម្មបើសំដែងដោយកាលកំណត់ឲ្យផ្លែវិផលនោះមាន ៤ យ៉ាងគឺ

១- ទិដ្ឋធម្មវេទនីយកម្ម កម្មជាកុសល ឬអកុសលដែលអាចឲ្យផលក្នុងរវាង ៧ ថ្ងៃ ឬក្នុងបច្ចុប្បន្នជាតិនេះ ។

២- ឧបបជ្ជវេទនីយកម្ម កម្មជាកុសល ឬអកុសលដែលឲ្យផលក្នុងជាតិជាលំដាប់ គឺជាតិទី ២ នោះ បើចំណែកខាងបុណ្យគឺឈានសមាបត្តិ បើចំណែកខាងបាបគឺបញ្ចានន្តរិយកម្ម ។

៣- អបរាបរវេទនីយកម្ម កម្មជាកុសល ឬអកុសលដែលប្រព្រឹត្តជាប់ទៅតាមខ្លួនបុគ្គលដូចស្រមោលតាមរូបឬដូចសុនខតាមម្រឹគ ។

៤- អហោសិកម្ម កម្មជាកុសល ឬអកុសលដែលកន្លងហួសទៅមិនឲ្យផលដល់អ្នកដែលធ្វើនោះឡើយ ដូចកម្មរបស់ព្រះចីណាស្រព ។

សួរ-៖ ម្តេចក៏មានសុភាសិតថាកំឡាំងអ្វីមិនស្មើកំឡាំងកម្ម ? ។

ឆ្លើយ-៖ កម្មនេះជាកុសល ឬអកុសលតែឲ្យផលវេលាណា គ្មានកំឡាំងអ្វីទៅទប់បានសោះឡើយ បានជាថា "កំឡាំងអ្វីមិនស្មើនឹងកំឡាំងកម្ម" ។

ផ្នែកអក្សរសាស្ត្រ

រឿងនេវន្ត (ពាក្យកាព្យ)

លោក អម្ពតក្សត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក-ថែម ពិនិត្យ (តមក)

យល់ពាដក្សត្រី ប្រុសស្រីសល់ស្រី ប្រកបលក្ខណា អង្គុយសំឡឹង
ក្មេបក្មាំងពាល់គ្នា សឹងគន់គិតថា នាងនេះល្អក្រៃ ។ នេះមិនគឺជា
កូនស្រីយាយតា សុទ្ធសាធស័ិយ សមជាធីតា ព្រះមហាក្សត្រៃថ្ងៃ
គ្រប់គ្រងក្រុងក្រៃ ដាំនានា ។ តាមដោយរូបនេះ ប្រាកដជាចេះ
សំដែងទេសនា រំភឹងគិតគន់ ស្រេចដណ្តឹងថា ប្រាកដជាក់ជា
ចេះពិតប្រាកដ ។

នាងនាដឆ្លើយថា ខ្ញុំចេះបានជា ខ្ញុំហ៊ានស្រដី ឯអង្គអាមាត្យ
ព្រះបាទចក្រី ស្តាប់វាក្សត្រី បន្ទូលសារសេង ។ ថ្វាយមាសមួយសែន
ដំឡឹងមានមែន ស្រេចលាលែងផ្តង ចូលទូលព្រះមហា-ក្សត្រាច្បាស់ច្បង
តាមដោយខំនង ជំណើរដែលយល់ ។

ព្រះពោធិសត្វ ពន្ធុកពុទ្ធរត្ន វរញ្ញាណទស្សាល ជ្រាបហើយព្រះអង្គ
ស្តេចទ្រង់អរសាល ស្ទើហាក់ឃ្លានយល់ សម្តេចមហេសី ។ ត្រាស់ថាបើបុ

ចូរទៅយោសនា អស់ពាស្ត្រប្រុសស្រី ព្រះពញាខុនណាង ក្មេងក្មាងតូចក្តី
កុំឲ្យឆ្លើអ្វី វេលាថ្ងៃនេះ ។ ឲ្យមកស្តាប់ទេសន៍ ព្រះធម៌វិសេស
មួយចូរចេះរៃ រើសយានឯណា គួរជាដំនិះ យកឲ្យទៅដែរ ឲ្យចូលមកធាប់
រើសស្រីដង្កែ ឲ្យសុទ្ធសឹងតែ ក្មេងៗប្រដាប់ នូវគ្រឿងអម្ពរ សឹងសបង្គាប់
ឲ្យគាន់ប្រដាប់ ផ្តិលសៃវិនី ។ កន្លោះព្រះពាន ព្រះស្រីឲ្យមាន
ចារៀបនារី ឲ្យដង្កែនាង ដូចយ៉ាងវៃនី ដង្កែទេព្ត ព្រះមហាកស្សត្រា ។
កស្សត្រីបវរ ចាឲ្យស្ទៀកស ពាក់សសោភា ខើបយល់ទត្តម
សាក់សមគួរជា អគ្គព្រះអាចារ្យ សំដែងធម៌ថ្លៃ ។ អស់អាមាត្យលោ
ព្រះមហាកស្សត្រា ចេញចាកពោធ៌ដ៏យ រួសរៀបប្រដាប់ ធាប់ៗ រៃ។ នាំចរ
ឆ្ពោះព្ញ លំទៅយាយតា ។ ខ្លះឡើយគង ដើរច្រាប់ពាស្ត្រផង សឹងស្រុះ
ស្រួលគ្នា មីរមកគាន់តាប់ ចាំស្តាប់ទេសនា រឹងអគ្គអា មាត្យនាំយាន
ទៅ ។ នាំគ្រឿងពាំងឡាយ ចរចូលថ្វាត់ថ្វាយ នាងនាដស្រីពៅ នាង
ចរចូលស្រង់ បំបង់ក្តីក្តៅ អស់ឥតហ្មងសៅ ទ្រង់គ្រឿងអម្ពរ ។ សសម
សោភ័ណមាសនាងប្រពាន ដល់យាយតាខ-ទួលខើបធីតា លីលាចេញចរ
អាមាត្យថ្វាយករ អញ្ជើញនាងទៅ ។ ឡើងគង់លើយាន សេនាពាហន
នាំមុខស្រីពៅ ក្មេងស្ទុះសឹងតែ ដង្កែទួលឡៅ យាយចង់តាមទៅ នាង
ឃាត់ឲ្យខាន ។ ក្មួងក្មួស់អកិរម្យ បើកចាំងលាំ យង់យល់ថ្លើងថ្លាន

រីអ្នកបួរ ប្រុសស្រីផងបាន យល់នាងកល្យាណ ថ្វាថ្ងៃបរ ។ សឹងមីរមក
មើល ស្ទើរនឹងភ្លុកផ្អើល ពាំងព្រះនគរ ប្រឹងមើលក្មេចក្មាំង ស្ទាំងតាំងពាំង
ឈរ ជ្រៀតជ្រួលកែវ ដេរពោលឈ្មោះគ្នា ។ អាមាត្យនាំដល់ សាលា
មណ្ឌល នាទីទេសនា រួតរត់ចរចូល ទៅទូលក្សត្រា បពិត្រព្រះមហា-
ក្សត្រក្សាន្តថ្កើងថ្កល់ ។ រីឯអគ្គិមា ចារ្យចេះទេសនា នោះនិមន្តដល់ ពេង
រៀបទេសនា ក្សត្រានិមិល ជ្រាបហើយត្រេកសល់ ទ្រង់គ្រឿងអម្ពរ ព្រម-
ព្រះមាតា យក្សាជាយា ស្តុះស្តិទ្ធចេញចរ · លង់លុះដល់ស្រេច សម្តេច
ភូធរ បួលគង់រែកវេក ទីចំពោះកន្ត្រែ ។ ទើបត្រាស់សារសង់ និមន្តទ្បើង
គង់ គ្រែធម្មាសន៍ជាក់ រីដនីពាន់ពាំង បិទបាំងព្រះកន្ត្រែ យង់យល់ស្គាល់
ជាក់ ជាព្រះស្វាមី ។ ទីងទៅបង្គំ ត្រែងក្សត្រែពិតពុំ ប្រោសប្រាណ
ប្រណី បិទបៃរបៃតពាន មកបានមហេសី ទំប្រុងស្មារតី ទបព្រះបិទ្ធា ។

សំដែងទេសពិធ ធម៌ថាបពិត្រ ព្រះមហាក្សត្រា ជាក្សត្រឫស់ឫង
គ្រប់គ្រងភពព ឲ្យចេះគោថា ពាំងដប់បទស្តេង ។ ទើបពស្ត្រសព្វស្រុក
ទឹងបានសាន្តសុខ សម្បត្តិលះលែង លាភោគោសោ ភោហោគ្រោងគ្រែង
ព្រោះព្រះអគ្គិតែង ប្រោសប្រាណមេត្តា ។ មួយឲ្យមហាក្សត្រ ទស្សាហ៍ប្រ
ណិប័តន៍ មាតាបិតា មួយឲ្យប្រដៅ បុត្រនូវកុំយា មួយឲ្យមេត្តា សង្រ្គោះ
ញាតិផង ។ មួយនីរាល គ្រប់ក្រុមក្រវៃល់ បម្រើព័ប់រង ទៀយព្រួយ

លំបាក គោកយ៉ាកកន្ធង គួរក្សត្រិយាស់ប្បធ រិះរង្វាន់វា ។ មួយនីរសួយ ខោះពីរខោះមួយ តិចតាមបូរ កុំស្តេចចង់ផ្ញើស ឲ្យលើសពុំជា មួយនីរដ្ឋាបូរាណជានី ។ តុំព្រះអង្គធ្វេស មាត់ងាយប្រហែស មួយបូរភូមី គោរពអតិវន្ត សមណព្រាហ្មណ៍ដី សាងផលជាទី បុណ្យបរលោកនាយ ។ មួយបូរមហាក្សត្រ រៀរដីវិតសក្ត តំរាំនតាំងឡាយ មួយទេពតក្តី ប្រដិតឆ្ងាយ ស្តេចរិះរៀបថ្វាយ ជាតិជាអាលដ្ឋ ។ មួយសូមកំសត់ កំសោយទុគ្គត អត់មហារធ ឥតហានឥតផ្តុះ គួរព្រះភូមី អាចឲ្យជន្មដ៏-វិតរាំគួរគាប់ ។ នេះហើយបពិត្រ ហៅធម៌ទសពិធ ពាជធម៌ជាប្បាប់ គួរក្សត្រិរវង្ស ព្រះអង្គអាចចាប់ ចេះប្លួលចិត្តរាប់ ជាតិជានិរន្តរ៍ ។ ទើបទេពតូចធំ អង្គឥន្ទ្រព្រហ្ម ដួយចំរើនជន្ម វិទ្ធីវិឌ្ឍន៍ ប្រាកដជាជន្ម ជាទីផលបុណ្យ ដល់បរលោកនាយ ។

លុះចប់ទេសនា មន្ត្រីសេនា ជាតិជនតាំងឡាយ សរសើរត្រេកអរ ស្មោះសរើរករាយ បូជាថ្វាត់ថ្វាយ ទ្រព្យផងក្រាសក្រៃ ។ រីមហាក្សត្រផ្ទៀង ស្តាប់ព្រះសូរសៀង ពិតពុំសង្ស័យ នេះប្រាកដជាត់ ជាអ្នកមាសថ្លៃ ជាថ្លើមហ៊ាយ សាច់សង្ឃាក ។ លុះនាងយាងយាស ពីត្រែថ្ងៃ ធម្មាសន៍ ព្រះបន្ទូលថា នាងជាពាជបុត្រ មហាក្សត្រឯណា កន្ទុនាមនាមនាងឈ្មោះអ្វី ។

នាងស្តាប់បន្ទូល មហាកស្សត្រៀង្គុល ទើបទូលវិនវ៉ី បពិត្រព្រះមហា
កស្សត្រាធិបតី ខ្ញុំជាបុត្រី កស្សត្រកន្យាឯតអង្គ ។ នាមយសវតី ខ្ញុំមកនឹង
ប្តី លុះមកដល់ក្នុង ដែនពារាណសី ស្ទឹមវារង្ស ឲ្យចាំព្រះអង្គ នៅនា
ដើមជ្រៃ ។ ក្រោយនោះមានយក្ខ ស្រីមួយអបល័ក្ខណ៍ ចិត្តចោរចង្រៃ
រាមកវាយដំ ស្មានខ្ញុំក្បាលក្បែយ ចោលក្នុងដលស័យ ខ្ញុំអណ្តែតទៅ ។
ចូលជាប់នឹងស្ពាន យាយតាមួយមាន សប្បុរសពេកក្រៃ គាត់មានករុណា
មេត្តាដូចទៅ នាំទៅលំទៅ មើលខ្ញុំគាល់ជា ។

ស្តេចស្តាប់ជាក់ជា ដឿជាមហា មហេសីប្រាប់ថា ម៉ៃបួនវាល័ក្ខណ៍
រួយកូមោហា បងដឹងជាក់ច្បាស់ - កដតាលមកដល់ ។ បងស្ទៀមពុំស្តី
ខ្លាសមុខមន្ត្រី ពាដវង្សសាមល់ អាចអត់អាហារ តោងនាតែងឆ្ងល់ ទុក្ខ
ពេមនស្សស្រល់ សែនសោយសោកា ។ ធ្វេសធ្វេលុះលង់ មានទេពឯក-
អង្គ មមាលសប្តិថា ប្អូនមាសពុំក្បែយ ប្រល័យជន្មា ឲ្យរកអ្នកណា
ចែងចេះធម៌ថ្លៃ ។ ហេតុនេះប្អូនអើយ បងអ្នកបានស្បែយ ទុក្ខពីហ័ទ្យ
តែមក្បាន្តសាន្តសុខ យល់មុខមាសថ្លៃ មាសមេពុំក្បែយ ដូចពាក្យទៅតា ។

កស្ត្រីឧត្តម ជរចូលបង្កើ ទុបបាទសោកា ស្តែងស្តេចថ្នាក់ថ្នម បី
បមប្អូនក្បា សែនសោយសោកា សន្ធប់សុបសៅ ។ រពាដវង្ស មន្ត្រីសេនា
ពស្តេចសក្តិឆ្ងាស់ យំស្រែកទ្រហោ ដំទះក្តៅ សោកសន្ធប់ទៅ ទីពាំង

អស់អង្គ ។ តាប់តាល់ណោះយក្ខ កុម្ភណ្ឌបួននាក់ នាំតស្ដីផលក្នុង ស្រះ
ស្រង់រង់ថ្ម ជាតិជាសួយពង្ស ពូជពោធិវង្ស ទៅទឹកស្រះស្រង់ ។ លុះហិច
ហោះដល់ មៀនមើលទៅយល់ ក្ស័ត្រចាត់ស្មារតី រាស្ត្រពលវង្ស សេនា
មន្ត្រី ក្មេងក្មាងតូចក្តី សឹងសោកសន្ធប់ ។ យក្ខផងកិតភ័យ រិះគិតសង្ស័យ
យកទឹកស្រោចស្រប់ ក្ស័ត្រចាំងពីរពង្ស ព្រះអង្គស្ទុះស្ទប់ យក្ខបួលសួរ
សព្វ ដឹងដើមសេចក្តី ។ ក៏ណាក្ស័ត្រទ្រង់យស់ ឲ្យយក្ខច្រោសប្រស់
រាជវង្សមន្ត្រី អស់រាស្ត្រប្រជា សេនាសេនី មែនមានស្មារតី បង្គំគាល់
រៅ ។ ហើយស្ដេចប្រើយក្ស ចាំងបួនចូរនាក់ នានាំគ្នារៅ ចាប់យក
យក្ខស្រី អប្រិយយោរយៅ កុំខុកឲ្យនៅ ពិឃាដឲ្យក្ស័យ ។

ក៏ណាណោះកុម្ភណ្ឌ ទទនអកវិន្ទ បង្គំក្ស័ត្រថ្លៃ មៀនមើលយល់ជាក់
កណ្ដាលពេនដ័យ រមន្ទុស្សផងតិយ តើតកោលាហល ។ រីរូបមហេសី
ប្រែជាយក្ខស្រី ងាត់ធំពះពល់ ពីរនាក់ចាប់ដៃ យក្ខស្រីខ្ញាំងសល់
រលាស់ស្ទុះដល់ ខាងក្រៅសាលា ។ យក្ខពីរចូលចាប់ ដៃចាំងពីរខ្ចាប់
យក្ខពីរម្ខាង ចរចូលជាក់ថង ចាប់ចងហត្ថា នាំថ្វាយព្រះមហា - បុរស
រត្នកដ ។ មន្ទុស្សម្នាយល់យក្ខ តិតភ័យក្បាក្បាក់ ព្រួញប្រាណខ្ចប់ខ្ចាច
ក្មេងខ្លាចយំកង រំពងប្រសាច ពេញពាសពុំអាច ឥតឮនឹងរៅបាន ។

ទើបព្រះទ្រង់ល័ក្ខណ៍ បន្ទូលសួរយក្ខ ម្ចៃមេសាមាន្យ ថានជាមិន

ធ្វើ អំពើឈ្មានពាន ច្នេះតើមិនមាន ចំណាំបងអ្នក ។

យក្ខិនីនោះ ទៀនឲ្យលស្មានស្មោះ សូមទ្រង់ប្រណី អញខ្ញុំឈ្មាន ពាន បងបានបត្រី ជាតិជាស្វាមី មិនមានកូតក ។

ស្តេចស្តាប់ក្តាត់ក្តៅ គ្រាស់ថាយកទៅ សម្លាប់ឲ្យមរណ៍ នាងនាជ ធ្វើយធ្វាស់ ឲ្យលាស់កូធរ ខ្ញុំសូមអង្វរ ព្រោះជាប្រយោ ។ នេះគឺអកុសល ពីព្រោះមកផ្តល់ មិនមានអ្នកណា ឯងអាចឲ្យទេ មានតែវេរ អង្គឯងបងអ្នក ឃ្លាបងឃ្លាតប្អូនបង ។

ព្រះបាទបច្ចន្តប្បាស់ ស្តាប់នាងឲ្យលាស់ ឲ្យលាមគន្ធ ធម្មារិសុទ្ធ ព្រះពុទ្ធឥតហ្មង ឥតមានចិត្តបង ទៅសង់ទ័យ ។ ទើបគ្រាស់ហៅអ្នក ទាំងបួនបងប្អូន នេះទោសតណ្ហា ពេលពាលក្តាត់ក្តៅ យកទៅខុតជា ប្រពន្ធពាល់គ្នា តាមចំណង់អ្នក ។

កុម្ភណ្ឌបួនប ង្គីគាល់ដួញជង្ហ. លុតលាយកយក្ខ ទៅនៅស្ងាល ស្នេហ៍ មួយខែមួយនាក់ មេត្រីរួមភ្ញៀ រួមរស់រៀងទៅ ។

ព្រៃពង្រោ ធីសត្វ ត្តមោ ព្រះអង្គឲ្យហៅ យាយតាទៅដល់ មណ្ឌលបមទៅ ប្រាសប្រពន្ធទូ មាសប្រាក់ពស្ត្រា ។ ប្រពន្ធដំរី សេះ គោក្របី រនេះមនុស្សម្នា តបគុណហើយទ្រង់ ឲ្យសង់គ្រែហា ប្រពន្ធ ឲ្យអ- ស្រ័យស្រុកក្នុងវាំង ។ ស្តេចនៅនិវុក្ខ តទៅសឹងសុខ ទៀង

ទើបអស់ពាំង មន្ត្រីព្រឹទ្ធប្រើ ឲ្យធ្វើសារស័ង ប្រើស្រាលស្រឹតស្រាំង ស្រី
ស្រុតក្រៅក្តង ។ រើសពាជមន្ត្រី បុត្រក្សត្រី រត្នៈយឯតអង្គ តាន់តាប់តប
តាយ ឆោមធាយវារវង្ស វារាសគួរគង់ គួរគាល់បំរើ ។ រើសរតជោត
ដ៏-យាយល់ប្រពៃ ច្រាមច្រាប់ឲ្យធ្វើ សាន៍សង៌មន្ទីរ ពិព្វទីប្រសើរ ទ្រង់
ពស្ត្រសារពើ ពិតពុំឲ្យខ្វះ ។ ដុំក្សត្រសាមល់ មិញមានមកដល់ លុះបាន
តេដះ ជោគជ័យអតិរេក អតិសេកអង្គព្រះ ពោធីទ្រង់តបៈ ទ្វាទានឯ
កល្យាណ ។ ពីរពង្សមហាក្សត្រ គង់លើថ្នក់ត្នៃ ស្រមណ៌ព្រាហ្មណ៌ត្រប់
ច្រាណ សូត្រផ្តុំសុគ្គី ថ្វាយដ៏យក្សត្រក្សាន្ត ផ្តុំត្រៃសព្វសាន ទ្វូឆ្លើងតន្ត្រី។
ពីរពង្សខត្តមោ លើសលើលោរកោ ជាឆ្នើមកងត្រៃ ដូចព្រះឥន្ទ្រា សុជ-
ភាមហាសី ត្រកាលឥតបី អ្នកណាផ្ទឹមផង ។ ឲ្យសេងមហោស្រព ច្រាំ
ពីរថ្ងៃគ្រប់ សប្បាយកន្ទង ព្រះពោធិវង្ស ទ្រទ្រង់ពស្ស្តង បិតាគ្រប់គ្រង
រួមរក្សាពស្ត្រ ។ ព្រះមហាក្សត្រា តែងទ្រង់សព្ធា ឲ្យទានច្រាក់មាស
តែវតង៌ពស្ត្រា អាហារពោរពាស សុះសព្វពស្ត្រទាស ទ្វូគ្រប់សព្វថ្ងៃ ។
ទ្រង់ទ្វេសពិធ ធម៌ទានរាជក្រិត្យ ជាក្រមក្សត្រថ្ងៃ តែងឲ្យទ្រព្យ ដនជាតិធ
ង៌ ព្ធលុះហើយនៃ ទ្រង់ទាន៖៧ ។ ហើយមហាក្សត្រក្សាន្ត ឲ្យសង៌ធ
ទាន សម្រាប់ទុក៖៧ ឯអង្គព្រះចាទ ខ្នាទ៧ចម៖៧ ស្តែងស្តេចតែង៖៧
ឲ្យទានសព្វគាល ។

(មានត)

កណ្ឌទី ៣០

ឧកញ៉ាវិបុលភក្តីសេនា ង្ហឺ-ភាង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
ទំងបេះទុបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

កងសុនកុងឆ្លើយថា ដែលបងគិតដូច្នោះកំត្រូវហើយ តែសូមឲ្យប្រើតាហានជាបំរើ ទៅស៊ើបស្តាប់តាសិនទើងឲ្យដឹងថា ចូឆ្នូទើងលើកទ័ពធ្វើមកវាយយកស្រុកយើងមែនឬទេ ? បើលើកមកមែនសឹមយើងទទួលចំញឹមអួនហ៊ីអួនសុងទុក បើចូឆ្នូមិនលើកទ័ពមកញីញក់ស្រុកយើងទេ យើងត្រូវចាប់ខ្លួនអួនហ៊ីអួនសុងសម្លាប់ចេញ រួចគាត់យកក្បាលទៅឲ្យចូឆ្នូ ។ កងសុនឱងយល់ឃើញត្រូវកំចាត់តាហានជាបំរើទៅស៊ើបស្តាប់ការព័តងំទ័ពចូឆ្នូ ។តាហានជាបំរើទទួលពាក្យហើយក៏លាទៅ កងសុនឱងកំចាត់ឲ្យតាហានចេញទៅទទួលនាំអួនហ៊ីអួនសុងចូលមក ។

ឯអ្នកហ៊ុំ អ្នកសុងក៏ប្រឹក្សាគ្នាថា តាហានក្នុងស្រុកលៀវតាំងនេះ មានប្រហែល ៥ ម៉ឺនជុំយ យើញថាល្មមនឹងទប់ទល់ទ័ពចូងបាន ប្រសិនបើយើងចូលទៅនៅហើយ ត្រូវរំនៃតជាណ្តើមយកស្រុកនេះរួចសម្លាប់កងស៊ុនខងចេញ ហើយនឹងបានបញ្ចុះបញ្ចូលប្រមូលអ្នកស្រុកផ្សំនឹងតាហានរបស់យើង លើកទៅច្បាំងជាណ្តើមយកខែត្រខ្លួងដើងរបស់យើងវិញ ។ លុះប្រឹក្សាគ្នាស្រេចហើយ ក៏នាំគ្នាចូលទៅជួបនឹងកងស៊ុនខងក្នុងខណៈនោះ កងស៊ុនខងឲ្យរៀបចំទីសំណាក់អាស្រ័យ ឲ្យអ្នកហ៊ុំអ្នកសុងនៅតាមសមគួរ ។ ឯកងស៊ុនខងក៏ធ្វើជាឈឺមិនសប្បាយ មិនបានចេញមកនិយាយការពាដការ ប្រាប់ថានឹងធ្វើស្តាប់ដំណឹងកងទ័ពចូង ។

ឯតាហានដែលទៅស៊ើបការ ក៏ត្រឡប់មកវិញនាំពាំងពាតិមានមកប្តឹងកងស៊ុនខងថា ឥឡូវនេះ កងទ័ពចូងមកតាំងបន្ទាយនៅក្នុងស្រុកអេកដាវ មិនបានរំនៃតនឹងលើកមកវាយស្រុកលៀវតាំងជាស្រុករបស់យើងទេ។ កងស៊ុនខងឮដូច្នោះ ក៏មានអំណរ ទើបចាត់តាហានប្រហែល ៥០ នាក់ កាន់អាវុធគ្រប់ដៃទៅពួនបង្កប់ទាំងក្នុងហើយបង្គាប់ថា បើអ្នកហ៊ុំអ្នកសុងចូលមកប្រឹក្សាការពាដការ ហើយឮសំឡេងយើងស្រែកថាយកចុះ ចូរនាំគ្នាចេញមកចាប់អ្នកហ៊ុំ អ្នកសុងនាំទៅសម្លាប់ចេញ លុះចាត់ចែងស្រេចហើយក៏ឲ្យបំរើទៅហៅអ្នកហ៊ុំអ្នកសុងចូលមកប្រឹក្សាការពាដការ កងស៊ុន-

ខ្ញុំឯងហើយ កំបើកភ្នែកសំឡក់ហើយស្រែកថា ឱធំបានតន្ទេលពីណាយក
ឲ្យអគ្គីយ ក្បាលឯងទាំង ២ នាក់នេះ ឱធំត្រូវដាក់ជាលនាំយកទៅផ្លូវ-
ឆ្ងាយ ហើយក៏ស្រែកថាគ្នាយើងចុះដៃគ្នា តាហានទាំងពួងក៏ចេញស្រែ
មកចោមរោមពីមុខពីក្រោយចាប់អ្នកហ៊ី អ្នកសុង តាប់សម្ងាប់នៅទីនោះ
ហើយគាត់យកក្បាលទៅច្រកជាលខុក កងស៊ុនខងក៏ឲ្យតាហាន
នាំយកក្បាលអ្នកហ៊ី អ្នកសុងនោះ ទៅឲ្យចូធូងស្រុកអេកដាវ តាហាន
ក៏នាំយកចេញទៅ ។

ខណៈ គាលដែលចូធូងតាំងទ័ពនៅក្នុងស្រុកអេកដាវនោះ ហៅហ៊ីខុនធីង
ទៀវលៀនយាយដាចូធូងថា លោកមិនលើកទ័ពទៅវាយស្រុកលៀវតាំង
ហើយក៏មិនត្រូវមកបង្អង់នៅធ្វើអ្វី ក្នុងទីនេះឲ្យឃ្លាតរាវទេ គួរតែលើកទ័ព
ត្រឡប់ចូលទៅស្រុកហ៊ូគោវិញស្រួលជាង ខ្លាចឡៅប៉ៅនឹងឡៅពី
លើកទ័ពមក ធ្វើអន្តរាយ ហើយនឹងបានរិះគិតការពារក្បាស្រុកគេទៅ ។
ចូធូងឆ្លើយថាអ្នករាល់គ្នានិយាយនេះត្រូវហើយ តែយើងសូមឲ្យបង្អង់ឈប់
ចាំពួកអ្នកស្រុកលៀវតាំង យកក្បាលអ្នកហ៊ី អ្នកសុង មកឲ្យយើងសិន
រួចសឹមយើងលើកកងទ័ពត្រឡប់ទៅវិញ សេនាតាហានទាំងពួងបាន
ស្តាប់ហើយ ក៏មិនមានសេចក្តីដឿងដល់តិចសោះ ទាំងអស់គ្នាមើលមុខគ្នា
ទៅវិញទៅមកក៏ញញឹម ខណៈនោះ មានអ្នកបំរើម្នាក់ចូលមកដំណឹងថា

ពាហានកងសុនខនាំក្បាលអ្នកហ្មឺ អ្នកសុងមកដូនលោក ក្នុងខណៈ
នោះ ទីប្រឹក្សាទងសេនាពាហាន ពាំងអស់ក៏តក់ស្លុតរន្ធត់ក្នុងចិត្តមើលមុខ
គ្នាស្ទាំងតាំងពាំងអស់គ្នា ចូរឆ្លូកឲ្យហៅបំរើកងសុនខងឲ្យចូលមក ពាហាន
នោះគំនាប់ហើយដំរាបថា កងសុនខងឮដំណឹងថា អ្នកហ្មឺ អ្នកសុង
ជាសត្រូវនឹងមហាទេវរាជ ទើបចាប់ខ្លួនសម្លាប់តាត់យកក្បាលឲ្យខ្ញុំបាទ
នាំមកដូនលោក ឯខ្លួនកងសុនខងនោះថា សូមពឹងបុណ្យមហាទេវ-
រាជតមក ។

ចូរឆ្លូរហើយក៏មានអំណរពន់ប្រមាណណាស់ សើចហើយ
និយាយទងពាហានពាំងពួងថា គុយកែនោះក្មេងតែខ្លួនទេ ឯត្រង់
ជម្រះប្រាជ្ញាវិញនោះ ទងសំគាល់មើលការអ្នកមិនចេះខុសសោះ ថាហើយ
ក៏យកមាសប្រាក់ទងគ្រឿងសម្ផែកបំពាក់មកឲ្យ បំរើកងសុនខងជាច្រើន
ហើយឲ្យធ្វើត្រា តាំងកងសុនខងជាចៅហ្វាយស្រុកលៀវតាំងជាបំណាច់
តាមគុណតាប់ ។ បំរើកងទទួលរបស់ទ្រព្យទងនឹងត្រាតាំង ហើយលាចូរឆ្លូ
វិលទៅស្រុកលៀវតាំងវិញ ទីប្រឹក្សាទងសេនាពាហានទាំងអស់គ្នាក៏
ដំរាបសួរចូរឆ្លូថា តាលបំរើកងសុនខងនាំក្បាលអ្នកហ្មឺ អ្នកសុងមកដូន
លោកមានប្រសាសន៍សរសើរគុយកែថា មានជម្រះប្រាជ្ញាប្រមាណការ
អ្នកមិនខុសនោះ គុយកែបានឆ្លើយថាម្តេចខ្លះខុសឲ្យលោក ? ។ ចូរឆ្លូក៏

លួកយកសំបុត្រគុយតែឲ្យទុកតាលដ៏តនឹងស្ងាប់នោះមកឲ្យអ្នកចាំងអស់គ្នា
មើល ឃើញសេចក្តីថា ខ្ញុំបាទគុយតែសូមដំរាបទុកដល់មហាឧបរាជ
សូមជ្រាប ព្រោះខ្ញុំបាទបានដឹងថា អ្នកហ៊ឺ, អ្នកសុន៍នោះនឹងតត់ទៅ
ទៅពីនឹងបុណ្យតន៍សុនទន៍ថៅហ្វាយស្រុកលៀតាំង កុំឲ្យលើកតន៍ទ័ព
ទៅធ្វើអន្តរាយស្រុកលៀតាំងនោះ ឲ្យបណ្តាពស្ត្រអ្នកស្រុកបានសេចក្តី
ត្រួយលំបាកក្តៅក្រហាយឡើយ ព្រោះហេតុថាតន៍សុនទន៍នឹង អ្នកហ៊ឺ,
អ្នកសុន៍នោះ មុនជានឹងប្រទូស្តរាយគ្នាមិនខាន បើលោកលើកទ័ពទៅរាយ
ស្រុកលៀតាំងវេលាណា ខ្ញុំបាទយើញថាតន៍សុនទន៍នឹងអ្នកហ៊ឺ, អ្នកសុន
ក៏តន៍នឹងរួមគំនិតគ្នា ក៏ប្រាំនឹងលោកឲ្យតាហានលោកបានសេចក្តីលំ-
បាក ទីប្រឹក្សាសេនាតាហានទាំងពួងឃើញសេចក្តីសំបុត្រដូច្នោះក៏អស្ចារ្យ
ក្នុងចិត្តនាំគ្នាទៅដែសរសើរគុយ.តថា មានដម្រេះប្រាជ្ញាសំគាល់ការ
អ្វីដូចខ្លួន មកបញ្ចាលឲ្យថាត្រូវមិនខុសសោះ ហើយនាំគ្នាតែងគ្រឿង
សែនមានទៀនធូបអុជបួងសពគុយ.តចាំងអស់គ្នា ។

កាលគុយតែទៅទៅនឹងចូនោះអាយុ ៤៧ ឆ្នាំ ធ្វើរាជការមាន
បំណាច់តាប់ប្រសើរ ១១ ឆ្នាំ កាលស្ងាប់នោះអាយុបាន ៣៨ ឆ្នាំ ។ ចូនួ
ក៏លើកតន៍ទ័ពទៅតាំងនៅក្នុងស្រុកគីដាវ ហើយឲ្យតាហាននាំយកសពគុយ
តែហៅទៅបញ្ចុះក្នុងស្រុកហ៊ូគោ ។ ដៀប៉ុកដំរាបចូនួថា អាណាខ្ញែត្រខាង

ទិសទក្ខរនោះ លោកតំបានប្រាប់ប្រាមរាបទាបហើយ សូមឲ្យលោក
លើកកងទ័ពត្រឡប់ទៅស្រុកត្រូងវិញ ដើម្បីនឹងបានបម្រុងសេនា-
ហានឲ្យមានកំឡាំង ហើយនឹងលើកទ័ពទៅវាយស្រុកស៊ីនគួន ។ចូរធ្លុតប
ថា ដែលអ្នកជាស៊ីតឿនដូច្នេះ កំត្រូវសមនឹងគំនិតរបស់យើងហើយ លុះ
ដល់ពេលយប់ចូរធ្លុកនាំសុនហ៊ីវឡើងលើសេះបន្ទាយ យើញផ្កាយទាង
ទិសទក្ខិណ មានរស្មីរុងរឿង កំចង្អុលឲ្យស៊ុនហ៊ីវមើលផ្កាយហើយថា
ដែលៈយើងនឹងលើកកងទ័ព ទៅវាយស្រុកកាំងតាំងនោះ យើញថាមិន
ស្រួលទេ ព្រោះផ្កាយទាងទិសទក្ខិណត្រង់ស្រុកកាំងតាំងមានរស្មីជ្រលោភ្លឺ
ត្រចះណាស់ ។ ស៊ុនហ៊ីវតបថា មហាទេពវាដមានវាសនាធំទូលាយក្រៃ
ពេកណាស់ ទោះបីបើផ្កាយទាងទិសទក្ខិណមានរស្មីបរិបូណ៌យ៉ាងណាក្តី
បើយើងនឹងលើកទ័ពទៅប្រាបប្រាម កំគង់នឹងឈ្នះបានជាមិនខាន ដោយបុណ្យ
នឹងអំណាចប្រាជ្ញារបស់លោងប្រាកដ ។ កាលកំពុងនិយាយគ្នានោះ
ចូរធ្លុនឹងសុនហ៊ីវទទួលក្រឡែតទៅទាងក្រោមសើន យើញពួរស្មើដាច
អណ្តាតភ្លើងឆេះឡើង កំពស់ប្រហែល ៤ ហត្ថ ចូរធ្លុកំសួរស៊ុនហ៊ីវថា
ហេតុម្តេចបានជាកើតភ្លើងភ្លឺដូច្នេះ ស៊ុនហ៊ីវតបថា ប្រហែលក្រោមដីនោះ
មានរបស់អ្វីចំឡែកខើបដូច្នេះ ចូរធ្លុចុះមកមើល ហើយឲ្យទាហានជីក
ប៉ានរូបក្លោកមាស ១ ក្រហម ទំហំប៉ុន្មែក្រូចដំបៀតប៉ាន ប្លែកក្រូចខ្ចៃ

ចូរធ្វើយកមកម៉ែលហើយសួរសុនហ៊ុំថា ដែលយើងបានរបស់យ៉ាងនេះ ជាល្អឬអាក្រក់ប្រការម្តេច ? ។ ស៊ុនហ៊ុំវិនធ្វើយថា កាលគ្រាមាតាព្រះចៅស៊ុនតេនៅជាវាស្តូចំណុះស្រុកក្រៅនៅឡើយ មានសុបិនឥតមិត្តថា បានលេបហង្សចម្ងាក់ចូលទៅក្នុងពោះ លុះអំណឹះតមកព្រះនាងក៏មានគភ៌ ប្រសូតចេញមកជាបុត្រប្រុស លុះមានវ័យចំរើនធំឡើងប្រាកដជាគតញ្ញូដឹងគុណណាស់ ។ ខណៈនោះ ព្រះចៅធ្វើរៀតបានសោយរាជសម្បត្តិ ទ្រង់ជ្រាបថា បុត្រព្រះនាងនោះមានសេចក្តីសុចរិតគតញ្ញូដឹងមាតា ទើបទ្រង់ព្រះរាជទានព្រះរាជធីតា អំណឹះតមក ក៏បានសោយរាជ-សម្បត្តិទ្រង់ព្រះនាមព្រះចៅស៊ុនតេ ដែលលោកបានរូបក្លោកមាសដូច្នេះ ល្អណាស់ ។

ចូរឮដូច្នោះ ក៏មានចិត្តសោមនស្សត្រេកអរពន់ប្រមាណ ប្រមូលពាហនទីដ្ឋកស្រុក ឲ្យតេជង្គកំបោរមកគរធ្វើជាប្រាសាទ នៅកន្លែងមាតាខ្ញុំដៀងហោ ត្រង់ដំបន់ធ្វើបគុន ប្រាសាទនោះខ្ពស់ធំណាស់ ធ្វើ ១ ឆ្នាំទើបហើយស្រេច រួចឲ្យយកមករូបក្លោកមាសទៅតាំងពុកលើប្រាសាទសម្រាប់ធីងបានគោរពបូជា ចោសិតជាប្អូនចោតីដំណរបច្ចូរជាបិតាថា បិតាសាងប្រាសាទនេះហើយ ត្រូវសាងជាទីបន្ទប់តាំងសងខាង ខាងស្តាំនោះ ឲ្យធ្វើជារូបមករ ខាងឆ្វេងឲ្យធ្វើជារូបហង្សពុក ហើយឲ្យធ្វើ

ស្តានតរហូតចូលទៅដាច់នឹងប្រាសាទធំ ត្រង់ទ្វារដើរចេញចូលបានរហូត
ទៅសងខាង ទើបនឹងល្អសមគ្នា ។ ចូរឆ្កឹចូលចិត្ត ទើបបង្គាប់ឲ្យចាកឹ
នឹងចាស់តធ្វើជាមេការត្រួតត្រាការនោះ ឯទៀវអៀវនោះឲ្យលើក
ទាហានទៅតាំងបំរុងការពាររក្សាចុងដែនស្រុកគីដីវ ។ ខណៈនោះ ចូរឆ្
បានទាហានរបស់អ្នកនៀវប្រហែល ៥០ ម៉ឺន នឹងទាហានឯកជាច្រើន
ចូរឆ្កឹឲ្យចាត់ចែងទុកព្រមស្រេចហើយ កំលើកទ័ពត្រឡប់ចូលទៅ
ក្រុងហ៊ូតោវិញ តាំងចែករង្វាន់ជាគុណបំណាច់តាមគុណានុរូប ហើយ
ចូរឆ្ឲ្យហៅខុនគុយអេកជាបុត្រកុយតែមក ចិញ្ចឹមរក្សាទុកឲ្យពាដការទើប
ប្រឹក្សានឹងខ្ញុំពាដការតូច ដំថា យើងនឹងលើកកងទ័ពទៅកំចាត់ខ្មៅប៉ាវ
នឹងស៊ុនគួនទៀត តើអ្នកពាល់គ្នាយល់ឃើញល្អ ឬអាក្រក់ប្រការម្តេច ។
ស៊ុនហុកធ្វើយថា លោកទៅធ្វើការសង្គ្រាម ទើបនឹងវិលមកថ្មី ។
ទាហានទាំងពួងកំពុងតែនឿយហត់នៅឡើយ សូមឲ្យឈប់បង្អង់បំរុងកំ
ឡាំងទាហានឲ្យស្រួលបួលសិន កាលណាចូលឆ្នាំថ្មីរួច សឹមលើកៈទៅ
ធ្វើការ ចូរឆ្កឹយល់ត្រូវផង ទើបតាំងហាត់សមទាហាន បំរុងគ្រឿងសស្ត្រា
វុធទុកព្រមព្រៀង នឹងឲ្យមានចិត្តក្លាហាន ក្នុងការសឹកសង្គ្រាម ។

ឯខ្មៅពីដែលនៅក្នុងដែនស្រុកតែងដីវនោះ ខ្មៅប៉ាវកំទុក
ចម្រុងដល់ខ្លាត សម័យមួយ មានបំរើរសេះម្នាក់ នាំសេចក្តីចូលមកដំ

កបខ្លៅប៉ៀវថា ខៀវប៊ូនឆ័តាន់ស៊ូន ដែលលោកឲ្យលើកទាហាន
ទៅយាមល្បាតផ្លូវគយ នៅស្រុកគាំងហែនឆ័ស្រុកគាំងតាំងនោះឥឡូវ
ខៀវប៊ូនឆ័តាន់ស៊ូននោះ លើកទាហានដើរពាតត្បាតយកបង់ទ្រព្យ
អាណាប្រជារាស្ត្រជាច្រើនច្រលំទាំងណាស់ ហើយមានចិត្តកំរើកតាំងរឹង
ទទឹងនៅស្រុកគាំងហែ ខ្លៅប៉ៀវឮហើយក៏តក់ស្លុតក្នុងចិត្ត ទើបប្រឹក្សា
នឹងសេនាទាហានទាំងពួងថា យើងនឹងរិះគិតប្រការម្តេច ? ។ ខ្លៅពី
ឆ្លើយថា ដែលខៀវម៉ូនតាន់ស៊ូនគិតប្រទូស្តកយនឆ័លោកនោះ ខ្ញុំបាទ
នឹងសូមទទួលអាសាទៅកំចាត់ចេញឲ្យបាន ខ្លៅប៉ៀវបានស្តាប់ដូច្នោះ
ក៏យល់ព្រម ទើបប្រមូលពលទាហានបាន ៣ ម៉ឺនប្រគល់ឲ្យខ្លៅ
ពី ។ ក៏នាំគ្នាអ៊ូ ខៀវហ៊ុយ ដូឡឆ័លើកទ័ពចេញទៅដល់ដែនស្រុក
គាំងហែ ហើយក៏ឲ្យតាំងបន្ទាយនៅទីនោះ ។

ឯខៀវប៊ូ តាន់ស៊ូនដឹងថា ខ្លៅពីលើកទ័ពមក ក៏លើកទាហាន
ចេញមកច្បាំងនឹងខ្លៅពី ។ ក៏នាំទាហានចេញទៅក្រៅបន្ទាយហើយ
ប្រើគ្នួនអ៊ូ ខៀវហ៊ុយ ដូឡឆ័ បរសេះចេញទៅមុខទាហានទាំងពួង
ខ្លៅពីឃើញសេះ ដែលខៀវប៊ូដឹះ មានលក្ខណៈថ្លីដើរស្ទួរហ៊ាស
ល្បឿនណាស់ ក៏និយាយនឹងគ្នួនអ៊ូ ខៀវហ៊ុយ ដូឡឆ័ថា សេះដែល
ខៀវប៊ូដឹះនោះ ល្អពេញចិត្តយើង ធ្វើម្តេច យើងនឹងបានយកមកទុក

ដៃ ។ ដូច្នេះឆ្លើយថា លោកកុំព្រួយឡើយ ខ្ញុំបានឮដំណឹងទួលយកពាសាចេញទៅចាប់យកសេះនោះដូនលោកឲ្យបាន ហើយក៏បរសេះពាំទួនចេញទៅចាំដឹងទៀបប៊ីបាន ៣ ភ្លែត ដូច្នេះយកខ្លួនចាក់ត្រួតទៀបប៊ីភ្ជាប់ពីលើសេះស្ទាប់ ហើយចាប់សេះនោះនាំមកឲ្យឡៅពី ។ គាន់ស្ងួនឃើញដូច្នេះក៏ខឹង បរសេះរាំងវាចេញមកតនឹងដណ្តើមយកសេះទៅវិញ ទួលទៀបហ៊ុយ ក្រឡេកឃើញក៏បរសេះចេញទៅស្ទាក់ព័ទ្ធ ហើយយកខ្លួនចាក់ត្រួតគាន់ស្ងួនភ្ជាប់ពីលើសេះស្ទាប់ ពាហានទៀបប៊ី គាន់ស្ងួនក៏បែកខ្ចាត់-ខ្ចាយទៅខ្លះ នាំគ្នាចូលមកនៅខាងឡៅពីខ្លះ ។

ខណៈនោះ ឡៅពីក៏ប្រាបប្រាមបណ្តាកស្ត្រ ក្នុងស្រុកគាំងហៃឲ្យនៅជាប្រក្រតី ហើយលើកទ័ពត្រឡប់មកវិញ ឡៅប៉ៃវាដឹងដំណឹងក៏ចេញទៅទួលឡៅពីដល់ទីព្រំស្រុក ហើយនាំឡៅពីចូលមក ឡៅពីក៏អធិប្បាយប៉ាយរឿងក៏វា ដែលទៅច្បាំងនោះ ឲ្យឡៅប៉ៃវាស្តាប់សព្វគ្រប់ប្រការ ឡៅប៉ៃវាត្រេកអរណាស់ ឲ្យរៀបតុះលៀងគោជនាហារឡៅពី ខណៈគាលឡៅពី កំពុងសេពសុរាបរិភោគអាហារនោះ ឡៅប៉ៃវាក៏សរសើរឡៅពីថា ប្អូនឯងមានសតិបញ្ញាឧត្តមថ្លៃដៃខ្លាំងពូកែណាស់ តែបងមានវិត្តក ព្រោះស្រុកយើងនេះជាស្រុកមុខគយ ។

(មានត)

រឿងសំឡាញ់ពីរនាក់បងប្អូនជ្រើងទឹកសមុទ្រ

លោក ទៀង តៃ ឈុន ប្រមៀបរៀង

តាមរឿងប្រឌិតមួយ កាលណោះ មានសំឡាញ់ពីរនាក់បានជួបគ្នា ហើយបាននិយាយសន្យាទៅវិញទៅមកថា: កាលបើយើងមានប្រពន្ធ រៀងខ្លួន បើអ្នកណាមួយមានទ្រព្យសម្បត្តិច្រើន ត្រូវអ្នកនោះជួយឧបត្ថម្ភ អ្នកមួយទៀត ឲ្យបានជិញ្ចឹមជីវិតផង ។

លុះបានពិភាក្សាគ្នាដូច្នោះហើយ សំឡាញ់ទាំងពីរនាក់ក៏សម្រេច តាមសន្យានេះដោយរឿងៗ ។

បន្ទាប់ពីពេលនោះមក មិត្តម្នាក់បានរៀបការការ៉ាប៉ាត់ នឹង ស្ត្រីម្នាក់ ប្រកបដោយមារយាទល្អគ្រប់បែបគ្រប់យ៉ាងឥតមានខ្ចោះ ។

ចំណែកសំឡាញ់មួយទៀត បានប្រពន្ធឥតល្អឆ្ងាញ់ ។

មានមួយយប់នោះ នៅពេលចូលដំណេក បុរសដែលមានការយោ គ្រប់លក្ខណ៍ បានប្រឹក្សានឹងប្រពន្ធថា យើងអាចរកស៊ីធ្វើរបរអ្វីបាន ដើម្បីឲ្យធាប់ទៅជាអ្នកមានធនធានច្រើន ។

-ឱស្ការមី ! ទោះបីបងចង់ធ្វើការរកស៊ីខ្លួនឯងឬបងប្រើខ្ញុំឲ្យត្បាញនឹង ខារស្បូត្រ អំបោះយកទៅលក់ ខ្ញុំស្ទាប់បង្គាប់បងជាដរាប ហើយខ្ញុំគ្មានការ

ដំណាស់ន៏ងសេចក្តីស្នេហ៍របស់បងទាំងអស់ ។

យប់បន្ទាប់មក នៅពេលចូលដំណេក ប្តីនិយាយទៅកាន់ប្រពន្ធជាលើកថ្មីទៀតថា បងនឹកឃើញមាត់ផ្សាច្បាយមួយយ៉ាងប្លែកដ ដើម្បីឲ្យបានទៅជាអ្នកមានស្តុកស្តម្ភ ។ រឿងនេះបើបានសម្រេចដូចគំនិតបងយើងនឹងបានដោយស្រួលនូវមាស ប្រាក់ (តាំពុលស្គរពោសស្បែកម្ខាង Timbale) ហើយនឹងថាស ។

- បើដូច្នោះ បងគិតធ្វើដូចម្តេច ដើម្បីឲ្យបានរបស់ទាំងអស់នោះ ? ។

នៅក្នុងសម្ពុទ្រ, ប្តីឆ្លើយវិញ, មានតាប៉ាល់ដំនួញមកពីគ្រប់ប្រទេសក្នុងពិភពលោក ។ តាប៉ាល់ខ្លះមានជាតាវសនា, ប៉ុន្តែពីរឆ្នាំកន្លងទៅហើយតាប៉ាល់ខ្លះទៀតជាច្រើនបានលិចលង់អស់ ។ សម្បត្តិទាំងអម្បាលមាណនៅក្នុងតាប៉ាល់នោះ ដូចជាមាសនឹងប្រាក់បានធ្លាក់ទៅបាតសមុទ្រៗដោយហេតុនេះ យើងទាំងពីរនាក់ទៅបាចទឹកសមុទ្រឲ្យពាល់តែហួតស្ងួតអស់ ។ បើប្រសិនជាគ្មានមាស ប្រាក់នឹងកំណប់ផ្សេងៗឯទៀតទេ យើងគង់តែចាប់បានត្រីគ្រប់បែបគ្រប់យ៉ាងដែរ ។ ត្រីទាំងនោះយើងនឹងយកមកវះពោះឲ្យស្អាតប្រឡាក់អំបិលហាលឲ្យស្ងួត ហើយធ្វើប្រហុក ។ ថ្ងៃស្អែកទៀតនឹង ឪពុកឯងជាំបាយនឹងបៀកស្ងោរ ងាក់ក្នុងតង្កៀមួយយកទៅ ។ លុះថ្ងៃត្រង់ៗ យើងនឹងយកស្ងោចទៅបាចទឹកសមុទ្រឲ្យរីង ។

កាលបើបានស្តាប់ប្តីនិយាយរួចហើយ, ប្រពន្ធក៏បានចាត់ចែងតាមបង្គាប់ទាំងអស់ ។ ដូច្នេះ ពេលថ្ងៃរះស្រាងៗ, ក្រោយដែលបានរៀបស្បៀងអាហារដែលបំរុងទុក រួចស្រេចហើយ, ប្តីនឹងភរិយាក៏បាននាំគ្នាទៅដល់មាត់សមុទ្រ ។

ទៅទីនោះ, អ្នកទាំងពីរទុកដាក់ស្បៀងអាហារដែលបំរុងទុកស្រួលបួល ហើយនាំគ្នាយកកញ្ចើលបង់ដងតទៅដងទឹកសមុទ្រចាក់ចោលទៅលើដីគោក ។ ប្តីនឹងប្រពន្ធខំប្រឹងងាចទឹកចាល់តែដល់ពេលយ្ងានចុយ ។ អ្នកទាំងពីរសំរាកបន្តិច ដើម្បីសុីចុយហើយចាចទឹកទៅលើដីទៀតៗ

ថ្ងៃបើពេលយប់ដឹតមកដល់, ប្តីនឹងប្រពន្ធចេះតែខំចាចទឹកឥតមានឈប់សំរាកមួយពេលវេលាសោះ ។ លុះយប់កាន់តែជ្រៅណាស់ហើយ ទើបអ្នកទាំងពីរត្រឡប់មកផ្ទះវិញ ។

កាលបើចាចទឹកដូច្នេះបានចំនួនប្រាំថ្ងៃហើយ ប្តីប្រាសដេកទៅលើមាត់សមុទ្រហើយយកដៃចាំងក្បែរមើលទៅមាត់សមុទ្រ នៃភរិយា, ប្តីស្រែកប្រាប់ប្រពន្ធ, ទឹកស្រកច្រើនណាស់ហើយ ? ។

ចាះបង បើដូច្នេះមែន យើងខំប្រឹងចាចឲ្យបានកន្លះទៀត យើងប្រាកដជាចាប់ត្រីបានគ្រប់បៃបគ្រប់យ៉ាងជាមិនខាន ។ ត្រីនោះយើងយកមកវះពោះហើយប្រឡាក់អំបិលហាលថ្ងៃឲ្យស្ងួតរួចស្រេច យើងធ្វើដៀតហើយ

យើងថ្វីងលក់យកប្រាក់ ។ ម្យ៉ាងទៀត យើងចូលទៅរៃអង្គតក់ក្នុងតុប៉ាល់ ដែលលិចលង់ពីពេលដែលកន្លងហើយ ដើម្បីយកមាស, ប្រាក់, ថាសនឹង ចានឆ្នាំង ដែលនៅក្នុងតុប៉ាល់នោះ ។ អ្នកណាដឹងថា យើងនឹងអាចយក របស់ទាំងនោះទៅបាន? ។

លុះពេលយប់ អ្នកទាំងពីរត្រឡប់ទៅផ្ទះវិញ ។ ប៉ុន្តែពេលថ្ងៃរះ ក្តី ប្រពន្ធត្រឡប់មកបាចទឹកទៀត ។ ធ្វើយ៉ាងដូច្នេះ ដូចលើកមុនៗជាដរាប ។

កាលណោះត្រីទាំងអម្បាលមាណ ដែលនៅក្នុងសមុទ្របានឮស្តាន- រហេតុទាំងលើនេះទាំងអស់ ។ លុះបានដឹងច្បាស់ដូរគោលបំណងរបស់ប្តី ប្រពន្ធនេះហើយ ត្រីទាំងអស់ក៏មានចិត្តកិតក្យយ៉ាងក្រៃលែង ហើយប្រជុំ គ្នាដើម្បីពិភាក្សាថា ម្តងនេះស្រេចហើយយើងទាំងអស់គ្នា យើងត្រូវនាំគ្នា ទៅទូលដល់ស្តេចត្រី ដែលជាទេវតាការពារសមុទ្រ ហើយយើងសូមឲ្យ ព្រះអង្គជួយជីវិតយើងផង ។

កាលបើបានសម្រេចសេចក្តីដូចខាងលើនេះហើយ, ហ្វូងត្រីនាំគ្នាហែល តម្រង់ទៅព្រះបរមរាជវាំងនៃស្តេចរបស់ខ្លួន ហើយក្រាបបង្គំទូលព្រះមហា- ក្សត្រថា សូមទ្រង់មេត្តាជ្រាបក្រាមល្អង់ធូលីព្រះបាទ, ដ្បិតមានបុរស ប្តីប្រពន្ធកំពុងបាចទឹកសមុទ្រឱ្យរីង កាលបើទ្រង់បានជ្រាបព្រឹត្តិការណ៍ នេះហើយ ទ្រង់មានព្រះបន្ទូលទៅកាន់ត្រីទាំងឡាយ ដែលមកគាល់ព្រះ

អង្គថា អ្នកចាំងអស់យកមាសច្រាំពាង ច្រាក់ច្រាំពាង ថាសនឹងតាំចុល (ស្គរពាសស្បែកម្ខាង) ហើយពាំរបស់ចាំងនេះនឹងមាត់អ្នកយកទៅដូនបុរសប្តីប្រពន្ធនោះ ដើម្បីតង្វាយគេ ឲ្យឈប់ចាចពង្រីងសមុទ្រទៅវិញ ។

លុះបានស្តាប់ព្រះឧណ្ហាព្រះមហាក្សត្រេបស់ខ្លួនហើយ ត្រីចាំងអស់នាំគ្នាប្រមូលវត្ថុនោះដោយរួសរាន់ ហើយពាំកន្ត្រកមាត់នាំយកទៅដល់អ្នកចាំងពីរនាក់ប្តីប្រពន្ធ អង្វរគេឲ្យឈប់ចាចពង្រីងទឹកសមុទ្រ ។

បន្ទាប់មក ត្រីហាមាត់ខ្មាក់នៅចំពោះមុខបុរសនឹងស្ត្រីនោះ ទូរភាងមាស ច្រាក់ ថាស តាំចុលនឹងចានឆ្នាំង គប់មុខ ។ ស្វាមីនឹងភរិយាចាំងពីរនាក់ឃើញដូច្នោះ ក៏មានចិត្តសប្បាយគេចយ៉ាងក្រៃលែង ហើយឈប់ចាចទឹកសមុទ្រនៅវេលានោះដែរ ។

បន្ទាប់មកទៀត, ប្តីនឹងប្រពន្ធនាំគ្នាទូលនឹងភ្នែកភ្នំចាំងនេះយកមកផ្ទះ ។ កាលបើបានទៅជាអ្នកមានសម្បត្តិសុភសួស្តីដូច្នេះ អ្នកចាំងពីរនាក់ប្តី ប្រពន្ធមានកេរ្តិ៍ឈ្មោះយ៉ាងអស្ចារ្យចាប់តាំងពីពេលនោះមក ស្គាល់តែសេចក្តីសប្បាយ បកបដោយសុភមង្គល ។

ដំណើរយើងអធិប្បាយអំពីសុំឡាញ់ ដែលរៀបអាពាហ៍ពិពាហ៍ស្រីឥតល័ក្ខណ៍ ។

ថ្ងៃមួយបុរសនោះគិតដល់សំឡាញ់ ដែលមានប្រពន្ធគ្រប់ល័ក្ខណ៍

ហើយនាំភរិយាខ្លួនដើរលេង។ ពាល់តែដល់គេហដ្ឋានរបស់សំឡាញ់នោះ។ កាលបើបានឡើងដល់លើផ្ទះហើយ បុរសនោះមានចិត្តរំភើបយ៉ាងខ្លាំងប្រកបដោយសេចក្តីគោរព ថែមទាំងបណ្តាលឲ្យទឹកឃើញដល់សេចក្តីស្និទ្ធស្នាលពីដើមមកផង ។ បុរសនោះពិចារណាអំពីភាពសុភស្តម្ភដោយវត្តុទាំងឡាយ ដែលជាក់សំញែងដុំវិញខ្លួន ហើយគិតថា "ពីដើម សំឡាញ់អញមានទ្រព្យគ្រាន់តែចិញ្ចឹមជីវិតប៉ុណ្ណោះ ឥឡូវនេះ វាកស៊ីធ្វើបរអ្វីបានជាមានសម្បត្តិសុភស្តម្ភយ៉ាងដូច្នេះ" លុះគ្រិះរិះរួចហើយ បុរសនោះនឹកតូចចិត្តខ្លួនឯង ហើយនិយាយទៅកាន់សំឡាញ់ថា **នុមិត្ត** សព្វថ្ងៃយើងរស់ដោយលំបាកតោកយ៉ាកខ្លាំងណាស់ ។ ចំណែកឯងធ្វើបរអ្វីបានជាមានធនធានច្រើនម្ល៉េះ ?

បុរសមានប្រពន្ធត្រង់ល័ក្ខណ៍ឆ្លើយថា សំឡាញ់ យើងគ្រាន់តែជាបច្ចឹកសមុទ្រជាមួយនឹងប្រពន្ធយើងប៉ុណ្ណោះ ។ មុនថ្ងៃរះ ប្រពន្ធយើងដាំបាយនឹងរៀបចំស្បៀងអាហារ ហើយដល់ថ្ងៃរះព្រាង។ យើងនាំគ្នាពាំងពីរនាក់ទៅជាបច្ចឹកសមុទ្រ ។ ពេលល្ងាច យើងត្រឡប់មកផ្ទះវិញ ។

បុរសនេះអធិប្បាយរឿងរ៉ាវរបស់សេចក្តី ពាល់តែដល់វេលាដែលស្តេចត្រីខ្ចាចហើយចង្អាប់ត្រីពាងឡាយ ដែលឋិតនៅត្រោមអំណាចឲ្យនាំយកមាស ប្រាក់ នឹងវត្ថុមានដំឡៃ មកឲ្យបុរសនោះនឹងភរិយា ។

កាលបើបានស្តាប់រឿងនោះចប់សព្វគ្រប់ហើយ បុរសមានប្រពន្ធឥតល័ក្ខណ៍ ក៏លាសំឡាញ់ ដែលមានប្រពន្ធគ្រប់លក្ខណ៍មកផ្ទះខ្លួនវិញ ហើយបានប្រាក់ខ្លះដែលសំឡាញ់នោះឲ្យយកមកខ្ចីមកដែរ ។

នៅពេលចូលដំណេក, បុរសកំសត់នេះនិយាយទៅកាន់ភរិយាថា ព្រឹកស្អែក, ប្អូនឯងជាំបាយមុនបបួសគេ ឪងរៀបចំរបស់ដែលត្រូវការតាំងអស់ ។ កាលថ្ងៃនេះ យើងនាំគ្នាទៅបាចទឹកសមុទ្រ ដើម្បីឲ្យបានមាស, ប្រាក់ឪងវិត្តមានដំរៀបដូចសំឡាញ់យើង ។

លុះដល់ពេលឪងចេញទៅ, ប្រពន្ធគ្រោកឡើងបង្អាត់ក្តីឪង រួចបើកគ្របតាឪងយកអង្ករមួយនាឡ ។ គ្រានោះ អង្ករធ្លាក់អស់មួយក្តាប់ ។ អ្នកស្រីយកអង្ករទៅលាងហើយដុតឲ្យឆាតអស់មួយក្តាប់ទៀត ។ នៅវេលាដែលយកអង្ករទៅច្រកឆ្នាំង, អង្ករនោះបាត់ថែមមួយក្តាប់ទៀត ។ ដល់ពេលទឹកពុះអង្ករហៀរធ្លាក់ចេញមកតាមមាត់ឆ្នាំង ជារៀងដោយអ្នកស្រីឥតល័ក្ខណ៍ជាក់ទឹកហួសប្រមាណ ។

នៅទីបំផុត, អង្ករដែលយកមកសម្រាប់ ជាំបាយឲ្យ បានមួយឆ្នាំង ពេញទៅសល់តែកន្ទុះឆ្នាំង ។

លុះថ្ងៃរះឡើងស់មនាទីហើយ អ្នកស្រីយកសម្បឹងតាំងអស់ដាក់ក្នុងកញ្ជើមួយ ។ ប្តីនឹងប្រពន្ធនាំគ្នាដើរតម្រង់ទៅសមុទ្រ ។

នៅវេលាដែលកំពុងចាប់ទឹក អ្នកទាំងពីរចេះតែឈ្លោះប្រកែកគ្នាឥតមានឈប់អស់ចំនួនច្រើនថ្ងៃ ។

កាលណោះត្រីទាំងអម្បាលមាណតិតភ័យយ៉ាងខ្លាំងជាថ្មីទៀត, តែត្រីទាំងនោះនៅស្ងៀមចាំស្តាប់ ។

មួយថ្ងៃនោះ ស្រ័ចណ្ឌាលនេះចាកកញ្ជើដែលសម្រាប់ចាប់ទឹកហើយពោលថា យើងចាប់ទឹកឃ្យុណាស់ហើយ ប៉ុន្តែអញមើលទៅដូចជាគ្មានបានការអ្វីបន្តិចបន្តួចសោះ អញមិនមែនទើបនឹងតែតឹមរៀលមិញទេ អញឈប់ចាប់ហើយ ! ។

ប្តីនឹងប្រពន្ធឈ្លោះប្រកែកគ្នាទៀត ។ ប្រពន្ធជេរដល់ស្តាយប្តី។ ជេរប្រមាថប្រពន្ធយ៉ាងធ្ងន់ៗអស្ចារ្យ រួចវាយតប់ប្រកៀកគ្នា ហើយសម្រាតសំពត់ទៅរៃក្បែរទៅមក ពាលតែនៅខ្នងទេពាំងពីរនាក់ ។

ដូច្នេះប្តីនឹងប្រពន្ធស្រាតនៅឈរលើមាត់សមុទ្រ ហើយនិយាយគ្នាថា យើងមិនគួរនឹងធ្វើចាប់ខ្លួនយើងយ៉ាងនេះសោះ ណ្តើយចុះបើទុកជាខ្ញុំគេក៏នៅជាខ្ញុំទៅចុះ យើងមិនត្រូវមកធ្វើខ្លួនយើងឲ្យអស់កំឡាំងបែបនេះឡើយ។

កាលណោះ ត្រីទាំងអម្បាលមាណ ដែលនៅស្ងៀមចាំស្តាប់អ្នកទាំងពីរនាក់ប្តីប្រពន្ធឮថាឈប់ចាប់ទឹកសមុទ្រហើយ ក៏មានចិត្តសប្បាយរីករាយយ៉ាងក្រៃលែង ។

ត្រីពាំនេះយល់ឃើញថា មិនចាំបាច់យកមាស ប្រាក់នឹងវត្ថុមានដំ
ឡៃឯទៀត មកអង្វរតែប្តីនឹងប្រពន្ធនេះ ឲ្យឈប់ពង្រីនទឹកសមុទ្រឡើយ។

កាលបើមើលឃើញបុរសនឹងភរិយាស្រាតខ្លួនទាំងយ៉ាងដូច្នោះ ត្រី
ពាំគ្នាសើចហើយលោតលេងក្នុងទឹក ។

ក្នុងចំណោមត្រីពាំនេះ មានត្រីសណ្តាយសើចខ្លាំងជាងគេពាំងអស់
ពាល់តែរហែកមាត់ ។

ហេតុដូច្នេះបានជា សព្វថ្ងៃត្រីប្រភេទនេះ មានរន្ទុះមាត់ធំហើយនឹង
ត្រចៀកធ្លុះពីម្ខាងទៅម្ខាង ។

រឿងព្រេងនេះសន្មតថាចប់ត្រឹមប៉ុណ្ណេះ ។





ស្មៀកសសាងព្រឹទ្ធិចិត្តនៅឡៅ ចោលច្រាជ្រគាមឡៅចង់ចៀសចាប
លួតវែកឲ្យដឹងរសប្រៃសាប យកខ្យាច់មកតាបបានប្រែងឬ ។
ឬសត្រីឆ្កែកាក់ជាក់គ្មានថ្នាំងឆ គឆ៍ស្គរតាំងវាយមិនឮ
សុរិយាមិនយកជាពន្ធឺ តាន់ដៀអំពិលអំពែកសត្វ ។
ចង់អ្វីមិនខ្ជាប់ស្មើសង្ឃរា ការអ្វីមិនស្មើការប្រតិបត្តិ
ស្វាត់អ្វីមិនស្មើចិត្តដែលស្វាត់ កាចអ្វីមិនស្មើជនពាល ។
រោគអ្វីមិនស្មើនឹងរោគឃ្លាន ទានអ្វីមិនស្មើទានទេសនា
មានអ្វីមិនស្មើមានប្រាជ្ញា ជាអ្វីមិនស្មើចិត្តជាបុណ្យ ។
រហ័សអ្វីមិនស្មើចិត្តដែលនឹក មុតអ្វីមិនស្មើទឹកហូរជោរដង់
ធ្ងន់អ្វីមិនស្មើព្រះគុណធ្ងន់ ឆន់អ្វីមិនស្មើឆន់ប្រពន្ធប្រើ ។
មើលមេឃគោឆ៍មើលទៅទេវតា ចូលព្រៃព្រឹក្សាគោឆ៍មើលលើ
យកមិត្រមើលចិត្តឲ្យស្មោះស្មើ យកក្តៅគោឆ៍មើលឲ្យសមប្រាណ
ធ្វើស្រែចំការឲ្យមើលស្មៅ ខុកជាកកូនចៅមើលសន្ដាន
ធ្វើទីលំនៅមើលភូមិឋាន បរិភោគប្រមាណមើលអាហារ ។
ជាវមុត មុតមែននៅក្នុងស្រោម វិជ្ជាចេះព្រមមិនត្រូវការ
ជាតិស្ត្រីឥតប្តីនឹងព្យាបាល គជសារឥតហ្មឺនឹងប្រដៅ ។

រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តមក)

លោក រ៉ាយ-ប៊ុក ប្រែរៀបរៀង

"ចានជារយើងនឹងយំព្រោះដល់ពេលនាគក្បាលប្រាំបីដងមកយកកូនស្រីយើងនឹង ៨ ហើយ . . ." រួចគាថាស់យាយថាស់តយំតទៀត . . ព្រះនាងគុនីសជាក្រមុំក្រេកទៅចំអាងទឹកស៊ុសាណូ . . . ។

អាទិទេពស៊ុសាណូពោលថា: "កុំឲ្យលោកតា, លោកយាយព្រួយបារម្ភអ្វី, សូមលោកតា, លោកយាយពន្យល់មកខ្ញុំតើខ្លាចអ្វី?" ។

គាថាស់ពោលថា ខ្ញុំមានកូនស្រី ៨ នាក់ ។ ក្នុងមួយឆ្នាំ ។ នាគក្បាលប្រាំបីមកចាប់កូនស្រីម្នាក់យកទៅធ្វើជាអាហារវៀនរាល់ឆ្នាំ, ខ្ញុំត្រូវនាគក្បាលប្រាំបីចាប់យកកូនស្រីប្រាំពីរទៅហើយ, នៅសល់តែកូនស្រីម្នាក់នេះ, វានឹងមកចាប់ទៀត ។ បើនាគនោះវាមកយកកូនស្រីនឹង ៨ នេះទៀតហើយ, យើងចាំងអស់គ្នាលែងបានសប្បាយទៅអនាគត យើងលែងមានទៅ ដែលជាអ្នកក្បែរកៃវ៉ែមតែង, ក្រោយដែលយើងខ្ជួលមរណភាពទៅគាន់បរលោក, ហើយគ្មានអ្នកណានឹងបូជាសពយើងផង ។

រួច តាបាស់ ហាយបាស់តំយ៉ែតទៅទៀត ។

លោកស៊ីសាណូតបបា ដូចម្តេចទៅនាគនោះ ។

តាបាស់តំតបបា: នាគមានរូបកាយធំសម្បើមអស្ចារ្យ, បណ្តាយ២ខ្នង, ចម្ងាយត្រោះក្បាំងត្រាំបី នឹងក្តួចត្រាំបី; វាមានក្បាលត្រាំបីកន្ទុយត្រាំបី, ក្បែកត្រហាម ដូចផ្លែស៊ីរសុំ ភោះវាត្រហាមដូចឈាម ហើយវាព្រួសអណ្តាតភ្លើងចេញមក ។

ហាយបាស់បន្តែមថា "រូបកាយវាមានស្នែស្រស់ធំនឹងសែង្រួធំសម្បើមអស្ចារ្យដុះដុំវិញ ។

អាទិទេពស៊ីសាណូលែងពោលតទៅទៀត ហើយក៏វិលត្រឡប់មកតាបាស់វិញដោយចង្អុលបង្ហាញព្រះនាងគុទីសង្ខាថា "បើព្រះនាងជាបុត្រីរបស់លោកតា តើលោកតាអាចឲ្យព្រះនាងមកធ្វើជាភរិយាខ្ញុំបានឬទេ? ។

ក្នុងពេលនោះ នេត្រាព្រះនាងឡៅល្អចោលស្នេមួយកែ្លត ហើយត្រេបកចក្ខុព្រះនាងក៏ទន់សំយ៉ុងចុះ ដូចជាអៀនខ្មាសពន់ពេក ដើមទ្រូងព្រះនាងប៉ោងខ្ទើង ចិត្តនាងរំជួលខ្លាំង ហើយព្រះនាងបញ្ចេញមនោសញ្ចេតនាដ៏រីករាយ ដោយមានអ្នកការោរយ៉ាងជំនាញ តស៊ូនឹងនាគក្បាលត្រាំបី ។

(មានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

ប្រវត្តិវិហារអង្គារស

លោក ហាប-ពិន រៀបរៀង

នៅប្រទេសកម្ពុជាយើងពាំងមូល គេតែងធ្វើវត្តធ្វើវិហារបែរមុខឆ្ពោះទៅទិសខាងកើតពាំងអស់ ។ នេះគឺជាទំនៀមទម្លាប់ដែលគេនិយមប្រកាន់ជាប់តាំងពីបុរាណកាលមក ។

ប៉ុន្តែលោក-អ្នកពាំងឡាយបានសង្កេតឃើញទេ នៅក្នុងប្រទេសខ្មែរយើង មានវិហារបែរមុខឆ្ពោះទៅទិសខាងដើងដែរ គឺ "វិហារអង្គារស" លើកំពូលភ្នំព្រះពជ្រភ្ញ ក្នុងស្រុកទត្តុង្គ ខេត្តកំពង់ស្ពឺ ។ សេចក្តីប្លែកនេះហើយដែលគួរឱ្យចង់ដឹងណាស់ ។

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ, ប្រវត្តិនៃវិហារនោះមានសេចក្តីដំណាលដូចតទៅនេះ :

កាលនៅគ្រិស្តសតវត្សទី ១៣ គឺនៅក្នុងសម័យអង្គរ ព្រះចៅប្រទេសចិនទ្រង់បានចាត់បេសកជនជាច្រើនក្រុមឱ្យមកដើរមើល ដើរស៊ើបសួរក្នុងប្រទេសនានា តើប្រទេសណាមានអារ្យធម៌ដូចម្តេចខ្លះ, បើប្រ-

ទេសណាមានអារ្យធម៌ថ្កើងរុងរឿងត្រកែត់ក្រាយកមកផ្សាយក្នុងប្រទេសចិន ហើយប្រទេសចិនគួរយកប្រទេសនោះជាមិត្ត, បើប្រទេសណាមានអារ្យ-ធម៌ខ្មែនអាប់ ប្រទេសចិនមិនដួយខ្នែកបំរុង ឬមួយនឹងយកធ្វើជាប្រទេសចំណុះ ។

កាលនោះ ក្រុមបេសកជនចិនបានចូលមកមើលស៊ើបសួរក្នុងប្រទេសខ្មែរយើងសព្វគ្រប់ហើយក៏ត្រឡប់ទៅទូលព្រះចៅក្រុងចិនវិញថា: ប្រទេសខ្មែរជាប្រទេសថ្កុំថ្កើងរុងរឿង តែអាប់ខ្មែនជាងកាលពីមុនបន្តិច ហើយ អ្នកស្រុកនៅដើរដើងទេ បរិភោគអាហារនឹងដៃ ក្បាលទេ ពុំសូវមានប្រើប្រាស់អ្វីឱ្យបានងាយស្រួលទេ, ប៉ុន្តែមិនយូរប៉ុន្មានទេ ប្រទេសខ្មែរមុខជាដួរបន្តែនូវសេចក្តីថ្កុំថ្កើងរុងរឿងអស្ចារ្យ ឡើងវិញលើសដើម, ដោយពួកបេសកជនទាំងនោះបានមកឃើញទីមួយដែលតាមក្បួនចិនសែថា ទីនោះអាចនឹងឱ្យផលល្អផ្សែង ។ ដល់ប្រទេស ។ ឯទីនោះ គឺភ្នំព្រះពន្ធទ្រព្យយើងសព្វថ្ងៃ ដែលនៅកងស្រុកទន្លុង ខេត្តកំពង់ស្ពឺ ។ ពួកបេសកជនចិនបានមើលឃើញភ្នំនោះមានពន្លឺដូចសត្វមករ គឺខ្នងមករនៅត្រង់ចេតិយត្រែត្រឹង្ស ក្បាលដំណពុតមាត់មករនៅត្រង់ចេតិយទន្លឹម កន្ទុយមករនៅត្រង់ព្រះពុទ្ធរូបចូលនិព្វាន ។ មិនត្រឹមតែប៉ុណ្ណោះទេ នៅលើកំពូលភ្នំនោះ ថែមទាំង

មានរូងមួយជ្រៅស្រឡះទៅក្រោមផង ។ ពួកចិនយល់ឃើញថាមិនយូរប៉ុន្មាន សត្វមកនឹងកម្រើកចេញតាមរូងនេះ ហើយតាមក្បួនចិនសែថា បើប្រទេសឯណាឬទីណាមានសត្វមកជុះឡើង ប្រទេសនោះនឹងមានខ្វែងអំណាចប្តូរថ្នូរនឹងគ្នា ពុំមានប្រទេសឯណាអាចនឹងតស៊ូបានទេ ។ ដូច្នេះ ដើម្បីជាសេចក្តីសុខដល់ប្រទេសចិនទៅអនាគត មន្ត្រីចិនពាំនឹងឡាយទូលសូមស្តេចចិនលើកទ័ព មកវាយយកប្រទេសខ្មែរធ្វើជាស្រុកចំណុះឲ្យហើយ ។ ស្តេចចិនទ្រង់ព្រះតម្រិះថា ធ្វើយ៉ាងនេះឃើញដូចជារំលោភលើប្រទេសខ្មែរជ្រុលពេក, ម្យ៉ាងទៀត ប្រទេសខ្មែរនៅខ្ទាំងតូចតែប្តូរថ្នូរនៅឲ្យ ពុំអាចនឹងវាយបានដោយងាយទេ ទោះបីប្រទេសខ្មែរច្បាំងចាញ់ប្រទេសចិនៗក៏មុខជាលំបាកខ្លួន អស់ពលយោធាច្រើនមានទុក្ខវេទនាដល់បណ្តាជនមិនខានឡើយ ។

ដំបូងឡើយ ដើម្បីនឹងបនឹបប្រទេសខ្មែរកុំឲ្យល្អតលាស់តទៅទៀតបាន នោះពួកចិនគិតសន្ធប់រូងក្តោះឲ្យដិតកុំឲ្យសត្វមកចេញមកបាន តែពួកចិនគិតថា បើយកដុំថ្មសន្ធប់រូងនោះទៅខ្ទាចត្រែងថ្ងៃក្រោយខ្មែរយល់គំនិតនឹងគាស់ចេញវិញបាន បើដូច្នេះពួកចិនស៊ើបទៅឃើញថា ប្រទេសខ្មែរគាន់ព្រះពុទ្ធសាសនាមុតមាំណាស់ ទៅទីណាមានព្រះពុទ្ធរូបមានវិហារ ខ្មែរពុំហ៊ានរំលាងរំលើងទីនោះទេ ។ ដោយហេតុ

នេះហើយបានជាស្តេចក្រុងចិនឲ្យមន្ត្រីមកសូមធ្វើវិហារនៅលើកំពូលភ្នំព្រះពុទ្ធគ្យា ។ លើកដំបូង ពួកចិនចាប់តសាងព្រះពុទ្ធរូបមុនគេ រួចមកទើបធ្វើវិហារនឹងសីមាតាមទំនៀមទម្លាប់ខ្មែរ ព្រមទាំងតាមក្បួនហោរាសាស្ត្រចិនផង ព្រោះហេតុនេះបានជាវិហារនោះបែរមុខឆ្ពោះទៅទិសខាងជើង គឺឆ្ពោះទៅរកប្រទេសចិន ។ ឯឈ្មោះវិហារនោះពុំដឹងជាពួកចិនហៅដូចម្តេចទេ តែដនជាតិខ្មែរយើងដោយយើញព្រះពុទ្ធរូបធំអស្ចារ្យមានកំពស់ ១៨ ហត្ថ ក៏នាំគ្នាហៅថា "វិហារអង្គារស" ។

តមក ស្តេចក្រុងចិនឲ្យមន្ត្រីចិននាំប្រស្នា ៣ ខ មកថ្វាយព្រះរាជាប្រទេសខ្មែរដោះស្រាយ បើប្រទេសខ្មែរដោះស្រាយប្រស្នាទាំង ៣ ខនេះពុំបាន នោះប្រទេសខ្មែរត្រូវទៅចំណុះប្រទេសចិន ត្រូវយកស្មួយសារអាករទៅថ្វាយស្តេចក្រុងចិនរាល់ឆ្នាំ ។ ឯប្រស្នាស្តេចក្រុងចិនទាំង ៣ ខ នោះ មានសេចក្តីដូចតទៅនេះ :

ដំបូង មន្ត្រីចិនម្នាក់ដែលជាអ្នកដឹកនាំប្រស្នាពីស្តេចក្រុងចិនមកថ្វាយព្រះរាជាខ្មែរដោះស្រាយនោះ ក្រោកឈរឡើងចំពោះព្រះភ័ក្ត្រព្រះរាជា ទើចំពោះមុខមន្ត្រីខ្មែរទាំងឡាយហើយធ្វើអាការដូចតទៅ :

ប្រស្នាទី ១ មន្ត្រីចិនចំគោនខ្នង លាដៃទាំងពីរធ្វើរបៀបដូចជាទុបរបស់អ្វីយ៉ាងធំ;

ប្រស្នាទី ២ មន្ត្រីចិនក្តាប់ដៃម្ខាងលើកឡើងកំពស់មុខ ;

ប្រស្នាទី ៣ មន្ត្រីចិនចោះដៃត្រង់ទៅមុខ លាម្រាមដៃចាំង ៥ ត្រញាងឡើង ។

ហើយថ្វាយការលបរិច្ឆេទចំពោះព្រះរាជាខ្មែរថា ៧ ថ្ងៃទើងត្រឡប់មកគាល់សូមព្រះរាជទានសេចក្តីដោះស្រាយ ។ ព្រះរាជាប្រទេសខ្មែរទ្រង់ព្រួយព្រះរាជហឫទ័យ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យអស់នាម៉ឺនមុខមន្ត្រីពិចារណាគិតរកប្រស្នាចាំងនេះ ប៉ុន្តែក្នុងចំណោមមន្ត្រីរបស់ទ្រង់ចាំងប៉ុន្មានពុំមានខ្លះណាម្នាក់អាចដោះស្រាយប្រស្នានោះបានឡើយ ។ ទើបព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យចាត់តែងរកអ្នកមានប្រាជ្ញាដោះស្រាយ ។

នៅសម័យនោះ មានគង្វាលគោម្នាក់បានឃើញគេប្រឹក្សាគ្នាដុំៗក៏ចូលទៅឈរស្តាប់ហើយឆ្លើយថាប្រស្នាចាំង ៣ ខ្នះ នេះ ងាយដោះស្រាយសោះ គឺ

ប្រស្នាទី ១ ដែលធ្វើដៃចាំងពីរដងនោះ ប្រែថា អង្រែតត្រី;

ប្រស្នាទី ២ ដែលក្តាប់ដៃម្ខាងលើកទៅលើនោះ ប្រែថា ស្នែតមួយ;

ប្រស្នាទី ៣ ដែលលាម្រាមដៃចោះត្រង់ទៅមុខនោះ ប្រែថា រកបានត្រី ៥ ។

អ្នកដែលបានស្តាប់ឮចាំងប៉ុន្មាន ក៏នាំគ្នាពិចារណា ហើយ

ស្តេរបុរសនោះថានិយាយលេងឬដូចម្តេច ? បុរសនោះធ្វើយប្រាប់គេវិញ
ថា ប្រស្នាទាំង ៣ ១ នេះ ប្រាកដជាប្រៃជ្ញច្នេះ ។ អ្នកស្រុកគេ
នាំពាក្យនោះទៅប្រាប់មន្ត្រីដែលចាំវែងឆ ។ មន្ត្រីនោះនាំបុរសគង្វាល
គោទៅថ្វាយព្រះមហាក្សត្រ ។ ដោយព្រះរាជាទ្រង់មានព្រះរាជទង្វើរ
ស្តេរបុរសនោះអំពីសេចក្តីដោះស្រាយប្រស្នាទាំង ៣ ១ នេះ, បុរសនោះក៏
ក្រាបបង្គំទូលដោយស្មាត់ថា :

ប្រស្នាទី ១ ប្រែថា មានផែនដីមួយ គឺប្រទេសខ្មែរយើង;

ប្រស្នាទី ២ ប្រែថា មានស្តេចមួយព្រះអង្គសោយរាជសម្បត្តិ
នៅលើផែនដីនោះ ;

ប្រស្នាទី ៣ ប្រែថា មានរដ្ឋមន្ត្រី ៥ នាក់ធ្វើការមើលសុខ
ទុក្ខរាស្ត្រឆ្ងាយឆ្ងាត់ព្រះរាជាមក ។

ដល់ថ្ងៃដែលបានកំណត់ មន្ត្រីចិនចូលគាល់ព្រះរាជាខ្មែរទូលសូម
សេចក្តីដោះស្រាយ ។ ព្រះរាជាខ្មែរមានព្រះរាជទង្វើរត្រាស់ហៅគង្វាល
គោឲ្យមកដោះស្រាយប្រស្នា ។ នៅវេលានោះ គង្វាលគោក្រាបថ្វាយ
បង្គំព្រះរាជារួចហើយ ក៏ដោះស្រាយប្រស្នាទាំង ៣ ១ នោះ ចំពោះមុខ
មន្ត្រីខ្មែរចិនថា ៖

ប្រស្នាទី ១ គឺ ចក្រវាឡ ១ ជានដល់ចក្រវាឡដែលយើង

នៅសព្វថ្ងៃ ។

ប្រស្នាទី ២ គឺ ចក្រវាឡនេះមានភ្នំព្រះសុមេរុ ១ ជំ
វៀរលែង ។

ប្រស្នាទី ៣ គឺ ក្នុងចក្រវាឡនេះ មានព្រះពុទ្ធគោស ៥
ព្រះអង្គ ។

មន្ត្រីចិនទទួលព្រមថា សេចក្តីដោះស្រាយប្រស្នាទាំង ៣ ខនេះត្រូវ
ហើយ រួចទើបក្រាបថ្វាយបង្គំលាព្រះពាជាប្រទេសខ្មែរយើងទៅទូលស្តេច
ខ្លួនវិញ ។ ព្រះពាជាក្រុងចិនក៏សូមបងធម៌មិត្រមេត្រីនឹងប្រទេសកម្ពុជាតាំង
ពីសម័យនោះដកបមកពុំហ៊ានរករឿងហេតុអ្វីទៀតឡើយ ។ ចំណែក
បុរសគង្វាលគោ ព្រះពាជាប្រទេសយើងទ្រង់ប្រោសព្រះពរជាន់សម្បត្តិ
ទ្រព្យជាច្រើនហើយតាំងគោរម្យងារជា "ធនញ្ជ័យបណ្ឌិត" ។

តមកជាយូរអង្វែង វិហារអង្គរសេក៏បាក់បែកខ្ទេចខ្ទីអស់នៅសល់
តែសីមានឹងព្រះពុទ្ធរូប ប្រទេសកម្ពុជាក៏ចេះតែគាប់ខ្នងបន្តិចម្តងៗ ដរាប
មក ។ នៅសម័យលង្វែក ព្រះចន្ទពាជាដែលជាព្រះមហាក្សត្រទ្រង់ធម៌
ទ្រង់ត្រាស់បង្គាប់ឲ្យសាងវិហារនោះជាថ្មី ។ ចំណែកព្រះពុទ្ធរូបនៅ
ដូចដើមពុំមានកែប្រែឡើយ គ្រាន់តែជួសជុលបន្តិចបន្តួចប៉ុណ្ណោះ ។

សុភាសិតសាសន៍ ប៉ែរ្ស

លោក រ៉ាយ - ប៊ុក ជាកវីរៀបរៀង

១- មនុស្សមានប្រាជ្ញាគេមិនចាត់ប្រគល់ការលំបាកឲ្យទៅមនុស្សល្ងង់ខ្លៅធ្វើទេ ។ ពិតមែនតែអ្នកគ្រាញកន្ទេលចេះម្សាញ គេមិននាំចូលទៅក្នុងរោងតម្បាញសូត្រទេ ។

២- អ្នកណាមិនអត់ទន្ទានទោស ឲ្យអ្នកដែលធ្លាក់ចុះដួនដាប់ទេ អ្នកនោះ ដល់ខ្លួនលិចលង់ដួនដាបវិញ គ្មានអ្នកណាជួយទេ ។

៣- មនុស្សម្នាក់ដកដើមឈើតូចងាយ បើមនុស្សនោះទុកឲ្យដើមឈើនោះចម្រើនធំឡើង , មនុស្សនោះ មិនអាចនឹងដកដើមឈើនោះបាន សូម្បីតែកំពាំងសេះបួនក៏មិនអាចដកបានដែរ ។ ឯងអាចទប់ប្រភពទឹកបានដោយយកដីខ្ទាចទៅជាក់ តែបើប្រភពនោះទៅជាស្ទឹងទន្លេ ឯងមិនអាចទប់ឈ្នះទេ សូម្បីជំរាមួយក៏ទប់មិនឈ្នះដែរ ។

៤- ចង់អប់រំមនុស្សពាលទុច្ចរិត ប្រៀបដូចយកទឹកមកចាក់លើដុំដែលមានទ្រនំច្រាយមូល ។ ការពិតត្រូវសម្អាប់វាចោលឲ្យអស់ ព្រោះថារំលត់ភ្លើងទុករងើក សម្អាប់ពស់វែកទុកកូនវា បណ្តិតមិនត្រូវប្រព្រឹត្តឡើយ ។

៥- កូនចចក បើពុកណាជារស់នៅជាមួយនឹងមនុស្សកំនឹងៗ ជាចចកជំមិនខាន ។

៦- ក្មេងធ្វើឱ្យឪពុក "ខុយលិប" ដុះនៅក្នុងទ្រូង, ឱ្យស្មៅដុះនៅក្នុងព្រៃ ។ គេមិនត្រូវយកបុប្ផា "ខុយលិប" ទៅជាំនឹងដីប្រែទេ, ហេតុនេះ ត្រូវព្រោះគ្រាប់ខុយលិបនឹងបំពេញកិច្ចការទាំងឡាយទៅទីដ៏ដ៏សមគួរ ទើបបុប្ផាខុយលិបនោះដុះបាន ។ ធ្វើល្អនឹងពួកគាចដូចគ្នាធ្វើអាក្រក់នឹងពួកសូត ។

៧- ព្រះពាយដែលបត់នៅរ៉ាលស្រែ ធ្វើឱ្យគម្រើតមែកពុក្កាសូល (Saule), មិនមែនគម្រើតឫជាបានទេ ។

៨- ពាំងអស់ដែលឯងឮនៅក្នុងធម្មជាតិគឺធម្មជាតិពាំងអស់ច្រៀងតួមភាពនៃព្រះអាទិទេព ។ ចិត្តដែលប្រកបដោយអកិដនភាពឮសំឡេងសូរដើពោះអស្ចារ្យដែលវត្តពាំងនោះពោល ។ ពិភពលោកប្រកបដោយសំណួរខ្លះៗសុខដុំម្ខេនា ។ ពិភពលោកញ៉ាំដោយសេចក្តីសប្បាយនឹងត្រេកត្រអាលជាពន្លឺក ។ តែតុព្រោមទុស្សភ្លាក់, តើនឹងបានឃើញរូបកាយខ្លួនទៅក្នុងកញ្ចក់ឬទេ ? ។

៩- បក្សាកវិកចេះតែច្រៀងសរសើរពីបុប្ផាកុលាប, ហើយ-បុប្ផានៃបុប្ផាកុលាបនីមួយៗជាកាសាមួយថ្លៃនឹងអំណរគុណបក្សាកវិក ។

១០- កាលណាមុខមាសរបស់ឯងលែងចោលស្មៅទៀតនាំក្អែកនារី ដែលឯងប្រាថ្នា , កញ្ចក់នឹងមាសរបស់ឯងមានដម្លៃដូចគ្នានឹងផង់ធួលដែរ ។

១១- ចូរឯងចោលក្អែកក្រខ្សែកទៅតាន់ផ្ទះមិត្តសិន តែឯងមិនត្រូវគោះទ្វារផ្ទះមនុស្ស ដែលឯងមិនស្គាល់សោះឡើយ ។

១២- ខន្តីមិនដែលស្ថិតនៅក្នុងចិត្តគូសង្សារស្រឡាញ់ គ្នាដូចជាទឹក មិនដែលស្ថិតនៅលើកញ្ជ្រោងវែងដូច្នោះ ។

១៣. គេមិនត្រូវបើកទ្វារតណ្ហាទេ, កាលណាទ្វារនេះបើកហើយ, មិនងាយនឹងបិទវិញទេ ។

១៤- មនុស្សណា ជាបណ្ឌិតខាងច្បាប់ តែធ្លាក់ខ្លួនទៅសប្បាយក្នុងអបាយមុខហើយ តែងមានចិត្តជាប់នឹងគ្រឿងតាំងនោះដូចជារុយដែលមានដើងជាន់ទឹកឃ្មុំដូច្នោះ ។

១៥- បើទុកជាមិនបានពាក់ចិញ្ចៀនជាំគ្បាន់ក៏ដោយ , ដៃនាងកញ្ញាក៏នៅតែស្អាត សែនស្អាត ។

១៦- នៅក្នុងចក្រវាឡ ការរោរាយនឹងអយុត្តិធម៌ជាច់ផ្តើមពីគូចទៅមុនជាដរាប ។

១៧ បើស្តេចសុលតង់ទ្រង់សោយផ្លែចាំមនៅសួនច្បារ ប្រជាពស្ត្រណាម្នាក់ ហើយព្រះពាជបរិពារដែលដង្ហែព្រះអង្គគាន់យកដើមចាំមទៅថ្វាយ ។

(មានត)

កំណត់ធំងប្រវត្តិការណ៍

តតិមាធដ្ឋង៦របស់ក្រសួងធម្មការ

លោក ប៉ាប-ពិន ថ្លែងតាមវិទ្យុជាតិ

នៅថ្ងៃ ១៣ មិថុនា ១៩៥៨

អំពីពិធីបើកការបង្រៀនភាសាសំស្ក្រឹត

ដ៏ប៉ងធម្មាចារ្យនៃសាលាពុទ្ធិកបឋមសិក្សា

កាលពីថ្ងៃទី ១១ ខែមិថុនា ១៩៥៨ វេលាម៉ោង ៤ រសៀលនៅក្នុងបរិវេណនៃគ្រឹះស្ថានពុទ្ធិកវិទ្យាល័យព្រះសុពម្រិត មានធ្វើពិធីបើកការបង្រៀនភាសាសំស្ក្រឹតដល់ធម្មាចារ្យនៃសាលាពុទ្ធិកបឋមសិក្សានាទាក្នុងព្រះរាជអាណាចក្រក្រោមអធិបតីភាព នៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ឧទ្ទិសក្រោមការចាត់ចែងរបស់លោកផ្ទ-ព្រឿងរដ្ឋមន្ត្រីក្រសួងធម្មការ ឧទ្ទិសលោក អ៊ុង-ហុងសាង ជារដ្ឋលេខាធិការក្រសួងធម្មការ ដោយមានព្រះតេជព្រះគុណព្រះអរិយកសប្បៃ កែវ-អ៊ូច ជាតំណាងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្ត, ព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សា ឧទ្ទិសព្រះពាជាគណៈឋានានុក្រម ក្នុងព្រះរាជធានីបាន

ទំមន្តមកដួបជុំជាកិត្តិយសដល់ពិធីបើកការបង្រៀនគរុកោសល្យនេះ ។

ចំណែកខាងក្រៅគ្រូហត្ថមានឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ព្រមដោយសហការីផ្ទាល់របស់លោក ៤ រូប ឧទ្ទិលោកតំណាងសមាគមមូលនិធិអាស៊ី លោក ចៅ-សេង រដ្ឋលេខាធិការក្រសួងសិក្សាធិការ លោក សម-ញ៉ា ណប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឧទ្ទិលជាប្រធានភ្ញៀវកិត្តិយសមកកាន់ដ្ឋាន លោក ប៉ាយ-ល្មុត លោក ម៉ុ-នរសីហ៍ អតីតរដ្ឋមន្ត្រីក្រសួងធម្មការ លោក ធឹង-ខេម ដំណាងឱកហ្វាយក្រុង លោក យ៉ែម-ព៉ែន ទីប្រឹក្សាបច្ចេកទេសនៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពាជ គហបតី ម៉ែ-យាន លោក ឧក-ញ៉ាវិសេសកោគា ង-ជាវលី គហបតី លី-គិមង្ហួន លោក ម៉ៅ-ម៉ី ឧទ្ទិលដល់លោកជាសាស្ត្រាចារ្យទាំងឡាយ បានអញ្ជើញទៅដួបជុំក្នុងឱកាសជាឧឡារិកនោះ ។

ការអប់រំខាងគរុកោសល្យដល់ជម្មាចារ្យចំនួន ៣០០ អង្គ ដែលទំមន្តមកពីគ្រប់វៃត្រ ក្នុងព្រះរាជអាណាចក្រនេះនឹងត្រូវធ្វើអស់រយៈពេល ១ ខែ គិតចាប់ពីថ្ងៃទី ១១ មិថុនា ដល់ថ្ងៃទី ១៤ កក្កដា ១៩៥៨ ក្រោមការដឹកនាំព្រៃរតេជព្រះគុណព្រះពោធិវ័ង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពាជ ។

អំពីការចេញដំណើរនៃគណៈប្រតិភូ

ជំណាងសម្តេចព្រះសង្ឃនាយកគណៈមហា

និកាយទៅកាន់ប្រទេសចិនប្រជាមានិត

តាមសេចក្តីនិមន្តរបស់ពុទ្ធសមាគមចិន គណៈប្រតិភូតំណាង
សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ នឹងនិមន្តចេញដំណើរពីចំណត
អាកាសយានពោធិចិនតុងនៅថ្ងៃអាទិត្យទី ១៥ មិថុនា វេលាម៉ោង ៨ ព្រឹក
តាមអាកាសយាន ដើម្បីឆ្ពោះទៅកាន់ក្រុងហុងកុង ។

ឯគណៈប្រតិភូនេះមានសមាសភាពដូចតទៅ:

— ព្រះពោធិវង្ស ហួត-តាត វង់ប្បញ្ញា ជាប្រធាន

— ព្រះគ្រូវិនយមុនី ជាប់-ប្រាង្គ ឥន្ទបញ្ញា ជាសមាជិក

— លោកអុង-តាំងសាយ ជាវេយ្យាវច្ចករ ។

តាមកម្មវិធីរបស់ពុទ្ធសមាគមចិន គណៈប្រតិភូព្រះសង្ឃដែលនិ-
មន្តទៅកាន់ប្រទេសចិន ត្រូវមានការៈដូចតទៅ:

១— ពិនិត្យមើលរបៀបសាសនានៅប្រទេសចិនដោយមានការ
សន្យានឹងតបតាមផ្លែងៗជាដើម ។

២— សង្កេតមើលស្ថានភាពប្រទេសចិនប្រជាមានិត និងដឹងភាព
នៃប្រជាពលរដ្ឋរបស់ប្រទេសនេះ ។

៣— ពិនិត្យមើលសារៈសំខាន់អំពីប្រវត្តិសាស្ត្រ ដែលអាចបញ្ជាក់ឲ្យឃើញអំពីការច្រាស្រ៊ុយគាត់ទន្ទឹងរវាងប្រទេសកម្ពុជា និងប្រទេសចិនក្នុងបុរាណកាល ។

យើងសូមបញ្ជាក់ថា ពុទ្ធសាសនាមិនបានមិនប្តូរសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តដែរ តែសម្តេចព្រះសង្ឃនាយកបានសូត្រព្រះវិន័យថា និងនិមន្តទៅប្តូរនឹងពាក់គណៈប្រគល់ឲ្យនិមន្តទៅ នៅពេលចេញព្រះវស្សាខាងមុខនេះ ។

អំពីសកម្មភាពរបស់ក្រុមសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ

រថយន្តផ្ទុកការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ដែលបានស្ថាបនាឡើងពីបុរាណឆ្នាំ ១៩៥៧ ដើម្បីពង្រីកការផ្សាយរបស់ក្រុមនេះឲ្យបានធំទូលាយផង ដើម្បីបំពេញអធ្យាស្រ័យនឹងសម្រួលនូវការសិក្សា ផ្នែកព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រ នៃពុទ្ធសាសនិកជនទូទៅក្នុងព្រះរាជអាណាចក្រឲ្យមានដំណើរប្រព្រឹត្តទៅបានដោយធូរស្រួល កុំឲ្យពុទ្ធបរិស័ទពាំងនោះលំបាកនឹងធ្វើដំណើរទៅមក រកជាវផ្ទាល់ដល់ក្រុមពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញផង បានធ្វើដំណើរទស្សនាចរចូលទៅច្រាស្រ៊ុយគាត់ទន្ទឹងផ្ទាល់ស្មើរគ្រប់វត្តអារាម ដែលស្ថិតនៅឆ្ងាយ ។ ពីរាជធានី ក្នុងខែត្រនានានៃព្រះរាជអាណាចក្រ តាំងពីដើមឆ្នាំ ១៩៥៨ ដរាបមកទល់នឹងខែទុសាមុននេះ បានចែកជាអំណោយនឹងបានជាវនូវសៀវភៅធម៌អាថិ

ផ្សេង ។ ដែលក្រុមពុទ្ធសាសនបណ្ឌិត្យ បានចោះពុម្ពផ្សាយមានចំនួន ដូចតទៅនេះ ៖ អំណោយចំនួន ៥០០ សៀវភៅ នីមួយផ្សេង ។ ចំនួន ៣០០ ជាវចំនួន ៥.៧៤៩ សៀវភៅ បានជាប្រាក់ចំនួន ៥៦.៣៨ ៥៣០ ជាប្រយោជន៍ដល់ថវិកាជាតិ ។

ឯសកម្មភាពទស្សនាចរនៃរថយន្តនេះ នឹងត្រូវបន្តដំណើរទៅកាន់ខែត្រកំពង់ចាមក្រុងនឹងស្នើនត្រែង ក្នុងបុរីខែមិថុនានឹងដើមខែកក្កដា ១៩៥៨ ហើយបន្ទាប់ពីនេះទៅទៀតនឹងត្រូវទៅកាន់ខែត្រព្រៃវែងនឹងស្វាយរៀង ក្នុងខែសីហា ១៩៥៨ ។

ដូច្នេះ សូមគោរពលោក អ្នកពុទ្ធបរិស័ទទាំងឡាយក្នុងខែត្រដូចបានរៀបរាប់ខាងលើនេះ អញ្ជើញចាំជាវសៀវភៅដែលមិនអាចផ្សេង ។ ពីរថយន្តនោះតាមត្រូវការ ។

អំពីការតាំងមន្ត្រីសង្ឃ

-បានតាំងកិត្តិវង្ស-ខូចហៅពិន នៅវត្តពោធិវ័នជាទីព្រះគ្រូវិនយមគ្គលជាសហការីនៃលោកមេគណខែត្រក្រចេះ ។

អំពីការតាំងអាចារ្យសម្រាប់វត្ត

-បានតាំងឈ្មោះ គង់ ថាន់ ជាអាចារ្យសម្រាប់វត្តបឹងល្វា ឃុំបឹងល្វា ស្រុកសន្ទុក (កំពង់ធំ) ។

-បានតាំងឈ្មោះ ឡុង-ផែ ជាអាចារ្យសម្រាប់វត្តចន្ទរង្សី ឃុំរំលេច

ស្រុកសិង្ហរកណ្តាល (ព្រៃវែង) ។

ជំណឹងផ្សេងៗ

កាលពីពេលព្រឹកថ្ងៃច័ន្ទទី៩មិថុនា១៩៥៨ មានព្រះសង្ឃ ជាតិចិន៤អង្គ ដែលទើបមកពីកោះហ្វ័រម៉ូស ចូលនិមន្តទៅទស្សនាពុទ្ធសាសនបណ្ឌិត្យ ហើយចាននឹងធ្វើអំណាយ ជាសៀវភៅជាមិកាសាចិនចំនួន៥ក្បាលដល់ក្រុមពុទ្ធសាសនបណ្ឌិត្យ ដើម្បីតម្កល់ទុកជូនសាធារណជនអានតាមត្រូវការ ។

ការតាំងសាស្ត្រាចារ្យសាលពុទ្ធិកបឋមសិក្សា

ក្នុងខែមិថុនា គ ស. ១៩៥៨

ចានតាំងលោកុមហាឈុន-ភ័ វត្តទិណ្ណាភាម ឃុំរកាក់ជ្រៃស្រុកចាក្តុំ (ព្រៃវែង)

-ដ. អ៊ិន ឈួន វត្តក្រចាំ ឃុំក្រចាំ ស្រុកកំចាយមារ -ដ.

-ដ. គិន គិមអាន វត្តសុពណ្ណ ឃុំកន្សោមអក ស្រុកកំពង់ត្របែក -ដ.

-ដ អ៊ុក ជាល វត្តក្តុំខែត ឃុំចំការក្រូច ស្រុកចំការលើ (កំពង់ចាម)

-ដ- ជួប ឃាន ក្រចេះ ឃុំសោប ស្រុកក្រចេះ (ក្រចេះ)

-ដ- អួង សៀង ពោធិលង្កា ឃុំសៀមរាប ស្រុកសៀមរាប(សៀមរាប)

-ដ- ពោ ឃុំ. . . . . .

-ដ. អ៊ុន ស៊ុន វត្តស៊ីសុវត្ថារាម ឃុំតាំងគ្រាំង ស្រុកដើងព្រៃ(កំពង់ចាម)

-ដ ពេជ្រ ហ៊ុម វត្តគគីរ ឃុំព្រែកអាដី ស្រុកក្រូចឆ្មា -ដ-

ពិធីបុណ្យស្រោចទឹកបៅអធិការ

លោក ឯឧ-ប៉ង់ រៀបរៀង

កាលពីថ្ងៃទី ១៦ មេសា ១៩៥៨ វេលាម៉ោង ៨ យប់ក្នុងបរិវេណវត្ត លង្កា មានធ្វើពិធីស្រោចទឹកជាទូទៅក ចំពោះព្រះតេជព្រះគុណព្រះពុទ្ធវង្ស កៅ-សុម សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ឡើងកាន់តំណែងជាបៅអធិការវត្តលង្កា ។

ក្នុងពេលនោះ យើងសង្កេតឃើញពុទ្ធបរិស័ទចាំងឡាយ ចាំងព្រះសង្ឃ ចាំងគ្រហស្ថកំពុងចាត់ចែងពិធីបុណ្យ សុទ្ធតែមានទឹកមុខរីករាយញញឹមញញែមមកគ្នា ហាក់ដូចជាមានសេចក្តីសង្ឃឹមថា វត្តលង្កានឹងមានសេចក្តីរុងរឿង ដូចកាលដែលសម្តេចព្រះធម្មលិខិត ស្រ៊ី-ឯមទត្តមប្រឹក្សាគណៈមហានិកាយគង់ព្រះជន្មនៅឡើយដែរ ។

នៅម៉ោង ១៨,ទឹង ៣០ នាទី បាននិមន្តព្រះសង្ឃ, ៦១ អង្គចំពោះព្រះបរិត្ត រួចនិមន្តព្រះតេជព្រះគុណព្រះពោធិវង្ស ហ-គាត ចាន់ហ្វាង ពុទ្ធិក-វិទ្យាល័យព្រះសុរាម្រិត សំដែងធម៌ទេសនា ។

ព្រឹកឡើងថ្ងៃទី ១៣ មេ.ស ១៩៥៨ វេលាម៉ោង ៩ ទឹង ៥ នាទី ពុទ្ធបរិស័ទចាំងឡាយបានទៅដង្ហែលោកគ្រូបៅអធិការថ្មី ពីកុដិរបស់លោកឲ្យមកឋិតនៅត្រង់ខាងជើងហោរត្រៃយជាកន្លែងកប់ចុតត្រ ហើយបានដាក់ចុតត្រ

ព្រះសង្ឃដែលគង់ក្នុងវត្តលង្កាចំនួន ៦១ អង្គ, ព្រះសង្ឃទាំងនេះបានសូត្រ
ធម្មប្រសិទ្ធិពរប្រគេនចៅអធិការថ្មី ។

ដល់ម៉ោង ៩.៣០ នាទី បានឯកឧត្តមលោកគ្រូចៅអធិការថ្មីទៅ
គង់លើបុស្សកត្រង់ខាងមុខព្រះវិហារ ដែលមានព្រះសង្ឃនិងគ្រហស្ថ
ឈរត្រៀបត្រាវធំចាំធ្វើតាវៃកិច្ច ។

លុះលោកគ្រូចៅអធិការថ្មីគង់សមរហើយ ព្រះសង្ឃចាំងឡាយដែល
មានសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណមហានិ-
កាយ, ព្រះតេជព្រះគុណព្រះពោធិវង្ស ហ-តាតចាង ហ្វាង ពុទ្ធិកវិទ្យាល័យ
ព្រះសុរាម្រឹត' ព្រះតេជព្រះគុណព្រះមហាព្រហ្មមុនី ខេត-អ៊ួចាង ហ្វាង
វង្ស ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតជាដើម បានឡើងទៅស្រោចទឹកដំឫមន្ត ។
បន្តបន្ទាប់មក សម្តេចបានថ្លែងសារសើរ អំពីការសូប់ស្វាត់ទីតាំងរៀបរយ
នៃកិក្ខុសាមណេ វត្តលង្កា ក្នុងអតីតកាល ទីជាបច្ចុប្បន្នកាលនេះថាក្នុង
អនាគតដ៏វែងឆ្ងាយ សង្ឃឹមថា ការសូប់ស្វាត់ទីតាំងរៀបរយនៃកិក្ខុសាមណេ
ចេះតែមានជាបមិនខាន, ក្នុងវត្តលង្កាគួរតែមានគណៈកម្មការបាសក
ទីឯគណៈកម្មការសង្ឃ, ប៉ុន្តែ គណៈកម្មការសង្ឃ ត្រូវមានចំនួនយ៉ាង
តិចត្រឹម ១២ រូប ដើម្បីចាត់ការក្នុងវត្តទើបមានល្បឿនលឿន ។

ក្រោយពីការស្រោចទឹកដំឫមន្តមក ពុទ្ធបរិស័ទចាំងឡាយដែលមាន

ព្រះតេជព្រះគុណព្រះពោធិវង្ស ហ តាត ជាដើមបានដង្ហែលោកទៅអធិ-
ការថ្មីឡើងទៅលើធម្មកុដ ហើយលើកព្រះពជ្រតម្រងតាំងសូត្រប្រគេនព្រះ
សង្ឃនីធីដូនគ្រហស្ថតាំងឡាយស្តាប់ ។

មុនអំពីការបញ្ចប់ពិធីនោះ ព្រះតេជព្រះគុណព្រះពោធិវង្សបានទូលវិ-
ញ្ញាណក្ខន្ធព្រះសពសម្តេចព្រះធម្មលិខិតសូមឲ្យសម្តេចជ្រាបពីការតាំងទៅ
អធិការថ្មី ហើយសូមឲ្យព្រះសពសម្តេចចងួយថែរក្សាវត្តលង្កា ធម្មកុដ សូម
ឲ្យជួយរក្សាទៅអធិការថ្មីឲ្យប្រកបដោយសេចក្តីសុខសួស្តីកុំបីឃ្លៀងឃ្លាត។

វត្តលង្កា ដែលចេញចាកក្នុងដូនពេញ មកបិតនៅខាងត្បូងសាលា
គរុវិជ្ជា ជាប់នឹងរូងវិថីព្រះបាទសីហនុ សង្កាត់លេខ ៦ ភ្នំពេញនេះ មាន
អតីតទៅអធិការ ៣ រូប រួមតាំងទៅអធិការបច្ចុប្បន្ននេះផងជា ៤ រូបគឺ

១- ព្រះតេជព្រះគុណព្រះញាណបវរវិជ្ជា អុក "១"

២- " " " " " ខាត់ "២"

៣- សម្តេចព្រះធម្មលិខិតស្វី- ឯមទគ្គមប្រឹក្សាគណៈមហានិកាយ។

៤- ព្រះតេជព្រះគុណព្រះពុទ្ធវង្សកៅ- សុីម សាស្ត្រាចារ្យពុទ្ធិកវិទ្យា-
ល័យព្រះសុរាម្រឹត ។

ព្រះតេជព្រះគុណព្រះពុទ្ធវង្សកៅ- សុីម នេះ ជាព្រះថេរៈរូបដែល

១-២- បានសូរព្រះតេជព្រះគុណព្រះពុទ្ធវង្សកៅ-សុីម ។

មានបំណងដាំដើមខាងពុទ្ធសាសនាយ៉ាងមុតមាំ ចានរៀបរៀងសៀវភៅជាច្រើន ដូចមានរៀងឈ្មោះនៅក្នុងដីវប្រវត្តិឯណោះស្រាប់ មានបំណងខាងអក្សរបាំង ទើងអក្សរសៀម ពាងមានចរិយាសណ្តាបធ្នាប់ សមជាសមណសារូប ទើងសមជាចៅអធិការវត្តលង្កា ដែលស្ថិតនៅក្នុងក្រុងភ្នំពេញ ជាវត្តមានភេរីឈ្មោះលីលីញ ដោយមានតិក្ខុសាមណេរចេះធម្មវិន័យ ហើយប្រព្រឹត្តល្អតាមធម្មវិន័យផង ។

ពិធីបុណ្យស្រោចទឹកចៅអធិការបានចប់នៅម៉ោង១០ ទើង៩នាទី ។

ជីវប្រវត្តិ

នៃព្រះតេជព្រះគុណព្រះពុទ្ធវង្ស កៅ-ស៊ុំម

កិត្តិ ឧយ ចេង រៀបរៀង ព្រះមហា សូរ-ស្ងួ ពិនិត្យ

ព្រះតេជព្រះគុណពុទ្ធវង្ស កៅ ស៊ុំម សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ ព្រះសុពាម្រឹត ប្រសូតនៅថ្ងៃព្រហស្បតិ៍ ៥ រោចខែពិសាខ (ទសកា) ព.ស. ២៤៤១ គ.ស. ១៨៩៨ នៅក្នុងឃុំសីធរស្រុកខ្សាច់កណ្តាល ខែត្រកណ្តាល ក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមព្រះសុវណ្ណគោដ្ឋ ។

បិតានាម កៅ-គង់ មាតានាម រ័ត្ន ជាអ្នកធ្វើស្រែចម្ការមានបងប្អូនរួមទាំង ៣ នាក់ គឺទី១ បងប្រុស, ទី២ បងស្រី ទី៣ ប្អូនប្រុសគឺព្រះពុទ្ធវង្ស កៅ-ស៊ុំម ។ បងទាំងអស់នោះអនិច្ចកម្មទៅហើយ ។

កាលដែលព្រះពុទ្ធវង្ស កៅ- ស៊ុំមនៅកុមារ មានអាយុ៨ឆ្នាំ មាតាបិតាបានយកទៅឧកជាក់ ឲ្យនៅរៀនអក្សរសាស្ត្រជាតិ ក្នុងសំណាក់សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សាគណៈមហានិកាយ កាលដែលនៅធ្វើចៅអធិការវត្តស៊ីធរនៅឡើយ ។

(មានត)

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អង្គក ន.បុ. អវយវៈ ; អង្គ, ខ្លួន ។

អង្គណា ន.បុ. អង្គណៈ;បុ. ន.បុ. ទំលាន ។

អង្គនា ស្ត្រី. ស្ត្រី, ប្រពន្ធ, សត្វញី ។

អង្គារ បុ. ធ្យូង, សេចក្តីខ្មាស ។ -ក បុ. ធ្យូង; ឈ្មោះផ្កាយអង្គារ, ឈ្មោះអសុរ ។ -កា ស្ត្រី. ឈ្មោះរក្សសី ។ -គា ស្ត្រី. ការនៃធ្យូង ។ -វតី ស្ត្រី. ឈ្មោះស្ត្រីម្នាក់ ។ -កមណ្ឌ បុ. ឡធ្យូង ។ -ការក បុ., -ការិន៍ បុ. ឬ -កូត៌ បុ. អ្នកធ្វើធ្យូង ។ -ធានី ឬ ធានិកា ស្ត្រី. ចង្ក្រានលើកជាន ។ -ឋាត្រី ស្ត្រី. ចង្ក្រានលើកជាន ។ -បុម្ភ បុ. ដើមអង្គារបុប្ប ។ -ភកដី ស្ត្រី. ចង្ក្រានដើរជានដោយកង់។ អង្គារភក្សយ ណ បុ. ប៉ែលសម្រាប់ចូកធ្យូងឬ គ្រឿងឧបករណ៍សម្រាប់លត់ភ្លើង ។

អង្គារកិត៌ គុ. ដែលកើតជាធ្យូង ។

អង្គារិ ស្ត្រី. ចង្ក្រានតូច ។


អង្គារិត៌ គុ. ដែលកើតជាធ្យូង ។

អង្គារិយ ដែលសម្រាប់ធ្វើជាធ្យូង ។

☞ មានត

ពជាតិសេតនៃព្រះគុណជាអម្ចាស់ដ៏វិតលើតួង នឹងសម្តេចព្រះមហា-
ក្សត្រិយានី ចាំងបញ្ចាំងភាពយន្តអំពីក្សួនហែព្រះសពសម្តេចព្រះធម្ម-
លិខិតឧត្តមប្រឹក្សាគណៈមហានិកាយ ឆ្ពោះទៅកាន់ព្រះមេរុជាដើម គួរជា
ទីឧស្សាហ៍នៃពុទ្ធបរិស័ទចាំងឡាយ ។

លុះព្រឹកឡើងថ្ងៃទី ៤៧ មេសា ១៩៥៨ វេលាម៉ោង១០ នឹង១៥
នាទី បានចាត់ចែងវេរកត្តប្រគេនព្រះសង្ឃចាំងពីរគណៈ មានព្រះសង្ឃ
វត្តទុណ្ណាលោមនឹងវត្តស្វាយពៃជាដើម ទុទ្ទិសភាគផលជាកិច្ចបញ្ចប់
ពីធីបុណ្យនោះ ។



ដំណឹងអស្ចារ្យ

កាលពីថ្ងៃទី ៤ ឧសភា ១៩៥៨ លោកគ្រូចៅអធិការ វត្តពាះ-
ឈរឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង សឹងយប់ដំណេកយើញថា
មានព្រះពុទ្ធរូបមួយព្រះអង្គ ផុសឡើងក្នុងទឹកស្រះ នៅចំពាក់កណ្តាល
ស្រះក្នុងវត្តនោះ លុះព្រឹកឡើង លោកគ្រូបានចាត់ឲ្យកិក្ខុសង្ឃ ចុះពាវក
ពេញស្រះចាំងអស់ ឃើញព្រះពុទ្ធរូបនោះមែន ឯព្រះពុទ្ធរូបទ្រង់ឈរយក
ព្រះហស្តចាំងពីរកឡើង កំពស់ ៣០ សង់ទីម៉ែត្រ ធ្វើអំពីសំរិទ្ធសុទ្ធ ។
ព្រះពុទ្ធរូបអង្គនេះ គេអាចដឹងបានថាសាងតាំងពីសម័យបុពណាកាល
ជ័យលេងមកហើយ ឥឡូវនេះ ពុទ្ធបរិស័ទដើងវត្តនឹងព្រះសង្ឃបាន
ជំកល់វាក្នុងកន្លែងវត្តនោះ សម្រាប់គោរពបូជាតទៅ ។



ភាគ្គិយសុត្តន្តិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣០ លេខ ៧ ខែកក្កដា

ព.ស. ២៥០១ គ.ស. ១៩៥៨

ភ្នំពេញ

វិសាខបូជានៅទីក្រុងប៉ារិស

កាលពីថ្ងៃសៅរ៍ ទី ៣ ឧសភា ១៩៨៩ មានធ្វើពិធីបុណ្យវិសាខបូជា នៅពិពិធកណ្ឌស្ថាន គីមេត៍ ដែលមានពួក"មិត្តពុទ្ធសាសនា"បានចូលរៀបរួមជាមួយ ព្រមទាំងជនជាតិខ្មែរ, ថៃ, ឥណ្ឌៀ នឹងសិង្ហឡជាច្រើន ក្រោយដែលព្រះមហាថេរៈជុកច័រពាហ៊ុល បានច្រាស្រ័យដោយមធុរវាចាយ៉ាងផ្អែមល្ហែម ទៅកាន់ក្បៀវចាំងនោះ ឯកឧត្តម ឯកអគ្គរាជទូតប្រទេសថៃឡង់ប្រចាំទីក្រុងប៉ារិស បានសូត្រនូវសង្កថាមួយ, ល៉ាជាប់តមក ឯកឧត្តមឯកអគ្គរាជទូតប្រទេសស៊ីឡង់ប្រចាំទីក្រុងប៉ារិស នឹងលោកហ៊ីល្ទហ្សារ, សាស្ត្រាចារ្យវិទ្យាល័យប្រទេសចាំងនឹងព្រះគ្រូសង្ឃសត្តា ប៉ុណ្ណ សុម្ភាជ ធម្មាភមោ បានថ្លែងបំភ្លឺនូវពិធីបុណ្យនេះដោយសង្ខេប ចំពោះពុទ្ធសាសនិកជនចាំងឡាយថា បុណ្យនេះជាបុណ្យរលឹកព្រះគុណព្រះសម្មាសម្ពុទ្ធជាម្ចាស់ ត្រង់ថ្ងៃដែលព្រះអង្គប្រសូត, ព្រះអង្គត្រាស់ដឹងនឹងព្រះអង្គចូលបរិនិព្វាន ។

ពិធីបុណ្យនេះ បានបញ្ចប់នៅម៉ោង ៦.៣ ដោយមានបញ្ចាំងភាពយន្តអំពីរឿង"ពុទ្ធប្រវត្តិ" ។

ថ្ងៃស្អែក,គឺថ្ងៃអាទិត្យ ទី ៤ ឧសភាពេលម៉ោង ១៤,មានពួកពុទ្ធមាមក-ជនជាច្រើនបានចូលមកកាន់ "សន្តិសាលា"នៃសមាគមមិត្តពុទ្ធសាសនា

តទៅទំព័រចុងក្រោយ



ភ័ទ្ធសុទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ ព្រះមហា ជា-ទាត់ រៀបរៀង	៥៣៤
	- វប្បធម៌ពុទ្ធសាសនា (តមក) ព្រះញាណវីរៈ: ភិន-សាមុំ រៀបរៀង	៥៨៣
	- សទ្ធម្មប្បជោត ព្រះមហា អ៊ុក-អឹន រៀបរៀង	៦០១
	- ពុទ្ធសាសនា ធៀបសាសនាឯទៃ របស់លោកជា-យូ	៦០១
ផ្នែកអក្សរសាស្ត្រ		
	- រឿងទេន្តរបស់អម្រឹតក្យត្រីម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ	៦០៩
	- រឿងសាមកុក (តមក) ឧកញ៉ា ន្នូ-ហន ប្រែ	៦២៣
	- ល្បែងបឋមសិក្សា (ភាសាភាសា លោក ស៊ីន-ហ៊ាន ចម្លងចេញពីសាស្ត្រាស្ទឹងត្រែត .	៦៣៧
	- សុភាសិតសាសន៍ចែប្ស លោក ភ័ឃ-ប៊ុក ប្រែរៀបរៀង	៦៤៩
	- រឿងព្រេងប្រាប្តកាក្យថា «ឆ្កែឆ្នាក់ឆ្មាទៅ» លោក ជាប-ពិន រៀបរៀង . .	៦៥៣
	- រឿងព្រេងទំនងរឿងបុកណានៃប្រទេសជប៉ុន (តមក) លោក ភ័ឃ-ប៊ុក	៦៦៦
ផ្នែកកំណត់ទឹងប្រវត្តិការណ៍		
	- ពត៌មានផ្សេង ។ របស់ក្រសួងធម្មការ . .	៦៨០
	- ដីវប្រតិនៃព្រះពុទ្ធវង្ស កៅ-សុីម ភ័ក្ខឧយ-ចេង	៦៨៣
	- វចនានុក្រមសំស្ក្រឹត.ខ្មែរ (តមក) ហ៊ាង ទាត់	៦៩១

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

-Histoire du Bouddhisme au Cambodge (suite) par Vén. *PANG-KHAT* 575
-Culture bouddhique par Vén. *VANN-SADUM* 587
-Saddhammappachota par Vén. *OUK-IN* 601
-Bouddhisme comparé par *M. CHEA-YOU* 611

PARTIE LITTERAIRE :

-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* 619
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . . 627
-Conseils aux jeunes (Poème) extraits du «Satra» par *M. SIN-HEAN* 637
-Proverbes persans par *M. RAY-BUC* 649
-Conte et légende «Donnez au chien ou au chat» par *M. CHAP-PIN* 653
-Conte et Légende du Japon (suite) traduits par *M.RAY-BUC* 656

NOTES ET CHRONIQUES :

-Chroniques du Ministère des Cultes 660
-Biographie du Vén. *KAO-SIM* par Vén. *CHAY-CHENG* 663
-Dictionnaire Sanskrit-Khmèr (suite) par Vén *PANG-KHAT* 671

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ជួង - ខាត់ រៀបរៀង

(តមក)

មួយទៀត នៅខួលព្រះធាតុ (ខេត្តកំពង់ស្ពឺ) ។ ព្រះពុទ្ធរូបទាំងនេះ ជាការចងនាក្នុងជា អង្គរបុរី បែបអមរាវតី ដូចព្រះពុទ្ធរូបនៅដុងយឿន (វៀតណាមកណ្តាល), នៅខួលសេតុនតាំង (សុមាត្រា), នៅជៃយ៉ា (ជ្វា), នៅស៊ីកេងជេង (កោះសៀម្បប) ។ ឯព្រះពុទ្ធរូបនៅនគរាជសីមា នៅនគរបឋម (សៀម) ជាការចងនាក្នុងជា នៅអង្គរបុរីដែរ ។ នៅបុរាណ-ដ្ឋាន អុក-អែវ សម័យនគរភ្នំ លោក ល.ម៉ាល្លឺរែត្បានរកឃើញព្រះ-ពុទ្ធរូបបុរាណធ្វើពីសំរិទ្ធច្រើនអង្គ ការចងនាបែបគន្ធារៈនិងអមរាវតី ។

សេចក្តីរៀបរាប់មកប៉ុណ្ណោះ សំដែងឲ្យឃើញថា ព្រះពុទ្ធសាសនា ថេរវាទចំរើនរុងរឿងណា ស់ក្នុងសម័យនគរភ្នំ ហើយមិនដែលសាបសូន្យ នៅក្នុងសម័យណាមួយទេ មិនមែនដូចពាក្យលោកចិនយី តឹង្ស(Yi Tsing) ដែលលោកសរសេរតាលោកមកកាន់តាស៊ីកាគតាគ្នេយ៍ ពី ព. ស. ១៦១៤-១៦៣៨ (គ.ស. ៦៧១-៦៩៥) ថា "នៅប្រទេសនគរភ្នំ ព្រះ

ពុទ្ធសាសនាចំរើនរុងរឿងណាស់ ហើយផ្សាយទូទៅ តមកមានព្រះក-
ជាមួយព្រះអង្គមិនសព្វព្រះទ័យ ហើយទ្រង់បំផ្លាញចោលអស់ទៅហើយ
ឥឡូវនេះ សូម្បីតែកំទូមួយអង្គក៏មិនសល់ទៅផង» នោះឯង ។

សម័យចេនឡា — ពុទ្ធសតវត្សទី១១ទៅទី១៤ (ព.ស. ១០៤៣-
១៣៤៥) គ្រិស្តសតវត្សទី ៦ ទៅទី៨ (គ.ស. ៥៤០—៨០៦) ពង្សាវតារ
ចិន (ពង្សាវតារគាំង) មានដើមពុទ្ធសតវត្សទី១១ (គ្រិស្តសតវត្សទី៦)
និយាយថា នៅប្រទេសហ្វូណាន មានការកន្តប្រែទៅក្នុងប្រទេស ។ ប្រ
ទេសចេនឡាលើកទ័ពមកវាយក្រុងហ្វូមូ (to-mou) = វ្យាធបុរៈ (ចាក្កំ)
ហើយព្រះរាជាវ្យាធបុរៈចេញទៅគង់នៅក្រុងមានឈ្មោះណា-ហ្វូ-ណា
(na-fou-na) នវារនគរ (អង្គរបុរី?) ។ ពង្សាវតារចិន (ពង្សាវតារស្រួយ)
និយាយថា មានកូនក្រុមប្រទេសចេនឡានាមចេ-ហ្វូ សេ-នា.ចិ តសេនាគឺជា
ព្រះអនុជព្រះបាទភវរ្ម័នទី ១ មកជណ្តើមយកក្រុងកំពុជ ។ សម័យនេះអ្នក
ប្រាជ្ញពង្សាវតារសន្មតឈ្មោះថា "សម័យចេនឡា" ។ មានព្រះរាជាសោយ
រាជ្យតសន្តតិវង្សមកគឺព្រះបាទភវរ្ម័នទី ១ ចិត្រសេនា មហេន្ទ្រវរ្ម័ន
(ពាក់កណ្តាលគ្រិស្តសតវត្សទី ៦) (ទាន់ចុងគ្រិស្តសតវត្សទី ៦) ឥសា-
សានវរ្ម័ន ក្នុង គ.ស. ៦១៦-៦២៦. ភវវរ្ម័នទី ២ ក្នុង គ.ស. ៦៣៤.
ជយវរ្ម័នទី១ក្នុងគ.ស.៦៥៧ ៦៨១ ។ ពុទ្ធសាសនាថេរវាទចំរើនរុងរឿង

នៅឡើយ តែសម័យនេះ មានការប្រែប្រួលគួរឲ្យកត់សំគាល់ គឺមានពុទ្ធ-
សាសនាលទ្ធិមហាយានចូលមកប្រទេសកម្ពុជាយើងមុនដំបូងនៅទាន់ដើម
ពុទ្ធសតវត្សរ៍ទី ១២ ។

ក្នុងរជ្ជកាលព្រះបាទគ្លៀសានវ៉ែនទី ១ ព.ស ១១៥៩-១១៦៩
(គ.ស. ៦១៦-៦២៦) មានសិលាចារឹកមួយនៅសម្បូណ៌ព្រៃគុក(ក្លៀសាន
ប៊ុរៈ) ខេត្តកំពង់ធំ ក្នុងព.ស. ១១៦៩ (គ.ស. ៦២៦) បញ្ជាក់ថាមានព្រះ
ពុទ្ធសាសនា ។ មានការគោរពនាគរាជមុចលិន្ទដែលប្រកព្រះពុទ្ធរូប ។
សិលាចារឹកនេះនិយាយពីព្រាហ្មណ៍ឈ្មោះ បសុបតិ ជាវរៈវិទ្យាវិសេសៈ
ជាអ្នកប្រាជ្ញមានការចេះដឹងខ្ពង់ខ្ពស់ ចេះអត្ថន តិផ្លូវវិទ្យាទាន់វេយ្យាករណ៍
ទាន់វ៉ៃសេសិកៈ ទាន់ន្យាយៈ ទាន់សម័ក្ស (សំខ្យា.) និងពុទ្ធសាសនា ។
ក្នុងសិលាចារឹកនៅកុំពុកាយណ៍ ក៏ឃើញមានព្រាហ្មណ៍ឈ្មោះ បសុបតិ
នេះដែរ ។ លោកសីដែសសរសេរថា សិលាចារឹកនេះជាគ្រឿងសំគាល់
ឲ្យដឹងថា មានសិលាចារឹកពុទ្ធសាសនាជាបឋម ក្នុងសម័យចេនឡា ។
តែមាំខ្លួនលិន ' តាមពង្សាវតារចិនពាក់ព័ន្ធ សួយ ថា ក្នុងរាជ្យអង្គនេះ
មានភិក្ខុ ភិក្ខុនី ច្រើនអង្គ ។ សម័យនេះ មានសិលាចារឹកដែលនិយាយ
ពីពុទ្ធសាសនាច្រើនទៀត ។

ក្នុងរជ្ជកាលព្រះបាទភវ៉ែនទី២ ព.ស. ១១៨២(គ.ស.៦៣៩) មាន

សិលាចារឹកមួយនៅភូមិទាវកំនប់ជិតអញ្ចាប្រទេស (សៀម) ថ្ងៃនិ៍ពុធ-សកម្មាក់ជារជា លីនាហ្វ ប្រាសាទព្រះវិហារមួយខុទ្ទិសថ្វាយព្រះពុទ្ធ-សាសនា ព្រមទាំងថ្វាយទ្រព្យសម្រាប់វិហារនឹងភាសាចាស់ក្មេង ចំនួន ៣២ នាក់ក៏ទាំងអ្នករក្សាចំការដូនស្មាច្រើនរយដើមផង ។

ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ១ ព.ស. ១២១០-១២៦៥ (គ.ស. ៦៩៧-៧២១) មានសិលាចារឹកពីរ មួយនៅវត្តព្រៃវៀរក្នុង ព.ស. ១២១៦ (គ.ស. ៦៦៤) ស្រុកកំពង់ត្របែកខេត្តព្រៃវែង (កាលដើមជាខេត្តបាភ្នំ) ចែងពុកថា មានតិក្ខពីរអង្គជាបងប្អូនបង្កើតជាតិជាកំរ្តែថេញ ទ្រង់បព្វជ្ជាហើយគង់នៅវត្តព្រៃវៀរនេះ ដូចសេចក្តីកងចារឹកនោះថា "ក្នុងដែនដីដែលទ្រង់គ្រប់គ្រងនេះ មានតិក្ខពីរអង្គជាបងប្អូនបង្កើត ទាំងពីរអង្គ មានសិល ជាពហុស្សូត្រ សុភាព មានវន្តី មានរូបឱ្ជាន់ហើយ មានកុណា មានសមាធិចិត្តជាអរិយទ្រព្យ មានឈ្មោះដើមថាវតន: ដូចគ្នា ហើយទាងចុង មួយជាភាណុ មួយទៀតជាសិង្ហ: គឺតិក្ខវតន-ភាណុ១ តិក្ខវតនសិង្ហ:១

វត្តព្រៃវៀរនេះ ជាវត្តមួយបរមបុរាណ ប៉ិតថេរចរិយាលភាំងពីកាលនោះរហូតមកដល់សព្វថ្ងៃនេះ ។ អ្នកស្រុកជិតខាងវត្ត តំរឿងបុរាណតៗគ្នាមក និយាយបញ្ជាក់ថា វត្តនេះព្រះរាជាសម័យពីដើមបានថ្វាយចំពោះ

ព្រះសង្ឃ ហើយប្រគល់ឲ្យកិក្ខុពីរអង្គជាតិកម្ពុជាបដិបត្តិតវែរក្សា ហើយហាមប្រាមមិនឲ្យជនណាមួយទៅបៀតបៀនវត្តនេះទេ ។ អ្នកស្រុកហាមប្រាមកូនចៅត ។ គ្នាមក ឲ្យរៀមមិនឲ្យទៅកាប់ឈើព្រៃក្នុងវត្តនេះសោះ ហើយខ្ចាចត ។ គ្នាមកដល់សព្វថ្ងៃនេះ បានជាវត្តនេះមានឈ្មោះថា "វត្តព្រៃរៀវ" រហូតមក ។

មួយទៀតនៅវត្តប្រាសាទស្រុកកំពង់ត្រែចកខែត្រព្រៃវែង(តាលេដើមជាខេត្តចាក្ដី) និយាយពីការថ្វាយទាស:ចំពោះពោធិសត្វ ៣ អង្គគឺសស្ដុះ១ មៃត្រេយ:១ អវលោកិតេស្វរ:១ តាំង ៣ អង្គនេះ មានសមណស័ក្ដិជា "ព្រះ កម្រតាង អ័ញ" ។ សិលាចារឹកនេះជាខ្មែរ លោកអាយម៉ូនីញ៉ែរថាតើត ក្នុងគ្រិស្ដសតវត្សទី៦ឬទី៧។ មានសិលាចារឹកមួយទៀតនៅសៀមរាបពីព ស ១៣៣៤ (គ.ស.៧៩១) និយាយពីការតសាងរូបពោធិសត្វអវលោកិតេស្វរ: ទុកដើម្បីគោរពបូជា បូជនីយដ្ឋាននេះ សព្វថ្ងៃហៅថាប្រាសាទ "តាកៀម" ។

សេចក្ដីនេះធ្វើយស្របគ្នានឹងឯកសារចិនដែរ ។ ពង្សាវតារប្រទេសខ្មែរសម័យចេនឡា ពុទ្ធសតវត្សទី ១៣(គ្រិស្ដសតវត្សទី ៧) ក្នុងរជ្ជកាលព្រះបាទភ្លៀសាន(ភ្លើង) មានទៅក្នុងពង្សាវតារចិន ពាក្យថ្ងៃស្ដួយ លោកម៉ា-ទួន លិន សរសេរបន្ថែមពីពុទ្ធសតវត្សទី ១៩ (គ្រិស្ដសតវត្សទី ១៣) ថាៈ

"ព្រះពជាប្រថាប់នៅក្នុងព្រះពជធានីក្រុង ឦ-ប៊ូ-ណា (ឦសាន-បុរៈ) ។ ក្រុងនេះ មានគ្រួសារជាង៦០គ្រួសារ ។ នៅកណ្តាលក្រុងមានប្រាសាទមួយដែលទ្រង់ប្រោសប្រទានទទួលពជបរិពារ ។ ក្នុងពជអាណាចក្រចាំងមូលមានទីក្រុង ៣០ ។ ក្រុងនីមួយ ។ មានទីលំនៅនៃគ្រួសារច្រើនណាស់ ហើយមានចៅហ្វាយខេត្តម្នាក់ត្រួតគ្រប់ ។ ព្រះពជាទ្រង់ចេញគាន់ទីសាលប្រជុំជាទៀងរាត្រី ៣ ថ្ងៃម្តងរៀងទៅ ទ្រង់ប្រថាប់លើព្រះខែនធ្វើពីទ្រឹមចន្ទន៍ក្រឹស្នា ៥ ប្រភេទ ដែលប្រជាប់ដោយរតនវត្ថុ ៧ ប្រការ លើព្រះខែនមានសុវត្ថិត្រ ជាន់ធ្វើពីឈើមានផ្ការុំព្រះខែនប្រកបក្នុងការយផ្កាយមាស ខាងក្រោយមានវាំងស្មើមាស... ។ នៅដងក្រុង មានភ្នំមួយឈ្មោះ លិង-គា-ប៊ូ-ប៊ូ- គឺលិង្គបពិត ។ នៅលើកំពូលភ្នំនេះ មានទេវាល័យមួយដែលជាកន្លែងសម្រាប់មនុស្សធ្វើយញ្ញពិធីមានតាហានមួយពាន់នាក់នៅចាំក្បា ។ នៅចេនឡា មានប្រជាជនច្រើនគាន់ពុទ្ធសាសនា ។ អ្នកស្រុកធ្វើស្រែចំការ ។ល។

ក្នុងសម័យចេនឡា យើងឃើញថា ព្រះពុទ្ធសាសនាលទ្ធិមហាយានរុងរឿង តែមិនសូវមានរូបពោធិសត្វលោកេស្វរៈទេ មានមួយនៅខែត្រក្រមួនស មួយទៀតនៅប្រាសាទតាកៀម (សៀមរាប) ។ ឯព្រះពុទ្ធសាសនាថេរវាទក៏មិនមែនសាបសូន្យដែរ មិនមែនដូចសេចក្តីដែល

លោកចិនយើ-គ្បឹងពោលមកថាដំលើនោះទេ ។ តាមពិត សាសនាព្រាហ្មណ៍ក្តី ពុទ្ធសាសនាក្តី នៅជាមួយគ្នាជិតរយរយៈកាលរហូតមក ។

សម័យមហានគរ.— ពុទ្ធសតវត្សទី ១៤ ទៅទី២០ (ព.ស.១៣៤៩-១៩៧៩) គ្រិស្តសតវត្សទី ៨ ទៅទី១៥ (គ.ស. ៨០២. ១៤៣៦) ព្រះបាទជ័យវរ្ម័នទី ២ ទ្រង់ទៀនសោយរាជក្នុងព.ស. ១៣៤៩ (គ.ស. ៨០២) ទ្រង់រៀបចំធ្វើតាំងព្រះរាជធានីនៅលើមហេន្ទ្របព៌តគឺភ្នំគូលែន ។ ព្រះស្តេងអញ្ជើរវៃលែកតាមស្តេចទៅនៅក្នុងព្រះរាជធានីនោះដែរ ។ កាលនោះ ទ្រង់បាននិមន្តព្រាហ្មណ៍ម្នាក់ឈ្មោះហិរណ្យទាមៈ ឲ្យមកដួយរៀបហោមពិធីប្រកាសឯករាជ្យជាចក្រពត្រាធិរាជ ហើយលើកកិត្តិយសព្រះអង្គជាតួអង្គ "ទេវរាជ គឺព្រះហរិហរៈ" ខ្មែរធ្វើមុនដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរ ។ ព្រះបាទជ័យវរ្ម័នទី ២ នេះ ជាអង្គព្រះមហាក្សត្រមួយប្រសើរក្រៃលែង ទ្រង់បានរួបរួមប្រទេសដែលបែកបាក់គ្នាជាពីរ ដែលចិនហៅចេនឡាលើក្រោម ឲ្យទៅជាប្រទេសមានឯកភាពតែមួយឡើងក្នុងពន្ធារ-តារខ្មែរ ។ ព្រះរាជាអង្គនេះ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ ទ្រង់មិនបានកាន់ពុទ្ធសាសនាទេ តែពុទ្ធសាសនាតាំងពីរនិកាយក៏នៅជាមួយគ្នាដូចដើម ។ តាំងពីពុទ្ធសតវត្សទី ១៤ (គ្រិស្តសត-វត្សទី១០) រៀងរហូតមក យើងសង្កេតឃើញមានភេទប្លែកពីអតីត

សម័យ គឺព្រះរាជានិងមុខមន្ត្រីកាន់សាសនាមិនសូវស្រេបគ្នាទេ បើព្រះរាជាកាន់សាសនាព្រាហ្មណ៍ មុខមន្ត្រីកាន់ពុទ្ធសាសនា បើព្រះរាជាកាន់ពុទ្ធសាសនា មុខមន្ត្រីកាន់សាសនាព្រាហ្មណ៍វិញ ។

ព្រះបាទឥន្ទ្រវរ្ម័នទី ១ ទ្រង់ឡើងសោយរាជ្យក្នុង ព.ស. ១៤២០ (គ.ស. ៨៧៧) ទ្រង់តាំងព្រះរាជធានីនៅតម្បន់រលួស ស្រុកសូត្រនិគមសព្វថ្ងៃនេះ ប្រាសាទបាគង់ជាហរិហរាល័យគឺជាឋានព្រះហរិហរៈ ។ ព្រះរាជាអង្គនេះ ទ្រង់កាន់សាសនាព្រាហ្មណ៍ គោរពព្រះហរិហរៈ តែទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ។ ក្នុងរជ្ជកាលព្រះអង្គ មានសិលាចារឹកមួយពី ព.ស.១៤២៩ (គ.ស.៨៨៦) នៅបានប៊ុនតេប្រាប់ថា មានមន្ត្រីម្នាក់ឈ្មោះសោមាទិត្យៈ បានកសាងព្រះពុទ្ធរូបមួយអង្គ ជាសាស្តាព្រៃលែងជាងសាស្តាពាំងឮៗយ ហើយថ្វាយព្រះនាមថា "ព្រៃលោកឝ្ចាថ" ដើម្បីជួយស្រោចស្រង់មនុស្សលោកឲ្យរួចផុតពីការកើតនិងស្លាប់ ។ មួយទៀត ក្នុងរជ្ជកាលព្រះអង្គនេះ គេសង្កេតឃើញពាក្យថ្មីកថា "កម្ពុជៈ" ។ សិលាចារឹកប្រាសាទព្រះគោកាលពី ព.ស. ៨៧៤ បានប្រើពាក្យថា "កម្ពុជទេស"ឬ"កម្ពុជទេស" មុនដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរ ព្រោះពីអតីតកាល មិនដែលឃើញមានចារឹកថា "កម្ពុជៈ" នេះទេ ហេតុនេះហើយបានជាក្នុងកាលតមក យើងហៅប្រទេសយើងថា "កម្ពុជា" ។

ព្រះបាទយសោវរ្ម័នទី១ ជាព្រះរាជបុត្រទ្រង់ឡើងសោយរាជ្យពី ព.ស.១៤៣៤ (គ.ស.៨៨៩) ហើយទ្រង់លើកព្រះរាជធានីទៅនៅទីក្រុងឈ្មោះ "យសោធរបុរៈ" គឺអង្គរធំសព្វថ្ងៃនេះ ។ ព្រះរាជាអង្គនេះ ទ្រង់ជាពុទ្ធសាសនិកមួយអង្គដ៏ប្រសើរ ទ្រង់បានទទួលស្គាល់ពុទ្ធសាសនាមហាយានជាផ្លូវការមុនដំបូងបង្អស់ក្នុងពង្សវង្សប្រទេសខ្មែរ តែទ្រង់ប្រោសប្រាណីសាសនាព្រាហ្មណ៍ដូចពុទ្ធសាសនាដែរ ។ ក្នុងកាលនោះពុទ្ធសាសនានឹងសាសនាព្រាហ្មណ៍មិនមានការប៉ះទង្គិចគ្នាទេ ។ ទ្រង់បានតសាងព្រះវិហារស្រមៃ ព្រះឥស្វរាស្រម ឧដ្ឋរសោតតាស្រម (អាស្រមថ្វាយព្រះសុគត) ច្រើនកន្លែង ។ សិលាចារឹកនៅប្រាសាទទេពប្រណាំម្យថ្លែងពីការកសាងសៅតតាស្រមនេះ ។ សាសនាពីរនេះមានសិទ្ធិសេរីភាពស្មើគ្នា ។ រជ្ជកាលតមក ព្រះរាជាច្រើនអង្គគាំទ្រសាសនាព្រាហ្មណ៍។

ព្រះបាទរាជេន្ទ្រវរ្ម័ន (រាជេន្ទ្រវរ្ម័នទី២) ទ្រង់ឡើងសោយរាជ្យក្នុង ព.ស.១៤៨៧ (គ.ស.៩៤៤) ទ្រង់គាំទ្រសាសនាព្រាហ្មណ៍ គោរពព្រះឥស្វរ តែទ្រង់ប្រោសប្រាណីពុទ្ធសាសនាដែរ ហើយការកសាងវត្តអារាមខាងពុទ្ធសាសនាមានកាន់តែច្រើនឡើង។ ហើយគាំទ្រតែសាសនៅ ចូលមកជិតព្រះរាជធានីថ្មមទៀត ។ ក្នុងរជ្ជកាលព្រះអង្គ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះកវីន្ទ្រារិមថនៈជាទេវានប្រិយៈ ចេះវិជ្ជាស្ថាបត្យកម្មដូច

អគ្គវិស្វកម៌ទៅបុត្រ ហើយជាមហាពុទ្ធសាសនិកមួយរូប ថ្កានកសាង
វិហារ ៣ កន្លែងនៅថ្កតដំ មួយថ្វាយព្រះសម្មាសម្ពុទ្ធ. មួយថ្វាយព្រះ
វជ្រថុណ៌ មួយទៀតថ្វាយព្រះនាងប្រាជ្ញាបារមីតា ។ ព្រះរាជអគ្គ
នេះ ទ្រង់មិនតាន់ពុទ្ធសាសនាពិតមែន តែទ្រង់តែងតាំងលោកតវ័ន្ទ្រា -
រមថនៈជាពុទ្ធសាសនិកជាប្រធានវជ្ជមន្ត្រី ហើយទ្រង់សរសើរជាពិសេស
ព្រមទាំងទ្រង់រៀបរាប់ពីបដិមាករ.ជលទ្រង់ថ្កានប្រថានថែមទៀតគឺ ១-
ព្រះពុទ្ធរូបព្រះពុទ្ធដ៏នស្រីនៅជយន្តប្រទេស (គ.ស.៩៤៦) ២- ព្រះពុទ្ធរូប
ព្រះលោកនាថនីឥរូបនាងទៅពីរអគ្គនៅកុដីស្វរៈ, ៣- ព្រះពុទ្ធបដិមាករ
ព្រះជនស្រីនីឥរូបទៀវទៅមួយ (ប្រាជ្ញាបារមីតា?) ព្រមទាំងរូបវជ្រថុណ៌
នៅប្រាសាទមេបុណ្យ (គ.ស. ៩៦៣) ក្នុងពាក្យនេះ សើរតាពក្នុងការតាន់
សាសនាខ្លាយណាស់ នេះហើយជាហេតុមួយនាំសាសនាព្រាហ្មណ៍លិច
ព្រះឥស្សរ នីឥពុទ្ធសាសនាឲ្យរលាយចូលគ្នាជាប់រហូតមកដល់ឥឡូវនេះ ។

ព្រះបាទជ័យវរ្ម័នទី៩ ជាព្រ ះរាជបុត្រព្រះបាទជេន្ទ្រវរ្ម័ន ឡើង
សោយរាជ្យក្នុងគ.ស.១៥១១(គ.ស.៩៦៨) ។ ក្នុងរាជ្យព្រះអង្គ មាន
ព្រឹត្តិការណ៍ដូចរាជ្យព្រះវរបិតាដែរ គឺទ្រង់តាន់សាសនាព្រាហ្មណ៍ដូច
ព្រះវរបិតា តែព្រះរាជត្រកូលនីឥមន្ត្រីជាន់ខ្ពស់តាន់ពុទ្ធសាសនា ។
ទ្រង់តែងតាំងកវីបណ្ឌិតជាប្រធានវជ្ជមន្ត្រី ដូចព្រះវរបិតាដែលតែងតាំង

តាំងត្រាំរមឋនៈជាប្រធានរដ្ឋមន្ត្រីដូច្នោះដែរ ។ សិលាចារឹកនៅវត្តស្រី-សន្ធរថែងថា កិរ្តិបណ្ឌិតជាពុទ្ធសាសនិកដ៏ម៉ុះម៉ុត ដូចសេចក្តីក្នុងសិលា-ចារឹកនេះថា ៖

"នមស្ការព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ព្រះពុទ្ធមានកាយ ៣ គឺ ធម្មិកាយ សម្ភោគកាយ និម្មិណកាយ (គាថាទី ១ ទៅទី ៤) សរសើរបារមីព្រះបាទជ័យវរ្ម័នទី ៤ ពីឆ្នាំ ៨៤៩ សក: គឺគ.ស. ៩៧៧ (គាថាទី ៤ ទៅទី ១៨) សរសើរកិរ្តិបណ្ឌិតដោយចំពោះការកែប្រែពុទ្ធសាសនាជារបៀបថ្មី ។ តទៅ មានន័យាយអំពីបដិសង្ខរណ៍ពុទ្ធ-រូបច្រើនអង្គ អំពីអាជ្ញាព្រះរាជាចំពោះការប្រតិបត្តិពុទ្ធសាសនា ។ល។"

ក្នុងសិលាចារឹកនេះ ពួកអ្នកប្រាជ្ញយល់ថា "មានការលាយឡំសាសនាព្រាហ្មណ៍និងពុទ្ធសាសនាចូលគ្នា មុនដំបូងបង្អស់នៅកន្លែងឥន្ទ្រវិហារប្រទេសខ្មែរ" ។ សិលាចារឹកមួយទៀតៈនៅភូមិបន្ទាយនាង និយាយពីមន្ត្រីឈ្មោះត្រៃកុវនវជ្រៈសាងបដិមាករ "ប្រាជ្ញាបារមីតា ឬ កគវតី" គឺអង្គមាតានៃព្រះពុទ្ធពីគ.ស. ៩៨១ ព្រមទាំងវត្ថុនានាដែលថ្វាយដល់ព្រះដគ-ទ័ស្វរៈទៀតផង ។ មន្ត្រីម្នាក់ទៀតឈ្មោះសោមវជ្រៈ ត្រូវជាបងថ្លៃនៃមន្ត្រីត្រៃកុវនវជ្រៈ បានថ្វាយបដិមាកររលោកកេស្វរៈកង គ.ស.៩៨២ ។ សិលាចារឹកនៅប្រាសាទប្រជាតថែងពីព្រះរត្នត្រ័យ គឺព្រះស្រីយនៈ (ព្រះ

ពុម្ព) ព្រះធម៌នឹងព្រះសង្ឃ ។

ព្រះចាន់សូរ្យវ៉ង្សទី ១ ទ្រង់ឡើងសោយរាជ្យក្នុង ព.ស. ១៥៤៥ (គ.ស. ១០០២) ។ ព្រះអង្គជាពុទ្ធសាសនិកជនមួយអង្គដ៏ប្រសើរវៃក្នុងសម័យមហានគរ មិនមែនគ្រាន់តែជ្រះថ្លាប៉ុណ្ណោះទេ ទ្រង់បានជាព្រះរាជសាសនូបត្ថម្ភក៍ដ៏ប្រសើរទៀតផង តែសង្ឃរបណ្ដិតដែលជាប្រធានមន្ត្រីព្រះអង្គគាន់សាសនាព្រាហ្មណ៍លទ្ធិព្រះឥសូរ ។ ព្រះរាជាអង្គនេះ ទំនងជាព្រះរាជវង្សានុវង្សព្រះវរបិតា មានកំណាត់ទង មកពីព្រះរាជា នាក្រុងតាំព្រលិង្គៈ (តាម្ពលិង្គៈ) នៅជ្រោយម៉ាឡាយូ ដែលកាលនោះនៅក្នុងអំណាចអាណាចក្រស្រីវិជយ (កោះសុមាត្រា) ខាងព្រះវរមាតាជាប់ទាក់ទងមកពីព្រះរាជវង្សសប្ដេវៃកុល ពីព្រះនាងប្រាណាជាអគ្គមហេសីនៃព្រះបាទរាជេន្ទ្រវ៉ង្សទី ២ ជាព្រះនាយិកានៃការិយាល័យរបស់ព្រះបាទជយវ៉ង្សទី ៥ ផង ។ ពុទ្ធសាសនាលទ្ធិមហាយាន បានផ្សាយឥទ្ធិពលចូលមកប្រទេសខ្មែរភ្ជាប់ពាក់ព័ន្ធក្នុងរាជ្យព្រះអង្គនេះ តម្លើជាកាក្ដី គ្រូបាអាចារ្យក្ដី សុទ្ធសឹងតែចេញមកពីតាំព្រលិង្គៈដែលជាមជ្ឈមណ្ឌលផ្សាយពុទ្ធសាសនា បានជាទីឋាននេះមានសមញ្ញាថា "ស្រីធម៌រាជនគរ ក្រុងនៃស្ដេចធម៌ដ៏មានសិរី" (នគរស្រីធម្មរាជនៅភាគខាងក្រោមប្រទេសថៃសព្វថ្ងៃនេះ) ។

ព្រះញាណវរិយៈ វ៉ាំង-សាំ៉ុ រៀបរៀង

(ភាគ ២)

មួយទៀត ភាសាលីនេះ នឹងហៅថា ពុទ្ធភាសា ក៏បាន ព្រោះជាភាសាបច្ចេកទេសមួយ ក្នុងចំណោមមគធភាសា ហើយកើតឡើងដោយការបន្ថែមរបស់ព្រះពុទ្ធ ។ តាលខ្ញុំ (អ្នកសរសេរឯកសារនេះ) ពេលបំពេញបេសកកម្មក្នុងផ្នែកសង្ឃយនៅប្រទេសភូមា ខ្ញុំបានឮជេវាក់ចាព្រះសង្ឃ-តិការៈខ្លះថា យើងបានស្គាល់គ្នាជាបដល់ទុកចិត្តស្និទ្ធស្នាល ដោយសារយើងបានចេះពុទ្ធភាសា ដូចអ្នកស្គាល់ដំណែ្សពេទ្យ ដោយសារចេះភាសាពេទ្យ ។

សព្វថ្ងៃអ្នកស្រុកភូមាក្តី ឥណ្ឌាក្តី តាលប្រាថ្នាឲ្យយល់អត្ថរសដ៏ជ្រាលជ្រៅនៃបាលីពុទ្ធភាសា គេតែងទៅទៅសិក្សាអប់រំ នៅប្រទេសស៊ីរីលង្កា ដូចព្រះពោធិបុត្រស្តេចខែ្មរពីសម័យបុរាណដែរ គេដឿថាប្រទេសនេះ បានសិក្សាហាត់ប្រឿនក្នុងអត្ថបទបាលីពុទ្ធភាសា តមកអំពីអ្នកប្រាជ្ញទាំងឡាយ មានព្រះមហាមហិទ្ធត្ថេរអគ្គអរហន្តជាដើមដែលជាអ្នកស្រុកមគធៈ (ដម្ពូទ្វីប) ហើយបានសង្ឃយនាធម្មវិន័យរក្សាទុកដរាប

មក ។ សូម្បីប្រទេសភូមា ដែលបានចាកព្រះត្រៃបិដកមួយចប់ ប៉ុះ
ក្តីសិលាតែវំចន្លួន ៧២៩ ផ្ទាំង នៅដើមពុទ្ធសតវត្សទី ២៥ នេះ ក៏ដោយ
សារបានចម្លងគម្ពីរស្នឹកតែតាប្រទេសសីរីលង្កាដែរ ។

ព្រឹត្តិការណ៍វិបត្តិពុទ្ធសាសនានៅកម្ពុជរដ្ឋ

ខ្ញុំបានពណ៌នាមកហើយថា វិបត្តិពុទ្ធសាសនាបានមកចាក់ឫស
ចាក់គល់ក្នុងប្រទេសខ្មែរតាំងពីសម័យនគរភ្នំ(ហ្វូណន) ឬមុននេះទៀត
តែវិបត្តិនេះតែងមានវិបត្តិសាសនាព្រាហ្មណ៍ ដែលមានមកជាយូរ
ដែរហើយនោះ ជាគូប្រឆាំងឬជាឧបសគ្គ ព្រោះក្នុងរជ្ជកាលតាមក មាន
ព្រះមហាក្សត្រច្រើនព្រះអង្គ ឬមន្ត្រីធំៗ ជាព្រាហ្មណិក (កាន់សាសនា
ព្រាហ្មណ៍)ហើយព្រះអង្គខ្លះទៀត បានតាំងព្រះអង្គជាគូប្រឆាំងឬជាសត្រូវ
នឹងវិបត្តិមានពុទ្ធសាសនាថែមទៀតមានប្រកាខ្លះថា ក្នុងកាលខ្លះព្រះ
ពុទ្ធសាសនាសាបសូន្យ ពីប្រទេសខ្មែរទៅហើយក៏មាន ដូចក្នុងរជ្ជកាល
តមកពីរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ សម័យអង្គរ មានមហាក្សត្រអង្គខ្លះ
ជាព្រាហ្មណិក លើកតម្កើងវិបត្តិព្រាហ្មណ៍ បំបាត់វិបត្តិពុទ្ធសាសនា
ដូចមានវិបត្តិមានការចារបស់ព្រាហ្មណ៍ នៅប្រាសាទបាយ័នបឹតទៅ
មកដល់សព្វថ្ងៃជាឧទាហរណ៍ស្រាប់ ។

ដំណើរខាងលើនេះ ធ្វើឲ្យយើងរឹតតែជ្រះថ្លាចំពោះគុណានុភាព

ព្រះពុទ្ធសាសនាថែមឡើងទៀត ព្រោះព្រះពុទ្ធសាសនាជាសាសនាសុតសុភាព ទោះក្នុងរដ្ឋកាលណាក៏ដោយ តាំងពីសម័យនគរភ្នំដល់ផុតសម័យអង្គរព្រះមហាក្សត្រជាពុទ្ធសាសនិកតាំងឡាយ មិនដែលតាំងព្រះអង្គជាគូសត្រូវនឹងសាសនាដទៃដល់ម្ដងទេ បើទាំងណាស់ត្រាន់តែមិនគោរពរាប់អានថ្វាយព្រះអង្គ ជាសាសន្ទូចតូម្ភក៏ប៉ុណ្ណោះ ទាហរណ៍ដូចប្រាសាទនគរវត្ត ដែលជាប់ឆ្ងាត់នៅក្នុងកណ្ដាប់ព្រះហស្តព្រះមហាក្សត្រជាពុទ្ធសាសនិក ឃើញគង់រូបនៅតាមដើមគ្រប់គ្រឿងរចនាអ្វីៗទាំងអស់ៗរដោយវប្បធម៌ពុទ្ធសាសនាសុតសុភាពបែបនេះហើយ មានការផ្ទុយផ្ទាយទៅគាន់រវៃនេយ្យសត្វ បើកសិទ្ធិឲ្យប្រើវិចារណញ្ញាណដេញដោលនឹងឥតមានការបង្ខិតបង្ខំ ក៏ទៅជាមានអានុភាពអាចចាក់ឫសដុះជាលក្ខន្តសន្ដានប្រជាជនជាសាសនេញទាំងដែន ទោះបីមានព្រះមហាក្សត្រឬមន្ត្រីធំៗជាគូសត្រូវយ៉ាងណាក៏ដោយ បើទាំងណាស់ត្រាន់តែប្រជាជនពុំអាចចេញមុខប្រកាសខ្លួនថាជាពុទ្ធសាសនិកប៉ុណ្ណោះ ទាហរណ៍ដូចរដ្ឋបុរសសំខាន់ៗទាំងឡាយរបស់ប្រទេសឥណ្ឌា មានលោកគន្ធី លោកវ៉ាដ្រែប្រាសាទនឹងលោកនេរូជាដើម បើពុំកជាលោកទាំងនេះ ពុំបានប្រកាសខ្លួនជាពុទ្ធសាសនិក ក៏អាចយើញថា វប្បធម៌ទាងពុទ្ធសាសនាចាក់ឫសដ្រួតដ្រាបយ៉ាងដ្រាលដ្រៅ ក្នុងសន្ដានចស់លោកទាំងនេះស្រេច

ទៅហើយ ព្រោះក្នុងសម័យមុនព្រះពុទ្ធគ្រាស់គ្មាននរណាអាចពោលធម៌
អាថប្រែកបដោយហេតុផល ហើយមានសន្ដានស្រឡាញ់កាតរកាពន្ធឹង
សមកាពតាមរបបលទ្ធិប្រជាធិបតេយ្យដូច្នេះទេ ។ ន្ធឹងថាព្រះពុទ្ធជា
មូលន្ធិន្ធាការទៅខាងលទ្ធិនេះក៏បាន ព្រោះព្រះអង្គប្រកបដោយព្រះមហា
ករុណា មានព្រះអធ្យាស្រ័យដ៏ធំទូលាយគ្មានទីបំផុត ។ ព្រះពុទ្ធសា-
សនាកើតក្រោយសាសនាព្រាហ្មណ៍ តែមានវប្បធម៌ខាងទស្សនវិជ្ជា
ប្រកបដោយអត្ថរសដ៏ជ្រាលជ្រៅក្រៃលែង ផុតវិស័យលទ្ធិព្រាហ្មណ៍ ។
សាសនាគ្រិស្ដន្ធឹងសាសនាមហាម៉ត តោះបើមានដើមកំណើតនៅទ្វីបអាស៊ី
ដូចព្រះពុទ្ធសាសនាដែរ ហើយកើតក្រោយព្រះពុទ្ធសាសនាផង កំមិន
ឃើញមានអត្ថរសណា ពិសេសជាងព្រះពុទ្ធសាសនាឡើយ ឃើញ
គ្រាន់បើ តែត្រង់បបួលន្ធឹងបង្គំគេឲ្យដឿព្រះអាទិទេព ដូចពួកព្រាហ្មណ៍
បបួលគេឲ្យដឿគោរពកោតខ្លាចព្រះព្រហ្ម ព្រះឥសូរន្ធឹងព្រះនារាយន៍ ។
ហេតុនេះ ឃើញថា វប្បធម៌ពុទ្ធសាសនាជាកំពូលខាងទស្សនវិជ្ជានៅ
ទ្វីបអាស៊ី ។ ចំណែកទ្វីបដទៃដែលទើបតែចម្លងយកវប្បធម៌ទៅពីទ្វីប
អាស៊ីក្រោយពុទ្ធកាល ដូចទ្វីបអាមេរិកបានទទួលវប្បធម៌ពីទ្វីបអ៊ឺរ៉ុបនោះ
មិនបានចាត់ជាបញ្ហាត្រូវដោះស្រាយក្នុងទីនេះទេ ។ រួមសេចក្ដីទៅ
អាចឃើញថា ព្រះពុទ្ធជាកំពូលអ្នកប្រាជ្ញក្នុងការរកហេតុផល ពាំង

ខាងរូបសាស្ត្រ ចាំងចិត្តសាស្ត្រ ។

វិប្បធម៌ពុទ្ធសាសនាសម័យក្រោយអង្គរ

ដោយវប្បធម៌ពុទ្ធសាសនាបានចាក់ឫសក្នុងសន្តានជនជាតិខ្មែរតាំងពីបុរាណកាលមក លុះដល់សម័យអង្គរ គឺរយៈពេលពីពុទ្ធសតវត្សទី ៦ ដល់ទី ១៥នេះ ទោះមានហេតុការណ៍ចលាចលជាញឹកញាយ ដោយពួកជនបរទេសចូលលុកលុយស្រុកពីបជាន់ បំផ្លិចបំផ្លាញជីវិត និងកោតសម្បត្តិជាដើមយ៉ាងណា ក៏ប្រជាជនខ្មែរនៅតែព្យាយាមអោបពាំងក្រជាបត្រដួសនូវព្រះពុទ្ធសាសនាមិនចុះបង់សោះឡើយ គឺនៅតែនាំគ្នាបួសជាកិក្ខុសាមណេរ ថ្វាយខ្លួនជាឧបាសក ឧបាសិកានិងសាងវិត្តអារាមសម្រាប់ព្រះសង្ឃគ្រប់ឃុំខេត្តនៃព្រះរាជអាណាចក្រ ។ សូម្បីតែខ្លួនណាឆ្លាប់ជាវិត្តអារាមរបស់សាសនាព្រាហ្មណ៍ ក៏បែរទៅជារបស់ព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ។ ម្ល៉ោះហើយវប្បធម៌ព្រាហ្មណ៍ ដោយគ្មានអ្នកគោរពរាប់អានក៏សាបសូន្យអស់ទៅ នៅសល់តែគ្រឿងរបាននិងការទំនៀមទម្លាប់បន្តិចបន្តួចក្នុងពិធីខ្លះ មានព្រះរាជពិធីអភិសេកជាដើមប៉ុណ្ណោះ ។ អាស្រ័យជនជាតិខ្មែរភាគច្រើនជាពុទ្ធសាសនិក និងមានព្រះមហាក្សត្រជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទើបប្រទេសខ្មែរ ក៏ជាប្រទេសពុទ្ធសាសនិកពេញទី ហើយខ្លួលស្គាល់តាមរដ្ឋធម្មនុញ្ញនូវព្រះពុទ្ធសាសនា

ថាជាសាសនារបស់រដ្ឋថែមទៀត ។

ក្នុងសម័យបច្ចុប្បន្ន នាពុទ្ធសតវត្សទី ២៥ នេះ ប្រទេសខ្មែរមានភ័ព្វសំណាងលើសលុបជាងសតវត្សមុនៗ ដែលមានបន្ទាប់មកពីសម័យអង្គរ ព្រោះបានឯកពាជ្យមានអធិបតេយ្យបរិបូណ៌ពាំងពាងក្នុងពាំងពាងក្រៅ ហើយមានទីបណ្តុះវប្បធម៌ពាងពុទ្ធសាសនា គឺកើតមានសាលារៀនធម្មវិន័យ សាលាពុទ្ធិកឧបមសិក្សា សាលាពុទ្ធិកវិទ្យាល័យ សាលាពុទ្ធិកមហាវិទ្យាល័យ ពុទ្ធសាសនបណ្ឌិត្យ ក្រុមដំនុំព្រះត្រៃបិដក សមាគមមិត្តពុទ្ធិកវិទ្យាល័យនិងពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋត្រមពាំងមានព្រះសង្ឃបានបំពេញតួនាទីធុរៈ រៀនប្រឡងជាប់ថ្នាក់ជាអ្នកធម្មវិទូ ជាមហាបធានវិជ្ជា និងជាមហាទត្តវិជ្ជាច្រើនពាន់រូប ហើយបញ្ជូនព្រះមហាទត្តវិជ្ជាច្រើនរូបឲ្យទៅសិក្សាអប់រំបំពេញវិជ្ជា ក្នុងប្រទេសផ្សេងៗមានប្រទេសឥណ្ឌានិងកូមាជាដើម ។

ដំណើរការពាងលើនេះនាំឲ្យប្រទេសខ្មែរមានកម្លាំងល្មមពេញចិត្តធ្វើបុណ្យសម្ពោធលើកស្ទួយព្រះពុទ្ធសាសនា ដែលមានអាយុគំរប់២៥០០ វស្សានេះផង និងនាំឲ្យមានការសង្ឃឹមថា វប្បធម៌ពុទ្ធសាសនាពាំងពាងទ្រឹស្តី ពាំងពាងប្រតិបត្តិ នឹងតែតែចាក់ឫសជុះលូតលាស់ចំរើនធំឲ្លួយឲ្លួទៅកងពិភពលោកផង ។

វិប្បដិបត្តិពុទ្ធសាសនាខាងទ្រឹស្តី

ជនជាតិខ្មែរ ជាប់យល់ឃើញតាមព្រះពុទ្ធសាសនាថា ការថ្វាយ
ចង្ហាន់ជាបរិសុទ្ធិនឹងមិនបរិសុទ្ធិ តើតមកអំពីខ្លួន មានខ្លួនជាទីសម្គាល់ មិន
មែនតើតដោយ ស្មាដៃទេវតាណាឡើយ ។ សូម្បីព្រះពុទ្ធជាគ្រូដើម ក៏
បានទទួលការថ្វាយ បរិសុទ្ធិ ព្រោះអំពើដែលជាសំណាងរបស់ព្រះអង្គ
ដែរ ។ កាលទ្រង់បំពេញពុទ្ធកិច្ច ទ្រង់គ្រាន់តែប្រាប់ផ្លូវនៃសេចក្តីថ្វាយ
បរិសុទ្ធិ ទ្រង់មិនអាចប្រទានសេចក្តីថ្វាយបរិសុទ្ធិដល់គេដែលមិនធ្វើដំណើរ
តាមផ្លូវនោះផងបានទេ ។ កាលមានវិប្បដិបត្តិខាងទ្រឹស្តីដូច្នេះ ទោះជន
ជាតិខ្មែរធ្វើការអ្វីដែលពាក់ព័ន្ធនឹងពិធីបន់ស្រន់ ក៏ធ្វើគ្រាន់តែជាទំនៀម
ទម្លាប់ជាប់តមកពីព្រាហ្មណសម័យប៉ុណ្ណោះ មិនមែនដឿឃា ទោះបីគ្មាន
អំពើសមហេតុផល ក៏អាចថ្វាយបរិសុទ្ធបានទេ ។ ទានសីលនឹងការនា
ចាត់ជាអំពើដែលសមហេតុផលនៃសេចក្តីថ្វាយបរិសុទ្ធិ ។ អ្នកប្រាជ្ញ
ពាំនឹងឲ្យមានព្រះពុទ្ធជាដើម ដែលបានទទួលសេចក្តីថ្វាយបរិសុទ្ធិ ក៏
ព្រោះតែអំពើនេះពាំនឹងអស់ ។ ពុទ្ធការកធម៌ ១០ ប្រការមានទានជាដើម
មានឧបេក្ខាជាអវសាន ដែលហៅថា ទសបារមី ក៏សង្គ្រោះចូលក្នុងអំពើ
នេះដែរ ។

វិប្បធម៌ពុទ្ធសាសនាខាងការប្រតិបត្តិ

ដោយសារទ្រឹស្តីមានដើមដូចបានពោលមកហើយនេះ ជនជាតិខ្មែរ
កំពានសទ្ធាជ្រះថ្លា ក្នុងទានសីលនិងភាវនាផង ក្នុងបុគ្គលដែលជាអ្នកទាន
សីលភាវនាផង ។ ដោយសារសទ្ធាជ្រះថ្លានេះ ទើបទំពេញទានសីល
និងភាវនាធ្វើខ្លួនឲ្យទៅជាអ្នកទានអ្នកសីលនិងជាអ្នកភាវនា ។ ក៏រណីយ
តិច្ចកម្មជីវិតរបស់ជនជាតិខ្មែរ តែងមានអំពើគឺទានសីលនិងភាវនានេះជាទី
ជ្រះថ្លានិងជាទីតក់ក្តៅដរាបអស់អាយុសង្ខារ ព្រោះយើញថាមានតែអំពើ
នេះទេ ដែលអាចសាងខ្លួនឲ្យទៅជាមនុស្សល្អ ត្រូវតាមព្រះពុទ្ធសាសនា
ហើយសមគួរដល់ខ្លួនដែលកើតហើយត្រូវចាស់ស្លាប់ ។

អ្នកទាន

អ្នកទានជាតិខ្មែរ តែងធ្វើទានដោយអនុគ្រោះផង ដោយបូជាផង
ជនខ្លះទាត្រូវគេធ្វើទានដោយអនុគ្រោះ, ជនមិនខ្លះទាត្រូវតែមានគុណធម៌
ល្អ គួរគេធ្វើទានដោយបូជា ប៉ែខ្លះទាត្រូវផង មានគុណធម៌ល្អផង គួរគេធ្វើ
ទានដោយអនុគ្រោះផង ដោយបូជាផង ។ ដូច្នេះដើម្បីឲ្យបានផលានិសង្ស
ច្រើនសមគួរដល់ទានដែលមានគុណអាចកំចាត់មច្ឆរិយៈ ចិត្តចង្អៀតហើយ
ធ្វើចិត្តឲ្យទូលាយ ជនជាតិខ្មែរទើបនិយមធ្វើទានដល់ពួកបព្វជិតក្នុងពុទ្ធ

សាសនា ជាដំណាងពួកជនឯទៀត ដរាបដល់ក្មេងតូចមានភាពជាកំមាន មុនពី
ឃើញថាពួកនេះតែងមានការខ្វះខាតគួរអនុគ្រោះផង មានគុណគួរបូជាផង
ការធ្វើទានដល់ពួកនេះ ជាមធ្យោបាយពន្លឹកសេចក្តីសុខចំរើនឲ្យកើតទៅ
ទៅដល់សត្វសត្វឥតរើសមុខ ព្រោះពួកនេះជាអ្នកបំរើពុទ្ធសាសនា ។
រដាយថ្នាក់មានប្រពៃណីធ្វើទានតាំងពីបុរាណកាល ទោះបីស្រុកទេសធ្លាក់
ក្នុងវិបត្តិធំៗ ១ត្រង់អ្នកប្រាជ្ញ១ត្រង់គម្ពីរក្សួនខ្លាត ដូចកាលសម័យ២ុះមានសម័យ
ក្រែលែងផ្លែកជាដើម ជនជាតិខ្មែរក៏នៅតែរក្សាប្រពៃណីធ្វើទានជារាប ។
បុណ្យធ្នូរ៉ាលុកចេតិយនិមន្តព្រះសង្ឃស្រែង់ទឹលចូលឆ្នាំ បុណ្យចូលវស្សា
បុណ្យកុំបិណ្ឌ បុណ្យចេញវស្សា បុណ្យមាឃបូជា នឹងបុណ្យពិសាខបូជា
ជាដើម សុទ្ធតែមានការធ្វើសក្ការៈគោរពរាប់អានបូជាព្រះរតនត្រ័យដោយ
អាមិសបូជានឹងបដិបត្តិបូជាជាប្រពៃណីពាំងអស់ ។ ហេតុនេះបានជា
វិប្បរិធម៌ព្រះពុទ្ធសាសនា មិនរលើងឆ្ងាយឡើយ ទោះប្រទេសនេះមានការកំន្តប្រែចលាចលឬមានជាតិសាសន៍ដទៃ
នាំសាសនាជាគូប្រឆាំងមកផ្សាយយ៉ាំងណាក៏ដោយ ។

អ្នកសីល

អ្នកសីលជាតិខ្មែរ ដែលមានប្រាជ្ញាតែងរក្សាសីលមានទិដ្ឋសីលជាដើម
រដើម្បីវៀរចាកការបៀតបៀនជនដទៃផង ដើម្បីផ្តាច់កន្ទុលភក្រែកដោយ

គាយរ៉ាចាដែលជាហេតុក្តៅក្រហាយចិត្តផង ដើម្បីរម្ងាប់ពៀរវេរ នឹង
សាងសេចក្តីកក់ក្តៅខុកចិត្តគ្នាក្នុងលោកផង ព្រោះជនទ្រុស្តសីលគ្មាន
អភយទានទេ ប្រៃសេចក្តីថាជាអ្នកឲ្យតែសេចក្តីភយបារម្ភ ឲ្យតែសេចក្តី
មិនខុកចិត្តដល់គ្នានឹងគ្នា ។ អ្នកសីលមិនអាចដើរទៅយាយបំបាត់ទ្រព្យសម្ប
ទ្រព្យពជគារ ទ្រព្យឯកជន ឬទទួលសំណូកយកទៅចិញ្ចឹមខ្លួន ចិញ្ចឹម
គ្រួសារ ឬធ្វើបុណ្យទានអ្វី ។ ឡើយ ។ ហេតុនេះអ្នកសីលអាចជាទី
កក់ក្តៅខុកចិត្តនឹងជាទីពឹងរបស់រដ្ឋទៀតផង ។ រដ្ឋបើមានអ្នកសីលជា
ពលរដ្ឋច្រើននឹងពុំអាចធ្លាក់ខ្លួនទៅជាចាវព្រៃរបស់រដ្ឋណាដោយងាយ។
ទេ ។ ដូច្នេះ ទើបរដ្ឋខ្លះខំអប់រំពលរដ្ឋឲ្យមានសីលធម៌តាំងពីក្មេង ។
រហូតដល់ទៅបំបាត់មិនឲ្យចិតស្រោកក្នុងស្រុក នឹងមិនឲ្យស្រោកកៀនចូល
ស្រុកទៀតផង ដូចគ្រួសារដែលមានសីលធម៌ល្អមិនចង់ឲ្យមានលៃង្ស៊ីស
សងឡើងផ្ទះ ព្រោះខ្លាចមានការខូចអាក្រក់ដល់កូនចៅ ។ អ្នកប្រាជ្ញ
ពាំងឲ្យតែងយើញអំពើទ្រុស្តសីល ឬលៃង្ស៊ីសង ថាជាភយរបស់
លោកសន្ទាំស ទើបមានហ៊ានតប្រៀបឡើមខ្លាចអំពើពាំងនេះ ដូចគេខ្លើម
ខ្លាចពស់អសិរពិសដែលពេនត្រាំក្នុងលាមក ។ កាលបើលោកសន្ទាំស
មានសីលធម៌ល្អ លោកសន្ទាំសនឹងមិនមានការបៀតបៀនគ្នា ។ អា-
ស្រយ័ការមិនបៀតបៀន សេចក្តីសុខក៏មានឡើង សមនឹងព្រះពុទ្ធទានថា

អព្យាបជ្ឈំ សុខំ លោកេ ការមិនបៀតបៀនគ្នាជាសុខក្នុងលោក ។
ជនជាតិខ្មែរឆ្ងាប់ជាអ្នកមានសីលធម៌បែបនេះមកតាំងពីបុរាណកាល តែ
មិនមានចំនួនច្រើនជាងមនុស្សទ្រុស្តសីលទេ ។ តទៀតរណាស់តែរដ្ឋ
រកមធ្យោបាយអប់រំពលរដ្ឋ ឲ្យទៅជាអ្នកសីលមានភាគច្រើនឡើងដើម្បីជា
ទីពឹងនៃរដ្ឋ ។

អ្នកភាវនា

អ្នកភាវនាជាតិខ្មែរ តែងមានការចំរើនភាវនា ទើងការនមស្ការ(ថ្វាយ
បង្គំព្រះ) ជាប្រពៃណីតាំងពីបុរាណកាល ។ ក្រៅពីចំរើនភាវនាក្នុង
ឫស្ថានីយដ្ឋានមានព្រះបដិមាយរៈ(ព្រះវិហារ) ជាដើម តែងភាវនានៅទី
ស្ងាត់ដើទើងនោះគេហៅស្ថានដែលហៅថា ធ្លើវត្តព្រឹកទើងវត្តល្ងាច ។ នៅក្បែរ
ព្រះសង្ឃ ទើងផ្ទះទាំងសកៈតែងមានតុតាំងដាក់ព្រះពុទ្ធរូបព្រមទាំងគ្រឿង
សក្ការៈបូជាដែលហៅថា គ្រែព្រះធម៌ ជាទីគោរពនមស្ការទើងជាទីចំរើន
ភាវនា ។ ឯការចំរើនភាវនានោះ គេតែងមានការចំរើនចតុភាវគ្គ-
កម្មដ្ឋានជាគោលគឺ

ក)ចំរើនភាវនារំលឹកពុទ្ធគុណ ធម្មគុណ ទើងសង្ឃគុណ ដើម្បី
បណ្តុះចិត្តសទ្ធាជ្រះថ្លាក្នុងព្រះគុណទាំងនោះ មិនឲ្យចិត្តរញ្ជាតយ ឬ
វិសាយចេញពីកុសលធម៌ ។

๑) ចំរើនព្រហ្មវិហារតើតាវនាផ្សាយមេត្តាដល់សត្វខ្លួនៅ ដោយតាំងចិត្តឲ្យបានតប់ប្រមែះតែនូវសេចក្តីសុខចំរើនគ្រប់គ្នា, ផ្សាយតុណ្ហដោយប្រាថ្នាឲ្យបានរួចរង់ចាកទុក្ខគ្រប់ប្រការ ផ្សាយមុទិតាដោយប្រាថ្នាមិនឲ្យប្រាសព្រាត់ចាកសេចក្តីសុខ ដែលបានហើយតាំងអស់គ្នា, ផ្សាយឧបេក្ខាដោយគិតថាសត្វតាំងអស់គ្នាតែងមានកម្មជារបស់ខ្លួន គឺថាបើខ្លួនធ្វើល្អនឹងទទួលផលល្អ ធ្វើអាក្រក់នឹងទទួលផលអាក្រក់ ដើម្បីកំចាត់បង់ចិត្តព្យាបាទ ចិត្តវិប្បដិសារីនឹងចិត្តឫស្សាឈ្នានីសគ្នាជាដើម ។

๔) ចំរើនអសុភកាវនាពិចារណាពាងតាយដែលជាទីប្រជុំធាតុ ๔ ឲ្យមើញថាពោរពេញដោយអាការៈស្មោកគ្រោកមិនស្អាត មានសត់រោមក្រចក ធ្មេញ សែ្បកជាដើម ។

๕) ចំរើនមរណសតិកាវនា នឹកពិចារណាសេចក្តីស្លាប់ដែលត្រូវមានដល់ខ្លួនដោយខៀងខាត់ តែមិនច្បាស់ជាមានមកដល់ថ្ងៃណា ព្រោះដាវិតមិនខៀង ដើម្បីបណ្តុះចិត្តសង្វេគហើយប្រញាប់ចាប់ធ្វើការដែលមានខ្លឹមសារ ឲ្យសមគួរដល់ខ្លួនដែលមានសេចក្តីស្លាប់ចាំស្កាត់ពីខាងមុខ ។

ការចំរើនកាវនាដែលរៀបរាប់មកនេះ ជាពិធីសាងសេចក្តីសួបសុខក្សេមក្តីចិត្ត ហើយអាចញ៉ាំងចិត្តជាឈានជាសីល ឲ្យតែតែមានដំហរវិនិច្ឆិនឹងឲ្យមានផលានិសង្សច្រើនខ្លៅតផង ។ ហេតុនេះខ្ញុំបាលោកអ្នក

ខ្លះ អាចលះបង់កង្វល់ផ្សេង។ ទៅសម្ងំចំរើនសមថកម្មដ្ឋានក្នុងទីស្ងាត់ដើម្បីឲ្យបានផលនិសង្សនេះផង ដើម្បីឲ្យបានសម្រេចឈានចិត្តដែលជាទីតាំងនៃវិបស្សនាកម្មដ្ឋានផង ។ ឯវិបស្សនាការនាក៏ជាការណីយកិច្ចត្រូវធ្វើបន្តបន្ទាប់មកពីការចំរើនចតុក្កកម្មដ្ឋាន ដែលហៅថាសមថការនានោះដែរ។ ហេតុនោះ តាលបានការនារំលឹកគុណព្រះរតនត្រ័យ ផ្សាយមេត្តា ចំរើនអសុភនិមិត្តសេចក្តីស្អប់ខ្ពើមហើយ តែងការនាវិបស្សនាកម្មដ្ឋានពិចារណាអត្តភាពតាំងមូលឲ្យឃើញថាគ្រាន់តែជានាមរូប ឬគ្រាន់តែជាខន្ធ ៥ ជាដើមប៉ុណ្ណោះ មិនមែនជាសត្វបុគ្គលគេយើងទេ ហើយលើកសការធម៌តាំងនេះឡើងកាន់ត្រៃលក្ខណ៍ ការនាបញ្ជាក់ឲ្យឃើញថាមិនទៀង ព្រោះតើតហើយរលត់ទៅនិងប្រែក្លាយទៅជាសភាពផ្សេង ។, ជាទុក្ខព្រោះតែងតែជាប់ជាភ្ញើងកិលេសនិងភ្ញើងទុក្ខគ្រប់យ៉ាង តើតរលត់ និងប្រែក្លាយ, ជាអនត្តាមិនមែនខ្លួន ព្រោះមិនទៅក្នុងអំណាច ដើម្បីរំលាយនូវទិដ្ឋានសេចក្តីប្រកាន់តាមលោកសម្មតិថា ជារបស់យើង ថាជាយើង និងថាជាខ្លួនប្រាណរបស់យើង ដែលជាហេតុនេះតែងតែ ឲ្យអស់សូន្យទៅពីខន្ធសន្តានហើយ ចានន្លូវព្រះនិព្វានគ្មានឆេះដោយភ្ញើងទុក្ខនិងភ្ញើងកិលេសឡើយ ។ សមនឹងព្រះពុទ្ធភាសិតថា :

សីលេន វិតិក្កមន្តំ បរិយុដ្ឋំ សមាធិនា

បញ្ញាយ អនុសយំ ឆិន្ទំ បត្តោ ឆឡភិញ្ញតមុត្តមំ ។

(អ្នកប្រាជ្ញ) តែងលះកិលេស (រាគៈ,ទោសៈ,មោហៈ) ថ្នាក់វីតិក្កមៈ ដោយសីល ថ្នាក់បរិយុដ្ឋានដោយសមាធិ, ថ្នាក់អនុស័យ ដោយបញ្ញា ទើបបានសម្រេចព្រះនិព្វានដ៏ខ្ពង់ខ្ពស់ ។

ជនជាតិខ្មែរ ពាំងបព្វជិតទាំងគ្រហស្ថ ច្រើនតែបានការនាអប់រំចិត្ត ដោយសមថៈនឹងវិបស្សនា តាំងពីបុរាណកាល ដូចពណ៌នាមកនេះ ។

ដូច្នេះហៅថា វប្បធម៌ពុទ្ធសាសនាជាតិប្រពៃ ។

សទ្ធម្មប្បជ្ជោត

ព្រះមហា អ៊ុក-អ៊ន រៀបរៀង

សត្វសត្វដែលកើតលើផ្ទៃនៃលោក មិនងាយនឹងបានជួបប្រទះនូវ ខណសម្បត្តិទេ ច្រើនតែជួបនូវខណវិបត្តិ ព្រោះសត្វពាំនោះត្រូវ អកុសលធម៌បង្អែរចិត្តត្រូវ ។

ខណសម្បត្តិមាន ៤:

១- ពុទ្ធសាសនុប្បាទក្ខណ: ខណ:កើតមានពុទ្ធសាសនា

២- បដិរូបទេសុប្បត្តិក្ខណ: ខណ:កើតកន្លែងប្រទេសសមគួរ

៣- សម្មាទិដ្ឋិប្បដិលទ្ធក្ខណ: ខណ:បានចំពោះនូវទិដ្ឋិល្អ;

៤- ឆឌ្ឍាយតនវេកល្យក្ខណ: ខណ:មិនខ្វះខាតអាយតន: ៦។

ពួកសត្វដែលបានជួបខណសម្បត្តិពាំង ៤ នេះ ជាសត្វមានភ័ព្វព្រោះងាយ បានបំពេញកុសលធម៌ គឺទាន . សីល ភាវនា ជាមាគ៌ានៃសន្តិ-ភាពឥតអាមិស ។

ដើម្បីសំដែងឲ្យច្បាស់នូវខណសម្បត្តិនោះ,ពុទ្ធសាសនបណ្ឌិតគួបាន ឲ្យរៀបរៀង "សទ្ធម្មប្បជ្ជោត" (ពន្លឺដ៏រុងរឿងគឺព្រះសទ្ធម្ម) ជា ៩ ផ្នែក គឺ

១- សទ្ធម្មុប្បត្តិ - ការកើតឡើងនៃព្រះសទ្ធម្ម;

២- សទ្ធម្មបវត្តេន - ការតាំងព្រះសទ្ធម្ម;

๓- ពុទ្ធសាសនូបទេស - ការតាំងពុទ្ធសាសនា;

๔- បញ្ចវគ្គប្បតិដ្ឋាន - ប្រតិស្ថានវគ្គ ៥ យ៉ាង;

๕- បញ្ចអនុត្តរជាន - អនុត្តរធាន ៥ យ៉ាង ។

๑ សទ្ធម្មប្បវត្តិ

លោកនៅក្នុងអាណានៃលោកវាជ គឺ

- អនិច្ចតា សភាពមិនទៀង;

- ទុក្ខតា សភាពលំបាក;

- អនត្តតា សភាពមិនលុះអំណាចខ្លួន ។

ត្រូវលោកវាជនោះញ៉ាំញីជាទិន្នន័យ ព្រោះជាប់ចោទបញ្ហាប្រចាំលោក ๓ ๑ គឺ

- ជាតិ ការកើតនៃខន្ធ;

- ជរា ការគ្រាំគ្រានៃខន្ធ;

- មរណៈ ការបែកធ្លាយស្លាប់នៃខន្ធ ។

លោកមិនអាចដោះស្រាយបញ្ហានោះបានអស់កាលមិនប្រាកដច្បាស់ដើម ព្រោះត្រូវមហន្ធការ គឺ អវិជ្ជា មានការមិនដឹងហេតុផលនៃសុខទុក្ខជាលក្ខណៈបិទបាំង ម្ល៉ោះហើយចេះតែបំពានលើផ្លូវខុសនាំគ្នាប្រព្រឹត្តទុច្ចរិតជាសមុដ្ឋាននៃទុក្ខវិនាសអសន្តិភាព សំគាល់ថាសុចរិតនាំមកនូវសុខចំរើន

សន្តិភាពទៅវិញ ព្រោះមិនមានបុគ្គលណាម្នាក់យកពន្លឺដុំរងើមកបំភ្លឺ ឲ្យឃើញមាគ៌ាដ៏ត្រង់ដែលនាំទៅកាន់សន្តិភាព ។

ឃ្លាអង្វែងណាស់, ទើបមានខ្លុកបុគ្គលម្នាក់មានបញ្ញាចក្ខុកើតឡើងក្នុងលោក ដោះបញ្ហាប្រចាំលោកដោយខ្លួនឯងរួចហើយយកពន្លឺដុំរងើមភ្លឺឲ្យលោកស្គាល់ទាំងដោះស្រាយបញ្ហានោះរួច ហើយឲ្យរួចផុតអំពីអាណាលោកពាដះទៅកាន់សន្តិភាព។ ខ្លុកបុគ្គលនោះ គឺព្រះពុទ្ធអ្នកត្រាស់ដឹងសច្ច: ៤ ហើយឲ្យគេត្រាស់ដឹងតាមផង, អ្នកក្បាត់ចេញពីស្រោម គឺអវិជ្ជាមុនគេ, អ្នកវែកផុតពីកក់កិគីលេសដូចផ្កាឈូក ។ កាលត្រាស់ដឹងហើយទ្រង់សំដែងព្រះធម្មចក្កប្បវត្តនសូត្រប្រោសបញ្ចវគ្គិយភិក្ខុជាមុនដំបូងបង្អស់ ។

ក្នុងធម្មចក្កនោះ ព្រះអង្គទ្រង់បដិសេធនូវបដិបទាអមពីរ គឺ

๑- ការប្រកបខ្លួនឲ្យជាប់ដោយកាមសុខក្នុងកាមទាំងឡាយជាហីនធម៌ គ្រាមធម៌ បុថុជ្ជនធម៌ មិនមែនអរិយធម៌ មិនប្រកបដោយប្រយោជន៍;

๒-ការប្រកបខ្លួនឲ្យលំបាកខ្លះ នាំមកនូវទុក្ខ មិនមែនអរិយធម៌ មិនប្រកបដោយប្រយោជន៍ ។

ទ្រង់ឲ្យដើរតាមមជ្ឈិមាបដិបទា ដែលព្រះអង្គត្រាស់ដឹងហើយធ្វើឲ្យមានចក្ខុ មានញាណ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ កើយាដឹង

ច្បាស់ តំរិយាគ្រាស់ដឹងដោយប្រពៃ ដើម្បីតំរិយាលត់ទុក្ខ ។ ទីបំផុត
ទ្រង់ប្រកាសអរិយសច្ចៈ ๔ គឺ

๑- ទុក្ខអរិយសច្ចៈ សេចក្តីពិតរបស់អរិយៈគឺទុក្ខ ជាន់ដល់ធម្មជាត
ដែលសត្វដឹកគាស់រំលើងបានដោយក្រ ធម្មជាតទន់ខ្ចី ធម្មជាតនាំឲ្យលំ-
បាកព្រួយ ពិបាកអត់ទ្រាំ ធម្មជាតដែលអរិយបុគ្គលខ្ពើមឆ្អើមធុញទ្រាន់
នឿយណាយ នោះគឺទុក្ខ ๑๒ កន្លែ គឺ

ក) ជាតិទុក្ខ តំរិយាកើត កើតព្រម តំរិយាចុះកាន់គតិតំរិយាកើត
តំរិយាកើតថ្មី តំរិយាមានប្រាកដនៃខន្ធ តំរិយាបានចំពោះនូវអាយតនៈ
ក្នុងសត្តនិកាយនោះៗ នៃពួកសត្វនោះៗ;

๑) ជរាទុក្ខ តំរិយាទ្រុឌ្រោម គ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ សែ្បែក
ជ្រួញជ្រីវ តំរិយាសាបសូន្យអាយុ តំរិយាចាស់ដុំវិញនៃឥន្ទ្រិយ;

ក) មរណៈទុក្ខ តំរិយាច្យុតិ ឃ្លាតចេញ បែកធ្លាយ អន្តរធាន
សេចក្តីស្លាប់ត័មច្ចុ កាលតំរិយា តំរិយាបែកធ្លាយនៃខន្ធ តំរិយាដាច់
រុចលន្លង់សាកសព តំរិយាផ្តាច់បង់ជីវិតិន្ទ្រិយ ។ (អនិច្ចកម្ម អនិច្ចធម្ម
សុគត ទៅកាន់បរលោក) ;

ឃ) សោកទុក្ខ សំណោក តំរិយាស្តាយ តំរិយាស្រណោះ
ស្រដេះស្រដោចខាងក្នុង សង្រេងសង្រៃខាងក្នុង នៃបុគ្គលប្រកបដោយ

សេចក្តីវិនាសអន្តរាយណាមួយ ដែលទុក្ខធម៌ណាមួយមកប៉ះពាល់ ;

๘) បរិទេវទុក្ខ ការយំខ្សឹកខ្សួល យំខ្សឹករៀបរាប់ អាការយំខ្សឹក អាការយំខ្សឹករៀបរាប់ ខ្សឹកខ្សួលអណ្តឹតអណ្តក ;

๙) ទុក្ខទុក្ខ សេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយប្រព្រឹត្តក្នុងកាយ ការយោទ្ធូលសោយនូវសេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយកើតអំពីការប៉ះពាល់ដោយកាយ ;

๑๐) ទោមនស្សទុក្ខ សេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយប្រព្រឹត្តក្នុងចិត្ត ការយោទ្ធូលសោយនូវសេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយកើតអំពីការប៉ះពាល់ដោយចិត្ត ;

๑๑) ឧបាយាសទុក្ខ សេចក្តីចង្អៀតចង្អល់ សេចក្តីគាន់តឹង ភាពចង្អៀតចង្អល់ ភាពគាន់តឹង នៃបុគ្គលប្រកបដោយវិនាសអន្តរាយណាមួយ ដែលទុក្ខធម៌ណាមួយមកប៉ះពាល់ ;

๑๒) អប្បិយេហិ សម្បយោគទុក្ខ ការប្រកបព្រមដោយសត្វ ធ៌ន សង្ខារមិនជាទីស្រឡាញ់ ជាទុក្ខ គឺការសង្គម សមាគម ប្រជុំព្រមលាយឡំដោយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ឬដោយពួកបុគ្គល មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសេចក្តីចំរើន មិនប្រាថ្នាការនៅសប្បាយ មិន

ប្រាថ្នាធម៌ក្សេមចាកយោគៈ,

ញ) ម៉ាយេមា វិបត្តយោគទុក្ខ គាត្រាត់ប្រាសចាកសង្ខារធំដ៏សត្វ ជាទីស្រឡាញ់ ជាទុក្ខ គឺការមិនមូលមិត្រ មិនជួបជុំ មិនមូលត្រកូល មិននៅណាយឡំគ្នា ដោយរបួសំឡេង កូន រស ជោជគ្គៈ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ឬជាយមាគាចិតា បងប្អូនប្រុស បងប្អូនស្រី អាមាត្យ ញាតិសាលោហិត ដែលប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីចំរើន ប្រាថ្នាធម៌ក្សេមចាកយោគ;

ឧ) យម្បិច្ចំ ន លភតិ តម្បិ ទុក្ខំ ការដែលប្រាថ្នារបស់ណាមិនបានរបស់នោះ ជាទុក្ខ គឺ ពួកសត្វមានកំណើត ការគ្រាំគ្រា ដម្ងីដម្ងាត់ សេចក្តីស្ងប់សេចក្តីសោកសេចក្តីខ្វល់ខ្វាយ ទុក្ខទោមនស្ស សេចក្តីចង្អៀតចង្អល់ជាធម្មតា មានសេចក្តីប្រាថ្នាថា "ឧ! ហ្ន៎ ធ្វើម្តេចយើងទាំងឡាយកុំគប្បីមានកំណើត ការគ្រាំគ្រា ដម្ងីដម្ងាត់ ។ល។ សេចក្តីចង្អៀតចង្អល់ ឧហ្ន៎ ធ្វើដូចម្តេចបាន កំណើត ការគ្រាំគ្រា ដម្ងីដម្ងាត់ ។ល។ សេចក្តីចង្អៀតចង្អល់កុំមកកាន់យើងទាំងឡាយ" (ប្រាថ្នានេះមិនសំរេច);

ជ) សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ដោយបំព្រួញៗបានតក្ខន្ធ ៥ ជាទុក្ខ គឺ

- រូបូបាទានក្ខន្ធ គឺនូវនៃសេចក្តីប្រកាន់មាំ គឺរូប;

- វេទនូបាទានក្ខន្ធ គំនរនៃសេចក្តីប្រកាន់មាំ គឺវេទនា,

- សញ្ញូបាទានក្ខន្ធ គំនរនៃសេចក្តីប្រកាន់មាំ គឺសញ្ញា,

- សង្ខារូបាទានក្ខន្ធ គំនរនៃសេចក្តីប្រកាន់មាំ គឺសង្ខារ,

- វិញ្ញាណូបាទានក្ខន្ធ គំនរនៃសេចក្តីប្រកាន់មាំ គឺវិញ្ញាណ,

២- ទុក្ខសមុទយអរិយសច្ច: សេចក្តីពិតរបស់អរិយៈ គឺហេតុដែនកើតព្រមនៃទុក្ខ បានដល់តណ្ហាប្រកបដោយនន្ទិរាគត្រេកអរក្នុងភាពនោះៗ រឿយៗ មិនជាប់ ញាំងសត្វឲ្យកើតក្នុងភពថ្មី ៣ គឺ

- កាមតណ្ហា សេចក្តីប្រាថ្នាក្នុងតម្រេងកើតមានកាម,

- ភវតណ្ហា សេចក្តីប្រាថ្នាក្នុងតម្រេងព្រហ្មមានរូប,

- វិភវតណ្ហា សេចក្តីប្រាថ្នាក្នុងតម្រេងកើតព្រហ្មឥតរូប ។

តណ្ហានោះកើតឡើងក្នុងធម្មជាតជាទីស្រឡាញ់ ជាទីត្រេកអរក្នុងលោក នៅអាស្រ័យក្នុងធម្មជាតនោះគឺ អាយតនៈខាងក្រៅ ៦ អាយតនៈខាងក្នុង ៦, វិញ្ញាណ ៦, សម្ផស្ស ៦, វេទនា ៦, សញ្ញា ៦, សញ្ចេតនា ៦, តណ្ហា ៦, វិតក្កៈ ៦, វិចារៈ ៦ ។

៣- ទុក្ខនិរោធអរិយសច្ច: សេចក្តីពិតរបស់អរិយៈ គឺកិរិយារំលត់តណ្ហាបណ្តាលទុក្ខ បានដល់កិរិយារំលត់តណ្ហានោះឥតមានសេសសល់កិរិយារលាស់ចោល បោះបង់ចោល កិរិយារួចផុតតណ្ហានោះ មិនមាន

អាល័យ ។ តិរិយាលេះបង់ តិរិយាវិលត់តណ្ហាដែលតើតឡើងអាស្រ័យ
ក្នុងធម្មជាតជាទីស្រឡាញ់ជាទីត្រេកអរមានអាយតនៈជាដើមនោះ ។

๔- ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ សេចក្តីពិត
របស់អរិយៈ គឺបដិបទានាំទៅកាន់ទីវិលត់តណ្ហាបណ្តាលទុក្ខ បានដល់
អរិយមគ្គមានអង្គ ๘ ។

ព្រះធម្មចក្កនេះ ជាព្រះសទ្ធម្មដែលព្រះអង្គទ្រង់សំដែងបំភ្លឺបង្ហាញផ្លូវត្រង់
ឆ្ពោះទៅកាន់សន្តដ្ឋាន ដើម្បីឲ្យស្រាយបញ្ហាប្រចាំលោកជាដំបូងបង្អស់ ។

ព្រះសទ្ធម្មចែកជា ๓ ប្រភេទគឺ

๑. បរិយត្តិធម៌ ពុទ្ធវចនៈ ព្រះត្រៃបិដកសំដែងអំពីគោលធម៌
របៀបបែបផែន ដំបូន្មាន ច្បាប់សម្រាប់ប្រតិបត្តិដែលពុទ្ធបរិស័ទត្រូវរៀន
ស្វាធ្យាយ ទ្រទ្រង់ បង្ហាត់បង្រៀន សំដែងប្រាប់ដល់អ្នកដទៃ ,

๒- បដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិប្រព្រឹត្ត តាមបានដល់សីល
សមាធិ បញ្ញា ឬសេចក្តីប្រតិបត្តិតាមធ្វើតាមកាន់តាម នូវធម៌ដ៏សមគួរដល់
ធម៌ដែលខ្លួនបានរៀន បានស្តាប់ បានចេះដឹង ដើម្បីឲ្យដល់នូវធម៌ដែលខ្លួន
មិនទាន់ដល់ឲ្យសំរេចនូវធម៌ដែលខ្លួនមិនទាន់សំរេច ដើម្បីឲ្យជាក់ច្បាស់ ។

๓ បដិវេធធម៌ ការត្រាស់ដឹង បានដល់តិរិយាបានសំរេច បាន
ជាក់ច្បាស់ចាក់ធ្លុះនូវបរមត្ថៈ គឺមគ្គ ផល និព្វាន ដែលជាផលសំរេចអំពី

ការរៀនស្តាប់ចេះដឹង ឱនប្រតិបត្តិនោះ ។

រីឯយ៉ាសត្ថដូចអ្នកដំណើរ, ព្រះសម្មាសម្ពុទ្ធដូចអ្នកស្គាល់ផ្លូវ បង្ហាញផ្លូវត្រង់, បរិយត្តិធម៌ដូចជាផ្លូវត្រង់; បដិបត្តិធម៌ដូចជាដំណើរទៅតាមផ្លូវត្រង់នៃអ្នកដំណើរ, បដិវេធធម៌ដូចជាដំណើរទៅដល់កន្លែងដែលត្រូវទៅឲ្យដល់នៃអ្នកដំណើរ ។ ព្រះសទ្ធម្មំពាំង ៣ប្រភេទនេះ បណ្ឌិតគប្បីលើកយកអរិយមគ្គមានអង្គ ៨ មកពិនិត្យឲ្យយល់ច្បាស់ថា :

ការរៀនចេះចាំបង្រៀនសំដែងនូវមគ្គ នោះជាបរិយត្តិ;

ការប្រឹងប្រែងប្រតិបត្តិប្រព្រឹត្តតាមអង្គមគ្គ នោះជាបដិបត្តិ;

ការបានសំរេចនូវអង្គមគ្គ នោះជាបដិវេធៈ ។

អរិយមគ្គមានអង្គ ៨:

๑- សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវ;

๒- សម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវ;

๓- សម្មាវាចា សំដីត្រូវ;

๔- សម្មាកម្មន្តៈ ការងារត្រូវ;

๕- សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ;

๖- សម្មាវាយាមៈ ព្យាយាមត្រូវ;

๗- សម្មាសតិ ការរលឹកត្រូវ;

๘ សម្មាសមាធិ ការដំកល់ចិត្តឲ្យនឹងត្រូវ ។

សម្មាទិដ្ឋិ

ប្រាជ្ញាយល់ឃើញត្រូវ បានដល់ប្រាជ្ញាដឹងក្នុងអរិយសច្ច:៤.

๑- ទុក្ខ: ធម្មជាតដែលនាំឲ្យលំបាកព្រួយមានជាតិដកមរណ:ជាដើម,

๒- ទុក្ខសមុទយ: ហេតុបណ្តាលឲ្យកើតទុក្ខបានដល់តណ្ហា,

๓- ទុក្ខនិរោធ: ព្រះនិព្វានរំលត់តណ្ហាបណ្តាលទុក្ខ,

๔- ទុក្ខនិរោធគាមិនីបដិបទា មគ្គមានអង្គ៨ឲ្យទៅកាន់ពី
រំលត់ទុក្ខ ។

សម្មាសង្កប្ប:

សេចក្តីត្រិះរិះត្រូវ បានដល់សេចក្តីត្រិះរិះត្រូវ ๓ យ៉ាង គឺ

๑- នេក្ខម្មសង្កប្ប: សេចក្តីត្រិះរិះក្នុងការចេញចាកកាម,

๒- អព្យាបាទសង្កប្ប: សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ,

๓- អវិហឹសាសង្កប្ប: សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ។

សម្មាវាចា

សំដីត្រូវ បានដល់ការវៀរចាកវចីទុច្ចរិត ๔ យ៉ាង គឺ

๑- មុសាវាទា វេរមណី ការវៀរចាកកិរិយាពោលកុហក,

๒-បិសុណាយ វាចាយ វេរមណី ការវៀរចាកសំដីញុះញង់,

(មានត)

ពុទ្ធសាសនាឥឡូវសាសនាជនៃ

របស់

ឃុនអត្ថកោវិទ ជា-យ្សរ

ឃុនសុត្តវេទ៍ យ្សរ-អ៊ុន ពាក្យកែសម្រួល

សាសនាកើតឡើងដោយអាការដូចម្តេច?

សាសនាកើតឡើងដោយអាការដូចមានសេចក្តីតទៅនេះ ៖

មនុស្សយើងដែលនៅក្នុងលោកនេះ ទីនៅតែឯកឯង ដោយមិនត្រូវពឹងពាក់អាស្រ័យគ្នានឹងគ្នា ពុំបាន ឡើយ ។ ការពឹងគ្នាទៅវិញទៅមកបាននោះ ជាហេតុឲ្យមនុស្សរួបរួមគ្នានៅជាពួក ជាគណៈ តាំងជាស្រុក ជាប្រទេស, កាលតាំងបានដូច្នោះហើយ ក៏ត្រូវតែតកៃទៅសាងជាតិរបស់ខ្លួន ពាក្យត្រូវមានគោលធម៌ណាមួយ ជាគ្រឿងចង្អុលពន្យល់ថា នេះគួរប្រតិបត្តិ នេះគួរលះវៀរ ដើម្បីជាគ្រឿងចំរើនដល់ពួកគណៈ ។ គោលធម៌ពាក្យនេះហើយ ដែលហៅថា សាសនា ។ សាសនាកើតឡើងដោយអាការដូចអធិប្បាយមកនេះឯង ។

សាសនាដែលគេរាប់អានច្រើន

សាសនាដែលមានបរិស័ទរាប់អានច្រើន មាន ៣ គឺ ពុទ្ធសាសនា ១ សាសនាគ្រិស្ត ១ សាសនាមហាម៉ត ១ ។

ព្រះពុទ្ធសាសនាកើតឡើងក្នុងពួកជន ដែលហៅថា អរិយៈ[๑] ។ ជនពួកនេះ កាលពីព្រេងនាយ បានលើកគ្នាចូលមកនៅក្នុងប្រទេសភារតវាសៈ[๒] គឺប្រទេស ឥណ្ឌៀ[๓] ក្នុងសម័យនេះ ។ ប្រទេសឥណ្ឌៀនេះ កាលមុនជនជាតិអរិយៈចូលមកនៅនោះ មានមនុស្សអាស្រ័យនៅពីរដើមជា ๒ ពួក គឺ ពួកអ្នកស្រុក ๑ ពួក ទឹងពួកមនុស្សដែលលុកលុយចូលមកនៅមុនពួកអរិយៈ ๑ ពួកទៀត, មនុស្សពុំងំ ๒ ពួកនេះ មានពណ៌

---

๑ ពាក្យថា " អរិយៈ " ជាឈ្មោះជាតិមួយ ។ ពាក្យនេះ ក្នុងគម្ពីរសំស្ក្រឹតប្រែថា "អ្នកមានត្រកូល" តែដោយហេតុព្រះសម្ពុទ្ធទំងព្រះសាវ័កជាជាតិអរិយៈ ពាក្យថា អរិយៈ មានសេចក្តីថា " អ្នកថ្លៃ " គឺគួរគោរពគប់អាន ឬ "អ្នកឆ្លាយ" គឺឆាយចាកកិលេស ។

๒ ភារតវាសិ: ជាពាក្យហៅប្រទេសឥណ្ឌៀ តែច្រើនប្រើក្នុងកាព្យឃ្លោងក្នុងភាសាសំស្ក្រឹត ។ ជួនកាលហៅថា " ភារតខណ្ឌ " ។ ភារត: ជាឈ្មោះស្តេចចក្រនៃពួកអរិយៈ ព័ប្ទណ, វាសិ:=សម័យ,ភារតវាសិ:=សម័យព្រះបាទភារត: ។ ភារតខណ្ឌ មានសេចក្តីដូចគ្នា។

๓ ពាក្យថា " ឥណ្ឌៀ " មកពីពាក្យថា សិន្ធុ (Sindus) ជាឈ្មោះទន្លេនៅខាងទិសឦសាយក្នុងប្រទេសឥណ្ឌៀ, សម័យឥឡូវនេះ គេហៅទន្លេ សិន្ធុ, សិន្ធុ ឬ ឥណ្ឌុស (Sind, Sindh ឬ Indus) ។ កាលពួកអរិយៈទើបចូលមកនៅក្នុងប្រទេសឥណ្ឌៀ បានតាំងភូមិលំនៅ នៅឆ្នេរទន្លេនេះមុនពួកអ៊ីរ៉ង់ (Perse) ដែលជាជាតិអរិយៈដែរ គេហៅពួកនេះតាមឈ្មោះទន្លេ តែភាសាអ៊ីរ៉ង់គ្មានអក្សរ ស,ពាក្យសំស្ក្រឹតដែលជាតួ ស អ៊ីរ៉ង់ជាតួ ហ ដូចពាក្យថា " សោម: " អ៊ីរ៉ង់ជា ហោម; "អសុរៈ" ជា អហុរៈ ទើបសរសេរឈ្មោះទន្លេនេះថា ហិន្ទុ (Hindhu) ពួកក្រិកនឹងរឿងទាំងនេះពីពួកអ៊ីរ៉ង់ តែអក្សរបស់ក្រិកគ្មានតួ ហ ទើបសរសេរជា ឥណ្ឌូ (Indoi) អង់គ្លេសហៅតាមក្រិក តែសរសេរក្លាយទៅជាឥណ្ឌៀ (India) ។

តាយ ពាបកន្តាល់ សម្បុរឡៅដ៏ងិត ជាពួកជនព្រៃផ្សៃ ។ កាលពួកអារ្យៈ
លើកទ័ពចូលមក ជនទាំងពីរពួកនេះក៏ញាស្ញើតគោតខ្លាច ចាញ់ថ្លើដែ
ដោយងាយ ជាប់ជាឈ្លើយរបស់ពួកអារ្យៈខ្លះ ខ្លះក៏លើកគ្រួសារគេចទៅនៅ
តាមព្រៃភ្នំក្រៃថ្ម ខ្លះក៏គេចទៅនៅតាមព្រៃស្រោងព្រៃរបោះ ។ ពួកអារ្យៈ
ហៅពួកនេះថា "ទស្យុ" ដែលយើងហៅថា "ខាស:" ក្នុងសម័យនេះ ។

សាសនាពួកអារ្យៈចូលមកក្នុងប្រទេសឥណ្ឌៀ

ពួកអារ្យៈក្នុងសម័យនោះ រាប់អានព្រះអាទិត្យ ថាជាប្រធាននៃ
ភពទ្រឹមធឹងកំដៅ ហៅថា"សវិតុ" រាប់អានភ្លៀង ហៅថា"វរុណ:" រាប់អាន
អ្នកបណ្តាលរបស់ផ្សែង ។ ក្នុងលោកឲ្យប្រព្រឹត្តទៅបាន ហៅថា "ឥន្ទ្រ:"
រាប់អានអ្នកទំលាយផ្តាច់ផ្តិល ហៅថា "ម្រឹត្យុ" ឬ "យម:" ដែលមាន
ក្នុងគម្ពីរសៃយសាស្ត្រ ហៅថា "ចតុលោកបាល [(๑)]" ។ កាលពួកអារ្យៈ
ចូលមកតាំងភូមិលំនៅក្នុងប្រទេសឥណ្ឌៀហើយ បានសង្កេតយើញពួក
ទស្យុ មានការរាប់អានខុសពីពួកខ្លួនច្រើនយ៉ាង ដូចរាប់អានខ្មោចថាសាច
ន៏ងធ្វើពិធីបួងសួងបូជាយ័ញជាដើម យើញថាលទ្ធិរបស់គេ ជាការគួរ

---

(๑) សវិតុ រក្សាទិស ឧតរ ត្រូវនឹងពាក្យភាសា កុវេរ:
វរុណ: " " បស្ចិម " " វរុបក្ខ:
ឥន្ទ្រ: " " បូព៌ " " ធតរដ្ឋ: } ក្នុងអាជ្ញានិយសូត្រ
ម្រឹត្យុ ឬ យម: " " ទក្សិណ " " វិរូឡ្ហក: }

ម្យ៉ាងដែរ ដើម្បីបម្រុងដំនឿចាំងនោះ បញ្ចូលមកក្នុងសាសនារបស់ខ្លួន បង្កើតទៅជាគម្ពីរវិសេយសាស្ត្រឡើង គឺចាត់ដល់ពិធីអាឃៈនឹងពួកទេវ្យ លាយចូលគ្នា ។ សាសនាពួកអារ្យៈដែលពោលមកនេះ បើបំប្រួញឲ្យខ្លី មានសេចក្តីសំខាន់ ២ យ៉ាង គឺ រាប់អានលោកចាលចាំងបួន ១ ធ្វើពិធីសែនភ្នោច បូជាយ័ញ្ញ ដែលរួបរួមយកមកពីពួកទេវ្យ ១ ។

កំណើតសាសនាព្រាហ្មណ៍

ចំណែកាលតមក សាសនាក៏តែតែចំរើន, អ្នកសង្កេតរកបស់ប្លែកក៏យើញមានច្រើនក្រៅពីលោកចាលចាំងបួន ដែលធ្លាប់រាប់អានមកពីដើម គេបង្កើតព្រះជាម្ចាស់ដទៃទៀតជាច្រើន ដូចព្រះចន្ទ ព្រះពាយុជាដើម គេសន្មតឲ្យមានខ្លួនប្រាណ ដូចទេវរូបផ្សេងៗដែលមានមកដល់សព្វថ្ងៃនេះ ។ កាលសាសនាតែតែចំរើន គំនិតរបស់មនុស្សក៏តែតែខ្ពស់ឡើងតាមលំដាប់ ។ មនុស្សខ្លះ មានសេចក្តីត្រិះរិះថា វត្ថុផ្សេងៗ ក្នុងលោកជារបស់គួរអស្ចារ្យ ប្រហែលមានលោកណាមួយជាអ្នកសាងឡើង ។ ចំណែកពួកព្រាហ្មណ៍យល់យើញថា អ្នកសាងលោកមានពិត ដើម្បីសន្មតនាមព្រះជាម្ចាស់ដែលសាងលោកថា "ព្រហ្ម" អ្នកដែលរាប់អានព្រះព្រហ្មគេហៅថា "ព្រាហ្មណ៍" ។

ព្រាហ្មណ៍ ២ ពួក

តមក អ្នកប្រាជ្ញក្នុងសាសនាព្រាហ្មណ៍ មានសេចក្តីយល់ឃើញ
ចែកខ្វែកគ្នាជា ២ ពួក គឺ មួយពួកពាក់អានព្រះព្រហ្មតែ ១ អង្គប៉ុណ្ណោះ,
មួយពួកទៀត ពាក់អានព្រះព្រហ្មនោះដែរ តែពាក់អានព្រះជាម្ចាស់ដទៃទៀត
ដែលធ្លាប់ពាក់អានមកអំពីដើមនោះផង ។ រឿងនេះ ធ្វើឲ្យពួកព្រាហ្មណ៍
តតែវិវាទទាស់ទែងគ្នា ព្រោះលទ្ធិគឺសេចក្តីប្រកាន់ មិនត្រូវគ្នា ។ ពួកទី ១
នៅក្នុងឥណ្ឌាមិនបាន កំលើកគ្រួសារតត់ចេញទៅនៅខាងបស្ចិមទិស
ប្រហែលពួកនេះឯង ជាបុព្វបុរសនៃសាសនាសូហ្វ ឬអ៊ីស្រាអែល
ដែលជាដើមចមនៃសាសនាគ្រិស្ត ។

ព្រាហ្មណ៍ក្នុងប្រទេសឥណ្ឌៀ

ចំណែកព្រាហ្មណ៍ពួកទី ២ ដែលនៅក្នុងប្រទេសឥណ្ឌៀ បានប្រដៅ
សាសនាតៗមក តែច្រើនជាអ្នកកាន់យកតែពាក្យស្មោក ឯអ្នកដែលចេះ
ដឹងពិតមានតិច ប៉ុន្តែដល់យូរៗទៅ មានសាស្តាឯកមកត្រាស់ដឹងធម៌ ។

ព្រះ ៥ ព្រះអង្គ

សាស្តាឯកនោះ មុនសាស្តាយើង៏ មាន ៣ ព្រះអង្គ គឺ ព្រះកកុ-
សន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ ទើបមកដល់ព្រះសមណគោ-
តម បរមគ្រូយើង៏ ។ មានពាក្យព្យាករថា កាលអស់ព្រះពុទ្ធសាសនា

នៃព្រះសមណគោតមនេះទៅ នឹងមានព្រះសាស្តាមកត្រាស់ ១ អង្គទៀត ទ្រង់ព្រះនាមថា អរិយមេត្តេយ្យ (ឬព្រះសិរីអារ្យមេត្រី) ព្រះសាស្តាពាំង ៥ អង្គនេះ គេហៅថា ព្រះ ៥ ព្រះអង្គ ។

កំណើតព្រះពុទ្ធសាសនា

ក្នុងសម័យដែលព្រះបរមគ្រូយើង ទ្រង់ចាប់បដិសន្ធិ ក្នុងពួកអរិយៈនោះ ប្រទេសឥណ្ឌាចែកចេញជាច្រើនអាណាចក្រ មានស្តេចផែនដីសោយរាជ្យគ្រប់អាណាចក្រ ។ ព្រះសម្ពុទ្ធរបស់យើងកើតក្នុង ២ ត្តិយត្រកូលក្នុងអាណាចក្រកាគលើ ព្រះបិតាព្រះនាម សិរិសុទ្ធោទនៈ សោយរាជ្យនៅក្រុងកបិលពស្តុព្រះមាតាព្រះនាម មហាមាយា ។ កាលប្រសូតហើយ មានឫសីទាយថា នឹងបានជាស្តេចចក្រ បើមិនដូច្នោះទេ នឹងបានត្រាស់ជាព្រះពុទ្ធ។ កាលទ្រង់ចំរើនវ័យឡើង ព្រះបិតាមានព្រះរាជបំណងចង់ឲ្យសោយរាជ្យតស្តេតិរាជ្យ ។ ដើម្បីការពារមិនឲ្យនឿយណាយក្នុងលោកិយសុខ ព្រះបិតាទ្រង់ចាត់ចែងបំរុងគ្រឿងត្រេកត្រអាលផ្សេងៗ មានស្រីស្រិង្គារជាដើមឲ្យនៅចោមរោមបំរើជានិច្ច ។ ទោះបីដូច្នោះ ព្រះមហាសត្វក៏នៅតែរលាស់ចោលចេញបាន ស្តេចចេញទ្រង់មហាភិនិស្ក្រមុ បំពេញទុក្ករកិរិយាបានសេចក្តីពិបាកដ៏លើសលុប ដើម្បីពិសោធន៍រកសេចក្តីពិត ក្នុងទីបំផុតទ្រង់បានសម្រេចព្រះសម្មាសម្ពោធិញ្ញាណដូចព្រះបំណង ទ្រង់ទេសនា

ប្រាសសត្វឲ្យបានសម្រេចមគ្គផលខ្លះ ឲ្យតាំងនៅជាកល្យាណបុថុជ្ជនខ្លះ ជាកសិណសាក្សីនៃការត្រាស់ដឹង រួចទ្រង់ប្រគល់ស្ថានព្រះពុទ្ធសាសនា ឲ្យបរិតរេតរៀងមក ។ ពួកយើង អ្នករៀន អ្នកស្តាប់ព្រះពុទ្ធវចនៈ តែងជ្រាបដឹងជាក់ច្បាស់ក្នុងដួងចិត្តថា ធម៌របស់ព្រះសម្មុទ្ធ សុទ្ធតែជារបស់ពិតតាំងអស់ ។

សាសនាស៊ិហ្វ ឬ អ៊ីស្រាអែល

ចំណែកសាសនាគ្រិស្តនោះ កើតក្រោយព្រះពុទ្ធសាសនា ដល់ទៅ ៥៤៣ ឆ្នាំ តាំងពាក្យប្រៀនប្រដៅដែលសំខាន់ ។ ក៏ដូចពាក្យប្រៀនប្រដៅរបស់ព្រះសម្មុទ្ធនៃយើងតាំងអស់ ។ សាសនាគ្រិស្តនេះ កើតនៅក្នុងប្រទេសស៊ុយជា ក្នុងពួកជនអ៊ីស្រាអែល ។ ជនពួកនេះ ពាប់អានព្រះយ៉ៈហ្វោរ៉ា តែមួយអង្គប៉ុណ្ណោះ ។ លុះក្រោយនេះ ប្រហែលជាប់មកពីពួកព្រាហ្មណ៍ដែលពាប់អានព្រះព្រហ្ម ហើយដែលរត់ទៅពីប្រទេសឥណ្ឌា ។ មុនដែលសាសនាស៊ិហ្វនឹងកើតជារូបរាងឡើងនោះ មានមុនី(អ្នកប្រាជ្ញ)ម្នាក់ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ហើយដែលពាប់ថាជាអ្នកតសាងសាសនាគ្រិស្ត ឈ្មោះមោសេស៍ ជាអ្នកមានសេចក្តីចេះដឹង តាំងជាមេត្រួតត្រាពួកអ៊ីស្រាអែល ដែលនៅក្រោមបង្គាប់ព្រះបាទ ហ្វារ៉ាអុង (pharaon) ក្នុងប្រទេសអេស៊ុប ។ សម័យនោះ ព្រះបាទហ្វារ៉ាអុង ទ្រង់ពាប់អាន

មោសេស៍ ថាជាមុនីយ៉ាន់ឆ្នើមម្នាក់ ។ កាលមានហេតុការណ៍អ្វីមួយ
កើតឡើង ព្រះជាម្ចាស់ទ្រង់ឲ្យមោសេស៍ថាយ ហើយទ្រង់ដឿនាក្បែលដែល
មោសេស៍ពិតខ្លួលគ្រប់យ៉ាង ។ សម័យមួយ មានការឡកណ្តើតឡើងក្នុង
អាណាចក្រអេស៊ុប ព្រះបាទហ្វារ៉ាអុងទ្រង់មានបន្ទូល ឲ្យហៅមោសេស៍
មកសួរថា តើការឡកណ្តើដែលកើតឡើងនេះ នឹងមានហេតុកើតដូចម្តេច ។
មោសេស៍ទូលថា ការណ៍ដែលពួកអ៊ីស្រាអែល នៅក្រោមបង្គាប់ពួក
អេស៊ុប ទាំងត្រូវពួកអេស៊ុបសង្កត់សង្កិនផងនោះ ព្រះជាម្ចាស់មិនសព្វព្រះ
ទ័យទេ ទើបបណ្តាលឲ្យកើតការឡកណ្តើយ៉ាន់នេះ បើព្រះបាទហ្វារ៉ាអុង
មានបំណងឲ្យអាណាចក្រអេស៊ុបរួចផុតពីអន្តរាយ ត្រូវតែដោះលែងពួក
អ៊ីស្រាអែលឲ្យរួចជាអ្នកជា ។ ព្រះបាទហ្វារ៉ាអុងទ្រង់ដឿ ក៏ទ្រង់បញ្ជាឲ្យ
ដោះទឹមកំណេលចេញពីពួកអ៊ីស្រាអែល ហើយឲ្យមោសេស៍ជាអ្នកដឹកនាំ
ពួកអ៊ីស្រាអែលចេញចាកប្រទេសអេស៊ុប ។ ដល់ពេលក្រោយ ទ្រង់
បានជ្រាបថា ទ្រង់ចាញ់បោកមោសេស៍ ក៏ទ្រង់ព្រះក្រែវក្រោធជាពន្លឹក
ទ្រង់បញ្ជាឲ្យទាហានលើកទ័ពទៅតាមចាប់មោសេស៍ ។ ទាហានលើក
ទ័ពទៅតាមចាន់នៅសមុទ្រក្រហម ។

(មានត)

ផ្នែកអក្សរសាស្ត្រ

រឿងនេវន្ត (ភាសាភាសា)

(តមក)

លោក អម្ចូតក្សត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម
លោក ញ៉ឹក-ថែម ពន្យល់

ពស្ត្រគ្រប់ហានបិត សោតសឹងចូលចិត្ត ឱដព្រះភូឋាល នីរណាយ
ទោសទុក្ខ ជាសុខត្រកាល ពុំដែលវង្គាល រង្គៀសឱដស្តេច ។
ស្តែងស្តេចទ្រទ្រង់ ពាក្យរឿងលុះលង់ តិចពៅសម្តេច រំពាដមាតា
ដកតស់តិច្ច តាយក៏សម្រេច រូបរំលាងបង់ ។ ស្តែងស្តេចធ្វើបុណ្យ
តបស្នងសងគុណ ស្រេចស្តេចឲ្យអង្គ អត័យកុមារ អនុជាវរង្ស
សោយពាក្យទ្រទ្រង់ ជាទបពាដា ។ រិះពាដការផង តាមច្បាប់ស្នាប់ស្នង
ព្រះមហាក្សត្រា ក្សត្រទ្រង់អំណាច សោយពាក្យដួបជា ប្រាំពីរវស្សា
ពស្ត្រសុខសប្បាយ ។

រីឱដសុវណ្ណ - កេសរសោភ័ណ ស្រីរត្នបវរ រួមរ័ត្យតិសវ្រង់ ឱដ
អង្គភូធរ ទ្រង់គតិតត់បរិ បូណាប្រាំពីរវ័ទ្ធ ។ ទៅតែ១បី ទៀតទើបក្សត្រី
ប្រសូតបុត្រស្នេហ៍ ថ្ងៃមួយចូលផ្ទំ ត្រៀមត្រាំរំរេ រិះគិតទៅឯ មាតាបិតា ។
លុតលើកតកំ-បង់បែរបង្គំ ទូលពោធីថា បពិត្រព្រះអង្គ សូមទ្រង់-

មេត្តា ដ្បិតខ្ញុំចិន្តា ដល់ក្សត្រពីរពេង្ស សន្ធត់ប្រាំពីរ ឆ្នាំគត់ន៏ធីរិល បង្គំព្រះអគ្គ ឥឡូវឆ្នាំគត់ កំណត់សូមទ្រង់ ប្រោសប្រាណនាំអង្គ នាំអញទៀ ។

ព្រះពោធិសត្វ ស្តាប់មហេសីភ្លេ ទុអ្ហែប្អូនឆៅ បងមាសតែងនឹក រលឹកបងឆៅ បងជូនប្អូនឆៅ កុំព្រួយចិន្តា ។ តែមើយើងឆៅ ផ្លូវគោក នោះហៅ តម្រមហិមា រីអស់ពលរេហ៍ ឆៅហែពាល់គ្នា សំលំបាករៀ ងឆ៍ងៅតុំបាន ។ នឹងឆៅអាកាស អាសូរមេត្រមាស តតិពេញក្នុងឆ៍ប្រាណ បើច្នេះយើងឆៅ សំពៅឡើបបាន សុខសព្វថាហាន ហែហើយសប្បាយ។ ស្តេចតតីនឹងនាង លង់លុះព្រឹកព្រាង ប្រាមប្រាប់គ្រប់នាយ តំរែតិតំ តសំពៅថ្នាយ មួយធំទូលាយ តួចល្មមប្រាំរយ ។

មន្ត្រីតួចធំ ប្រដេញដឹងដំ ប្រយ័ត្នមិនឲ្យ ពួនព័ទ្ធរៀរៀ ពីរៃ ស្រែចដោយ មុខឆ៍រមុនក្រោយ ចូលទូលថ្នាត់ថ្នាយ ។ រីឯសំពៅ ទីនាំឯបមឆៅ ធេងធំទូលាយ ជាក់ជាំកញ្ចក់ ក្នុងក្នុកភ្លែងភ្លាយ ភ្លែងភ្លេ ទ្វេរលេចលាយ លេចលាស់ពាំងទង ។ ពាំងទីតំនាល់ តំណត់ឡើងគាល់ ពិភានជាសចង បុប្ផាមាលា វិនាផលផង ស្អាតស្អំឥតហ្មង ឥតទ្វេះ មានទាត ។ ទោះពាំងព្រាវរាំង បង្អួចជញ្ជាំង មានរឿងគ្រប់ជាតិ គ្រប់ជាន់ សួគ៌ស្ថាន សឹងមានព្រះចាខ ចក្រពត្តិនរនាថ អមរាត់ទ្រូវព្រហ្ម ។ មាន

រូបកន្ទេះ រោងកាយការ តាន់តាប់បង្គុ - ម៉ាមានគ្រប់ទ្វារ លីលាលាយឡំ
លោមលេងឲ្យអំ- ណារនៅសប្បាយ ។ មានរូបខេវគា កន្ទីរកន្ទក នៅ
កៃលាសនាយ រូបខ្ញាមួនមាំ ដេញទាំប្រើសត្រាយ រួតរត់ប្រញាយ
ប្រញាប់ពួននៅ ។ អស់ម្រឹគបក្សី ព្រៃព្រឹក្សស្រេស្រើ ស្រះសមុទ្រនៅ
សោឡសសួគ៌ហាន សឹងមានរូប ៗ នាគឯសំពៅ សំពោងទូលាយ ។

ស្តេចស្តេចឲ្យផុត មាសប្រាក់គ្រប់មុខ ទ្រព្យផងចាំងឡាយ
សំពៅប្រាំរយ ស្តេចឲ្យចែកចាយ មន្ត្រីគ្រប់កាយ គ្រប់កងរោងជា ។
ស្តេចឲ្យរើសឆ្នប គ្រប់អ្នកប្រកប នូវមន្តវិជ្ជា ឲ្យចុះសំពៅ យកទៅ
បង្ការ សម្តេចពនិតា ប្រសូតបុត្រថ្លៃ ។ ពងព្រុទ្ធឆ្នូរ ស្តេចបើក
បន្ទូល ផ្តែផ្តាំផ្ទេរផ្តែ ត្រាមត្រាំក្រៃក្រែង ឲ្យអង្គអភយ ស្នងអង្គក្សត្រថ្លៃ
រក្សាពស្ត្រប្រជា ។

លង់លុះបានឫក្ស ជោគជ័យអធិក ស្តេចនាំពនិតា មន្ត្រីចាស់ខ្លះ
នូវស្នំស្នេហា ចចុះកេត្រា ឲ្យបើកចេញទៅ ។ សំពៅប្រាំរយ បើកវែហា
ម៉ុខក្រោយ សំពៅចមទៅ ដើរជាយមគ្គា ដល់សាគ្រាលត្រៀ
វាយោទាំទៅ ក្សេមក្សាន្តសប្បាយ ។ ស្តេចនាំមហេសី ឡើងលើ
បាឡី ព្រះពាយផាត់ផាយ ត្រសៀកកំកើយ ល្អែរល្អើយព្រះកាយ ខេត
ត្រីចាំងឡាយ បង្ហាញមហេសី មាសមើលត្រីត្រេច វែហវែហលហក់

ហ៊ិច អេកចំណ៏ ទឹងទំស្ទុះស្ទែង ខ្លះវែងខ្លះខ្លី ខ្លះខ្មែនជាត្រី ក្បាលដូចមនុស្ស ។ មាសមើលខ្លះទៀ ប៉ប៉ុនសំពៅ សំពោងសោះសាខ្លះភ្ញាំងហ៊ក់ហ៊ិច ហក់ដេញវេច អេងនាំគ្នា រត់លេចលាន់ ។ ខ្លះហែលហួសឆ្ងាយ ដំទឹកខ្លះភ្លាយ ខ្លះតាមទៅជាន់ ហែលហែកស្ទ្រែ ជាតិជាដូរជាន់ អនេកសល់ពាន់ សល់ពុំស្គាល់គ្រប់ ។ ស្តេចទៅកន្លះវែងទៀនទើបព្រះ គតិគ្រប់វែងដប់ ឈើធៀបរិតរែង នាងនឹងសម្ភព ស្តេចត្រាស់សួរសព្វ ហោរានឹងទាយថា ។ នាងនឹងសម្ភព ស្តេចឲ្យបញ្ជាប់អស់ពាន់កេត្រា ព្ងដឹកណ្តាល ប្រាំលដលសា - គរគម្ពីរ តំរៀសុះសាន្ត ។ ឆ្មបនាំចមទៅ ចោមជុំគាល់ហ្មៅ ពេលពេលាបាន នាងប្រសូត្របុត្រ វិសុទ្ធច្រោសច្រាណ ប្រុសប្រសើរមាន រូបពង្ស្អស្អះ ។ សម្តេចពង្សោ-ធិកដរវេច ស្តេចទ្រង់ត្រេកអរ ឲ្យនាមពដបុត្រ សមុទ្រសាគរតាមហេតុព្រោះប្រ-សូតកង្ស៏សមុទ្រ ។ ស្តេចបើកសំពៅ ចរចេញទៀតទៅ កន្លះវែងគត់ ដល់ដែនស្រុកស្រេច សម្តេចពង្សព្រុទ្ធ ស្តេចឲ្យបោះយុ-ថ្កាថ្កើងនិត្យទៅ ។ ហើយព្រះភូនាថ ឲ្យតែងពដសារ រើសពដខូតទៅ ខូតខូលថ្វាយសារ ក្បត្រាចមទៅ ត្រេកទ្រង់ហារហៅអាឡក់សូត្រសារ ។

ព័រពង្សពដបុត្រ បត់បាខលុះលុត ដួញដង្ស៏សិរសា ខន្ធាបដាក់ដោម

ក្រាយ្យក្រោមជាត ទោសយើងខ្ញុំមហា គរុទោសធ្ងន់ ។ ពុំគួរ
ជ្រាណាជ្រោស ជ្រោសប្រណីទោស ទោសដល់ដីពជន្ម សូមចូល
អតិវាទ ក្រោមបាទព្រះគុណ ជ្រាតដសូមជន្ម សូមដីវតវិធ ។ ដ្បិត
ភាលវិរវត់ សោតសន្ទតិមត់ ជ្រាំពីរឆ្នាំនឹង លះលែងពិតព ត្រឡប់វិល
រឹង វិលមកពាក់ពីង បុណ្យបទទោសទាស ។ ឥឡូវគិតគត់ កត់
កាំលុសន្ទត ជនជាំជាក់ប្បាស់ វិលមកបង្គំ ព្រះអគ្គអម្ចាស់ មកបតចាំ
ស្រាស់ ចាំទ្រង់ជ្រោសជ្រាណ ។ បើជ្រោសមេត្តា ឲ្យមកថ្ងៃណា
ថ្ងៃនេះនឹងបាន ឡើងមកបង្គំ បរមត្ថត្រកូន្ត សេចក្តីពុំហាន មកឯង
ហាក់ធ្ងន ។

ចាំងពីរពន្លឺស្រួត ស្តាប់សារបុត្រត្ន ទុនអង្គឥតហ្មង យល់គាប់គួរ
ក្រៃ ក៏ត្រៃថ្ងៃច្បាស់ច្បង ត្រេកអរកន្ធង ឥតអ្វីធ្ងន់ឡើយ ។ ឥត
អង្គគាក់អួល គ្រាស់ទ្រង់ត្រេកស្រួល បន្ទូលថាអើ កុំអាលឡើងមក ចាំ
ប្រជាប់ធ្វើ មគ្គាជំណើរ ដំណាក់ទទួល ។ បើធ្វើមគ្គា រៀបរួចគាល
ណា ឫក្សាសោតស្រួល សឹមឲ្យសេនា យោធាបបួល តាមទៅ
ទទួល ចូលគាន់ហានបាត ។ ឯងប្រាប់កូនថា អញពុំគ្រោធ នឹងកូន
ស្នេហ៍ស្និទ្ធ ឮកូនវិលវិញ អង្គអញអរក្តិត កុំឲ្យកូនគិត តិតភ័យបារម្ភ ។

ទូតស្តាប់ទន្ទឹង ព្រះបាទកូវនាថ លើកតរប្រណម្យ លាចុះ

សំពោ ចូលទៅបង្គំ ទូលព្រះបរម- ពោធិសម្ភារ ។ តាមដោយដំ-
ណើរ ក្សត្រកន្ត្រប្រសើរ សែនសោមនស្ស ស្តេចអនុន លំ
ពោនសរសា ប្រែព្រះកន្ត្រា បង្គំឆ្ពោះត្រង់ ។

ឧទ្ធវថ្វេងកាលគ្រា កាលក្រោយទូលលា ហើយក្សត្រាទ្រង់ បន្ទូល
ក្រោមក្រាប់ បង្គាប់ព្រះអង្គ មន្ត្រីចតុរង្គ បណ្តាគាល់ថា ។ ចូរបាប្រើ
ក្រាប ផ្លូវផងដរាប កំពង់តេត្រា បាធ្វើឲ្យត្រង់ ឲ្យសង់រានផ្សារ រៀបរៀង
មគ្គា ជានគាល់ដល់ទៅ ។ រៃរៀបរានផ្សារ ខ្លះដាក់តាសា យម-
នាខោអាវ ខ្លះឲ្យដាក់ស្រា មំសំខ្លះទៅ ខ្លះឆ្អិនក្តៅៗ ដាក់រានមីមគ្គា ។
រានខ្លះដាក់ចាយ តោដនពាំង ឡាយ រានខ្លះដាក់ក្លា កុំឲ្យមានខ្លះ រានខ្លះដាក់
ស្រា ដាក់សព្វអាហារ ចំណីគ្រប់រាន ។ ចំណីចំណុក ពីបរទេសស្រុក
ដទៃសព្វហាន ក្រែងអស់យោធា សេនាពាហាន ឯណារាំងមាន រាំចង់
ស៊ីអ្វី ។ កុំបីឲ្យគ្មាន សុគសីងឲ្យមាន មួយទីរស្រែ ប្រុសប្រើដាក់ផ្សារ
អាហារចំណី អាត្រក់កុំបី ឲ្យរង្គួយទៅ ។ រីផ្លូវសង់ខាង បាឯងឲ្យ
ស្អាង រថាំឥតសៅ-ហ្មងមកជុំចាំ រៀរៀងទៅ ពាលទីសំពោ ឲ្យ
មនុស្សម៉ើលលេង ។ មួយសោតបារៀប អស់ពាំងរមៀប របបគ្រប់
ភ្លេង បារើសចម្រៀង ច្រួចច្រៀងល្បើយល្បែង សូរសេមស័ព្ទភ្លេង ជាន្ទែង
យោធា ។ មួយសោតចូរទៅ រើសរៀបពលទៅ ទទួលបុត្រា ស្រិត

ស្រាងស្អិតស្អាង រួបរាងសោភា សោភាពដូចគ្នា សុទ្ធសឹងតំឡោះ ។ រីគ្រឿងប្រដាប់ ប្រជាសម្រាប់ សំអាងអង្គនោះ ខៀវលឿងត្រៃត្រុ ក្រហមសែតសោះ សាសសមស្មោះ ឲ្យប្លែកៗគ្នា ។ ស្បៃកពាក់ក្រហម គ្រឿងផងឲ្យត្រម ជាក់ដោយហត្ថា នាឥន្ទ៍ក្រហម ឲ្យត្រមពណ៌ដា ថាបើពួកណា ស្បៃកពាក់ពណ៌អ្វី ។ ឲ្យមានប្រដាប់ ត្រមនូវសម្រាប់ សម្រាំងសឹងថ្មី មួយអស់ថាស់ខុំ នូវស្នំសាវស្រី ទៅហែបុត្រី អង្គុំអញ្ជ ឯនាយ ។ ឲ្យមានប្រដាប់ គ្រប់ពណ៌សម្រាប់ អស់អង្គរួបកាយ ដោយពណ៌មួយៗ កុំឲ្យឡំលាយ ស្បៃកលឿងពាក់ស្មាយ នោះអញមិនត្រម។ មួយរីបុត្រា អស់អគ្គសេនា ឥតួចៗល្មម ប្រដាប់រុងរឿង សោតលឿងក្រមាម គ្រប់ពណ៌ឲ្យត្រម ចូរឆាប់ចេញទៅ ។

ចតុស្តម្ភស្តាប់ ខ្នួលបង្គាប់ ចង្កឹចមទៅ ចេញទៅចាត់ចែង តាក់តែងប្រើហៅ ឲ្យចូរជាស្មៅ ព្រៃច្រាបមគ្គា ។ ច្រាំពីរថ្ងៃគត់ រួចដូចតំណាត់ តំណាន់ពល់គ្នា ពាស្តរវៀបពលសេះ រនេះគជា គជេន្ទ្រអស្សា អស្សាពាហ៍ក្លាហាន ។ មានគ្រឿងប្រដាប់ ប្រជាសម្រាប់ ពាស្តរាជអស្សយាន រីសេនានាយ តែងតាយសឹងមាន ពណ៌ប្រដាប់ប្រាណ ប្លុងប្រចាំដៃ ។ នាយរថរៀបរថ ទំមពញគាន់កត់ រៀបរៀងរៀយរៃ ចាប់ដៃដឹកជាក់ ឲ្យអ្នកនោះនេះ នោះទៅចាំដៃ រថនោះប្លុងព្រ័ត្រ ។

នាយដំរីរៀប ដំរីត្រួតត្រៀប ត្រួតត្រាំកំណាត់ កំណាន់ដំរីសារ កង្វែរគាន់
កត់ កាន់គាវបានបាច បានបរច្រើនជង ។ ខ្លះរៀបកងយោធ
យោធាពាហន ចាស់ខ្លាំងផង សឹងរៀបប្រជាប់ សម្រាប់ឥតហ្មង់ រៀប
រួចគ្រប់គង គ្រប់កំណាន់នាយ ។ ស្រេចហើយនាំទៅ ចាស់ទីលំនៅ
ត្រៀមពលចាំងឡាយ ហើយអស់សេនា យោធាគ្រប់នាយ ចាប្លែ
ភ្នាត់ឋាយ បង្គំទូលថា ។ បពិត្រព្រះបាទ ព្រះបរមនាថ ឥសូរសិរ-
សា ទ្រើសទ្រង់តបេះ ជាតិព្រះបិតា ឲ្យយើងកាលគ្នា មកអញ្ជើញចូលរួ ។

កាលណោះព្រះពោ ធិសត្វទត្តមៃ ពន្យុព្ធន្ធីរ ជ្រាបសព្វិសេច
ត្រេច ស្តែងស្តេចបន្ទូល ច្រាប់ប្រើប្រមូល ពួកពលព្រះអង្គ ។ ស្រួច
នាំពនិតា នូវព្រះបុត្រា លីលាទ្បើតង់ ពាជយានជីឆ្នាំង ក្ស័ត្រញុំង្គ៌ពីរ
ពន្យ រួហានហាក់អង្គ ឥន្ទ្រអែបសុជតា ។ អស់អកញ្ចុំ មេទំ
ន្លូវស្ទឹ ខ្លះដំរេថា ខ្លះដំដុំរី សេនីសេនា ខ្លះដំអស្សា ខ្លះដើរជង្ហែ ។
តូរត្រែខ្ទឹងផង ប្រគំអឺងកង សមសព្ទសង្ខ្លែត្រែ រំអស់សេនា យោធាស្មឹងតែ
គាន់ទន្ទឹងត្រែហែ ដោយពលពួកពល ។ ថ្មើនសក្តិថ្មើនយស់ ថ្មើន
កេរឱ្យដំរស់ ថ្មើនអង្គយង់យល ហាកឥន្ទ្រផ្ទះផាក ចេញចាកមណ្ឌល
ខេតចាំងសាគល ហៅរាលទៅ ។ រីពួកយោធា ខ្លះឥតគង្វា ឥតស្រាប់
ខ្លុតទៅ ហើយពាក់តម្រង ជាផងដើរទៅ ខ្លះផឹកទឹកក្តៅ តាមបំណងយានៗ

(មានត)

កណ្ឌទី ៣០

នាយ៉ាវិបុលភាងសេនា ង្វួ-ភាង ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកភាងវៃឆ្លាស បើបានអាន
> ធំងបេះខ្យបាយកលបំណាន
> ទាំងមានសន្ដានស្នេហាជាតិ ។

ភូចសុនគួនចៅហ្វាយស្រុកគាំងតាំង ១ ទៀតឡូចៅហ្វាយស្រុកតាំងធួន ១ នឹងស្រុកឡាំអួត ដែលនៅក្រៅដែនស្រុកចិន (ស្រុកតេង់ដីវ) ១ នឹងលើកទៅមកផ្ញើអក្ខរកាយស្រុកយើង ។ ឡូតាំងនេ្ហយថា តាហានខ្ញុំបាន ៣ នាក់ សុទ្ធតែមានថ្វីដៃខ្លាំងពូកែក្លាហានណាស់ ហើយលោកយើញថា នៅតែយដំបន្ថែងណាជាផ្លូវមុខទ័ព នឹងឲ្យទៅឈរតែ៉ារាវរក្សាស្រុកនៅដំបន់កលោះចុះ ។

ឡូតាំងប្រាប់ដំនឹងបញ្ជាសដូច្នោះ តាមានសេចក្តីត្រេកអរណាស់ទើបឲ្យសាមតាហានទាំង ៣ នាក់នោះ មកមើលរូប ហើយឲ្យទៀ-

ហ៊ុយនាំតាហានចេញទៅឈរវៃក្សាគយតដែនស្រុកឡាំអ៊ូត ឲ្យគួនអ៊ូនាំតា
ហានទៅឈរវៃក្សាគយតដែនស្រុកតាំងជួន ឲ្យដួឡងនាំតាហានទៅឈរ
វៃក្សាគយតដែនស្រុកកេងដីវ តដែនស្រុកកាំងតាំង ។ណៈនោះ ឡៅប៉ៀរ
ក៏ទុកចិត្ត មិនបានគិតខ្វាចបារម្ភសឹកសត្រូវស្រុកណានឹងលើកមកធ្វើអន្ត-
រាយស្រុកនោះឡើយ ។

លុះក្រោយពីនោះមក ឈួម៉ក់ចូលទៅនិយាយច្រាប់នាងឈួហ៊ុយិន
ជាបងដែលជាភរិយាឡៅប៉ៀរថា ឥឡូវនេះ ឡៅប៉ៀរដឿស្តាប់ពាក្យសំដី
ឡៅពីណាស់ ឲ្យសេនាឡៅពីចាំងៗនាក់ លើកតាហានទៅឈរវៃក្សា
គយចុងដែនចាំងៗជំបន់ ឯខ្លួនឡៅពីនោះនៅក្នុងស្រុកយូរទៅខ្លាំយើញថា
គង់នឹងមានភ័យដល់ខ្លួនយើង នឹងឡៅប៉ៀរជាច្រោកជ ហើយឈួម៉ក់
លាថយចេញទៅវិញ លុះវេលាយប់នាងឈួហ៊ុយិន ក៏ក្លែងកល់មាយា
និយាយនឹងឡៅប៉ៀរថា សព្វថ្ងៃនេះ ខ្ញុំឮដំណឹងថា បណ្តាអ្នកស្រុកក្នុង
ស្រុកកេងដីវតែងទៅមករកឡៅពីជាអ្វីអរណាស់ សូមឲ្យលោកគិតរកាំងខ្លួន
ឲ្យមែនទែន បើមិនដូច្នោះទេ ត្រូវឲ្យឡៅពីចេញទៅនៅវៃក្សាស្រុកខាង
ក្រៅ ដែលជាចំណុះស្រុកយើង ស្រួលជាងឲ្យនៅក្នុងស្រុកនេះ បើលោក
មិនដឿស្តាប់ខ្ញុំទេ ភ័យអន្តរាយគង់នឹងមានដល់ខ្លួនលោកទៅថ្ងៃមុខ។ ឡៅ
ប៉ៀរឆ្លើយតបថា ឯឡៅពីនោះជាមនុស្សគាន់ស័ត្យសុចរិត មិនមែនប្រ-

ខ្ញុំស្តាយដល់យើងខ្លះ ។ នាងឈួងហ៊ួយនឹងឆ្លើយថា ដែលលោកមកតិត
ប្រមាណចិត្តខ្ញុំពីថាជាគ្រូដ៏ល្អនោះ គ្រូដ៏គេមិនដែលមាន គ្រូដ៏ជួបប្រសាសន៍
លោកថា ។ ខ្ញុំប៉ៅវ៉ែតនៅស្ងៀមមិនថាប្រការម្តងឡើយ ។

លុះក្រោយនោះមកមានថ្ងៃ ១ ខ្ញុំប៉ៅដំរេះនាំគាហានចេញទៅ
រេងក្រៅស្រុក ខ្ញុំពីកំដំរេះតាមទៅ ខ្ញុំប៉ៅក្រឡេកឃើញសេះ
ខ្ញុំពីល្អ ក៏សួរថា សេះនេះឯងបានមកពីណា ? ។ ខ្ញុំពីឆ្លើយថា សេះ
នេះរបស់ខ្ញុំប៉ៅ តាលម្ចាស់ស្លាប់ទៅហើយ ខ្ញុំតឹយកខ្មុកដំរេះ ខ្ញុំប៉ៅពុ
ជ្ជុះ តិពិនិត្យមើលលក្ខណៈសេះនោះសព្វគ្រប់ សរសើរថាល្អស្អាតស-
ម្បុរពព្រុះ ខ្ញុំពីយល់ថា ខ្ញុំប៉ៅមានចិត្តស្រឡាញ់សេះនោះ ក៏ចុះចេញ
ពីលើខ្នងនោះថា លោកចូលចិត្តស្រឡាញ់ឬ ខ្ញុំបានដូនខ្មុកដំរេះរេង ? ។ ខ្ញុំ
ប៉ៅក៏ទទួលអំណោយសេះនោះ ហើយឡើងដំរេះត្រឡប់មកផ្ទះវិញ តេង
អ្នកឃើញខ្ញុំប៉ៅបានសេះថ្មីក៏សួរខ្ញុំប៉ៅថា សេះនេះលោកបាន
មកពីណា ? ។ ខ្ញុំប៉ៅប្រាប់ថា សេះនេះរបស់ខ្ញុំប៉ៅ ខ្ញុំ
ពីទៅចាំងដណ្តើមបានមកយកមកឲ្យយើង តេងអ្នកក៏តិពិនិត្យមើលលក្ខ-
ណៈសេះនោះឃើញត្រូវយ៉ាងច្បាស់ ក៏ដំណាលថា តេងលៀងបង ខ្ញុំបានចេះ
មើលលក្ខណៈសេះល្អអាត្រក់ជាប្រាកដណាស់ តាលតេងលៀងដឹត
ស្ងាប់ បានប្រាប់ខ្ញុំបានឲ្យរៀនមើលតម្រានៅសព្វថ្ងៃ ខ្ញុំបានបានពិនិត្យ

បើលោយើញសេះនេះមានថ្លៃដ៏ធំនឹងកំពូរជំរួសហើយ តែមានក្រយៅតាចនៅស្បែរភ្នែកខាំង ២ ខាងក្រោមនោះហៅថា រងទឹកភ្នែក ខាងចំញើមនោះ មានពោមតាចសម្បុរស្រែម ទៀបបូដំនេះនេះច្បាងទើបដល់សេចក្តីស្លាប់ ដែលលោកនឹងយកសេះនេះមកទុកដំមិនស្រួលទេ ព្រោះលក្ខណៈសេះនេះ ធ្វើទុក្ខឲ្យចោសម្ចាស់របស់ ។

ទៀបប៉ៀវឮដូច្នោះ ក៏ដៀពាក្យកេងអួត លុះវេលាព្រឹកឡើងទើបឲ្យហៅទៀតមកស៊ីលៀងហើយថា ដែលបួនឲ្យសេះមកបង់នោះ បង់អារគុណណាស់ តែខ្លួនបង់មិនបានចេញទៅធ្វើសង្រ្គាមទេ បួនត្រូវយកសេះនេះទៅទុកដំសម្រាប់ដើរច្បាងចុះ ។ ទៀតមិនបានដឹងហេតុកំខ្លួលយកសេះនោះទៅវិញដោយសេចក្តីត្រេកអរ ហើយគំនាប់ទៀបប៉ៀវឲ្យមនុស្សនាំសេះនោះទៅ ទៀបប៉ៀវនិយាយនឹងទៀតថា សៀងអាហារកេងស្រុកស៊ីនអៀកបរិបូណ៌ត្រម បួនចូរនាំគ្រួសារនឹងសេនាពាហនទៅនៅរក្សាស្រុកស៊ីនអៀចុះ ។ ទៀតកំខ្លួល លុះពេលព្រឹកឡើង ក៏រៀបចាត់ចែងពាហនទឹងរបស់ទ្រព្យ ហើយនាំគ្រប់គ្រួចេញទៅ ទៀតដំនេះចេញពីស្រុកកេងដីរ ទៅដួបនឹងអ៊ីដៀ ដែលនៅនឹងទៀបប៉ៀវ ទៀតកំចុះពីលើសេះគំនាប់អ៊ីដៀ ។

ចំណែកអ៊ីដៀកំប្រាប់ទៀតថា តើម្យាលមិញខ្ញុំបានឮកេងអួត

ក្រាបទូលប៉ៀវថា សេះនេះណាអ្នកតទូល្អ លក្ខណៈគាចឲ្យទោស
ដល់ម្ចាស់របស់ ទូលប៉ៀវក្នុចបានជាបង្ខិលឲ្យលោកវិញ លោកមិនជ្រាប
ទេឬ បានជាយកសេះនេះមកដែរ? ។ ទូលពីត្បូហើយក៏ថា ដែលបាន
ឲ្យដំណឹងយើង ។ គាប់ចិត្តណាស់ហើយ ហេតុដែលល្អនឹងគាត្រាក់នោះ
ក៏តាមបុណ្យ តាមកម្មរបស់ខ្លួនតសាងមក ខ្ញុំមិនត្រូវសង្ស័យអ្វីទូលឡើយ
ហើយទូលពីកំណើតដៀតដល់ស្រុកស៊ុន់ដៀតំនុកបំរុងអាណាប្រជាពស្ត្រ
ដោយសុចរិតយុត្តិធម៌ បណ្តាមហាជនតំងពួងក៏មានចិត្តស្រឡាញ់ពាក់អាន
ទូលពីជាច្រើន ឯអ៊ីដៀតំតែងតៅមករកទូលពីជានិរន្តរ៍ ។

សម័យនោះ ព្រះចៅហៀនតេ ស្តេចតៅប្រថាប់តង់តុងត្រួងហ៊ូគោ
បាន ១២ ឆ្នាំ ឯនាងតាំហ៊ូយិន ដែលជាភរិយាទូលពីក៏មានគតិចាស់ទៃ
លុះដល់ទៃមាយខាងខ្ចីត ពេលតណ្តាលអង្រាត្រ នាងតាំហ៊ូយិនបាន
ឮសំឡេងសត្វវាយុកស្ង ស្រែកត្រងំដំបូលពីលើប្រហែល ៤០ ម៉ាត់ ហើយ
ហើរស្រែកចេញពីទិសបស្ចិម មានកូនត្រឿងក្រអូបបណ្តាលធុំក្រឡប់អប់
ចេញក្នុងទីលំនៅ ហើយនាងតាំហ៊ូយិនក៏ប្រសូតបុត្រប្រុសចេញមក កាល
នាងតាំហ៊ូយិនមាគតិជាដំបូងនោះ មានន័យក្តីថា "អាកៅ" ព្រោះពាក្យ
ថា "អាកៅ" នោះតាសាចិនហៅថាផ្កាយក្រពើ ខណៈនោះ ទូលពី
ដឹងដំណឹងថា ចូរធ្វើលើកទ័ពតៅអាណាខែត្រខាងទិសទុត្តរទៀត ទូល

ពីកំចូលទៅស្រុកកេងដ៏វែ ហើយច្រាប់ឡៅប៉ៃវ៉ាថា ឥឡូវចូរឆ្លៀតកងទ័ពទៅអាណាខែត្រខាងទិសឧត្តរខៀត ខ្ញុំចង់ទទួលកេណ្ឌពលយោធា ក្នុងស្រុកកេងដ៏វែនឹងស្រុកចំណុះឲ្យអស់រលីង លើកទៅវាយយកស្រុកហ៊ីគោ ឃើញថានឹងបានដោយងាយ ។ ឡៅប៉ៃវែតបថា ខែត្រយើងមានស្រុកចំណុះដល់ ៩ មណ្ឌល កំលុំមជាសុខហើយ ដែលនឹងរិះគិតរំលងទៅយកស្រុកគេឯខៀត ធ្វើឲ្យអន្តរាយដល់សេចក្តីសុខរបស់គេផងមិនគួរទេ បើគេលើកមកប្រទូស្តរាយយើងមុននោះ សឹមយើងរិះគិតការពាររក្សាស្រុក ឲ្យបានសុខសាន្តស្រួលជាង ឡៅពីកំមិនបានធ្វើយតបជាអ្វី ឡៅប៉ៃវែតំនាំឡៅពីចូលទៅបរិភោគអាហារខាងក្នុង ។

ខណៈកាលកំពុងបរិភោគនោះ ឡៅប៉ៃវែតំដកដង្ហើមធំ ឡៅពីសួរថា លោកមានសេចក្តីព្រួយចិត្តពីអ្វី ទើបដកដង្ហើមធំដូចោះ ឡៅប៉ៃវែឆ្លើយថា បងមានសេចក្តីព្រួយរំខាន ក្នុងចិត្តជាទីបំផុត ដែលនឹងចាប់ដកយកមកបង្ហាញនោះមិនកើត ឡៅពីកំអង្វរថា សេចក្តីទុក្ខរបស់លោកនោះយ៉ាងណា ចូរមានប្រសាសន៍មកឲ្យខ្ញុំដឹងផងចុះ ។ ទទួលឡៅប៉ៃវែក្រែឡៅពីយើញនាងឈូរហ៊ួយិនជាកំរោអើតមុខចេញមក ឡៅប៉ៃវែតំគ្រវីក្បាលឲ្យឡៅពី លុះបរិភោគអាហារបួច ឡៅពីកំលាឡៅប៉ៃវែត្រឡប់ទៅស្រុកសុិនអៀ ទទួលក្តាំដណឹងថា ចូរឆ្លៀតកងទ័ពបកត្រឡប់

មកស្រុកហ៊ូគោវិញ ខ្ញុំភ័ន្តកស្តាយណាស់អង្គុយដកដង្ហើមធំ ព្រោះខ្ញុំប៉ៅមិនព្រមធ្វើតាមគំនិត ប្រសិនបើលើកកងទ័ពទៅក្នុងវេលាដែលគិតនោះគឺនឹងវាយយកស្រុកហ៊ូគោបានយ៉ាងស្រួល ។

ខណៈនោះ មានបំរើសេះមកប្រាប់ខ្ញុំពីថា ខ្ញុំប៉ៅឲ្យអញ្ជើញទៅស្រុកកេងដែរ នោះខ្ញុំពីក៏ចូលទៅ ដល់ហើយក៏គំនាប់ខ្ញុំប៉ៅហើយថា ដែលឲ្យហៅខ្ញុំមកដោយហេតុអ្វី ? ។ ខ្ញុំប៉ៅប្រាប់ថា គាលបួនឱយាយឲ្យបងលើកកងទ័ពទៅវាយស្រុកហ៊ូគោនោះ បងក៏មិនយល់ព្រមព្រោះបងគិតខុស ឥឡូវបងឮដំណឹងថា ចូរឲ្យលើកទ័ពត្រឡប់ចូលមកស្រុកហ៊ូគោវិញហើយ កំពុងរិះគិតនឹងលើកទ័ពមកវាយស្រុកយើងទៀត ។ ខ្ញុំពីតបថា លោកនឹងប្រញាប់តូចចិត្តថ្លៃការនោះមិនគួរទេ ព្រោះក្នុងសម័យនេះផែនដីកំពុងតែកើតចលាចលខ្លាំងណាស់ បើចូរឲ្យលើកទៅធ្វើការសឹកទៅដំបន់ឯណា យើងមើលទៅយើញបានការហើយ សឹមលើកកងទ័ពទៅចាំមវាយយកស្រុកហ៊ូគោ ក៏គង់តែនឹងបាន ខ្ញុំប៉ៅយល់យើញថា ស្រួលក៏និយាយថាដែលបួនគិតនេះ យើញថាគួរណាស់ហើយក៏នាំខ្ញុំពីចូលទៅបរិភោគអាហារ កាលដែលកំពុងបរិភោគអាហារសេពស្រា នោះខ្ញុំប៉ៅក៏យំសោក ខ្ញុំពីយើញដូច្នោះក៏សួរថា ហេតុម្តេចបានជាលោកចេះតែយំសោកសៅច្រើនម្ល៉ះ ? ខ្ញុំប៉ៅតបថា

សេចក្តីទុក្ខក្តៅក្តួលក្នុងទ្រង់បង្ហាញសព្វថ្ងៃនេះ ជាទម្ងន់ខ្លាំងណាស់ តាលមុន
នោះបួនសួរសាកវៀបតែនឹងនិយាយប្រាប់ តំប្រាប់មិនទាន់ ឡៅតាំថារឿង
ទុក្ខរបស់លោកនោះដាយ៉ាងម្តេច ? ចូរប្រាប់ឲ្យខ្ញុំដំណងផងចុះ ទោះបីបើ
លោកត្រូវការមើងប្រើប្រាស់ឲ្យខ្ញុំទៀងណាក្តី ខ្ញុំតំត្រូវទទួលអាសាគ្រា
តែអស់ជីវិត ។

ឡៅប៉ៀនិយាថា នាងកាន់ស៊ីជាតរំយោធំរបស់បង ដែលស្លាប់ទៅ
ហើយនោះ មានបុត្រម្នាក់ឈ្មោះឡៅគី មានប្រាជ្ញាឆ្លៀវឆ្លាតណាស់
តែជាមនុស្សចិត្តទន់ បើនឹងគិតការអ្វីក៏មិនរហូតទៅបាន ឯឡៅចុងបុត្រ
នាងឈ្មោះហ៊ូយិនជាតរំយោបងសព្វថ្ងៃនេះ មានប្រាជ្ញាស្មារតីឆ្លាត បើនឹង
គិតការអ្វីក៏មាំមួន ល្អជាងឡៅគីជាបង ឥឡូវបងគិតថានឹងឲ្យឡៅចុង
ឆ្លើជាចៅហ្វាយស្រុក ដំនួសបង តែខ្លាចខ្លុសចំណាប់ចំនៀមបុរាណ
មនុស្សគាំងពួងនឹងគរហានិន្ទាបាន បើនឹងតាំងឡៅគីជាបងវិញ ឲ្យឆ្លើ
ចៅហ្វាយស្រុកនេះតាមប្រពៃណី តំខ្លាចញាតិសន្តានបងប្អូនងាយ
ឈ្លោះប្រយុទ្ធ ដែលឆ្លើជានាម៉ឺនមុខមន្ត្រី តួនស្រុកនេះច្រើនគ្នាមានអាឃាត
ញាក់ចុងមិនបានសេចក្តីសុខ ព្រោះបណ្តាខ្លាំងជាតូចចាប តំនៅក្រោម
បង្គាប់ បើអត់ពីបងទៅតនឹងតើតអន្តរាយដល់ឡៅគី ហេតុដូច្នេះបានជា
បងតើតទុក្ខព្រួយពេកណាស់ ឡៅពីតបថា ដែលលោកនឹងឲ្យបុត្រទៅ

ធ្វើចៅហ្វាយស្រុកមុនបុត្រឆ្ងន់នោះមិនគួរ បើជាអារម្មណ៍ខ្ញុំចង្រៃឆ្ងន់ញាតិសាលោហិតនាងឈួហ៊ួយិនទឹងប៉ងប្រទូស្តភាយឡៅគីនោះត្រូវរិះគិតផ្លូវសង្គ្រោះកំឡាំងមនុស្សពួកនោះចេញខ្លះឲ្យបានស្រាលស្តើង រួចសឹមតាំងឡៅគីជាចៅហ្វាយស្រុកដំនួសលោក ទើបមិនមានអន្តរាយ ឡៅប៉ៃវ៉ៃបានស្តាប់ហើយក៏ញាក់មុខយំឡៃត ។

ឯនាងឈួហ៊ួយិននៅឯបន្ទប់ពីខាងក្នុង លុះបានឮឡៅប៉ៃវ៉ៃនិងឡៅពីនិយាគ្នាដូច្នោះ ក៏មានសេចក្តីខឹងក្តៅនឹងឡៅពីពន់ប្រមាណណាស់ ឡៅពីនិយាយនឹងឡៅប៉ៃវ៉ៃហើយក៏ត្រឡប់គិតឃើញ ខ្ញុំចនាងឈួហ៊ួយិនមកឯបន្ទប់ឮ ទើបភ្លែងធ្វើជាក្រោកឡើងគំនាប់ឡៅប៉ៃវ៉ៃហើយថា ខ្ញុំបាទសូមលាលោកចេញទៅក្រៅ ១ រំពេច ឡៅពីធ្វើជាយំហើយក៏ត្រឡប់ចូលមកវិញ ឡៅប៉ៃវ៉ៃឃើញដូច្នោះក៏សួរឡៅពីថា ហេតុអ្វីបានជាឯងយំ ឡៅពីភ្លែងក្រាប់ថា ខ្ញុំបាទដឹងសេះគ្រាណាទើបងប្អូយក៏បែកចេញលោហិតហូរដាជកបរក្បាក៏ជាសះទៅវិញ រំលេងនេះខ្ញុំបាទដឹងសេះមិនឈប់ជាយូរពេក ក៏បែករលួយអស់ទៅឡៃត ខ្ញុំបាទឃើញថាអាយុនឹងអស់ត្រឹមណោះហើយ ប្រាំហាលមិនបានរស់នៅទំនុកបំរុងផែនដីតទៅឡៃតទេ បានជាខ្ញុំបាទយំអាណិតខ្លួនដោយហេតុនេះ ។ ឡៅប៉ៃវ៉ៃថា កាលគ្រាឯងទៅនៅស្រុកហ៊ូគោនោះ បងឮដំណឹងមកថា មួយថ្ងៃនោះ ចូរ

ន័ងបួនទៅជីកស្រាស៊ីផ្ទៃស្តុំ (ឬកន្ត) ជាមួយគ្នាក្នុងសួន ចួតួស៊ូរ
ថា ចៅហ្វាយស្រុកទេសឯណា មានសត្តបញ្ញាខ្លាំងពូកែ ? បួនកំប៉ាន
បរិយាយប្រាប់ចួតួថា មានជារ៉ាប់ខែត្រ ចួតួមិនយល់ព្រមផង
ហើយថា ក្នុងស្រុកក្រែងនឹងអាណាខែត្រក្រៅពាំងពួននោះ នឹងរកអ្នកឯណា
ឲ្យមានសត្តបញ្ញាជ្រៅជ្រួលយ ដូចចួតួនឹងបួននោះគ្មានសោះ ព្រោះ
ចួតួនោះ មានគំនិតនេះ គិតជ្រៅជ្រួលយពាន់ឆ្នាំសេនាឥហាន ក៏មានថ្លឹងដៃ
ខ្លាំងពូកែប្រើន ក៏នៅតែមិនអាចលើកខ្លួនថាល្អលើសជាងបួន ហេតុម្តេចក៏
បួននឹងមកគិតគោតញ៉ើតខ្លាច នឹងមិនបានទំនុកបម្រុងដែនដីដូច្នេះ ។

ខណៈនោះ ខ្លៅពីជីកស្រាស្រាប់ណាស់ លុះខ្លៅបៀរ និយាយ
ដូច្នោះ ក៏មានចិត្តកំរើកដោយអំណាចស្រាប់ និយាយតបថា ខ្ញុំ
ចាខគាំងក្លាមហាន ជាទីខ្លាចខ្លួនបានហើយ នឹងទៅខ្លាចអ្វីនៃអាណាខែត្រ
ពាំងអស់នោះ ឧបមាដូចកូនមាន់នៅក្នុងកណ្តាប់ដៃខ្ញុំចាខ ខ្លៅបៀរ
បានស្តាប់ ក៏មិនបានតបថាប្រការម្តេច ។ ខ្លៅពីលង់សំដីប៉ុណ្ណោះគិតគិត
ឃើញថា ចាចានេះមិនស្រួលលើសហួសការ ក៏ធ្វើជាស្រាប់ខ្លាំងហើយ
លាខ្លៅបៀរទៅគាន់ទីដំណាក់ក្នុងស្រុកគេនឹងដើរ ។

(មានត)

ភាសាភាស

សុំឲ្យ.ហ៊ាង

ចម្លងចេញពីសាស្ត្រាស្នាក់រាត

អហំនមា-មិសិរសា សុសម្ពុទ្ធំ លោកជាថ ធម្មមលំ
អដ្ឋតលាំ បុញ្ញក្ខេត្តា ។ យើងខ្ញុំនអង្គ វន្ទាឆ្ពោះត្រង់ ព្រះ
សម្ពុទ្ធា ព្រះអង្គគ្រាស់ត្រេច សម្រេចបរមា- កិសេកព្រមប្រាំ- កដកើត
ក្នុងលោក ។ ព្រះអង្គនិរទុក្ខ និរព័យបានសុខ ហើយមានជ័យជោគ ជា
ទីពឹងមាំ នាំសត្វចាកលោក ប្រាប់ផ្លូវបថមោក្ខ គឺនិព្វានពិត ។ ហើយ
ខ្ញុំវន្ទា ឆ្ពោះព្រះធម្ម ដែលព្រះទ្រង់រិទ្ធិ ខ្ញុំនាំនប្រជោ នាំសត្វប្រព្រឹត្ត
កាយវាចាចិត្ត ចាកមន្ទិលបង់ ។ ហើយខ្ញុំវន្ទា ឆ្ពោះព្រះគណា អរិយសង្ឃ
មានពួកប្រាំបី ហប្តូយផ្លូវផង់ ជាខេត្តបុណ្យត្រង់ ដល់សត្វត្រូវការ ។
តេជះយើងខ្ញុំ ក្រាបថ្វាយបង្គំ ដោយនូវវៀហារ ឆ្ពោះព្រះត្តត្រ័យ ថ្វា
ថ្ងៃអស្ចារ្យ មានពាប្រការ ដោយចិត្តសាទរ ។ សូមកើតសិរី មង្គល
សួស្តី ជោគជ័យនូវពរ ចូរមកប្រសិទ្ធិ ដោយចិត្តត្រេកអរ ចៀសក្តី
អន្តរ- ជានផង់ពាំងឡាយ ។ ហើយខ្ញុំសូមថ្លែង សេចក្តីលើកតែង ជាពាក្យ
អក្ខរាយ តាំងខុតជាច្បាប់ សម្រាប់រូបកាយ ដើម្បីទឹងផ្សាយ ក្នុងពុទ្ធ

សាសនា ។ ទេះនឹងសាស័ព្ទ លើតែងជាប្លាប់ សម្រាប់សិក្សា ខុក
គ្រាន់កុលបុត្រ រៀនពិចារណា លះបង់ធម្មតា ប្រគាន់តាមត្រូវ ។ គួរតែ
ប្រតិបត្តិ អាក្រក់គួរគាត់ ប្រគាន់តាមផ្លូវ ណាជាប្រយោជន៍ សិក្សាយក
ទៅ ខុកគ្រាន់ប្រដៅ ខ្លួនជាបុរស ។ ថោកស្រេចនូវលួងំ ថោកពូជ
ថោកពន្យឺ ថោកទ្រព្យរបស់ បើមានតិចតួច ថោកចាបចាំងអស់ ថោក
ក្តើរថោកឈ្មោះ សូន្យសោះអស្ចារ ។ ថ្ងៃស្រេចនូវចេះ អំណាចចំណេះ
ចេះគ្រប់ប្រការ ថ្កើងពូជះថ្កើងពន្យឺ វង្សត្រកូអាចារ្យ ខ្ពស់មុខអស្ចារ្យ ថ្កើង
លើសតន្ទឹង ។ ថោកផុតនូវលួងំ ថោកពូជថោកពន្យឺ ដល់តួជាម្ចាង
ថ្ងៃផុតនូវចេះ វិជ្ជាធម៌ផង ថ្ងៃសុខឥតហ្មង ថ្កើងញាតិកា ។ ចេះមក
ពីរៀន ចំណេះរបៀន មកពីទស្សាហ៍ ព្យាយាមសន្សំ ធនបុណ្យអាត្ម
មានលាភលក្ខណា ក្រោះសាងពីព្រេង ។ ត្រូវខំរក្សា ដឹងគុណមាតា
នូវបិតាឯង គុណគ្រូអាចារ្យ ច្រើនថ្នាក់កោតក្រែង ខំស្រុះខំស្រែង រកគុណ
តបគុណ ។ ត្រូវពាប់អានញាតិ សាលោហិតជាតិ គាន់ចិត្តឲ្យធ្ងន់
រួសពាប់សួរសាក រាក់ទាក់ជាមុន នូវអស់មហាជន កុំឲ្យមានទោស ។
ពោលនឹងអកផង ដឹងប្លួនដឹងបង កុំធ្វើតោសម៉ោស ធនិតាស់ព្រឺក្នា
ជាតជាសន្តោស កុំឲ្យមានទោស សមគួរទើបគាប់ ។ ពេះបីមិត្រក័ត្តិ
បើជួយធុរៈ កុំច្រាច្បាស់ទ្រព្យ ឲ្យតែសុចរិត ផ្សាយចិត្តកេរប់- អានឲ្យបាន

ជាប់ ជាមិត្តមេត្រី ។ អ្នកស្រុកដឹតខាង គិតគួរជាអាង ចោះប្រុស ចោះស្រី ញាតិទីដ៏យើងអត់ កុំអាលស្រដី ក្រែងកើតអប្រិយ ចោសនឹងអាត្មា ។ ខុសពាប់ជាមិត្រ សម្លាញ់ពិត ។ មានបសំសា នឹងខ្ញុំឯងជាយ ដោយក្តីស្នេហា បបួលសិក្សា សុចរិតតាមខ្លួន ។ ចៀសពាលកុំគប់ កុំដើរលេងយប់ ដូចចោរក្រែងជួន មានគ្រោះមានថ្នាក់ ខាតលំភូណ៌យ៉ាងមួន នឹងខូចឈ្មោះខ្លួន គេថាអាក្រក់ ។ កុំសេពសុក កុំគាន់ភ័យ ព្រហើនតក់ម៉ក់ កុំលើកខ្លួនឯង ក្លែងក្លូតកុហក កុំលួចកុំឆក់ របស់ទ្រព្យគេ ។ កុំឆ្គួតដោយស្រី ប្រពន្ធគេក្តី ស៊ូនៅឲទេ កុំសម្លាប់សត្វ ឲ្យបង់ជីវ៉ៅ កុំពោលពាក្យដេរ ប្រមាទមើលងាយ ។ រៀនគោតខ្ចាចចាស់ ជួបជៀសរហ័ស គោរពនិយាយ ស្មោះស្មោនគួរសម កុំលេញរលង់ លាយ ដោយពាក្យសម្ដុយ ពាយងាយឥតខ្លាត ។ ត្រូវរក្សាផ្ទះ ចូរកចាំផ្តម្រះ ចោសច្រាសសំអាត ទីយប់ទីថ្ងៃ កុំធ្វេសប្រមាទ ដួសដុលសំអាត កុំឲ្យពាយមាយ ។ រៀនផ្គត់មារយាទ កុំតែងហួសជាតិ ហើយរៀននិយាយ តាមគួរអក្ខរៈ ឮញ៉ែនៈចាំងឮាយ រៀនស្រៈសម្រាយ ខ្ចូវស្រៈចាំលី ។ កុមារពាល់គ្នា រៀនច្បាប់នេះជា វិសេសគប្បី ប្រឹងខំសិក្សាសាស្ត្រាចាំលី ចោលឫកអប្រិយ រៀនស្រឡាញ់វត្ត ។ ចូលរៀនសាលាគោងខំទស្សាហ៍ គោរពប្រតិបត្តិ ចូលរៀនតាមពេល ដែលគ្រូបញ្ជត្ត

ពន្យល់ឲ្យហាត់ ច្បាប់ផងចាំផងឡាយ ។ កុំធ្វើជូរជាតិ ជូរឥតមានយោគ
ដោយឫកពាយមាយ ជឿងធុរៈគ្រូ តែតគួរក្រែងាយ គោរពនិយាយ ដោយ
វត្តប្រតិបត្តិ ។ គេលព្រឹកកាលណា ចោសច្រាសសាលា រៀនរ៉ៀបរៀប
ចាត់ ខំទុកបំរុង ប្រៀនប្រុងប្រយ័ត កន្លោះខឹតមាត់ ចាត់លាងប្រក្រតី ។
រៀបស្រេចចូលរៀន តាមគ្រូប្រិតៈប្រៀន រិដ្ឋាអ្វី ។ ក្លែកមើលមាត់ថា
ប្រុងជ្រាវផងវៃ ស្មារតីប្រពៃ កួចតតសញ្ញា ។ ដៃហាត់សរសេរ អក្សរ
ខេមរ មូលជ្រៀងផងណា ឲ្យល្អត្រឹមត្រូវ តួពងអក្ខរ ហើយទំសក្សា
ចំណេះតទៅ ។ រៀនលេខនព្វន្ត ឲ្យស្ទាត់ហ្មាតគុន លុបលេខត្រឹមត្រូវ
រៀនបូកចំណោម ដោះចោមតម្រូវ សងចែកខៀតទៅ ឲ្យចេះចាំស្ទាត់ ។
បើបាទៅផ្ទះ រៀនរៀបរហ័ស ដូចកាលនៅវត្ត ចំណេះរៀនបាន. អាន
ឲ្យត់មាត់ ហើយទំប្រតិបត្តិ មាតាបិតា ។ តើតមកជាមនុស្ស តោងដឹងគុ
ត្រូវទុស ដោយពិចារណា រិះគិតឲ្យឃើញ ថ្លៃសគល់អាត្មា គឺគុណមាតា
បិតាស្ងួនត្រង់ ។ មាតាបិតា ខ្ពស់លើសសិរសា កាលដើមនោះហោង
អស់យើងចាប់ផ្តែ ក្រៃក្រែតន្ទុង ឯបិតាផង ដឹងដោយមាតា ។ តាំង
រៀបដំកល់ គ្រឿងរក្សាគត់ បង្ខាំងញាប់ញ័ល យកខ្នងព័ទ្ធរង ធុរៈមាតា
ព្រោះចិត្តមេត្តា កួនទៅក្នុងផ្តែ ។ សោតឯមាតា កាលទំងរក្សា គត់
តម្រៃក្រៃ មិនហានបរិភោគ តាមចង់អស្រ័យ ល្ងីងហឺរផ្ទៃប្រៃ ក្រែងកួន

ពុំសុខ ។ លុះគ្រប់ខែហើយ កាលណោះអ្នកអើយ អ្នកម្តាយមានទុក្ខ
កាលនឹងប្រសូត្រ កិតភ័យស្លុតមុខ ឈឺញាប់ផ្អក ។ ស្ទើរស្លាប់ស្ទើរខ ។
ខន់អស់ពាំនាំក្រហែ ពាក្យពីបូពណ ហៅធ្លុនខន្ទេ ខ្យល់បក់ខ្យៃបលិច
ក្រនឹងផ្តួចផ្តើរ រួចដោយបុព្វ គ្មានពៀរវេរ ។ រួចរាល់សព្វគ្រប់
ញ៉ាំខ្លួនចំប្រប់ ឈឺហួសឧបមា បើនឹងបានក្សាន្ត ដោយចិត្តកុណា
អស់ញាតិកា ដួបជុំជួយខប់ ។ លុះកូនដឹងក្តី ពោះប្រុសពោះស្រី យើង
គេពាំនាំគ្រប់ មាតាបិតា រក្សាថ្នាក់ថ្នម ពាំនាំថ្ងៃពាំនាយប់ ដោយចិត្តមុទិតា ។
លុះបានធំឡើង ដូចជារូបយើង មាតាបិតា ខ្វល់តាមសង្រ្កែះ ដោយចិត្ត
ទេក្ខា អ្នករៀនសិក្សា ត្រូវធ្វើតបគុណ ។ មាតាបិតា បីបាច់រក្សា ឧប-
ការជាមុន ផ្សាយព្រហ្មវិហារ គុណជាខន្ធ ដៃអស់មហាជន ចូរដឹងចំ
ពោះ ។ មាតាបិតា មានចិត្តស្នេហា ឈ្មោះថាសង្រ្កែះ ឲ្យបានចំរើន
គ្រប់រូបគ្រប់ឈ្មោះ ដោយហេតុពាំនោះ មាន ៥ បទថា: ។ ១ ហាម
ដាច់ មិនឲ្យធ្វើបាប មិនឲ្យផឹកស្រា ហាមសម្លាប់សត្វ ហាមលួចទ្រព្យា
ហាមលួចភរិយា ហាមស្តីកុហក ។ ២ នាំដំកល់ ឲ្យធ្វើកុសល រៀ
កម្មអក្រក់ ឲ្យចេះគោរព លោកសង្ឃឫបាសក ឲ្យនាំពាយក ធ្វើការកុ-
សល ។ ៣_នាំឲ្យរៀន ចំណេះរបៀន ឲ្យមានកង្វល់ ក្នុងសិល្បសាស្ត្រ
សង្ឃឹតដំកល់ នាំទុកដាក់ដល់ ដៃគ្រូបង្ហាត់ ។ ៤_រើសរកមៀប ត្រ

កូលរបៀប មានទ្រព្យសម្បត្តិ ហើយរៀបមង្គល ខ្ចាយទ្រលំចែនចាត់
នាំកូនសណ្តែត ក្នុងត្រកូលទុតម ។ ៤ រៃរកចែក ឲ្យបានចំណែក យ៉ាន
ទ្រព្យគួរសម ជារស្រែចំការ គោសេះតូចធំ ទំរកសន្សំ មត៌កទុកឲ្យ ។
ពាក្យនេះគួរស្តាប់ ប្រាជ្ញប្រដៅប្រុប់ កូនចៅខាងក្រោយ បានរៀនចែន
ចាត់ ប្រតិបត្តិកុំខ្ជោយ កុំខ្ជាប់បណ្តោយ បណ្តែតរវេ ។ ចូរចៅប្រុន
ស្តាប់ ប្រាជ្ញនឹងថ្លែងប្រុប់ ប្រដៅគ្រប់គ្នា ឲ្យដឹងឲ្យឃល់ ឬសតល់ធម្ម
មាតាបិតា មែនមានគុណហើយ ។ អ្នកអើយគុណនោះ ស្តាប់ហើយ
គិតចុះ ណាកុមារអើយ គុណព្រោះគ្រប់គ្រង រក្សាយើងហើយ តាំងពី
ដើមឡើយ ទ្រាំទ្រៃថ្លៃ ។ លុះបានកើតមក លាងជូតស្មោកគ្រោក
ជាំជោកនៅដៃ បីបាច់រក្សា ជាអង្គែ្រយ កូនចៅអាស្រ័យ មាតាបិតា ។
ហើយបានផ្សាយចិត្ត មេត្តាអណិត ស្រឡាញ់ករុណា ខន់ខ្ជួនខន់ចិត្ត
ជាមុខិតា មានតំណទបេក្ខា ដល់អស់នាងអ្នក ។ ហើយប្រៀនប្រដៅ
ឲ្យដឹងខុសត្រូវ វិជ្ជារាត់ ។ ឈ្មោះថាគ្រូដើម គុណខ្ពស់ជោយថ្នាក់ យក
អ្វីមកជាក់ ប្រៀបផ្ទឹមពុំបាន ។ មានតែគុណគ្រូ អ្នកប្រាជ្ញលោកផ្ទ
តាំងពីបូពណ ថាគុណតំងបី ទុកស្មើមួយប្រាណ ព្រោះគ្រូលោកបាន
ប្រដៅធម្ម ។ ឲ្យចេះប្រតិបត្តិ នាំសិស្សសណ្តែត ក្នុងផ្លូវសួគ៌ សម្បត្តិ
មនុស្សលោក យកទុកអង្គា សន្សំទុកជា បច្ច័យនិព្វាន ។ តីចេះពី

គ្រូ ចេះគិតចេះគូ រក្សាសីលធាន ចំណេះលោកិយ តង់សម្រេចបាន ប្រយោជន៍មិនខាន លួមគិតតាំងត ។ គ្រូមានគុណខ្ពស់ ជាអ្នកសង្គ្រោះ ច្រាប់ផ្លូវគម្រ ដូចអ្នកភ្នែកភ្លឺ សង្គ្រោះអ្នកក្រ ច្រាប់កំណាប់ល្អ ឲ្យចាយ ប្រើច្រាស់ ។ ចូរច្បាដឹងគុណ គ្រូជាទម្ងន់ ខ្ពស់ស្មើអាកាស ឲ្យដួយធុរៈ កុំធ្វើផ្តេសផ្តាស ច្រាដ្បរប្រៀបប្រកាស ឲ្យដឹងគ្រប់គ្នា ។ ចូរបាគោរព ប្រតិ-បត្តិលើសល្អប ហើយធ្វើប្តេជ្ញា ឲ្យលោកអត់ទោស បវរណា ដួនក្រែងអាត្មា ខុសគាប់ជាក្រោយ ។ ឲ្យលោកវិលឹក ទោះយប់ទោះព្រឹក កុំព្រមបណ្តោយ ដ្បិតខ្លួនចេះតិច ធ្វើការច្រើនគ្រោយ សូមលោកថាឲ្យ ត្រឹមត្រូវតទៅ ។ កុមារទំរៀន ចំណេះរបៀន កំពាត់ល្ងង់ខ្លៅ ទំនងបានចំរើន រុងរឿងខ្លួនឋា ថ្កើងដល់ញាតិផៅ បងប្អូនពាំងអស់ ។ ធម្មតាមនុស្សល្ងង់ ថោកទាបពូជពង្ស គ្មានទ្រព្យរបស់ លួងដូចតិរច្ឆាន គ្មានប្រយោជន៍សោះ សាបសូន្យពាំងអស់ គ្មានយសសក្តា ។ យល់ឃុំសថាត្រូវ ឃើញលំអានផ្លូវ ស្មានជាបន្ទូ ដើរចៀសផៅដួន ព្រៃមានតាស់ភ្លឺ លំបាកអាត្មា ដួនដល់អន្តរាយ ។ លួងឥតគេរាប់ ច្រើនវិនាសទ្រព្យ អាត្រកំរបូកាយ ពុំសូវដឹងគុណ លោកម្តាយញាតិផង ពាំងឡាយ មិនយកជាគ្នា ។ លួងគ្មានប្រព្រឹត្ត មិនចេះរិះគិត គន្ធង់ធម្មា ដូចសត្វកង្កែប ជ្រកក្រោមបឹងមា គ្មានបានគន្ធា អប់អង្គលំអ ។

ល្ងង់ព្រោះមិនរៀន កំដៅអៀនប្រៀន ដូរជាតិរៀចវែ មិនចំទន្ទេញ
លេងលេញកូតកវ ស្មៀមដូចមនុស្សគ បង្អាប់មុខខ្លួន ។ អាប់មុខព្រោះ
ខ្លៃល, ខ្លៃលជាមន្ទិល ដូចសត្វវែះពួន រកស៊ីតាំងតែយ អប្រិយយ៉ាងមួន
កុំយកជាក់ខ្លួន កុមារពាល់គ្នា ។ ហ៊ីនល័ក្ខណ៍មាន ៣ ពោះប្រុសពោះ
ស្រី តើតក្តីលោភ អនិមន្តិតំ យរំ តន្តា អធិប្បាយប្រែថា ជាមនុស្ស
ខាតល័ក្ខណ៍ ។ ឥតគេហៅកេ ចេះតែទៅមក មិនស្គាល់ជ្រុះ គេមិន
ពាប់អាន ឯងធ្វើពាក់ពាក់ ក្អែកក្តីដូចខ្វាក់ ទៅមកឥតស្រាក ។ អប្បុច្ចកា
បរំមុខ្ញា ឥតគេស្ងួរសាក ធ្វើយតែខ្លួនឯង ចចាកអាពក គោក ។ កាក។
លើកខ្លួនប្រសើរ ។ អត្តានញ្ច, បសំសាសៈ គ្មានគេសរសើរ អួត
តែខ្លួនឯង ខ្ពស់សព្វជំណើរ ដើកអង្គុយដើរ សរសើរតែខ្លួន ។ នេះ
ហៅខាតល័ក្ខណ៍ ខាតយសខាតស័ក្តិ គ្មានមាំគ្មានមួន ពុកជាចេះច្រើន
ថោកតេញសំនួន កុំយកជាក់ខ្លួន កុមារពាល់គ្នា ។ ត្រូវថ្នមចិត្ត
ញាតិ សន្តានជាប់ជាតិ ផ្សាយចិត្តឲ្យជា ពាប់រកគួរសម ដោយ
នៅអធ្យា. ស្រ័យស្រួលរក្សា ដោយក្តីគួរសម ។ ញាតិខ្ពើយើង
អត់ ឲ្យបានលត់ ពុកជាទិយម ខ្លួនឲ្យបាន ដោយអត់ជាធំ
ហៅចិត្តចេះគ្រាំ អត់គ្នាខ្លួនាន ។ បើញាតិតំណាញ់ យើងធ្វើអស់អញ
ដោយឲ្យជនជាន ឲ្យញាតិខ្ចាចចិត្ត តើតជាពាប់អាន ខ្លួនាន ឲ្យបាន

រតឹតជាពាប់រក ។ យើញញាតិទ្រគោះ ស្តីលេងលេះលោះ កុហកកូតក
យើងស្តីទៀងមែន ដោយពាក្យពិតល្អ ជាពាក្យប្រៀនប្រ-ដៅញាតិ-
ឲ្យបាន ។ ឯអស្បប្បរស មិនដឹងធម៌ខ្ពស់ ធ្លើចិត្តឲ្យក្សត្ត សម្តែងសំប្ប-
រស ពាំងអស់រាប់អាន ដោយរឿងនិទាន ខូន្ទានឲ្យដឹង ។ នាគាមគោជក
ជាមេការស្រុក កុំធ្វើឲ្យខឹង យកចិត្តទុកជាក់ អ្នកជូនដំណឹង គ្រាន់តែង-
ពាក់ពីង ទើបបានជាសុខ ។ កុំអួតចំណេះ កុំដៀលកុំតិះ ដល់ម្តាយ-
ឪពុក កុំអួតទ្រព្យធន កុំតុះឈ្មោះស្រុក កុំអួតក្តីសុខ ជាងអ្នកដទៃ ។
ចូរស្តាប់ច្បាប់នេះ ចូរឿនឲ្យចេះ រំពឹងរំពៃ ច្បាប់នេះស្មើទ្រព្យ គាប់-
មានតម្លៃ រក្សាសព្វថៃ្ង ដោយចិត្តជាក់ទុក ។ ឲ្យរៀនគួរសម ស្គាល់-
គួចស្គាល់ធំ ស្គាល់ល្អអាក្រក់ ស្គាល់ដូរស្គាល់ជា ស្គាល់សង្ឃថ្លាសក
ស្គាល់អ្នកមានមុខ ស្គាល់ច្រាជស្គាល់ខ្លៅ ។ បើភ្ញៀវមកផ្ទះ ខ្ទួលរហ័ស
រួសរាន់ចៅអើ សាកសួរសុខទុក្ខ សួរទីលំនៅ រៀបឲ្យតាមត្រូវ
ការគេមកម្តង ។ ឲ្យចាយចំណី ពោះប្រុសពោះស្រី ស្រដីសាសង ឲ្យ
ល្មមពេញចិត្ត តាមប្អូនតាមបង សួរពីបំណង ច្រាំថ្នាការអ្វី ។ បើភ្ញៀវ
លាទៅ ជូនបង្ហាញផ្លូវ ដើរជោយគប្បី មានទ្រព្យគួរឲ្យ ដោយគួរសំដី
ទុកជាមេត្រី ឲ្យមានសរសើរ ។ បើជួបដោយប្រពៃ ឬស្រុកគេនៃ ជាអ្នក-
ដំណើរ ដូចគ្នាគួរស្និទ្ធ ធ្លើស្និទ្ធសួរសុខ អង្គុយឬដើរ សមគួរតាមកេរ ។

បើនឹងហៅកេ ទៅវិញទៅមក ឲ្យសមតាមហេតុ ចាស់ហៅតាមចាស់ ឲ្យច្បាស់ដោយនេត្រ បើល្មមស្មើគេ សន្មតជាបង ។ ក្មេងហៅនាងអ្នក ឬក្មួយស្មោះស្ម័គ្រ ដោយបញ្ញាចង មនុស្សគោចឲ្យជា ចូលចិត្តមកផង សសោះអន្ទង ប្រជៀតធម្មា ។ បើអ្នកណាមាន ព្យាយាមសិលាន ទ្រ-ទ្រង់ធុក មានវត្តប្រតិបត្តិ មានចិត្តសទ្ធា ចូលទៅយកជា កល្យាណមិត្រ ។ ត្រូវតាមស្រឡាញ់ ដោយចិត្តអស់អញ ចូលអត្តិយជិត ដើម្បីចំរើន ព្យាយាមពិត ។ បានមកពីមិត្រ ជាជាន់ខ្ពង់ឯង ។ ពាលកុំដំនុំ អត្តិយប្រដុំ ឲ្យពាលថ្នាំថ្នែង ពាលគ្មានចេះធម៌ នាំចេញសំដែង ពាលចេះចាត់ចែង តែខាងខុចិត ។ បើធ្វើដោយកាយ ត្រេកអរសប្បាយ ឧត្តំ សម្ផាប់សត្វ ហើយនឹងលួចទ្រព្យ ចាក់កាប់ទ្រុស្តមិត្រ ប្រពន្ធ-គេពិត ពាលលួចប្រក្រតី ។ ពាលពុតមោហា បើនឹងចរចា ដោយ ពាក្យសំដី តុហកញ៉ុះញ៉ង់ ទ្រគោះអប្រិយ ពាលពោលពាក្យក្តី តែពាក្យ ត្រៃធម៌ ។ ពាលចិត្តអាត្រក់ ព្រហើនតក់ម៉ក់ គ្មានគាំងដំកល់ តិតតែ ចង់ពេស លោភលើសខ្ញុយខ្ញល់ ពាលគ្មានដឹងធម៌ យកទុសជាត្រូវ កូនណើយឪពុក ចាស់ហើយផ្តាំខុក ដល់កូនក្មេងនៅ បើក្មេងខ្លីបខ្លួ គ្មាន មនុស្សដើងត្រូវ សុទ្ធតែពាលនៅ ពេញពាំងខ្លីបនោះ ។ កូនកុំអាល័យ ចេញទៅនៅព្រៃ ផ្រែកដោយកៀនគោះ ប្រព្រឹត្តឯកឯង ជាសប្បុរស

ពួកពាលទាំងនោះ កុំយកជាគ្នា ។ កូនណើយអ្នកប្រាជ្ញ កូនគប្បីអាច
ស្និទ្ធស្នាលសន្តាប់ អ្នកប្រាជ្ញចេះធម៌ ទ្រទ្រង់ធុរៈ កូនសេពគប់ជា ក-
ល្យាណមិត្ត ។ ប្រាជ្ញប្រតិបត្តិត្រូវ គួរកូនចូលទៅ អង្គុយជិតៗ នឹង-
បានចេះធម៌ ស្គាល់ផ្លូវសុចរិត ចំរើនព្រោះដឿត ប្រាជ្ញចេះធម្មា ។ ប្រាជ្ញ
មានប្រតិបត្តិ ចេះធម៌បរមត្ថ សំខាន់ជា។ បើកូនចូលទៅ សាកសួរ-
សន្ទនា ចេះព្រមព្រៀងគ្នា ដូចគល់ញាតិសាច់ ។ បើមិនចេះច្រើន
គង់បានចំរើន សីល ៥ ជាស្រេច បើសេពរឿយ។ ទៅនឹងសម្រេច
ព្រោះប្រាជ្ញមានសច្ច- ធម៌ជាសុចរិត ។ បើនឹងធ្វើការ រឿងបាណាចារ
មិនសម្លាប់សត្វ មិនលួចទ្រព្យគេ ដោយចិត្តទុស្តត្បត់ ប្រាថ្នាបរិសុទ្ធ
រឿងបរទាគា ។ បើនឹងស្រដី ដោយពាក្យគប្បី សុចរិតវាចា មិនកួតកុហក
ញុះញង់ផ្តាសា រឿងផ្សុសវាចា រឿងពាក្យក្រៅធម៌ ។ ថាបើនឹងគិត
ដោយចិត្តប្រព្រឹត្ត រឿងគាំងដំកល់ លោភលើសបុណ្យខ្លួន រឿងឆ-
ោសដល់ សត្វគិតភ្លាយខ្លួ យកខុសជាត្រូវ ។ ប្រាជ្ញគាន់សុចរិត តាយ
វាចាចិត្ត ពន្យល់តាមផ្លូវ គន្ធនឹព្រះពុទ្ធ សុចរិតខុកនៅ បើអ្នកចូលទៅ
ប្រជៅធម៌នោះ ។ ហេតុនោះគួរគប់ អ្នក ប្រាជ្ញជាមួយ គ្រាន់នឹងពិគ្រោះ
ផ្លូវសួគ៌និព្វាន ដឹងបានចំពោះ សេពអ្នកប្រាជ្ញនោះ ខ្ពស់ផុតលោកា ។
ខុកជាស្ងប់ទៅ ហៅថារស់នៅ ដឿតមានចេតនា ជាមគ្គជាផល ដំកល់-

អត្តា ចូរកូនទស្សាហ៍ យកច្រាជ្ជជាមិត្រ ។ ដើម្បីសុខរៀន ដើម្បីចំរើន ប្រយោជន៍ពិតៗ បានពីស្ទួនស្ទាល សេពគប់បណ្ឌិត នឹងបានធ្វើចិត្ត ចុះផ្លូវ អរិយា ។ យើងតែងច្បាប់នេះ ដោយនូវតម្រិះ ចិត្តតាំងច្រាំង ឧកឲ្យ កុលបុត្ត កំណត់សិក្សា ផុតពុទ្ធសាសនា និដ្ឋិតាចប់ហោង ។

ចប់ល្បើតបឋមសិក្សាត្រឹមបុណ្ណោះ ។



សុភាសិតសាសន៍ម៉ែរូ

(តមក)

លោក រ៉ាយ - ប៊ុកិ ជនស្រុងរៀបរៀង

១៨- បើសំពត់រាស្រាស់ ត្រូវប្រើម្ជុលធ្វើពីដែកថែប ។

១៩- បើគេលក់ទឹកដមិតដោយយកកិត្តិយសជាតម្លៃ, បណ្ដិតណា ក៏មិនទិញដែរ ព្រោះថា ស្ងាប់ដោយកិត្តិយសប្រសើរជាងរស់នៅ ដោយខ្មាស់គេ ។

២០- បើឯងមានភោគទ្រព្យ, ចូរគាន់ចិត្តសប្បុរស ដូចដើមគ្លោត បើឯងក្រ ចូរធ្វើចិត្តមានសភាពសើរ ដូចដើមស៊ីប្រៃស៍(១) ។

២១- ធម្មតាសត្វសិង្ហ, បើទុកជាឃ្លានស្មៅរស្ងាប់នៅតែងរួងវ៉ា, តែវាមិនអាស្រ័យរំពោះឆ្អែតទេ ។

២២- បើនាងឯងមានគុណវិបត្តិ៧០យ៉ាង ហើយមានគុណសម្បត្តិតែមួយយ៉ាង, ប្រុសដែលស្រឡាញ់នាង នឹងឃើញតែគុណសម្បត្តិនាងតែម្យ៉ាងប៉ុណ្ណោះ ។

២៣- បើឯងមិនអាចដឹងបានខ្លួវស្ថានភាពស្រមោច នៅក្រោម

| ១ ស៊ីប្រៃស៍ វាគ្មានឆ្អែតទេ តែវាមានពណ៌ខៀវស្រស់ជានិច្ច ។ ដើមនេះជាកេតនភណ្ឌ នៃសេរីភាព ។

ចាទដើន្ធឯន្ធទេ ចូរឯន្ធដឹន្ធថា ស្ថានភាពនោះ ដូចគ្នាន្ធឹន្ធឯន្ធនៅក្រោមដើន្ធ ដំរដូច្នោះ ។

๒๔- កុំឲ្យបង្ហាញចំណេះពាន្ធ៌អស់ ចំពោះកូនសិស្សរបស់ឯន្ធ ។ តើឯន្ធ ន្ធឹន្ធដឹន្ធបានថា ក្នុន្ធកាលអនាគត កូនសិស្សនោះវ៉ា ទៅជាបច្ចាមិត្ត ឯន្ធវិញឬ ។

๒๕- គេយកបុប្ផាកុលាបមកបះសន្ធឹកវ៉ាចោលចេញ តែបន្ធាវ៉ានៅ, គេលួចសម្បត្តិទ្រព្យនៅក្នុន្ធគុហាក្តី តែគេមិនបានសម្ងាប់ពស់នៅក្នុន្ធ គុហានោះទេ ។

๒๖- អ្នកណាមានមាសអ្នកនោះមានកំឡាំន្ធ ។ អ្នកត្រយើញមាស គេវែក ទុនក្បាលសំឡឹន្ធចុះ ស្មើរប៉ះន្ធឹន្ធដន្ធវែក ។

๒๗ សត្វសិង្ហដែលមានក្រចកមុតចូលទៅនឹន្ធរំពាវរបស់វ៉ា មិនខ្ចាចឆ្កែព្រុះទេ ។

๒๘- កាន់ជាវៃហ៍សពេក អាចឲ្យឯន្ធស្តាយក្រោយមិនខាន ។

๒๙ អ្នកមានគុណវិបត្តិពាន្ធ៌អស់គ្នា ។ កុំឲ្យរិះគន់គុណវិបត្តិបន្ធ្លួនឯន្ធ ។ អ្នកណាដែលស្គាល់គុណវិបត្តិខ្លួន ដោយឯន្ធច្រើន មានចិត្តសន្តោសត្រាប្រណីដល់គុណវិបត្តិអ្នកដទៃ ។

๓๐- នៅទីណា កន្លែន្ធណា អ្នកមានកោតទ្រព្យ គេទន្ធួលដោយសេចក្តីពាក់ពាក់ពាន្ធ៌អស់ ។

៣១- បណ្ឌិតប្រៀបដូចជាមាសសុទ្ធ នៅទីណាគេគោរព គេបម្រើជានិច្ច ។ បុត្រល្ងង់នៃអ្នកមានកោតទ្រព្យ ដូចជារបួយៈធ្មេញពីស្បែកដែលគេយកទៅចាយបរទេសមិនបាន ។

៣២- អន្ធាក់ដែលជាក់ព្រាប គំនុំតែព្រាបណាហើរឆ្ងាយពីសំបុក ។

៣៣- មនុស្សណាទស្សាហ៍ធ្វើការជាដរាបគេ ហើយបំណងតស៊ូនឹងផ្គាត់ការសនារបស់ខ្លួន នឹងទៅស្ងាប់ឯវាលខ្ពាច់រហោស្ថាន គ្មានឈ្មោះ ។

៣៤- បើគ្មានប្រាក់, មិនបើកផ្លូវឲ្យទៅទេ ។

៣៥ ជាស្ត្រួចមុតមិនអាចកាប់សរសៃសូត្រទន់បានទេ ។ ដោយប្រើសំដីផ្អែមល្ហែម ពោលពាក្យល្អ ឯងអាចយកសរសៃសត់មួយ ដឹកដំរីបានដោយងាយ ។

៣៦- បើឯងធ្វើចាបមនុស្សម្នាក់ បើខុកជាមនុស្សនោះ បម្រើឯងមួយពាន់យ៉ាងក៏ដោយ កុំឲ្យខុកចិត្តមនុស្សនោះសោះឡើយ ។ គេបានដកដែកមុតពីដំបៅ តែសេចក្តីខុកខ្លួំបាក ដែលដែកស្ត្រួចមុតវាឲ្យផលពីមុនមកស្ងួតនៅ ក្នុងស្មារតីមនុស្សនោះជាប់ជានិច្ច ។

៣៧- បើគាលណារបោមវាហើរប្រើនដូចពពក វាហានតយុទ្ធនឹងដំរី ។ បើស្រមោចតាំងឡាយមានចិត្តសាមគ្គីគ្នា ស្រមោចនោះអាចឈ្នះសត្វឥន្ទ្រីបាន ។

៣៨- ជាញឹកញាយ, ដួនកាលយោបលបណ្ឌិតមិនឲ្យផលកំសឹងមាន, ដួនកាលក្មេងលួងបាញ់ឆ្កួឈ្នះអ្នកបាញ់ជ្រដៃចាស់កំសឹងមាន ។

៣៩- ឈើពីរកំណាត់អាចឲ្យអណ្តាតភ្លើងខ្ពស់ជាងឈើមួយកំណាត់ ។

៤០- មនុស្សពីរនាក់រស់នៅឥតប្រយោជន៍: មនុស្សមួយទំប្រមូលថ្នាក់ហើយមិនបានយកថ្នាក់នោះទៅប្រើថ្នាស់, មនុស្សមួយទៀត បេះដឹងតែមិនបានយកចំណេះនោះទៅអនុវត្ត ។ សេះទេស ដែលផ្ទុកសៀវភៅលើខ្នង វាមិនមែនជាបណ្ឌិត ជាអ្នកថ្នាដូទេ ។ តើសេះទេសនេះវាអាចដឹងបានថា ឈើឬសៀវភៅ ដែលផ្ទុកលើខ្នងវា ។

៤១- បណ្ឌិតនិយាយច្រើន ប្រៀបដូចជាមនុស្សឆ្កួត គ្រវីចង្កៀងរបស់ខ្លួន បណ្ឌិតនោះ បំភ្លឺតែអ្នកឯទៀត ហើយខ្លួនឯងច្រើនជួបប្រទះនឹងទុបស្ថគ្គ:គ្រប់យ៉ាង ។

៤២- ចូរអ្នកធ្វើគ្រាប់ទំមចន្ទន៍ ដែលឲ្យកូនក្រអូបដល់មុខពូរហើយដែលធ្វើឲ្យមានរបួស ។

(មានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់

បរិយាយពីពាក្យទំនឹមទំនៀមថា "ឆ្កែឆ្មាកំឡៅ"

លោក ចាប-ពិន រៀបរៀង

នៅក្រុមពុទ្ធសាសនបណ្ឌិត្យ ក្នុងក្រសួងធម្មការ នឹងសាសនសិក្សាធិការ មានការិយាល័យ ១ ហៅថា " ការិយាល័យក្រុមជំនុំទំនៀមទម្លាប់ខ្មែរ " ដែលស្ថាបនាឡើងពីឆ្នាំ ១៩៣៤ ជាការិយាល័យមានភារៈខាងការស្រាវជ្រាវរកឯកសារ ជាក្បួនខ្នាតទំនៀមទម្លាប់បុរាណមកដាក់លុកហើយរៀបរៀងចោះពុម្ពផ្សាយជាសៀវភៅឡើង មានសៀវភៅព្រះរាជពិធីច្រើនសមាសជាដើម ។

ឯកសារដែលក្រុមជំនុំប្រឹងស្រាវជ្រាវរកនោះ ដោយរបៀបដូចខ្លះ គឺ

- ដោយកត់ត្រាចម្ងាំអំពីក្បួនខ្នាតបុរាណ;
- ដោយសាកសួរអំពីពួកសមាជិកធ្វើយធ្វង;
- ដោយការប្រឡងប្រជែងជ្រើសយកតាមលំដាប់ធមាស ។

ចំពោះការសាកសួរតាមផ្លូវសមាជិកធ្វើយធ្វង យើងបានទទួល

ឯកសារជាច្រើនមុខ អំពីសមាជិកពាន់ឆ្នាំយដែលបានឱ្យតារាណ៍មក, តែវេលានេះ សូមស្រង់យកតែឯកសារ ១ របស់ទុកញ៉ា តែវ-ហង្ស អតីតចាងហ្វាង នៅឃុំសួង ស្រុកត្បូងឃ្មុំ ភំពង់ចាម ដែលចែងអំ-ពីរឿងព្រេង ១ ចាក់ទន្ទេរដោយពាក្យទំនឹមទំនៀម ចំពោះផ្ទៃក្តួនចៅឱ្យមានគូស្រករ ដែលអ្នកស្រុកក្នុងសង្គមខ្មែរតែងតែនិយាយថា "ឆ្កែឆ្មាក៏ឱ្យចៅ" ជាពាក្យបន្ថយសេចក្តីប្រាថ្នា ដើម្បីកុំឱ្យសើចក្តួនប្រសាទ្ធាំងពេក ។

រឿងព្រេងនោះដំណាលថា :

ពីព្រេងនាយ មានមេសុនទ្រ ១ តែងបរិភោគត្រយាសំណល់ដែលគេចោលក្នុងព្រះសុពណ្ណស្រី (តន្ទោរព្រះបស្ប្រាវ:) របស់ព្រះពជា ១ ព្រះអង្គ ។ មេសុនទ្រនោះយូរៗទៅមានផ្ទៃពោះ ដល់ពេលសម្រាលក្តួន រាំទៅសម្រាលទៅរួងភ្នំ ១ ។ ក្តួននោះកើតឡើងជាកូនមនុស្ស ស្រី ២ ប្រុស ១ ។ រួងភ្នំនោះនៅជិតព្រៃទីក្រសាលនៃព្រះពជា ។ មេសុនទ្រស្រឡាញ់ក្តួនណាស់ទំដើរតេសំពត់អាវមកឱ្យស្លៀកពាក់ ។ ពេលថ្ងៃ១ ដែលចេញទៅតេអាហារ ផ្តាំក្តួនថា "កុំចេញពីក្នុងរួង" ។ ថ្ងៃ ១មេសុនទ្រមិនទៅ ព្រះពជាទ្រង់ចេញទៅក្រសាលព្រៃនោះ ព្រមទាំងរៀបពលទ្រង់ទតឃើញក្តួនស្រីពាន ២ មានរូបឆោមល្អក៏ទ្រង់យកទៅជាព្រះអគ្គម-

ហោសី ។ មេសុនខត្រឡប់មកវិញមិនឃើញកូនស្រីក៏ទៅតាម ។ ព្រះ
រាជាត្រាស់សួរ នាងតាំង ២ ទូលបង្គំថា "មិនមែនម្តាយខ្ញុំទេ" ។ ពួក
ពលគេរៀបណ្តេញមេសុនខនោះចេញទៅ ។ កូនប្រុសដ៏ឆ្មើងឆ្មៃនឹង
បង់ស្រី។ ក៏នាំម្តាយទៅនៅជ្រកអាស្រ័យនឹងផ្ទះសេដ្ឋី ១ សុំគេធ្វើជាឧបុក
ធម៌ ដោយប្រាប់ត្រង់ថាជាម្តាយរបស់ខ្លួន ។ ថ្ងៃក្រោយកូនប្រុស
ផ្ញើម្តាយនឹងសេដ្ឋីហើយលាទៅរៀនសិល្បៈនឹងឥសី ១ អង្គនៅដើនកុំ ១
លុះរៀនសិល្បៈចប់ សិល្បៈជបចេះស្ទាត់ហើយលាឥសីមកកេម្តាយវិញ ។
តមក កូនប្រុសនោះបានសំដែងសិល្បៈគួរឲ្យនឹងព្រះរាជា ក៏មានជ័យ
ជំនះ បានជាព្រះរាជាសោកជ្រះនៅនគរនោះ ។

ឯសេដ្ឋីជាឧបុកធម៌ក៏បានផ្សំផ្គុំកូនស្រីថ្វាយជាព្រះអគ្គមហេសី ដោយ
ពាក្យថា "ឆ្កែធ្មាក់ឲ្យទៅ" ។ ឯកូនប្រុសនោះ ដល់បានជាព្រះរាជាហើយ
បានដឹងម្តាយជាមនុស្សល្ងីល្ងើ ។ ព្រោះហេតុមានរឿងដូច្នេះ បានជា
ជាប់មានពាក្យថា " ឆ្កែធ្មាក់ឲ្យទៅ " រៀងមកដល់សព្វថ្ងៃនេះ ។

រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តមក)

លោក រ៉ាយ-ប៊ុក ប្រៀបរៀង

តែតាមប្រពៃណី គេមិនដែលរៀបវិវាហមង្គលការកូនស្រីដោយមិនបានសួរពត៌មានសព្វគ្រប់នោះទេ ។

តាចាស់សួរលោកស៊ុសាណូថា ខ្ញុំសូមអភ័យទោស ខ្ញុំសូមសួរលោក តើលោកឈ្មោះអ្វី ? ព្រោះខ្ញុំមិនស្គាល់លោកសោះ ។

លោកស៊ុសាណូតបថា "ខ្ញុំឈ្មោះស៊ុសាណូជាបងប្រុសនៃព្រះនាងសុរិយាទៅ ខ្ញុំទើបនឹងចុះមកកាន់ផែនដីមនុស្សលោក" ។

តាចាស់យាយចាស់ក៏នាំគ្នាសើចហើយក៏សួរគ្នាទៅវិញទៅមកដោយខ្ជិលៗ រួចតាអាសីនហ្សុីកំពោលថា "យើងសូមជូននូវបុត្រីយើង ទៅលោកដោយគោរព" ។

លោកស៊ុសាណូយកដៃកាន់ស្មាព្រះនាង ស្រាប់តែព្រះនាងក្លាយទៅជាត្រាសមួយ មានផ្នែញច្រើនជាអនេក ហើយលោកក៏ពោលទៅកាន់តាចាស់យាយចាស់ថា ឥឡូវនេះ ខ្ញុំសូមតស៊ូនឹងនាគ ។

លោកស៊ុសាណូ គិតរំពឹងអស់កាលជាយូរ លោកបានពាល់ដងព្រះខន្លោក ដែលលោកយល់ថា វែងមាំ ពូកែ ។ តែនឹងតស៊ូនាគយ៉ាងណា,

បើទុកជាមានព្រះទន័ថែមទេនេះ ក៏ការនេះមិនងាយ ព្រោះនាគនោះមានដង
ខ្លួនមណ្ដាយស្រោះភ្នំស្រាំបី ទឹងភ្នំតូចស្រាំបីទៀត គួរតែប្រើទាយកល
វិញ ។

លោកស៊ុសាណូក៏តបទៅគាថាស់យាយថាសវិញថា សូមលោកតាលោក
យាយធ្វើតាមខ្ញុំ ។ សូមលោកាធ្វើរបងឲ្យមាំ ដែលអាចការពារគេហ-
ដ្ឋាននៃលោកតាខាងទិស ដែលនាគនោះចូលមកយាយី រួចលោកតាចោះ
ទ្វារស្រាំបីកន្ទែងទៅមុខទ្វារពាងស្រាំបី លោកតាជាក់ដើងតាងស្រាំបីហើយ
យកដបតែវស្រាំបីមកតម្កល់ ។ នៅក្នុងដបតែវនឹមួយៗ លោកតាចាក់ស្រា
សាតេ ស្រាធ្វើពីចាយជម្ពា មានសភាពខ្លាំងស្រាំបីដងរួចលោកតារង់ចាំ ។
- តាចាស់យាយចាស់ក៏ធ្វើតាមបង្គាប់លោកស៊ុសាណូពាងអស់ ហើយ
ក៏រង់ចាំ ។ លោកស៊ុសាណូក៏ចាំដែរ ។ លោកបានអង្អែលជាវលោក
ដួនតាលលោកយកគ្រាសមករៀបចំ ។ ជោគវាសនានេះចំឡែតពន់ពេក
ដោយលោកស៊ុសាណូបានប្រុងប្រៀបតស៊ូទឹងនាគ ដើម្បីព្រះនាងដែល
បានកន្ទែងខ្លួនជាគ្រាសមួយ សៀតលើកូនសក់លោកស៊ុសាណូ ។

ក្នុងមួយរំពេច គេក្រឡេកទៅឃើញអំពីចម្ងាយ រស្មីនៃពន្លឺក្រ-
ហមផ្លេតឺក្អែកនៃក្បាលនាគពាងស្រាំបីនោះឯង ។ គេបានឮសូរស៊ីឮ
រមែកឈើបាក់ប្រេះប្រាវ ដើមឈើបាក់មែកខ្ចេចខ្ចី រួចគេ

យើញយ៉ាងច្បាស់លាស់ នូវខ្លួនសភាវមួយធំសម្បើមអស្ចារ្យ ដូចជាភ្នំម៉ូយ
កម្រើកដូច្នោះ ។

នាគនោះខឹគគាន់តែដឹង ។ មក ហើយដូចជានឹងចង់អាស្រ័យសាច់
ស្រស់ព្រះនាង ។

តែនាគនោះពេញចិត្តខាងផឹកស្រាណាស់ដែរ ។ ភ្លុនស្រាធុំ
ភាយៗ ទៅលើច្រមុះវា ។ នាគនោះក៏ខ្មេនក្បាលចាំងច្រាំបី ទៅភ្ជួងជបតែ
ហើយត្រេចផឹកទូវស្រានោះ . . . . ។

នាគនោះផឹកស្រាចាស់តែស្រវឹង ស្រវឹងណាស់ទៅជាដេក ។ ជនខ្លះ
ធំសម្បើមពន់ពេក ស្ថិតនៅចំពីមុខគេហដ្ឋានលោកតាអស៊ីណាហ្សុស៊ី ។

ក្នុងពេលនោះ លោកស៊ុសាណូហូតព្រះខ័នថ្វា កំសួះទៅចាក់
នាគនោះត្រូវចំចង្កេះខាងឆ្វេង ស្រាប់តែឈាមចាញ់ឡើងលើគ្នាក់មក
ដូ,ហូរដូចទឹកស្ទឹង នាគនោះក៏ក្រញែងខ្លួន ហើយថ្លាតែមិនអាចក្បាក់បាន។
លោកស៊ុសាណូក៏បានយកព្រះខ័នថ្វាចាក់នាគ ត្រង់ចង្កេះខាងស្តាំ ឈាម
ចាញ់ឡើងលើ ហើយហូរទៅធ្លាក់ក្នុងស្ទឹងពេញពោរ មានពណ៌ក្រហម ។

នាគដូចជាគ្មានដឹងតែ ដើម្បីតាវោរតទៅទៀត លោកស៊ុសា-
ណូ ក៏យកព្រះខ័នថ្វាចាក់នាគ ចំកណ្តាលខ្លួនដែលមានសភាពធំសម្បើម
អស្ចារ្យ ស្រាប់តែព្រះខ័នថ្វាបាក់បែកទ្វេចខ្លី តែសំណាងល្អ

នាគនោះពិតជាវាស្មាប់មែន ។

លោកស៊ុសាណូឆ្ងល់ ហើយចង់ដឹងថា ចុងព្រះខ័នថ្លាលោកប៉ះនឹងអ្វី ចានជាចុកបែកដូច្នេះ ។ លោកក៏ពុះខ្លួននាគដូចជាគេបើកល្អៀងខ្ទុំ ។ នៅខាងក្នុងខ្លួននាគនោះ មានជាវមួយវែងធ្នា ។

លោកស៊ុសាណូចានយកជាវវែងធ្នានោះខុក នឹងថ្វាយព្រះនាងសុរិយាទេវី ។

លោកស៊ុសាណូចានជតគ្រាសដែលមានធ្មេញច្រែនចេញពីសក់, ហើយក៏សូត្រមន្តអាគមផ្ទុំគ្រាសនោះ ទៅជាព្រះនាងកុនីសជា ។

ព្រះនាងទ្រង់បញ្ជាឲ្យមនោសញ្ចេតនាត្រេកអរនឹងលោកស៊ុសាណូ ដែលចានជួយស្រោចស្រង់ព្រះនាងផុតពីកណ្តាប់ដៃនាគក្បាលប្រាំបី ហើយព្រះនាងទ្រង់មានចិត្តប្រតិព័ទ្ធស្និទ្ធស្នេហា ចំពោះលោកស៊ុសាណូជាយ៉ាងក្រៃលែង ។

ព្រះនាងនឹងលោកស៊ុសាណូក៏ទៅគង់ប្រថាប់ឯប្រាសាទសុគៈ (សួគ៌) ដែលមានពពកគ្រាសប្រាំបីផ្ទាំងអមផ្ទុំវិញ ដូចជាវេងមួយការពារកុំឲ្យក្អែកអ្នកដទៃឃើញនូវទឹកន្ទេង ដែលអ្នកគាំងផ្សំដំណេក ។

អ្នកទាំងពីរកំសៅនៅជាយូរអង្វែងធ្នាំ សុខកាយសប្បាយចិត្តហើយមានកូនជាច្រើន ។

(មានត)

កំណត់ធ្វើដំណើរ

ពត៌មានផ្សេងៗ របស់ក្រសួងព័ត៌មាន

សោកយូរ-អ៊ុន ថ្លែងតាមវិទ្យុជាតិ

នៅថ្ងៃទី ១៧ មិថុនា ឆ្នាំ ១៩៥៨

បើរលឹកពីដែលព្រះតេជព្រះគុណព្រះពោធិវង្សហ្គត-គាត់ធ្វើមកពីប្រទេសបិនប្រជាមានិត

នៅថ្ងៃទី ១៦ ពេលម៉ោង ៧-២០ គណៈប្រតិភូបានទៅដល់ក្រុងកួាង-ចូវ នៃខែត្រកង់តុង បានទៅសំណាក់នៅហោតែល «Aichun hotel» ។ កង់ដំណើរទៅ គាំងពីភ្នំពេញរហូតដល់ក្រុងកង់តុង សុខសប្បាយស្រួលទេ មានគេចាំទទួលសម្រួលដំណើរ មិនឲ្យមានការលំបាកអ្វីឡើយ ក្នុងថ្ងៃទី ១៧ ដែលនៅក្នុងក្រុងកួាងចូវនេះ គេនាំមើលវត្តអាចារ្យមាងព្រះពុទ្ធសាសនា ជួបជុំជាមួយពួកបព្វជិត គេនាំមើលសាលសន្និសីទជាអនុស្សាវរីយនៃលោកជុតទ័រ សុន-យ៉ាត់សេន ពីកន្លែងផ្សេងៗ ដែលគួរទស្សនា រហូតដល់ម៉ោង ៦ ល្ងាច ទើបត្រឡប់មកសណ្ឋាគារវិញ ។

ដល់ម៉ោង ៩ យប់ថ្ងៃនេះ នឹងចេញដំណើរតាមរថភ្លើង ឆ្ពោះទៅប៉េកាំង ដល់ថ្ងៃទី ២០ ខែនេះ ទើបដល់ប៉េកាំងនៅវេលាយប់ ប៉ុន្តែទៅតាមផ្លូវនោះ នឹងត្រូវឈប់មួយយប់នៅក្រុងហាន់គៅ ។

អ្នកចាត់ការដួនដំណើរក្រាប់ថា បំរុងឲ្យទៅក្រុងប៉េកាំង តាមអាកាស-យាន ប៉ុន្តែ ដំណើរយើងនេះហ៊ាសពេក ខ្វែពេក បានជាគេឲ្យទៅតាមរថភ្លើង ដើម្បីទទឹងបានឈប់ទស្សនា តាមផ្លូវបណ្តើរឲ្យហើយ លុះទៅដល់ប៉េកាំង គេទទឹងរៀបចំកម្សាន្តឲ្យទំមន្តទៅតាន់ទីផ្សែង ។ តាមដំណើរដ៏គួរ ។

ការធ្វើដំណើរ ៣ ថ្ងៃមកហើយនេះ ឥតមានសេចក្តីលំបាកអ្វីទេ ទាំងអាហារគោជន ក៏គេចាត់ចែងឲ្យធាន់ឥតលំបាកដែរ ។

ម្យ៉ាងទៀត គ្រឿងបំរុងស្បៀង ដែលគេរៀបចំឲ្យយកទៅតាមផ្លូវនោះ មិនឥតប្រយោជន៍ទេ ។

នៅក្រុង ក្វាង-ចូវ ពេលមួយថ្ងៃនោះ អាកាសត្រជាក់ស្រួលណាស់ ឥតបែកញើសទេ ពីរបីថ្ងៃមុន ក្តៅបន្តិច ។ ភ្លៀងមានធ្លាក់បរបូណ៌ទៅតាមរថភ្លើង គេធ្វើស្រែងាំដំណាំ ស្មើរតែឥតមានដីសល់ទំនេរ សូម្បីដីលើភ្នំ ក៏កំពុងតែកាប់គាស់កកាយ ធ្វើឲ្យកើតផលប្រយោជន៍ ទាំងដីដែលទៅកៀនគោះបន្តិចបន្តួច ក៏មានការបណ្តុះដាំដែរ ។

សូមលោកផ្សាយដំណឹងដល់លោកអ្នកដែលគួរដឹងបានជ្រាបផង ។

ហត្ថលេខា : ព្រះពោធិវង្ស

អំពីការតាំងមន្ត្រីសង្ឃ

-បានតាំងលោកចៅអធិការ ណុន-ឌុល វត្តត្រពាំងព្រីងឃុំអង្គប្រស្រែ ស្រុករមាសហែក (ស្វាយរៀង) ជាទីអនុគណ ស្រុករមាសហែក តាមសញ្ញាប័ត្រលេខ ៦៧៧០ ចុះថ្ងៃទី ៧ ខ ៥៨ ។

-បានតាំងលោកចៅអធិការ លាក់-ប៊ូ វត្តសមណាភាម ឃុំកំពង់ត្រាច ស្រុករមាសហែក(ស្វាយរៀង) ជាទីព្រះសមុហ៍អនុគណស្រុករមាសហែក តាមសញ្ញាប័ត្រលេខ ៦៧៧១ ចុះថ្ងៃទី ៧ ខ-៥៨ ។

អំពីការតាំងអាចារ្យសម្រាប់វត្ត

ខេត្តចាត់ដំបង- - - - - - -៤ វត្ត

" ព្រៃវែង - - - - -៦ "

" កំពង់ធំ - - - - -១ "

អំពីការតាំងចៅអធិការ

-បានតាំងកិក្ខុ ហ៊ួ-អ៊ាម ជាចៅអធិការ វត្តពោធិសាលា ឃុំព្រៃតក្រៅ ស្រុក កងមាស ខេត្តកំពង់ចាម ។

ជីវប្រវត្តិ

នៃព្រះតេជព្រះគុណព្រះពុទ្ធវិជ្ជ កៅ សុឹម

(តចប់)

ភិក្ខុ ចយ-ចេង រៀបរៀង ព្រះមហា សូរ-សុ ពិនិត្យ

កុមារ កៅ-សុឹម បានទំស៊ប់ក្នុងអក្សរសាស្ត្រជាតិ ១ឆ្នាំ ក៏បានសម្រេចតំបូងសិក្សា ហើយបានបន្តវិជ្ជាជាន់ខ្ពស់តទៅទៀត គឺចៅអធិការស្លឹ-ឯម បានឲ្យរៀនទន្ទេញមេសូត្រ ពាល់តែចាំមាត់ស្ទាត់ហើយក៏ប្រគល់កុមារនេះ ឲ្យបំរើលោកគ្រូអាចារ្យ ម៉ឺ-នាង ហើយប្រាប់ថា ឲ្យបង្រៀនមូលកច្ចាយនសន្ធិ, លោកគ្រូអាចារ្យ ម៉ឺ-នាងបានបង្រៀនមូលកច្ចាយនសន្ធិ, មូលនាមផ្លូក១-២ ។ កុមារ កៅ-សុឹម បានអាយុ១២ឆ្នាំ ម្តាយមីង បាននាំទៅឲ្យបួសជាសាមណេរ ក្នុងសំណាក់ចៅអធិការ ស្លឹ ឯម ក្នុងព.ស. ២៤៥៤ គ.ស. ១៩១១ ។ ចៅអធិការស្លឹ-ឯម ក៏បានបង្រៀន មូលកច្ចាយននាមផ្លូក ១-២- សមាស-តទ្ធិត អស់រវាងពីរឆ្នាំ ស្រាប់តែមាតាអនិច្ចកម្មទៅ, សាមណេរកៅ សុឹម ក៏លាចាកសិក្ខាបទ ទៅប្រកបអាជីវកម្ម បំរើបិតា។ ក៏អនិច្ចកម្មទៅទៀត ។ ដល់អាយុ ២០ ឆ្នាំ នៅថ្ងៃព្រហស្បតិ៍ ១១ កើតខែជេស្ឋ ព.ស. ២៤៦០ គ.ស. ១៩១៩ បងប្រុសបាននាំទៅឲ្យបួសជាភិក្ខុភាវៈ ក្នុងព្រះពុទ្ធ

សាសនា ដែលមានលោកគ្រូ កែ-សម ជាឧបជ្ឈាយ៍, សម្តេចព្រះធម្មលិខិតល្អី-ឯម ទត្តមប្រឹក្សា ជាកម្មវាចាចារ្យ លោកគ្រូមាស-សាន ជាអនុសាវនាចារ្យ ឲ្យនាមធម្មោជា សិរីបញ្ញោ ក្នុងវត្តស៊ីធរ ។

តិក្ខុកៅ-សឹម ត្រូវសម្តេចព្រះធម្មលិខិតជាគ្រូដើម បាននាំមកឲ្យសិក្សាការសាបាលីនៅវត្តលង្កា ។ សម្តេចឲ្យនៅក្នុងសំណាក់លោកគ្រូសូត្រនាម គង់-កង[1] ជាឧបាចារ្យ ។ ហើយបានប្រឡងជាប់ជាសិស្សសាលាបាលីជាន់ខ្ពស់ក្នុង ព.ស. ១៤៦៣ គ.ស. ២៤២០ ។

ដល់ ព.ស. ២៤៦៧ គ.ស.១៩២៤ តិក្ខុកៅ សុឹម ប្រឡងជាប់បានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។

ពេលដែលទើបនឹងប្រឡងចេញបាន ១ ឆ្នាំនោះ ព្រះតេជព្រះគុណមហាវិមលធម្ម នាម ថោង ចាន់ហ្វាង់សរលាបាលីជាន់ខ្ពស់ បានចាត់ឲ្យទៅធ្វើអាចារ្យបង្រៀនបាលី នៅសាលាបាលីវត្តមង្គលវង្សី ព្រែកថ្មែ ខេត្តព្រៃវែង ចំនួន២ឆ្នាំ ។ ដល់ព.ស. ២៤៧០,គ.ស. ១៩២៧ សម្តេចបវរប៉ុន, បានចាត់ឲ្យទៅធ្វើគ្រូបង្រៀនអក្សរសាស្ត្រ ព្រះសង្ឃនៅសាលាអនុវត្តន៍ (Ecole d'Application des bonzes) ថ្នាក់អាទិភណ្ឌនក្នុងវត្តយាយវេត្ស ខេត្តកំពង់ធ្នាំង ៥ ឆ្នាំ ។ ដល់ព.ស. ២៤៧៦ គ.ស.

១- សោកគ្រូ គង់-កង សព្វថ្ងៃជាគ្រូហស្តមានគោរម្យងារជាឧកញ៉ាព័ករក្តិកដិដ្ឋានធ្វើការនៅក្នុងព្រះបរមរាជវាំង ។

๑๙๓๓ ព្រះមហាកៅ សុីម បានបង្រៀនបាលីនៅសាលាបាលីវត្ត លង្កា ក្នុងពេញ ๑ ឆ្នាំ ។ ព.ស. ๒๔๗๗ គ.ស. ๑๙๓๔ បានធ្វើគ្រូបង្រៀនបាលីនៅសាលាបាលីវត្ត ពោធិវាល ខែត្របាត់ដំបង ๑ ឆ្នាំ ។ ព.ស. ๒๔๗๘ គ.ស. ๑๙๓๕ បានធ្វើគ្រូបង្រៀនបាលីនៅសាលាបាលីវត្តកំពង់ធំ ខែត្រកំពង់ធំ ๓ ឆ្នាំ ។ ក្នុងកាលនោះ បានជួយបន្តមកសាងសាលាបាលីវត្ត ๒ ខ្នងផង ។

នៅថ្ងៃទី๘ ខែតុលា គ. ស. ๑๙๓๙ ព្រះមហាកៅ សុីបានចូលទៅធ្វើជាក្រុមដំនុំប្រែព្រះត្រៃបិដក នៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ។ លុះបានធ្វើប្រមាណ ๑៥ថ្ងៃស្រាប់តែមានសេចក្តីសុំ រកគ្រូដំនួយបង្រៀនបាលីសាលាបាលីជាន់ខ្ពស់ លោកស្រីការប៊ុលែស ក៏បានតម្រូវលើរូបលោកឲ្យធ្វើគ្រូដំនួយ ។

ដល់ ព. ស. ๒๔๘๕ គ. ស. ๑๙๔๒ បានឡើងតាន់តំណែងជាអគ្គានុរក្សនៃសាលៈបាលី (Surveillant général) តមកបានឡើងជាអ្នករៀបចំសេចក្តី (Rédacteur) ទស្សនាវដ្តីកម្ពុជសុរិយា ។

នៅថ្ងៃព្រហស្បតិ៍ ៥រោចខែចេត្រ ឆ្នាំមមីចត្វាស័ក ព.ស. ๒๔๘๕ ត្រូវនឹងថ្ងៃ ๒๗ ខែមេសា ๑๙๔๓ សម្តេចព្រះធម្មលិខិត ទត្តមប្រឹក្សាគណៈមហានិកាយ វត្តលង្កា បានអាំងព្រះមហាកៅ-សុីម ជាគ្រូសូត្រ

ធ្វើ សម្រាប់ឲ្យទបសម្បទាដល់កុលបុត្រ ក្នុងវត្តលង្កាតរៀងមក ដោយ ប្រកាសនិយ័ត្រលេខ ៩ ។

នៅថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំមមែបញ្ចស័ក ព. ស. ២ ៨៦ ត្រូវ នឹងថ្ងៃទី ១២ ខែមករា ១៩៤៤ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណមហានិកាយ ព្រះនាម "ហ៊ុន" វត្តសាវ័នតេជោបានតាំងឲ្យ ឡើងទីជាឋានា "ព្រះបាឡាត់ធម្មបតី" ដើម្បីជួយចាត់ចែងសង្ឃកិច្ច អម សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា សម្រេចតាមប្រកាសនិយ័ត្រលេខ ១១ ។

នៅថ្ងៃចន្ទ ៨ រោច ខែចេត្រ ឆ្នាំមមែបញ្ចស័ក ព. ស. ២៤៨៦ ត្រូវនឹង ថ្ងៃទី ១៧ ខែមេសា ១៩៤៤, លោកព្យែរ ឌុយប៊ុង់ (Piére du pont) អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំព្រះពាជានុញ្ញាត ដើម្បី ឲ្យតាំងជាទីព្រះគ្រូ "បញ្ញាលិខិត" តាសុំនោះក៏បានសម្រេចតាមព្រះ រាជក្រមលេខ ១៦ ប្រកាស ចុះថ្ងៃទី ៨ កុម្ភៈ ១៩៤៣ ប្រកាសនិយ័ត្រ លេខ ៧ ប្រកាស ១ នៃប្រទេសកម្ពុជា ។ ដល់ព. ស. ២៤៨៨ គ. ស. ១៩៤៥ បានធ្វើជាសស្ត្រាចារ្យ នៅសាលាចុលីជាន់ខ្ពស់ សម្រេចតាម ប្រកាសនិយ័ត្រលេខ ១៣ (C.A.D.) ។

តាមព្រះពាជក្រឹត្យលេខ ៤៣ ប. រ. ចុះថ្ងៃពុធ ៤ រោច ខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩ ត្រូវនឹងថ្ងៃ ២៦ ឧសភា ១៩៤៨ ព្រះ

ត្រូបញ្ជាលិខិត កៅ-សឹម មានជន្មាយុ ៥០ឆ្នាំ វស្សាផ្នួស ៣០ បានឡើង
សមណស័ក្តជា "ព្រះវិកន្តុញ្ញាណ" ពីពជាគណៈថ្នាក់ចត្វា ។

នៅថ្ងៃ ១២ កើត ខែកត្តិក ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៤៨៦ ត្រូវ
នឹងថ្ងៃទី ១៧ ខែវិច្ឆិកា ១៩៤៣ ព្រះករុណាជាអម្ចាស់ជីវិតព្រះបាទសម្តេច
ព្រះនរោត្តម សីហនុវរ្ម័ន ទ្រង់ព្រះពជនាគ្រឿងឥស្សរិយយសមេជាយ
"អស្សរិទ្ធិមុនីសារក័ណ" ។

តាមព្រះរាជក្រឹត្យ លេខ ប.រ. ចុះថ្ងៃព្រហស្បតិ៍ ៣ កេច ខែបុស្ស
ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៨៦ ត្រូវនឹងថ្ងៃទី ២១ មករា ១៩៤៤ ព្រះ
វិកន្តុញ្ញាណ កៅ សុឹម មានជន្មាយុ ៥៥ ឆ្នាំ វស្សាផ្នួស ៣៥ បាន
សមណស័ក្តជា"ព្រះពុទ្ធវង្ស" ពជាគណៈថ្នាក់ត្រី ។

តាមពុទ្ធិកសមាគមកម្ពុជរដ្ឋ លេខ១៨ចុះថ្ងៃទី ១៨ កុម្ភៈ ១៩៥៨ ព្រះ
ពុទ្ធវង្ស កៅ-សុឹម បានធ្វើជាទីប្រឹក្សា ១ រូប ។ ព្រះពុទ្ធវង្ស កៅ សុឹម
បានរៀបរៀងចងក្រងធម៌ ជាសៀវភៅ គតិលោក គតិធម៌ផ្សេងៗ មាន
ចោះពុម្ពរួចហើយ ៣ខ្នះ មិនទាន់ចោះពុម្ព ២ខ្នះ ដូចតទៅនេះ :

១-រឿងដំណើរ (មគ្គុទ្ទេសក៍នគរវត្ត) នាំសមណនិស្សិតទៅមើល
នគរវត្តពី ព.ស.២៤៨០ គ.ស. ១៩៣៩ ។

២-មិត្តកថា ចោះពុម្ព ក្នុងព.ស. ២៤៨៣ គ.ស. ១៩៤២ ។

៣-ធម្មចរិយោយកថា ទេសនាផ្ចុ យតាមវិទ្យុជាតិព័ ព.ស.២៤៩០ គ.ស. ១៩៤៧ បានចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា ។

៤-អវិជ្ជាកថា ចោះពុម្ពក្នុង ព ស. ២៤៩៤ គ.ស. ១៩៥១ ។

៥-តបិនចរិយោយ ។ ចោះពុមក្នុង ព.ស.២៤៩៤ គ.ស. ១៩៥២។

៦-និព្វានកថា ចោះពុមក្នុង ព.ស. ២៤៩៤ គ.ស. ១៩៥២ ។

៧-រឿងបុកណានិវេសន៍ ចោះពុម្ពចុះក្នុងទស្សនាវដ្តីសមាគមមិត្ត-សាលាចាលីក្នុង ព.ស. ២៤៩៩ គ.ស. ១៩៥៦ ។

៨ ជាតុបុរាណាម ចោះពុម្ព ក្នុងព.ស.២៤៩៩ គ.ស. ១៩៥៧ ។

៩- បុញ្ញបុរាកេទ ចោះពុម្ព ក្នុងព.ស. ២៤៩៩ គ.ស. ១៩៥៧ ។

១០-ទានបរិយោយចោះពុម្ព ក្នុង ព.ស. ២៥០០ គ.ស.១៩៥៨ ។

១១-យុវចរិយោកថា ចោះពុម្ព ចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា ក្នុងព.ស. ២៤៨៨ គ.ស.១៩៤៧ ។

១២- ចតុព្ភិធវិនយកថា រៀបរៀងក្នុង ព.ស. ២៤៩៧ គ.ស. ១៩៥៥មិនទាន់ចោះពុម្ព ។

១៣ អបណ្ណកជាតក រៀបរៀង ក្នុង ព.ស. ២៤៩៤ គ.ស. ១៩៥១តុំទាន់ចោះពុម្ព ។

១៤ សៀវភៅសុន្ទរកថា អំណរបុណ្យកត្តញ្ញាព្រះសពសម្តេចព្រះធម្ម-

លិខិតទុក្ខមប្រឹក្សាគណៈមហានិកាយ ក្នុងព.ស. ๒๔๙๙ គ.ស. ๑๙๕๖។

គាលព.ស. ๒๔๙๐ គ.ស.๑๙๔๙ បានកសាងកុដិក្នុងវត្តលង្កា គ្រឿងឈើសុទ្ធ តក្លាប់ពីកុដិចាស់ ๑ខ្នង๖ ម៉ែត្រ បណ្តោយ๙ ម៉ែត្រ រួមចូលជាមួយគ្នានឹងលោកគ្រូចៅអធិការ លីធេង-ចាន នៅវត្តកំពង់ស្វាយ ខែត្រកំពង់ធំ ជាមេគំនិត អស់បច្ចុយ๔๙๐๐๐រៀល ក្នុងវត្តលង្កាក្រុមទី๗។

គាលព.ស, ๒๔๙๘ គ.ស. ๑๙๕๕ បានជួយកសាងកនហាលខាងមុខកុដិចាស់នេះទៀត រួមចូលជាមួយនឹងលោក ង្ហួន សំនុក លោកស្រី យ៉ិត-ស្រុន-សុខា ដែលបានចេញបច្ចុយ๙๐๐រៀល រួមទាំងអស់ ๑๙.๗๙๖រៀល ទុកក្នុងវត្តលង្កាក្រុមទី ๗ ។

នៅថ្ងៃទី ๙ មេសា ๑๙๕๘ មេសង្កាត់លេខ๑๖ ភ្នំពេញព្រមទាំងសហការី បាននាំយកសញ្ញាប័ត្រចៅអធិការទៅប្រគេនព្រះពុទ្ធវង្ស ។

ក្នុងសញ្ញាប័ត្រនោះ តាមបញ្ជាក្តព្រះរាជក្រមលេខ ๑๒ ចុះថ្ងៃអង្គារ ๙ កើត ខែ មាឃ ឆ្នាំមមីចត្វាស័ក ត្រូវនឹងថ្ងៃ ទី ๙ កុម្ភៈ ๑๙๔๓ ។

តាមបុតហ្វាយក្រសួងធម្មការលេខ๗๓๔ចុះថ្ងៃពុធ ๑๓កើត ខែបត្រង្នាំ ឆ នៅក្នុងឆ្នាំរសីស័ក ព.ស. ๒๙๐๐ត្រូវនឹងថ្ងៃ ទី ๙ មេសា ๑๙๙๘ ព្រះពុទ្ធវង្ស កៅ-សុីម មានជន្មាយុ๖๑ ឆ្នាំ បានឡើងកាន់តំណែងជាចៅអធិការវត្តលង្កា ។

មុនពីការឡើងកាន់តំណែងថៅអធិការ ព្រះភិក្ខុសង្ឃក្នុងវត្តលង្កា ដែលមានសម្តេចព្រះមហាសុមេធាធិបតី ជ. ណាត សង្ឃនាយកគណៈមហានិកាយជាប្រធាន បានធ្វើកិច្ចបោះឆ្នោត ចំពោះបេក្ខសមណៈ២រូបគឺ ព្រះញាណកោសល ញាណ-ឈឹន ព្រះពុទ្ធវង្ស កៅ-សុឹម, ភិក្ខុអ្នកបោះឆ្នោត មានចំនួន១៩ការូប សម្រេចលទ្ធផល ១១សន្លឹក ខ្វះ៨ ២៩ សន្លឹក គឺព្រះពុទ្ធវង្ស កៅ សុឹម បានឆ្នោត១១សន្លឹក, ព្រះញាណកោសល ញាណ-ឈឹន បានឆ្នោត២៩សន្លឹក ។

ដល់ថ្ងៃ១២ មេសា ១៩៥៨ បានធ្វើពិធីស្រោចទឹកជាកិច្ចអវសាន។

ជីវប្រវត្តិនៃព្រះតេជព្រះគុណព្រះពុទ្ធវង្សកៅ-សុឹម

ចប់ដោយសង្ខេប ។

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អង្គិនី គុ. នែលមានអង្គ ឬ មានអវយវៈ , មានទ្រព្យ ។ បុ. សត្វ ។

អង្គិរស៍ បុ. ឈ្មោះឫសី ឬ អ្នកតែងគម្ពីរ ឬ គ្រូទ (មិនសូវមានដា អង្គីរ, អង្គីរស ទេ) ។ ឈ្មោះភូត , ឈ្មោះដាយ ។ ពហុ. ពួកសត្វទិព្វកាក់កណ្តាល ឬ ពួកកាបស ។ គឺតៈក្នុងអថិវវេទៈ , អ្នកប្រដាអថិវវេទៈ ; ឮដពង្សអង្គិរស ។

អង្គិរស បុ. សត្រូវនៃព្រះវិស្ណុនែលអវតារដាបរឝុរាម ។

អង្គិរីយក នបុ. ចិញ្ចៀន ។


អង្គិល បុ. ទំហំម្រាមដៃ (មាត្រាង្វាស់) ។

អង្គិលិ ស្ត្រី. ម្រាមដៃ , ម្រាមជើង ដា អង្គុលី ក៏មាន ។ -ត្រ ឬ -ត្រាណ នប. គ្រឿងការពារនូវម្រាម (សម្រាប់ពួកឮាន់ធ្នូ) ។ -មុខ នបុ. ចុងម្រាមដៃ ។ -មុទ្រា ឬ -មុទ្រិកា , ស្ត្រី. ចិញ្ចៀនក្រា ។ -មោដន , នបុ. កិរិយាកាច់នូវសន្ធាក់នៃម្រាមដៃឲ្យលាន់ ។ -វេដ្ត , បុ. ស្រោមដៃ ។ -សំខេត . បុ. កិរិយាឲ្យសញ្ញាដោយម្រាមដៃ ។ -ស្ផោដន , នបុ. កិរិយាកាច់នូវសន្ធាក់នៃម្រាមដៃឲ្យលាន់ ។

(មានត)

ដើម្បីនឹងចម្រើនសមថកម្មដ្ឋាន ។ ក្នុងពេលនោះ ព្រះមហាថេរៈពហុលនឹងព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សុម្ភាដ បានឲ្យសីលចំពោះទុបាសកទុបាសិកាដែលអញ្ជើញមកសន្និបាតនៅទីនោះ ។

គេបានដឹងថា ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ សុម្ភាដសង្កាជាវត្តពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ជាព្រះកិត្តិយ្យ ១ អង្គ ដែលគង់នៅទីក្រុងប៉ារីសដែលលោកបាននិមន្តមកអស់រយៈកាលបានពីរខែហើយ ។ លោកបានគង់នៅគេហដ្ឋានប្រទេសកម្ពុជា លោកបាននិមន្តទៅសិក្សា ឯសាលាអនុវត្តទត្តមសិក្សានឹងវិជ្ជាស្ថានអាវ្រូធមិតណ្ឌៀនៃសាលា "សរបោន, ឯសាលាពាណិជ្ជនេះ ត្រូវសិក្សាអស់រយៈវេលា ៣ ឆ្នាំទើបចប់ការសិក្សា ។



អគ្គិភ័យនៅវត្តសីហរតនារាមក្នុងខេត្តតាកែវ

កាលពីថ្ងៃទី ៦ មេសា ១៩៥៨ វេលាម៉ោង ៤ នឹង ៥០ នាទីរសៀល នៅវត្តសីហរតនារាម ជាវត្តលោកគ្រូមេគណ ខេត្តតាកែវ មានអគ្គិភ័យមួយ បណ្តាលមកពីកូនសិស្សម្នាក់ ជាំបាយក្នុងពេលសឹកដឹតកុដិ បានឆេះពលជាលដល់កុដិធំៗ ធ្វើឲ្យអន្តរាយកុដិថ្មពីរជាន់មួយខ្នង, កុដិឈើធំ ៗ ប្រក់ក្បឿង ៣ ខ្នង, កុដិលេបប្រក់ស្បឹក ៥ ខ្នង, នឹងតូបស្បឹកតូចៗអស់ ៦៧ ខ្នង ។ អគ្គិន្តរាយនេះ បានធ្វើឲ្យសិស្សសាលាបឋមសិក្សា នឹងសិស្សអនុវិទ្យាល័យព្រះទ័យ ជាង ៣០០ នាក់ គ្មានទីដម្រេក នឹងគ្មានសំលៀកបំពាក់ តែគ្មានគ្រោះថ្នាក់ដល់ជីវិតមនុស្សទេ ។



ភាគ័ម្ភសន្ទេយ្យា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣០ លេខ ៨ ខែសីហា

ព.ស. ២៥០១ គ.ស. ១៩៥៨

ភ្នំពេញ



ភាសិតសុនីយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣០ លេខ ៨ ខែសីហា

ព.ស.២៥០១ គ.ស.១៩៥៨

ភ្នំពេញ

ដំណឹងពីពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនបណ្ឌិត្យ សូមប្រគេន សូមជូនដំណឹងដល់បពិត្រជាគ្រហស្ថទាំងឡាយ

សូមជ្រាប ។

ដ្បិតសៀវភៅផ្សេង ។ ជាគតិធម៌ ដូចជាសៀវភៅវចនានុក្រមខ្មែរ សៀវភៅមេរៀនខាងពុទ្ធិកវិទ្យាល័យ ឬខាងសាលាធម្មវិន័យ ព្រមទាំងសៀវភៅរឿងផ្សេង ។ ទៀត ដែលបានជាវអស់ពីលើកមុននោះ ឥឡូវនេះ បានសើរើរបោះពុម្ពឡើងវិញរួចហើយ ។

ចំណែកសៀវភៅថ្មីៗទៀត ដូចជាសៀវភៅរឿងព្រះបាទអសោក-ពន្ធុគាស៊ីខ្ចីប, -បញ្ញាសជាតក, ហើយនឹងសៀវភៅលោកន័យបករណ៍ ដែលជាពាក្យភាគ្យ ស្នាដៃរបស់ទកញ៉ាព្រះឃ្មាំន ន ។ល។ ក៏បានបោះពុម្ពរួចហើយដែរ មានជាវសព្វថ្ងៃនេះ ។

ដូច្នេះ សូមនិមន្ត សូមអញ្ជើញជាវតាមត្រូវការ នៅក្រុមពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ ។



ភាគ៥ សន្ទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង . . .	៦៣៥
	- សទ្ធម្មប្បជោតៈ (តមក) ព្រះមហា អ៊ុក-អ័ន រៀបរៀង	៦៧១
	- ពុទ្ធសាសនា ធៀបសាសនាដទៃ (តមក) របស់លោកជា-យូ	៦៨៦
	- ព្រហ្មចរិយកថា ព្រះញាណ-ឈឺន រៀបរៀង	៦៩៧
ផ្នែកអក្សរសាស្ត្រ		
	- រឿងទេវន្តរបស់អម្រឹតក្យត្រីម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ	៧០៥
	- រឿងសាមពុក (តមក) ឧកញ៉ា ន្ហូ-ពន ប្រែ	៧០៩
	- សុភាសិតសាសន៍បែរ្យ (តមក) លោក ភ័យ-ប៊ុក ប្រែរៀបរៀង	៧១៥
	- រឿងព្រេងនិងរឿងបុរាណនៃប្រទេសជិប៉ុន (តមក) លោក ភ័យ-ប៊ុក ប្រែរៀបរៀង	៧២១
	- អធិប្បាយឮៗ ប៉ាកេ្ត កាល ស្រ៊ី-អ៊ូ រៀបរៀង	៧២៦
	- ទំនៀមបង្គំលពលិស អ្នកប្រើ ពេត្រ-សល់ ហៅថា សារីៈយ៉ាន់ រៀបរៀង . . .	៧៣៦
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍		
	- ពត៌មានផ្សេង ។ របស់ក្រសួងធម្មការ	៧៤១
	- ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរក្នុងឆមាសទី ២ ឆ្នាំ ១៩៥៨	៧៤៨
	- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហាជាំង-ខាត់ រៀបរៀង	៧៥៦

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

-Histoire du Bouddhisme au Cambodge (suite) par Vén. *PANG-KHAT* 675
-Saddhammappajota (suite) par Vén. *OUK-IN* 681
-Bouddhisme comparé (suite) par *M. CHEA-YOU* 686
-Promhcharyakatha par Vén. *NHEAN-CHHŒUN* 697

PARTIE LITTERAIRE :

-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* 705
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . 709
-Proverbes persans (suite) par *M. RAY-BUC* 715
-Conte et Légende du Japon (suite) traduits par *M.RAY-BUC* 721
-Commentaire du Chbab kel-kal par *M. SREY-OU* . . . 726
-Les plaques «Popil» et leur pratique traditionnelle par Mme *SRIN-SARIYANN* 736

NOTES ET CHRONIQUES :

-Chroniques du Ministère des Cultes 741
-Concours littéraire institué par la Commission des Mœurs et Coutumes 748
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT*. 756

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

ផ្នែកសាសនា

ប្រវត្តិពុទ្ធសាសនាដៅប្រទេសខ្មែរ

ព្រះមហា ជ័ង - ខាត់ រៀបរៀង

(តមក)

ក្នុងរជ្ជកាលព្រះអង្គ រាជអាណាចក្រខ្មែរធំទូលាយណាស់ ព្រោះបានរួមចំនួលពីប្រជាអាណាចក្រមនសម័យទ្វារវតី ជាដែនដីដែលមនមកពីជា-ពុទ្ធ (សុធម្មបុរៈ) នឹង បើតួព្រមចាំងមនទៅទន្ទេមណាមនឹងទន្ទេ ឥរាវតី (ឥរាវតី?) ដែលបានតសាងជាកម្ពុជប្រទេសឡើង ។ ព្រះបាទសូរ្យវរ្ម័ន ជាព្រះរាជាមានព្រះប្រាជ្ញាធ្វើរឿងសាសណាស់ ទ្រង់ប្រកបដោយទន្តិ ធម្មយ៉ាងខ្ពង់ខ្ពស់ ទ្រង់ជាពុទ្ធសាសនិកជនលទ្ធិមហាយាន តែចេះរក្សា ហើយប្រោសប្រណីពុទ្ធសាសនាថេរវាទ ព្រមចាំងសាសនាព្រាហ្មណ៍ ដោយធម្មីថែមទៀត មិនឲ្យសាសនាចាំងនេះមានមោះហ្មងនឹងគ្នាបានឡើយ ។ សិលាចារឹកខ្មែរនៅលង្វែកបុរី ពីគ. ស. ១០២២-១០២៩ ចែងពុកថា កិត្តិមហាយានក្តី កិត្តិថេរវាទក្តីនៅជាមួយគ្នាសុខក្សេមក្សាន្ត ឯពួកតាបសស្ងើយគី កិប្រតិបត្តិតាមលទ្ធិសាសនាព្រាហ្មណ៍បានដោយសេរី មិនមានការសង្កត់សង្កិនគ្នាទៅវិញទៅមកឡើយ ។ អ្នក

ប្រាជ្ញខាងសិល្បសាស្ត្រចាន់យើញថា មានការកើតព្រះពុទ្ធរូបប្រាក់នាគ ដំបូងក្នុងពាជ្យព្រះអង្គ ដែលមិនធ្លាប់មានមកពីអតីតកាល ។ តាមមែនតែ ទ្រង់ជាកូត្រពុទ្ធសាសនិក តែទ្រង់នៅគោរព"ទេវពាជ" តាមប្រពៃណី ពាជសម្បត្តិដូចដើម ។ លុះទ្រង់ទិវង្គតទៅ គេថ្វាយព្រះបច្ចាមរណនាម ព្រះអង្គថា "ព្រះនិព្វានបទ" ។

ព្រះបាទសូរ្យវរ្ម័នទី ២ ឡើងសោយពាជ្យក្នុង ព.ស. ១៦៥៦ (គ.ស. ១១១៣) ។ ទ្រង់គាន់សាសនាព្រាហ្មណ៍ គោរពព្រះវិស្ណុ ហើយប្រហែលទ្រង់ទិវង្គតក្នុង ព.ស.១៦៨៣ (គ.ស. ១១៤០)។ តមក ព្រះបាទធរណីន្ទ្រវរ្ម័នទី ២ ឡើងសោយពាជ្យក្នុង ព.ស. ១៦៤០ ព្រះនាង ស្រីជយពាជបូងាមណីជាព្រះអគ្គមហេសី មានព្រះពាជបុត្រមួយព្រះអង្គ ប្រកបដោយគុណសម្បត្តិគ្រប់ប្រការ ជាមកុដពាជកុមារ ទៅអនាគតតីអង្គ ព្រះបាទជយវរ្ម័នទី ៧ ។ ព្រះបាទធរណីន្ទ្រវរ្ម័នទ្រង់គាន់ពុទ្ធសាសនាមុត មាំណាស់ ។ សិលាចារឹក (តាថាទី ១៧) ទៅប្រាសាទតាព្រហ្មសរសើរ ព្រះអង្គថា:

តាសៀន្តាសនសុធាជនិតាត្តតប្តិ: កិកូទ្ធិជថិជនសាតកតតូតិសារ: ||
សាពញ្ញិយស្សគុកាយតនាទសាពភ្ភាយាទជស្រជនជាទតូតានតិយ: ||

"ទ្រង់ (ព្រះបាទធរណីន្ទ្រវរ្ម័នទី២) សព្វព្រះពាជហឫទ័យភ្ញាំងចំពោះ

ទឹកអម្រឹតនៃសាសនាព្រះចន្ទ្រគោលគឺព្រះសាក្យមុនី ទ្រង់បានប្រគល់សិទ្ធិ
ដល់តក្កព្រាហ្មណ៍ឱនឱប្រជាជនព្រះអង្គដែលចង់បាន ទ្រង់មានព្រះរាជបំ-
ណងចង់យកសារធម៌ពីកាយដែលមិនមានសារៈ ពោលគឺកាយតនៈជា
អសុភហើយទ្រង់បង្ហោនព្រះវរកាយគ្រាបថ្វាយបង្គំដោយគោរព ចំពោះ
ព្រះបាទនៃព្រះជនស្រីគ្រប់កាលទាំងពួង ។ ១៧។

ព្រះបាទវ៉ែនទី៧ ឡើងសោយរាជ្យក្នុង ព.ស. ១.៦៤ (គ.ស.
១១៨១) ។ ព្រះអង្គជាព្រះរាជាមានព្រះតិត្តិនាមល្បីល្បាញចំផុតក្នុង
ពង្សវតារខ្មែរ ទ្រង់ជាពុទ្ធសាសនិកឆ្នើម គោរពពោធិសត្វលោកេស្វរៈ
ឱនព្រះប្រាជ្ញាចារមីតាមក្រសែព្រះវរបិតា ។ ប្រពៃណីគោរព"ទេវ-
រាជ" ពីបុរាណកាលគឺតាំងពី ព.ស.១៣៤៩ គ.ស.៨០២ មក ព្រះអង្គ
ផ្ទាស់គោរព"ពុទ្ធរាជ"វិញព្រោះទ្រង់សព្វព្រះរាជហឫទ័យចំពោះទឹកអម្រឹត
នៃសាសនាព្រះចន្ទ្រគឺព្រះសាក្យមុនី ។ សម័យនេះ ពុទ្ធចក្រក្តី អាណា-
ចក្រក្តីចំរើនរុងរឿងអស្ចារ្យ ។ ក្សត្រមួយអង្គ។ ជាអង្គទេពតាទាំងអស់
គោះថ្នាក់តែទៅហើយក្តី គោះមានព្រះជន្មនៅក្តី គឺសុទ្ធតែជាអង្គពោធិសត្វ
អវលោកិតេស្វរៈ ឬព្រះប្រាជ្ញាចារមីតាដែលប្រកបដោយព្រហ្មវិហារធម៌ ។
ពិតមែនតែទ្រង់កាន់ពុទ្ធសាសនាមុតមាំ តែទ្រង់ប្រោសប្រោណសាសនា
ព្រាហ្មណ៍ដែរ ។ សាសនាព្រាហ្មណ៍មិនខ្វះខាតឡើយទេ ។ ក្នុងរាជ្យព្រះអង្គ
ទ្រង់បានតែងតាំងព្រាហ្មណ៍ម្នាក់ឈ្មោះហម៌ាកគៈ វណ្ណៈជាការឫាជៈ ស្រុក

កំណើតទៅនរបតប្រទេសជាបុរេហិតព្រះអង្គ ជាវេជ្ជយមហាប្រធាន។
សិលាចារឹកទៅអង្គរធំចែងថា "ទៅតម្កុជប្រទេសមានអ្នកប្រាជ្ញចេះដឹង
គ្រែវេទច្រើនណាស់" ។ មានបដិមាករ ៤ គេដឿថាជាបដិមាកព្រះបាទ
ជយវរ្ម័នទី ៧ គឺព្រះអង្គមានព្រះវរកាយធំសក្តិសម ព្រះភេសបួន
បដិមរូបបែបនេះ មានទៅតាមរូបចម្លាក់ប្រាសាទទៅអង្គរ ។ បដិមាកមួយ
ទៅប្រាសាទអង្គរធំ មួយទៀតទៅប្រាសាទពិមាយ (ប្រទេសសៀម)
ហើយគេយកទៅដំកល់ទុកក្នុងពិពិធកណ្ឌស្ថានក្រុងបាងកក ។

ក្នុងរជ្ជកាលព្រះអង្គ ប្រាង្គប្រាសាទពដ្ឋានមានកំពូលខ្ពស់ត្រដួច
ត្រដាមស្ទឹមស្កៃ សុទ្ធសឹងលោកេស្វរៈសមន្តមុខ ព្រះនេត្រចំពាក់កណ្តាល
សំឡឹងចុះមកក្រោម ហើយព្រះតក្រែញញឹមស្រស់ប្រឹមប្រិយ ហៅថា
"ញញឹមបែបសិល្បៈអង្គរ" គន់មើលទៅឃើញហាក់បីដូចអង្គព្រះបាទ
ជយវរ្ម័នទី ៧ ដែលជាតួអង្គព្រះពោធិសត្វអវលោកិតេស្វរៈហោះហ្មាងចុះ
ពីឋានសុខាវតីមកថ្នាក់ថ្នមបីបម្រៀបក្បាប្រជាជនខ្មែរព្រមទាំងសត្វលោក
ឲ្យបានសេចក្តីសុខក្សេមក្សាន្តនិរទុក្ខនិរភ័យ ផុសផុលតើតច្រេះច្រាងដេរ
ជាសញ្ញាសព្វព្រះពដ្ឋអាណាចក្រកម្ពុជា ។ ទ្រង់បានកសាងប្រាសាទ
បន្ទាយក្តី តាព្រហ្ម ព្រះខាន់ ប៉ាយ័ន មន្ទីរពេទ្យ (អារោគ្យសាលា)
តាមថ្នល់ធំដែលទ្រង់កសាងតាមហានគរទៅពិមាយ (សៀម) ទៅប្រ-

ទេសចម្បា ។ ក្រៅព្រះពជធានីនៅមហានគរ ទ្រង់សាងប្រាសាទវត្តនគរ (កំពង់ធំ) តាព្រហ្ម ទន្ទេចាំ (តាកែវ) ប្រាសាទមួយទៀបន្ទាយ ឆ្នាំថ្វាយព្រះស្រីន្ទ្រកុមារជាព្រះពជបុត្រ នឹងទីឋានជាច្រើនទៀតច្រើនអនេក ដើម្បីឲ្យសមតាមព្រះពជបំណងថា «កសាងប្រទេសកម្ពុជាឲ្យក្សេមក្សាន្ត ជាឋានសួគ៌» (នឹងកសាងប្រជាជនខ្មែរឲ្យទៅជាទេពតា) ។

ទ្រង់សាងប្រាសាទតាព្រហ្មហើយឲ្យឈ្មោះថា "ព្រះពជវិហារ" ពី ព ស. ១៧២៩ (គ.ស. ១១៨៦) ទុំថ្វាយព្រះពុទ្ធសាសនា ដើម្បីជំនស់ បដិមាករព្រះនាងជយពជចូឌាមណីជាព្រះវរពជមាតាទុកជាអង្គព្រះប្រាជ្ញាបារមិតា គឺជាម៉ាតាបង្កើតព្រះពុទ្ធ នឹងបដិមាកវត្តអង្គព្រះពជគ្រូមួយទៀត ឈ្មោះជយមង្គលថៈ ។ សិលាចារឹកនៅប្រាសាទតាព្រហ្ម — ជាស្នាព្រះហស្តព្រះពជបុត្រព្រះអង្គព្រះនាមសូរ្យកុមារទ្រង់តែងឡើង រៀបរាប់ពីការកសាងនឹងការទុំនុកបំរុងវត្តនេះ បទដើមទមស្ការ សរសើរបារមីព្រះពុទ្ធជ័យវរ្ម័នទី ៧, បញ្ជីវត្ថុគ្រឿងទបកោគបរិកោគ វត្ថុសម្រាប់ពុទ្ធបូជា ។ ខ្ញុំដកស្រង់សេចក្តីខ្លះមកទុកក្នុងទីនេះ ។

នមស្ការព្រះរតនត្រ័យ

សម្ពារវិស្ដរវិការវិតធម្មកាយសម្ពោគនិមិតវិបុត្តគវាន្ទិតក្តៈ
យោគោចរពេជនជនាត្តដទេហកាជាំវុទ្ធាយកូតគរណាយ នមោស្តុ តស្មៃ
វន្ទេ និរត្តរមនុត្តរពោធិមគ្គំ កូតាថ៌ទគនទិកវរណែកនបូមិ
ថ្លៃ

ធម្មំត្រិលោកវិទំតាមវេស្សវនៃមន្តវំសត្ថ[1] ទូរបណ្ឌវិទ្ធណ្ឌគ្គមិ ។

សម្បត្តិមុក្តិបរិបន្ថតយា វិមុក្តសង្គ្រោ ច សន្តតកហ៊ីតបពន្ធសង្គ្គ: ។

សង្គ្គីយមានដនគាសនគាសិតាខ្យាន សង្គ្រោកសំហិតហិតប្រកវោតាទូ: ។

"ព្រះពុទ្ធដ៏មានបុណ្យអង្គ្គណា មានកាយចែកជា ៣ ចំណែក គឺធម៌កាយ ១ សម្ភោគកាយ ១ និម៌ានកាយ ១ ដែលជាផលកើត ចេញមកពីសម្ភារៈគឺបុណ្យ យើងខ្ញុំនមស្ការចំពោះអង្គព្រះពុទ្ធនោះ ដែលជាចំណែកនៃពាងកាយព្រះជនស្រីនឹងបុត្រនៃព្រះជនស្រី ហើយកើតបានជាសរណៈនៃសត្វលោក ។๑។

"យើងខ្ញុំសូមគ្រាបបង្គំចំពោះព្រៃធម៌ដ៏ក្សេម ជាមាគ៌ានៃពោធិ-ញ្ញាណដ៏ប្រសើរ ជាទ្រឹស្តីឯកបើកឲ្យបានយល់ធម៌ពិត ដែលជាធម៌គឺពួក អរិយក្ខន្ធ៌ត្រៃកតគួរគោរពវន្ទា ពុកជាព្រះខាន់សម្រាប់កាប់បំផ្លាញនូវគុម្ព បន្ទាលគឺសឹកសត្រូវខាងក្នុង ៦ ប្រការ ។๒។

" ដោយអានុភាពព្រះសង្ឃដែលមានប្រកពនៃប្រយោជន៍រួមគ្នា សូមអង្គលោកប្រទូរស្រឡះហើយដោយប្រពៃ អំពីសឹកសត្រូវនៃវិមុត្តិ-ញ្ញាណ ប៉ុន្តែលោកនៅជាប់ពាក់ពន្ធនឹងប្រយោជន៍នៃជនដទៃ ដែលអង្គ លោកបានប្រតិបត្តិត ។ មកហើយ អង្គលោកស្វាធ្យាយន៍អង្គលោកផង

---

๑. អនសែត + បទ + អរិ ធំ កាមៈ, ក្រោធៈ, លោភៈ, មោហៈ, មទៈ, មាត្សរ្យំ (មច្ឆរិយៈ) ។

ចម្រៀនទូវដំនសាសនាដល់ដនដទៃតាំងឡាយផង សូមការពារទូវលោក
អ្នកតាំងឡាយគ្រប់គ្នាកុំឃ្លាតឃ្លាឡើយហោង ។ ៣ ។

ព្រះសូរ្យកុមារជាព្រះពាជបុត្រសរសើរចារមីចំពោះអង្គព្រះ ចាទជយវ៌្ម័ន
ទី ៧ ជាអនេកប្បការតទៅទៀតត្រង់គាថាទី ៣៥នឹងទី៣៦ ដែលនៃយយ
ពីកសាងព្រះពាជវិហារ (ប្រាសាទតាព្រហ្ម) , សម្រាប់ដំកល់បដិមាករ
ព្រះនាងស្រីជយពាជចូឌាមណី ទ្រង់មានព្រះបន្ទូលថា

ទត្យាទិតា តេនកុជាគ្គហីតឆត្រាំ បុរីរាជវិហារនាម្មី
រត្នាល្ងសត សុណិកូមិភាគ្គី មុនិន្ទ្រមាតុកិរណេនិយុក្តា‖
ប្រាតិប្តបច្ច្រីជយពាជចូឌាមណី មណិខ្យោតិតបុណ្យទេហាម
តស្យាញ្ញនន្យា ជិនមាតុមូត្តិ៌ មូត្តិ៌ សមូត្តិ៌ខ្យុតតតាគ្គ្រវ៌ប:‖

"បុរីឈ្មោះពាជវិហារ (ប្រាសាទតាព្រហ្ម) នេះមានអង្គស្ថិតស្ថាន៍ហើយ
ដោយសុវណ្ណភូប្រុះឆ្នុះច្រវាត់ដោយពេជ្រ ទ្រង់(ព្រះចាទជយវ៌្ម័នទី ៧)ចាន
តសាង៍នៅលើផែនដី ដែលព្រះអង្គចាំង៍យកមកចាន៍ដោយ ព្រះហស្ត
ព្រះអង្គ ដើម្បីដំកកុលន់ទូវមុនិន្ទ្រមាតា. ។ ៣៥ ។

"ទ្រង់ដំកល់កុតន្ទូវបដិមាករនៃព្រះជមនីព្រះអង្គ ព្រះនាមស្រីជយពាជ
ចូឌាមណី ដែលមានព្រះតាយភ្នំ ផ្ទុកដោយតែវមណី កុតជាអង្គបដិមាករ-
នៃព្រះជនមាតាក្នុងឆ្នាំ ១១០៨ សក.[1] ។ ៣៦ ។

១- ១១០៨ សក: + = ១១៨៦ គ.ស. + ៥៤៣= ១៧២៩ ព.ស. ។

តទៅ, សិលាចារឹកនេះ រៀបរាប់ពីបញ្ជីមុខវត្ថុអាហារគោជនទឹង គ្រឿងប្រដាប់សម្រាប់ចំនុកបំរុងវត្ត "ព្រះពជវិហារ" នេះទៀត ។

នេះបញ្ជីគ្រឿងពុទ្ធបូជារាល់ថ្ងៃ ។ សម្រាប់បដិមាករ "ស្រីដយពជ ចូដាមណីទឹងទេវរូបបរិពារ" គឺ អង្គរ ២ ត្រាណៈ, ២ ប្រស្នៈ, ៧ភាគ - វិតា: ល្ង: ១១ ប្រស្នៈ; ២ ត្រាណៈ, ២ កុឌុវៈ; សណ្តែកដី:២ ត្រាណៈ, ២ កុឌុវៈ; សណ្តែកពជមាស: ១៤ ប្រស្នៈ; ទឹកដោះខាប់: ១ឃដី, ៣កុឌុវៈ; ឧធ ក្សីរ ទឹកឃ្មុំ: ៧ប្រស្នៈ ក្នុងមួយមុខៗ; ទឹកកេសជ្ជៈ ផ្អែម: ១ឃដី, ២ប្រស្នៈ ២កុឌុវៈ; ប្រេងល្ង: ៣ប្រស្នៈ, ២កុឌុវៈ ប្រេងតវុផល: ៣កុឌុវៈ, ។ មានគ្រឿងប្រដាប់ដទៃទៀត ..... ។

ទេវពស្ត្រ (សំលៀកបំពាក់ទេវតា) ៤៦០គូ, ត្រៃចិនសម្រាប់គ្រប ការពារព្រះភ្លៅទេវរូបកុំឲ្យមូសបៀតបៀន ៤៥ ។ វត្ថុសម្រាប់ចែកអ្នក ទៅជាមួយសាស្ត្រាចារ្យនឹងអ្នកទេសនា: អង្គរ១៤ភារ, ១ត្រាណៈ ៥ប្រស្នៈ, រាល់ៗថ្ងៃ ។

នេះបញ្ជីវត្ថុដែលត្រូវប្រើក្នុងរៀងរាល់ថ្ងៃបុណ្យមួយៗរាល់ឆ្នាំត្រូវប្រើ: អង្គរ ១០១៥ ភារ; ល្ង ៤០ ភារ; សណ្តែកដី ៤ ភារ ៣ ត្រាណៈ;

(មានត)

៣- ជនុសាយ ភាចាយ វេរមណី ការវៀរចាកសំដីទ្រគោះ

៤- សម្ផប្បលាបា វេរមណី ការវៀរចាកកិរិយាពោលរឿង
ឥតប្រយោជន៍ ។

សម្ភាកម្មន្តៈ

ការងារត្រូវបានដល់ការវៀរចាកកាយទុច្ចរិត ៣ យ៉ាង គឺ

១- ចាណាតិចាតា វេរមណី ការវៀរចាកកិរិយាបំបាត់
ប្រាណសត្វ;

២- អទិន្នាទានា វេរមណី ការវៀរចាកការគាន់យកវត្ថុដែល
គេមិនឲ្យ;

៣- កាមេសុមិច្ឆាចារា វេរមណី ការវៀរចាកការប្រព្រឹត្តិ
ខុសក្នុងកាមទាំងឡាយ ។

សម្ភាអាជីវៈ

ការចិញ្ចឹមជីវិតត្រូវ, សម្រាប់គ្រហស្ថ ចាន់ដល់ការវៀរចាកជំនួញ
ខុស កិរិយាលះបង់ការបំបាត់ដោយដញ្ជីនជាដើម ការធ្វើជាសាក្សីគេជ,

ការល្អកសំណុក ហើយប្រកបអាជីវកម្ម ដោយវណិជ្ជកម្មដែលនាំ
ឲ្យសេដ្ឋកិច្ចជាតិចំរើន, ដោយវិជ្ជាជីវៈ ដ៏យុត្តិធម៌, ដោយតស៊ូកម្ម ជា
ទុក្ករកម្ម និងគោរក្ខកម្ម; សម្រាប់បព្វជិត បានដល់ការលះបង់មិច្ឆាអាជីវៈ
ដោយអនេសនៈជាបធម៌ មានខួតកម្ម វៀរកម្មជាដើម ការត្រាច់ទៅតាម
អគោចរដ្ឋាន ហើយចិញ្ចឹមជីវិតដោយកិរិយាចរិយធម៌ដ៏ស្មើ ឬបច្ច័យដែល
កើតឡើងតាមធម៌ ។

សម្មាវាយាមៈ

ព្យាយាមត្រូវ បានដល់សម្មប្បធាន គឺការបង្កើតឆន្ទៈ ព្យាយាម
ប្រារព្ធ វិរិយៈ តាំងបធាន ផ្គងចិត្តៈ

-ដើម្បីមិនឲ្យអកុសលធម៌លាមក មិនទាន់កើតឡើង កើតឡើងបាន;

- ដើម្បីលះបង់នូវអកុសលធម៌លាមកកើតឡើងហើយ;

- ដើម្បីឲ្យកុសលធម៌មិនទាន់កើតឡើង កើតឡើង;

- ដើម្បីឲ្យកុសលធម៌កើតឡើងហើយ ឋិតនៅ មិនសាបសូន្យ
ឲ្យចំរើនច្រើនឡើង ឲ្យចំរើនពូលំពូលាយ ឲ្យបរិបូណ៌ ។

សម្មាសតិ

ការរលឹកត្រូវ បានដល់សតិប្បដ្ឋាន៤គឺ

๑- កាយានុបស្សនាសតិប្បដ្ឋាន តំរិះដំកល់សតិខ្ជាប់
ខ្ជួនពិចារណារឿយ ។ កូនកាយៈ

๒- វេទនានុបស្សនាសតិប្បដ្ឋាន ការយាងកំណត់សតិ ខ្ជាប់ខ្ជួនពិចារណារឿយៗ ក្នុងវេទនា;

๓- ចិត្តានុបស្សនាសតិប្បដ្ឋាន ការយាងកំណត់សតិ ខ្ជាប់ខ្ជួន ពិចារណារឿយ ៗ ក្នុងចិត្ត;

๔- ធម្មានុបស្សនាសតិប្បដ្ឋាន ការយាងកំណត់សតិ ខ្ជាប់ខ្ជួន ពិចារណារឿយ ៗ ក្នុងធម៌ ។

សម្មាសមាធិ

សមាធិត្រូវ បានដល់ឈាន៤ ដែលកើតអំពីសូន្យចាកកាមធាតុ ឬយ ចាកអកុសលធម៌ធាតុ ឬយ ហើយបានសំរេច គឺ

๑ បឋមជ្ឈាន ប្រកបដោយវិតក្ក: វិចារ: មានបីតិ សុខ: កើតអំពីវិវេក;

๒- ទុតិយជ្ឈាន រម្ងាប់វិតក្ក: វិចារ: ថ្កាល្អខាងក្នុង មានឯកោ-ទិភាពចិត្ត មានបីតិសុខកើតអំពីវិវេក;

๓- តតិយជ្ឈាន ប្រាសចាកបីតិ មានសុខ: នឹងបេក្ខា,

๔- ចតុត្ថជ្ឈាន លះបង់សុខនឹងទុក្ខ មិនមានសោមនស្សនឹងទោមនស្ស ជាអទុក្ខមសុខ: មានសតិប្រកបដោយឧបេក្ខាជំរះសុទ្ធ ។

បណ្ណាមក្តងាំង ๘

- សំម្មាទិដ្ឋិ ញ៉ាំងលោកឲ្យដឹងច្បាស់នូវ អរិយសច្ចា ទុក្ខ-

តា អនត្តតា, នូវសម្មុទ័យនៃលោកប្បញ្ញា គឺតណ្ហា, នូវទុក្ខាយដោះ
នឹងកិរិយាដោះ;

- សម្មាសង្កប្ប: ឲ្យស្គាល់សម្មុដ្ឋានអសន្តិភាព គឺតាម: ព្យា-
បាទ: វិហឹសា ហើយឲ្យសាធសន្តិភាពដោយតាមវិតក្ក ព្រហ្មវិហារធម៌៤
ជាធម្មស្ងួនលោក;

- សម្មាវាចា ឲ្យមានសច្ច: មានសន្តិភាពសាមគ្គីអរិយធម៌ដោយ
វាចានឹងវាចាប្រកបដោយប្រយោជន៍;

- សម្មាកម្មន្ត: ឲ្យគោរពសិទ្ធិ សេរីភាព អធិបតេយ្យដែលមាន
សំពាប់តាយកិតចេតសិកសុខដ៏វិត សវិញ្ញាណកាវិញ្ញាណកទ្រព្យ ត្រាមធម៌;

- សម្មាអាជីវ: ឲ្យប្រកបអាជីវកម្មដោយធម៌;

- សម្មាវាយាម: ឲ្យលះបង់អាលស្យភាព (កំដិល) ដែលជា
ប្រធានអកុលសធម៌;

- សម្មាសតិ ឲ្យមានសតិសម្បជញ្ញ:ជានិច្ចថា«លោកមានសម
ភាពទៅវិញទៅមក» ព្រោះលោកជាទឹក ដី ភ្លើង ខ្យល់ បិតនៅក្នុង
អាណា អនិច្ចតា ទុក្ខតា អនត្តតា ដូចគ្នា ជាប់ពាក់ពន្ធលោកប្បញ្ញា
ដូចគ្នា;

- សម្មាសមាធិ ឲ្យមានចិត្តស្អាតផូរផង់ តាំងនៅមាំមួនចំពោះ
សភ្លឹងនឹងសង្ខារ។

มគ្គ៨នេះចាត់ចូលក្នុងសិក្ខា៣ គឺ

សម្មាទិដ្ឋិ សម្មាសង្កប្បៈ ចូលក្នុងអធិប្បញ្ញាសិក្ខា,

សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ចូលក្នុងអធិសីលសិក្ខា,

សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ចូលក្នុងអធិចិត្តសិក្ខា ។

ព្រះពុទ្ធសាសនា មានគោលធម៌ប៉ុណ្ណេះជាដើម ដែលជាពន្លឺបំភ្លឺលោក ឲ្យភ្លឺស្វាង ចាកមហន្ធការគឺអវិជ្ជា ហើយឲ្យស្គាល់មគ្គាបាយសាធនសន្តិភាពសម្រាប់សាកលលោក នឹងឯកន្តសន្តិភាព គឺសន្តិភាពសម្រាប់ខ្លួននាបច្ចុប្បន្ន អនាគត នឹងសន្តិភាព រួចចាកអាណាលោកវាជ នឹងលោកប្បញ្ញានាអវសានជាតិ ។

រាត្រីសតវត្សទី២៥ នៃពុទ្ធសកវាជ, ពិភពលោកក្នុងកំឡុងកាលស្មើអាទិត្យ ត្រូវលោកសង្គ្រាមគំហុកយ៉ាងខ្លាំង ព្រោះលោកខ្វះមនុស្សធម៌ ដល់គំរប់២៥០០ វស្សានៃពុទ្ធសកវាជ ក៏មានចិត្តស្នេហាសន្តិភាពជាខ្លាំង ធ្វើបុណ្យរំលឹករយៈកាល២៥០០ វស្សា ដើម្បីសន្តិភាព ប៉ុន្តែសន្តិភាពមិនមែនមានត្រង់អំនួតថា "ខ្ញុំធ្វើពិធីនេះដែរ" ទេ ព្រោះដំណើរនោះជាអាកប្បកិរិយាក្លែងបន្លំក៏សឹងមាន សន្តិភាពឥតអាម៉ិសមានទៅត្រង់ការប្រតិបត្តិ

តាមគោលនៃព្រះសទ្ធម្ម ๘ ដែលពោលមកហើយនោះពិត ។ ។

បើលោកត្រូវការសន្តិភាព ស្រឡាញ់សន្តិភាព សូមអញ្ជើញធ្វើតាមគោលព្រះសទ្ធម្ម ๘ នោះចុះ ។

๒- សទ្ធម្មបរិប្ដេទ

ព្រះសទ្ធម្មគឺព្រះពុទ្ធសាសនា ដែលព្រះមានជោគប្រកាសដោយប្រពៃ ហើយយើងជាពុទ្ធបរិស័ទបានជឿថា នឹងឋិតនៅអស់កំរិត ๕๐๐๐ឆ្នាំ ។

ព្រះសម្មាសម្ពុទ្ធទ្រង់សាងព្រះសទ្ធម្មដោយញាណពល ជ្រាបស្ថិតិពលព្រះសទ្ធម្មដោយអនាគតំសញ្ញាណ ព្រោះអាស្រ័យហេតុនោះ ។ ដូចព្រះពុទ្ធដីកាដែលព្រះមានជោគត្រាស់នឹងអានន្ទត្ថេរ ក្នុងកិកុនីវគ្គៈថា

វស្សសហស្សំ អានន្ទ សទ្ធម្មោ តិដ្ឋេយ្យ សចេ កិកុនិយោ ន បព្វជិតា អស្សុ បញ្ចវាទានំ អានន្ទ វស្សសតានិ សទ្ធម្មោ ឋស្សតិ

ម្នាលអានន្ទ ព្រះសទ្ធម្មគប្បីឋិតនៅអស់ពាន់ឆ្នាំ ប្រសិនបើ កិកុនីទាំងឡាយ មិនគប្បីបានបួស ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្មនឹងឋិតនៅតែ ๕๐๐ឆ្នាំវិញ ។

(មានត)

ពុទ្ធសាសនាដៀបសាសនាដទៃ

របស់

ឃុនអត្តការិទ ជា-យ្សរ

ឃុនសុត្តវេទី យ្សរ-អ៊ុង ពាក្យកែសម្រួល

(តមក)

តាមគម្ពីរនៃអ៊ីស្រាអែល ពោលថា កាលមោសេស៍មកដល់ឆ្នេរ សមុទ្រក្រហម ព្រះយេហូវ៉ាទ្រង់បណ្តាលឲ្យទឹកសមុទ្រធំ មោសេស៍ ព្រមទាំងបក្ខពួកបានឆ្លងសមុទ្ររួចដល់ត្រើយនាយទាំងអស់ ។ ចំណែក អេហ៊ាពលព្រះបាទហ្វារ៉ាអុង ដែលលើកដេញតាមទៅនោះ កាលដល់ កណ្តាលសមុទ្រ ព្រះជាម្ចាស់បណ្តាលឲ្យទឹកជោរ ពួកពលទាំងនោះក៏ លង់ទឹកស្លាប់អស់ ។ ពួកអ៊ីស្រាអែល ដែលរួចផុតពីកណ្តាប់ដៃអេស៊ុប បានមកតាំងភូមិលំនៅក្នុងប្រទេសស៊ុយដា មានសេចក្តីចំរើនរុងរឿងជាយ ូរជាប់ ។ លទ្ធិសាសនាក្នុងសម័យដែលអ៊ីស្រាអែលរើខ្ទួនរួចជាអ្នកជានោះ មានការបូជាយ ញ្ញ នឹងការធ្វើតាមពាក្យប្រៀនប្រដៅរបស់មោសេស៍ ជា លទ្ធិស្រដៀងនឹងលែបបចាស់របស់ពួកព្រាហ្មណ៍ ខុសគ្នាបន្តិចបន្តួច ។

កំណើតសាសនាគ្រិស្ត

កាលពុទ្ធសករាជកន្លងទៅបាន ៥៤៣ ឆ្នាំ ព្រះយេស៊ូ បានមកចាប់ បដិសន្ធិក្នុងផ្ទៃមាតាដែលនៅក្នុងចំណោមជនជាតិអ៊ីស្រាអែល ។ តាមប្រវត្តិ

របស់ព្រះយេស៊ូថា ព្រះយេស៊ូមានមាតាឈ្មោះ ម៉ារី បិតាមិនច្បាស់ឈ្មោះ ព្រោះនាងមានគភ៌តាំងពីមុនបាន សាំងត៍-យ៉ូសេប្ប៉ (saint-joseph) ជាស្វាមី ។ ព្រះយេស៊ូកាលចំរើនវ័យធំឡើង បានជ្រើសរើសយកពាក្យប្រៀនប្រដៅដែលល្អ។ ក្នុងសាសនាអ៊ីស្រាអែលនោះឯង មកប្រៀនប្រដៅពួកជន ហើយប្រកាសខ្លួនថាជាកូនព្រះយេហូវ៉ា មានសិស្សានុសិស្សតែតែច្រើនឡើង ។ មេសាសនាអ៊ីស្រាអែលឃើញថា តើយ៉ោព្រះយេស៊ូនេះជាហេតុឲ្យសាបសូន្យសាសនារបស់ខ្លួន ទើបឲ្យចាប់ព្រះយេស៊ូយកមកប្រហារជីវិត ធ្វើទណ្ឌកម្មដោយវាយដែកគោល នៅដៃខ្លះនៅដើមខ្លះឆ្កាងដោយឈើឆ្កាង ទុកថាលែងតែអស់ជីវិត ។

សាសនាគ្រិស្តក្នុងប្រទេសអឺរ៉ុប

កាលព្រះយេស៊ូអនិច្ចកម្មទៅហើយ សាវ័កដែលនៅសេសសល់ ក៏លាក់ខ្លួនបំពួនអាត្មា នៅក្នុងប្រទេសស៊ុយដា តែមិនបានសេចក្តីសុខ ។ មានសាវ័កម្នាក់ឈ្មោះ សេន្តពីត្រែ រត់ទៅអាស្រ័យនៅក្នុងក្រុងរ៉ោម ។

ជាតិរ៉ោម៉ាំងក្នុងសម័យនោះ ជាជាតិដែលមានអំណាចធំជាងគេក្នុងអឺរ៉ុប ពង្រីកអាណាខេត្តបានយ៉ាងទូលំទូលាយ ។ រដ្ឋស៊ុយដាដែលជាទីកើត នៃសាសនាសូហ្វូនីធ សាសនាគ្រិស្ត ក៏នៅក្រោមបង្គាប់ចក្រពត្តិរ៉ោម៉ាំង តែលទ្ធិសាសនាជាន់នោះនៅថោកទាបផ្តេសផ្តាសនៅឡើយ

កាលសេន្តពីតេរបួលទៅនៅក្នុងស្រុកពេម ជានយកលទ្ធិរបស់ខ្លួនទៅ
ប្រដៅពួកពេមុំនដោយលួចលាក់ ។ ពួកជនានុជនតំមានសទ្ធាជ្រះថ្លា
ជឿតាន់ដោយច្រើន ។ រជ្ជាភិបាលពេមុំនជានដឹងតំចាប់សេន្តពីតេរ
យកទៅប្រហារជីវិតបង់ ។ ឯសាវ័កដែលនៅសេសសល់ជានរួបរួមគ្នា
តាំនជាពួកខ្មែរនខ្មែត ត្រូវរជ្ជាភិបាលចាប់ប្រហារខ្មែត ។ សាសនា
គ្រិស្តជានត្រូវគេចាប់ប្រហារជាច្រើនលើក តែដោយសាសនានេះមាន
ទ្ងឹមសារជាងសាសនាពេមុំន ទើបអំណោះតមក សាសនាគ្រិស្តតំជាន
រីកសាយភាយពេញក្រុងពេម ។ កាលពួកពេមុំនរាប់អានសាសនាគ្រិស្ត
ពេញពីហើយ ពេលដែលលើកទ័ពទៅច្បាំនទឹនប្រទេសផ្សេង ។ មាន
ប្រទេសប្រឹតន្ទឹក (Pritannigue អន់គ្លេស) ទឹនប្រទេសគោឡា
(gola ជាកំនើសែស) ជាដើម មានជ័យជំនះហើយ សាសនាគ្រិស្តតំ
ផ្សាយចូលទៅក្នុងប្រទេសនោះ ។ ផន ។ តមក សាសនាគ្រិស្តជានផ្សាយ
ចូលទៅក្នុងប្រទេសដទៃខ្មែត ដោយអាការដូចជានពោលមកនេះដែរ ។

ការប្រៀបធៀបព្រះពុទ្ធសាសនា
ទឹងសាសនាគ្រិស្ត

ព្រះពុទ្ធសាសនា ទឹនសាសនាគ្រិស្ត កាលបើប្រៀបធៀបគ្នាហើយ
តំមានគោលសំខាន់ ដែលយើនទឹនឃើញជានដូចតទៅនេះ ៖

១- ព្រះសម្ពុទ្ធរបស់យើងទ្រង់កើតក្នុងវត្តិយត្រកូល ។	១-ព្រះយេស៊ូកើតក្នុងត្រកូលជាងឈើ ។
២- ព្រះបិតានៃព្រះសម្ពុទ្ធជាជាតិក្សត្រ ។	២- បិតាព្រះយេស៊ូ មិនប្រាកដឈ្មោះ ។
៣- ព្រះសម្ពុទ្ធទ្រង់ពោលចំពាស់សាសនាព្រាហ្មណ៍ ទោះបីជាយ៉ាងនោះ ពួកព្រាហ្មណ៍កាលបានស្តាប់ពាក្យព្រះអង្គហើយក៏សំគាល់តែឃើញថាត្រូវពិត នាំគ្នាចុះចូលជាច្រើនទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនា បានចំរើនរុងរឿងដោយស្នាព្រះឧស្សាហ៍របស់ព្រះអង្គ ដោយគ្មានអន្តរាយ ។	៣-ព្រះយេស៊ូពោលចំពាស់សាសនាស៊ូហ្វ ត្រូវគេចាប់ប្រហារជីវិត ។
៤- ព្រះពុទ្ធសាសនា កើតមុនសាសនាគ្រិស្ត ។	៤- ពាក្យប្រដៅព្រះយេស៊ូគោលសំខាន់ៗនៅក្នុងសាសនធម៌របស់ព្រះសម្ពុទ្ធ ។
៥- ព្រះសម្ពុទ្ធទ្រង់សំដែងធម៌មានហេតុផល មិនបានបង្គាប់បញ្ជាឲ្យគេជឿតាមទេ តែធម៌របស់ព្រះអង្គជាធម៌ពិត នាំឲ្យអ្នកស្តាប់កើតសទ្ធាជឿការាន់ដោយខ្លួនឯង ។	៥- សាសនាគ្រិស្តបង្គាប់ថា ត្រូវមានសេចក្តីជឿក្នុងព្រះយេស៊ូយ៉ាងមាំជាមុនសិន ។

សេចក្តី ៖ នេះបំភ្លឺឲ្យឃើញថា ព្រះពុទ្ធសាសនាមានតម្លៃជាង
សាសនាគ្រិស្ត ។ បើប្រៀបធៀបអ្នកសាងសាសនា គ្រឹមមេលខ្ចី
នឹងមេលខ្ចីប៉ុណ្ណោះ យើងក៏ឃើញបានថា ព្រះសម្ពុទ្ធព្រះអង្គប្រសើរ
ជាងព្រះគ្រិស្ត ព្រោះព្រះអង្គជាទត្តិយត្រកូល បានទទួលសេចក្តី
សុខជាអនេក តែទ្រង់ស៊ូលះសេចក្តីសុខ មកទទួលយកសេចក្តីទុក្ខពិបាក
ដើម្បីធ្វើប្រយោជន៍ដល់បណ្តាជនទូទៅ ជាការដែលគេធ្វើបានដោយក្រ
តែក្រលែង ។ សាសនធម៌នៃព្រះអង្គ អ្នកមានក្តី អ្នកទ័លក្រក្តី អាចធ្វើបាន
ដោយងាយ ព្រោះជាផ្លូវប្រតិបត្តិកណ្តាល មិនតឹងពេក មិនធូរពេក ។
ព្រះសម្ពុទ្ធទ្រង់ប្រៀនប្រដៅពួកព្រាហ្មណ៍ ដែលមានសេចក្តីចេះដឹងជិន្តិន
ខ្ពស់ ពាំនាំលទ្ធិសាសនាកំចាត់រើនជាងពួកភេម៉ាំងច្រើនកាត បានផលសំរេច
ដោយស្នាព្រះឧស្សាហៈរបស់ព្រះអង្គ ។ ព្រះពុទ្ធសាសនាផ្សាយចូលទៅក្នុង
ប្រទេសដទៃបានដោយស្រួល ព្រោះគេឃើញសាសនធម៌របស់ព្រះអង្គ
សុទ្ធតែជារបស់ពិត ពាំនាំជាគ្រឿងធ្វើឲ្យផុតចាកទុក្ខ ជាធម៌គួរគាន់យក
គួរធ្វើទុកក្នុងចិត្ត មិនចាំបាច់អាស្រ័យអំណាចនៃជាតិណាជួយឡើយ ។

ចំណែកសាសនាគ្រិស្ត ផ្សាយចូលទៅក្នុងប្រទេសអឺរ៉ុប ក្នុងពេល
ក្រោយក៏ពិតមែន តែផ្សាយចូលទៅដោយពិបាកក្រៃលែង ត្រូវអាស្រ័យ
អំណាចជាតិភេម៉ាំងជួយផង ទើបសម្រេច ។

ហេតុដែលធ្វើព្រះពុទ្ធសាសនាឲ្យសាបសូន្យ

ធំឯគោលដែលគួរប្រយ័ត្ន

ក្នុងសម័យដែលព្រះសម្ពុទ្ធបរិនិព្វានទៅហើយ កន្លងមកដល់ខណៈធ្វើសង្គាយនាគ្រាទី ២ ភិក្ខុបែកគ្នាជាពីរគណៈ ដោយហេតុមានសេចក្តីយល់ឃើញបែកខ្វែកគ្នាក្នុងមាត្រាវិន័យបញ្ញត្តិ មានអាទិ៍ថា "វេលាវិកាល" ។ ភិក្ខុគណៈកណ្តាលប្រកាន់ថា តាំងអំពីថ្ងៃជ្រេពីត្រង់ទៅ ជាវេលាវិកាល ទើបតំណាក់ថា ព្រះសង្ឃឆាន់ចង្ហាន់បាន តាំងពីព្រះអាទិត្យរះទៅល់ធឹងថ្ងៃត្រង់ប៉ុណ្ណោះ ចំណែកការលាភក្នុងវិកាល គឺភិក្ខុលាភិក្ខុផងគ្នាទៅកាន់ស្រុក កំណត់យកពេលព្រះអាទិត្យលិចរហូតដល់ភ្លឺស្រាង ភិក្ខុឆាន់ចង្ហាន់ក្តីចេញទៅកាន់ស្រុកក្តី ធ្វើបានតាំងពីព្រះអាទិត្យរះរហូតដល់ព្រះអាទិត្យលិច ។ សេចក្តីយល់ឃើញបែកខ្វែកគ្នាទាំង ២ យ៉ាងនេះ គាត់ឲ្យខ្វីមកថា ភិក្ខុគណៈកណ្តាលប្រកាន់ថាតាំងពីព្រះអាទិត្យជ្រេទៅ ឆាន់ចង្ហាន់មិនបាន ពួកវជ្ជបុត្រប្រកាន់ថា ឆាន់បានតាំងពីព្រះអាទិត្យរះរហូតព្រះអាទិត្យលិច ចំណែកការលាភិក្ខុផងគ្នាក្នុងវេលាវិកាល គាន់ត្រូវគ្នាទាំង ២ គណៈ ។ សេចក្តីឃើញបែកខ្វែកគ្នាដូច្នេះ នៅមានច្រើនទៅទៀត ។

តមក ពួកភិក្ខុវជ្ជបុត្រចាន់ទៅប្រកាសសាសនា ប៉ែកខាងទិស

ទត្តរនឹងទិសបូព៌ា គឺទៅខាងប្រទេសឥណ្ឌា ចិន, ជប៉ុន, ចុះមកដល់ប្រទេសយួន គាំងជាពួកគណៈ មានរហូតដល់មកសព្វថ្ងៃនេះ ។ ចំណែកពួកភិក្ខុនិកាយកណ្តាល ផ្សាយសាសនាចុះមកខាងទិសទក្សិណ គឺមកខាងប្រទេសលង្កា, កូមា, ថៃ, រហូតមកដល់ប្រទេសខ្មែរយើង ។

គម្ពីរដែលប្រតិស្ថានព្រះពុទ្ធវចនៈ ពួកវដ្ដប៉ុត្រប្រើភាសាសំស្ក្រឹត តាមរបៀបដើម បែកខាងនិកាយកណ្តាលផ្ទាស់ប្រើជាភាសាមគធៈ ដើម្បីជាសំរួលដល់ពួកទក្ខិណទិស ដែលច្រើនតែនិយាយភាសាមគធៈ ។ កាលបើគម្ពីរដែលប្រដៅសាសនាប្រើភាសាទុំសគ្នាដូច្នេះហើយ ការវិវាទគ្នាក៏តិតែមានច្រើនឡើង ។

កំណើតនិកាយមហាយាន និងហីនយាន

ពួកភិក្ខុវដ្ដប៉ុត្រដែលប្រើគម្ពីរជាភាសាសំស្ក្រឹត គេអាងថាបានរក្សាទុកនូវព្រះពុទ្ធសាសនាដែលពិតប្រាកដ ទើបឲ្យនាមនិកាយរបស់ខ្លួនថា មហាយាន គឺជាយានធំ ដែលអាចនាំព្រះពុទ្ធសាសនាឲ្យសំរេចបានតាមគោលដើម ហៅភិក្ខុគណៈកណ្តាលថា ហីនយាន ជាយានថោកទាប ព្រោះប្រើភាសាមគធៈ ដែលជាភាសាចុងស្រុក ។ តមកគណៈទាំង ២នេះ ក៏បានដើរបែកខ្វែកគ្នាទៅ ។ កាលបើករណីយកិច្ច

សព្វបើប្រើបាលី តំប្រើផ្សេងគ្នាទៅហើយ តំអស់ផ្លូវដែលនឹងរួបរួមគ្នាបាន ។ ហេតុដែលកត់ទុកបែកគ្នាជា ២ គណៈនេះ ជាការណ៍នាំឲ្យព្រះពុទ្ធសាសនាសាបសូន្យជាគ្រាដំបូង ។

សេចក្តីសាបសូន្យ នៃព្រះពុទ្ធសាសនា
នៅប្រទេស ទីបេត៍ ចិន ជប៉ុន យួន

ព្រះសង្ឃចិន ជប៉ុន យួន ដែលប្រើភាសាសំស្ក្រឹត តាមលទ្ធិមហាយានខាង តមកភាសាក៏ក្សាបានសាបសូន្យចុះជាយលំដាប់ ព្រោះព្រះសង្ឃមិនយកចិត្តទុកដាក់ ។ ពេលក្រោយមក គេយល់ឃើញព្រមគ្នាថា ភាសាសំស្ក្រឹតជាភាសាពិបាកពោល ទើបរិះរកភាសាដែលងាយពោល បានយល់ឃើញថាភាសាជាតិ ជាភាសាងាយពោល គេទើបប្រើភាសាជាតិជាភាសាបាលី ដំនួសសំស្ក្រឹត តើតទៅជាចំនៀមឡើង គឺព្រះសង្ឃចិនសូត្រធម៌ជាភាសាចិន ព្រះសង្ឃជប៉ុនសូត្រធម៌ជាភាសាជប៉ុន ព្រះសង្ឃយួនសូត្រធម៌ជាភាសាយួន ដូចយើងតែងឃើញព្រះសង្ឃយួនសូត្រក្នុងតិកនៅសម័យនេះ ។ ភាសាសំស្ក្រឹត ទោះបីបានផ្ទាស់ប្តូរមកហើយក៏ដោយ គេក៏មិនបានលះចោលដោយជាប់ស្រឡះទេ គេសរសេរជាមន្តអាគមជាដើម ក្នុងដំបូងដំណើរដោតតំកល់ទុក បើអ្នកណាចង់បានបុណ្យច្រើន តែមិនចេះសូត្រភាសាសំស្ក្រឹត គ្រាន់តែយកដៃទៅបង្វិលបំពង់ឲ្យ

វិលប៉ុណ្ណោះ តំណាប់ថាបានបុណ្យច្រើនអនន្ត ។ ព្រះពុទ្ធសាសនាក្នុងប្រទេសចាំងនេះ រដ្ឋាភិបាលមិនបានទំនុកបម្រុង បើព្រះសង្ឃមិនយកចិត្តទុកជាក់ ក្នុងព្រះធម៌វិន័យដោយម៉ត់ចត់ទេ លុះទីមហាយានក៏នឹងចេះតែសាបសូន្យទៅដោយលំដាប់ ហើយនឹងសល់នៅតែពាក្យប៉ុណ្ណោះ ។

សេចក្តីសាបសូន្យនៃព្រះពុទ្ធសាសនា នៅប្រទេសយើង

ចំណែកលទ្ធិហីនយានដែលផ្សាយចូលមកក្នុងប្រទេសយើង សូម្បីមានរដ្ឋាភិបាលទំនុកបម្រុងក៏ពិតមែន តែបើព្រះសង្ឃមិនប្រតិបត្តិតាមធម៌វិន័យដោយម៉ត់ចត់ទេ ព្រះពុទ្ធសាសនាក៏នឹងចេះតែសាបសូន្យទៅមួយបន្តិចមួយបន្តិច ក្នុងទីបំផុតក៏នឹងសរសេរមន្តអាគម ជាតំនៅខាងក្រៅ បង្គឹតទុកតាមវត្ត ឬតាមភូមិ ឬក៏សរសេរព្រះបត់ព្យុះទុកតាមសាលា ដោយគិតថាធ្វើដូច្នេះ ជាបុណ្យជាកុសលពេញទី ។ សេចក្តីសាបសូន្យនៃព្រះពុទ្ធសាសនាដែលប្រព្រឹត្តទៅតាមទំនងនេះ ដោយហេតុ ២ ប្រការគឺ

๑- មកពីព្រះសង្ឃដែលបួស ក៏សោះតែថាបួស មិនយកចិត្តទុកជាក់ក្នុងព្រះធម្មវិន័យដោយម៉ត់ចត់ ។

๒- គ្រហស្ថដែលទំនុកបម្រុងព្រះសង្ឃ មិនចេះរើសថា ព្រះសង្ឃណា គួរទំនុកបម្រុង ឬមិនគួរទំនុកបម្រុង ។

ការបួស

ការបួសនោះតាមគោលបំណងនៃព្រះពុទ្ធសាសនា មិនមែនបួសដើម្បីអាជីព មិនមែនបួសដើម្បីសម្រាកពាងកាយឲ្យស្រួលមួយជន្មមួយគ្រា ឬមិនមែនបួសចៀសកិច្ចការដែលខ្ជិនខ្ជិលប្រតិបត្តិនោះទេ ។ ការបួសដោយពិតនោះ សំដៅយកការបួសដើម្បីលាស់ការកេងំលំកន្ត្រាក់ទ្រព្យសម្បត្តិដែលជាគ្រឿងធ្វើចិត្តឲ្យសៅហ្មងផ្សេង ។ ឬថាបួសដើម្បីលាស់ទុក្ខ ធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ក្នុងដួងចិត្ត ។

ព្រះសង្ឃដែលគួរទំនុកបម្រុង

๑- បួសបំណងលាស់តាម តាំងធ្វើប្រយោជន៍ដល់ប្រជាជន ។

๒- បួសតាំងចិត្តព្យាយាមរៀនធម្មវិន័យ ដើម្បីទ្រទ្រង់ទុកឲ្យបានបរិសុទ្ធរហូតកាល ។

๓- បួសរៀនចេះហើយ ប្រដៅប្រជាជន ឲ្យរៀបចាកទុច្ចរិត្តមានមិនឲ្យបៀតបៀនគ្នានឹងគ្នាជាដើម ។

๔- បួសហើយប្រព្រឹត្តត្រឹមត្រូវ ធ្វើឲ្យជាតួយ៉ាងដល់សហព្រហ្មចារី ។

๕- បួសហើយ មិនចង់បានប្រៀបនឹងពួកអ្នកស្រុក គឺរង់ចាំទទួលតែការទំនុកបម្រុងប៉ុណ្ណោះ មិនធ្វើប្រយោជន៍តបវិញ គឺមិនជួយក្លែរលាស់គ្រហស្ថជាដើម ។

(មានត)

ព្រហ្មចរិយកថា

ព្រះញាណកោសល ញាណ-ឈិន រៀបរៀង

ឧមត្តំ រតនត្តយំ សរ្ជ

សូមថ្វាយបង្គំចំពោះព្រះរតនត្រ័យដោយសេចក្តីគោរព ។

វេលានេះ សូមសំដែងអំពីព្រហ្មចរិយធម៌ ដែលមានសេចក្តីពិស្តារក្នុងអដ្ឋកថាមង្គលសូត្រ ត្រង់គាថា ទី៤ មង្គលទី៣៦ ត្រមាំងទាហរណ៍សម្រាប់បំភ្លឺសេចក្តីនៃព្រហ្មចរិយធម៌នោះ ។ ដោយបំប្រួញដូចមានតៗថា :

ក្នុងវារៈឯបឋមពោធិកាល ដែលព្រះសម្ពុទ្ធជាម្ចាស់របស់យើងនេះបានត្រាស់ដឹងពោធិញ្ញាណហើយថ្មីៗ វេលានោះ ស្តេចប្រថាប់នៅនាវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីដ៏ជិតក្រុងសាវត្ថី មានពួកទេព្តាជាច្រើនចូលមកក្រាបបង្គំទូលសួរនូវមង្គល ចំពោះព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលទេព្តា មង្គលមាន ៣៨ ប្រការ មានភាវៈមិនសេពគប់នូវជនពាលជាដើម ទើបមានសេចក្តីក្សេមចាកគ្រឿងសៅហ្មងគ្រប់យ៉ាងគឺព្រះនិព្វាន ជាទីបំផុត, គាថានេះ ជាមង្គលដ៏ឧត្តមរបស់ទេព្តាទើបមនុស្សទាំងឡាយ ។

លុះព្រះសម្ពុទ្ធទ្រង់តបដូច្នេះហើយ ពួកទេព្តាមានចិត្តរីករាយត្រេក

អាសាទរ ចំពោះកាសិតដែលទ្រង់សំដែងនោះ កំនាំគ្នាថ្វាយបង្គំលាព្រះមានព្រះភាគ ត្រាកចាកទីនោះចៀសចេញទៅ ។

ឯព្រហ្មចរិយកថា[1] នោះ មានន័យដូច្នេះថា ព្រហ្មចរិយំ ជាមគ្គផលវេយ្យាវច្ចមញ្ញសីលអប្បមញ្ញាមេថុនវិរតិសន្តោសវិរិយឧបោសថង្គអរិយមគ្គសាសនវិសេសទាំង បោតិ សេចក្តីថា ធម៌ពាំង១០ប្រការគឺ

๑- ការបរិច្ចាគទាន,

๒- ការរួលរាយបំរើព្រះរតនត្រ័យ,

๓- ការរក្សានិច្ចសីលមានអង្គ ๕ ប្រការ,

๔- ការចំរើនព្រហ្មវិហារពាំង ๔ ប្រការ,

๕- ការវៀរចាកសេពមេថុន,

๖- ការសន្តោសចំពោះតែប្រពន្ធខ្លួន,

๗- ការប្រព្រឹត្តិព្យាយាម,

๘- ការរក្សាឧបោសថសីលមានអង្គ ๘ ប្រការ,

๙- ការប្រតិបត្តិតាមអដ្ឋង្គិកមគ្គ,

๑๐- ការអនុវត្តន៍តាមសាសនា ។ ពាំងអស់នេះហៅថាព្រហ្មចរិយធម៌ ប្រែថា «សភាពប្រព្រឹត្តយ៉ាងប្រសើរវិសេស» ។

๑- មង្គលត្ថទីបនីភាគ ๔ ទំព័រ ๑๙๓ ។

ក្នុងចំណោមព្រហ្មចរិយធម៌ទាំង ១០ប្រការនេះ មិនបានសំដែងឲ្យចប់សព្វគ្រប់ទេ សូមសំដែងចំពោះតែតាន ព្រហ្មចរិយៈទី ១ នៃសាសន៍ព្រហ្មចរិយទី ១០ មានសេចក្តីដូចតទៅនេះ ៖

តានព្រហ្មចរិយៈបានដល់តាន ពីរ យ៉ាងគឺ តាមិសតាន ១ ធម្មតាន ១ ។ តាមិសតានបានដល់តានវត្ថុ ១០ យ៉ាងជាដើម ។ ឯធម្មតានមានពីរប្រការ គឺធម្មតានដែលសំដែងដោយមុខថ្ម មាត់ទេ ខ្លួនមិជាចំណុចចិត្ត ជាធម៌ស័ក្តិសិទ្ធិ ឲ្យងាយយល់ងាយស្តាប់ ប្រការ ១, ធម្មតានដែលបានចារ សរសេរ ចោះពុម្ពជាលាយលក្ខណ៍អក្សរប្រការ ១ ។

បណ្តាធម្មតានទាំងពីរប្រការនេះ ចំណែកធម្មតានដែលមានលាយលក្ខណ៍អក្សរប្រសើរជាង ព្រោះបិតថែរនៅបានយូរ ។ តាហារណ៍ ដូចធម្មតាន គឺការកសាងព្រះត្រៃបិដក ដែលក្រុមពុទ្ធសាសនបណ្ឌិតក្នុងកំពុងចោះពុម្ពផ្សាយទូទៅចំពោះពុទ្ធបរិស័ទ ក្នុងប្រទេសនិងក្រៅប្រទេស ក្រោមការទទួលភ្នក់ព្រះពរជ័យរាជាធិបាល ដើម្បីជាគោលច្បាប់សម្រាប់ពុទ្ធសាសនាផង ហើយជាធម្មសម្បត្តិសម្រាប់ប្រទេសផង ទាំងបច្ចុប្បន្ន ទាំងអនាគតនោះ ។ ព្រះត្រៃបិដកនេះ លោកនាយកក្រសួង ព្រមទាំងសហការីរបស់លោកខំតាំងព្យាយាមយកចិត្តទុកដាក់ក្នុងកិច្ចការណ៍នោះ ។ ដោយមិនសំចៃកំឡាំងឡើយ សូមឲ្យមានទស្សនៈគួរមកពាំងក្នុងកាលៈទេសៈ

គឺសម្ភារៈសម្រាប់បោះពុម្ពឡើងវិញថ្មីបូបម្តេចក្តី កំគង់តស៊ូខំធ្វើឲ្យតែខាងបានកើតជាគម្ពីរនេះ ដើម្បីបំពេញតំណែងព្រះពុទ្ធសាសនាឲ្យបំពេញបំណងរបស់អស់លោក - អ្នកជាពុទ្ធសាសនូបត្ថម្ភក្នុងសាសនមណ្ឌល ។ ឥឡូវគម្ពីព្រះត្រៃបិដកនេះ បានបោះពុម្ពរៀងពីភាគទី ១ ដល់ភាគទី ៤៣ រួចហើយ ចាំងបោះពុម្ពសារជាថ្មីទៀតបន្តោះភាគដែលខ្វះ តរៀងទៅជាលំដាប់ ដោយបន្ទុំចង់ឲ្យព្រះត្រៃបិដកបានល្អ ហើយជាប់មាំមួន បានចប់រួសរាន់ខាន់បំណងរបស់លោក - អ្នកជាវគ្រប់ៗគ្នា ។ តែថា ក្នុងករណីនេះ ត្រូវតាស្រ័យពុទ្ធបរិស័ទអ្នកមានសទ្ធាជាវ ជួយជាវឲ្យបានច្រើនឡើងដែរ ទើបប្រកៃ ព្រោះព្រះត្រៃបិដកនេះ មិនងាយនឹងធ្វើបានគ្រប់ពេលវេលាទេ ។ ដោយពិសេសទៀតទៀត ព្រះត្រៃបិដកនេះជាគ្រឿងប្រដាប់ជំពិចិត្រ សម្រាប់តែអ្នកនិពន្ធរឿងបែកខាងព្រះពុទ្ធសាសនា យាំងខ្លំខ្លាយឥតមានខ្ចោះ ហើយជាធម្មទានយាំងថ្លៃថ្លា ដែលសង្គ្រោះបូលក្នុងទានព្រហ្មចរិយធម៌ ទី ១ ដូចបានពណ៌នាហើយខាងដើមនោះ ។ ពណ៌នាមកក្នុងទានព្រហ្មចរិយ ទី ១ អស់សេចក្តីដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

ឯសាសនព្រហ្មចរិយៈនោះ បានដល់ពុទ្ធសាសនាខាងមូលដែលសង្គ្រោះដោយសិក្ខា ៣ យាំងគឺ អធិសីលសិក្ខា ត្រង់នឹងបាតិ-

មោក្ខសំវរសីល ๑ អធិចិត្តសិក្ខា ត្រង់នឹងសមាបត្តិ ๘ ប្រការ ๑ អធិប្បញ្ញាសិក្ខា ត្រង់នឹងវិបស្សនាញាណចាំងហាសិបមួយ សឹងមានខ្លួនក្នុងព្រះត្រៃបិដក គឺ វិនយបិដក សុត្តន្តបិដក នឹងអភិធម្មបិដក ។

បំប្រួញចូលមកហៅថា (ពុទ្ធសាសនា ឬ សាសនព្រហ្មចរិយៈ) តែមួយបទប៉ុណ្ណោះ ។

មួយទៀត ពុទ្ធសាសនាចែកចេញជា ๓ ប្រភេទគឺ

๑ - បរិយត្តិសាសនា ជានខាងផ្នែកការសិក្សារៀនពុទ្ធវិន្យាគ្រប់បែបបទ មានរៀននិកាយចាំង ๕ ជាដើម ។

๒ - បដិបត្តិសាសនា ជានខាងផ្នែកសេចក្តីគោរពកោតក្រែងអនុវត្តធ្វើតាមពុទ្ធប្បញ្ញត្តិ នឹងពុទ្ធានុញ្ញាតសព្វអន្ទើ ๑ សមដូចពុទ្ធានុសាសតក្នុងគម្ពីរបញ្ចកង្គុត្តរៈ[๑] ថា ម្នាលភិក្ខុចាំងឡាយធម៌ ๕ យ៉ាងប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម គឺសាសនាសាបសូន្យ អន្តរាជានទៅ ។ ធម៌ ๕ យ៉ាងដូចម្តេចខ្លះ ? គឺភិក្ខុបរិស័ទជាអាទិ៍ ក្នុងសាសនានេះ មិនស្តាប់ធម៌ដោយគោរព ๑ មិនរៀនធម៌ដោយគោរព ๑ មិនទ្រទ្រង់ចាំពុកនូវធម៌ដោយគោរព ๑ មិនពិចារណាអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ๑ ដឹងអត្ថដឹងធម៌ហើយមិនប្រតិបត្តិតាមសមគួរដល់ធម៌ដោយ

๑. ព្រះត្រៃបិដក ភាគ ๒๕ ទំព័រ ๙๕ ។

គោរព๑ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ๔ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរាធានទៅ ។

ន័យដទៃទៀតថា ធម៌ ๔ យ៉ាងប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរាធានទៅទេ ។ ធម៌ ๔ យ៉ាងដូចម្តេចខ្លះ ? គឺ ភិក្ខុបរិស័ទជាអាទិភ្នំនៃសាសនានេះ ស្តាប់ធម៌ដោយគោរព ๑ រៀនធម៌ ដោយគោរព ๑ ទ្រទ្រង់ធម៌ដោយគោរព ๑ ពិចារណាអត្ថនៃធម៌ដែលខ្លួន ទ្រទ្រង់ហើយដោយគោរព ๑ ដឹងអត្ថ ដឹងធម៌ហើយកំប្រតិបត្តិតាមសម គួរដល់ធម៌ដោយគោរព ๑ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ๔ យ៉ាងនេះ ឯងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរាធាន ទៅឡើយ ។

๓ - បដិវេធសាសនា បានន័យថាផ្នែកវិបស្សនាបញ្ញាសម្រាប់ ចាក់ធ្លុះនូវអរិយមគ្គ អរិយផល មានសោតាបត្តិមគ្គជាប្រធាន ទាំង ๓ នេះ ក៏ហៅថា « សាសនព្រហ្មចរិយៈ » ដែរ ។

ទាំងធម្មទេសនាក៏ថា ការសិក្សាដែលធម៌ក៏ហៅថា ព្រហ្មចរិយៈព្រោះ ការសិក្សានោះ ជាហេតុនាំមកនូវគុណដ៏ប្រសើរ ចំពោះអ្នកយកជន ច្រើនផង ព្រោះជាសាសនធម៌ ពាក្យប្រៀនប្រដៅប្រកបដោយប្រ- យោជន៍ កាប់ចូលក្នុងត្រៃសិក្ខា ដូចបានអធិប្បាយហើយពីខាងដើមផង

ជាសុភាសិតដ៏ខ្ពស់ខ្ពុលយ៉ាងនេះ. ចាំនឹងធម្មស្សវនតថាត្រង់គាថាទី ๗ ដែលជាគួនឹងគ្នាសោត មានសេចក្តីថា កិរិយាស្តាប់ធម៌ដែលបុគ្គលបានអប់រំល្អហើយ រមែងនាំឲ្យបានដល់នូវអរហត្តផលដោយពិត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ចត្តារោ មេ ភិក្ខវេ កាលា សម្មា ភាវិយមានា សម្មា អនុបវត្តមានា អនុបុព្ពេន អាសវានំ ខយំ ចាបេន្តិ(๑)

ម្នាលភិក្ខុចាំនួយ កាលចាំន ๔ ដែលបុគ្គលបានអប់រំល្អហើយ បានប្រវត្តរឿយៗល្អហើយ រមែងនាំឲ្យបានអស់នៃអាសវធម៌ដោយលំដាប់ (បន្តិចម្តងៗ) ។ កាលចាំន๔ដូចម្តេចខ្លះ? គឺកាលគួរនឹងស្តាប់ធម៌ ๑ កាលគួរនឹងសួរនូវបញ្ហាធម៌ ๑ កាលគួរនឹងសំដែងធម៌๑ កាលគួរដើម្បីរៀនយកវិបស្សនាកម្មដ្ឋាន๑ ។ កាលចាំន๔នេះ រមែងនាំឲ្យបានដល់នូវអរហត្តផល តុំសោះសូន្យឡើយ, គួរនាដូចទឹកភ្លៀងមានគ្រាប់ធំថ្លោស ។ ដែលបង្អុរធ្លាក់ចុះមកលើកំពូលភ្នំ រមែងហូរទៅតាន់ទីទំនាប ហើយបំពេញជ្រោះជ្រលងដងអូរប្រឡាយតូចធំ រណ្តៅតូច-ធំ ស្ទឹងតូច ធំ ឲ្យពេញប្រៀបដោយទឹក យ៉ាងដូចម្តេចមិញ, កាលចាំន๔ដែលបុគ្គលបានអប់រំល្អហើយ បានប្រវត្តរឿយៗល្អហើយ រមែងនាំឲ្យ

๑. មង្គលត្ថទីបនី ភាគ ๔ ទំព័រ ๓๐ ។

បានអស់ទៅនៃអាសវធម៌ គឺបានដល់អរហត្តផល ដោយលំដាប់ ក៏យ៉ាង
ដូច្នោះឯង ។

ភិរិយាសំដែង នឹងការស្តាប់ចាំងគួរនេះ ក៏ហោចថា សាសនព្រហ្ម-
ចរិយដែរ ។ ព្រហ្មចរិយធម៌មានការបរិបូរគ្រាន់ជាដើម នឹងការអនុវត្តន៍
តាមសាសនាជាខាងចុងបំផុត ដែលបានសំដែងហើយដោយបំប្រួញនេះ
ជាមគ្គលដ៏ឧត្តម រមែងនាំមកនូវសេចក្តីសុខ ក្នុងឥធលោក នឹងបរលោក
ជាពិតដល់ព្រះនិព្វានជាអវសាន ពុំយឺតឃ្លាតឡើយ ។



ផ្នែកអក្សរសាស្ត្រ

រឿងនេវន្ត (ភាសាភាស)

(តមក)

លោក អម្ចូតក្សត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម
លោក ញ៉ឹក-ថែម ពិនិត្យ

ខ្លះចូលស៊ីបាយ កែករសើចសាយ អ្នកខ្លះស៊ីសា ស៊ីក្លាសឹងមាន
ត្រេប៉ា ដោយភាន រឿងរមគ្គា ។ ខ្លះស៊ីចំណី ចំណង់អ្វី ។
សឹងបានកោតា សប្បាយនិងគ្នា តាមចិត្តប្រាថ្នា រីករស្តុប្រជា ប្រជុំគ្នា
មក ។ ដេរជាសម្លៀកខ្លួន មើរមកទទួល ក្សត្រតីរពន្ធក សរសើរបារមី
ពោះបីចិត្តក្អក ចង់ស៊ីអ្វីយក ស៊ីសព្វតាមចិត្ត មើលរាំបណ្តើរ សប្បាយឥត
ថើ ឥតបីគន់គិត លង់លុះព្រះលាន ក្សត្រក្សាន្តទ្រង់រំខ្ញិ ទ្រង់រៀបពលនិស្ស
ពលនៅខាងក្រៅ ។ ស្តេចនាំទើរ មេនំនារ ខ្លួរបុត្រចូលទៅ លុះ
ដល់ពេនវ័ត្ត ពិចត្រង្គិនផ្ទៅ ក្សត្រតីរគង់នៅ ក្រឡាពេនរម្យ ។
ពង្សពុទ្ធនរបតី ខ្លួរព្រះមហេសី ក្រាបថ្វាយបង្គំ មាតាបិតា ថ្វៃថ្វា
ទុតម ព្រះហស្តទុតម ក្រួញក្រាបគាល់នៅ ។

ស្តេចយសវតី បង្គាសបង្គី ពង្សពុទ្ធទៅ មហេសីបវរ
ត្រែតអរទៅកៅ អង្គុលទុបទៅ ថៃថើបកេសា ។ ក្សត្រតំណពីរពង្ស

គយគន់អស់អង្គ ពន្ធកពុទ្ធា តាយកបនវល័ក្ខណ៍ ដៀងជាត់ប្រុសប្រុ-
កដកបបញ្ចា រំពោះញ្ញាយញ្ញាណ ។ ទ្រង់ត្រេកទ្រង់ត្រិះ ទុកូនអញ
ញ ញ
បេះ រិះរកប្តីបាន បរិបូណ៌ស្ងួនសត្តិ កបល័ក្ខណ៍មែនមាន រិទ្ធីថ្កើងថ្កាន
នីរអ្នកណាស្មើ ។ គិតស្រេចសួរថា ហៃកូនស្ងួនក្ងា មាសមិត្រប្រសើរ
ប្រុសស្រីឯស្រុក សាន្តសុខសារតើ តោងន៍តស្តុនោះតើ ត្រាន់បរិបូណ៌ឬ។
ឬក្រតុំងាយ រីពស្ត្រតាំងឡាយ បានធ្វើស្រែភ្នំ ក្ងៀងទុរជោគជាំ សព្វ
ឆ្នាំមកឬ ឬមានជម្ងឺ ដំគាត់ជៀតបណ្ឋ ។ មួយព្រះបិតា មាតាស្ងួន
ក្ងា សប្បាយកាយន្ត្រី ទ្រើសទ្រង់ផ្គងផ្គត់ ពស្ត្រវង្ឋបូរន្ត្រែ រីក្បែត្រងៃប-
តន្ត្រែ ចាស់ជពហើយ ។

ពោធិសត្តា ក្រញ្ជក្រាចទូលថា បពិត្រម្ចាស់អើយ រីព្រះមាតា
បិតាត្រានត្រើយ ស្តេចក្សត្រិណក្សត្រិយហើយ ពុំចេរកវុណា ។ ក្សត្រ
ក្សាន្តប្រសើរ ថ្កែងប្រាប់ដំណើរ ទូលព្រះបិតា បពិត្រស្រុកនាយ
សប្បាយសុខសា ចាន់បរិបូណ៌ជា ឥតមានទុក្ខសោក ។ មួយសោត
ក្ងៀងផ្ទរ ស្រែស្រូវអង្ករ ពស្ត្រវង្ឋរិះរក ចាយបរិបូណ៌បាន មិនមាន
ទុក្ខកេ- តាកើតមានមក ជៀតជៀនបណ្ឋា ។ មួយសោតស្រុកគាយ
ញ្ជាំងសុខសប្បាយ អស់ពស្ត្រប្រជា ក្នុងរាជ្យរម្យរដ្ឋ ឥតអង្គអស់អា-
ហារហើយពុំសា ចាយបរិបូណ៌ផង ។ ក្ងៀងអាចនុវឲ្យ បរិបូណ៌ដូច

ដោយ រដូវសព្វដង សព្វដែនតូចធំ និគមគ្រាមគ្រង ក្រុមគ្រប់ពស្ត្រ
ផង ឬមួយដួចម្តេច ។ មួយវ័ព្រះនេត្រ ងងឹតហើយហេតុ ដាកម្ម
កិច្ច មួយទៅក្តីច្បាស់ មួយព្រះទន្តស្តេច ពុំបានសម្រេច បាត់បង់បូ -
ណ៌ទៅ ។

ស្តេចស្តាប់សុណិសា បន្ទូលច្រាប់ថា ហៃបាតោមផ្លៅ រ័ងនិ-
គម តូចធំក្នុងក្រៅ ក្នុងក្រុងនេះទៅ ជាសុខសាទរ ។ រីពស្ត្រពាំង
ឡាយ ជាសុខសប្បាយ មួយសោតភ្លៀងផ្គរ ទរឲ្យត្រឹមត្រូវ រដូវពស្ត្រ
រក៏ ស៊ីសោតបានបរិ- បូណ៌ឥតអត់ឡើយ ។ កូនអើយវ័ឆ្នេញ អាពុក
នេះមិញ រង្គើអស់ហើយ មួយន័យនេត្រា មាសអាពុកអើយ ចង់ងងឹត
ហើយ ពុំដួចដើមទេ ។ កូនអើយអាពុក តិតហើយកើតទុក្ខ សព្វ
ថ្ងៃឥតល្អែ ដូរតខ្លួនសោះសូន្យ ឥតកូនប្រុសទេ បានអ្នកមាសស្នេហ៍
មកជាបុត្រា ។ អាឥតថ្ងៃឯប្តី ឯកឥតអ្នកនឹង ប្រហប្រៀចទបមា អា-
ពុកផ្ទះវង្ស ក្រោមត្រៃឲ្យបា គ្រងពដ្យរក្សា ប្រជាជនផង ។ បើអ្នក
នៅអាយ នៅស្រុកឯនាយ អ្នកនឹងផ្គូរផ្គង នៃអ្នកឯណា ធានាគ្រប់
គ្រង ពដ្យរក្សាពស្ត្រផង ទម្ងន់បាបាន ។

ពោធីខ្ញុលថា បពិត្រកុរ្រា អង្គអញ្ជឹមាន អនុជប្រសា
ជាតិជាប្រធាន គ្រប់គ្រងពដ្យបាន កុំព្រួយចិត្តា ។ ព្រះបាទកូនរ

រីឯទ្រង់ត្រែកអរ ត្រែកឥតឧបមា ស្តេចទ្រង់ប្រាមប្រាប់ បង្គាប់សេនា
ឲ្យរៀបប្រជា ប្រជាប់អតិសេក ។ អញ្ជើញពីក្បែត្រែ គង់លើផ្នែកភ្នែ
រុងរឿងឯងឯក ចំរើនពរ ជយាអតិរេក ថ្កើងបុណ្យអនេក ប្រសើរ-
លើសលែង ។ ស្តែងស្តេចសាន្តសុខ នីរណាយទោសទុក្ខ ចារមើយល់
ស្តែង ច្បាស់លើសលើនា ប្រជាជនតែង សានសុខឥតក្រែង ប្រ
ទេសនានា ។ ទោះស្តេចសកល ប្រឡងមណ្ឌល ជម្ពូទ្វីបា ឮនាម
សឹងខ្ទាច អំណាចចេស្តា នាំអស់ស្តួយសា មកជាប្រក្រតី ។ ហើយ
ព្រះឆត្តារ ឲ្យតែងសព្ទសារ ឲ្យអស់មន្ត្រី មកពីរាជដ្ឋាន ពារាណសី
វិលទៅបូរី បរមនាមា ។ ឲ្យអគ្គអភ័យ គ្រប់គ្រងក្រុងក្រៃ ស្ងាប់-
ស្ងប់ក្បែគ្រោ រីឈ្មួញសាគរ តែងចរលីលា ទៅមកសព្ទគ្រោ ពិតពុំដែលខាន ។ ឯព្រះពន្ធុរោ_ធិសត្វរោ ឲ្យសង់ឆត្តាន ហើយក៏ត្រែវរង្វ
ស្តេចទ្រង់ប្រោសប្រាណ រាស្ត្រជនសឹងមាន សម្បត្តិដូចគ្នា ។ កុម្ភណ្ឌ
ពាំងឡាយ វែតងនាំដង្វាយ មកថ្វាយសព្ទគ្រោ ពុំដែលខ្វេសខ្វះ រីឯ-
ស្វាឡា មកតែក្រុងពា_រាណសីនគរ ។ រីរាជអស្សាចារ្យ ស្តេចឲ្យ
រក្សា អនុជបវរ ក្រែងមានកើតហេតុ កិតកេរក្រីក្រ ឲ្យចាំចហោះចរ
ទៅខួលចក្រី រីចាស់ពីរនាក់ ស្តេចឲ្យមាសប្រាក់ ឥសាឥសី គោ
ក្របីសេះ រះទះសាលី មានស្មើសេដ្ឋី ដោយទ្រង់មេត្តា ។

(មានត)

ភាគ ទី ៣១

ឧកញ៉ាវិបុលរាជសេនា ង្វៀ-ភាង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
ធំងបេះទុយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

កាលឡៅពីចេញផុតទៅហើយ ឡៅប៉ៃក៏គិតធ្ងល់ក្នុងចិត្តនឹងឡៅពី ហើយចូលទៅខាងស្លែងក្នុង នាងឈួហ៊ូយិនក្តែងញុះឡៅប៉ៃថា អម្បាញ់មិញនេះ ឡៅពីនិយាយប្រមាថមើលងាយគាណាខ្ញុំត្រចាំនឹងតួង ឯខ្ញុំនលោកក៏ជាទៅហ្វាយខ្ញុំត្រឹមឈរនៅជំបន់ ១ ដែរ ដែលឡៅពីនិយាយដូច្នោះ លោកយើញច្បាស់ណាស់ហើយឬ យូរទៅយើញថា ឡៅពីនឹងគិតយកស្រុកនេះមិនខាន សេចក្តីអន្តរាយគង់នឹងមានដល់លោក សូមឲ្យលោកខំរិះគិតកំចាត់ឡៅពីចេញ ទើបលោករួចខ្លួនក្តីយ

បាន ខ្លៅប៉ៀវស្គាប់ហើយក៏គ្រវីក្បាលមិនបានតបថាអ្វីឡើយ នាងឈួ
ហួយិនក៏ចូលទៅគាន់ទីដំណោកប្រើស្រីម្នាក់ ឲ្យទៅហៅខ្លួនឈួម៉ចូលមក
ហើយព៉ាយព៉ាប់រឿង ដែលខ្លៅពីនិយាយនោះ ច្រាប់ឈួម៉ស្តាប់គ្រប់ប្រការ
ឈួម៉ឆ្លើយថា អ្នកកុំខ្វិតក្តុឡើយ ឥឡូវខ្លៅពីកំពុងស្រវឹងស្រាខ្លាំនឹង
ស្រួតទៅសម្លាប់ចេញ រួចសឹមវិលមកដំកបខ្លៅប៉ៀវ ឲ្យគ្រាបជាក្រោយ
នាងឈួហួយិនក៏យល់ត្រូវ ទើបថា ការនេះឲ្យប្អូនខំគិតឆ្លើជាធាប់ទៅចុះ
ឈួម៉ក៏លាថយចេញទៅ លុះពេលព្រលប់ក៏ចាត់ចែងតាហានព្រមគ្នា ។

ឯខ្លៅពីកំពុងខំអុជខ្នែងម៉ែលសំបុត្រ អង្គុយចាំតែជល់យាម ១ ជាយ
ខណៈនោះ អ៊ីដៀដឹងការ ក៏ចូលទៅច្រាប់ខ្លៅពីថា ឈួម៉ត្រៀមតាហានប្រចាំការ ងាងក្រៅទុកស្រេច ប៉ងនឹងធ្វើប្រទូស្តកាយលោក
ហើយក្នុងពេលយប់នេះ លោកត្រូវតែរិះគិត រត់ចេញឲ្យរួចខ្លួនចុះ ។
ខ្លៅពីតបថា កាលខ្ញុំនៅមិនទាន់ឈ្លោខ្លៅប៉ៀវ នឹងឲ្យខ្ញុំរត់ទៅជួចម្តេច
បាន ? ។ អ៊ីដៀតបថា លោកនឹងកង្វល់ពីព្រោះខ្លៅប៉ៀវនោះ មុខជា
ឈួម៉ននឹងសម្លាប់លោកបានហើយ ។ ខ្លៅពីយល់ឃើញត្រូវ ក៏លាអ៊ីដៀ
នាំតាហានដែលតាមមកនោះ រត់ចេញទៅដល់ស្រុកសុំនអៀ ។

លុះពេលប្រហែលយាម ២ ជាយ ឈួម៉ក៏លើកតាហាន
មកដល់ទីដំណាក់ខ្លៅពី មានគេច្រាប់ថា ខ្លៅពីរត់ចេញទៅយូរ

ហើយ ឈួមម៉ៅដូច្នោះ កំមានសេចក្តីខឹងក្តៅក្រហាំងណាស់ ទើបក្តែងចូលទៅសរសេរឃ្លោង ៤ បទខុតនៅជញ្ជាំងផ្ទះសំណាក់ឡៅពី បីដូចឡៅពីសរសេរខ្លួនឯង ហើយឈួមម៉ក៏នាំគាហានចេញទៅវិញ លុះព្រឹកឡើងឈួមម៉កំចូលទៅដំរាបឡៅប៉ៀវថា ខ្ញុំបាទដឹងថា ឡៅពីនឹងគិតប្រទូស្តរាយដល់លោក កាលនឹងទៅក៏មិនបានលាលោក ហើយសរសេរឃ្លោងខុតនៅជញ្ជាំងក្បែរដំណេក ៤ បទ បើលោកមិនជឿ សូមអញ្ជើញទៅមើលចុះគង់ឃើញច្បាស់ ឡៅប៉ៀវក៏ដើរទៅមើលដល់ទីសំណាក់ឡៅពី ឃើញឃ្លោងដែលសរសេរខុតនោះ មានសេចក្តីថា :

ស៊ូត្រាំចាំចិត្តរាតជាខុក្ខ ព្រោះពីទំនុកចង់ទបជ្ជាក
មនុស្សក្នុងបរិវេណដែលលំបាក តុំមានល្អែស្រាកមកយូរឆ្នាំ ។
ប្រសិនបុណ្យជួនបានសម្បត្តិ នៅក្រោមស្មុតធ័ត្រនឹងហត្ថកម្ម
ធ្វើឲ្យរុងរឿងថ្កើងឆ្ងេងស្តាំ មិនឲ្យបែកស្រាំនាំសៅហ្មង ។
ធម្មតាជាជាតិមកស្រុក មកនៅក្នុងថ្កុកគូចកន្ធង
នៅម្តេចនឹងបានក្សាន្តចិត្តផង ព្រោះមានពួកកង់ហូងច្រើនណាស់ ។
បើបានសម្បុរធំផុតកត នឹងប្រឹងប្រាថ្នាខ្ជិតបះ
ហោះហើរទៅលើមេឃស្រឡះ ឲ្យគេឃើញច្បាស់នឹងនេត្រា ។

ខ្ញុំប៉ៀរមើលហើយក៏ខឹងខ្លាំងណាស់ ពាញហូតក្រៃមកគាន់ហើយ ថា អញនឹងសំឡាប់ខ្ញុំពីឲ្យបាន ព្រោះវាជាមនុស្សខ្ទុះយសអាក្រក់ណាស់ ហើយដើរចេញទៅក្រៅស្លូន បំណងនឹងបង្គាប់ប្រើពាហាន ចាប់តែខ្លីឆ្ងាយ ខ្ញុំពីមកនៅនេះក៏យូរណាស់ហើយ មិនច្រាកដថា ខ្ញុំ-ពីចេះធ្លើយឃ្លានយ៉ាងនេះបាន ប្រហែលនរណាឯទៀត មានចិត្តឫស្យាទឹងស្អប់ ក្លែងមកធ្លើបទឃ្លាននេះ ទុកឲ្យយើងមានសេចក្តីទឹងសង្ស័យនឹងខ្ញុំពី ហើយខ្ញុំប៉ៀរក៏ដើរត្រឡប់ចូលទៅក្នុងវិញ យកបុងក្រមុំគោសលុប អក្សរនោះចេញអស់ ហើយក៏រៀលទៅគាន់ទឹគេហផ្ទាន់វិញ ។ ឈួម៉ក៏និយាយដំរាបខ្ញុំប៉ៀរថា ពាហានប្រមូលព្រមមូល សូមឲ្យលោកបង្ខំលើកកងទ័ពទៅចាប់ខ្ញុំពី មកសម្លាប់ចេញ ទើបនឹងមិនមានភ័យអន្តរាយដល់លោក ។ ខ្ញុំប៉ៀរតបថា ខ្ញុំពីនឹងរត់ទៅឯណាឲ្យផុត ពីដៃយើងនោះគ្មានទេ ចាំរៃគិតឲ្យផុតពីសេចក្តីគរហានិន្ទាសិន ហើយក៏បរសេះចូលទៅដល់ទីកន្លែង ។ ឈួម៉ឃើញខ្ញុំប៉ៀរឯអង់ មិនយល់តាមគំនិតរបស់ខ្លួនដូច្នោះ តិលបចូលទៅប្រាប់នាងឈួហ៊ូយិន តាមការដែលបានធ្វើមកហើយថា នៅ ៣ ថ្ងៃទៀតនឹងដល់កំណត់ចូលឆ្នាំថ្មី ពេលហ្នុងស្រុកចំណុះពាងអស់នឹងមកប្រជុំព្រមគ្នា នៅស្រុកស៊ុងយ៉ុង ខ្ញុំនឹងរៃគិត

សម្ងាប់ខ្លៅពីរចេញឲ្យបាន នាងឈួងហ៊ួយនធ្វើយថា ៗ ចៅបួរទំរ៉ះគិតធ្វើ
ការឲ្យសំរេចជាធាប់ៗចុះ ឈួមំខលួលពាក្យហើយក៏ចំយាចេញមក លុះ
វេលាព្រឹកឡើង ឈួម៉ក៏ចូលៗជំរាបខ្លៅប៉ៀវថា នៅ ៣ ថ្ងៃទៀតនឹង
លំកំណត់ៗហ្វាយស្រុកចំណុះ ចូលមកប្រជុំគ្នាគំនាប់ នៅស្រុកសុង-
យ៉ុង លោកនឹងចាត់ចែងការដូចម្តេច នឹងបាននៅពន្យល់បណ្តានាម៉ឺននឹង
ៗហ្វាយស្រុកចាំងពួងឲ្យដឹង ។ ។ ខ្លៅប៉ៀវថា ខ្ញុំនយើងឈឺប្រហែល
ជានឹងចេញៗខលួលគំនាប់មិនបានទេ នឹងឲ្យតែខ្លៅគី , ខ្លៅបុងជា
បុត្រចាំង ២ ៗជំនួស ។ ឈួម៉ថា បុត្រលោកចាំង ២ នោះនៅក្មេង
សេចក្តីណាស់ ដែលនឹងឲ្យៗខលួលគំនាប់នាម៉ឺនមុខមន្ត្រីចាំងពួងនោះ
មិនគួរទេ ការប្រវៃណាស្រុកក៏នឹងខូចៗ ។ ខ្លៅប៉ៀវធ្វើយថា បើដូច្នោះ
នឹងឲ្យអញ្ជើញខ្លៅពីៗខលួលគំនាប់ជំនួសយើងចុះ ឈួម៉បានឮក៏មាន
អំណរណាស់ គិតថា គ្រានេះខ្លៅពីមុខជាមិនរួចនឹងដៃយើង ហើយក៏
ចាយចេញមក ទើបចាត់ប្រើមនុស្សឲ្យៗទៅប្រាប់ខ្លៅពីថា ឥឡូវ ខ្លៅប៉ៀវ
មានជម្ងឺឈឺមានប្រសាសន៍មកថា ៤ ថ្ងៃទៀត ឲ្យអញ្ជើញលោកៗ
ខលួលគំនាប់នាម៉ឺនមុខមន្ត្រីចាំងពួង ជំនួសខ្លៅប៉ៀវឯស្រុកសុងយ៉ុង អ្នក
បំរើក៏លាឈួម៉ៗទៅប្រាប់ខ្លៅពី ។ កំព្រមអារខលួល ។

ឯគួនអ៊ូ , ខ្លៅហ៊ុយ ៨ ឮនដឹងដំណឹងថា ខ្លៅពីមក

ឈរក្បាស្រុកសុំនអៀហើយ កំនាំគ្នាលើកចាហានមកសួរខ្ញុំពី ។
ខណៈនោះ ស៊ុនខៀនដំរាបខ្ញុំថា ព័ម្យលមិញលោកត្រឡប់មកពី
ស្រុកកេងដែរ ខ្ញុំបានឃើញកិរិយាមិនសូវសប្បាយ លោកមានបរិតក្តពី
អ្វី ដែលខ្ញុំប៉ៀវឲ្យអញ្ជើញលោកទៅ ខលួលគំនាប់នាម៉ឺនមុខមន្ត្រីដំ
ន្លួសនោះ? លោកកុំអញ្ជើញទៅឡើយ ខ្ញុំពីក៏អធិប្បាយសេចក្តីដែល
បាននិយាយនឹងខ្ញុំប៉ៀវនោះ ឲ្យស៊ុនខៀនស្តាប់សព្វសេចក្តី ហើយថា
អ័ដៀមកច្រាប់ថា ឈូម៉ូមកគិតធ្វើប្រទូស្តកាយយើង ។ ក៏រត់មក គួន
អ៊ូតបថា ឯស្រុកសុំនយ៉ុងនោះ ផ្លែកំដិតនឹងស្រុកនេះដែរ ប្រសិនបើ
មាននរណានឹងគិតប្រទូស្តកាយយ៉ាងម្តេច កំលូមនឹងតែងៗបានទេ ដែល
លោកនឹងប្រញាប់ជឿស្តាប់ពាក្យមនុស្ស មកនិយាយនោះមិនគួរទេ ព្រោះ
ថាមិនបានឃើញនឹងភ្នែក ឮនឹងត្រចៀក បើលោកមិនបួលទៅ ខ្ញុំប៉ៀវ
នឹងមានសេចក្តីសង្ស័យ សមប្រកបនឹងពាក្យ ដែលគេនិយាយខ្ញុំតមក
នោះមែន ។

(មានត)

សុភាសិតសាសន៍ប៉ែរ្ស

(តមក)

លោក រ៉ាយ-ប៊ីក ជាអ្នករៀបរៀង

៤៣- ចូរឲ្យបច្ចាមិត្តឯងក្តាប់ដៃវាយក្បាលឥស់វែកចុះ, កិច្ចនេះមានប្រយោជន៍សំខាន់ដល់ឯង ។ បើបច្ចាមិត្តឯងឈ្នះ, ឥស់វែកនោះក៏ស្ងាប់ហើយ បើបច្ចាមិត្តឯងត្រូវឥស់ចឹក, ឯងនឹងបានរួចពីកណ្តាប់ដៃបច្ចាមិត្តមួយ, នៅសល់តែមួយប៉ុណ្ណោះ ។

៤៤- បើស្ត្រីណាចង់ក្បែរឯង ដើម្បីទទួលនូវការថើបជាដំបូង, ចូរឯងកុំប្រមាទ, ព្រោះនាងនោះបានស្គាល់គោតន្ត្រីឯង ។

៤៥- អ្នកដែលប្រើជីវិតខ្ជូនមិនប្រាស់ឡាស់ មិនបានតម្លៃអ្វីឡើយ, អ្នកនោះដូចជាចោលមាសទៅក្នុងសមុទ្រ ។

៤៦- កុំយកចិត្តទៅផ្តេកផ្តួលលើស្ត្រីដែលមានប្រុសច្រើន ។ បើឯងគាន់ចិត្តដូច្នេះ, ចូរឯងបម្រុងនឹងចាំធ្មេចុះ ។

៤៧- កុំឲ្យប្រាប់នូវការស្ងាត់កំបាំងរបស់ឯងទាំងអស់ ចំពោះមិត្រសំឡាញ់ឯង, តើឯងនឹងដឹងថាមិត្រនេះ នឹងទៅជាបច្ចាមិត្រឯងក្នុងកាលអនាគត ឬ កុំឲ្យធ្វើបាបបច្ចាមិត្រឯងខ្លាំងពេក តើឯងនឹងអាចដឹងបានថា បច្ចាមិត្រនេះ នឹងប្រែទៅជាមិត្តឯងក្នុងថ្ងៃណាមួយឬ ។

ការស្វាត់កំចាំងនេះ ត្រូវឯងកុំប្រាប់អ្នកណាឲ្យសោះ សូម្បីតែមិត្ត-សំឡាញ់ ក៏មិនត្រូវខ្វុកចិត្តផង ។ ដូចម្តេចក៏ដោយ ចំពោះការស្វាត់កំចាំង ឯងមិនត្រូវខ្វុកចិត្តមនុស្សដែលខើបនឹងស្គាល់ម្ដងនោះទេ ។

๔๘- ចូរឯងស្ងៀមៗ កុំឲ្យប្រាប់ការស្វាត់កំចាំងទៅអ្នកណាឲ្យសោះ ហើយពោលថា "ឯងកុំប្រាប់ទៅអ្នកឯទៀត" ។ ๑! ឯងចង់ចប់ទន្ទេ្រង្រប់ក្រតព តែឯងនឹងអាចទប់បាន លុះត្រាតែចំតទន្ទេ្រនោះហួរផុតពីប្រកតចម្ងាយ ๒-๓ ចាំវ៉ាសង្គ (๙ . ๒๙๐ ម= ๑ ចាំវ៉ាសង្គ) ។

๔๙-កុំឲ្យពោលពាក្យស្វាត់កំចាំងមួយម៉ាត ដែលឯងមិនអាចពោលចំពោះមនុស្ស ๑๐๐ នាក់បាន ។

๕๐- បច្ចាមិត្តខ្សោយដែលចូលមកប្រគល់ខ្លួនចុះចាញ់ឯង មានចិត្តសន្សឹមថាដល់មានពលភាពថ្ងៃក្រោយនឹងថ្មាច់ជាបច្ចាមិត្តវិញ។ កុំឲ្យខ្វុកចិត្តមិត្តដែលពោលពាក្យបញ្ឆោតឯង ។ អ្នកណាមួយប្រមាទ ចំពោះបច្ចាមិត្តខ្ទុលភាព ប្រៀបដូចជាមនុស្សដែលប្រមាថមិនរំលត់ភ្លើងដែលឆេះជាដំបូង ។

๕๑- បើស្ត្រីម្នាក់ពោលចំពោះឯងថា " ខ្ញុំមិនបានសុំបេះដូងឯងទេ ខ្ញុំសុំតែត្រឹមរូបកាយនឹងការ ច្រកចាប់អង្អែលស្រួលបេះឯងប៉ុណ្ណោះ " , នារីនេះជាស្ត្រីប៉ិនប្រសប់ ចូរឯងភ្ញាក់ស្ត្រីនោះព្រោះថា នាងចេះក្បួនដែលអ្នកប្រមាញ់ធ្វើឲ្យខ្លារខិនចូលក្នុងអន្ទាប់ ។

๕๒- មានន័យម្នាក់ទៀតពោលថា " ខ្ញុំចង់បានតែបេះដូង-
ទេ , ចូរឯងទាញស្ត្រីបែបនេះទៀត ព្រោះគាត់យល់ថា
បណ្តាបុរសខ្លះដឹងតែចង់បេះដូងគឺចិត្ត ប្រៀបដូចត្រណាប់ដូច្នោះ ។

๕๓- ការងារជាទុក្ខសេចក្តីនាញមួយក្នុងកាលដែលយើងមានទុក្ខ-
លំបាក ។

๕๔- អ្នកណាប្រកាសសន្តិភាព ទីបំផុតមិត្តនៃមិត្តខ្លួន អ្នកនោះ
មានបំណងចង់ឲ្យមិត្តខ្លួនទៅមនុស្សនឹងខ្លួន ។

๕๕- ចូរឯងរុះបង់ចោលនូវមិត្តណា ដែលជាគ្មានទីបញ្ចប់មិត្ត
របស់ឯង ។

๕๖- បើឯងមានចិត្តរួញរា មិនហ៊ានសម្រេចនូវកិច្ចការអ្វីមួយ
ចូរឯងសម្រេចកិច្ចការណា ដែលមិនសូវមានទុបស័គ្គ ឬ មានទុបស័គ្គតិច-
ជាងគេ ។

๕๗- សេចក្តីស្នេហាជាអគ្គិភ័យ ដែលទឹកនៃទន្លេពាន់ប៉ុន្មានមិន
អាចរំលត់បាន ហើយសេចក្តីខ្ជិនៅទៀតអ្នកគាន់ស្នេហា គឺជារងើកភ្លើង
មានកំនួនត្រអូប ។

๕๘- ពេលយប់ដំបូងផ្សំដៃណែក កុំឲ្យឯងបង្ហាញនូវសេចក្តីយោរ-
យៅខ្លាំងពេក ព្រោះថា ឯងមិនអាចកំណត់ថាយកនារីនេះជាកវិយា
អស់រយៈវេលាមួយឆ្នាំក៏មិនដឹង មួយជីវិតក៏មិនដឹង ។

๕๘- អ្នកឃ្វាលចៀមសួរបិតាខ្លួនថា "សូមបិតាពន្យល់ខ្ញុំ យ៉ាងដូចម្តេច ដែលហៅថា ចិត្តល្អ ឬ ចិត្តសប្បុរស បិតាក៏តបទៅវិញ ថា: "ឯជ្រូកមានចិត្តសប្បុរស តែកុំកាន់ចិត្តពាល់តែធ្វើចចកឲ្យក្លាហាន ហួសហេតុ ។

๖๐- អ្នកដែលបានធ្វើដំណើរទៅកាលឱ្យចាប់រហោស្ថាន ជ្រាបច្បាស់ថា មនុស្សណាដែលធ្វើដំណើរសន្សឹម ។ មិនបំបោល មនុស្សនោះ នឹងទៅដល់ភូមិមុនអ្នកតស៊ូ ។

๖๑- ពេលវេលាដែលលំបាកជាងគេ ចំពោះសេចក្តីស្នេហា គឺពេលដែលធ្លាក់ទៅកាន់សេចក្តីស្នេហាម្តងទៀត ហើយបានត្រែបរស - ជាតិឆ្អែតស្កប់ស្កល់ ។

๖๒- បេះដូងជាទ្រូងនៃការស្វាគ៌ាំពាំងនៃសេចក្តីស្នេហា ។ បក្សី ដែលនៅក្នុងទ្រូង តែហើរចេញរួចលែងវិលត្រឡប់មកកាន់ទ្រូងវិញ - ហើយ ។

๖๓- អណិតអាសូរឱ្យ តែបង្ហាញនូវសេចក្តីអយុត្តិធម៌ ចំពោះចៀម ។

๖๔- ការពិឃាតមនុស្សជាការងាយ, តែធ្វើឲ្យមនុស្សរស់ - ពនមានជីវិតឡើងវិញជាការលំបាក ។

๖๕- ចូរឯងត្រឡែកមើលទៅស្ត្រី ដែលស្នេហាឯង បើនាងដោះ

សែ្នកដើនមុន, សេចក្តីស្នេហារបស់នាងនៅនឹងក្បាលហើយ ឯងនឹងៗ ជាចំណែនៃស្ត្រីនោះ ។

๖๖- បើកាលណាឃើញនាងកញ្ញាម្នាក់ដើរមកដិត ឯងត្រូវគ្រេប យកនុជារសនៃសេចក្តីស្នេហា រួចឯងនឹងគិតពិចារណាថា កាលណាសេចក្តីស្នេហាមកដល់ មានតែខុក្ខលំបាកប៉ុណ្ណោះ ។

๖๗- លំអនៃពាក្យដែលថ្លៅដោះ មានតម្លៃដូចគ្នានឹងលំអនៃនាងកញ្ញាដែរ ។

๖๘- ចូរអ្នកធ្វើទានចំពោះអ្នកល្អ នឹងអ្នកកាច; ការឲ្យដល់អ្នកល្អ, អ្នកឯងនឹងបន្ថែមនូវគុណធម៌របស់អ្នក; ការឲ្យដល់អ្នកកាច, អ្នកនឹងការពារនូវគ្រោះថ្នាក់ទៅក្នុងអនាគតរបស់អ្នក ។

๖๙- មនុស្សស្អាប់មិនដែលស្អាប់ពីរដងទេ ។

๗๐- ភាសាសម្រាប់ឲ្យមនុស្សដឹងតម្លៃគ្នាទៅវិញទៅមក ។

๗๑- បើស្រមោចពាន់អស់មានសាមគ្គីព្រមព្រៀងគ្នា, ស្រមោចនោះអាចសម្លាប់សិង្ហបាន ។ សក់តូចធ្នាមែនពិត, បើវៃគួចដិតមាំទៅមានសភាពមាំរឹងជាងប្រភ៉ាក់ដែតទៅទៀត ។

๗๒- ទឹកនឹកញ្ចាក់មិនមែនមានសភាពថ្លាដូចគ្នាទេ ។

๗๓- ខ្ញុំមិនឃើញអ្វីវិសេសវិសាល ជាងចិត្តសន្តោសត្រាប្រណីទៅលើចិត្តទោមនស្សសោះឡើយ ។

๗๔- កណ្ឍាណមិត្តរបស់យើង គឺអ្នកចុកភ្នួនដូចជាថ្ម ឬ បន្ទាយនៅពីមុខដំណើរយើង ។

๗๕- ស្រមោចតូចមែនពិត តែមិនសូវអត់ឃ្លានទេ ។ សង្ឃ ពិតមែនតែមានចង្ហឹម ឥន្ទ្រកចកមុត, មិនសូវបានអ្វីបរិភោគទេ ។

๗๖- មេអំបៅពេញចិត្តលោតភៀតក្តីក្តៅបន្តិច មិនព្រមស្ថិតនៅកន្លែងអន្ធការឡើយ ។

๗๗- ផ្លែឈើដែលឯងបរិភោគ វាមិនអាចដឹងខ្លួនថាវាសដែលឯងជញ្ជក់នោះទេ ។

๗๘- គ្រំសមុទ្រពាំងអស់ មិនមែនសុទ្ធតែមានតជទេ ។

๗๙- ត្រូវតែបេះផ្លែប៉ែស្យ មិនត្រូវគិតនូវយោបល់នៃតលប៉ែស្យនោះសោះឡើយ ។

๘๐- ផ្កាក្តីតូចមួយអាចធ្វើឲ្យឆេះព្រៃបាន ។

๘๑- ពាក្យពោលរបស់អ្នកស្រែលង់ភ្លៅ, ជួនកាលប្រសើរជាងពាក្យនៃពួកទស្សនវិទូ ខ្លះ ។

๘๒- ចូរអ្នកបេះបុប្ផាកុលាបកុំឲ្យគិតពីបន្លាវ៉ា ។

๘๓- ស្មៅមួយសរសៃជាស្មៅកៅមួយ, តែយើងត្រូវបេះពន្យល់បំភ្លឺន័យ នៃស្មៅនោះឲ្យច្បាស់លាស់, ទើបអាចយល់បាន ។

រឿងព្រេងនិងរឿងប្រវត្តិសាស្ត្រប្រទេសជប៉ុន

(តមក)

លោក ភ័យ-ប៊ុក ប្រែរៀបរៀង

អ្នកនេសាទអ៊ូរ៉ាស្បីម៉ាតារ៉ូ

នៅចំកណ្តាលកោះជប៉ុនពាំនឹងឃ្លាយ មានសមុទ្រមួយ សមុទ្រនោះ មានទេសភាពជាច្រើនបែបច្រើនយ៉ាង ហើយមានសម្រស់គួរឲ្យចាប់ចិត្តពន់ពេក ។ គឺកោះធំៗ មានថ្មលឿងស្រគាំ , មានដើត្រហមព្រឿងៗ ហើយទេស្អាត គ្មានស្មៅវល្លិ៍ដុះសោះឡើយ ។ មានកោះតូចៗប្រកបដោយដើមស្រល់ដុះស្រោងស្រាង ថ្មប្រកបដោយទម្រង់ផ្សេងៗ មានចំនួនច្រើនជាអនេក នៅតាមមាត់សមុទ្រ មានភូមិតូចៗនៃពួកអ្នកនេសាទ ឋិតនៅក្នុងឈូងសមុទ្រស្ងាត់ ។

តាំងពីមុនប្រាំសតវត្សមកហើយ, ពេលបច្ចុប្បន្នសម័យនៃវត្ថុនេះ មួយមានអ្នកនេសាទម្នាក់ នាម អ៊ូរ៉ាស្បីម៉ាតារ៉ូ បានធ្វើដំណើរចេញពីភូមិមួយ ទៅតាមទូកឈើលាតគ្មានចង្កូត ។

អ៊ូរ៉ាស្បីម៉ាតារ៉ូនេះជាបុរសមានរូបឆោមលោមពណ៌ល្អចំណាប់ មានភក្ត្រាស្អាត សាច់ពាបស្មើម៉ត់ , ភ្នែកភ្លឺចាំង , ពន់ស្ពើងខ្លួន ។

ពេលនោះ , អ៊ូរ៉ាស្បីម៉ាតារ៉ូ បានទៅនេសាទ គ្មានបានត្រីមួយសោះ ។ ក្នុងមួយរំពេច បុរសក៏បានឃើញចុងសន្ទូចនោះ ជ្រុលជាទៅ

ក្នុងទឹកភ្នំធំ ដូចជាមានជាប់សត្វអ្វី បុរសក៏ចាន់ចាញសន្ទូចមកយើញ
ជាប់ចុងសន្ទូចនូវអណ្តើកសមុទ្រមួយតូច ។

នៅប្រទេសជប៉ុន , គេថា អណ្តើក អាចរស់នៅបានមួយរយពាន់ឆ្នាំ
អណ្តើកជាសត្វរបស់នាគអាទិទេព នៃមហាសាគរ ។ ការដែលពិ-
យាជអណ្តើកនេះ ជាចាបអកុសល មិនត្រូវធ្វើទេ ។

អ៊ីរ៉ស្ត្រាម៉ាតូ ដឹងជាក់ច្បាស់នូវតណ្ហាយកចិត្តរបស់ខ្លួន ក៏ដោះអណ្តើក
ចេញពីសន្ទូច , ស្តាបអង្អែលអណ្តើកនោះ ហើយពោលដោយពាក្យស្រ-
ទន់ថា «អណ្តើកតូចអើយ , អ្នកឯង បើប្រសិនជាប៉ះពាល់លើបុគ្គល
ក្បាចពាលខុសច្បាប់ , តើធំឯងទៅជាយ៉ាងណាទៅ ? បុគ្គលនោះមុខជាសម្លាប់
ឯង , យកឯងទៅស្ងោរ ដើម្បីនឹងបរិភោគសាច់ឯងមិនខាន ។ តែមិនគួរ
ឲ្យដំរិតរបស់ឯងវិនាសជាអសារឥតការយ៉ាងនេះសោះ ព្រោះថា ឯងនឹង
អាចរស់នៅបានមួយសតវត្សរ៍ ប្រែនសតវត្សរ៍ទៅទៀតបាន . . . ខ្ញុំ
នឹងបូជាឯង ចំពោះព្រះអាទិទេពមហាសាគរ ហើយចូរឯងនាំដំណឹងល្អ
នេះទៅក្រាបបង្គំទូលដោយសេចក្តីគោរព ជាយ៉ាងជ្រាលជ្រៅ ចំពោះ
ព្រះអាទិទេពនេះផង ។

បុរសក៏យកអណ្តើកនោះ ចោះចាលទៅក្នុងទឹក អណ្តើកនោះត្រេក
អរឥតឧបមា ក៏មុជក្នុងទឹកបាត់ទៅ ។

ឥឡូវនេះ បុរសនេះមិនពេញចិត្តនឹងធ្វើនេសាទតទៅទៀត ។ -

ប៉ុស្តេវជាមានចិត្តអណ្តែតអណ្តូង កំដេកនៅក្នុងទូកសន្ធឹងដើង ខ្លួនស្តិតនៅឯបាតទូក ក្រឡេកមើលទៅអាកាសប្រកបដោយពណ៌ខៀវស្រងាត់ មានរស្មីព្រោងព្រាយ ហើយមានពពក ស អណ្តែតត្រសែត . . . ។ ប៉ុស្តេនឹកឃើញអនុស្សាវរីយ៍ត្រង់យ៉ាង . . . នឹកឃើញភូមិ យុព៌ កំពង់នាវ តូច ដែលមានទូកសំចតពាសពេញ . . . គេហដ្ឋានឈើមានទ្បាន ជិតនៅជុំវិញ . . . ព្រះវិហារស័ង្ឃតូ សង់នៅជិតសមុទ្រ . . . ដូចស្ថានដែលកប់សពនៃដីដូនដីតារបស់ខ្លួន ។ ប៉ុស្តេនឹកឃើញបិតា , មាតារបស់ខ្លួន ដែលបានថែទាំបីបាច់រក្សាខ្លួនពីតារកវ័យយុវ័ន ។

ពេលនោះ ជាពេលថ្ងៃត្រង់ជាក់ . . . អាកាសចេញចំហាយក្តៅ ។ គ្មានស័ព្ទសូរសម្លេងអ្វីឡើយ ទាំងលើអាកាសទាំងលើសមុទ្រ ។ ក្នុងពេលនោះ ទូកក៏បរទៅតាមទំនើងចិត្តវា , ក្នុងចំហាយក្តៅគាយ មានសភាពស្ងប់ស្ងាត់ . . . អ៊ុំស្តេម៉ាតារ៉ូ ក៏និទ្រាលក់ទៅ . . . ។

ក្នុងពេលនោះ ស្រាប់តែមានអ្វីមួយមកស្ទុះអង្អែលដៃគាត់ . . . ហើយគាត់ភ្ញាក់ក្អាម , គាត់ប៉ើងភ្នែកមើល ស្រាប់តែឃើញនាងកញ្ញាម្នាក់ មានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយឈរចំពីមុខគាត់ , ស្បែកសំពត់ មានពណ៌ក្រហមផ្លោងឆ្អែតខៀវផ្ទៃមេឃ នាងមានសក់វែងខ្មៅស្រឡែតប្រាស់ស្មា , វែងហួសដល់តែងដើង នេះជាទំនៀមក្នុងពេលនោះ គេទុកសក់យ៉ាងដូច្នេះឯង ។

នាងមកកាន់បុរសកំឡោះដើរតាមរលកទឹក. ហើយមកដល់ពួកកំជាស់បុរសនោះ ហើយពោលពាក្យដ៏ផ្អែមពីពោះអស្ចារ្យ ដូចជាក្មេងទៀត្យដូច្នោះថា កុំឲ្យសង្ស័យអ្វីឡើយ . . . ខ្ញុំជាបុត្រីព្រះចាទស្តេចនាគដែលគង់នៅក្នុងមហាសាគរនេះ ។ បិតាខ្ញុំ ឲ្យខ្ញុំមកជំរាបបង ថា: លោកសូមថ្លែងនូវកតញ្ញូតាធម៌ចំពោះបង ដោយបងបានឲ្យជីវិតដល់អណ្តើកតូចនោះ ។ លោកថា បងមានចិត្តសប្បុរសពន់ពេក លោកមានប្រសាសន៍ បងគប្បីសង្គ័សងគុណបង . . . ចូរបងអញ្ជើញមកជាមួយខ្ញុំ ទៅឯព្រះបរមកដរាំងក្នុងព្រះពដអាណាចក្រព្រះបិតាខ្ញុំ ។ ព្រះបរមកដរាំងនោះបិត ដែលប្រកបដោយវិស្ថានរដូវជាសុភមង្គលជាយ៉ាងក្រៃពេក បើបងអញ្ជើញទៅជាមួយនឹងខ្ញុំ ។ នឹងទៅជាទេពីរបស់បង ហើយយើងទាំងពីរនាក់នឹងបានរួមសុខទុក្ខជាមួយគ្នា នៅក្នុងព្រះដំណាក់ព្រះបរមរាជរាំងឯណោះ ។

អ៊ុំស្រីម៉ាតារួក្រៃពេកទៅឃើញព្រះនាងមានសម្រស់ នឹងលំអជាយ៉ាងក្រៃពេក ក៏នឹកក្នុងចិត្តថា អញមិនដែលឃើញស្ត្រីណាមានលំអដ៏វិសេសវិសាលយ៉ាងនេះសោះឡើយ ។ បុរសក្រឡេកឃើញព្រះនាងក៏មានចិត្តប្រតិព័ទ្ធស្និទ្ធស្នេហាពន់ពេក . . . . . តែមនោសញ្ចេតនានោះមានសភាពរាំងគ្មាតេក ពាល់តែបុរសនោះហាមាត់និយាយមិនរួចហួចមិនចេញ . . . . ។

តែព្រះនាងមិនបានរំពឹងបុរសតបទៅព្រះនាងវិញឡើយ ។ ទ្រង់
កំពានថែវមួយ បុរសកំពានថែវមួយ នាំគ្នាថែវទូកនោះទៅ ក្នុងពេលនោះ
មានសុភវិត្ថស្ងាត់ ត្រៃលែងស្ងាត់ គេឮតែសម្លេងរលកបុកទឹកសមុទ្រ
នឹងសំឡេងរលក ។

ទូកនោះក៏ទៅដល់កោះដ៏ប្រសើរ មួយ ។ កោះដែលគ្មានមនុស្ស -
សាមញ្ញណាមួយចូលទៅដល់ ។

ក្នុងចំណោមទេវតាដែលប្រកបដោយសោភណភាពដ៏អស្ចារ្យ មានបុប្ផា
ជារច្រើនពណ៌ជុះនៅទីនោះ មានប្រាសាទមួយធ្វើពីថ្មកែវ មានបញ្ចេះត្បូង
ពិទូរ្យច្រាលផ្លេ ។ មានទាសា ១០០ នាក់ ទាសី ១ ០ នាក់ ចេញមក
ដង្ហែព្រះអគ្គមហាសក្យត្រី នឹងព្រះស្វាមីចូលទៅក្នុងព្រះដំណាក់ ហើយទ្រង់
ស្តេចទៅតាមយ៉ាងៗ ដែលអាកាសមានអប់គន្ធតិដោរដ៏ឈ្ងុយឈ្ងប់ រហូត
ទៅដល់ព្រះបន្ទូបមួយ ដែលមានជញ្ជាំងលាបលនដោយទឹកមាស ដែល
ស្តេចមហាសាគរទ្រង់គង់លើព្រះបល្ល័ង្កដ៏ប្រសើរ ។ មានទាគជាទិព្វមួយ
ចានថ្វាយពរសម្តែងសាធុការៈ ចំពោះស្វាមីនឹងកវិយា ។

(មានត)

អធិប្បាយប្បាប់ក្តៀកាល

ស្រី- អ៊ូ រៀបរៀង

បុព្វបុរសរបស់យើង សម័យពីព្រេងនាយ មានការពិនិត្យ នឹងការពិសោធន៍ជាច្រើនលើកច្រើនគ្រា នូវកិរិយារបស់មនុស្សគ្រប់ប្រហែលបានធ្វើការអ្វីមួយ ។ តែងមានខុស មានត្រូវ មិនខឿនឡើយ ។ តែការខុសភ្លាត់នោះ បើយើងចង់ចៀសវាង ក៏អាចចៀសវាងបានដែរ ដោយការដឹងត្រឹងត្រាប់តាមពាក្យចាស់ប្រៀនប្រដៅ ។ ចាស់ព្រឹទ្ធាចារ្យពាំនឹងឱ្យយមានធម៌មេត្តាដល់យើងជាច្រើន បានជាលោកតែងប្បាប់ជាពាក្យកាព្យខ្លី ។ ឲ្យងាយនឹងចាំ ទុកជាប្រស្នាឲ្យយើងរិះគិតដោះស្រាយ ដូចតទៅនេះ :

១ កើតក្តៀកាលពីព្រេងព្រឹទ្ធ សាធសុចរិតទៀងទុកដៅ
សេដ្ឋីផ្តាំប្រដៅ បុត្រសង្ឃរទុកត្រកាយហោង ។

អធិប្បាយ- អ្នកនិទ្ទានបានតែងប្បាប់ក្តៀកាលនេះឡើង ដោយលើកយកឈ្មោះសេដ្ឋីមកជាគំរូ ព្រោះសេដ្ឋីជាអ្នកមានព្យាយាមចេះប្រកបការងារគ្រប់ចំពូក បានតាំងខ្លួនជាអ្នកមានទ្រព្យសម្បត្តិសុកសប្បាយ បានជាលោកយកឈ្មោះសេដ្ឋីមកជាកស្តុតាងថា :

សេដ្ឋីបានឲ្យដំបូន្មាន ប្រៀនប្រដៅផ្តាំផ្ញើទុកឲ្យកូនប្រុសស្រី ជាទី

ស្នេហាពាំងឡាយ ដែលកើតជាន់ក្រោយ តាមនុស្សជាតិជាទីស្រឡាញ់ ដែលកើតតៗគ្នា ទៅអនាគតកាល ឲ្យយកចិត្តទុកជាក់ ប្រព្រឹត្តសុចរិត ពាំង ៣ យ៉ាង គឺកាយសុចរិត វចីសុចរិតនឹងមនោសុចរិត ឲ្យភ្ជាប់ខ្លួន ឲ្យឋិតនៅជានិច្ច សុចរិតនេះហើយដែលជាកេរ្តិ៍មត៌ក ជាដំណែលរបស់ចាស់ព្រឹទ្ធាចារ្យ តាំងពីសម័យព្រេងនាយមក ។

៤- កូនអើយកេរ្តិ៍មេថា ចូរកុំឆ្គងឆ្គត់តែត្រង់
ថែទាំចាំរួសរង់ ប្រុងប្រយ័ត្នប្រយោជន៍យូរ ។

អធិប្បាយ_: ត្រង់បទថា កូនអើយកេរ្តិ៍មេថា គឺ ម្នាលកូន! កេរ្តិ៍ឈ្មោះចរិយាមារយាទសណ្តាប់ធ្នាប់ល្អ របស់វង្សត្រកូលក្តី កេរ្តិ៍មត៌ក គឺទ្រព្យសម្បត្តិដែលមានវិញ្ញាណ ដូចក្របីគោ សេះ ដំរី ជាដើមក្តី ទ្រព្យសម្បត្តិដែលមិនមានវិញ្ញាណ ដូចមាស ពេជ្រ ច្រាក់កាស ចានជាសតុខ្លួរ ស្រែចំការជាដើមក្តី ដែលមាតាបិតាដូនដីតា បានប្រព្រឹត្តល្អមក ចែកឲ្យមកហើយ ។ ត្រង់បទថា ចូរកុំឆ្គងឆ្គត់តែត្រង់ ថែទាំចាំរួសរង់ ប្រុងប្រយ័ត្នប្រយោជន៍យូរ គឺត្រូវកូនប្រុស-ស្រីថែរក្សា ប្រព្រឹត្តឲ្យត្រឹមត្រូវល្អ ប្រុងប្រយ័ត្នទុកជាក់ឲ្យគង់ កុំយកទៅលក់បញ្ចាំ លេងល្បែងស៊ីសង មានធ្លាប់ជាដើម ឬក៏ យកទៅលក់បញ្ចាំដក់អាកៀនផឹកស្រាជាដើម ជាហេតុនាំឲ្យវិនាសទ្រព្យសម្បត្តិជាកេរ្តិ៍ ដែលមាតាបិតា

ដ៏ជួនដ៏តាចែកមកឲ្យនោះ ត្រូវចេះថែរក្សាខ្នុកប្រើប្រាស់ឲ្យបានយូរអង្វែង
តទៅ ។

ទ្រឹហរណ៍

មានបុរសប្តីប្រពន្ធ មានកូនប្រុស ៣ នាក់ ដល់ពេលដែតស្លាប់
បានចែកទ្រាក់មួយណែនម្នាក់ៗ គ្រប់កូនចាំង ៣ នាក់ ។ បងចាំងពីរ
នាក់ កាលមាតាបិតាស្លាប់ទៅហើយ គិតតែពីស៊ីចាយខ្ជះខ្ជាយ ដាច
ទាល់តែអស់ទ្រាក់ជាកេរ្តិ៍មែតែក ទៅជាអ្នកក្រីក្រ ដើរកេស៊ីឈ្នួលគេ
គ្រាន់តែចិញ្ចឹមពោះ ស្ទើរតែមិនគ្រប់ព្រឹកល្ងាចផង ។

ឯប្អូនពៅបង្អស់ តាំងពីបានទទួលទ្រាក់មួយណែន ជាកេរ្តិ៍មែតែក
អំពីឪពុកម្តាយនោះមក មិនហ៊ានស៊ីចាយខ្ជះខ្ជាយទេ ជាអ្នកចេះសំចៃផ្គត់
ផ្គង់ ទិញបានមេគោមួយនឹម មកចិញ្ចឹម ។ មេគោនោះសាយកូនណាស់
កូន ១ ឆ្នាំមានកូន ១ កល់មេ, ២ឆ្នាំបានកូន ៤ ។ យូរៗទៅ បុរសនោះ មាន
គោពេញក្រោល លក់ដូរឲ្យអ្នកជាខែទៀតផង ទៅជាអ្នកមានទ្រព្យសម្បត្តិ
ស្តុកស្តម្ភ ដោយអំណាចចេះថែរក្សាកេរ្តិ៍មែតែក មិនចាយវាយខ្ជះខ្ជាយ ។

៣- ធម្មតាអ្នកជាជាតិ តាលតែអាធឲ្យតិតក្តួរ
ក៏ខ្ជិលដេកគន់ទ្វារ ដល់ថ្ងៃរះពេញពន្លឺ ។

អដ្ឋប្បាយ- ធម្មតាអ្នកមានជាតិត្រកូលល្អ មានពូជអម្បាលល្អ

កាលបើមានគេផ្តួចផ្តើមធ្វើកិច្ចការអ្វី ។ ដែលមានប្រយោជន៍ដល់ប្រទេសជាតិ គេត្រូវតែតផ្តើមធ្វើកិច្ចការនោះ។ ឲ្យកើតបានដែរ ឬក៏ ចូលហ៊ុនជាសមាគមជាមួយនឹងអ្នកដែលផ្តើមធ្វើជាដំបូង ឲ្យពាល់តែកើតឡើងបានគេមិនត្រូវខ្វល់ច្រអូស ដេកលក់ស្ងាប់គំនិតស្ងាប់ស្មារតី ឲ្យអ្នកដទៃស្រាវយកប្រយោជន៍ពីមុខបានឡើយ ដូចយ៉ាងកិច្ចសិក្សារៀនសូត្រកាលបើពាជការ ជាន់បង្កើតសាលាសម្រាប់បង្រៀនអក្សរសាស្ត្រ នឹងចំណេះវិជ្ជាផ្សេង។ គេត្រូវតែស្ទុះស្ទារចូលទៅរៀនសូត្រ ឲ្យបានទាន់គេកុំខ្វល់ច្រអូសឡើយ ។

ទិដ្ឋាហរណ៍

មានកុមារ ៤នាក់ ម្នាក់ឈ្មោះ (ក) ម្នាក់ឈ្មោះ (ខ) អាយុ ៩ឆ្នាំ នៅផ្ទះជិតគ្នា ក្នុងភូមិជាមួយគ្នា ។ ថ្ងៃមួយ មានអ្នកពាជការមកជាសំគេនឲ្យកូនចៅអ្នកស្រុកទៅរៀនឯសាលា នៅក្បែរថ្នល់ធំ ចម្ងាយពីផ្ទះកុមារទាំងនោះ ចំនួនពីរគីឡូម៉ែត្រ ។

កុមារឈ្មោះ (ក) ជាអ្នកខ្វល់ច្រើន មិនត្រមៅរៀនសោះ ទោះបីគេបង្ខិំយ៉ាងណា ក៏មិនត្រមៅរៀន ដោយខ្វល់ដើរទៅសាលាឆង្ងាយខ្លះខ្លាចមេរៀនផង ។ ឯកុមារឈ្មោះ (ខ) ត្រមៅរៀនដោយសេចក្តីសប្បាយរីករាយ មិនខ្វល់ច្រអូសសោះ សប្បាយនឹងការរៀនពន់

ពេក រៀនបានឡើងថ្នាក់ពល់ធ្នាំ រហូតដល់ប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់បាន បានខួលហាន:ជាមន្ត្រីយ៉ាងធំ ។ ឯកុមារឈ្មោះ (ក) កាលគេជាស់តឿនឲ្យទៅរៀន មិនព្រមទៅរៀនសូត្រនឹងគេសោះ ទៅជាអ្នកឆ្កែខ្សោយ រកស៊ីចិញ្ចឹមពោះស្ទើរតែមិនគ្រប់ត្រឹកល្ងាច ។

៤_ តាក់តែងខ្ទុំកំជរ ចេញទៅរកធ្វើស្រែកូ
ចិញ្ចឹមគោក្របី រកខ្សែស្ងៃទោះគ្រោលឃ្នង។

អធិប្បាយ_. កាលបើដល់រដូវធ្វើស្រែ គេត្រូវចាត់ចែងរៀបចំជាស់តឿនកម្មករ ឲ្យប្រុងប្រៀបនង្គ័លនង្គាស់ ហើយឲ្យទៅភ្ជួរពស់ គឺត្រូវភ្ជួរជាស់ឲ្ញាលជាមុន ដើម្បីនឹងយកពូជទៅសាប ហើយទើបភ្ជួរជាស់ស្រែគូប_ធំជាលំជាប់តទៅ ។ លុះដល់សំណាបល្មមស្ទូង គេត្រូវចាត់ចែងឲ្យស្ទូងស្រែនេះជាមុន ដូច្នេះជាដើម ឈ្មោះថា តាក់តែងខ្ទុំកំជរចេញទៅរកធ្វើស្រែកូ ។ ការចិញ្ចឹមគោក្របី គេត្រូវចាត់ចែងឲ្យកម្មករ វេញវៃ្យ វេញកន្ទុះ_ពួរព្រ័ត្រចំរូងទុក ឲ្យមានបរិបូណ៌ គេត្រូវឲ្យធ្វើរោង ធ្វើក្រោលឲ្យមាំមួន ។

ពាក្យថា ក្រោល មាន ២ យ៉ាងគឺ ១_ ក្រោលមានបង្គើលធំៗ ៥ គេជាប់ធ្វើប្រាំសិកវបា ឬ រនុកវាយស្មៀតឲ្យណែនទុកព្រាវ ១ សម្រាប់ឲ្យក្របី_គោចេញ_ចូលរួច ។ ២_ ក្រោលដែលគេជាំបង្គើល

តួច ។ ជាច្រើនបន្តិច ។ ជាង ៤ ជ្រុងទ្រវែង ហើយគេយកកូនឈើតួច ។ ជាច្រើនជាក់គងលើគ្នា ។ ពាល់តែខ្ពស់ឡើង ល្មមក្របីគោលោតរំលងមិនរួច គេទុកទ្វារល្មមគោក្របីចេញចូលបាន ក្រោលរបៀបនេះ ហៅថា ក្រោលឃ្នង ដើម្បីថែទាំរក្សាគោក្របីឲ្យគង់វង្ស ឲ្យបានចំរើនច្រើនឡើង ។

๙- ធ្វើស្រែធំសន្ធាំបី ខុំប្រុសស្រីចេញផ្លូវ[1] ជង
មើលដូរស្រះរបង កាំងចំណារភ្ជួរកក្ខ[2] ។

អធិប្បាយ- ត្រង់បទថា: ធ្វើស្រែធំសន្ធាំបី គឺឲ្យមានស្រែច្រើនទិស ច្រើនស្រុក ច្រើនភូមិ ច្រើនដំបន់ ដើម្បីការពារនូវសេចក្តីកំដរស្ងួត, បើស្រុក ១ កំង ស្រុក ១ មានភ្លៀង គ្រាន់តែធ្វើស្រែពាល់តែឆ្នាំ កុំឲ្យខ្វះស្រូវអង្គរបរិភោគ បើមានស្រែតែមួយស្រុក ដួលជាស្រុកមួយនោះ គ្មានភ្លៀង មុខជាមានធ្វើស្រែហើយ កាលបើមានធ្វើស្រែហើយ មុខតែអត់ឃ្លានក្រៃក្រលំបាក បានជាប្រាថ្នាឲ្យមានស្រែច្រើនស្រុក ច្រើនភូមិ ។ បើចំណែកខាងការរៀនសូត្រ គេត្រូវរៀនឲ្យចេះច្រើនយ៉ាង ដូចអក្សរ ចាក់ដែង អង់គ្លេស ជាដើម ។ ត្រង់បទថា ខុំប្រុសស្រីចេញផ្លូវ ជង ត្រូវពាក់ព័ន្ធរៀបចំតម្លួតរ ប្រុស

---

๑. សាស្ត្រាខ្វះថា ខុំប្រុសស្រីចេញផ្លូវផង ។ ๒. សាស្ត្រាខ្វះថា កាំងចំណារភ្ជួរអាញ ។

ស្រីឲ្យចេះលក់ដូរ ដួញប្រែផងខ្មែត ដើម្បីយកចំណេញឲ្យបានកើនចំ
រើនទ្រព្យសម្បត្តិ កុំឲ្យខ្វះខាតក្រៃក្រលំបាកទៅថ្ងៃក្រោយ ។ ត្រង់បទថា
មើលផ្ទះស្រែរបង់ កំផង់ចំណារភ្លែរកឯ គឺមានផ្ទះសំបែង
ហើយ ត្រូវធ្វើរបងកំផែង ឲ្យមាំមួនព័ទ្ធជុំវិញ ដើម្បីការពាររក្សាគ្រឹះ
ស្ថានឲ្យបានល្អផង រក្សាការពារទ្រព្យនយើងផង កុំឲ្យសត្រូវគេចោរកំណាច
ចូលមកលួចប្លន់កាប់សម្លាប់បានរួយ ព្រោះគ្រឹះស្ថានណា ដែលគ្មាន
របងកំផែងជាគ្រឿង ការពារមាំមួនទេ គ្រឹះស្ថាននោះ ម្ចាស់ជាសត្រូវ
មើលងាយពិតប្រាកដ ។

៦_ ឲ្យមានក្តីចារម្ភ ធ្វើស្រែកុំចោលចំការ
ដីធំដែកកាំបិតត្រា ទុកឲ្យជាកុំឲ្យចាត់ ។

អធិប្បាយ_ ត្រង់បទថា ឲ្យមានក្តីចារម្ភ គឺត្រូវឲ្យមានសេចក្តី
ទឹកព្រួយទុកជាមុន ក្រែងសេចក្តីក្រីក្រលំបាក ឬមានទុក្ខទោសអ្វីផ្សេង។
មកគ្របសង្កត់ មិនត្រូវធ្វេសប្រហែសទេ ។ ត្រង់បទថា ធ្វើស្រែកុំ
ចោលចំការ គឺយើងធ្វើស្រែហើយ ត្រូវធ្វើចំការជាំដំណាំផ្សេង។ ដូច
ជាពោតសណ្តែក ត្រឹម ម្រេច ស្វាយ ត្រប់ តាសក់ ជាដើម
សម្រាប់បរិភោគឲ្យបានគ្រប់គ្រាន់ កុំឲ្យជាប់លុយកាក់ទិញបន្ទែនោះ ។ ។
មួយទៀត កុំអាងតែបានធ្វើស្រែហើយចោលចំការនោះ ត្រូវធ្វើចំការផង។

ចំណែកអ្នករៀនចំណេះវិជ្ជា កុំអាងតែចេះវិជ្ជាមួយមុខ។ នោះ ត្រូវ

ឲ្យចេះវិជ្ជាច្រើនមុខ ។

ត្រង់បទថា ដីឥដ្ឋដែលកាំបិតត្រា គឺគ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ដូចយ៉ាង ដីឥដ្ឋ ពូថៅ ចប កាំបិតជាដើម ត្រូវសំលៀងឲ្យមុត កុំឲ្យប្រែរចាប់ ។

ត្រង់បទថា ឧកញ្ញាឲ្យជាកុំឲ្យចាត់ គឺមិនត្រូវធ្វេសប្រហែសចោលរាត់រាយដោយដំណើរ ត្រូវរក្សាទុកឲ្យគង់ អាចប្រើប្រាស់បានយូរឆ្នាំ ។

៧-ដេកយប់ឲ្យរាំងទ្វារ ទ្រព្យសម្ភារៀបប្រុយ័ត្ន ចង្ក្រកកុំឲ្យសាត់ ដួងចាក់បែកជាប់ទល់ទ្រ ។

អធិប្បាយ- ត្រង់បទថា ដេកយប់ឲ្យរាំងទ្វារ គឺពេលយប់មុនចូលដំណេក ត្រូវបិទបង្អួច ពាសទ្វារឲ្យជាប់មាំមួន ការពារកុំឲ្យចោរចូលមកលួចយកទ្រព្យសម្បត្តិបាន ។ ម្យ៉ាងទៀត ពេលយប់ត្រូវសង្រួមទ្វារមាត់ កុំនិយាយពាក្យមិនគួរ ត្រែងមានពាសទុក្ខពីព្រោះនិយាយ ដូចមានសុភាសិតថា និយាយយប់បន្ទប់ព្រៃ និយាយថ្ងៃរំពៃក្អែក ។

ត្រង់បទថា ទ្រព្យសម្ភារៀបប្រុយ័ត្ន គឺទ្រព្យសម្បត្តិដែលស្រាលៗ ដោយលើកជាក់ចាន ត្រូវប្រមូលរៀបចំទុកជាក់ក្នុងផ្ទះ ក្នុងកន្លែងសមគួរ លុះរៀបចំទុកជាក់ត្រឹមត្រូវហើយ ទើបចូលទៅក្នុងដំណេក ។

ត្រង់បទថា ចង់ទុកកុំឲ្យសាត គឺទុកដែលចតទៅមាត់កំពង់ ត្រូវយកពួរ ឬ ច្រវក់ ចង ចាក់សោឲ្យជាប់មាំមួន ដើម្បីការពារកុំឲ្យសោត់អណ្តែតទៅតាមទឹលបក់ជាត់ផង ការពារកុំឲ្យចោរលួចយកបានដោយងាយផង ។

ត្រង់បទថា ផ្ទះចាក់បែកចាប់ទល់ទ្រ គឺផ្ទះសំបែងកាលបើខ្វែតត្រោត ឬ ចាក់បែកធ្ងន់ភ្លាយដំបូល ត្រូវប្រញាប់ទល់ទ្រ ចាញ តម្រង់ប្រក់ព្រំ ជួសជុលឡើង ដោយរួសរាន់កុំឲ្យរួចអន្តរាយ កាលបើយើងមិនរៀសរាវជួសជុលទេ ជាហេតុនាំឲ្យវិនាសរួចធាប់ហ័ស សូម្បីចំណេះវិជ្ជាខឿតសោត កាលបើខ្ជិលទន្ទេញ ជាហេតុនាំឲ្យភ្លេចបាត់ទៅវិញដែរ សមដូចសុភាសិតថា មន្តវិជ្ជាដែលភ្លេចបាត់ទៅវិញ ព្រោះការមិនស្វាធ្យាយន៍ ផ្ទះពាំង្គាយដែលរួចវិនាសទៅ ព្រោះមិនប្រញាប់ជួសជុល ពណ៌សម្បុរមិនល្អ ព្រោះខ្ជិលជុសដំរះ ជាដើម ។

(១)
៨- សារតើទ្រព្យអ្វី ។ មើលស្រែដ៏ទុកឲ្យល្អ
ទុសធីកស្រូវអង្គរ យកចេញចាយគ្មានកំណាត់ ។

អធិប្បាយ.. ទ្រព្យសម្បត្តិផងពាំងពួន ត្រូវត្រួតត្រាមើលថែទាំ និយាយជាសត្វតឿនមនុស្សម្នា ឲ្យរៀបចំទុកជាក់ឲ្យគង់ សូម្បីទស

(១) សាស្ត្រាខ្វះជា ប្រុងស្មារតីទុកឲ្យល្អ ។

ទឹកស្រូវអង្គរ កំត្រូវប្រើប្រាស់ចាយវាយ ឲ្យមានកំណត់ត្រឹមត្រូវ មិនត្រូវចាយវាយខ្ជះខ្ជាយ ឥតសណ្តាប់ធ្នាប់នោះទេ ។

៩- កុំអាងតែទ្រព្យច្រើន ពុំត្រូវលើនរកផ្តង់ផ្តិត
យកចាយៗដោយបន្ទោរនឹងទុកៗដោយខ្ជាត ។

អធិប្បាយ- គេមិនត្រូវគិតអាងថា "យើងមានទ្រព្យច្រើនគិតតែចាយខ្ជះខ្ជាយ លែងរវៀសរវៃទិតទំរកបំពេញបន្ថែមទៀតនោះទេ" គេត្រូវតែទស្សាហ៍រិះរកឲ្យបានច្រើនឡើងថែមទៀត ទោះបីចាយវាយ គេត្រូវចាយដោយការចាំបាច់ ទោះបីនឹងទុក គេទុកដោយកំរិតដោយខ្ជាត ។

១០- រនេះសេះដំរី ភប់បញ្ជើកុំឲ្យឃ្លាត
ទ្វីណាមានមារយោធ ទុកជាកក់ដៃឲ្យរកឃ្លា ។

អធិប្បាយ-· យានដំនិះ ឬ សត្វពាហនៈ ដូចគោ ក្របី សេះដំរី ត្រូវមានបញ្ជើកត់ក្រោ ឲ្យដឹងចំនួន ជាគ្រឿងជាយចំណាំ ឲ្យដឹងជាក់ជឹងគង់ ត្រូវចុះឈ្មោះរបស់ពាំនោះ ក្នុងបញ្ជីថា " រនេះគោ មានចំនួនប៉ុណ្ណេះ រនេះក្របី មានចំនួនប៉ុណ្ណេះ ។ល។ សេះដំរីញី មានចំនួនប៉ុណ្ណេះ - ឈ្មោលមានប៉ុណ្ណេះ ! - តូចប៉ុណ្ណេះ - ធំប៉ុណ្ណេះ គាលបើចុះក្នុងបញ្ជី ជឹងចំនួនប៉ុណ្ណេះប៉ុណ្ណោះហើយ ត្រូវសង្កេតមើលកម្មករណា ដែលមានសណ្តាប់ធ្នាប់ល្អ ចិត្តស្មោះត្រង់ធ្ងន់នាយ ចៅហ្វាយ គេត្រូវប្រគល់បញ្ជីឲ្យពៅកម្មករនោះត្រួតត្រាមើលដំនួស ។

(មានត)

តាមឯកសារនៃក្រុមជំនុំទំនៀមទម្លាប់

ទំនៀមបង្វិលពពិល

ក្នុងរឿងមង្គលការខ្មែរ

អ្នកស្រី ពេជ្រ-សល់ ហៅ សារិះយ៉ាង

រៀបរៀង

ក្នុងពេលរៀបមង្គលការកូនប្រុសស្រី, អស់លោក-អ្នកសឹងគ្រប់រូបតែងបានឃើញ បានធ្វើនូវពិធីផ្សេងៗ ច្រើនចំពូកណាស់ ប៉ុន្តែខ្ញុំយល់ថា មានអស់លោក-អ្នកកាតតិចទេ ដែលយល់នូវន័យពិធីទាំងនោះ ។ ដូច្នេះ ខ្ញុំសូមលើកយកតែទំនៀមបង្វិលពពិលមួយមុខមកថ្លែងជូនអស់លោក-អ្នក ដូចតទៅនេះ ៖

ពពិលធ្វើអំពីអ្វី? មានប៉ុន្មានយ៉ាង?

ពពិលធ្វើអំពីសម្រឹទ្ធិ ឬស្ពាន់ គឺពពិលមានសណ្ឋានដូចស្លឹកពោធិ៍ មានដងកាន់ដូចសណ្ឋានស្លឹកពោធិ៍ ម្ខាងរលីង ម្ខាងមានរូប ។ តែពពិលខ្លះ ពងមួលមានដងកាន់ដូចគ្នា ។ ពពិលដែលអ្នកផងឆ្ងាប់បានឃើញ គឺពពិលមានរូបយ័ន្ត រូបទេពប្រណម្យ រូបឥសីកាន់ក្រាំង

រូបព្រហ្ម រូបក្បីក្បើន រូបត្រែរួត រូបនាងគង្គីនព្រះធរណី ។ ល ។ រៀលចង្វិលអាចរួយកពពិល ៣ មកអុជទៀនមួយៗ បិទនៅកំពូលនៃពពិលនោះ ហើយកាន់ដងហុចបន្តគ្នាពីស្តាំទៅឆ្វេង ហៅថាទក្ខិណាព័ត៌ ក្នុងពេលដែលពពិលរៀលតាមលំដាប់មកដល់ខ្លួន អ្នកដែលត្រូវកាន់ពពិលចង្វិលតគ្នាចាំនឹងប៉ុន្មាន តែងយកដៃឆ្វេងទទួលកាន់ដងពពិល ដៃស្តាំគ្រវាសផ្សែងទៀនបញ្ចូលទៅលើជនជាគូស្វាមីភរិយា ដែលត្រូវទទួលពរសព្វសាធុការ ។ ការបក់ផ្សែងចូលនេះហើយ ដែលជាការសំដែងចិត្តរបស់អ្នកបង្វិលស្រោចចុះទៅលើជន ដែលត្រូវទទួលពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ។ ក្នុង ១ ដុំ អាចរួយជាក់ស្តឹកមួ ១ សន្ធឹកជាខ្នាប់ ។ គ្រប់ ៩ ដុំកាលណា អាចរួយប្រមូលពពិលមកលត់ទៀនដោយស្តឹកមួ ហើយបក់ផ្សែងជាក់មុខសាមីខ្លួន ចាំនឹងប្រុសស្រី ។

ឯរឿងព័រពាក់ព័ន្ធដោយពពិល មានសេចក្តីដូចតទៅនេះ :

តាមឯកសាររបស់ក្រុមដំនុំចំនៀមទម្លាប់ខ្មែរ ដែលលោកគង់_ចណ្ឌនៈ នៅឃុំជ្រៃវៀន ស្រុកព្រៃឈរ (កំពង់ចាម) ជាសមាជិកធ្វើយធ្វង់របស់ក្រុមដំនុំបានឲ្យការណ៍មក ដោយមានដំណាលថា ៖

កាលពីព្រេងនាយ ព្រះឥសូរជាកំពូលលើមនុស្សលោកទ្រង់ឋិតនៅឯឋានកៃលាស ។ មនុស្សសោមញ្ញទៅមិនដល់

ហានបៃស្រទន់ទេ ។ ទ្រង់មានអគ្គទេពី ๑ ព្រះអគ្គព្រះនាម ។មាកតវតី ជាស្ត្រីគ្រប់លក្ខណ៍ ប្រសើរលើសស្ត្រីពាន់ពួន ។ ព្រះឥសូរមានវិញ្ញាន-ភាពលើសលុប ទោះពពួកទេវតា ឥន្ទ្រ ព្រហ្ម យម យក្ស គន្ធព្វ គ្រុឌ នាគ ពិទ្យាធរ ក៏ស្ងប់ស្ងែងកោតខ្លាច ចូលទៅគោរព សូមរៀនសិល្ប-សាស្ត្រពីព្រះអគ្គពាន់អស់ ។ មិនត្រឹមតែសត្វមានជីវិតទេ ដែលខ្លាច ព្រះអគ្គ សូម្បីតែសាកសពដែលនៅតែឆ្អឹងបន្តិចបន្តួច ក៏ខ្លាចរិទ្ធិព្រះអគ្គដែរ បើព្រះអគ្គចង់ដឹងថាជាឆ្អឹងរបស់អ្នកណាដែលស្លាប់ ទៅកើតនៅទីណា ទ្រង់គ្រាន់តែយកឆ្អឹងមកគោះសួរ ឆ្អឹងនោះក៏អាចឆ្លើយថ្លាយដំណឹងទ្រង់បាន ។

អស់ពួកសិស្សព្រះអគ្គពាន់ប៉ុន្មាន តែកាលណារៀបចំផ្សំផ្គុំកូនទៅឲ្យមានគូស្រករ តែងនាំគ្នាទៅសុំពរពីព្រះឥសូរសិន ដើម្បីឲ្យគូថ្មីនោះមានកូនមកជាមនុស្សមានបុណ្យអំណាចដូចព្រះអគ្គ ។

លុះចំណេរតមក មានស្តេចមនុស្សលោកមួយព្រះអង្គ ព្រះនាម ដ័យសុរិយោ នៅឧត្តរកែកេតដម្ពូ ព្រះអង្គបានយាងរករៀនសិល្បសាស្ត្រ ក្នុងព្រៃហេមពាន្ត អស់ពេលមួយឆ្នាំ ពុំបានជួបប្រទះនឹងតាបសឫសីណាមួយសោះ ។

ថ្ងៃមួយនោះ ព្រះឥសូរមានសេចក្តីអផ្សុកក៏ហោះចុះមកក្រសាល-

ឯជម្ពូទ្វីប ទ្រង់ឃើញព្រះដ័យសុរិយាផ្ទុលក់ក្រោមដើមឈើ ទ្រង់ជាស់ឡើងសួរដើមចន្លសព្វគ្រប់ហើយ កំបង្គាប់ឲ្យព្រះពាជកុមារហាព្រះនស្ត ឡើង ព្រះឥសូរស្តេះទឹកព្រះនស្តជាក់ព្រះពាជកុមារ ។ លេបចូលបាត់ ៧ កំភើតជាមានកម្លាំងហោះរួច ។ ព្រះឥសូរកំនាំទៅឯហានកៃលាស ដើម្បីបង្រៀនសិល្បសាស្ត្រផ្សេង ។ ។

លុះចប់សិល្បសាស្ត្រហើយ ព្រះដ័យសុរិយាតំលាព្រះឥសូរជាគ្រូ ត្រឡប់មកនគរវិញ ។ ព្រះបិតារៀបអភិសេកព្រះពាជកុមារឲ្យឡើង សោយពាជសម្បត្តិតំណាងព្រះអង្គ ។ ព្រះដ័យសុរិយាក៏បាននាំព្រះ ពាជទេពីទៅថ្វាយបង្គំសុំពរដ័យពីព្រះឥសូរ ដើម្បីទុកជាព្រះក្តីរនៅ ក្នុងជម្ពូទ្វីប ។

ព្រះឥសូរទ្រង់ព្រះតម្រិះសព្វគ្រប់ទៅថ្ម គ្មានពរអ្វីអាចនៅបិតថែរ បានឡើយ ទ្រង់ក៏ដប់ខឿន ។ ធ្វើអំពីថ្មពេជ្រជាតំណាងអង្គជាតព្រះអង្គ ឧដ៏ស្ទឹកពោធ៌ ១ ជាតំណាងយោនីព្រះនាង ។ មាកតវតី ទ្រង់ប្រសិទ្ធិ ហើយតាលណា ក៏ទ្រង់សន្មតឈ្មោះថា « ពតិលវត្ថ (១) » ព្រោះមាន រស្មីដូចពេជ្រ ។

ដោយមានរឿងព័ន្ធយ៉ាងនេះ បានជាជនជាតិខ្មែរធ្វើពិធីបង្វិល

---

๑ បើតាមរឿងនេះ គួរសរសេរថា « ពតិល » ឬ « ពតិល » ?

ពពិលឲ្យកូនប្រុសស្រីដែលរៀបការថ្មី ដើម្បីឲ្យមានសិរីសួស្តីជ័យមង្គល ឲ្យមានឫទ្ធិភ្ញាំងភ្លឺកែ ។

បើតាមរឿងព្រាហ្មណ៍លើនេះ ពពិលដូចជាគួរប្រើចំពោះតែមង្គលការកូនប្រុសស្រីប៉ុណ្ណោះ ចុះហេតុអ្វីក៏បានជាមានទំនៀមបង្ហិលពពិលក្នុងពិធីផ្សេងទៀត ដូចជាការបំបួសនាគ បញ្ចេញមួយកូនស្រីកោរជុកជាដើមផងដែរ ? ពាំនេះមកអំពីខ្មែរយើងពីដើមកាន់ព្រហ្មញ្ញសាសនាគោរពព្រះឥសូរ បានជាមានធ្វើទំនៀមនេះជាប់ដរាបមកដល់សព្វថ្ងៃ ។



ផ្នែកកាត់ឆន្ទប្រវត្តិការណ៍

ឥតមានដេរថ្នន់ ។ របស់ក្រសួងធម្មការ

អំពីការតាំងមន្ត្រីសង្ឃ

-ចានតាំងលោកលោកចៅ អធិការ ណុប-ឌុល វត្តត្រពាំងព្រីង ឃុំអង្គព្រះស្រែ ស្រុករមាសហែក(ស្វាយរៀង) ជាចំអនុគណស្រុករមាសហែក តាមសញ្ញាប័ត្រលេខ ៤៧៧០ ចុះថ្ងៃទី ៧-៦-៥៨ ។

-ចានតាំងលោកចៅអធិការ លាក់-ប៊ូ វត្តសមណាភមឃុំតំពន់ត្រាច ស្រុករមាសហែក(ស្វាយរៀង) ជាចំព្រះសមុហ៍អនុគណស្រុករមាសហែក តាមសញ្ញាប័ត្រលេខ ៤៧ ១ ចុះថ្ងៃទី ៧-៦-៥៨ ។

អំពីការតាំងចៅអធិការ

១-ចានតាំងកិត្តិ ហ៊ូ-អាម ជាចៅអធិការ វត្តពោធិសាលាឃុំព្រែកក្រចៅ ស្រុកកងមាស ខែត្រកំពង់ចាម ។

២-ចានតាំងកិត្តិ ថាច់-សៅរ ជាចៅអធិការ វត្ត គោរវែក ឃុំ ឫស្សីក្រោក ស្រុក មង្គលបុរី ខែត្រ ចាត់ដំបង ។

៣- ចានតាំងកិត្តិ ច័ន្ទ-ឌី ជាចៅអធិការវត្ត គោកធ្នង់

ឃុំ អូរត្រាសាខ ស្រុកមង្គលបុរី ខេត្ត ចាត់ដំបង ។

៤- ចានតាំងតាំងកុំ គីម-មាស ជាចៅអធិការ វត្ត អូរអណ្តូង
ឃុំ បន្ទាយនាង ស្រុក មង្គលបុរី ខេត្ត ចាត់ដំបង ។

៥- ចានតាំងតាំងកុំ សោម-អេង ជាចៅអធិការ វត្ត ចម្ការរំចេក
ឃុំ តាយម៉ែង ស្រុក មង្គលបុរី ខេត្ត ចាត់ដំបង ។

៦- ចានតាំងតាំងកុំ ត្រុំ ហង្ស ជាចៅអធិការ វត្ត តាយម៉ែង
ឃុំ តាយម៉ែង ស្រុក មង្គលបុរី ខេត្ត ចាត់ដំបង ។

៧- ចានតាំងតាំងកុំ សឺង-តឹក ជាចៅអធិការ វត្ត ផ្សារសៀម
ឃុំ តាយម៉ែង ស្រុក មង្គលបុរី ខេត្ត ចាត់ដំបង ។

៨-ចានតាំងតាំងកុំ ចិត-សេង ជាចៅអធិការ វត្ត សីហរតនារាម
ឃុំ តែវ ស្រុក ត្រាំង ខេត្ត តាកែវ ។

៩- ចានតាំងតាំងកុំ ជា-ម៉ាច ជាចៅអធិការ វត្ត ឈើទាលខ្ពស់ត្រា
ឃុំ រកា ស្រុក ត្រាំង ខេត្ត តាកែវ ។

១០- ចានតាំងតាំងកុំ ម៉ម-ដួប ជាចៅអធិការ វត្ត រំចេកព្រៃតផ្លាំ
ឃុំ ព្រៃតដំបូក ស្រុក ស្រែសន្លារ ខេត្ត កំពង់ចាម ។

១១- ចានតាំងតាំងកុំ តែវ-ប៊ឹង ជាចៅអធិការ វត្ត វិហារហ្លួង
ឃុំ វិហារហ្លួង ស្រុក កូនឃុំ ខេត្ត កំពង់ចាម ។

១២- ចាន់តាំងកក្កុ យឹម-ខូ ជាចៅអធិការ វត្ត ឯកាវាម
ឃុំ កំពង់លាវ ស្រុក វៃព្រៃវែង ខែត្រ វៃព្រៃវែង ។

១៣- ចាន់តាំងកក្កុ ម៉ម-អ៊ូ ជាចៅអធិការ វត្ត កំពង់ក្តុំក្រៅ
ឃុំ កំពង់ក្តុំ ស្រុក លើកដែក ខែត្រ កណ្តាល ។

១៤- ចាន់តាំងកក្កុ ញ៉ែ-ដឹម ជាចៅអធិការ វត្ត អញ្ជាញ
ឃុំ អំពៅព្រៃ ស្រុក កណ្តាលស្ទឹង ខែត្រ កណ្តាល ។

១៥- ចាន់តាំងកក្កុ ម៉ា-មី ជាចៅអធិការ វត្ត ចំប៉ក់ធំ
ឃុំ មេសរថ្មក ស្រុក ស្វាយចាប ខែត្រ ស្វាយរៀង ។

១៦- ចាន់តាំងកក្កុ ចៅ-អ៊ួន ជាគ្រូសូត្រស្តាំ វត្ត បុពណានិវេស
ឃុំ តាស់ក្រឡ ស្រុក មោងឫស្សី ខែត្រ ចាត់ដំបង ។

១៧-ចាន់តាំងកក្កុ ប៊ុល-យួម ជាគ្រូសូត្រឆ្វេង វត្តបុពណានិវេស
ឃុំ តាស់ក្រឡ ស្រុក មោងឫស្សី ខែត្រ ចាត់ដំបង ។

១៨- ចាន់តាំងកក្កុ សេង-ហុង ជាគ្រូសូត្រស្តាំ វត្ត គោះសិនថ្ម
ឃុំ ដូនទ្រី ស្រុក មោងឫស្សី ខែត្រ ចាត់ដំបង ។

១៩-ចាន់តាំងកក្កុ ឈឿក-ហាច ជាគ្រូសូត្រឆ្វេង វត្ត គោះសិនថ្ម
ឃុំ ដូនទ្រី ស្រុក មោងឫស្សី ខែត្រ ចាត់ដំបង ។

២០- ចាន់តាំងកក្កុ អ៊ុច-សម្បត្តិ ជាគ្រូសូត្រស្តាំ វត្ត គោះកែវ
ឃុំ ឫស្សីក្រោក ស្រុក មង្គលបុរី ខែត្រ ចាត់ដំបង ។

២១- បានតាំងកិច្ច សូរ-ស៊ុន ជាគ្រូសូត្រធ្វើន វត្ត គោះកែវ
ឃុំ ឫស្សីក្រោក ស្រុក មង្គលបុរី ខេត្ត បាត់ដំបង ។

២២-បានតាំងកិច្ច មាយ-ស្រ៊ឹត ជាគ្រូសូត្រស្តាំ វត្ត អូរអណ្តូង
ឃុំ បន្ទាយនាង ស្រុក មង្គលបុរី ខេត្ត បាត់ដំបង ។

២៣- បានតាំងកិច្ច យិម-យឹង ជាគ្រូសូត្រធ្វើន វត្ត អូរអណ្តូង
ឃុំ បន្ទាយនាង ស្រុក មង្គលបុរី ខេត្ត បាត់ដំបង ។

២៤- បានតាំងកិច្ច ប៉ែន-យី ជាគ្រូសូត្រស្តាំ វត្ត ចំការចេក
ឃុំ គយម៉ែង ស្រុក មង្គលបុរី ខេត្ត បាត់ដំបង ។

២៥-បានតាំងកិច្ច ភូមា-ផែង ជាគ្រូសូត្រធ្វើន វត្ត ចម្ការចេក
ឃុំ គយម៉ែង ស្រុក មង្គលបុរី ខេត្ត បាត់ដំបង ។

២៦- បានតាំងកិច្ច កឹង-ថ្មឹន ជាគ្រូសូត្រស្តាំ វត្ត គយម៉ែង
ឃុំ គយម៉ែង ស្រុក មង្គលបុរី ខេត្ត បាត់ដំបង ។

២៧- បានតាំងកិច្ច កែវ-ណាត់ ជាគ្រូសូត្រធ្វើន វត្ត គយម៉ែង
ឃុំ គយម៉ែង ស្រុកមង្គលបុរី ខេត្ត បាត់ដំបង ។

២៨- បានតាំងកិច្ច ពួង-សារិន ជាគ្រូសូត្រស្តាំ វត្ត ផ្លូវស្បែម
ឃុំ គយម៉ែង ស្រុក មង្គលបុរី ខេត្ត បាត់ដំបង ។

២៩- ចាន់តាំងកិក្ខុ អត-ហ៊ាន ជាគ្រូសូត្រធ្វើន វត្ត ផ្លូវសៀម ឃុំ គយម៉ែង ស្រុក មង្គលបុរី ខែត្រ បាត់ដំបង ។

៣០-ចាន់តាំងកិក្ខុ គង់-ជ័យ ជាគ្រូសូត្រស្តាំ វត្ត សីហរតនារាម ឃុំ តាកែវ ស្រុក ត្រាំង ខែត្រ តាកែវ ។

៣១-ចាន់តាំងកិក្ខុ កែវ-គាន់ ជាគ្រូសូត្រធ្វើន វត្ត សីហរតនារាម ឃុំ តាកែវ ស្រុក ត្រាំង ខែត្រ តាកែវ ។

៣២- ចាន់តាំងកិក្ខុ គិម-សម ជាគ្រូសូត្រស្តាំ វត្ត រំចេកព្រៃកផ្តាំ ឃុំ ព្រៃកដំបូក ស្រុក ស្រីសន្ធរ ខែត្រ កំពង់ចាម ។

៣៣- ចាន់តាំងកិក្ខុ ខែន-ស៊ុយ ជាគ្រូសូត្រធ្វើន វត្ត វិហារខន្ធីម ឃុំ សួង ស្រុក កងមឃុំ ខែត្រ កំពង់ចាម ។

៣៤- ចាន់តាំងកិក្ខុ ហាន់-ប៊ូ ជាគ្រូសូត្រស្តាំ វត្ត សុវណ្ណមាលី ឃុំ ខន្ធបិខ ស្រុក កងមឃុំ ខែត្រ កំពង់ចាម ។

៣៥- ចាន់តាំងកិក្ខុ ម៉ែន ស៊ុយ ជាគ្រូសូត្រធ្វើន វត្ត សុវណ្ណមាលី ឃុំ ខន្ធបិខ ស្រុក កងមឃុំ ខែត្រ កំពង់ចាម ។

ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

ក្នុងធមាសទី ២ ឆ្នាំ ១៩៥៨

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ២ មុខ គឺ

ទី ១- អំពីជម្ងឺ និងការព្យាបាលជម្ងឺ ;

ទី ២- អំពីការលក់ និងការទិញ ។

អត្ថបទសម្រាប់ប្រឡងប្រជែងនេះ សម្រេចយកនៅធមាសទី២ គឺ តាំងពីខែកក្កដា ដល់ដាច់ខែធ្នូ ឆ្នាំ ១៩៥៨

ដូច្នេះ អស់លោកអ្នកចេះដឹងតាំងពីក្មេយ ចោះជាស្ត្រី បុរស គ្រហស្ថ ឬបព្វជិត ដែលស្ម័គ្រចិត្តធ្វើជាបេក្ខជនប្រឡង សូមសរសេរតែងអត្ថបទស្តីអំពីជម្ងឺនិងការព្យាបាលជម្ងឺ, អំពីការលក់និងការទិញ តាមគោលសំខ្លួរដូចរៀបរាប់ខាងមុខ ឲ្យការណ៍ទៅដល់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមដាច់ខែធ្នូ ឆ្នាំ ១៩៥៨ ។

បេក្ខជននឹងយកអត្ថបទប្រឡងប្រជែងទៅឲ្យផ្ទាល់ខ្លួនកំពុង ផ្ញើ

តាមប៉ុស្តិ៍ទៅកំបាន យកទៅដូនសាលាឃុំ ឬសាលាស្រុក - ខេត្ត
សុំឲ្យផ្ញើទៅឲ្យកំបាន ដោយគាំទ្រដ៏សំបុត្រថា:

ជំលៀក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

អត្ថបទដែលប្រឡងជាប់ ត្រូវបានរង្វាន់ជា ៤ ថ្នាក់ ៖

រង្វាន់លេខ ១ . . . . . ៣០០៛០០

រង្វាន់លេខ ២ . . . . . ៥០០៛០០

រង្វាន់លេខ ៣ . . . . . ៣០០៛០០

រង្វាន់លេខ ៤ . . . . . ២០០៛០០

បេក្ខជនមួយរូប ។ អាចសរសេរតែដ៏ពាំង ២ មុខបាន ។ លោក
អ្នកដែលសរសេរអត្ថបទណា ១ មុខ ឬពាំង ២ មុខទៅដាក់ប្រឡង សូម
សរសេរនាម ព្រមទាំងទីលំនៅរបស់ខ្លួនឲ្យច្បាស់ដល់លើអត្ថបទនោះ ។ ។
ឯសំនួរខាងមុខនេះ ក្រុមដំនុំសួរពុំបានសព្វគ្រប់ទេ បើបេក្ខជន
ណាជ្រាបការណ៍ឯទៀតក្រៅអំពីសំនួរនេះ ហើយអាចសរសេរឲ្យការណ៍
ទៅបាន នោះក្រុមដំនុំអរគុណណាស់ ពីព្រោះសំនួរទាំងប៉ុន្មាននេះគ្រាន់
តែជាលំនាំ ត្រាយផ្លូវអ្នកតែងប៉ុណ្ណោះ ឯការធំបំផុត គឺក្រុមដំនុំត្រូវការ
តែឯកសាររបស់បេក្ខជនណាដែលឲ្យការណ៍ពិស្តារ ហើយនឹងមានគោល
ចារឹកត្រឹមត្រូវល្អសព្វគ្រប់ តែបើមិនអាចតែងពិស្តារទាំងអស់ តែងតែ

ចំពោះខ្ញុំណាមួយខ្លី ។ តាមដែលចេះចាំ កំក្រុមដំនុំត្រូវការដែរ ឲ្យតែអាដ
គោលច្បាស់លាស់ហើយប្រាប់ដើមកំណើតថា តែងតាមក្បួនណា ឬតាម
បានឮពីជនណា ? នៅទីណា ?

គោលបញ្ហានៃការប្រឡង

ន ១- អំពីជម្ងឺ និងការព្យាបាលជម្ងឺ

តាមរឿងដែលជាក់ជូនលោកអ្នកប្រឡងនេះ លោកអ្នកគាចមាន
ការសរសេរតែងច្រើនណាស់ ក្រៅពីគោលធំ ។ ដែលសួរជាលំនាំ
ព្រោះថា លោកអ្នកពុំមែនគ្រាន់តែសរសេរចំពោះការ ដែលលោកធ្លាប់
បានធ្វើ បានឃើញគេធ្វើប៉ុណ្ណោះទេ គឺសរសេរពាំនាំការដែលលោកអ្នក
បានជ្រាបដោយសាកសួរគ្រូពេទ្យផង ឆ្លងផង អាចារ្យ ឬមេមត់ផង ។

ខាងក្រោមនេះ សូមជូនសេចក្តីជាលំនាំដល់លោកអ្នក ដើម្បីឲ្យ
លោកអ្នកនឹកឃើញការដែលលោកអ្នកត្រូវសរសេរតែងអំពីជម្ងឺ និងការ
ព្យាបាលនេះ ៖

ក) ដើមហេតុនៃជម្ងឺតាមទំនៀមខ្មែរ :

- ជម្ងឺដែលបណ្តាលអំពីពេតជាធម្មជាតរបស់ខ្លួន
- ជម្ងឺដែលបណ្តាលអំពីខ្មោចព្រាយបិសាចអ្នកតា

- ជម្ងឺដែលបណ្តាលអំពីពិសសិល្បៈ ។

បណ្តាលជម្ងឺទាំង ៣ ចំពូកនេះ ជម្ងឺនីមួយ ។ តើគេធ្វើម្តេចដើម្បីជំនះហេតុដែលបណ្តាលឲ្យឈឺនោះ?

ខ) ឈ្មោះជម្ងឺផ្សេងៗ :

- គេអាចស្គាល់ថាជាជម្ងឺនេះ ជម្ងឺនោះបានដោយអាការយ៉ាងណា?

- គេព្យាបាលជម្ងឺនោះ ដោយវេជ្ជបណ្ឌិតដូចម្តេចខ្លះ?

គ) ជម្ងឺបណ្តាលអំពីគ្រោះថ្នាក់ :

- ជម្ងឺដែលកើតឡើងដោយគ្រោះថ្នាក់ជាបន្ទាន់ ដូចរបួស សត្វទាំ ចិច គ្រេច ចាក់ ជាដើម តើគេព្យាបាលដោយពិធី ឬថ្នាំដូចម្តេចខ្លះ?

ឃ) ថ្នាំផ្សេងៗ :

- ថ្នាំពាំនោះ នៅពេលដែលគេលាប ឬគេប្រើព្យាបាលអ្នកជម្ងឺនោះ។ តើគេធ្វើដូចម្តេចខ្លះ?

គេទៅកថ្នាំពាំនោះ ដោយវិធីដូចម្តេចខ្លះ? គេយកមកធ្វើដូចម្តេចទើបប្រើកើត? កាលកើតជាថ្នាំហើយ ដូចជាថ្នាំទឹក ថ្នាំគលីកា ថ្នាំមានរសផ្អែម ល្វីង ជូរ ចត់ ឬថ្នាំដទៃក្រៅពីនោះ តើគេប្រើម្តងចំនួនប៉ុន្មាន? ក្នុង ១ ថ្ងៃប្រើបានប៉ុន្មានដង? ។ល។

ជ) ជម្ងឺដែលមានតាំងពីកំណើត:

-មានជម្ងឺខ្លះ ជាជម្ងឺមានតាំងពីកើតមក ដូចក្មេងកើតស្រាំដ ស្រែង-ចំកដោះ រមាក រលាក ។ល។ តើខ្មែរយើងតែងមានដំនឿថា ត្រូវធ្វើពិធីដូចម្តេច? ត្រូវប្រើថ្នាំអ្វី? ដើម្បីបំបាត់ជម្ងឺនោះ ។ ។

ឋ) ការមើលជម្ងឺតាមពុទ្ធសាសនា និងតាមមន្តអាគមផ្សេងៗ

- តាមរបៀបពុទ្ធសាសនា ឬតាមរបៀបមន្តអាគម បើមើលជម្ងឺចំពោះរូបម្នាក់ ។ ចំពោះគ្រួសារ ឬមើលជម្ងឺឆ្លង តើគេតែងមើលដោយរបៀបដូចម្តេចខ្លះ?

សូមអធិប្បាយនឹងពន្យល់អំពីរឿងវៃល្ង៏ កថា ដែលគេតែងចង់ឲ្យអ្នកជម្ងឺ អំពីសំណែន អំពីពិធី ដែលគេតែងធ្វើដល់អ្នកជម្ងឺម្នាក់ៗ របស់គ្រួសារទាំងមូល នឹងអំពីកិច្ចការរបស់អ្នកស្រុកអ្នកភូមិនៅពេលដែលមានកើតជម្ងឺ ហើយគេលៀងអារក្ស ឬសែនអ្នកតា ។ល។

ការប្រឡងលើកនេះ ក៏ដូចលើកមុនៗដែរ ។ ក្រុមជំនុំសូមឲ្យលោកអ្នកប្រឡងសរសេរតែង ដោយពន្យល់ឲ្យច្បាស់លាស់មែនទែន នឹងសូមអធិប្បាយឲ្យបានសព្វគ្រប់ ដើម្បីឲ្យអ្នកដែលពុំធ្លាប់បានស្គាល់ ចំនៀមនោះ ។ អាចមើលយល់បានដោយងាយផង ។

ម្យ៉ាងទៀត សូមឲ្យលោកអ្នកប្រឡងប្រុងប្រយ័ត្នឆ្ងន ដែលលោក

អ្នកបាននយើញគេធ្វើពិធីនោះថា បាននយើញផ្កាលំភែក ឬរោយឮឈ្មោះ ណា នៅទីណា គេនិយាយច្រាប់ ។

ន ២ អំពីការលក់ដឹងការទិញ

ការលក់នឹងការទិញ ដែលក្រុមដំនុំជាក់ជូនលោកអ្នកប្រឡងនេះ ពុំមែនចង់ដឹងរបៀបការរកទួលបាន ខាងផ្លូវដំនួញរបស់ខ្មែរយើង ដូចការគិតលេខនពុទ្ធគណហាយ៉ាងណាជាដើម ដែលជាវិជ្ជា ខាងដំនួញនោះទេគឺថាក្រុមដំនុំត្រូវការចង់ដឹងចំពោះដំនឿនឹងទំនៀមទម្លាប់ដែលខ្មែរយើងធ្លាប់ដឿធ្លាប់ប្រកាន់ក្នុងរឿងលក់នឹងរកឹនទិញរបស់ផ្សេងៗ ទោះជាការបន្តិចបន្តួចក៏ដោយ ព្រោះខ្មែរយើងតែងមានដំនឿ-ទំនៀម-ត្រណម-ព្រះផ្ចុលជាច្រើន ក្នុងការលក់នឹងការទិញ គឺខាងការលក់ដូចពួកមនុស្សដែលលក់កន្ទេល លក់សំពត់ហូល លក់សំពត់ផ្សេង ។ លក់កញ្ច្រែង លក់ស្រូវអង្គរ ។ល។ ខាងការទិញដូចពួកមនុស្សដែលមកកងកូម ដើម្បីទិញបន្លែ- ស៊ុតសត្វ-ជ្រូក-មាន់-ទា-គោ ។ល។ ពោលរោយបំប្រួញ ដំ-នឿ-ទំនៀម-ត្រណម ដែលក្រុមដំនុំចង់ដឹងនោះចែកជា ២ យ៉ាង ៖

ក) ដំនឿ-ទំនៀម-ត្រណម ខាងអ្នកលក់ គឺខាងអ្នកលក់តែងដឿ-កាន់- តម ដូចម្តេចខ្លះក្នុងការលក់?

ខ) ដំនឿ-ទំនៀម-ត្រណមខាងការទិញ គឺខាងអ្នកទិញតែងដឿ

ដឿ-កាន់-តម ដូចម្តេចខ្លះក្នុងការទិញ?

ជំនឿ-ទំនៀម-ត្រណមទាងការលក់ការទិញនេះហើយ ដែលក្រុមដំទុំចង់ដឹង ។ សូមលោកអ្នកប្រឡងអធិប្បាយពន្យល់ដោយពាក្យ ពាហារណ៍មកបញ្ជាក់គ្រប់អន្លើផង ។

សូមលោកអ្នកប្រឡងបញ្ជាក់ការ ដែលលោកអ្នកសរសេរតែងនោះដូចតទៅនេះ ៖

ការដែលលក់ផលានុផលដំណាំរបស់អ្នកស្រុក ដូចបន្លែ ស្ពៃក្តោត ។ល។ ក្នុងពេលដែលគេត្រូវការលក់ តើគេមួលមាត់គ្នា ឬណាត់គ្នាមែបណាខ្លះ ?

ចំពោះពួកអ្នកត្បាញសំពត់ផ្សេងៗ អ្នកធ្វើចង្អេរ, ធ្វើកង្ហែន, ឬធ្វើនំចំណីផ្សេងៗ តើអ្នកទាំងនោះគេទៅរកឬទិញសម្ភារៈដែលត្រូវការប្រើនឹងរបស់ដែលត្រូវការធ្វើ ដូចជាអំបោះ សូត្រ ល័ត្ត ជាដើមអំពីទីឯណា ? អំពីនរណា ?

សូមលោកអ្នកប្រឡងអធិប្បាយអំពីអ្នកលក់ដូរបន្តិចបន្តួច ដូចជាលក់អីវ៉ាន់នៅពេលមានធ្វើបុណ្យម្តងម្កាល, អំពីអ្នកលក់នាំយករបស់ទៅលក់ឯផ្សារ, អំពីអ្នកទៅទិញអីវ៉ាន់ពីភូមិដទៃមកលក់ ។

នៅពេលខ្លះ គេរួបរួមគ្នាយកអីវ៉ាន់ទៅលក់ ដូចនៅភូមិខ្លះគេលក់

ស្រូវដែលគេអង្គាសអំពីអ្នកស្រុកមកពួនក្នុងស្រូវ តើគេធ្វើរបៀបណាខ្លះ?

សូមអធិប្បាយឲ្យសព្វគ្រប់ ។

សូមលោកអ្នកកុំភ្លេចអធិប្បាយអំពីពំនៀមថ្មែក ។ ដែលលោកអ្នកបានជ្រាប ដូចជាពំនៀមមើលថ្ងៃលិច អណ្តែត ល្អ អាក្រក់ នឹងពំនៀមលក់ ពំនៀមទិញគោក្តី ទិញខ្លួកក្តី ។ល។

សូមជ្រាបថា ការប្រឡងប្រជែងលើកនេះមាន ២ អត្ថបទ គឺទី១ អំពីជម្ងឺនឹងការព្យាបាលជម្ងឺ ទី២ អំពីការលក់នឹងការទិញ ។ បើបេក្ខជន ១ រូបត្រូវការសរសេរទាំង ២ អត្ថបទ ទៅដាក់ប្រឡង សូមសរសេរអត្ថបទមួយ ។ លើសៀវភៅយ៉ាងល្អត្រឹមត្រូវ កុំសរសេរលើក្រដាសរំកាច់រំកោចឡើយ ហើយត្រូវធ្វើជាសៀវភៅដាច់ដោយឡែកពីគ្នា ដើម្បីងាយយកទៅដាក់ក្នុងថតខ្លួនឯកសារនៅមន្ទីរក្រុមដំនុំពំនៀមទម្លាប់ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អង្គុលី_បញ្ចក គុ. ដែលមានម្រាមដៃជាគម្រប់ប្រាំ, ន.បុ. ម្រាមទាំងប្រាំ ។ *អង្គុលី_បវ៌ន* ន.បុ. សន្ធាក់នៃម្រាមដៃ ។ *អង្គុលី_សំភូត*, ន.បុ. «ដែលកើតពីម្រាម» ក្រចកម្រាមដៃ ។ *អង្គុល្យគ្រ*, ន.បុ. ចុងម្រាមដៃ ។

អង្គុលីយ ន.បុ. ចិញ្ចៀន. ។ _ *ក* ន.បុ. ចិញ្ចៀន ។

អង្គុ៎ច្រ, ន.បុ. ម៉ៃដែ, ម្រាមដើងធំ; ទំហំម៉ៃដែ (មាត្រាវង្វាស់) ។_ *បវ៌ន*, ន.បុ. សន្ធាក់ម៉ៃដែ ។ _ *មាត្រ* ឬ _*មាត្រក* គុ. ដែលមានម៉ៃដែជាមាត្រ ។ _ *មូល* ន.បុ. គល់នៃម៉ៃដែ ។

អង្ក្រ៊ិ ប៊ុ. ដើង ឫស (ឈើ) ដែងកៅអី ; ។_ *នាមក* ប៊ុ. ឬនាម *ន* ន.បុ. ពាក្យដែលជាការទំលាក់ន័យដើង អង្ក្រ៊ិ ។_*ប* «ប៊ុ.ដែលដឹកដោយដើង» ឈើ ។ _*ជាត*ប៊ុ. ការិយាយោះឬឈានដើង , ដំហាន ។ *អង្ក្រ៊ិវ៉ែនជន* ឬ *អង្ក្រ៊ិវ៉ែនជនី* គុ. (វត្ថុ) ដែលសម្រាប់លាងដើង ។ *អង្ក្រ៊ិវ៉ែមជនតូ* ន.បុ. ការនៃការិយាលាងដើង ។

អប, ឆាគុ មើលពាក្យ *អញ្ច*, ទៅ , មក , កម្រើក, ប្លែក, ន័យាយមិនច្បាស់ ។

ព្រះពោធិវង្ស ហួត-តាត ប្រធានគណៈប្រតិភូខាងព្រះពុទ្ធ-សាសនា និមន្តត្រឡប់មកកាន់រាជធានីភ្នំពេញវិញហើយ

ភ្នំពេញ-. ព្រះពោធិវង្ស ហួត-តាត ប្រធានគណៈត្រកូខាងព្រះពុទ្ធ-សាសនាទីជាចាងហ្វាងសាលាពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត នឹងលោក ត្រួមហា ណាច់ ប្រធាន ដែលបាននិមន្តទៅទស្សនាសាធារណរដ្ឋចិនប្រជា-មានិត កាលពីថ្ងៃទី ១៥ មិថុនា ១៩៥៨ តាមសេចក្តីនិមន្តនៃរដ្ឋាភិបាល សាធារណរដ្ឋចិនប្រជាមានិតនោះ បាននិមន្តត្រឡប់មកដល់ក្រុងភ្នំពេញ តាមអាកាសយាន នៅថ្ងៃទី ២៦ កក្កដា ១៩៥៨ វេលាម៉ោង ២, ទីនាទីរសៀល ប្រកបដោយសុវត្ថិភាព ។